- ព្រោះអ្នកណាពោលដោយភាពជឿជាក់នឹងវា ព្រមទាំងចិត្តស្មោះចំពោះអល់ឡោះ វាគឺជាហេតុនាំឲ្យគេរួចខ្លួនផុតពីភ្លើងនរក។ ណាពីមូហាំម៉ាត់សូមពរជ័យនិងសន្តិភាពកើតមានដល់គាត់បានមានប្រសាសន៍ថា: “អល់ឡោះហាមឃាត់លើភ្លើងនរកចំពោះជនណាដែលពោលថា: គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈពិត លើកលែងតែអល់ឡោះ ដោយចិត្តស្មោះត្រង់ចំពោះអល់ឡោះ”។(អាល់ពូខរី ៤១៥)
- ព្រោះអ្នកណាហើយស្លាប់ដោយបាននិយាយ និងមានជំនឿចំពោះពាក្យនេះ គេនៅជាមួយពួកអ្នកចូលឋានសួគ៌។ ណាពីមូហាំម៉ាត់សូមពរជ័យនិងសន្តិភាពកើតមានដល់គាត់បានមានប្រសាសន៍ថា: “ជនណាស្លាប់ហើយគេដឹងថា: គ្មានព្រះជាម្ចាស់ក្រៅពីអល់ឡោះ គេនឹងបានចូលឋានសួគ៌”។(អ៊ុះម៉ាត់ ៤៦៤)
- ដូច្នេះ ភាពចាំបាច់នៃការយល់ដឹងពីពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈពិត លើកលែងតែអល់ឡោះ គឺជាកាតព្វកិច្ចដ៏ឧត្តម និងមានសារៈសំខាន់បំផុត។

### អត្ថន័យនៃពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈពិត លើកលែងតែអល់ឡោះ

មានន័យថា គ្មានព្រះណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ មានតែអល់ឡោះមួយអង្គគត់ដែលត្រូវគោរពសក្ការៈ។ ជាការបដិសេធភាពជាព្រះណាដែលក្រៅពីអល់ឡោះ និងទទួលយកអល់ឡោះតែមួយគត់គ្មានអ្នកចូលរួមជាមួយទ្រង់ឡើយ។

ព្រះមានន័យថា អ្វីដែលត្រូវគោរពសក្ការៈ។ នរណាគោរពសក្ការៈអ្វីមួយក្រៅពីអល់ឡោះ អ្នកនោះពិតជាយកអ្នកផ្សេងធ្វើជាព្រះ។ ទាំងអស់នោះមិនមែនជាព្រះពិតនោះទេ មាននៃព្រះមួយគត់ ទ្រង់ជាម្ចាស់ និងជាអ្នកបង្កើត។

អល់ឡោះទ្រង់បកបេដោយភាពស្អាតស្អំ ជាព្រះសក្តិសមនូវការគោរពសក្ការៈតែមួយ

គត់ដោយគ្មានអ្នកផ្សេងឡើយ។ ទ្រង់ជាទីគោរពសក្ការៈនៃចិត្តទាំងឡាយ ដោយក្ដីគោរពស្រឡាញ់ ការកោតខ្លាច ការបន្ទាបខ្លួន ការឱនលំទោន ការកោតខ្លាច ការជឿទុកចិត្ត និងការបួងសួងសុំចំពោះទ្រង់។ ដូច្នេះ គេមិនត្រូវបួងសួង មិនជឿទុកចិត្ត មិនថ្វាយបង្គំ មិនសំឡេះសត្វ លើកលែងតែចំពោះអល់ឡោះប៉ុណ្ណោះ។ ម្យ៉ាងទៀតចាំបាច់ត្រូវតែគោរពសក្ការៈដោយចិត្តស្មោះត្រង់ចំពោះទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថា: “ហើយគេមិនបានបង្គាប់ប្រើពួកគេឲ្យធ្វើអ្វីក្រៅពីឲ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះ ដោយចិត្តស្មោះត្រង់ចំពោះទ្រង់” ។(អាល់ហ្ពៃយីណះ ៥)

នរណាហើយគោរពសក្ការៈ ដោយចិត្តស្មោះត្រង់ចំពោះអល់ឡោះ ស្រមាប់អ្នកនោះគឺបានសម្រេចនូវពាក្យថា គ្មានព្រះជាម្ចាស់ក្រៅពីអល់ឡោះ ហើយគេនឹងទទួលបាននូវសេចក្ដីសុខសុភមង្គល សម្បូរសប្បាយរីករាយ ជីវិតល្អប្រសើរថ្លៃថ្លា។ ស្រមាប់ដួងចិត្តមិនអាចមានភាពកុកក្ដៅ ស្កប់ស្កល់ ស្ងប់ចិត្តបានទេឡើយ លុះត្រាតែប្រតិបត្តិការគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់។ អល់ឡោះទ្រង់មានបន្ទូលថា: “អ្នកណាដែលបានសាងអំពើល្អក្នុងចំណោមបុរស ឬស្ត្រី ហើយគេជាអ្នកមានជំនឿ គឺយើងពិតជានឹងធ្វើឲ្យគេមានជីវិតរស់ដ៏ល្អប្រសើរ”។(អាន់ណះល៍ ៩៧)

## គោលគ្រឹះនៃពាក្យ គ្មានព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈពិតលើកលែងតែអល់ឡោះ

ពាក្យដ៏ឧត្តមនេះមានគោលគ្រឹះពីរដែលត្រូវយល់ដឹងឲ្យបានច្បាស់ចំពោះអត្ថន័យ និងភាពចាំបាច់របស់វា។

**1**

គោលគ្រឹះទី១ គ្មានព្រះជាម្ចាស់ គឺជាការបដិសេធចំពោះការគោរពសក្ការៈអ្វីទាំងឡាយក្រៅពីអល់ឡោះ បំបាត់អំពើស៊ីរិក និងចាំបាច់ត្រូវប្រឆាំងនឹងអ្វីៗដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ ទោះវានោះជាមនុស្ស ឬសត្វធាតុ ឬរូបបដិមា ឬផ្កាយ ឬជាអ្វីៗផ្សេងៗទៀត។

**2**

គោលគ្រឹះទី២លើកលែងតែអល់ឡោះ គឺជាការទទួលស្គាល់ការគោរពសក្ការៈស្រមាប់អល់ឡោះតែមួយគត់ ហើយប្រតិបត្តិចំពោះទ្រង់តែមួយគត់នូវគ្រប់ប្រភេទនៃការគោរពសក្ការៈទាំងអស់ដូចជាសឡាត( ការថ្វាយបង្គំ) ការបួងសួងសុំ ការជឿទុកចិត្ត។ល។

ហើយរាល់ការគោរពសក្ការៈគ្រប់ប្រភេទទាំងអស់ថ្វាយជូនចំពោះអល់ឡោះតែមួយគត់ដោយគ្មានការគោរពសក្ការៈចំពោះអ្នកផ្សេងរួមជាមួយទ្រង់ឡើយ។ ហើយអ្នកដែលថ្វាយការគោរពសក្ការៈជូនអ្នកដទៃក្រៅពីទ្រង់ គេពិតជាបានប្រព្រឹត្តអំពើស្ហ៊ីរិកចំពោះទ្រង់។

អល់ឡោះទ្រង់មានបន្ទូលថា: “អ្នកណាដែលគោរពសក្ការៈម្ចាស់ផ្សេងរួមជាមួយអល់ឡោះ គ្មានភស្តុតាងអ្វីស្រមាប់គេដោយការគោរពនោះ ពិតណាស់ ការជំនុំជម្រះ(ទង្វើអាក្រក់)របស់គេគឺស្ថិតនៅលើម្ចាស់របស់គេ។ ពិតណាស់ ពួកដែលប្រឆាំងនោះពុំជោគជ័យឡើយ”។(អាល់មុមីនូន ១១៧)។ អត្ថន័យនៃពាក្យ គ្មានព្រះជាម្ចាស់ក្រៅពីអល់ឡោះ និងគោលគ្រឹះរបស់វាមានបញ្ជាក់ដោយបន្ទូលរបស់អល់ឡោះថា: “ហេតុនេះ អ្នកដែលប្រឆាំងនឹងតហ្គូត(អ្វីៗដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ) ហើយមានជំនឿចំពោះអល់ឡោះនោះ អ្នកនោះប្រាកដជាបានប្រកាន់ខ្ជាប់នឹងខ្សែរឹងមាំ(សាសនាឥស្លាម) «។ បន្ទូលរបស់ទ្រង់: □អ្នកដែលប្រឆាំងនឹងតហ្គូត(អ្វីៗដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ)" គឺជាអត្ថន័យនៃគោលគ្រឹះទីមួយ (គ្មានព្រះជាម្ចាស់)។ បន្ទូលរបស់ទ្រង់: □ហើយមានជំនឿលើអល់ឡោះ" គឺជាអត្ថន័យនៃគោលគ្រឹះទីពីរ (លើកលែងតែអល់ឡោះ)។

# > ការសច្ចាថា មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ

## ការស្គាល់ណាពីមូហាំម៉ាត់សូមពរជ័យនិងសន្តិភាពកើតមានដល់គាត់



### 1 កំណើតរបស់ណាពីមូហាំម៉ាត់

គាត់បានកើតនៅទ្រីកុងម៉ាក្កះ ឆ្នាំ៥៧០គ.ស ក្រំពាឪពុក បន្ទាប់មកម្តាយគាត់ក៏បាត់បង់ជីវិតទៀតក្នុងវ័យកុមារ ក្រោយមកគាត់ត្រូវបានជីតារបស់គាត់គឺ អាប់ឌុលមុត្តាឡិបជាអ្នកមើលថែរក្សា។ បន្ទាប់មកឪពុកមារបស់គាត់គឺអាពូតាឡិបមើលថែរក្សាគាត់រហូតដល់ពេញវ័យ។



### 2 ជីវិត និងការធំពេញវ័យរបស់ណាពីមូហាំម៉ាត់

គាត់រស់ក្នុងកុលសម្ព័ន្ធរបស់គាត់ ឈ្មោះកូរេស្ស(Quraysh) រយៈពេល ៤០ឆ្នាំមុននឹងទទួលតំណែងជាណាពី(ពីឆ្នាំ៥៧០គ.ស ដល់ឆ្នាំ៦១០គ.ស)។ គាត់ជាមនុស្សគំរូស្រមាប់មនុស្សលោកទាំងមូលឲ្យយកត្រមាប់តាមភាពខ្ជាប់ខ្ជួន និងភាពល្អប្រសើររបស់គាត់ ដែលពួកគេគឺបានដាក់ងារដ៏ល្បីល្បាញមួយដល់គាត់គឺ អ្នកទៀងត្រង់។ ណាពីមូហាំម៉ាត់បានប្រកបអាជីពជាអ្នកឃ្វាលសត្វ ក្រោយមកជាអ្នកធ្វើជំនួញ។

មុននឹងអ្នកនាំសារទទួលសាសនាឥស្លាម គាត់ស្ថិតនៅលើសាសនាដ៏ត្រឹមត្រូវឥតលម្អៀង គាត់គោរពសក្ការៈចំពោះអល់ឡោះលើមាគ៌ាសាសនាណាពីអ៊ីព្រហ៊ីមដោយបដិសេធការគោរពសក្ការៈទេវរូប និងការប្រតិបត្តិជំនឿទេវរូប។

### ឈ្មោះរបស់ណាពីមូហាំម៉ាត់

មូហាំម៉ាត់កូនអាប់ឌុល្លោះកូនអាប់ឌុលមុត្តាឡិបកូនហាស្ហិមកុលសម្ព័ន្ធកូរេស្ស ហើយជាអម្បូរអារ៉ាប់ដ៏ល្អជាងគេ។

### ណាពីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះទៅកាន់មនុស្សលោកទាំងមូល

អល់ឡោះទ្រង់បានបញ្ជូនណាពីមូហាំម៉ាត់ទៅកាន់មនុស្សលោកទាំងមូល គ្រប់ជាតិសាសន៍ និងពូជអម្បូរ ហើយទ្រង់បានដាក់កាតព្វកិច្ចលើមនុស្សលោកទាំងមូលប្រតិបត្តិតាមណាហ្វី។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ចូរអ្នក(ណាពីមូហាំម៉ាត់)ពោលថា ៈឱមនុស្សលោកទាំងឡាយ! ពិតណាស់ ខ្ញុំគឺជាអ្នកនាំសាររបស់អល់ឡោះមកកាន់ពួកអ្នកទាំងអស់គ្នា”។ ( អាល់អាក់រ៉ហ្វ ១៥៨)។

## 3 ការតែងតាំងណាពីមូហាំម៉ាត់ជាអ្នកនាំសារ



នៅពេលអ្នកនាំសារមានវ័យ៤០ឆ្នាំ គាត់បានធ្វើការត្រិះរិះពិចារណា និងគោរពសក្ការៈចំពោះអល់ឡោះនៅក្នុងរូងហ៊ីរ៉ក នៅភ្នំអាន់នួរ( ជាភ្នំមួយនៃបណ្តាភ្នំដែលស្ថិតនៅជិតទីក្រុងម៉ាក្កះ)។ អល់ឡោះបានប្រទានវ៉ាហ៊ី និងគម្ពីរអាល់គួរអានចាប់ផ្តើមបញ្ចុះពីពេលនោះមក ហើយអ្វីដែលបញ្ចុះមុនគេបង្អស់អំពីគម្ពីរអាល់គួរអាននោះគឺ: (( اقْرَأْ بِاسْمِ رَبِّكَ الَّذِي خَلَقَ )) មានន័យថា: «ចូរអ្នកសូត្រ»ជាប្រកាសឲ្យដឹងថាការតែងតាំងជាអ្នកនាំសារនេះ គឺជាការចាប់ផ្តើមយុគសម័យថ្មីដែលពោរពេញដោយចំណេះវិជ្ជា ការអាន ពន្លឺរស្មី និងការចង្អុលបង្ហាញស្រមាប់មនុស្សលោក បន្ទាប់មកគម្ពីរអាល់គួរអានបានបញ្ចុះមកកាន់ណាពីមូហាំម៉ាត់ជាបន្តបន្ទាប់អស់រយៈកាល២៣ឆ្នាំ។

## 4 ការចាប់ផ្តើមផ្សព្វផ្សាយរបស់ណាពីមូហាំម៉ាត់

អ្នកនាំសារបានចាប់ផ្តើមផ្សព្វផ្សាយសាសនារបស់អល់ឡោះដោយសម្ងាត់រយៈពេល៣ឆ្នាំ។ ក្រោយមកគាត់បានលាត្រដាងការផ្សព្វផ្សាយនិងបើកចំហក្នុងរយៈពេល១០ឆ្នាំ។ ណាពីមូហាំម៉ាត់ និងសហការីរបស់គាត់បានទទួលរងការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពានពីសំណាក់កុលសម្ព័ន្ធកូរ៉េស្សក្នុងរយៈពេលនេះ។ គាត់ក៏បានអំពាវនាវដល់កុលសម្ព័ន្ធផ្សេងៗទៀតដែលបានមកធ្វើពិធីបុណ្យហាជ្ជ( នៅទីក្រុងម៉ាក្កះ )ឲ្យទទួលយកសាសនាឥស្លាម ហើយពលរដ្ឋក្រុងម៉ាឌីណះក៏បានទទួលយកសាសនាឥស្លាម ហេតុនេះហើយ ទើបអ្នកឥស្លាមចាប់ផ្តើមភៀសខ្លួនទៅកាន់ក្រុងម៉ាឌីណះជាបន្តបន្ទាប់។

### គម្ពីរអាល់គួរអានបានបញ្ចុះមកកាន់ណាពីមូហាំម៉ាត់

គម្ពីរអាល់គួរអានបានបញ្ចុះមកកាន់ណាពីមូហាំម៉ាត់ជា គម្ពីរដ៏ឧត្តុង្គឧត្តមជាទីបំផុត ពីព្រោះគម្ពីរនេះប្រការខុសឆ្គងទាំងឡាយមិនកើតមានដល់វាឡើយ។

### ណាពីមូហាំម៉ាត់ជាណាពី និងជារ៉ស៊ូលចុងក្រោយបង្អស់

អល់ឡោះបានបញ្ជូនណាពីមូហាំម៉ាត់ជាណាពីចុងក្រោយបង្អស់ គ្មានណាពីណាក្រោយគាត់ទៀតឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “ក៏ប៉ុន្តែគាត់ជាអ្នកនាំសាររបស់អល់ឡោះ និងជាណាពីចុងក្រោយបង្អស់”។ ( អាល់អះហ្សាប ៤០ )។




## 5 ការភៀសខ្លួនរបស់គាត់

អ្នកនាំសារបានភៀសខ្លួនទៅកាន់ក្រុងម៉ាឌីណះដែលពីមុនគេឲ្យឈ្មោះក្រុងនេះថាយេសរិបនៅឆ្នាំ៦២២គ.ស ពេលនោះគាត់មានអាយុ៥៣ឆ្នាំ។ ការភៀសខ្លួនរបស់គាត់គឺបន្ទាប់ពីមេដឹកនាំកុរ៉ស្ស៊ីប្រឆាំងនឹងការផ្សព្វផ្សាយរបស់គាត់បានប៉ុនប៉ងនិងព្យាយាមធ្វើឃាតគាត់។ គាត់បានរស់នៅនិងផ្សព្វផ្សាយសាសនាឥស្លាមនៅក្រុងម៉ាឌីណះអស់រយៈពេល១០ឆ្នាំ គាត់បានបង្គាប់ប្រើមនុស្សលោកឲ្យសុឡាត(ថ្វាយបង្គំព្រះ) ដកហ្សាកាត់(បង់ប្រាក់តាមច្បាប់ឥស្លាម) និងប្រតិបត្តិតាមច្បាប់ឥស្លាមផ្សេងៗទៀត។




## 6 ការពង្រីកសាសនាឥស្លាមរបស់គាត់

អ្នកនាំសារបានស្ថាបនាមជ្ឈមណ្ឌលអរិយធម៌ឥស្លាមនៅក្រុងម៉ាឌីណះក្រោយការភៀសខ្លួនចន្លោះឆ្នាំ(៦២២--៦៣២គ.ស)។ គាត់បានបោះយុថ្កាពង្រឹងគោលអត្តសញ្ញាណសង្គមឥស្លាម ដោយបានលុបបំបាត់ការរើសអើងកុលសម្ព័ន្ធ ការផ្សព្វផ្សាយចំណេះដឹង ពង្រឹងគោលការណ៍យុត្តិធម៌ ភាពត្រឹមត្រូវ ភាតរភាព សាមគ្គីភាព និងប្រព័ន្ធវិន័យ។ មានកុលសម្ព័ន្ធខ្លះបានព្យាយាមបញ្ចប់ជីវិតសាសនាឥស្លាមជាហេតុនាំឲ្យកើតមានចម្បាំង និងព្រឹត្តិការណ៍មួយចំនួន ប៉ុន្តែអល់ឡោះបានជួយសាសនានិងអ្នកនាំសាររបស់ទ្រង់។ ក្រោយមកមនុស្សលោកបានចូលសាសនាឥស្លាមជាបន្តបន្ទាប់។ ប្រជាជននៅក្រុងម៉ាក្កះ ក៏ដូចជាប្រជាជននៅតាមទីក្រុងផ្សេងៗទៀត និងកុលសម្ព័ន្ធជាច្រើននៅឧបទ្វីបអារ៉ាប់បានចូលសាសនាឥស្លាមដោយស្ម័គ្រចិត្ត និងពេញចិត្តជាទីបំផុតចំពោះសាសនាដ៏ឧត្តុង្គឧត្តមនេះ។



## 7 មរណភាពរបស់ណាពីមូហាំម៉ាត់

នៅក្នុងខែខស្សេហ្វើរ ឆ្នាំទី១១នៃមូហាំម៉ាត់សករាជ ក្រោយពីណាពីមូហាំម៉ាត់បានផ្សព្វផ្សាយសារ និងបំពេញសចក្តីទុកចិត្ត ហើយអល់ឡោះទ្រង់បានប្រទានដល់ពរជ័យមនុស្សលោក ដោយឲ្យសាសនាពេញបរិបូរហើយនោះ ណាពីក៏កើតជំងឺគ្រុនក្តៅ និងឈឺធ្ងន់ ហើយក៏លាចាកលោកនេះទៅនៅថ្ងៃចន្ទ ខែរ៉ាពីអ៊ូលអាវ៉ាល់ ឆ្នាំទី១១នៃមូហាំម៉ាត់សករាជ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ៦៣២នៃគ.ស នៅអាយុ៦៣ឆ្នាំ។ សពរបស់គាត់បានបញ្ចុះនៅផ្ទះអាអីស្ហះស្ថិតនៅក្បែរម៉ាស្ជិតណាពី។

## អត្ថន័យនៃពាក្យសច្ចាថា មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ

ពាក្យ ឬឃ្លានេះមានន័យថា ជំនឿចំពោះរាល់ដំណឹងរបស់គេ ប្រតិបត្តិតាមបទបញ្ញត្តិ និងជៀសវាងប្រមាមរបស់គាត់។ យើងត្រូវគោរពសក្ការៈចំពោះអល់ឡោះស្របតាមច្បាប់របស់អ្នកនាំសារ និងអ្វីដែលគាត់បានបង្រៀនយើង។

### តើជំនឿខ្ញុំថាណាពីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះត្រូវមានអ្វីខ្លះ

### 1 ជំនឿចំពោះដំណឹងទាំងឡាយដែលអ្នកនាំសារបានប្រាប់ក្នុងគ្រប់វិស័យទាំងអស់ដូចជា:

- រឿងអាថ៌កំបាំង ថ្ងៃបរលោក ឋានសួគ៌ បរមសុខក្នុងឋានសួគ៌ ឋាននរក និងទារុណកម្មក្នុងឋាននរក។
- ព្រឹត្តិការណ៍កើតតែឡើងនៅថ្ងៃបរលោក សញ្ញាៗជិតថ្ងៃបរលោក និងអ្វីៗដែលកើតតែឡើងនៅសម័យចុងក្រោយ(មុនថ្ងៃបរលោក)។
- ដំណឹងពត៌មានមនុស្សនៅយុគសម័យកាលបុរាណ និងអ្វីដែលបានកើតតែឡើងរវាងបណ្តាណាពីនិងកុមរបស់គាត់។



> ចាំបាច់លើអ្នកមូស្លីមជឿជាក់ចំពោះអ្វីដែលត្រូវបានបង្ហាញនៃសុណ្ណះរបស់រ៉ស៊ូលុលឡោះ សល់ឡល់ឡោហ៊ូអាឡាយហ៊ីវ៉ាសាល់ឡាំ

### 2 ការប្រតិបត្តិតាមបទបញ្ញត្តិ និងការជៀសវាងពីប្រមាមរបស់អ្នកនាំសារដូចជា:

- ការប្រតិបត្តិតាមអ្វីៗដែលអ្នកនាំសារបានបង្គាប់បញ្ជាចំពោះយើង និងភាពជឿជាក់របស់យើងគឺជឿថា គាត់មិននិយាយតាមទំនើងចិត្តឡើយ ក៏ប៉ុន្តែពាក្យសំដីរបស់គាត់គឺជាវ៉ាហ៊ីមកពីអល់ឡោះ។ អល់ឡោះទ្រង់មានបន្ទូលថា: “អ្នកណាហើយប្រតិបត្តិតាមអ្នកនាំសារ(ណាពីមូហាំម៉ាត់) គឺគេពិតជាបានប្រតិបត្តិតាមអល់ឡោះ”។ ( អាន់នីសាក ៨០)។
- ការជៀសវាងពីប្រមាដែលគាត់បានហាមឃាត់ដូចជា ចរិតមិនល្អ និងអាកប្បកិរិយាអាក្រក់។ ហើយយើងជឿជាក់ថា ការហាមប្រាមចំពោះពួកយើងពីប្រមាមទាំងនោះគឺជាហេតុផលដែលអល់ឡោះទ្រង់បាចនានិងដើម្បីផលប្រយោជន៍យើងគ្រាន់តែជួនកាលយើងមិនអាចដឹងពីវាតែប៉ុណ្ណោះ
- យើងជឿជាក់ច្បាស់ថា ការប្រតិបត្តិតាមបទបញ្ញត្តិ និងការចៀសវាងប្រមាមរបស់អ្នកនាំសារ គឺនាំមកនូវភាពល្អប្រសើរ និងសេចក្ដីសុខនៅលើលោកិយនេះ និងនៅបរលោក។ អល់ឡោះទ្រង់មានបន្ទូលថា: “ហើយចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសារ(ណាពីមូហាំម៉ាត់)ដើម្បីឲ្យពួកអ្នកទទួលបានការអាណិត្រសឡាញ់”។ ( អាលីអ៊ីមរ៉ន ១៣២)។
- ជំនឿរបស់យើងគឺ អ្នកណាល្មើសនឹងបទបញ្ញត្តិរបស់ណាពី គឺអ្នកនោះសក្តិសមនឹងត្រូវទទួលទារុណកម្មយ៉ាងឈឺចាប់។ អល់ឡោះទ្រង់មានបន្ទូលថា: “ដូច្នេះចូរឲ្យពួកដែលប្រឆាំងនឹងបទបញ្ជារបស់គេ ប្រុងប្រយ័ត្នចំពោះគ្រោះអាសន្ននឹងធ្លាក់លើពួកគេ ឬទារុណកម្មយ៉ាងឈឺចាប់ធ្លាក់លើពួកគេ”។ ( អាន់នូរ ៦៣)។

## 3 យើងត្រូវគោរពសក្ការៈចំពោះអល់ឡោះស្របតាមច្បាប់របស់អ្នកនាំសារ ហើយច្បាប់នោះមានមាត្រាជាច្រើនដែលចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ រួមមាន:

- ការយកត្រាប់តាមអ្នកនាំសារ: តាមមាគ៌ា ការចង្អុលបង្ហាញ និងជីវិតរស់នៅរបស់អ្នកនាំសារ រួមមានពាក្យសំដី ទង្វើ ការយល់ស្រប និងការទទួលស្គាល់របស់អ្នកនាំសារ គឺជាត្រាប់ស្រមាប់រាល់ភារកិច្ចជីវិតរស់នៅរបស់ពួកយើង។ ហើយខ្ញុំរបស់ទ្រង់កាន់តែជិតស្និទ្ធចំពោះទ្រង់ និងឋានៈរបស់គេក៏កាន់តែខ្ពស់ដែរ នៅពេលដែលគេយកត្រាប់តាមមាគ៌ា និងការចង្អុលបង្ហាញរបស់អ្នកនាំសារ។ អល់ឡោះទ្រង់មានបន្ទូលថា:
  “ចូរអ្នកពោលថា ប្រសិនបើពួកអ្នកស្រឡាញ់អល់ឡោះ ចូរពួកអ្នកប្រតិបត្តិតាមខ្ញុំ អល់ឡោះពិតជាស្រឡាញ់ពួកអ្នក និងអភ័យទោសឲ្យពួកអ្នកនូវបាបកម្មទាំងឡាយរបស់ពួកអ្នក។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រឡាញ់”។ ( អាលអ៊ិមរ៉ន ៣១ )។
- ច្បាប់សាសនាដ៏ពេញលេញ: អ្នកនាំសារបានផ្សព្វផ្សាយសាសនា និងច្បាប់សាសនាដ៏ពេញលេញគ្មានការខ្វះខាត ដូច្នេះមិនបានអនុញ្ញាតឡើយចំពោះអ្នកណាម្នាក់បង្កើតការគោរពសក្ការៈរបៀបថ្មី ដែលអ្នកនាំសារមិនបានដាក់ច្បាប់ការគោរពសក្ការៈនោះស្រមាប់ពួកយើងទេនោះ។.
- ច្បាប់របស់អល់ឡោះប្រសិទ្ធភាពសំរាប្រគប់សម័យកាល និងគ្រប់ទីកន្លែង: ក្រិត្យក្រមវិន័យ និងច្បាប់សាសនាដែលមាននៅក្នុងគម្ពីររបស់អល់ឡោះ( គម្ពីរអាល់គួរអាន ) និងក្នុងមាគ៌ាអ្នកនាំសារមានប្រសិទ្ធភាពស្រមាប់គ្រប់សម័យកាល និងគ្រប់ទីកន្លែង។ គ្មានអ្នកណាម្នាក់ដឹងផលប្រយោជន៍របស់មនុស្សលោកជាងម្ចាស់ដែលបានបង្កើតពួកគេអំពីទេទស្សនៀននោះឡើយ។
- ស្របតាមមាគ៌ា( អ្នកនាំសារ ): ការទទួលយកការគោរពសក្ការៈចាំបាច់ត្រូវតែនៀត( ការតាំងចិត្ត )ដោយស្មោះត្រង់ចំពោះអល់ឡោះ និងស្របតាមច្បាប់( មាគ៌ា )អ្នកនាំសារ។ អល់ឡោះទ្រង់មានបន្ទូលថា:
  “ដូច្នេះអ្នកណាដែលសង្ឃឹមថានឹងបានជួបម្ចាស់របស់គេ ចូរឲ្យគេសាងអំពើល្អ ហើយកុំឲ្យគេយកអ្នកណាម្នាក់ធ្វើជាដៃគូរក្នុងការគោរពសក្ការៈចំពោះម្ចាស់របស់គេឲ្យសោះ”។ ( អាល់កះហ្វ៍ ១១០ )។ ( ល្អ )មានន័យថា ត្រឹមត្រូវ និងស្របតាមមាគ៌ាណាពី។
- ការហាមឃាត់ចំពោះការបង្កើតថ្មីក្នុងសាសនា: អ្នកណាបង្កើតទង្វើអ្វីមួយ នឹងការគោ



> ចិត្តបរិសុទ្ធជ្រះថ្លានិងចិត្តស្ងប់ដោយការគោរពទៅចំពោះព្រះអលទ្បោះតែមួយគត

រពសក្ការៈដែលមិនមែនជាមាគ៌ាណាហ្វី ហើយគេចផុតគោរពសក្ការៈចំពោះអល់ឡោះនឹងការបង្កើតថ្មី ដូចជាបង្កើតសឡាត( ការថ្វាយបង្គំ )ថ្មីខុសពីមាគ៌ាសាសនា ដូច្នេះវាពិតជាល្មើសនឹងបទបញ្ញត្តិរបស់គាត់ គេមិនទទួលយកទង្វើនោះឡើយ ហើយថែមទាំងទទួលបាបកម្មដោយសារទង្វើនោះទៀតផង។ អល់ឡោះទ្រង់មានបន្ទូលថា: “ដូច្នេះចូរឲ្យពួកដែលប្រឆាំងនឹងបទបញ្ជារបស់គេ ប្រុងប្រយ័ត្នចំពោះគ្រោះអាសន្ននឹងធ្លាក់លើពួកគេ ឬទារុណកម្មយ៉ាងឈឺចាប់ធ្លាក់លើពួកគេ”។ ( អាន់នូរ ៦៣ )។ អ្នកនាំសារមានប្រសាសន៍ថា: “អ្នកណាបង្កើតថ្មីក្នុងកិច្ចការ( សាសនា )របស់យើងដែលមិនមកពីវា( កិច្ចការសាសនា )ទេនោះ ប្រាកដណាស់វាត្រូវបានគេច្រានចោល( មិនទទួលយក )”។ (អាល់ពូខរី២៥៥០ និងមូស្លីម១៧១៨)។



# > គោលជំនឿទាំងប្រាំមួយ

## អត្ថន័យនៃជំនឿចំពោះអល់ឡោះ

គឺជំនឿដ៏ច្បាស់លាស់ថា អល់ឡោះមានពិត ទទួលស្គាល់ទ្រង់ជាព្រះជាម្ចាស់ និងជាព្រះដែលត្រូវគេគោរពសក្ការៈតែមួយគត់ ទ្រង់មានព្រះនាម និងព្រះលក្ខណៈដ៏វិសេសវិសាល។.

យើងនឹងបកស្រាយអំពីបការទាំងបួនយ៉ាងលម្អិត ដូចតទៅនេះ:

## 1 ជំនឿថា អល់ឡោះមានពិត

### និស្ស័យដែលអល់ឡោះផ្តល់ពីកំណើត

ការទទួលស្គាល់ថា អល់ឡោះមានពិតគឺជានិស្ស័យពីកំណើតមិនចាំបាច់ត្រូវការភស្តុតាងក៏បានដែរ។ ហេតុនេះមនុស្សភាគច្រើនដែលកាន់សាសនា និងលទ្ធិផ្សេងៗគ្នា តែងតែទទួលស្គាល់ថាមានព្រះជាម្ចាស់(អល់ឡោះ)។.

រីឯពួកយើងក៏មានអារម្មណ៍ក្នុងជម្រៅបេះដូងរបស់យើងថា ទ្រង់ពិតជាមានពិត យើងត្រូវការពឹងអាស្រ័យចំពោះទ្រង់នៅពេលមានការលំបាកខ្លាំង និងពេលមានគ្រោះអាសន្ន ដោយនិស្ស័យពីកំណើតរបស់យើងដែលមានជំនឿ សុភាវៈធម្មជាតិនៃការប្រកាន់សាសនាដែលអល់ឡោះបានផ្តល់ឡើងក្នុងខ្លួនប្រាណមនុស្សគប់ៗរូប ទោះបីជាមនុស្សលោកខ្លះព្យាយាមលុបបំបាត់ និងបំភ្លេចវាក៏ដោយ។

ហើយពួកយើងធ្លាប់បានឮបាននឃើញអំពីការឆ្លើយតបនឹងពួកអ្នកបួងសួងសុំការប្រទានចំពោះពួកអ្នកដែលបានសុំ ហើយឆ្លើយតនឹងពួកអ្នកដែលមានគ្រោះអាសន្ន វាគឺជាការចង្អុលបង្ហាញឲ្យឃើញយ៉ាងច្បាស់លាស់ថាអល់ឡោះមានពិត។

### ភស្តុតាងដែលបញ្ជាក់ថាអល់ឡោះមានពិតវាច្បាស់ជាងការរំឭកប្រាប់ និងការគណនា ដូចជា

- បុគ្គលគ្រប់រូបដឹងយ៉ាងច្បាស់ថា រាល់ហេតុទាំងអស់ត្រូវមានអ្នកបង្កហេតុ ហើយសភាវលោកដ៏ច្រើនលើសលប់ដែលយើងបានឃើញគប់ពេលវេលា ចាំបាច់ត្រូវតែមានព្រះជាម្ចាស់បង្កើតវា ទ្រង់នោះគឺអល់ឡោះ។ ពីព្រោះវាមិនអាចទេអ្វីដែលកើតឡើងដោយគ្មានព្រះជាម្ចាស់បង្កើតវា ក៏ដូចគ្នាដែរមិនអាចទេអ្វីដែលកើតឡើងឯកឯងនោះ។ ព្រោះអ្វីក៏ដោយមិនអាចបង្កើតខ្លួនឯងឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “តើពួកគេត្រូវបានគេបង្កើតដោយគ្មានអ្នកបង្កើត ឬមួយពួកគេជាអ្នកដែលបង្កើតខ្លួនឯង?”។ (



ខ្លួនមនុស្សផ្ទាល់គឺជាភស្តុតាងដ៏ធំបំផុតដែលបញ្ជាក់លើវត្តមានរបស់អល់ឡោះសម្រាប់អ្នកដែលធ្វើការវិភាគ ពិចារណា និងដាក់ភ្នែកមើលទៅកាន់អ្វីដែលអល់ឡោះបានប្រទានឲ្យនូវសិទ្ធពរប្រាជ្ញា និងសុក្រឹតភាពនៃវិញ្ញាណទាំងប្រាំនិងសណ្តាប់ធ្នាប់នៃសភាវៈទាំងឡាយ និងភាពឥតខ្ចោះរបស់វាដូចជាអល់ឡោះបានមានព្រះបន្ទូលថា៖ ហើយចំពោះខ្លួនរបស់អ្នកផ្ទាល់ក៏ដូច្នោះដែរតើអ្នកបានមើលឃើញទេ?

អាត់តួរ ៣៥)។អត្ថន័យនៅក្នុងវាក្យខណ្ឌនេះគឺ ប្រាកដណាស់ពួកគេមិនអាចកើតដោយគ្មានព្រះជាម្ចាស់បង្កើតនោះទេ ហើយពួកគេក៏មិនបានបង្កើតខ្លួនឯងបានដែរ ដូច្នេះចាំបាច់តូវតែមានព្រះជាម្ចាស់បង្កើតពួកគេ ទ្រង់នោះគឺអល់ឡោះ។

- ពិតណាស់កុំគ្រាន់តែប្រព័ន្ធច្រកវាលមានមេឃ ផែនដី ផ្កាយទាំងឡាយ និងរុក្ខជាតិ។ល។ ចង្អុលបង្ហាញយ៉ាងច្បាស់លាស់ថា ស្រមាប់ច្រកវាលនេះមានព្រះជាម្ចាស់តែមួយគត់ ទ្រង់នោះគឺអល់ឡោះ។ អល់ឡោះទ្រង់មានបន្ទូលថា: “ជាការបង្កើតរបស់អល់ឡោះដែលទ្រង់បានបង្កើតអ្វីៗគ្រប់យ៉ាងល្អឥតខ្ចោះ”។ ( អាន់ណាំល៍ ៨៨)។

បណ្តាភព និងបណ្តាផ្កាយទាំងនោះជាឧទាហរណ៍វាធ្វើចលនាជាប្រព័ន្ធដ៏ល្អសុក្រឹតឥតខ្ចោះគ្មានខុសពីគន្លងវាឡើយ គ្រប់ភពទាំងអស់ធ្វើចលនាក្នុងគន្លងរបស់វាគ្មានការខុសឆ្គងឬហួសពីគន្លងរបស់វាឡើយ។

អល់ឡោះទ្រង់មានបន្ទូលថា: “ព្រះអាទិត្យមិនអាចធ្វើចលនាទាន់ព្រះច័ន្ទឡើយ។ រីឯពេលយប់ក៏មិនអាចមកដល់មុនពេលថ្ងៃបានដែរ។ ហើយអ្វីៗទាំងអស់តូវធ្វើដំណើរតាមគន្លងរបស់វារៀងៗខ្លួន”។ ( យ៉ាស៊ីន ៤០)។

## 2 ២ ២ ជំនឿចំពោះភាពជាម្ចាស់របស់អល់ឡោះ

### អត្ថន័យនៃជំនឿចំពោះភាពជាម្ចាស់របស់អល់ឡោះ

គឺជាការទទួលស្គាល់ និងការជឿជាក់យ៉ាងច្បាស់លាស់ចំពោះអល់ឡោះជាម្ចាស់ទ្រង់គ្រប់គ្រង បង្កើត ប្រទានលាភសក្ការៈចំពោះអ្វីៗទាំងអស់។ ទ្រង់ជាអ្នកប្រោសឲ្យមានជីវិតជាអ្នកឲ្យជីវិតស្លាប់ ប្រទានផល ប្រទានគ្រោះ រាល់កិច្ចការទាំងអស់គឺតាមបទបញ្ញត្តិរបស់ទ្រង់ព្រះហស្ត(កណ្តាប់ដៃ)របស់ទ្រង់ពោរពេញដោយសេចក្តីល្អប្រសើរ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់ កិច្ចការទាំងអស់នេះគ្មានអ្នកណាចូលរួមជាមួយទ្រង់ឡើយ។



ដូច្នេះ ការទទួលស្គាល់អល់ឡោះតែមួយគត់ ចំពោះរាល់ទង្វើរបស់ទ្រង់ត្រូវជឿថា

ពិតណាស់ អល់ឡោះតែមួយគត់ ទ្រង់បង្កើតចក្រវាលទាំងមូល គ្មានអ្នកបង្កើតផ្សេងក្រៅពីទ្រង់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “អល់ឡោះគឺជាអ្នកដែលបានបង្កើតរាល់អ្វីៗទាំងអស់»។ ( អាស់ហ្សូមើរ ៦២ )។

រីឯការបង្កើត ការច្នៃប្រឌិតរបស់មនុស្សលោកវិញគឺជាការប្រែពីលក្ខណៈមួយទៅលក្ខណៈមួយផ្សេងទៀត ឬក៏ជាការប្រមូលផ្ដុំ ឬផ្គុំ និងផ្សេងៗទៀត ដោយវាពុំមែនជាការបង្កើតពិត្រប្រាកដនោះឡើយ មិនមែនជាការបង្កើតពីភាពគ្មាន ហើយក៏មិនមែនជាការបង្កើតឱ្យរស់ក្រោយពេលស្លាប់។

ពិតណាស់ទ្រង់ពិតជាអ្នកប្រទានលាភសក្ការៈដល់សភាវលោកទាំងអស់ គ្មានអ្នកណាផ្ដល់លាភសក្ការៈក្រៅពីទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថា: “គ្មានសត្វលោកណាមួយដែលរស់នៅលើផែនដីលើកលែងតែអល់ឡោះផ្ដល់លាភសក្ការៈដល់ពួកគេឡើយ»។ ( ហ៊ូទ ៦ )។

ហើយពិតណាស់ ទ្រង់គឺជាស្ដេចគ្រប់គ្រងរាល់អ្វីៗគ្រប់យ៉ាង ហើយគ្មានអ្នកណាគ្រប់គ្រងពិតក្រៅពីទ្រង់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “ការគ្រប់គ្រងមេឃជាច្រើន និងផែនដី ព្រមទាំងអ្វីៗដែលមាននៅក្នុងវាទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ”។ ( អាល់ម៉ាអ៊ីដះ ១២០ )។

ហើយទ្រង់គឺជាអ្នកចាត់ចែងអ្វីៗទាំងអស់ គ្មានអ្នកចាត់ចែងណាក្រៅពីអល់ឡោះឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “ទ្រង់ចាត់ចែងកិច្ចការពីលើមេឃមកកាន់ផែនដី»។ ( អាស់សាជដះ ៥ )។

រីឯការចាត់ចែងរបស់មនុស្សលោកចំពោះកិច្ចការ ជីវិតរស់នៅ និងការរៀបចំកិច្ចការរបស់ពួកគេមានភាពស្មុគស្មាញ និងមានដែនកំណត់ត្រឹមតែអ្វីៗដែលនៅក្នុងកណ្ដាប់ដៃរបស់គេ អ្វីៗដែលគេគ្រប់គ្រង និងមានលទ្ធភាពប៉ុណ្ណោះ។ ជួនកាលការចាត់ចែងរបស់គេទទួលបានផល ហើយជួនកាលបរាជ័យ។ ក៏ប៉ុន្តែការចាត់ចែងរបស់ទ្រង់ជាអ្នកបង្កើតវិញពេញលេញគ្មានចន្លោះប្រហោងត្រង់ណាឡើយ។ ម្យ៉ាងទៀតវាប្រព្រឹត្តទៅយ៉ាងរលូនគ្មានអ្វីរារាំង និងគ្មានការប្រឈមមុខអ្វីឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “ចូរដឹងថា! ការបង្កើត និងការគ្រប់គ្រងគឺជាកម្មសិទ្ធិរបស់ទ្រង់។ អល់ឡោះដ៏មហាឧត្ដុង្គឧត្ដមជាម្ចាស់គ្រប់គ្រងពិភពទាំងអស់”។ ( អាល់អាក់រ៉ហ្វ ៥៤ )។



គ្មានសត្វលោកដែលដើរ ហើយរស់នៅលើលោកិយនេះ លើកលែងតែអល់ឡោះជាអ្នកផ្ដល់លាភសក្ការៈឲ្យពួកគេ

## ពួកអារ៉ាប់ដែលគោរពពហុទេពនៅសម័យអ្នកនាំសារ ពួកគេមានជំនឿចំពោះភាពជាម្ចាស់របស់អល់ឡោះ

ពួកអ្នកក្របឆាំងនៅសម័យអ្នកនាំសារបានទទួលស្គាល់ថាអល់ឡោះទ្រង់ពិតជាអ្នកបង្កើត ជាអ្នកគ្រប់គ្រង និងចាត់ចែង ប៉ុន្តែជំនឿនេះធ្វើឱ្យពួកគេចូលសាសនាឥស្លាមបានទេ គ្រាន់តែទទួលស្គាល់ប៉ុណ្ណឹងនោះ។ អល់ឡោះទ្រង់មានបន្ទូលថា: "ហើយប្រសិនបើអ្នក( ណាពីមូហាំម៉ាត់) សួរពួកគេ( ពួកពហុទេព) ថា: តើអ្នកណាដែលបានបង្កើតមេឃជាច្រើនជាន់ និងផែនដី? ពួកគេពិតជានឹងឆ្លើយថា: គឺអល់ឡោះ"។ ( លុកម៉ាន ២៥)។

ពីព្រោះអ្នកដែលបានទទួលស្គាល់ថាអល់ឡោះជាម្ចាស់គ្រប់គ្រងពិភពទាំងអស់ មានន័យថា ទ្រង់គឺជាអ្នកបង្កើត គ្រប់គ្រង និងមើលថែរក្សាពួកគេដោយពរជ័យរបស់ទ្រង់ ចាំបាច់ណាស់គេត្រូវតែគោរពសក្ការៈចំពោះទ្រង់តែមួយគត់ ដោយមិនគោរពសក្ការៈអ្នកដទៃឡើយ។

សមហេតុផលយ៉ាងដូចម្ដេច ដែលមនុស្សទទួលស្គាល់ថា អល់ឡោះជាអ្នកបង្កើតគ្រប់អ្វីៗទាំងអស់ និងជាអ្នកចាត់ចែងប្រក្រតីលុះទ្រង់ជាអ្នកធ្វើឲ្យមានជីវិត និងឲ្យស្លាប់ ហើយគេបែរជាថ្វាយអ្វីមួយនៃការគោរពសក្ការៈជូនចំពោះអ្នកផ្សេងក្រៅពីទ្រង់?! នេះជាទង្វើដ៏អយុត្តិធម៌បំផុត និងអំពើបាបដ៏ធ្ងន់ធ្ងរបំផុត។ ដូច្នេះហើយណាពីលុកម៉ានបានពោលទៅកាន់កូនគាត់ដោយទូន្មាន និងណែនាំថា: □ឱកូនសម្លាញ់! ឯងកុំធ្វើស្ទីរិកចំពោះអល់ឡោះឲ្យសោះ។ ពិតណាស់អំពើស្ទីរិកគឺជាបាបកម្មមួយដ៏ធំ□។ ( លុកម៉ាន ១៣)។
ហើយនៅពេលគេសួរអ្នកនាំសារថា: បាបកម្មអ្វីដែលធំជាងគេចំពោះអល់ឡោះ? គាត់ក៏ឆ្លើយថា: □គឺឯងប្រព្រឹត្ត( គោរពសក្ការៈ) ទៅចំពោះអ្នកដទៃផ្សេងដូច( គោរពសក្ការៈ) ចំពោះអល់ឡោះដែលទ្រង់បានបង្កើតអ្នក□។ (អាល់ពូខរី៤២០៧ និងមូស្លីម៨៦)។

## ជំនឿចំពោះភាពជាម្ចាស់របស់អល់ឡោះធ្វើឲ្យចិត្តស្ងប់ស្ងាត់ស្ងួល

កាលណាខ្ញុំ( របស់អល់ឡោះ) ដឹងយ៉ាងច្បាស់ថាគ្មានអ្នកណាម្នាក់អំពីសភាវលោកអាចគេចចេញព្រឹត្តិលិខិត( បានកំណត់) របស់អល់ឡោះ ពីព្រោះអល់ឡោះទ្រង់គ្រប់គ្រង ចាត់ចែងពួកគេតាមការសព្វព្រះទ័យស្របតាមគតិបណ្ឌិតរបស់ទ្រង់ដែលទ្រង់ជាអ្នកបង្កើតពួកគេទាំងអស់។ អ្វីៗក៏ដោយក្រៅពីអល់ឡោះត្រូវបានគេបង្កើតឡើង មានលក្ខណៈ ខ្វះខាត ត្រូវការទ្រង់ដែលជាអ្នកបង្កើតគេ។ គ្រប់ភារកិច្ចទាំងអស់នៅក្នុងកណ្ដាប់ដៃរបស់ទ្រង់ គ្មានអ្នកបង្កើត គ្មានអ្នកប្រទានលាភសក្ការៈ និងគ្មានអ្នកចាត់ចែងប្រក្រតីលោកក្រៅពីទ្រង់តែមួយគត់នោះទេ។ សូម្បីតែគ្រាប់ធញ្ញជាតិមួយគ្រាប់ក៏មិនប្រែប្រួលបានដែរ លុះត្រាតែមានការអនុញ្ញាតពីទ្រង់ ហើយគ្រាប់ធញ្ញជាតិមួយគ្រាប់ផ្សេងទៀតមិនប្រែប្រួ



> ការជឿជាក់ចំពោះភាពជាម្ចាស់ថែរក្សារបស់អល់ឡោះ ធ្វើអោយមានចិត្តស្ងប់

រូល         ក៏តាមបទបញ្ញារបស់ទង្វៃដរ។ ហេតុដូច្នេះ         ទើបត្រូវឲ្យចិត្តមនុស្សលោកផ្សាភ្ជាប់នឹងអល់ឡោះ បួងសួងសុំ ត្រូវការ និងពឹងចំពោះទ្រង់តែមួយគត់នូវគ្រប់កិច្ចការជីវិតរបស់គេ។ ការសែដាឆ្ពោះទៅមុខ ការខ្ជាប់ខ្ជួនក្នុងការប្រឈមនឹងឧបសគ្គជីវិត ប្រកែបដោយភាពស្កប់ស្កល់ រឹងប៉ឹង និងមានភាពនឹងនរយ៉ាងពេញលេញពីព្រោះជានិច្ចកាលគេតែងតែប្រើបាស្រគប់មធ្យោបាយ និងបួងសួងសុំចំពោះអល់ឡោះ ដើម្បីទទួលបានសម្រេចតាមបំណងប្រាថ្នាចង់បានក្នុងកិច្ចការជីវិត។ គ្រប់តិបត្តិតាមភារកិច្ចរបស់គេ នៅពេលនោះខ្លួនគេនឹងស្កប់ស្កល់មិនសម្លឹងមើល(         ចង់បាន) អ្វីៗដែលនៅក្នុងកណ្ដាប់អ្នកដទៃ។ តាមពិតកិច្ចការទាំងអស់នៅក្នុងកណ្ដាប់របស់អល់ឡោះ ទ្រង់បង្កើតអ្វីដែលទ្រង់ប្រាថ្នា និងជ្រើសរើស។

## 3 ជំនឿចំពោះភាពជាព្រះរបស់អល់ឡោះ

### អត្ថន័យនៃជំនឿចំពោះភាពជាព្រះរបស់អល់ឡោះ ?

គឺជាការជឿជាក់យ៉ាងដាច់ខាតថា អល់ឡោះតែមួយគត់ដែលស័ក្តិសមនឹងទទួលការគោរពសក្ការៈគ្រប់ប្រភេទទាំងអស់ ទាំងការគោរពសក្ការៈផ្នែកខាងក្រៅ និងផ្នែកខាងក្នុង។         ដូច្នេះយើងត្រូវប្រតិបត្តិការគោរពសក្ការៈទាំងអស់ជូនចំពោះទ្រង់តែមួយគត់ដូចជាការបួងសួងសុំ កោតខ្លាច ជឿទុកចិត្ត សុំជំនួយ សទ្បាត(ការថ្វាយបង្គំ) បង់ហ្សាកាត់(         បង្រួំទ្រព្យសម្បត្តិតាមច្បាប់តស្លាម) អំណត់បួស ហើយគ្មានអ្នកណាត្រូវគេគោរពសក្ការៈដ៏ពិត្រប្រាកដក្រៅពីអល់ឡោះឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា:         “ហើយព្រះជាម្ចាស់របស់ពួកអ្នកគឺជាព្រះជាម្ចាស់តែមួយគត់។         គ្មានព្រះជាម្ចាស់ណាដែលត្រូវគេគោរពសក្ការៈដ៏ពិត្រប្រាកដក្រៅព្រីទង្វៃដលមហាស



> ការទទួលស្គាល់អល់ឡោះតែមួយគត់ជាព្រះដែលត្រូវគោរពសក្ការៈពិតប្រាកដហើយការគោរពសំពះទៅចំពោះទ្រង់គឺជាភាពពិតនៃអត្ថន័យនៃពាក្យ គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈពិតប្រាកដលើកលែងតែងអល់ឡោះ

បុរស មូហាអាណិតស្រឡាញ់នោះឡើយ”។ (អាលហ្គាកេរ៉ោះ ១៦៣)។

ទ្រង់ប្រាប់ថា ព្រះជាម្ចាស់គឺជាព្រះតែមួយ មានន័យថា ត្រូវគេគោរពសក្ការៈតែមួយគត់។ ដូច្នេះ មិនអនុញ្ញាតឲ្យយកព្រះជាម្ចាស់ផ្សេងគោរពសក្ការៈក្រៅពីទ្រង់ជាដាច់ខាត។

## សារៈសំខាន់នៃជំនឿចំពោះភាពជាព្រះរបស់អល់ឡោះ

សារៈសំខាន់នៃជំនឿចំពោះភាពជាព្រះរបស់អល់ឡោះត្រដាងឡើងក្នុងផ្នែកជាច្រើនដូចជា

1. ពិតណាស់វាជាគោលដៅនៃការបង្កើតជិន (ដែលអល់ឡោះបង្កើតវាពីភ្លើង) និងមនុស្សលោក គ្មានអ្វីក្រៅពីការគោរពសក្ការៈចំពោះទ្រង់តែមួយគត់ដោយគ្មានការគោរពសក្ការៈចំពោះអ្នកផ្សេងរួមជាមួយទ្រង់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា៖ “ហើយយើងមិនបានបង្កើតជិន និងមនុស្សលោកក្រៅពីឲ្យពួកគេគោរពសក្ការៈមកចំពោះយើងឡើយ”។ (អាស់ហ្សារីយ៉ាត ៥៦)។



2. ជាការពិតគោលបំណងនៃការបញ្ជូនបណ្ដាអ្នកនាំសារ និងការបញ្ចុះបណ្ដាលគម្ពីរពីលើមកនោះគឺការទទួលស្គាល់ថា អល់ឡោះជាអ្នកដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ ហើយប្រឆាំងចំពោះអ្វីៗដែលគេគោរពសក្ការៈក្រៅពីទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថា៖ “ហើយជាការពិតណាស់ រាល់ប្រជាជាតិនីមួយៗយើងបានតែងតាំងអ្នកនាំសារម្នាក់ ដោយបង្គាប់ពួកគេឲ្យគោរពសក្ការៈចំពោះអល់ឡោះ និងជៀសវាងពីតហ្គ៊ូត (អ្វីៗដែលគេគោរពសក្ការៈផ្សេងក្រៅពីអល់ឡោះ)”។ (អាន់ណះល៍ ៣៦)

3. ពិតណាស់វាជាកាតព្វកិច្ចដំបូងបង្អស់មកលើមនុស្សលោក ដូចអ្វីដែលណាពីបានផ្ដាំផ្ញើចំពោះមូអាស៊្យពិនហ្ចាបាល ពេលណាពីបញ្ជូនគាត់ទៅកាន់ប្រទេសយេម៉ែនដោយមានប្រសាសន៍ថា៖ “ពិតណាស់អ្នកនឹងទៅជួបមួយក្រុមនៃពួកអះលីគីតាប (ពួកដែលអល់ឡោះផ្ដល់គម្ពីរឲ្យគឺពួកយ៉ាហ៊ូទី និងណាសរ៉នី) ដូច្នេះអ្វីដែលអ្នកត្រូវតែអំពាវនាវពួកគេដំបូងបង្អស់នោះគឺការសច្ចាថា គ្មានព្រះជាម្ចាស់ក្រៅពីអល់ឡោះ”។ (អាល់ពូខរី ១៣៨៩ និងមូស្លីម ១៩)។ វាគឺត្រូវឲ្យអ្នកអំពាវនាវពួកគេឲ្យធ្វើការគោរពសក្ការៈគ្រប់ប្រភេទទាំងអស់ជូនចំពោះអល់ឡោះតែមួយគត់។

4. ពិតណាស់ជំនឿចំពោះភាពជាព្រះគឺជាអត្ថន័យពិតនៃពាក្យ គ្មានព្រះជាម្ចាស់ក្រៅពីអល់ឡោះ។ ព្រះមានន័យថា អ្នកដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ ដោយគ្មានអ្នកដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ ហើយយើងមិនថ្វាយប្រការណាមួយនៃការគោរពសក្ការៈគ្រប់ប្រភេទទាំងអស់ជូនអ្នកផ្សេងក្រៅពីទ្រង់ឡើយ។

5. ពិតណាស់ជំនឿចំពោះភាពជាព្រះ (របស់អល់ឡោះដែលត្រូវតែគេគោរពសក្ការៈ) គឺជាលទ្ធផលសមហេតុផលនៃជំនឿថា អល់ឡោះជាអ្នកបង្កើត ជាអ្នកគ្រប់គ្រង និងជាអ្នកចាត់ចែង។

## > តើការគោរពសក្ការៈមានន័យដូចម្តេច ?

ការគោរពសក្ការៈគឺគប់នាម(គ្រប់អ្វីៗ)ដែលអល់ឡោះទ្រង់សទ្បាញ់យល់ព្រម ហើយវាមានទាំងវាចា និងកាយវិការដែលទ្រង់បញ្ញត្ត និងត្រូវឲ្យមនុស្សបតិបត្តិវា ទោះវាជាការប្រតិបត្តិផ្នែកខាងក្រៅដូចជា សទ្បាត(ការថ្វាយបង្គំ) ហ្សាកាត(ការបង់ទព្យសម្បត្តិតាមច្បាប់ឥស្លាម) ការធ្វើហាជ្ជ(នៅក្រុងម៉ាក្កះ) ឬវាជាការប្រតិបត្តិផ្នែកខាងក្នុងដូចជា ការស្រទ្បាញ់អល់ឡោះ ការស្រទ្បាញ់អ្នកនាំសាររបស់ទ្រង់ ការកោតខ្លាចចំពោះទ្រង់ ការជឿទុកចិត្តលើទ្រង់ ការសុំជំនួយពីទ្រង់ៗល។

### ការគោរពសក្ការៈប្រព្រឹត្តទៅលើគប់វិស័យរស់នៅរបស់មនុស្សលោក

ការគោរពសក្ការៈគឺគបដណ្តប់លើរាល់សកម្មភាពរបស់អ្នកមានជំនឿកាលណាគេនៀត(ការតាំងចិត្ត)នៃសកម្មភាពនោះដើម្បីសក្ការៈចំពោះអល់ឡោះ។ ការគោរពសក្ការៈក្នុងសាសនាឥស្លាមពុំមែនត្រឹមតែជាអត្តសញ្ញាណសាសនាដូចជា សទ្បាត(ការថ្វាយបង្គំ) អំណត់បួស ៗល។ ដែលគេស្គាល់នោះទេ។ ផ្ទុយទៅវិញរាល់សកម្មភាពណាដែលមានសារៈប្រយោជន៍ដោយមាននៀត(ការតាំងចិត្ត)ដែលល្អត្រឹមត្រូវ សកម្មភាពនោះក៏ក្លាយជាការគោរពសក្ការៈដែលទទួលបានផលបុណ្យ។ ប្រសិនបើអ្នកឥស្លាមបរិភោគ ឬទទួលទាន ឬស្រូបទាន់ដោយប្រាថ្នាចង់ឲ្យរាងកាយមាំមួនដើម្បីប្រតិបត្តិជូនចំពោះអល់ឡោះ ប្រាកដណាស់គេពិតជាទទួលបានផលបុណ្យ។ ហេតុដូច្នេះទាមទារឲ្យអ្នកឥស្លាមប្រើប្រាស់ជីវិតរបស់ពួកគេទាំងអស់ថ្វាយជូនអល់ឡោះ។ គេបរិភោគអាហារចង់ឲ្យរាងកាយមាំមួនដើម្បីប្រតិបត្តិចំពោះអល់ឡោះ នោះការបរិភោគអាហារដោយគេប្រាថ្នាដូច្នោះនោះ គេក៏បានផលបុណ្យនការគោរពសក្ការៈផងដែរ។ គេរៀបការដើម្បីរក្សាខ្លួនពីប្រមាថ(របស់អល់ឡោះ) នោះអាពាហ៍ពិពាហ៍របស់គេក៏បានផលបុណ្យនការគោរពសក្ការៈផងដែរ។ ដូចគ្នាដែរការប្រាថ្នាល្អត្រឹមត្រូវក្នុងជំនួញ មុខងារតួនាទីនិងប្រាក់ចំណូល(ដែលល្អត្រឹមត្រូវ)របស់គេបានផលបុណ្យនការគោរពសក្ការៈផងដែរ។ ការទទួលបានចំណេះដឹង សញ្ញាប្រតការសិក្សាស្រាវជ្រាវ ស្វែងរកចំណេះដឹងការច្នៃប្រឌិត(ផលិតផល) ទាំងអស់នោះគេនឹងទទួលបានផលបុណ្យនការគោរពសក្ការៈផងដែរ។ ការមើលថែរក្សារបស់ភរិយាចំពោះស្វាមី កូនៗ ផ្ទះសំបែងរបស់នាង នោះនាងនឹទទួលបានផលបុណ្យនការគោរពសក្ការៈផងដែរ។ ដូច្នេះ គ្រប់វិស័យរស់នៅគ្រប់សកម្មភាព និងកិច្ចការដែលមានសារៈប្រយោជន៍របស់មនុស្សលោក ទទួលបានផលបុណ្យនការគោរពសក្ការៈជានិច្ច កាលណាអ្វីៗទាំងអស់នោះប្រកបដោយការនៀត(ការតាំងចិត្ត)ល្អ និងស្អាតស្អំ។.



> ទង្វើទាំងអស់ដែលអោមជាមួយការប៉ុនប៉ោងល្អត្រឹមត្រូវ គេចាត់ទុកថាជាអំពើដាក់ ដែលនឹងត្រូវបានតបស្នងទៅលើបុគ្គលដែលបានសាងវា។

## ការគោរពសក្ការៈគឺជាគតិបណ្ឌិតនៃការបង្កើត( ជិន និងមនុស្សលោក )

អល់ឡោះទ្រង់មានបន្ទូលថា: "ហើយយើងមិនបានបង្កើតជិន និងមនុស្សលោកក្រៅពីឲ្យពួកគេគោរពសក្ការៈចំពោះយើងឡើយ។ យើងមិនត្រូវការលាភសក្ការៈពីពួកគេ ហើយយើងក៏មិនត្រូវការឲ្យពួកគេផ្តល់អាហារដល់យើងដែរ។ ពិតណាស់អល់ឡោះជាអ្នកផ្តល់លាភសក្ការៈដែលមានអានុភាពខ្លាំងក្លាជាទីបំផុត"។ ( អាស់ហ្សារីយ៉ាត ៥៦- ៥៨)។ អល់ឡោះបានប្រាប់ថាពិតណាស់គតិបណ្ឌិតនៃការបង្កើតជិន និងមនុស្សលោកគឺ ប្រតិបត្តិការគោរពសក្ការៈរបស់ពួកគេចំពោះអល់ឡោះ។ ពុំមែនមានន័យថា ទ្រង់ត្រូវការការគោរពសក្ការៈរបស់ពួកគេនោះទេ តែតាមពិតគឺពួកគេត្រូវការការគោរពសក្ការៈចំពោះទ្រង់ទៅវិញ ពីព្រោះពួកគេគ្រក់ទុរគតត្រូវការទ្រង់។

ប្រសិនបើមនុស្សលោកព្រងើយកន្តើយពីបំណងប្រាថ្នា (ការគោរពសក្ការៈ)នេះ និងងប់ងុលក្នុងភាពត្រេកត្រអាលលើលោកិយ ដោយគ្មានការភ្ញាក់រឭកចំពោះគតិបណ្ឌិតព្រះជាម្ចាស់នៃការមានវត្តមានរបស់គេ(នៅលើលោកិយ)នេះ គេគឺនឹងក្លាយជាសភាវលោកដែលគ្មានលក្ខណៈល្អប្រសើរជាងសភាវលោកដទៃទៀតលើភពផែនដីនេះឡើយ។ សត្វពាហនៈស៊ីចំណី ផឹកទឹក ហើយមិនខ្វល់ខ្វាយនឹងអ្វីឡើយ ដោយសារពួកវាពុំត្រូវគេនាំមកជំនុំជម្រះ(កាត់សេចក្តី)នៅថ្ងៃបរលោកឡើយ។ ខុសពីមនុស្សលោកដែលពួកគេត្រូវគេជំនុំជម្រះ(កាត់សេចក្តី)។ អល់ឡោះទ្រង់មានបន្ទូលថា: "រីឯពួកដែលប្រឆាំងវិញ ពួកគេសាយសុខ(នៅក្នុងលោកិយ) និងស៊ីចុកដូចជាសត្វពាហនៈស៊ីដូច្នោះដែរ។ ហើយនរកគឺជាកន្លែងជ្រកកោនសម្រាប់ពួកគេ"។ ( មូហាំម៉ាត់ ១២)។ មនុស្សលោកប្រព្រឹត្តដូចសត្វពាហនៈទាំងសកម្មភាពនិងទំនើងចិត្ត ក៏ប៉ុន្តែពួកគេ(មនុស្សលោក) នឹងទទួលការតបស្នងវិញរាល់អ្វីដែលពួកគេបានសាង ពីព្រោះពួកគេមានសតិបញ្ញាយល់ដឹងខុសត្រូវ ស្រេចខ្លួនខុសពីសត្វពាហនៈដែលគ្មានសតិបញ្ញាយល់ដឹងខុសត្រូវស្រេចខ្លួនអ្វីឡើយ។



> លក្ខណៈលើភាពត្រឹមត្រូវនៃអំពើដាក់ត្រូវមានចិត្តបរិសុទ្ធជូនអល់ឡោះមហាខ្ពង់ខ្ពស់ ហើយនិងធ្វើតាមរស៊ូលរបស់ទ្រង់ក្នុងការអនុវត្តអំពើដាក់នោះ

## គោលគ្រឹះនៃការគោរពសក្ការៈ

ពិតណាស់ ការគោរពសក្ការៈដែលអល់ឡោះទ្រង់បង្គាប់នោះផ្អែកលើគោលការណ៍សំខាន់ៗពីរ៖

ទីមួយ: ការបន្ទាបខ្លួន និងកោតខ្លាចដើម្បីញលញ។

ទីពីរ: សេចក្តីស្រឡាញ់ពេញចិត្តដ៏ខ្ពង់ខ្ពស់បំផុតចំពោះទ្រង់។

ការគោរពសក្ការៈដែលអល់ឡោះដាក់កាតព្វកិច្ចលើខ្ញុំរបស់ទ្រង់គួរតែបន្ទាបខ្លួន ប្រណិប័តន៍ និងកក្តុតខ្លាចដើម្បីញៀលុញចំពោះទ្រង់ ជាមួយនឹងសេចក្តីស្រឡាញ់ពេញចិត្ត ប្រាថ្នា ចូលចិត្ត និងសេចក្តីសង្ឃឹមដ៏ខ្ពង់ខ្ពស់បំផុតចំពោះទ្រង់។

យោងតាមការបក្រសាយខាងលើបញ្ជាក់ថា សេចក្តីស្រឡាញ់ចូលចិត្តដែលគ្មានការកោតខ្លាច និងបន្ទាបខ្លួននោះ ដូចជាការស្រឡាញ់ចូលចិត្តចំណីអាហារ ទ្រព្យសម្បត្តិ ពុំមែនជាការគោរពសក្ការៈនោះទេ។ ក៏ដូចគ្នានោះដែរ ការកោតខ្លាចដោយគ្មានការស្រឡាញ់ចូលចិត្តដូចជាសេចក្តីភ័យខ្លាចពីសត្វសាហាវ និងអ្នកកាន់អំណាចរំលោភបំពាន គេមិនបានចាត់ទុកជាការគោរពសក្ការៈនោះទេ។ កាលណាការកោតខ្លាច និងការស្រឡាញ់ពេញចិត្តកើតឡើងព្រមគ្នាក្នុងការប្រតិបត្តិអ្វីមួយនោះ ពិតណាស់ការប្រតិបត្តិនោះក្លាយជាការគោរពសក្ការៈ។ ការគោរពសក្ការៈគឺសំរាប់អល់ឡោះតែមួយគត់គ្មានអ្នកណាផ្សេងក្រៅពីទ្រង់ឡើយ។

## លក្ខខណ្ឌនៃការគោរពសក្ការៈ

ដើម្បីឲ្យការគោរពសក្ការៈមានភាពត្រឹមត្រូវ និងគេទទួលយកនោះ ត្រូវមានពីរលក្ខខណ្ឌ៖

1. លក្ខខណ្ឌទី១: ការគោរពសក្ការៈដោយស្មោះត្រង់ជូនចំពោះអល់ឡោះតែមួយគត់ដោយគ្មានការគោរពសក្ការៈចំពោះអ្នកផ្សេងរួមជាមួយទ្រង់ឡើយ។
2. លក្ខខណ្ឌទី២: ការប្រតិបត្តិគោរពសក្ការៈត្រឹមត្រូវតាមមាគ៌ាអ្នកនាំសារ។

អល់ឡោះទ្រង់មានបន្ទូលថា: “ការពិតមិនមែនដូច្នោះទេ (អ្នកដែលបានចូលឋានសួគ៌នោះ) គឺអ្នកដែលបានប្រគល់ខ្លួនប្រាណរបស់គេចំពោះអល់ឡោះដោយប្រតិបត្តិកុសលធម៌។ ដូច្នេះ ស្រមាប់អ្នកនោះនឹងទទួលបានផលបុណ្យពីម្ចាស់របស់គេ ហើយពួកគេគ្មានការភ័យខ្លាច និងព្រួយបារម្ភអ្វីឡើយ”។ ( អាល់ហ្គាកេរ៉ោះ ១១២ )។

ឃ្លា “ប្រគល់ខ្លួនប្រាណរបស់គេចំពោះអល់ឡោះ” ន័យរបស់វាគឺសម្រេចបាននូវជំនឿឯកទេវៈ( ជំនឿលើអល់ឡោះតែមួយគត់ ) ដោយការគោរពសក្ការៈរបស់គេស្មោះត្រង់ជូនចំពោះអល់ឡោះ។ ឃ្លា “ដោយប្រតិបត្តិកុសលធម៌” ន័យរបស់វាគឺប្រតិបត្តិតាមច្បាប់អល់ឡោះ និងមាគ៌ាអ្នកនាំសារ។

ការប្រតិបត្តិតាមមាគ៌ាអ្នកនាំសារ វាគឺសំរាប់តែការគោរពសក្ការៈតែប៉ុណ្ណោះដូចជា សឡាត( ការថ្វាយបង្គំ ) អំណត់បួស ហ្សីកៀរ( ការនឹក )ចំពោះអល់ឡោះ ។ល។ រីឯអ្វីដែលនៅក្រៅរង្វង់នៃការគោរពសក្ការៈដូចជា ទំនៀមទម្លាប់ និងសកម្មភាពដែលបុគ្គលនៀត( តាំងចិត្ត ) ចង់បានផលបុណ្យពីអល់ឡោះដូចជា ការធ្វើលំហាត់ប្រាណដោយនៀត( តាំងចិត្ត )ចង់ឲ្យរាងកាយរឹងមាំដើម្បីប្រតិបត្តិតាមអល់ឡោះ ការប្រកបអាជីពជំនួញ( ដែលត្រឹមត្រូវ )ដើម្បីយកកំរៃចិញ្ចឹមគ្រួសារ និងកូនចៅ គេមិនទាមទារឲ្យតាមមាគ៌ាអ្នកនាំសារនោះទេ តែគេមិនអនុញ្ញាតឲ្យប្រព្រឹត្តបទល្មើសនឹងប្រមាម( ក្នុងសាសនា )ទៅបាននោះហើយ។



## > ស៊ីរិក

- ស៊ីរិកគឺផ្ទុយពីជំនឿភាពជាព្រះតែមួយរបស់អល់ឡោះ។ ប្រសិនជាជំនឿភាពជាព្រះតែមួយរបស់អល់ឡោះ និងការគោរពសក្ការៈចំពោះទ្រង់តែមួយគត់ជាកាតព្វកិច្ចដ៏សំខាន់ និងធំចម្បងជាទីបំផុតនោះ។ ដូច្នេះ ស៊ីរិកចំពោះអល់ឡោះគឺជាបទល្មើសដ៏ធំបំផុតដែរ វាគឺជាបាបកម្មតែមួយដែលទ្រង់មិនលើកលែងទោសជាដាច់ខាតទាល់តែតាវហ្ពាត់( សារភាពកំហុស) ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ពិតណាស់អល់ឡោះមិនអភ័យទោសឲ្យអ្នកដែលធ្វើស៊ីរិកចំពោះទ្រង់នោះឡើយ តែទ្រង់នឹងអភ័យទោសឲ្យចំពោះបាបកម្មផ្សេងពីនោះសម្រាប់អ្នកណាដែលទ្រង់មានចេតនា”។ ( អាន់នីសាក ៤៨)។ នៅពេលគេសួរអ្នកនាំសារអំពីបាបកម្មអ្វីដែលធំជាងគេចំពោះអល់ឡោះ? គាត់ឆ្លើយថាៈ “ នោះគឺអ្នកធ្វើស៊ីរិកចំពោះអល់ឡោះ ហើយទ្រង់ជាអ្នកបង្កើតអ្នក” ។ (អាល់ពូខរី៤២០៧ និងមូស្លីម៨៦)។
- ស៊ីរិកធ្វើឲ្យអំពើល្អទាំងឡាយបាត់បង់រលាយសាបសូន្យ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ ប្រសិនបើពួកគេ( បណ្ដាណាពី) បានធ្វើស៊ីរិកនោះ អ្វីដែលពួកគេធ្លាប់បានសាងពិតជាបាត់បង់ពីពួកគេជាមិនខាន”។ ( អាល់អាន់អាម ៨៨)។

  អ្នកដែលប្រព្រឹត្តស៊ីរិកត្រូវតែចូលក្នុងនរកជើហាន់ណាំជារៀងរហូត។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ ពិតណាស់ អ្នកណាធ្វើស៊ីរិកនឹងអល់ឡោះ អល់ឡោះពិតជាបានហាមឃាត់គេពីឋានសួគ៌ ហើយកន្លែងស្នាក់នៅរបស់គេគឺឋាននរក”។ (អាល់មាអ៊ីដះ ៧២)។

### ស៊ីរិកមានពីរប្រភេទៈ គឺស៊ីរិកធំ និងស៊ីរិកតូច

**1** **ស៊ីរិកធំ គឺខ្ញុំ(របស់អល់ឡោះ) ថ្វាយការគោរព សក្ការៈណាមួយចំពោះអ្នកផ្សេងក្រៅពីអល់**ឡោះ។ រាល់ពាក្យសុំដី និងទង្វើដែលអល់ឡោះទ្រង់សព្វព្រះទ័យ ហើយថ្វាយជូនចំពោះទ្រង់នោះ គឺជាជំនឿភាពជាព្រះជាម្ចាស់តែមួយរបស់ទ្រង់ ហើយ ថ្វាយជូនចំពោះអ្នកផ្សេងក្រៅពីទ្រង់គឺជាស៊ីរិកធំចេញពីសាសនា( ឥស្លាម)។.

ស៊ីរិកធំមានដូចជាការបួងសួងសុំទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះ ការសុំទៅកាន់អ្នកផ្សេងក្រៅពីទ្រង់ឲ្យជាសះស្បើយពីជំងឺ ឲ្យទទួលបានលាភសក្ការៈសម្បូរហូរហៀរ ការជឿទុកចិត្ត ឬស៊ូជោត( ក្រាបគោរព) ចំពោះអ្នកផ្សេងក្រៅព្រទង់។ល។

អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយម្ចាស់របស់អ្នកបានមានបន្ទូលថា ចូរពួកអ្នកបួងសួងសុំចំពោះយើងចុះ យើងនឹងទទួលយកការបួងសួងសុំរបស់ពួកអ្នក”។ ( ហ្គហ្វៀរ ៦០)។

អល់ឡោះទ្រង់មានបន្ទូលទៀតថាៈ “ហើយចូរពួកអ្នកប្រគល់ការទុកចិត្តចំពោះអល់ឡោះចុះ ប្រសិនបើពួកអ្នកជាអ្នកមានជំនឿ”។ (អាល់មាអ៊ីដះ ២៣)។

អល់ឡោះទ្រង់ក៏មានបន្ទូលថាៈ “ដូច្នេះ ចូរពួកអ្នកស៊ូជោត( ក្រាបគោរព) និងគោរពសក្ការៈចំពោះអល់ឡោះចុះ”។ ( អាន់ណាចម៍ ៦២)។

ដូច្នេះ អ្នកណាថ្វាយការគោរពសក្ការៈចំពោះអ្នកផ្សេងក្រៅពីអល់ឡោះ គឺគេជាអ្នកធ្វើស៊ីរិកធំចេញពីសាសនា( ឥស្លាម)។

## 2 ស៊ីរិកតូច គឺរាល់ពាក្យសំដី ឬទង្វើដែលជាមធ្យោបាយ និងជាផ្លូវនាំឲ្យធ្លាក់ទៅក្នុងស៊ីរិកធំ។.

ឧទាហរណ៍: ទង្វើដែលចង់បង្ហាញគដូចជាបុគ្គលម្នាក់ជូនកាលែគសឡាត(ថ្វាយបង្គំ) ប្រើរយៈពេលយូរដើម្បីបង្ហាញមនុស្សឲ្យឃើញ ឬជូនកាលែគបន្លឺសម្លេងអានអាល់គួរអាន ឬហៀកៀរ ដើម្បីឲ្យមនុស្សលាន់ឮនឹងកោតសរសើរ។
អ្នកនាំសារមានប្រសាសន៍ថា: “អ្វីដែលខ្ញុំខ្លាចបារម្ភជាងគេទៅលើពួកអ្នកឯងនោះ គឺស៊ីរិកតូច។ ពួកគេសួរថា: ឱអ្នកនាំសារអ្វីជាស៊ីរិកតូចនោះ គាត់ឆ្លើយថា: ការបង្ហាញឲ្យគេឃើញ(ទង្វើ)របស់ខ្លួន”។ (អ៊ីម៉ាំអះម៉ាត់ ២៣៦៣០)។.

ត្រីបសិនបើអ្នកណាម្នាក់គ្មានចេតនាគោរពសក្ការៈទៀយក្រៅព្រីប្រពឹត្តដើម្បី(បង្ហាញ) មនុស្សលោក(ឲ្យឃើញ) តែប៉ុណ្ណោះដូចជា គេសឡាតអំណាតប្ចុស៊ដើម្បី(បង្ហាញ) មនុស្សលោកពិតណាស់ទង្វើនោះគឺជាទង្វើរបស់ពួកមុណាហ្វិក ហើយវាគឺជាស៊ីរិកធំចេញពីសាសនាឥស្លាម។

### តើការស្នើសុំចំពោះមនុស្សលោកជាស៊ីរិកដែរឬទេ?

សាសនាឥស្លាមបានរំដោះមនុស្សឲ្យមានសិទ្ធិសេរីភាពពីអប្បិយជំនឿនិងជំនឿអូមអាម ហើយរំដោះខ្លួនគេអំពីការគោរពព្រហ្មណិបត្តន៍អ្នកផ្សេងក្រៅពីអល់ឡោះ។

ដូច្នេះមិនអនុញ្ញាតឲ្យឡើយការសុំការគោរពព្រហ្មណិបត្តន៍ និងការបន្ទាបខ្លួនចំពោះសាកសពឬភាវៈគ្មានជីវិតជាដាច់ខាត ហើយវាគឺជាអប្បិយជំនឿ និងជាស៊ីរិក។
រីឯការសុំពីអ្នកនៅរស់ និងមានវត្តមាននូវអ្វីៗដែលគេមានលទ្ធភាពដូចជាជំនួយ ឬការសង្គ្រោះពីការលង់ទឹក ឬការស្នើសុំអ្នកផ្សេងឲ្យសុំពីអល់ឡោះ (នូវត្រូវការរបស់គេ) វាត្រូវបានអនុញ្ញាត។





> ការស្នើសុំអ្វីពីមនុស្សដែលរស់ដែលនៅចំពោះមុខនូវអ្វីដែលគេមានសមត្ថភាពគឺជាប្រភេទមួយនៃទំនាក់ទំនងជាមួយមនុស្សនិងការសេពគប់រវាងពួកគេប្រចាំថ្ងៃដែលត្រូវបានអនុញ្ញាត

តើការស្នើសុំពីភាវៈគ្មានជីវិត ឬ អ្នកដែលបានស្លាប់បាត់ដែរឬទេ?

បាទ នេះ

ទេ:

នេះគឺជាស៊ីរិក(ធំ)ផ្ទុយពីសាសនាឥស្លាម និងជំនឿ(ដ៏ត្រឹមត្រូវ) ពីព្រោះអ្នកដែលស្លាប់ និងភាវៈគ្មានជីវិត គ្មានសមត្ថភាពស្ដាប់ឮ និងផ្ដល់តាមការសុំរបស់គេឡើយ។ ការសុំទូអាគឺជាការគោរពសក្ការៈ ហើយការថ្វាយការគោរពសក្ការៈចំពោះអ្នកណាផ្សេងក្រៅពីអល់ឡោះគឺជាស៊ីរិក។ អំពើស៊ីរិករបស់ជនជាតិអារ៉ាប់នៅសម័យអ្នកនាំសារគឺ ការសុំរបស់ពួកគេចំពោះភាវៈគ្មានជីវិត និងអ្នកដែលបានស្លាប់ទៅហើយ។

ទេ: ការស្នើសុំពីអ្នកនៅរស់ដែលស្ដាប់លឺពាក្យសំដី និងការស្នើរបស់អ្នក។ តើគេមានសមត្ថភាពអាចឆ្លើយតបនឹងការស្នើសុំរបស់អ្នកដែរឬទេ? ដូចជា ស្នើសុំពីគេឲ្យជួយអ្នកនូវអ្វីៗដែលគេមាន និងមានសមត្ថភាព?

បាទ នេះ

ទេ:

បាទ នេះគឺជាការស្នើសុំធម្មតាដែលគេអនុញ្ញាត គ្មានបញ្ហាអ្វីឡើយ វាគឺជាផ្នែកមួយអំពីការទំនាក់ទំនងរវាងមនុស្សលោកប្រចាំថ្ងៃ។

ទេ: ពិត្របាកដការស្នើសុំពីអ្នកនៅរស់នូវអ្វីៗដែលគេគ្មានសមត្ថភាព ហើយពុំមែនជាកម្មសិទ្ធិរបស់គេដូចជា អ្នកដែលគ្មានកូនសុំពីអ្នកនៅរស់ឱ្យផ្ដល់កូនចៅល្អដល់គេ ការធ្វើដូច្នេះគឺជាស៊ីរិកធំផ្ទុយពីសាសនាឥស្លាម ពីព្រោះវាគឺជាការសុំអ្នកដទៃក្រៅពីអល់ឡោះ។

## > ជំនឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់អល់ឡោះ

គឺជាជំនឿចំពោះអ្វីៗដែលអល់ឡោះបានបញ្ជាក់ស្រមាប់ទ្រង់ដោយព្រះអង្គផ្ទាល់ក្នុងគម្ពីររបស់ទ្រង់ ឬមាគ៌ារបស់អ្នកនាំសាររៃនព្រះនាម និងលក្ខណសម្បត្តិទាំងឡាយដែលសក្ដិសមនឹងទ្រង់។

ស្រមាប់អល់ឡោះគឺមានព្រះនាម និងលក្ខណៈសម្បត្តិដ៏ល្អប្រពៃ និងពេញលក្ខណៈ គ្មានអ្នកណាដូចទ្រង់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ "គ្មានអ្វីប្រដូចនឹងទ្រង់ឡើយ។ ហើយទ្រង់មហាឮមហាឃើញ "។(អាស្ហូរ៉ 11)។អល់ឡោះទ្រង់ស្អាតស្អំពីការប្រដូចព្រះនាម និងលក្ខណសម្បត្តិទាំងឡាយរបស់ទ្រង់ នឹងអ្នកណាម្នាក់នៃសភាវលោករបស់ទ្រង់។

### អំព្រីពៈនាមខ្លះៗរបស់អល់ឡោះ

អល់ឡោះបានមានបន្ទូលថាៈ "ទ្រង់ជាម្ចាស់មហាសប្បុរស មហាអាណិត្រសឡាញ់"។( អាល់ហ្វាតីហៈ ៣)។

អល់ឡោះបានមានបន្ទូលថាៈ "ហើយទ្រង់មហាឮ មហាឃើញ"។(អាស្ហូស្ហូរ៉ ១១)។

អល់ឡោះបានមានបន្ទូលថាៈ "ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត"។ (លុកម៉ាន ៩)។

អល់ឡោះបានមានបន្ទូលថាៈ "អល់ឡោះតែមួយគត់គ្មានម្ចាស់ណាដែលត្រូវគេគារពសក្ការៈដ៏ពិត្រប្រាកដផ្សេងព្រីទ្រង់ដែលមានជីវិតអមតៈគ្រប់គ្រងលើអ្វីគ្រប់យ៉ាង" ។( អាល់ហ្គាករ៉ោះ ២៥៥)។

អល់ឡោះបានមានបន្ទូលថាៈ "ការសរសើរគឺស្រមាប់អល់ឡោះដើលជាម្ចាស់នៃសកលលោកទាំងមូល"។(អាល់ហ្វាតីហៈ ២)។



## ផលប្រយោជន៍នៃជំនឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់អល់ឡោះ

1 ១ ស្គាល់អល់ឡោះ អ្នកណាជឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់ ធ្វើឲ្យគេស្គាល់ទ្រង់កាន់តែខ្លាំង ជំនឿរបស់គេចំពោះទ្រង់ក៏កាន់តែច្បាស់ ជំនឿកេទពរបស់គេចំពោះទ្រង់កាន់តែរឹងមាំ ជាការពិតស្រមាប់អ្នកដែលស្គាល់ព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់ ចិត្តគំនិតរបស់គេពោរពេញដោយការលើកតម្កើង ការស្រឡាញ់ និងប្រណិប័តន៍ចំពោះទ្រង់។

2 ២ ការកោតសរសើរស្ញប់ស្ញែងចំពោះអល់ឡោះ ដោយព្រះនាមដ៏ល្អប្រសើរជាទីបំផុតរបស់ទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ឱបណ្ដាអ្នកដែលមានជំនឿ! ចូរពួកអ្នករំឭកចំពោះអល់ឡោះឲ្យបានច្រើន"។ (អាល់អះហ្សាប ៤១)។

3 ៣ ការសុំទូអាចំពោះអល់ឡោះដោយព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ហើយបណ្ដាព្រះនាមដ៏ល្អប្រពៃពជាកម្មសិទ្ធិរបស់អល់ឡោះ។ ដូច្នេះចូរពួកអ្នកបួងសួងសុំទ្រង់តាមរយៈព្រះនាមទាំងនោះចុះ"។ (ជំពូក៧ អាល់អាក់រ៉ហ្វ វាក្យខណ្ឌទី១៨០)។ ឧទាហរណ៍ដូចជាគេពោលថាៈ ឱទ្រង់មហាប្រទានលាភសក្ការៈសូមទ្រង់បទានលាភសក្ការៈចំពោះខ្ញុំផង ឱទ្រង់មហាទទួលយកការសារភាពកំហុស សូមទ្រង់ទទួលយកផងចុះការសារភាពកំហុសរបស់ខ្ញុំ ឱទ្រង់មហាអាណិតស្រឡាញ់ សូមទ្រង់អាណិតស្រឡាញ់ចំពោះខ្ញុំផង។

## លំដាប់ខ្ពស់បំផុតនៃជំនឿ

ជំនឿមានលំដាប់ថ្នាក់របស់វា ជំនឿរបស់ អ្នកឥស្លាមមានការថយចុះតាមការព្រងើយ និងបទល្មើសរបស់គេ ហើយជំនឿរបស់គេកើនឡើងនៅរាល់ពេលដែលការប្រតិបត្តិការគោរពសក្ការៈ និងការកោតខ្លាចរបស់គេចំពោះអល់ឡោះកើនឡើង។

ហើយក្រមិតខ្ពស់បំផុតនៃជំនឿ គឺ អ្វីដែលច្បាប់បានឲ្យឈ្មោះថាៈ"អាល់អ៊ិះសាន" ណាពីបានឲ្យនិយមន័យរបស់វាគឺៈ "អ្នកត្រូវគោរពសក្ការៈចំពោះអល់ឡោះដូចអ្នកឃើញទ្រង់ ប្រសិនបើអ្នកមិនបានឃើញទ្រង់ តែបាកដណាស់ទ្រង់ពិតជាឃើញអ្នក" ។ (អាល់ពូខរី៥០ និងមូស្លីម៨)។

អ្នកនឹងឃើញ ពេលឈរ អង្គុយ ពេលម៉ត់ចត់ ពេលលេងសើច និងរាល់ស្ថានភាពរបស់អ្នក។ អល់ឡោះពិតជាដឹង និងឃើញអ្នក ដូច្នេះចូរអ្នកកុំល្មើសចំពោះទ្រង់ឲ្យសោះ អ្នកត្រូវដឹងថាទ្រង់ឃើញអ្នក។ ចូរអ្នកកុំឲ្យសេចក្ដីភ័យខ្លាច អស់សង្ឃឹមគ្របគ្រងអ្នក អ្នកត្រូវដឹងថាទ្រង់នៅជាមួយអ្នក។ តើអ្នកមានអារម្មណ៍ឯកោដូចម្ដេច បើអ្នកបួងសួងសុំទូអា និងសឡាត(ថ្វាយបង្គំ)នោះ។ តើអ្នកឱ្យចិត្តរបស់អ្នកអូសទាញអ្នកឱ្យប្រព្រឹត្តបទល្មើសដូចម្ដេច បើជឿជាក់ច្បាស់ថាទ្រង់ដឹងអាថ៌កំបាំង និងការលាត្រដាងរបស់អ្នក។ ប្រសិនបើអ្នកភ្លាត់ ឬច្រឡំធ្វើខុស អ្នកត្រូវត្រឡប់សារភាពកំហុស និងសុំអភ័យទោសព្រះទ្រង់ នោះទ្រង់នឹងទទួលយកការសារភាពកំហុស និងសុំអភ័យទោសរបស់អ្នក។





## អំពីផលប្រយោជន៍នៃជំនឿចំពោះអល់ឡោះ

1 ១ ជាការពិតណាស់អល់ឡោះការពារអ្នកដែលមានជំនឿ(ចំពោះអល់ឡោះ) ពីរាល់ប្រការដែលគេមិនពេញចិត្ត ទ្រង់ឲ្យគេជៀសផុតអំពើគ្រោះលំបាក ហើយទ្រង់ថែរក្សាគេពីឧបាយកលស្រួតូវ។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ប្រាកដណាស់អល់ឡោះនឹងការពារបណ្តាអ្នកដែលមានជំនឿ(ពីឧបាយកលរបស់ពួកដែលគ្មានជំនឿ)"។ (អាល់ហាជ្ជ ៣៨)។

2 ២ ពិត្រូបាកដជំនឿ(ចំពោះអល់ឡោះ)ជាហេតុនាំមកនូវជីវិតដ៏ល្អប្រសើរ សេចក្តីសុខ និងភាពសប្បាយរីករាយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ "អ្នកណាដែលបានសាងអំពើល្អក្នុងចំណោមបុរស ឬស្ត្រី ហើយគេជាអ្នកមានជំនឿទៀតនោះ គេយើងពិតជានឹងធ្វើឲ្យគេមានជីវិតរស់នៅដ៏ល្អប្រសើរ"។ (អាន់ណះល៍ ៩៧)។

3 ៣ ជំនឿ(ចំពោះអល់ឡោះ)ធ្វើឲ្យជីវិតរួចផុតពីជំនឿមិនត្រឹមត្រូវ។ អ្នកណាជឿចំពោះអល់ឡោះពិត្រូបាកដនោះ គេពិតជាពឹងអាស្រ័យកិច្ចការរបស់គេលើទ្រង់តែមួយ។ ទ្រង់ជាម្ចាស់នៃសកលលោកទាំងមូល ទ្រង់ជាព្រះពិតគ្មានព្រះផ្សេងទៀតឡើយ។ ដូច្នេះគេមិនត្រូវខ្លាចសភាវលោកណាឡើយ គេមិនត្រូវពឹងលើមនុស្សលោកណាម្នាក់ឡើយ។បន្ទាប់មកគេគរំដោះខ្លួនឱ្យរួចផុតពីអបិយជំនឿ និងគំនិតជឿផ្តេសផ្តាស

4 ៤ ឥទ្ធិពលដ៏ធំធេងនៃជំនឿ(ចំពោះអល់ឡោះ) គឺទទួលបានការយល់ព្រមពីអល់ឡោះ ចូលឋានសួគ៌ ភាពជោគជ័យបានពរជ័យជារៀងរហូត និងក្តីអាណិតស្រឡាញ់ដ៏ពេញលេញ។

# > ជំនឿចំពោះម៉ាឡាអ៊ីកាត់ ( ពួកទេវតា )

## អត្ថន័យនៃជំនឿចំពោះម៉ាឡាអ៊ីកាត់ ( ពួកទេវតា )

គឺជាការជឿជាក់យ៉ាងដាច់ខាតថាមានម៉ាឡាអ៊ីកាត់ ( ពួកទេវតា ) ហើយពួកគេគឺជាសភាវលោកមួយអាថ៌កំបាំង។ ពួកគេពុំមែនជាសភាវលោក្របេភទមនុស្ស និងជិននៃដរ។ ពួកគេមានភាពឧដុង្គឧត្តមក្រោតខ្លាច គោរពសក្ការៈចំពោះអល់ឡោះដ៏ពិត្របាកដ ពួកគេអនុវត្តតាមបទបញ្ជារបស្រ់ទង់ជានិច្ចដោយមិនល្មើសនឹង្រទង់ឡើយ។

អល់ឡោះ្រទង់មានបន្ទូលថា: “ផ្ទុយទៅវិញពួកេគ ( ម៉ាឡាអ៊ីកាត់ )គឺជាខ្ញុំរបស់អល់ឡោះដែល្រត្រូវគេលើកតេម្កើង។ ពួកេគមិនហ៊ាននេផ្តើមសដីមុន្រទង់ឡើយ ហើយពួកេ្រគប្រតិបត្តិតាមការបញ្ជារបស់្រទង់”។ (អាលអាំពីយ៉ាក ២៦- ២៧ )។

ជំនឿចំពោះម៉ាឡាអ៊ីកាត់ ( ពួកេទវតា )គឺជាេគាលេគ្រះមួយៃនេគាលេគ្រះជំនឿទាំង្របាំមួយ។ អល់ឡោះ្រទង់មានបន្ទូលថា: “អ្នកនាំសារ ( ណាពីមូហាំម៉ាត់ ) មានជំនឿេលើអ្វីៗដែលម្ចាស់របស់គបានបញ្ចុះមកឲ្យគេ ហើយបណ្តាអ្នកមានជំនឿក៏ដូចគ្នាដែរ។ ពួកេគទាំងអស់មានជំនឿេលើអល់ឡោះ និងបណ្តាម៉ាឡាអ៊ីកាត់របស្រ់ទង់ និងបណ្តាគម្ពីររបស្រ់ទង់ ហើយនិងបណ្តាអ្នកនាំសាររបស្រ់ទង់”។ (អាល់ហ្គាេកៅរ៉ោះ ២៨៥ )។ អ្នកនាំសារមាន្របសាសន៍ថា: “អ្នក្រត្រូវជឿចំពោះអល់ឡោះ ម៉ាឡាអ៊ីកាត ( ពួកេទវតា ) គម្ពីរអ្នកនាំសាររបស្រ់ទង់ ថ្ងៃបរេលាក ហើយអ្នក្រត្រូវជឿចំពោះ្រពះលិខិតល្អ និងអា្រក់”។ ( មូស្លីម ៨ )។

## ជំនឿចំពោះម៉ាឡាអ៊ីកាត់ ( ពួកេទវតា ) មានអ្វីខ្លះ ?

1 ជឿថាពួកេគមាន។ ដូច្នេះ្រត្រូវជឿថាពួកេគជាសភាវេលាករបស់អល់ឡោះដែលមានយ៉ាងពិតប្រាកដ ្រទង់បេង្កើតពួកេគពីពន្លឺ។ ្រទង់េធ្វើឲ្យពួកេគេគារពសក្ការៈនិង្របតិបត្តិតាម្រទង់។.

2 ២ ជឿចំពោះេឈ្មាះណាដែលេយើងបានស្គាល់ដូចជា: ជ្រីពីល និងេជឿជាលក្ខណៈរួមចំពោះេឈ្មាះណាដែលេយើងមិនបានស្គាល់។.

3 ៣ ជឿនូវអ្វីៗដែលេយើងបានដឹងៃនលក្ខណៈសម្បត្តិរបស់ពួកេគដូចជា៖:

- ពួកេគបិតេនៅក្នុងពិភពអាថ៌កំបាំងតួនាទីពួកេគគឺេគារពសក្ការៈចំពោះអល់ឡោះ ពួកេគគ្មានលក្ខណៈសម្បត្តិជា្រពះ ឬម្ចាស់េនាះេទ។ ផ្ទុយេទៅវិញពួកេគគឺជាខ្ញុំរបស់អល់ឡោះ ្របតិបត្តិតាម្រទង់យ៉ាងខ្ជាប់ខ្ជួន។ អល់ឡោះ្រទង់មានបន្ទូលថា: “ពួកេគមិនជំទាស់នឹងអល់ឡោះនូវអ្វីដែល្រទង់បានបញ្ជាដល់ពួកេគ ហើយពួកេគេធ្វើនូវអ្វីដែលអល់ឡោះបញ្ជា”។ (អាត់តះរីម ៦ )។

- ្របាកដណាស់ពួកេគបេង្កើតពួកេគពីពន្លឺ។អ្នកនាំសារមាន្របសាសន៍ថា: “េគបានបេង្កើតម៉ាឡាអ៊ីកាត់ពីពន្លឺ”។ ( មូស្លីម ២៩៩៦ )។

- ពួកេគមានស្លាប។ ពិតណាស់អល់ឡោះបាន្របាប់ថា្រទង់បានបេង្កើតម៉ាឡាអ៊ីកាត់មានចំនួនស្លាបខុសៗគ្នា។ អល់ឡោះ្រទង់មានបន្ទូលថា: “រាល់ការសរេសើរគឺ្រសាប់អល់ឡោះដែលជាអ្នកបេង្កើតេមឃជា្រេចើនជាន់ និងែផនដី ដែលជាអ្នកបេង្កើតម៉ាឡាអ៊ីកាត់ជាអ្នកនាំសារដែលមានស្លាបជា្រេចើន មានពីរ មានបី និងមានបួន។ ្រទង់បែន្ថមក្នុងការបេង្កើតនូវអ្វីដែល្រទង់មានេចតនា។ ្របាកដណាស់អល់ឡោះមានអានុភាពេលើអ្វីៗទាំងអស់”។ (ហ្វាេតៀរ ១ )។

4 ៤ ជំនឿចំពោះអ្វីដែលយើងបានដឹងពីតួនាទីរបស់ពួកគេ ដែលពួកគេបានអនុវត្តតាមបទបញ្ជារបស់អល់ឡោះដូចជា::

- អ្នកដែលមានតួនាទីទទួលវ៉ាហ៊ីពីអល់ឡោះទៅកាន់បណ្ដារ៉ស៊ូលគឺ ជ្រីពីល។.

- អ្នកដែលមានតួនាទីយកជីវិតគឺ ម៉ាឡាកុលម៉ោត។

- អ្នកដែលមានតួនាទីថែរក្សានិងកត់ត្រាអំពើល្អ និងអំពើអាក្រក់របស់ខ្ញុំរបស់អល់ឡោះគឺ អាល់គីរ៉មអាល់កាតីពូន។

## ផលប្រយោជន៍នៃជំនឿចំពោះម៉ាឡាអ៊ីកាត់

ជំនឿចំពោះម៉ាឡាអ៊ីកាត់មានផលប្រយោជន៍ដ៏ធំធេងសម្រាប់ជីវិតអ្នកដែលមានជំនឿ ដូចជា:

1 ដឹងពីឧត្តមភាពភាព មហិទ្ធិឫទ្ធិ និងអានុភាពដ៏អស្ចារ្យរបស់អល់ឡោះ។ ប្រាកដណាស់ភាពធំធេងរបស់សូភាវលោកបញ្ជាក់ឲ្យឃើញពីភាពធំធេងរបស់អល់ឡោះដែលធ្វើឲ្យអ្នកមានជំនឿកោតស្ញប់ស្ញែង និងលើកតម្កើងទ្រង់កាន់តែខ្លាំងឡើងថែមទៀត ដោយទ្រង់បានបង្កើតពីពន្លឺនូវម៉ាឡាអ៊ីកាត់ដែលមានស្លាប។.

2 ២ ការប្រកាន់ខ្ជាប់នឹងការប្រតិបត្តិតាមអល់ឡោះ។ អ្នកណាជឿថា ម៉ាឡាអ៊ីកាត់កំពុងកត់ត្រាទង្វើទាំងអស់របស់គេ ដូច្នេះគេចាំបាច់ត្រូវកោតខ្លាចអល់ឡោះ ហើយមិនប្រព្រឹត្តបទល្មើសចំពោះទ្រង់ទាំងការបើកចំហ និងអាថ៌កំបាំង។

3 ៣ ការអត់ធ្មត់លើការប្រតិបត្តិតាមអល់ឡោះ និងការមានអារម្មណ៍កក់ក្ដៅ និងស្ងប់ស្ងាត់ នៅពេលអ្នកមានជំនឿដឹងច្បាស់ថា នៅជាមួយគេក្នុងចក្រវាលដ៏ធំធេងនេះមានម៉ាឡាអ៊ីកាត់រាប់ពាន់ដែលកំពុងប្រតិបត្តិតាមអល់ឡោះយ៉ាងល្អឥតខ្ចោះ និងពេញលក្ខណៈបំផុត។

4 ៤ ការថ្លែងអំណរគុណអល់ឡោះចំពោះការថែរក្សាចំពោះមនុស្សលោក ដោយទ្រង់បានបង្កើតម៉ាឡាអ៊ីកាត់ជាអ្នកជួយថែរក្សា ការពារពួកគេ។



> រ៉ស៊ូលុលឡោះ-សល់ឡល់ឡោហ៊ូអាឡាយហ៊ីវ៉ាសាល់ឡាំ-បានប្រាប់ថាមេឃាធ្ងន់ដោយសារអ្នកដែលនៅលើមេឃ ដូច្នេះគ្មានផ្ទៃមេឃមួយចំអាមលើកលែងតែមានទេវតាមួយនៅឈរឬអោនរ៉ូកុ ឬអោនក្រាបស៊ូជូទ

# > ជំនឿចំពោះគម្ពីរ

## អត្ថន័យនៃជំនឿចំពោះគម្ពីរ

ការជឿជាក់យ៉ាងដាច់ខាតថាអល់ឡោះបានបញ្ចុះគម្ពីរមកលើបណ្តាអ្នកនាំសាររបស់ទ្រង់ទៅកាន់បណ្តាខ្ញុំរបស់ទ្រង់(មនុស្សលោក)។

ជំនឿចំពោះគម្ពីរគឺជាគោលគ្រឹះមួយនៃគោលគ្រឹះជំនឿ(ទាំងប្រាំមួយ)។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកជឿលើអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ និងគម្ពីរដែលទ្រង់បានបញ្ចុះមកលើអ្នកនាំសាររបស់ទ្រង់ ហើយនិងគម្ពីរដែលទ្រង់បានបញ្ចុះពីមុនមក”។ (អាន់នីសាក ១៣៦)

អល់ឡោះទ្រង់បានប្រើឲ្យជឿចំពោះអ្នកនាំសារ និងគម្ពីរដែលទ្រង់បានបញ្ចុះមកលើអ្នកនាំសាររបស់ទ្រង់ គឺគម្ពីរអាល់គួរអាន។ ក៏ដូចគ្នាដែរទ្រង់បានប្រើឲ្យជឿចំពោះបណ្តាគម្ពីរដែលបានបញ្ចុះមុនគម្ពីរអាល់គួរអាន។

អ្នកនាំសារមានប្រសាសន៍អំពីជំនឿថាៈ “អ្នកត្រូវជឿចំពោះអល់ឡោះ ម៉ាឡាអ៊ីកាត់របស់ទ្រង់ គម្ពីររបស់ទ្រង់ អ្នកនាំសាររបស់ទ្រង់ ថ្ងៃបរលោក និងអ្នកត្រូវជឿចំពោះព្រហ្មលិខិតល្អ អាក្រក់”។ (រាយការណ៍ដោយមូស្លីម ៨)



> គម្ពីគួរ៉ានដ៏ថ្លៃថ្នូរត្រូវបានសរសេរចប់ជាស្ថាពរដោយយោងទៅតាមការត្រួតពិនិត្យយ៉ាងល្អិតល្អន់បំផុតនិងផ្ទៀងផ្ទាត់យ៉ាងល្អឥតខ្ចោះជាទីបំផុត

### តើជំនឿចំពោះគម្ពីរមានអ្វីខ្លះ?

1. ត្រូវជឿថាការបញ្ចុះគម្ពីរគឺមកពីអល់ឡោះយ៉ាងពិតប្រាកដ។.
2. ត្រូវជឿថាគម្ពីរគឺជាពាក្យសំដីរបស់អល់ឡោះ។.
3. ត្រូវជឿចំពោះឈ្មោះគម្ពីរដែលទ្រង់បានដាក់ឈ្មោះវាដូចជា អាល់គួរអានដែលទ្រង់បានបញ្ចុះមកលើណាពីមូហាំម៉ាត់ គម្ពីរតាវរ៉ត ដែលត្រូវបានបញ្ចុះមកលើណាពីមូសា និងគម្ពីរអ៊ិនជីល(គម្ពីរប៊ីប) ដែលត្រូវបានបញ្ចុះមកលើណាពីអ៊ីសា។.
4. ត្រូវជឿចំពោះដំណឹងត្រឹមត្រូវដែលមកពីគម្ពីរទាំងនោះ។

## លក្ខណៈពិសេសនៃគម្ពីរអាល់គួរអាន

ពិតណាស់អាល់គួរអានគឺជាពាក្យបន្ទូលរបស់អល់ឡោះដែលបានបញ្ចុះមកលើណាពីរបស់យើង គឺរសូលុយឡោះមូហាំម៉ាត់( សូមពរជ័យនិងសន្តិភាពកើតមានដល់គាត់)។ ដូច្នេះអ្នកមានជំនឿត្រូវតែលើកតម្កើងគម្ពីរនេះ ហើយខិតខំប្រឹងប្រែងអនុវត្តតាមច្បាប់របស់វា សូត្រវា និងត្រិះរិះពិចារណា។.

គ្រប់គ្រាន់ហើយសម្រាប់ពួកយើងដែលមានគម្ពីរអាល់គួរអានជាត្រីវិស័យរបស់យើងនៅលើលោកិយ និងជាមូលហេតុនៃភាពជាគជ័យរបស់យើងនៅថ្ងៃបរលោក។

គម្ពីរអាល់គួរអានមានលក្ខណៈពិសេសជាងគម្ពីរមុនៗដែលបានបញ្ចុះពីលើមយដូចជា៖

1 គម្ពីរអាល់គួរអានរួមមាននៃសេចក្តីសង្ខេបនៃច្បាប់របស់ព្រះជាម្ចាស់។ ការបញ្ចុះគម្ពីរអាល់គួរអានមកនេះដើម្បីគាំទ្រ និងបញ្ជាក់ពីសច្ចភាពដែលមាននៅក្នុងគម្ពីរមុនៗនៃបទបញ្ជាឲ្យគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់។.

អល់ឡោះទ្រង់មានបន្ទូលថា: “ហើយយើងបានបញ្ចុះគម្ពីរគួរអានឲ្យអ្នកយ៉ាងពិតប្រាកដដើម្បីបញ្ជាក់ពីសច្ចភាពដែលមាននៅក្នុងគម្ពីរមុនៗ និងត្រួតពិនិត្យលើគម្ពីរទាំងនោះ” ។ (ជំពូក៥ អាល់ម៉ាអ៊ីដះ វាក្យខណ្ឌទី៤៨)

مُصَدِّقًا لِمَا بَيْنَ يَدَيْهِ مِنَ الْكِتَابِ

អត្ថន័យរបស់វាគឺស្របគ្នាជាមួយនឹងអ្វីៗដែលមាននៅក្នុងគម្ពីរមុនៗទាំងគោលជំនឿ និងដំណឹងផ្សេង។

وَمُهَيْمِنًا عَلَيْهِ

អត្ថន័យរបស់វាគឺជាសេចក្តីទុកចិត្ត និងជាសាក្សីទៅលើគម្ពីរមុនៗ។

2 ចាំបាច់លើមនុស្សទាំងអស់ដែលមានអំបូរ ជនជាតិ និងភាសាផ្សេងៗគ្នាត្រូវតែប្រកាន់ខ្ជាប់ និងប្រតិបត្តិតាមការចង្អុលបង្ហាញរបស់គម្ពីរអាល់គួរអាន ទោះបីជាពួកគេកើតនៅសម័យកាលក្រោយការបញ្ចុះគម្ពីរអាល់គួរអានក៏ដោយ។ ខុសពីគម្ពីរមុនៗដែលសម្រាប់តែក្រុមមួយជាក់លាក់ និងសម័យកាលមួយជាក់លាក់។ អល់ឡោះទ្រង់មានបន្ទូលថា: “ហើយគម្ពីរគួរអាននេះគេបានបញ្ចុះមកឲ្យខ្ញុំដើម្បីដាស់តឿនដល់ពួកអ្នក និងអ្នកដែលគម្ពីរគួរអានបាននៅទៅដល់”។ (ជំពូក៦ អាល់អាន់អាម វាក្យខណ្ឌទី១៩))

3 អល់ឡោះទ្រង់បានធានាថែរក្សាគម្ពីរនេះ។ហេតុដូច្នេះគ្មានអ្នកណាអាចកែប្រែ និងផ្លាស់ប្តូរបាននៅឡើយ។

អល់ឡោះទ្រង់មានបន្ទូលថា: “ពិតណាស់យើងបានបញ្ចុះគម្ពីរគួរអាន ហើយប្រាកដណាស់យើងជាអ្នកថែរក្សាវា”។ (ជំពូក១៥ អាល់ហិជរ៍ វាក្យខណ្ឌទី៩)

ដូច្នេះរាល់ដំណឹងរបស់វាទាំងអស់គឺសុទ្ធតែត្រឹមត្រូវ ចាំបាច់ត្រូវតែជឿតាម។



## អ្វីជាកាតព្វកិច្ចយើងចំពោះគម្ពីរអាល់គួរអានដ៏បៃពនេះ?

- ចាំបាច់លើយើងត្រូវតែត្រូវតែស្រឡាញ់ពេញចិត្ត គោរពលើកតម្កើងចំពោះគម្ពីរអាល់គួរអានព្រោះវាជាពាក្យបន្ទូលរបស់ព្រះជាម្ចាស់ដែលជាពាក្យពិត និងបវរមហាប្រសើរ។.
- ចាំបាច់លើយើងត្រូវតែសូត្រ សិក្សាយល់ដឹងនូវវាក្យខណ្ឌ និងជំពូកទាំងឡាយ ដើម្បីត្រិះរិះពិចារណាចំពោះដំបូន្មាន ដំណឹង និងរឿងរ៉ាវជំនាន់មុន ហើយយើងត្រូវមកឆ្លុះបញ្ចាំងនឹងជីវិតយើង ដើម្បីឲ្យយើងដឹងច្បាស់រវាងការពិត និងការមិនពិត។.
- ចាំបាច់លើយើងត្រូវតែអនុវត្តតាមច្បាប់ ប្រតិបត្តិតាមបទបញ្ជា និងសីលធម៌ ហើយទុកវាជាមាគ៌ានៃជីវិតរបស់យើង។.

នៅពេលគេសួរអាអ៊ីស្ហះពីអត្តចរិតរបស់ណាពី គាត់(អាអ៊ីស្ហះ) បានឆ្លើយថាៈ “អត្តចរិតរបស់គាត់(ណាហ្គីមូហាំម៉ាត់) គឺអាល់គួរអាន”។ (រាយការណ៍ដោយអះម៉ាត់២៤៦០១ និងមូស្លីម ៧៤៦)

អត្ថន័យហាទីសគឺថា អ្នកនាំសារក្នុងការរស់នៅរបស់គាត់ កិច្ចការគឺជការអនុវត្តជាក់ស្តែងស្រមាប់ច្បាប់គម្ពីរអាល់គួរអាន។ ណាពីមូហាំម៉ាត់បានសម្រេចយ៉ាងពេញលក្ខណៈក្នុងការអនុវត្តតាមការចង្អុលបង្ហាញនៃគម្ពីរអាល់គួរអាន ហើយគាត់ជាគំរូដ៏ល្អប្រសើរស្រមាប់យើងគប់ៗគ្នា។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ជាការពិតណាស់ ពួកអ្នកមានអ្នកនាំសាររបស់អល់ឡោះ(ណាហ្គីមូហាំម៉ាត់) ជាគំរូដ៏ល្អស្រមាប់អ្នកណាដែលសង្ឃឹមថានឹងបានជួបអល់ឡោះ នឹងថ្ងៃបរលោក ហើយនឹងបានរំឭកចំពោះអល់ឡោះយ៉ាងច្រើន”។ (ជំពូក៣៣ អាល់អះហ្សាប វាក្យខណ្ឌទី២១)



## អ្វីជាគោលជំហររបស់យើងចំពោះអ្វីដែលមាននៅក្នុងគម្ពីរមុនៗ?

អ្នកមូស្លីមជឿថាគម្ពីរតាវ៉ារ៉ែតដែលគេបានបញ្ចុះមកលើណាពីមូសា និងគម្ពីរអ៊ីនជីល(គម្ពីរប៊ីប) ដែលគេបានបញ្ចុះមកលើណាពីអ៊ីសាគឺជាការពិតពីអល់ឡោះ។ គម្ពីរទាំងពីរពោរពេញដោយក្រឹត្យក្រមច្បាប់ ដំបូន្មាន និងដំណឹងដែលមានសេចក្តីចង្អុលបង្ហាញ និងជាពន្លឺសម្រាប់មនុស្សលោកក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងបរមសុខនៅថ្ងៃបរលោក។.

ក៏ប៉ុន្តែអល់ឡោះទ្រង់បានប្រាប់នៅក្នុងគម្ពីរអាល់គួរអានថា ពួកម្ចាស់គម្ពីរនៃពួកយ៉ាហ៊ូទី និងណាសរ៉នីបានកែប្រែគម្ពីររបស់ពួកគេ ពួកគេបានបន្ថែម និងបន្ថយនូវអ្វីដែលមាននៅក្នុងគម្ពីរទាំងពីរនេះ។ ដូច្នេះទើបក្នុងគម្ពីរទាំងពីរត្រូវបាត់បង់នូវអ្វីដែលអល់ឡោះទ្រង់បានបញ្ចុះមក។.

គម្ពីរតាវ៉ារ៉ែតដែលមាននាបច្ចុប្បន្នគឺមិនមែនជាគម្ពីរតាវ៉ារ៉ែតដែលគេបានបញ្ចុះមកលើណាពីមូសាទេ។ ពីព្រោះពួកយ៉ាហ៊ូទីបានកែប្រែ និងផ្លាស់ប្តូរបាត់អស់ទៅហើយ។ ពួកគេបានលុបចោលជាមួយក្រឹត្យក្រមច្បាប់ជាច្រើនរបស់វា។ អល់ឡោះទ្រង់មានបន្ទូលថា: “នៅក្នុងចំណោមពួកយ៉ាហ៊ូទីមានអ្នកខ្លះកែប្រែបន្ទូលរបស់អល់ឡោះឲ្យខុសពីកន្លែងរបស់វា”។ (ជំពូក៤ អាន់នីសាក វាក្យខណ្ឌទី៤៦)

ក៏ដូចគ្នាដែរគម្ពីរអ៊ីនជីល( គម្ពីរប៊ីប) ដែលមាននាបច្ចុប្បន្នគឺមិនមែនជាគម្ពីរអ៊ីនជីល( គម្ពីរប៊ីប) ដែលគេបានបញ្ចុះមកលើណាពីអ៊ីសាទេ។ ប្រាកដណាស់ពួកណាសរ៉នីបានកែប្រែ និងផ្លាស់ប្តូរក្រឹត្យក្រមច្បាប់ជាច្រើនរបស់វា។ អល់ឡោះទ្រង់មានបន្ទូលពីពួកណាសរ៉នីថា: “ហើយប្រាកដណាស់នៅក្នុងចំណោមពួកគេ(អះលីគីតាប) គឺមានក្រុមមួយដែលកែប្រែនិងផ្លាស់ប្តូរគម្ពីរ(តាវរ៉ែត) ដើម្បីឲ្យពួកអ្នកស្មានថា វាមកពីគម្ពីរនេះ តែតាមពិតវាមិនមែនមកពីគម្ពីរទេ។ ហើយពួកគេនិយាយថា: វាមកពីអល់ឡោះ តែតាមការពិតវាមិនមែនមកពីអល់ឡោះទេ។ ហើយពួកគេគឺកំពុងតែនិយាយកុហកទៅលើអល់ឡោះ ខណៈដែលពួកគេដឹងហើយនោះ”។ (ជំពូក៣ អាលីអ៊ិមរ៉ន វាក្យខណ្ឌទី៧៨)

“ហើយយើងបានចងសន្យាជាមួយនឹងពួកអ្នកដែលបាននិយាយថា: ពួកយើងជាណាសរ៉នី តែពួកគេបានភ្លេច(បោះបង់ចោល)មួយចំណែកនៃអ្វីដែលគេបានរំឭកពួកគេ ហើយយើងបានធ្វើឲ្យពួកគេក្លាយជាសត្រូវនឹងគ្នា ស្អប់ខ្ពើមគ្នារហូតដល់ថ្ងៃបរលោក។ ហើយអល់ឡោះនឹងប្រាប់ពួកគេឲ្យដឹងនូវអ្វីដែលពួកគេបានប្រព្រឹត្តកន្លងមក”។ (ជំពូក៥ អាល់ម៉ាអ៊ីដះ វាក្យខណ្ឌទី១៤)

ហេតុនេះ ទើបយើងឃើញថា បច្ចុប្បន្ន អ្វីដែលគេហៅថាគម្ពីរពិសិដ្ឋដែលមាននៅក្នុងដៃអ្នកដែលបានទទួលគម្ពីរ(នៃពួកយ៉ាហ៊ូទី និងណាសរ៉នី) គឺគម្ពីរតាវរ៉ែត និងអ៊ីនជីល(គម្ពីរប៊ីប) ដែលពោរពេញដោយជំនឿមិនត្រឹមត្រូវ ដំណឹងមិនពិត




> អ្នកមូស្លិមជឿជាក់ថាប្រាកដណាស់តាវរ៉ែត អ៊ិញ្ជីលទាំងពីរនេះត្រូវបានបញ្ចុះមកពីអល់ឡោះ ប៉ុន្តែគម្ពីរទាំងពីរនេះត្រូវបានបញ្ចូលនូវការកែប្រែនិងផ្លាស់ប្តូរជាច្រើន ហើយយើងមិនត្រូវជឿជាក់ចំពោះវាឡើយ លើកលែងតែអ្វីដែលសមស្របនឹងអាល់គួរអាននិងសុណ្ណះ

និងការប្រឌិតរឿងកុហកជាច្រើន។ យើងមិនអាចជឿដំណឹងដែលនៅក្នុងគម្ពីរទាំងពីរនេះបានទេ លុះត្រាតែអ្វីដែលគម្ពីរអាល់គួរអាន និងសុណ្ណះបញ្ជាក់ថាជាការពិតទើបយើងអាចជឿបាន។ ហើយយើងមិនជឿនូវអ្វីដែលគម្ពីរអាល់គួរអាន និងសុណ្ណះបដិសេធចោល។

ក្រៅពីនេះយើងត្រូវនៅស្ងៀមមិននិយាយពីអ្វីផ្សេងទៀតដែលនៅសល់ ដោយយើងមិនជឿ ហើយក៏មិនបដិសេធដែរ។.

ជាមួយគ្នានេះអ្នកមូស្លីមត្រូវគោរពគម្ពីរទាំងនោះដោយមិនត្រូវមើលស្រាល និងបន្ទាបបង្អាប់ឡើយ ពីព្រោះនៅក្នុងគម្ពីរទាំងនោះមានផ្នែកខ្លះជាពាក្យបន្ទូលរបស់អល់ឡោះនៅគង់វង្សមិនបានកែប្រែ។



## ផលប្រយោជន៍នៃជំនឿចំពោះគម្ពីរ

ជំនឿចំពោះគម្ពីរមានផលប្រយោជន៍ជាច្រើនដូចជា៖:

1 យល់ដឹងពីការថែរក្សារបស់អល់ឡោះចំពោះខ្ញុំទាំងឡាយ និងករុណារបស់ទ្រង់ដ៏ពេញលេញ ដោយទ្រង់បានបញ្ជូនទៅក្រុមមនុស្សនីមួយៗនូវគម្ពីរមួយផ្សាប់ដើម្បីចង្អុលបង្ហាញផ្លូវដល់ពួកគេ និងសម្រេចនូវសុភមង្គលសម្រាប់ពួកគេនៅលើលោកិយនេះ និងនៅបរលោក។.

2 យល់ដឹងពីគតិបណ្ឌិតរបស់អល់ឡោះដែលមាននៅក្នុងច្បាប់របស់ទ្រង់ ដោយទ្រង់ដាក់ច្បាប់សម្រាប់ក្រុមមនុស្សនីមួយៗតាមអ្វីដែលសម្រួសបនឹងស្ថានភាពរបស់ពួកគេ និងល្អប្រសើរសម្រាប់បុគ្គលិកលក្ខណៈរបស់ពួកគេ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ រាល់ប្រជាជាតិនីមួយៗក្នុងចំណោមពួកអ្នក យើងបានបង្កើតច្បាប់ និងមាគ៌ាយ៉ាងច្បាស់លាស់”។ (ជំពូក៥ អាល់ម៉ាអ៊ីដះ វាក្យខណ្ឌទី៤៨))

3 ថ្លែងអំណរគុណចំពោះពរជ័យរបស់អល់ឡោះក្នុងការបញ្ចុះគម្ពីរទាំងនេះ។ ដោយគម្ពីរទាំងនេះជាពន្លឺ និងជាការចង្អុលបង្ហាញផ្លូវនៅលើលោកិយនេះ និងនៅបរលោក។ ដូច្នេះចាំបាច់ត្រូវតែថ្លែងអំណរគុណអល់ឡោះចំពោះពរជ័យដ៏ធំធេងនេះ។

## > ជំនឿចំពោះពួកអ្នកនាំសារ

### ត្រូវការរបស់មនុស្សចំពោះសារ(របស់ព្រះជាម្ចាស់)

ចាំបាច់ស្រមាប់មនុស្សត្រូវមានសា្ថរបស្រពះជាម្ចាស់បញ្ញាក្រប់បព្រឹកត្រ្យកមច្បាប់ស្រមាប់ពួកេគ និងចង្អុលបង្ហាញពួកេគេទៅរកភា្លព្រតឹម្រតូវ។ សារ(របស់អេល់ទ្បាះ)គឺជាវិញ្ញាណជីវិត និងជាពន្លឺរបស់ពិភពេលាក។ េតើពិភពេលាកមានភាពល្អប្រេសើរែដឬេទ េបើគ្មានវិញ្ញាណ ជីវិត និងពន្លឺេនាះ?

ដូច្នេះេទើបអេល់ទ្បាះទ្រង់ដាក់េឈ្មាះសាររបស្រទ់ងថាវិញ្ញាណ។ កាលេបើគ្មានវិញ្ញាណ ជីវិតក៏បាត់បង់ែដរ។ អេល់ទ្បាះទ្រង់មានបន្ទូលថា: “េហើយដូច្នោះែដរ េយើងបានបញ្ចូះវិញ្ញាណ(គម្ពីរអាល់គួរអាន) ឲ្យអ្នកតាមបទបញ្ជារបស់េយើង េដាយអ្នកមិនធ្លាប់បានដឹងថាអ្វីជាគម្ពីរ េហើយអ្នកក៏មិនដឹងថាអ្វីជាជំេនឿែដរ។ ក៏ប៉ុែន្តេយើងបានេបង្កើតវា(គម្ពីរអាលគួរអាន) ជាពន្លឺមួយែដលេយើងនឹងចង្អុលបង្ហាញតាមរយៈវាចំេពាះអ្នកណាែដលេយើងមាេនចតនាក្នុងចំេណាមខ្ញុំរបស់េយើង”។ (ជំពូក៤២ អាស៊ូស្ហូរ៉ វាក្យខណ្ឌទី៥២)

េដាយសារ ដប្រិត្រាជ្ញាស្គាល់ល្អ អាក្រក់ជាលក្ខណៈទូេទៅក៏េដាយ ែតវាមិនអាចស្គាល់លំ្អិតល្អន់និង្រគប់ជុងេជ្រាយេទ្បើយ េហើយការប្រពឹត្តិការេគារពសក្ការៈ និងរេបៀបរបស់វាមិនអាច្រប្រពឹត្តេទាបានេទ្បើយ លុះត្រាែតតាមរយៈវាហីនិងសារ(របស់អេល់ទ្បាះ)។.



ដូច្នេះគ្មានផ្លូវនាំេទារកសុភមង្គល និងភាពេជាគជ័យេនាក្នុងេលាកទាំងពីរបាេនទ្បើយ លុះត្រាែតតាមរយៈបណ្តាអ្នកនាំសារ។ េហើយគ្មានផ្លូវអាចស្គាល់ល្អអាក្រក់េដាយច្បាស់លាស់បាេនដែរ លុះត្រាែតតាមមាគ៌ារបស់ពួកេគ។ អ្នកណាងាកេចញពីសារ(របស់អេល់ទ្បាះ) អ្នកេនាះនឹងជួបឧបសគ្គចបូក្រចបល់ ព្រួយបារម្ភ និងការវេង្វងអពមង្គលតាមទំហំនបទេល្មើស និងការងាកេចញរបស់េគពីសារ(របស់អេល់ទ្បាះ)។

## គោលគ្រឹះមួយនៃគោលគ្រឹះជំនឿ

ជំនឿចំពោះអ្នកនាំសារគឺជាគោលគ្រឹះមួយនៃគោលគ្រឹះជំនឿទាំងប្រាំមួយ។ អល់ឡោះទ្រង់មានបន្ទូលថា: “អ្នកនាំសារ(ណាពីមូហាំម៉ាត់) មានជំនឿលើអ្វីៗដែលម្ចាស់របស់គេបានបញ្ចុះមកឲ្យគេ ហើយបណ្តាអ្នកមានជំនឿក៏ដូច្នោះដែរ។ ពួកគេទាំងអស់មានជំនឿលើអល់ឡោះ និងបណ្តាម៉ាឡាអ៊ីកាត់របស់ទ្រង់ និងបណ្តាគម្ពីររបស់ទ្រង់ ហើយនឹងបណ្តាអ្នកនាំសាររបស់ទ្រង់។ (ពួកគេបាននិយាយថា) ពួកយើងមិនបែងចែកអ្នកនាំសារណាម្នាក់ក្នុងចំណោមអ្នកនាំសារទាំងឡាយរបស់អល់ឡោះ”។ (ជំពូក២ អាល់ហ្ពាកោរ៉ោះ វាក្យខណ្ឌទី២៨៥) វាក្យខណ្ឌនេះបានចង្អុលបង្ហាញពីភាពចាំបាច់នៃជំនឿចំពោះបណ្តាអ្នកនាំសារទាំងអស់ដោយគ្មានការបែងចែក។ ដូច្នេះយើងមិនត្រូវជឿចំពោះអ្នកនាំសារខ្លះ ហើយបដិសធចំពោះអ្នកនាំសារខ្លះទៀតដូចទង្វើរបស់ពួកយ៉ាហ៊ូទី និងណាសរ៉និទ្បើយ។

អ្នកនាំសារមានប្រសាសន៍ពីជំនឿថា: “ អ្នកត្រូវជឿចំពោះអល់ឡោះ ម៉ាឡាអ៊ីកាត់របស់ទ្រង់ គម្ពីររបស់ទ្រង់ អ្នកនាំសាររបស់ទ្រង់ ថ្ងៃបរលោក និងអ្នកត្រូវជឿចំពោះព្រះលិខិតល្អ អាក្រក់”។ (រាយការណ៍ដោយមូស្លីម ៨)

## អត្ថន័យនៃជំនឿចំពោះពួកអ្នកនាំសារ

គឺជាការជឿជាក់យ៉ាងច្បាស់ថា អល់ឡោះទ្រង់បានបញ្ជូនទៅកាន់រាល់ៗអ៊ូម៉ាត់( ក្រុមមនុស្ស)នូវអ្នកនាំសារអំពីពួកគេ ដើម្បីអំពាវនាវពួកគេឲ្យគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ដោយគ្មានស្ហ៊ីរិកចំពោះទ្រង់។ ហើយបណ្តាអ្នកនាំសារទាំងអស់ជាអ្នកប្រកាន់សច្ចធម៌ គេជឿទុកចិត្តថាជាអ្នកប្រកាន់សច្ចធម៌កោតខ្លាច(ចំពោះអល់ឡោះ)និងទៀងត្រង់។ ពួកគេបានផ្តល់នូវអ្វីដែលអល់ឡោះបញ្ជូនមកឲ្យពួកគេដោយឥតលាក់លៀម ផ្លាស់ប្តូរ និងបន្ថែមបន្ថយតាមទំនើងចិត្តរបស់ពួកគេ សូម្បីតែមួយពាក្យ ឬមួយអក្សរក៏គ្មានដែរ។ អល់ឡោះទ្រង់មានបន្ទូលថា: “ដូច្នេះ តួនាទីរបស់បណ្តាអ្នកនាំសារគ្មានអ្វីក្រៅពីការផ្សព្វផ្សាយសារយ៉ាងច្បាស់លាស់នោះឡើយ” ។ (ជំពូក១៦ អាន់ណះល៍ វាក្យខណ្ឌទី៣៥)

## តើជំនឿចំពោះអ្នកនាំសារមានអ្វីខ្លះ?

**1** ជំនឿថាសាររបស់ពួកគេគឺជាការពិតពីអល់ឡោះ ហើយសារទាំងអស់នោះគឺអំពាវនាវទៅរកការគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ដោយគ្មានស៊ីរិកចំពោះទ្រង់។ ដូចអល់ឡោះទ្រង់មានបន្ទូលថា: “ហើយជាការពិតណាស់ រាល់ប្រជាជាតិនីមួយៗយើងបានតែងតាំងអ្នកនាំសារម្នាក់ ដោយបង្គាប់ពួកគេឲ្យគោរពសក្ការៈចំពោះអល់ឡោះ និងចៀសវាងពីតហ៊្គូត(អ្វីដែលគេគោរពសក្ការៈផ្សេងក្រៅពីអល់ឡោះ) ”។ (ជំពូក១៦ អាន់ណះល៍ វាក្យខណ្ឌទី៣៦) រីឯក្រឹត្យក្រមច្បាប់ណាពីនីមួយៗក្នុងរឿងមកធាងនៃច្បាប់ដូចជាហាឡាល់( អ្វីដែលត្រូវអនុញ្ញាត) និងហារ៉ាំ(អ្វីដែលត្រូវហាម) អាចមានចំណុចខុសគ្នាអាស្រ័យលើអ៊ូម៉ាត់( ក្រុមមនុស្ស) នីមួយៗ។ អល់ឡោះទ្រង់មានបន្ទូលថា: “ រាល់ៗប្រជាជាតិក្នុងចំណោមពួកអ្នក យើងបានបង្កើតជាច្បាប់និងមាគ៌ាយ៉ាងច្បាស់លាស់”។ (ជំពូក៥ អាល់ម៉ាអ៊ីដះ វាក្យខណ្ឌទី៤៨)

**2** ជំនឿចំពោះបណ្តាណាពី និងអ្នកនាំសារទាំងអស់គឺយើងត្រូវជឿចំពោះអ្នកណាដែលអល់ឡោះបានប្រសិទ្ធនាមឈ្មោះពួកគេដូចជា: មូហាំម៉ាត់ អ៊ីព្រហ៊ីម មូសា អ៊ីសា ណួហ។ ហើយណាពី និងអ្នកនាំសារដែលយើងមិនបានស្គាល់ឈ្មោះ យើងត្រូវជឿចំពោះពួកគេជាទូទៅ។ អ្នកណាបដិសធម្នាក់( នៃអ្នកនាំសារ) ណាមួយក្នុងចំណោមបណ្តាណាពី និងអ្នកនាំសារ អ្នកនោះពិតជាបានបដិសធពួកគេទាំងអស់គ្នា។.

**3** ការជឿយ៉ាងពិត្រាបាកដនូវអ្វីដែលត្រឹមត្រូវនៃដំណឹង និងអច្ឆរិយភាព(ភាពអស្ចារ្យដែលអល់ឡោះទ្រង់បទានឲ្យ)ពួកអ្នកនាំសារដែលមាននៅក្នុងគម្ពីរអាល់គួរអាន និងស៊ុណ្ណះ ដូចជាសមុទ្រញែកជាពីរសម្រាប់ណាពីមូសា។

**4** ការអនុវត្តតាមក្រឹត្យក្រមច្បាប់អ្នកនាំសារដែលគេបញ្ជូនមកកាន់ពួកយើង។ គាត់ជាអ្នកដែលល្អប្រសើរបំផុតក្នុងចំណោមអ្នកនាំសារទាំងអស់ និងជាអ្នកនាំសារចុងក្រោយបង្អស់គឺមូហាំម៉ាត់។

## អំពីលក្ខណសម្បត្តិអ្នកនាំសារ

| | |
|---|---|
| 1 | ពិតណាស់ពួកគេគឺជាមនុស្សលោក ហើយចំណុចខុសគ្នារវាងពួកគេនឹងមនុស្សលោកផ្សេងទៀតនោះគឺអល់ឡោះទ្រង់បានជ្រើសរើសពួកគេដោយវ៉ាហ៊ី និងសារ(របស់ទ្រង់)។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងមិនបានបញ្ជូនអ្នកណាម្នាក់មុនអ្នក(ឱមូហាំម៉ាត់) ក្រៅពីបុរសៗដែលយើងផ្តល់វ៉ាហ៊ីដល់ពួកគេនោះឡើយ”។ (ជំពូក២១ អាល់អាំពីយ៉ាក វាក្យខណ្ឌទី៧)<br>ដូច្នេះសម្រាប់ពួកគេគឺគ្មានលក្ខណៈពិសេសជាព្រះជាម្ចាស់នោះទេ។ ក៏ប៉ុន្តែពួកគេគឺជាមនុស្សលោកដែលមានលក្ខណៈរូបសម្បត្តិពេញលេញ និងចរិយាសម្បត្តិដ៏ឧត្តុង្គឧត្តម ពួកគេមានពូជអំបូរល្អជាងគេ មានប្រាជ្ញាឈ្លាសវៃការនិយាយស្ដីពាក្យពេចន៍មានវោហារ ដែលធ្វើឲ្យពួកគេមានសមត្ថភាពអាចទទួលភារកិច្ចនាំសារ(របស់អល់ឡោះ) និងប្រតិបត្តិតួនាទីជាណាពី។<br>ពិតណាស់អល់ឡោះបានបង្កើតអ្នកនាំសារពីមនុស្សលោកដើម្បីជាគំរូដល់ពួកគេ(ពីព្រោះអ្នកនាំសារជាមនុស្ស)។ ដូច្នេះការប្រតិបត្តិតាម និងការយកគំរូតាមអ្នកនាំសារគឺស្ថិតក្នុងក្រមិត និងលទ្ធភាពដែលមនុស្សលោកអាចធ្វើបាន ។ |
| 2 | អល់ឡោះទ្រង់បានជ្រើសរើសពួកគេដោយផ្តល់សារ និងវ៉ាហ៊ី(របស់ទ្រង់)ខុសពីមនុស្សលោកដទៃទៀត។ អល់ឡោះទ្រង់មានបន្ទូលថាៈ<br>“ចូរអ្នក(ឱមូហាំម៉ាត់) ពោលថាៈ តាមពិតខ្ញុំជាមនុស្សលោកដូចពួកអ្នកដែរ គ្រាន់តែគេបានផ្តល់វ៉ាហ៊ីមកឲ្យខ្ញុំថាៈ ម្ចាស់របស់ពួកអ្នកគឺជាម្ចាស់តែមួយគត់”។ (ជំពូក១៨ អាល់កះហ្វិ វាក្យខណ្ឌទី១១០)<br>ការទទួលតំណែងជាណាពី និងសារ(របស់អល់ឡោះ)ពុំមែនរកបានតាមរយៈការហាត់ពត់ភាពបរិសុទ្ធនៃវិញ្ញាណ ឬដោយប្រាជ្ញាឈ្លាសវៃ ឬដោយគំនិតកត្តាភាពនោះទេ។ តែការពិតគឺជាការជ្រើសរើសរបស់ព្រះជាម្ចាស់ អល់ឡោះបានជ្រើសរើសអ្នកនាំសារពីបណ្ដាមនុស្សលោកទាំងឡាយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “អល់ឡោះដឹងបំផុតអ្នកណាដែលទ្រង់នឹងផ្តល់សាររបស់ទ្រង់”។ (ជំពូក៦ អាល់អាន់អាម វាក្យខណ្ឌទី១២៤)។ |
| 3 | ពួកគេគ្រាបាសចាកពីកំហុសឆ្គងនូវអ្វីដែលពួកគេនាំមកពីអល់ឡោះ គ្មានការភាន់ច្រឡំក្នុងការផ្សព្វផ្សាយ និងមិនខុសឆ្គងក្នុងការប្រតិបត្តិតាមអ្វីដែលអល់ឡោះបានបញ្ចុះវ៉ាហ៊ីមកកាន់ពួកគេ។ |
| 4 | សច្ចភាព ឬស្មោះត្រង់ បណ្ដាអ្នកនាំសារទាំងអស់ជាអ្នកប្រកាន់សច្ចធម៌ទាំងពាក្យសំដី និងទង្វើរបស់ពួកគេ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “នេះគឺជាអ្វីដែលម្ចាស់មហាសប្បុរសបានសន្យា និងអ្វីដែលអ្នកនាំសារដ៏ស្មោះត្រង់បានបញ្ជាក់ប្រាប់”។ (ជំពូក៣៦ យ៉ាស៊ីន វាក្យខណ្ឌទី៥២) |
| 5 | ការអត់ធ្មត់ ពួកគេបានអំពាវនាវ(មនុស្សលោក)ទៅរកសាសនាអល់ឡោះដោយប្រាប់ដំណឹងល្អ និងដាស់តឿនពីរឿងអាក្រក់។ ពួកគេបានទទួលរងនូវការធ្វើទុកបុកម្នេញ និការលំបាកសព្វបែបយ៉ាង ពួកគេបានអត់ធ្មត់ និងស៊ូទ្រាំក្នុងការលើកតម្កើងសាសនាអល់ឡោះ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ដូច្នេះចូរអ្នក(ឱមូហាំម៉ាត់) អត់ធ្មត់ដូចបណ្ដាអ្នកដែលមានឆន្ទៈមោះមុតក្នុងចំណោមអ្នកនាំសារទាំងឡាយបានអត់ធ្មត់” ។ (ជំពូក៤៦ អាល់អះកហ្វ វាក្យខណ្ឌទី៣៥) |

## សញ្ញា និងអច្ឆរិយភាពរបស់អ្នកនាំសារ

អល់ឡោះបានគាំទ្រអ្នកនាំសារឲ្យមានភាពរឹងមាំដោយភស្តុតាង និងការចង្អុលបង្ហាញជាច្រើនបញ្ជាក់ពីសច្ចភាព និងភាពជាណាពីរបស់ពួកគេ។ ដូច្នេះការគាំទ្រចំពោះពួកគេដោយអច្ឆរិយភាព និងសញ្ញាច្បាស់លាស់ដែលមនុស្សលោកគ្មានសមត្ថភាពធ្វើបាន នោះគឺដើម្បីបញ្ជាក់ពីសច្ចភាព និងភាពជាណាពីរបស់ពួកគេ។.

អច្ឆរិយភាពគឺជាភាពអស្ចារ្យខុសពីធម្មតាដែលអល់ឡោះបានផ្តល់ចំពោះណាពី និងអ្នកនាំសារ ហើយមនុស្សលោកដទៃទៀតមិនអាចធ្វើដូចពួកគេឡើយ។

អច្ឆរិយភាពទាំងនោះមានដូចជាៈ

- ការប្រែប្រែឈើដំបងឲ្យទៅជាសត្វពស់
- ណាពីអ៊ីសាអាចប្រាប់ទៅកាន់កុមររបស់គាត់នូវចំណីដែលពួកគេនឹងបរិភោគ និងចំណីដែលពួកគេត្រូវត្រៀមទុកក្នុងផ្ទះរបស់ពួកគេ។
- ព្រះចន្ទបែកជាពីរចំណែកជាភស្តុតាងសម្រាប់ណាពីមូហាំម៉ាត់។

## ជំនឿរបស់អ្នកមូស្លីមចំពោះណាពីអ៊ីសា

1. គាត់គឺជាអ្នកនាំសារដ៏ឧត្តុង្គឧត្តម និងខ្ពង់ខ្ពស់អ្នកនាំសារម្នាក់ក្នុងចំណោមអ្នកនាំសារទាំងឡាយ ហើយគាត់គឺជាម្នាក់ក្នុងចំណោមអ្នកនាំសារដែលមានឆន្ទៈមោះមុត ពួកគេគឺ មូហាំម៉ាត់ អ៊ីព្រហ៊ីម ណួស មូសា និងអ៊ីសា។ ពួកគាត្រូវបានអល់ឡោះរំឭកក្នុងពាក្យបន្ទូលរបស់ទ្រង់ថាៈ “ហើយ(ចូរចងចាំ) នៅពេលដែលយើងបានទទួលយកពីបណ្តាណាពីនូវកិច្ចសន្យារបស់ពួកគេ និងពីអ្នក(ណាពីមូហាំម៉ាត់) និងណួហ អ៊ីព្រហ៊ីម និងមូសា ហើយនិងអ៊ីសាកូនម៉ារយ៉ាំ។ ហើយយើងបានទទួលយកកិច្ចសន្យាមួយដ៏មុឹងម៉ាត់ពីពួកគេ”។ (ជំពូក៣៣ អាល់អះហ្សាប វាក្យខណ្ឌទី៧)

2. **ពិតណាស់ណាពីអ៊ីសាគឺជាមនុស្សម្នាក់នៃកូនចៅណាពីអា**ដាំ។ អល់ឡោះបានលើកតម្កើង និងបញ្ជូនគាត់មកកាន់អំបូរអ៊ីស្រាអែល ហើយបានផ្តល់អច្ឆរិយៈភាពដល់គាត់ តែគាត់គ្មានលក្ខណៈពិសេសជាព្រះជាម្ចាស់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “គេ(ណាពីអ៊ីសា) គ្រាន់តែជាខ្ញុំម្នាក់ដែលយើងបានប្រទាននៀកម៉ាត់(អ្វីដែលអល់ឡោះប្រទានឲ្យ) ដល់គេប៉ុណ្ណោះ ហើយយើងបានយកគេធ្វើជាសញ្ញាសម្រាប់អំបូរអ៊ីស្រាអែល”។ (ជំពូក៤៣ អាហ្សហ្សុខរ៉ុហ្វ វាក្យខណ្ឌទី៥៩)

   ហើយគាត់ក៏មិនបានបញ្ជាក្រុមរបស់គាត់ឲយយកគាត់ និងមាតារបស់គាត់ជាព្រះផ្សេងក្រៅពីអល់ឡោះដែរ តែការពិតគាត់បានពោលនូវអ្វីដែលអល់ឡោះបានបញ្ជាគាត់ៈ “ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់របស់ខ្ញុំ និងជាម្ចាស់របស់ពួកអ្នក”។ (ជំពូក៥ អាល់ម៉ាអ៊ីដះ វាក្យខណ្ឌទី១១៧)

3. **ពិតណាស់ណាពីអ៊ីសាគឺជាកូ**ននាងម៉ារយ៉ាំ(ព្រះនាងម៉ារី) ដែលជាស្ត្រីដ៏ល្អគ្រប់លក្ខណ៍ ជាអ្នកប្រតិបត្តិគោរពសក្ការៈចំពោះព្រះជាម្ចាស់ ស្អាតស្អំ ព្រហ្មចារីបរិសុទ្ធ។ គាត់ពរពោះណាពីអ៊ីសាអត់មានឪពុកទេ តែដោយមហិទ្ធិឫទ្ធិរបស់អល់ឡោះ ទ្រង់បង្កើតគេដោយអច្ឆរិយភាពដ៏អស្ចារ្យ ដូចទ្រង់បានបង្កើតណាពីអាដាំអត់មានឪពុកម្តាយនោះដែរ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ពិតណាស់ការប្រៀបធៀប(ការបង្កើត) អ៊ីសាសម្រាប់អល់ឡោះដូចជា(ការបង្កើត) អាដាំដែរ គឺទ្រង់បានបង្កើតគាត់ពីដី បន្ទាប់មកទ្រង់បានមានបន្ទូលទៅកាន់គាត់ថាៈ ចូរកើតចុះ វាក៏កើតឡើងភ្លាម”។ (ជំពូក៣ អាលីអ៊ិមរ៉ន វាក្យខណ្ឌទី៥៩))

4. **ពិតណាស់គ្មានទេរយៈ**រវាងគាត់ និងមូហាំម៉ាត់អ្នកនាំសារផ្សេងទៀត។ គាត់បានប្រាប់ដំណឹងល្អពីមូហាំម៉ាត់ដូចអល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយ(ចូរចងចាំ) នៅពេលដែលអ៊ីសាកូនម៉ារយ៉ាំបានពោលថាៈ ឱអំបូរអ៊ីស្រាអែល! ពិតណាស់ ខ្ញុំជាអ្នកនាំសាររបស់អល់ឡោះមកកាន់ពួកអ្នក ដោយបញ្ជាក់ពីសច្ចភាពដែលមានមុនខ្ញុំនៅក្នុងគម្ពីរតាវរ៉ត និងផ្តល់ដំណឹង

រីករាយដល់ពួកអ្នកនូវអ្នកនាំសារម្នាក់ដែលនឹងមកដល់បន្ទាប់ពីខ្ញុំដែលគាត់មានឈ្មោះថា អះម៉ាត់ (ណាពីមូហាំម៉ាត់)។ ប៉ុន្តែនៅពេលដែលគាត់បានមកកាន់ពួកគេជាមួយនឹងភស្តុតាងដ៏ច្បាស់លាស់ជាច្រើននោះ ពួកគេបែរជានិយាយថា៖ នេះជាមន្តអាគមយ៉ាងច្បាស់លាស់” ។ (ជំពូក៦១ អាសសហ្វ វាក្យខណ្ឌទី៦)

5 យើងជឿចំពោះ៖អច្ឆរិយភាពដែលអល់ឡោះផ្តល់ចំពោះគាត់ដូចជា ការព្យាបាលជំងឺឃ្លង់ខ្វាក់ឲ្យជាសះស្បើយ ការប្រោសជីវិតស្លាប់ឲ្យរស់ឡើងវិញនិងការប្រាប់នូវអ្វីដែលមនុស្សលោកបរិភោគនិងត្រៀមទុកក្នុងផ្ទះរបស់ពួកគេ។ ទាំងអស់នេះគឺតាមការអនុញ្ញាតរបស់អល់ឡោះ ទ្រង់បង្កើតអច្ឆរិយភាពទាំងអស់នេះគឺជាភស្តុតាងយ៉ាងច្បាស់លាស់បញ្ជាក់ពីភាពពិតថាគាត់ជាណាពីនិងជាអ្នកនាំសារ។

6 អ្នកណាម្នាក់នៃមនុស្សលោកមិនទាន់មានជំនឿគ្រប់គ្រាន់ទេទាល់តែជឿថាណាពីអ៊ីសាគឺជាខ្ញុំរបស់អល់ឡោះ និងជាអ្នកនាំសាររបស់ទ្រង់។ ហើយគាត់ត្រូវបានស្អាតស្អំពីការចោទប្រកាន់របស់ពួកយ៉ាហ៊ូទីពីលក្ខណៈអាក្រក់ និងមិនពិត (ថាគាត់ជាកូនឥតខាន់ស្លា) ដែលអល់ឡោះបានផ្តល់ភាពជ្រះស្អាតពីការចោទប្រកាន់ទាំងនោះ។ ក៏ដូច្នោះដែរពួកយើងក៏ឃ្លាតឆ្ងាយពីជំនឿពួកណាសរ៉នីដែលវង្វេងមិនយល់ពីការពិតរបស់ណាពីអ៊ីសាកូននាងម៉ារយ៉ាំ (នាងម៉ារី) ដោយពួកគេបានយកគាត់និងមាតារបស់គាត់ជាព្រះផ្សេងក្រៅពីអល់ឡោះ ហើយខ្លះអំពីពួកគេថាគាត់ជាបុត្ររបស់អល់ឡោះ ខ្លះទៀតថា គាត់ជាព្រះមួយនៃព្រះទាំងបី (ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ) អល់ឡោះមហាស្អាតស្អំ (ការចោទប្រកាន់) ហួសហេតុនិងជាអំពើបាបដ៏ធ្ងន់ធ្ងរ។

7 គាត់មិនត្រូវបានគេសម្លាប់ និងឆ្កាងនោះទេ។ ផ្ទុយទៅវិញអល់ឡោះបានលើកគាត់ទៅលើមេឃនៅពេលដែលពួកយ៉ាហ៊ូទីចង់សម្លាប់គាត់ ហើយទ្រង់ធ្វើឲ្យអ្នកផ្សេងប្រែមុខមាត់ និងរូបរាងដូចគាត់ម្ល៉ោះហើយពួកគេក៏សម្លាប់ និងឆ្កាង ដោយពួកគេគិតស្មានថាម្នាក់នោះគឺជាណាពីអ៊ីសា។ អល់ឡោះទ្រង់មានបន្ទូលថា៖ “ដោយសារតែពាក្យសំដីរបស់ពួកគេថាពួកយើងបានសម្លាប់ម៉ាសៀហអ៊ីសាកូនម៉ារយ៉ាំដែលជាអ្នកនាំសាររបស់អល់ឡោះហើយពួកគេមិនបានសម្លាប់គាត់ និងមិនបានចងឆ្កាងគាត់ទេឡើយ តែទ្រង់បានបំភាន់ពួកគេដោយឱ្យបុរសម្នាក់ដូចអ៊ីសា។ ពិតណាស់ ពួកដែលបានខ្វែងយោបល់គ្នាក្នុងរឿងនេះ ស្ថិតក្នុងភាពសង្ស័យពីវា។ ពួកគេគ្មានចំណេះដឹងអ្វីក្នុងរឿងនេះក្រៅពីការស្មាននោះឡើយ។ ហើយពួកគេក៏ពុំបានសម្លាប់គាត់យ៉ាងពិតប្រាកដនោះដែរ។ ផ្ទុយទៅវិញអល់ឡោះបានលើកគាត់ (ណាពីអ៊ីសា) ទៅកាន់ទ្រង់។ ហើយអល់ឡោះមហាខ្លាំងពូកែ មហាគតិបណ្ឌិត។ មិនសេសសល់ពួកអះលីគីតាបដែលអល់ឡោះផ្តល់គម្ពីរឲ្យ លើលែងតែមានជំនឿចំពោះអ៊ីសាក្រោយពេលគាត់ចុះពីលើមេឃមុននឹងការស្លាប់របស់គាត់ ហើយនៅថ្ងៃបរលោកគាត់នឹងធ្វើសាក្សីលើពួកគេ”។ (ជំពូក៤ អាន់នីសាក វាក្យខណ្ឌទី១៥៧ -១៥៩)

8 ពិតប្រាកដណាស់ទ្រង់មហាបរិសុទ្ធបាននៅផុតពីក្បាននេះលើកគាត់ទៅកាន់ទ្រង់នៅលើមេឃ ហើយគាត់នឹងចុះមកលើផែនដីវិញនៅដំណាក់កាលចុងក្រោយ គាត់នឹងកាត់សេចក្តីតាមច្បាប់ណាពីមូហាំម៉ាត់ បន្ទាប់មកគាត់នឹងទទួលមរណភាព ហើយគេបញ្ចុះសពគាត់នៅលើផែនដី ហើយគេឲ្យគាត់រស់ឡើងវិញនៅលើផែនដីនេះផងដែរដូចអំបូរអាដាំដទៃទៀតគ្រប់ៗគ្នា យោងបន្ទូលរបស់អល់ឡោះគឺ៖ “អំពីដីនេះហើយដែលយើងបានបង្កើតពួកអ្នក ហើយយើងនឹងធ្វើឲ្យពួកអ្នកត្រឡប់ទៅជាដីវិញ (ស្លាប់) ហើយ (នៅថ្ងៃបរលោក) យើងនឹងបញ្ចេញពួកអ្នកពីវាម្តងទៀត (រស់ឡើងវិញ)”។ (ជំពូក២០ តហា វាក្យខណ្ឌទី៥៥)

## ជំនឿចំពោះមូហាំម៉ាត់ជាណាពី និងជាអ្នកនាំសារ

- **យើងជឿថាមូហាំម៉ាត់គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់អល់ឡោះ** គាត់គឺជាថៅហ្វាយមនុស្សលោកទាំងមូល តាំងពីជំនាន់មុន និងជំនាន់ក្រោយ ហើយគាត់គឺជាណាពីចុងក្រោយបង្អស់ ដោយគ្មានណាពីណាក្រោយគាត់ទៀតឡើយ។ គាត់បានផ្សព្វផ្សាយសារ ប្រតិបត្តិតួនាទីចង្អុលបង្ហាញផ្លូវដល់ប្រជាពលរដ្ឋ ហើយគាត់បានតស៊ូពុះពារក្នុងមាគ៌ារបស់អល់ឡោះយ៉ាងពិត្រប្រាកដ។
- **យើងជឿនូវអ្វីដែលគាត់ប្រាប់ ប្រតិបត្តិតាមនូវអ្វីដែល**គាត់បញ្ជា ជៀសឆ្ងាយពីអ្វីដែលគាត់ហាមឃាត់ ត្រូវគោរពសក្ការៈចំពោះអល់ឡោះឲ្យស្របតាមមាគ៌ារបស់គាត់ និងយកគំរូតាមគាត់ដោយគ្មានអ្នកផ្សេង។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ជាការពិតណាស់ ពួកអ្នកមានអ្នកនាំសាររបស់អល់ឡោះ (ណាពីមូហាំម៉ាត់) ជាគំរូដ៏ល្អសម្រាប់អ្នកដែលសង្ឃឹមថានឹងបានជួបអល់ឡោះ និងថ្ងៃបរលោក ហើយនិងបានរំឭកចំពោះអល់ឡោះយ៉ាងច្រើន"។ (ជំពូក៣៣ អាល់អះហ្សាប វាក្យខណ្ឌទី២១)
- **យើងត្រូវតែផ្តល់សេចក្តីស្រឡាញ់ចំពោះ**គាត់ជាងស្រឡាញ់ឪពុកម្តាយ កូនចៅ និងមនុស្សលោកទាំងអស់។ អ្នកនាំសារមានប្រសាសន៍ថាៈ "អ្នកណាម្នាក់ក្នុងចំណោមពួកអ្នកមិនទាន់មានជំនឿពេញលេញនៅឡើយទេ ទាល់តែគេស្រឡាញ់យើងខ្លាំងជាងឪពុកម្តាយ កូនចៅរបស់គេ និងមនុស្សលោកទាំងមូល"។ (រាយការណ៍ដោយអាល់ពូខរី១៥ និងមូស្លីម៤៤)

ហើយការស្រឡាញ់ដ៏ពិតប្រាកដនោះគឺត្រូវឲ្យប្រតិបត្តិតាមមាគ៌ារបស់គាត់ និងយកត្រាប់តាមសកម្មភាពរបស់គាត់។ ហើយសុភមង្គលដ៏ពិតប្រាកដ និងការស្វែងរកមាគ៌ាដែលត្រឹមត្រូវមិនទាន់អាចសម្រេចបានទេ លុះត្រាតែប្រតិបត្តិតាមគាត់។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ហើយប្រសិនបើពួកអ្នកគោរពប្រតិបត្តិតាមគេ (ណាពីមូហាំម៉ាត់) នោះ ពួកអ្នកនឹងទទួលបានការចង្អុលបង្ហាញជាមិនខាន។ ហើយកាតព្វកិច្ចរបស់អ្នកនាំសារគ្មានអ្វីក្រៅពីការផ្តល់សារដ៏ច្បាស់លាស់នោះឡើយ"។ (ជំពូក២៤ អាន់នូរ វាក្យខណ្ឌទី៥៤)



- **ចាំបាច់លើយើងត្រូវតែទទួលយកនូវអ្វីដែលណាពីមូហាំម៉ាត់នាំមក** ប្រកាន់ខ្ជាប់នឹងមាគ៌ារបស់គាត់ ហើយយើងត្រូវតែឲ្យតម្លៃការចង្អុលបង្ហាញរបស់គាត់ជាទីគោរពដ៏ខ្ពង់ខ្ពស់។ អល់ឡោះទ្រង់មានបន្ទូលថាៈ “សូមស្បថចំពោះម្ចាស់របស់អ្នក! ពួកគេគ្មានជំនឿទេ លុះត្រាតែពួកគេសុំឲ្យអ្នក(ណាពីមូហាំម៉ាត់) កាត់សេចក្តីនូវអ្វីដែលពួកគេបានឈ្លោះទាស់ទែងគ្នា បន្ទាប់មកពួកគេគ្មានការចែងឿតចង្អល់ក្នុងចិត្តនូវអ្វីដែលអ្នកបានកាត់សេចក្តីឡើយ ហើយទទួលយកវាដោយពេញចិត្ត”។ (ជំពូក៤ អាន់នីសាក វាក្យខណ្ឌទី៦៥)
- **ចាំបាច់លើយើងត្រូវតែប្រុងប្រយ័ត្នពីការប្រឆាំងនឹងបទបញ្ជារបស់គាត់។ ពីព្រោះ**ការប្រឆាំងនឹងបទបញ្ជារបស់គាត់ជាហេតុនាំឲ្យកើតមានគ្រោះអាសន្ន ការវង្វេង និងទារុណកម្មយ៉ាងឈឺចាប់។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ដូច្នេះចូរឲ្យពួកដែលប្រឆាំងនឹងបទបញ្ជារបស់គាត់(ណាពីមូហាំម៉ាត់) ប្រុងប្រយ័ត្នចំពោះគ្រោះអាសន្ននឹងធ្លាក់មកលើពួកគេ ឬទារុណកម្មយ៉ាងឈឺចាប់ធ្លាក់មកលើពួកគេ”។ (ជំពូក២៤ អាន់នួរ វាក្យខណ្ឌទី៦៣)

## លក្ខណៈពិសេសនៃសាររបស់ណាពីមូហាំម៉ាត់

សាររបស់ណាពីមូហាំម៉ាត់មានលក្ខណៈពិសេសជាងសារពីមុនៗដោយលក្ខណៈពិសេសមួយចំនួនដូចតទៅ៖ៈ



- **សាររបស់ណាពីមូហាំម៉ាត់ជាសារចុងក្រោយនៃសារមុនៗ។ អល់ឡោះទ្រង់មានបន្ទូលថាៈ** “ណាពីមូហាំម៉ាត់មិនមែនជាឪពុករបស់អ្នកណាម្នាក់ក្នុងចំណោមបុរសរបស់ពួកអ្នកឡើយ ក៏ប៉ុន្តែគាត់ជាអ្នកនាំសាររបស់អល់ឡោះ និងជាណាពីចុងក្រោយបង្អស់”។ (ជំពូក៣៣ អាល់អះហ្សាប វាក្យខណ្ឌទី៤០)
- សាររបស់ណាពីមូហាំម៉ាត់លុបចោលនូវសារមុនៗ ដូច្នេះអល់ឡោះមិនទទួលយកទេអ្នកណាម្នាក់កាន់សាសនាផ្សេងក្រោយពីបានបញ្ជូនណាពីមូហាំម៉ាត់ លុះត្រាតែអ្នកនោះប្រតិបត្តិតាមណាពីមូហាំម៉ាត់ (កាន់សាសនាឥស្លាម)។ ហើយក៏គ្មានអ្នកណាម្នាក់ឈានដល់ពរជ័យនៃឋានសួគ៌បានទេ លុះត្រាតែតាមរយៈមាគ៌ាគាត់។ គាត់គឺជាអ្នកនាំសារដែលល្អប្រសើរជាងគេ ប្រជាពលរដ្ឋរបស់គាត់ជាប្រជាពលរដ្ឋល្អជាងប្រជាពលរដ្ឋដទៃទៀតទាំងអស់ ហើយច្បាប់របស់គាត់មានលក្ខណៈពេញលេញជាងច្បាប់ផ្សេងៗទៀត។អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយអ្នកណាស្វែងរកសាសនាផ្សេងក្រៅពីសាសនាឥស្លាម អល់ឡោះនឹងមិនទទួលយក(ទង្វើល្អ)ពីគេឡើយ។ ហើយនៅថ្ងៃបរលោកគេនឹងស្ថិតនៅក្នុងចំណោមពួកដែលខាតបង់”។ (ជំពូក៣ អាលីអ៊ិមរ៉ន វាក្យខណ្ឌទី៨៥)

ហើយអ្នកនាំសារមានប្រសាសន៍ថាៈ “ស្បថចំពោះទ្រង់ដែលជីវិតមូហាំម៉ាត់នៅក្នុងដៃរបស់ទ្រង់ អ្នកណាម្នាក់មិនបានស្តាប់តាមយើងទោះបីជាជាតិនេះ គេជាយ៉ាហ៊ូទី ឬណាសរ៉នី ក្រោយមកគេស្លាប់ដោយមិនបានជឿចំពោះសារដែលយើងបាននាំមកនោះទេនោះ គេគឺគ្មានអ្វីក្រៅពីស្ថិតក្នុងចំណោមពួកអ្នកចុះនរកនោះឡើយ”។ (រាយការណ៍ដោយមូស្លីម១៥៣ និងអះម៉ាត់៨៦០៩)

- សាររបស់ណាពីមូហាំម៉ាត់ជាសារទូទៅនាំទៅកាន់ក្រុមជិន និងមនុស្សលោក។ អល់ឡោះទ្រង់មានបន្ទូលលើកឡើងអំពីពាក្យសំដីរបស់ជិនថាៈ “ឱក្រុមរបស់ពួកយើង(ជិន)! ចូរពួកអ្នកឆ្លើយតបចំពោះអ្នកអំពាវនាវរបស់អល់ឡោះ(ណាពីមូហាំម៉ាត់) និងមានជំនឿចំពោះគេចុះ”។ (ជំពូក៤៦ អាល់អះកហ្វ វាក្យខណ្ឌទី៣១)

អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងមិនបានបញ្ជូនអ្នក(ណាពីមូហាំម៉ាត់) លើកលែងតែទៅកាន់មនុស្សលោកទូទៅ ដើម្បីផ្តល់ដំណឹងរីករាយ និងជាសេចក្តីដាស់តឿនឱ្យប្រុងប្រយ័ត្នពីទារុណកម្ម”។ (ជំពូក៣៤ សាហ្ពាក វាក្យខណ្ឌទី២៨)

ហើយអ្នកនាំសារមានប្រសាសន៍ថាៈគេផ្តល់ភាពល្អប្រសើរដល់ខ្ញុំជាងបណ្តាណាពីដទៃទៀតនូវប្រាំមួយប្រការៈ ១ គេផ្តល់ឲ្យខ្ញុំនូវពាក្យសំដីខ្លីខ្លឹម ២ គេឲ្យខ្ញុំឈ្នះ(ស្រតូវ) ដោយភាពភ័យខ្លាច(ក្នុងចិត្តសត្រូវ) ៣ គេអនុញ្ញាតស្រមាប់ខ្ញុំនូវទ្រព្យជ័យភណ្ឌ ៤ គេចាត់ទុកដីជាវត្ថុសម្អាតនិងជាម៉ាស្ជិទ(សឡាត)ស្រមាប់ខ្ញុំ ៥ គេបញ្ជូនខ្ញុំទៅកាន់មនុស្សលោកទាំងអស់ ៦ គេបញ្ចប់ការបញ្ជូនបណ្តាណាពីចុងក្រោយដោយខ្ញុំ”។ (រាយការណ៍ដោយអាលពូខរី២៨១៥ និងមូស្លីម៥២៣)

# ផលប្រយោជន៍នៃជំនឿចំពោះអ្នកនាំសារ

ស្រមាប់ជំនឿចំពោះអ្នកនាំសារមានផលប្រយោជន៍ច្រើនអនេកដូចជា៖

1 យល់ដឹងអំពីក្តីអាណិត្រសឡាញ់ និងការថែរក្សារបស់អល់ឡោះចំពោះខ្ញុំរបស់ទ្រង់ ដោយទ្រង់បានបញ្ជូនអ្នកនាំសារទៅកាន់ពួកគេដើម្បីចង្អុលបង្ហាញផ្លូវត្រឹមត្រូវ និងបញ្ជាក់ប្រាប់ពួកគេនូវរបៀបគោរពសក្ការៈចំពោះអល់ឡោះ។ ពីព្រោះប្រាជ្ញារបស់មនុស្សលោកមិនអាចដឹងដោយឯកឯងបាននូវរឿងទាំងនេះ។ អល់ឡោះទ្រង់មានបន្ទូលពីណាពីមូហាំម៉ាត់ថាៈ "ហើយយើងមិនបានបញ្ជូនអ្នក(ណាពីមូហាំម៉ាត់)ឡើយ លើកលែងតែដើម្បីផ្តល់ក្តីមេត្តាករុណាចំពោះពិភពលោកទាំងមូល"។ (ជំពូក២១ អាល់អាំពីយ៉ាក វាក្យខណ្ឌទី១០៧)

2 ថ្លែងអំណរគុណអល់ឡោះចំពោះពរជ័យដ៏ធំធេងនេះ។.

3 ស្រឡាញ់ លើកតម្កើង និងកោតសរសើរបណ្តាអ្នកនាំសារឱ្យបានសក្តិសមនឹងពួកគេ។ ពីព្រោះពួកគេបានប្រតិបត្តិការគោរពសក្ការៈចំពោះអល់ឡោះ ផ្សព្វផ្សាយសាររបស់ទ្រង់ និងជាសេចក្តីជឿនខ្ញុំរបស់ទ្រង់។.

4 ការប្រតិបត្តិតាមសារដែលអ្នកនាំសារបាននាំមកពីអល់ឡោះនោះគឺ ការគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ដោយគ្មានស្ទាក់ស្ទើរចំពោះទ្រង់ និងការអនុវត្តតាមសារ ដូច្នេះវានឹងសម្រេចបាននូវស្រមាប់អ្នកមានជំនឿនូវសេចក្តីល្អប្រសើរ ការចង្អុលបង្ហាញផ្លូវ និងសុភមង្គលក្នុងជីវិតរបស់ពួកគេនៅលើលោកទាំងពីរ។

អល់ឡោះទ្រង់មានបន្ទូលថាៈ "អ្នកណាដែលបានដើរតាមការចង្អុលបង្ហាញរបស់យើងនោះ គេគឺមិនវង្វេង(នៅក្នុងលោកិយ) និងមិនលំបាកឡើយ(នៅថ្ងៃបរលោក)។ តែបើអ្នកណាហើយបានងាកចេញពីការដាស់តឿន(គម្ពីរអាល់គួរអាន) របស់យើង ពិតណាស់ស្រមាប់គេគឺការរស់នៅយ៉ាងលំបាកវេទនា( ទោះបីជារូបភាពខាងក្រៅរបស់គេជាអ្នកមាន ឬមានឋានៈខ្ពង់ខ្ពស់ក៏ដោយ)"។ (ជំពូក២០ តហា វាក្យខណ្ឌទី១២៣-១២៤)



> វិហារ អាល់អ៊ីកសា សម្រាប់ពួកមូស្លីមមានឋានៈគឺមានលំដាប់ថ្នាក់ទីពីរបន្ទាប់ពីវិហារដែលត្រូវបានសាងនៅលើផែនដីបន្ទាប់ពីវិហារ ហារ៉ាមដែលនៅម៉ឹកកៈ ហើយប្រាកដណាស់រ៉ស៊ូលុលឡោះសល់ឡល់ឡោហ៊ូអាឡាយហ៊ីវ៉ាសាល់ឡាំនិងពួកណាពីៗផ្សេងទៀតបានថ្វាយបង្គំនៅក្នុងវិហារអ៊ីកសានោះ។

## > ជំនឿចំពោះថ្ងៃបរលោក

### អត្ថន័យនៃជំនឿចំពោះថ្ងៃបរលោក

គឺជាការជឿជាក់យ៉ាងច្បាស់លាស់ថាអល់ឡោះនឹងធ្វើឲ្យអ្នកដែលនៅក្នុងផ្នូរទាំងអស់រស់ឡើងវិញ បន្ទាប់មកទ្រង់ជំនុំជំរះពួកគេ និងតបស្នងចំពោះពួកគេតាមទង្វើរបស់ពួកគេ ដើម្បីឲ្យបណ្តាអ្នកឋានសួគ៌ស្ថិតនៅទីកន្លែងរបស់ពួកគេ និងពួកឋាននរកស្ថិតនៅទីកន្លែងរបស់ពួកគេ។

ជំនឿចំពោះថ្ងៃបរលោកជាគោលគ្រឹះមួយនៃគោលគ្រឹះជំនឿទាំងប្រាំមួយ ដូច្នេះជំនឿមិនត្រឹមត្រូវទេ លុះត្រាតែមានជំនឿចំពោះថ្ងៃបរលោក។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ប៉ុន្តែអំពើល្អនោះគឺអ្នកណាដែលមានជំនឿលើអល់ឡោះ និងថ្ងៃបរលោក”។ (ជំពូក២ អាល់ហ្ពាកោរ៉ោះ វាក្យខណ្ឌទី១៧៧)

### ហេតុអ្វីបានជាគម្ពីរអាល់គួរអានបញ្ជាក់យ៉ាងច្បាស់ពីជំនឿចំពោះថ្ងៃបរលោក?

គម្ពីរអាល់គួរអានបញ្ជាក់យ៉ាងច្បាស់ពីជំនឿចំពោះថ្ងៃបរលោក និងបាននិយាយរំឭកចំពោះថ្ងៃបរលោកជារឿយៗ ហើយបញ្ជាក់យ៉ាងច្បាស់លាស់ថាវានឹងកើតឡើង ដោយប្រើសំនួនភាសាអារ៉ាប់ផ្សេងៗគ្នា។ គម្ពីរអាល់គួរអានក៏បានផ្សារភ្ជាប់ជំនឿចំពោះថ្ងៃបរលោក និងជំនឿចំពោះអល់ឡោះនៅកន្លែងជាច្រើនក្នុងគម្ពីរនេះ។

ពីព្រោះជំនឿចំពោះថ្ងៃបរលោកជាហេតុផលនាំឲ្យជឿចំពោះអល់ឡោះ និងភាពយុត្តិធម៌របស់ទ្រង់ដែលមហាបរិសុទ្ធ។ ដើម្បីបញ្ជាក់ពីរឿងនេះគឺ៖

អល់ឡោះមិនទទួលស្គាល់អំពើអយុត្តិធម៌ ហើយមិនទុកពួកអ្នកបំពានរួចខ្លួន មិនទុកឲ្យជនរងគ្រោះដោយគ្មានភាពយុត្តិធម៌ និងមិនបោះបង់អ្នកសាងទង្វើកុសលដោយគ្មានផលបុណ្យតបស្នងនោះដែរ ហើយទ្រង់នឹងផ្តល់ឲ្យគ្រប់គ្នាទទួលបានសិទ្ធិរបស់ខ្លួន។ យើងឃើញហើយថាជីវិតនៅលើលោកិយមានអ្នកដែលរស់នៅប្រព្រឹត្តអំពើអយុត្តិធម៌ ស្លាប់ទៅក្នុងនាមជាអ្នកជាប្រព្រឹត្តអំពើអយុត្តិធម៌ ហើយមិនទាន់បានទទួលការដាក់ទោសរីឯខ្លះទៀតរស់នៅជាជនរងគ្រោះ ស្លាប់ដោយអយុត្តិធម៌មិនទាន់ទទួលបានសិទ្ធិរបស់ខ្លួននៅឡើយ បើដូច្នោះមែនតើពាក្យថាអល់ឡោះមិនទទួលយកអំពើអយុត្តិធម៌មានន័យដូចម្តេចដែរ? អត្ថន័យរបស់វាគឺ ត្រូវតែមានជីវិតមួយទៀតបន្ទាប់ពីជីវិតដែលយើងកំពុងរស់នៅ(លើលោកិយ) ត្រូវតែមានពេលវេលាផ្សេងទៀតដែលគេនឹងតបស្នងអ្នកសាងអំពើកុសល និងធ្វើទារុណកម្មអ្នកសាងអំពើអកុសល ហើយគ្រប់ៗគ្នាដែលមានសិទ្ធិនឹងទទួលបានសិទ្ធិរបស់ខ្លួនវិញ។

> សាសនាឥស្លាមអប់រំមនុស្សយើងទៅរកការឃ្លាតឆ្ងាយអំពីភ្លើងនរក ដោយធ្វើល្អទៅចំពោះអ្នកដទៃទោះជារឿងនោះដោយការបរិចាកមួយចំហៀងផ្លែល្មើ។



## តើជំនឿចំពោះថ្ងៃបរលោកមានអ្វីខ្លះ ?

ជំនឿរបស់អ្នកមូស្លីមចំពោះថ្ងៃបរលោកមានប៉ុន្មានប្រការដូចជា៖:

1 **ជំនឿចំពោះ**ការរស់ឡើងវិញនិងនិងការប្រមូលមនុស្សទាំងអស់: វាគឺជាការធ្វើឲ្យអ្នកស្លាប់នៅក្នុងផ្នូរទាំងអស់រស់ឡើងវិញ វិញ្ញាណរបស់ពួកគេត្រឡប់ទៅរកខ្លួនប្រាណពួកគេវិញ។ មនុស្សលោកទាំងអស់ក្រោកឡើងទៅកាន់ម្ចាស់នៃសកលទាំងមូល បន្ទាប់មកគេប្រមូលផ្តុំពួកគេនៅទីកន្លែងតែមួយ ពួកគេគ្មានស្បែកជើង និងស្លៀកពាក់ដូចគេបានបង្កើតពួកគេចេញពីពោះម្តាយរបស់ពួកគេកាលពីដំបូងនោះដែរ។.

ជំនឿថាអ្នកដែលនៅក្នុងផ្នូរទាំងអស់រស់ឡើងវិញគឺជាអ្វីដែលគម្ពីរអាល់គួរអានម្ចាស់ណាពីមូហាំម៉ាត់ សតិបញ្ញា និងនិស្ស័យពីកំណើតបានបញ្ជាក់ជាភស្តុតាង។ ហើយយើងជឿយ៉ាងច្បាស់ថាអល់ឡោះនឹងធ្វើឲ្យអ្នកដែលនៅក្នុងផ្នូរទាំងអស់រស់ឡើងវិញ វិញ្ញាណនឹងត្រឡប់ទៅរកខ្លួនប្រាណពួកគេវិញ មនុស្សលោកទាំងអស់ក្រោកឡើងទៅកាន់ម្ចាស់នៃសកលលោកទាំងមូល។

អល់ឡោះទ្រង់មានបន្ទូលថា: “បន្ទាប់មកពួកអ្នកពិតជាស្លាប់ក្រោយពេលដល់អាយុត្រូវស្លាប់)។ បន្ទាប់មកពួកអ្នកពិតជានឹងត្រូវរស់ឡើងវិញនៅថ្ងៃបរលោក”។ (ជំពូក២៣ អាល់មុមីនូន វាក្យខណ្ឌទី១៥- ១៦)

បណ្តាគម្ពីរទាំងអស់ដែលគេបញ្ចុះពីលើមេឃបានឯកភាពគ្នាចំពោះរឿងនេះ។ ព្រោះវាជាការចាំបាច់បំផុតនៃគតិបណ្ឌិតគឺ: ចាំបាច់ណាស់អល់ឡោះត្រូវតែបង្កើតស្រមាប់សភាវលោកទាំងអស់នូវការវិលត្រឡប់( មានជីវិតសាជាថ្មី) ដើម្បីតបស្នងពួកគេនូវរាល់អ្វីដែលទ្រង់ត្រូវឲ្យពួកគេគោរពប្រតិបត្តិតាមរយៈបណ្តាអ្នកនាំសាររបស់ទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថា: “តើពួកអ្នកគិតថា យើងបានបង្កើតពួកអ្នកគ្រាន់តែជាការលេងសើច ហើយពួកអ្នកពិតជាមិនត្រូវវិលត្រឡប់មកជួបយើងវិញ( ដើម្បីជំនុំជម្រះ) ទេឬ?”។ (ជំពូក២៣ អាល់មុមីនូន វាក្យខណ្ឌទី១១៥)

## អំពីភស្តុតាងនៃគម្ពីរអាល់គួរអានបញ្ជាក់ថាមនុស្សក្នុងផ្នូរទាំងអស់រស់ឡើងវិញគឺ

• ពិតណាស់អល់ឡោះបង្កើតមនុស្សលោកតាំងពីដំបូង។ អ្នកដែលមានអានុភាពបង្កើតមនុស្សលោកពីដំបូងបាន ពិតណាស់នឹងមានសមត្ថភាពបង្កើតមនុស្សលោកសាជាថ្មីម្តងទៀត។ អល់ឡោះទ្រង់មានបន្ទូលថា: “ហើយទ្រង់ជាអ្នកចាប់ផ្តើមបង្កើតមនុស្សលោក បន្ទាប់មកទ្រង់នឹងបង្កើតវាសាជាថ្មីម្តងទៀត(នៅថ្ងៃបរលោក)”។ (ជំពូក៣០ អើររ៉ូម វាក្យខណ្ឌទី២៧)

អល់ឡោះទ្រង់មានបន្ទូលបញ្ជាឲ្យឆ្លើយតបនឹងពួកអ្នកដែលបដិសេធនឹងការធ្វើឲ្យឆ្អឹងរស់ឡើងវិញខណៈដែលវាបានពុកផុយហើយនោះថា: “ចូរអ្នក(ណាពីមូហាំម៉ាត់) ពោលថា: អ្នកដែលធ្វើឲ្យវារស់ឡើងវិញនោះ គឺអ្នកដែលបានបង្កើតវាពីដំបូងនោះហើយ។ ទ្រង់ដឹងបំផុតនូវអ្វីដែលទ្រង់បានបង្កើត”។ (ជំពូក៣៦ យ៉ាស៊ីន វាក្យខណ្ឌទី៧៩)



- ពិត្រប្រាកដដីដែលស្ងួតហួតហែងគ្មានរុក្ខជាតិពណ៌បៃតង នៅពេលភ្លៀងធ្លាក់វាក៏មានជីវិតពណ៌បៃតងរស់(ដុះ)ឡើងវិញនូវរុក្ខជាតិគប់ប្រភេទយ៉ាងស្រស់ស្រពោង។ អ្នកដែលមានអានុភាពអាចធ្វើឲ្យវារស់(រុក្ខជាតិដុះ)ឡើងវិញក្រោយពីវាបានស្លាប់(គ្មានរុក្ខជាតិដុះ) ពិតជាមានអានុភាពធ្វើឲ្យអ្នកស្លាប់រស់ឡើងវិញ។ អល់ឡោះទ្រង់មានបន្ទូលថា: "ហើយយើងបានបញ្ចុះទឹកភ្លៀងដែលមានពរជ័យពីលើមេឃ រួចយើងបានបណ្ដុះចេញពីវានូវចំការដំណាំជាច្រើន និងប្រភេទធញ្ញជាតិដែលអាចច្រូតកាត់(ប្រមូលផល)បាន និងដើមល្មើខ្ពស់ស្កឹមស្កៃដែលមានផ្លែផ្លែស្អកស្កុះជាជួរ។ ជាលាភសក្ការៈសម្រាប់ខ្ញុំរបស់អល់ឡោះ។ ហើយយើងបានធ្វើឲ្យដីដែលស្លាប់(គ្មានជីជាតិ) មានជីវិត(មានជីជាតិ) ឡើងវិញដោយសារវា(ទឹកភ្លៀង)។ ដូច្នោះដែរ យើងបានធ្វើឲ្យពួកអ្នករស់ឡើងវិញ(នៅថ្ងៃបរលោក)"។ (ជំពូក៥០ កហ្វ វាក្យខណ្ឌទី៩-១១)

- រាល់អ្នកដែលមានសតិបញ្ញាដឹងថាអ្នកដែលមានសមត្ថភាព ឬអានុភាពលើកិច្ចការដ៏ធំធេងនោះ ពិតណាស់ចំពោះកិច្ចការតូចតាចវិញនោះវាងាយជាទីបំផុត។ អល់ឡោះទ្រង់បង្កើតមេឃ ដី និងច្រកវាលជាកិច្ចការធំធេង និងវិសាលភាពរបស់វា ហើយភាពអស្ចារ្យនៃទម្រង់ទាយរបស់វា។ ទ្រង់ពិតជាមានអានុភាពអាចធ្វើឲ្យឆ្អឹងដែលពុកផុយទៅហើយនោះរស់ឡើងវិញ។ អល់ឡោះទ្រង់មានបន្ទូលថា: "តើអ្នកដែលបង្កើតមេឃជាច្រើនជាន់ និងផែនដីមិនមែនជាអ្នកដែលមានសមត្ថភាពបង្កើតឲ្យដូចពួកគេទេឬ? ផ្ទុយទៅវិញ ទ្រង់ជាអ្នកមានអានុភាពបង្កើតទ្រង់មហាដឹង"។ (ជំពូក៣៦ យ៉ាស៊ីន វាក្យខណ្ឌទី៨១)

## 2

ជំនឿចំពោះការជំនុំជម្រះ និងជញ្ជីង(ថ្លឹងទង្វើរបស់មនុស្សលោក)គឺ: អល់ឡោះនឹងជំនុំជម្រះទង្វើដែលគេបានប្រព្រឹត្តក្នុងជីវិតនៅលោកិយនេះ។ អ្នកណាដែលឋិតក្នុងចំណោមអ្នកដែលគោរព សក្ការៈអល់ឡោះតែមួយគត់ ហើយប្រតិបត្តិតាមទ្រង់និងអ្នកនាំសាររបស់ទ្រង់នោះ ការជំនុំជម្រះសម្រាប់គេគឺងាយស្រួល ហើយអ្នកណានៅក្នុងចំណោមអ្នកដែលស៊ីរិក និងប្រព្រឹត្តបាបកម្មជាការពិតណាស់ការជំនុំជម្រះសម្រាប់គេគឺពិបាកជាទីបំផុត។.

គេនឹងថ្លឹងទង្វើនៅលើជញ្ជីងដ៏ធំមួយ គេក៏ដាក់អំពើកុសលនៅផ្នែកម្ខាងនៃជញ្ជីង និងអំពើអកុសលនៅផ្នែកម្ខាងទៀតនៃជញ្ជីង។ អ្នកណាដែលធ្ងន់ភ្នកជញ្ជីងអំពើកុសលរបស់គេធ្ងន់ជាងអំពើអកុសល គេនឹងស្ថិតនៅក្នុងចំណោមអ្នកឋានសួគ៌ ហើយអ្នកណាដែលធ្ងន់ភ្នកជញ្ជីងអំពើអកុសលរបស់គេធ្ងន់ជាងអំពើកុសល គេនឹងស្ថិតនៅក្នុងចំណោមអ្នកឋាននរក។ ម្ចាស់របស់អ្នកទ្រង់មិនបានបំពានលើអ្នកណាម្នាក់ឡើយ។.

អល់ឡោះទ្រង់មានបន្ទូលថា: "ហើយយើងនឹងដាក់ជញ្ជីងយុត្តិធម៌នៅថ្ងៃបរលោក។ ដូច្នេះជីវិតគប់រូបនឹងមិនត្រូវគេបំបាត់អ្វី(ទង្វើរបស់គេ) បន្តិចឡើយ។ ហើយសូម្បីវាមានទម្ងន់ប៉ុនគ្រាប់ល្ង ក៏យើងនាំវា(អំពើល្អ និងអំពើអាក្រក់)មកដែរ។ គ្រប់គ្រាន់ហើយយើងជាអ្នកជំនុំជម្រះ"។ (ជំពូក២១ អាល់អាំពីយ៉ាក វាក្យខណ្ឌទី៤៧)

## 3

ឋានសួគ៌ និងឋាននរក ឋាននសួគ៌គឺជាទីកន្លែងមានពរជ័យជាអមតៈ។ អល់ឡោះទ្រង់បានរៀបចំវាសម្រាប់អ្នកដែលកោតខ្លាចទ្រង់ គោរពប្រតិបត្តិតាមទ្រង់និងអ្នកនាំសាររបស់ទ្រង់។ នៅក្នុងឋានសួគ៌មានពរជ័យសព្វបែបយ៉ាងដែលឋិតថេរជារៀងរហូត មានអ្វីៗទាំងអស់តាមចំណង់ចំណូលចិត្ត រីករាយជាទីបំផុតដោយអ្វីៗដែលខ្លួនពេញចិត្តគឺមានទាំងអស់។.

អល់ឡោះទ្រង់មានបន្ទូលទាក់ទាញខ្ញុំរបស់ទ្រង់ដើម្បីប្រញាប់ប្រញាល់ទៅកាន់ការគោរពប្រតិបត្តិតាម និងទៅកាន់ឋានសួគ៌ដ៏ធំល្វឹងល្វើយគឺទំហំរបស់វាដូចទំហំមេឃជាច្រើនជាន់និងផែនដីថា: "ហើយចូរពួកអ្នកប្រញាប់ប្រញាល់ទៅរកការអភ័យទោស និងទៅរកឋានសួគ៌ដែលទំហំរបស់វាដូចទំហំមេឃជាច្រើនជាន់ និងផែនដីដែលគេបានរៀបចំវាសម្រាប់បណ្ដាអ្នកដែលកោតខ្លាច"។ (ជំពូក៣ អាលីអ៊ិមរ៉ន វាក្យខណ្ឌទី១៣៣)

រីឯឋាននរកវិញជាទីកន្លែងទារុណកម្មជារៀងរហូតគ្មានទីបញ្ចប់។ អល់ឡោះទ្រង់បានរៀបចំវាសម្រាប់អ្នកប្រឆាំង ដែលប្រឆាំងចំពោះអល់ឡោះ និងល្មើសចំពោះអ្នកនាំសាររបស់ទ្រង់។ នៅក្នុងឋាននរកមានទារុណកម្ម និងការឈឺផ្សាជាទីបំផុតដែលជារឿងនឹកស្មានមិនដល់។ អល់ឡោះទ្រង់មានបន្ទូលជាការព្រមានខ្ញុំរបស់ទ្រង់អំពីឋាននរកដែលទ្រង់បានរៀបចំវាសម្រាប់អ្នកប្រឆាំងថា: “ដូច្នេះ ចូរពួកអ្នកខ្លាចភ្លើងនរកដែលឥន្ធនៈរបស់វាគឺមនុស្ស និងដុំថ្មដែលគេបានរៀបចំសម្រាប់ពួកដែលប្រឆាំង”។ (ជំពូក២ អាល់ហ្គាកេរ៉ោះ វាក្យខណ្ឌទី២៤)

ឱអល់ឡោះពិតណាស់ពួកយើងសុំទៅកាន់ទ្រង់នូវឋានសួគ៌ និងអ្វីដែលនាំឲ្យខិតជិតឋានសួគ៌ទាំងពាក្យសំដីនិងទង្វើ។ យើងក៏សុំពីទ្រង់ឲ្យចៀសផុតពីឋាននរក និងពីអ្វីដែលនាំឲ្យខិតជិតឋាននរកទាំងពាក្យសំដី និងទង្វើ។

## 4 ទារុណកម្ម និងពរជ័យនៅក្នុងផ្នូរ:

យើងជឿថាការស្លាប់គឺជាការពិត។ អល់ឡោះទ្រង់មានបន្ទូលថា: “ចូរអ្នក( ណាពីមូហាំម៉ាត់) ពោលថា: ម៉ាឡាអ៊ីកាត់យកជីវិតមនុស្សដែលត្រូវគេបញ្ជូនទៅកាន់ពួកអ្នក និងយកជីវិតពួកអ្នក។ បន្ទាប់មកពួកអ្នកត្រូវវិលត្រឡប់ទៅកាន់ម្ចាស់របស់ពួកអ្នកវិញ”។ (ជំពូក៣២ អាស់សាជដះ វាក្យខណ្ឌទី១១)

វាគឺជារឿងឃើញច្បាស់ផ្ទាល់នឹងភ្នែកគ្មានការសង្ស័យឡើយ។ យើងជឿថារាល់អ្នកដែលស្លាប់ ឬត្រូវគេសម្លាប់ ឬដោយមូលហេតុអ្វីក៏ដោយ វាគឺជាទីបញ្ចប់នៃជីវិតរបស់គេ។ ជាការពិតណាស់ វាគឺជាពេលកំណត់របស់គេដែលមកដល់គ្មានការផ្លាស់ប្តូរអ្វីឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “ដូច្នេះ នៅពេលដែលការកំណត់ជីវិតរបស់ពួកគេបានមកដល់ ពួកគេមិនអាចសុំពន្យារពេល ឬសុំមុនពេលកំណត់បានឡើយ សូម្បីមួយវិនាទីក៏ដោយ”។ (ជំពូក៧ អាល់អាក់រ៉ហ្វ វាក្យខណ្ឌទី៣៤)

- អ្នកណាស្លាប់ ពិតប្រាកដថាបរលោករបស់គេបានមកដល់គេហើយ ហើយគេក៏ផ្លាស់ទៅកាន់ទីកន្លែងបរលោក។.
- មានហាទីសជាច្រើនពីអ្នកនាំសារបញ្ជាក់ពីទារុណកម្មនៅក្នុងផ្នូរចំពោះអ្នកប្រឆាំង អ្នកល្មើស ហើយពរជ័យជាច្រើនសម្រាប់អ្នកមានជំនឿ និងអ្នកសាងអំពើកុសល។ ហើយយើងជឿលើរឿងដូច្នោះ ដោយយើងមិនបាច់លម្អិតចំពោះលក្ខណៈរបស់វាឡើយ។ ពីព្រោះគំនិតបញ្ញាគ្មានលទ្ធភាពអាចដឹងលក្ខណៈ និងភាពពិតរបស់វាបានឡើយ ដោយសារវាស្ថិតក្នុងភាពអាថ៌កំបាំងដូចជាឋានសួគ៌ និងឋាននរក គឺវាមិនបាននៅក្នុងដែនដែលយើងអាចមើលឃើញ។ លទ្ធភាពគំនិតបញ្ញាអាចវាស់វែងដោយការប្រៀបធៀបប្រមាណ សន្និដ្ឋាន និងការវិនិច្ឆ័យតាមអ្វីដែលគេដឹងថាមានភាពស្រដៀងគ្នា និងទៅតាមការស្ទង់ថ្លឹងថ្លែងវានៅក្នុងដែនលោកិយដែលអាចមើលឃើញ។.
- ក៏ដូចគ្នាដែរស្ថានភាពនៅក្នុងផ្នូរជារឿងអាថ៌កំបាំងដែលឥន្ទ្រិយារម្មណ៍មិនអាចដឹងបានឡើយ។ ហើយប្រសិនបើឥន្ទ្រិយារម្មណ៍អាចដឹងមែននោះ ជំនឿចំពោះរឿងអាថ៌កំបាំងគ្មានប្រយោជន៍អ្វីឡើយ ហើយគតិបណ្ឌិតនៃការដាក់បន្ទុក( កាតព្វកិច្ច) លើមនុស្សលោកក៏ពុំមានដែរ ហើយនៅពេលនោះដែរមនុស្សលោកនិងបញ្ឈប់ការបញ្ចុះសព។ អ្នកនាំសារមានប្រសាសន៍ថា: “ប្រសិនបើពួកអ្នកមិនត្រូវបានបញ្ចុះសពគ្នាទេនោះ យើងនឹងសុំអល់ឡោះឱ្យពួកអ្នកស្តាប់ឮនូវអ្វីដែលយើងបានឮនៃទារុណកម្មនៅក្នុងផ្នូរ ”។ (រាយការណ៍ដោយមូស្លីម២៨៦៨ និងណាសាអ៊ី២០៥៨) ហេតុនេះដោយសារតែគតិបណ្ឌិតនេះគ្មានទាក់ទងជាមួយនឹងសត្វពាហនៈទេនោះ សត្វពាហនៈបានស្តាប់ឮនិងអាចដឹងពីទារុណកម្មនៅក្នុងផ្នូរ។

## ផលប្រយោជន៍នៃជំនឿចំពោះថ្ងៃបរលោក

1 ជំនឿចំពោះថ្ងៃបរលោកមានឥទ្ធិពលជាទីបំផុតក្នុងការចង្អុលបង្ហាញមនុស្សលោកឲ្យ ប្រកាន់ខ្ជាប់ខ្លួននឹងទង្វើកុសល និងការកោតខ្លាចចំពោះអល់ឡោះ ហើយចៀសវាងពីភាពអាត្មានិយម និងការសាងទង្វើកុសលដើម្បីចង់បង្ហាញឲ្យគេឃើញ។ នេះហើយជាហេតុនាំឲ្យមានការផ្សារភ្ជាប់រវាងជំនឿចំពោះថ្ងៃបរលោក និងទង្វើកុសលនៅកន្លែងជាច្រើនក្នុងគម្ពីរអាល់គួរអាន ដូចអល់ឡោះទ្រង់មានបន្ទូលថា: “ការពិតអ្នកដែលកសាងឬថែរទាំវិហាររបស់អល់ឡោះនោះ គឺមានតែអ្នកមានជំនឿលើអល់ឡោះនិងថ្ងៃបរលោក”។ (ជំពូក៩ អាត់តាវហ្ពះ វាក្យខណ្ឌទី១៨) អល់ឡោះទ្រង់មានបន្ទូលទៀតថា: “ហើយបណ្ដាអ្នកដែលមានជំនឿនឹងថ្ងៃបរលោក គឺពួកគេមានជំនឿនឹងវា (គម្ពីរអាល់គួរអាន) ហើយពួកគេថែរក្សាសឡាត្រង់ពេលវេលា”។ (ជំពូក៦ អាល់អាន់អាម វាក្យខណ្ឌទី៩២)

2 ការជាសះស្បើយចំពោះអ្នកដែលធ្វេសប្រហែសងប់ងល់នឹងកិច្ចការជីវិត និងការត្រេកត្រអាលនៅក្នុងលោកិយដែលពួកគេមិនយកចិត្តទុកដាក់ពីការប្រកួតប្រជែងគ្នាក្នុងការប្រតិបត្តិ (សាងទង្វើកុសល) និងមិនយកចិត្តទុកដាក់ពីការឆ្លៀតពេលវេលាដើម្បីបញ្ជិតខ្លួនចំពោះអល់ឡោះដោយការប្រតិបត្តិ ឱ្យយល់ជីវិតឲ្យពិត និងរយៈដ៏ខ្លីរបស់ជីវិត ហើយថ្ងៃបរលោកគឺជាទីកន្លែងបិតថេរ និងអមតៈ។ ខណៈដែលអល់ឡោះទ្រង់កោតសរសើរលើអ្នកនាំសារក្នុងគម្ពីរអាល់គួរអាន និងរំឭកទង្វើរបស់ពួកគេ ទ្រង់សរសើរពួកគេជាមួយនឹងមូលហេតុដែលជំរុញពួកគេឱ្យសាងទង្វើល្អជាទី និងកុសលធម៌ ទ្រង់មានបន្ទូលថា: “ពិតណាស់ យើងបានជ្រើសរើសពួកគេជាពិសេសដោយយើងធ្វើឲ្យការរំឭកចំពោះថ្ងៃបរលោកឋិតក្នុងដួងចិត្តពួកគេ”។ (ជំពូក៣៨ សទ វាក្យខណ្ឌ៤៦) បានសេចក្ដីថាមូលហេតុនៃទង្វើល្អនោះគឺដោយសារពួកគេមានលក្ខណៈពិសេសក្នុងការនឹករឭកចំពោះថ្ងៃបរលោក ដូច្នេះការរំឭកនេះជំរុញឲ្យពួកគេសាងអំពើល្អ និងកិច្ចការទាំងនោះ ។ ហើយនៅពេលដែលអ្នកមូស្លីមខ្លះច្រអូសពេលហើយកន្ត្រើយពីការប្រតិបត្តិតាមបទបញ្ជារបស់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់នោះ ទ្រង់ក៏មានបន្ទូលដាស់តឿនពួកគេថា: “តើពួកអ្នកពេញចិត្តនឹងការរស់នៅក្នុងលោកិយជាងបរលោកឬ? ប៉ុន្តែសុភមង្គលនៃការរស់នៅក្នុងលោកិយមិនអាចប្រៀបនឹងថ្ងៃបរលោកបានទេ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ”។ (ជំពូក៩ អាត់តាវហ្ពះ វាក្យខណ្ឌទី៣៨) នៅពេលដែលមនុស្សលោកជឿចំពោះថ្ងៃបរលោក គេពិតជាដឹងច្បាស់ថា គ្រប់ពរជ័យទាំងអស់នៅលើលោកិយមិនអាចប្រៀបផ្ទឹមនឹងពរជ័យនៅថ្ងៃបរលោកបានទេឡើយ។ ម្យ៉ាងទៀត សេចក្ដីសុខក្នុងលោកិយមិនអាចប្រៀបនឹងការជ្រលក់ចូលម្ដងក្នុងទារុណកម្មនៅបរលោក។ គ្រប់ទារុណកម្ម (ការលំបាក) នៅលើលោកិយ-ក្នុងការគោរពតាមមាគ៌ារបស់អល់ឡោះ- មិនអាចប្រៀបផ្ទឹមទៅនឹងទារុណកម្មនៅថ្ងៃបរលោកបានទេឡើយ។ ម្យ៉ាងវិញទៀតទុក្ខលំបាកក្នុងលោកិយមិនអាចប្រៀបនឹងការជ្រលក់ម្ដងចូលក្នុងបរមសុខនៅបរលោក។

3 ភាពស្ងប់ស្ងាត់ គឺមនុស្សលោកទទួលបានចំណែករបស់ខ្លួន។ បើសិនជាសម្បត្តិណាមួយនៃជីវិតរស់នៅរបស់គេលើលោកិយបានបាត់បង់នោះ គេពុំត្រូវអស់សង្ឃឹម ហើយពុំត្រូវធ្វើអត្តឃាតដោយសារការកើតទុក្ខនោះទេ។ ផ្ទុយទៅវិញគេត្រូវតែព្យាយាមតស៊ូ ហើយជឿជាក់ថា អល់ឡោះមិនបំបាត់ផលបុណ្យពីអ្នកសាងទង្វើកុសលទេឡើយ។ ទោះបីជាត្រូវគេបំពាន ឬបោក្របាស់ប្លន់ទ្រព្យគេដោយ ទ្រង់នឹងផ្ដល់ឲ្យវិញនូវអ្វីដែលគេត្រូវការចាំបាច់បំផុតនៅថ្ងៃបរលោក។ តើគេកើតទុក្ខ ម្ដេចនឹងកើត បើគេដឹងថាចំណែករបស់គេនឹងមកដល់គេវិញដោយគ្មានការសង្ស័យនៅក្នុងគ្រាដែលគ្រោះថ្នាក់បំផុត? តើគ្រប់ឃុបឃិតម្ដេចកើត បើគេដឹងថា អ្នកដែលកាត់ក្ដីរវាងគេនិងគូវិវាទរបស់គេ គឺទ្រង់ជាអ្នកកាត់ក្ដីយុត្តិធម៌បំផុត?

# > ជំនឿចំពោះព្រះលិខិត

## អត្ថន័យនៃជំនឿចំពោះព្រះលិខិតៈ ?

គឺការជឿជាក់យ៉ាងដាច់ខាតថារាល់ល្អ និងអាក្រក់វាគឺជាការកំណត់( នៅក្នុងព្រះលិខិត) របស់អល់ឡោះរួចជាស្រេច ហើយទ្រង់ធ្វើនូវអ្វីដែលទ្រង់ប្រាថ្នា អ្វីក៏ដោយមិនអាចកើតឡើងបានឡើយ លុះត្រាតែទ្រង់ប្រាថ្នាឲ្យវាកើតឡើង។ អ្វីក៏ដោយមិនអាចចេញផុតពីចេតនារបស់ទ្រង់បានឡើយ។ ហើយអ្វីក៏ដោយនៅក្នុងភព( ចក្រវាល) ទាំងអស់មិនអាចចេញផុតពីការកំណត់របស់ទ្រង់បានឡើយ។ គ្មានអ្វីអាចកើតឡើងលើកលែងតែតាមការរៀបចំរបស់ទ្រង់។ ជាមួយគ្នានេះទ្រង់បានដាក់បញ្ញានិងប្រាជ្ញាចំពោះខ្ញុំទាំងអស់ ហើយទ្រង់បើកសិទ្ធិឲ្យពួកគេជ្រើសរើសតាមចិត្តសម្រាប់រាល់ទង្វើរបស់ពួកគេ ដោយគ្មានការបង្ខិតបង្ខំឡើយ។ ផ្ទុយទៅវិញទង្វើរបស់ពួកគេកើតឡើងអាស្រ័យទៅតាមលទ្ធភាព និងចេតនារបស់ពួកគេផ្ទាល់ខ្លួន។ អល់ឡោះទ្រង់ជាអ្នកបង្កើតពួកគេ និងលទ្ធភាពរបស់ពួកគេ ទ្រង់ចង្អុលបង្ហាញអ្នកណាដែលទ្រង់មានចេតនា ហើយទ្រង់ធ្វើឲ្យវង្វេងចំពោះអ្នកណាដែលទ្រង់មានចេតនាដោយគតិបណ្ឌិតរបស់ទ្រង់។ ទ្រង់មិនត្រូវគេសួរដេញដាលនូវអ្វីដែលទ្រង់ធ្វើ តែពួកគេទេដែលត្រូវគេ(អល់ឡោះ) សួរដេញដាលនោះ។.

ជំនឿចំពោះព្រះលិខិតរបស់អល់ឡោះជាគោលគ្រឹះមួយនៃគោលគ្រឹះជំនឿ( ទាំងប្រាំមួយ) ដូចមាននៅក្នុងចម្លើយរបស់អ្នកនាំសារនៅពេលដែលជីព្រីលសួរគាត់អំពីជំនឿ គាត់ឆ្លើយថា: "អ្នកត្រូវជឿចំពោះអល់ឡោះ ម៉ាឡាអ៊ីកាត់របស់ទ្រង់ គម្ពីររបស់ទ្រង់ អ្នកនាំសាររបស់ទ្រង់ ថ្ងៃបរលោក និងអ្នកត្រូវជឿចំពោះព្រះលិខិតល្អ អាក្រក់"។ (រាយការណ៍ដោយមូស្លីម ៨)

## តើជំនឿចំពោះព្រះលិខិតមានអ្វីខ្លះ ?

ជំនឿចំពោះព្រះលិខិតមាន៤ប្រការៈ

- ជំនឿថា អល់ឡោះទ្រង់ដឹងនូវអ្វីយ៉ាងជាលក្ខណៈរួម និងលំអិត ទ្រង់ដឹងចំពោះសភាវលោករបស់ទ្រង់ទាំងអស់តាំងពីលោភសក្ការៈ ពេលវេលានៃការស្លាប់ ពាក្យសំដី និងទង្វើរបស់ពួកគេមុននឹងទ្រង់បង្កើតពួកគេ។ ទ្រង់ដឹងពីការកេរ្រមែក និងការនៅស្ងៀមរបស់ពួកគេ។ ទ្រង់ដឹងពីការអាថ៌កំបាំង និងការពលាត្រូតដាំងរបស់ពួកគេ អ្នកណាដែលនៅក្នុងចំណោមពួកអ្នកឋានសួគ៌ និងអ្នកណាដែលនៅក្នុងចំណោមពួកអ្នកឋាននរក។ អល់ឡោះទ្រង់មានបន្ទូលថា: "ទ្រង់គឺអល់ឡោះជាម្ចាស់ ដែលគ្មានម្ចាស់ណាត្រូវគេគោរពសក្ការៈដ៏ពិត្រប្រាកដក្រៅពីទ្រង់។ ទ្រង់ជាម្ចាស់ដែលដឹងនូវការអាថ៌កំបាំង និងការលាត្រូតដាង"។ (ជំពូក៥៩ អាល់ហាស្ហ័រ វាក្យខណ្ឌទី២២))
- ជំនឿថា ទ្រង់ពិតជាបានសរសេរនៅក្នុងគម្ពីរ( ឡាវហ៊ុលម៉ះហ្វ៊ូស) នូវអ្វីដែលទ្រង់បានដឹងរួចជាមុន។ ភស្តុតាងគឺពាក្យបន្ទូលរបស់ទ្រង់ថា: "គ្មានគ្រោះថ្នាក់ណាមួយបានធ្លាក់មកលើផែនដី ហើយក៏គ្មានគ្រោះថ្នាក់ណាមួយបានធ្លាក់ទៅលើពួកអ្នក លើកលែងតែបានកត់ត្រាទុកក្នុងគម្ពីរ( ឡាវហ៊ុលម៉ះហ្វ៊ូស) មុននឹងយើងបានបង្កើតវា"។ (ជំពូក៥៧ អាល់ហាទីត វាក្យខណ្ឌទី២២)

  ហើយណាពីមានប្រសាសន៍ថា: "អល់ឡោះទ្រង់បានលិខិតកំណត់កត់ចំពោះសភាវលោកទាំងអស់មុននឹងទ្រង់បង្កើតមេឃ និងផែនដីចំនួនហាសិបពាន់ឆ្នាំ"។ (រាយការណ៍ដោយមូស្លីម ២៦៥៣)
- ជំនឿថា ចេតនារបស់អល់ឡោះគឺត្រូវតែកើតឡើងគ្មានអ្វីអាចរារាំងបាន ហើយអានុភាពរបស់ទ្រង់គ្មានអ្វីអាចយកឈ្នះបានដែរ។ គ្រប់ហេតុការណ៍ទាំងអស់កើតឡើងអាស្រ័យទៅតាមចេតនា និងអានុភាពរបស់ទ្រង់។ អ្វីដែលទ្រង់មានចេតនា គឺត្រូវតែកើតឡើង ហើយអ្វីដែលទ្រង់គ្មានចេតនា

គឺមិនអាចកើតឡើងជាដាច់ខាត។ អល់ឡោះទ្រង់មានបន្ទូលថា: “ហើយពួកអ្នកមិនអាចមានបំណងធ្វើអ្វីមួយបានឡើយ លើកលែងតែអល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពទាំងអស់មានចេតនាប៉ុណ្ណោះ”។ (ជំពូក៨១ អាត់តឹកេវៀរ វាក្យខណ្ឌទី២៩)

- ជំនឿថា អល់ឡោះជាអ្នកបង្កើតឲ្យមានអ្វីៗគ្រប់យ៉ាងទាំងអស់ ទ្រង់ជាអ្នកបង្កើតតែមួយគត់ អ្វីដែលក្រៅពីទ្រង់គឺជាសភាវលោករបស់ទ្រង់ ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។ អល់ឡោះទ្រង់មានបន្ទូលថា: “ហើយទ្រង់បានបង្កើតនូវរាល់អ្វីៗទាំងអស់ បន្ទាប់មកទ្រង់បានកំណត់វាយ៉ាងសុក្រឹតតែម្តង”។ (ជំពូក២៥ អាល់ហ្វួរកន វាក្យខណ្ឌទី២)

## មនុស្សលោកមានសិទ្ធិជ្រើសរើស មានលទ្ធភាព និងចេតនាខ្លួនឯង

ជំនឿចំពោះព្រះលិខិតគឺមិនមែនបដិសេធចេតនារបស់មនុស្សក្នុងការធ្វើទង្វើអ្វីមួយ តាមជម្រើសរបស់គេនោះទេ។ ហើយក៏មិនបដិសេធលទ្ធភាពនៃការជ្រើសរើសផងដែរ ពីព្រោះតាមច្បាប់ និងភាពជាក់ស្តែងបានបញ្ជាក់យ៉ាងដូច្នោះ។.

តាមច្បាប់គឺអល់ឡោះទ្រង់មានបន្ទូលពីចេតនាថា: “នោះគឺជាថ្ងៃដែលនឹងកើតឡើងយ៉ាងពិតប្រាកដ។ ដូច្នេះអ្នកណាហើយចង់ (គេចផុតពីភាពលំបាកនៅថ្ងៃបរលោក) នោះ ចូរឲ្យគេជ្រើសរើសកន្លែងវិលត្រឡប់ទៅកាន់ម្ចាស់របស់គេចុះ”។ (ជំពូក៧៨ អាន់ណាហ្ពាក វាក្យខណ្ឌទី៣៩)

ហើយអល់ឡោះទ្រង់មានបន្ទូលពីលទ្ធភាពថា: “អល់ឡោះមិនដាក់បន្ទុកលើអ្នកណាម្នាក់ហួសពីលទ្ធភាពរបស់គេឡើយ។ អ្នកណាបានសាងអំពើល្អគឺទទួលបានផលល្អ ហើយអ្នកណាបានសាងអំពើអាក្រក់គឺទទួលបានផលអាក្រក់” ។ (ជំពូក២ អាល់ហ្ពាកេរ៉ោះ វាក្យខណ្ឌទី២៨៦)

រីឯភាពជាក់ស្តែងវិញគឺមនុស្សគ្រប់រូបមានចេតនា និងលទ្ធភាពប្រព្រឹត្ត ឬមិនប្រព្រឹត្ត (ទៅតាមចេតនា និងលទ្ធភាពរបស់គេ)។ គេអាចបែងចែករវាងអ្វីដែលកើតឡើងតាមចេតនារបស់គេ ដូចជាការដើរ និងអ្វីដែលកើតឡើងដោយគ្មានចេតនា ដូចជាសេចក្តីភ័យខ្លាច ការដួលភ្លាមៗ។ ក៏ប៉ុន្តែចេតនារបស់មនុស្ស និងលទ្ធភាពរបស់គេកើតឡើងទៅតាមចេតនារបស់អល់ឡោះ និងអានុភាពរបស់ទ្រង់ ដូចអល់ឡោះទ្រង់មានបន្ទូលថា: “សម្រាប់អ្នកណាដែលមានបំណងចង់ដើរលើមាគ៌ាដ៏ត្រឹមត្រូវក្នុងចំណោមពួកអ្នក ហើយពួកអ្នកមិនអាចមានបំណងធ្វើអ្វីមួយបានឡើយ លើកលែងតែអល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពទាំងអស់មានចេតនាប៉ុណ្ណោះ”។ (ជំពូក៨១ អាត់តឹកេវៀរ វាក្យខណ្ឌទី២៨- ២៩)

ក្នុងនេះទ្រង់បញ្ជាក់ពីបំណងនិងចេតនារបស់មនុស្ស បន្ទាប់មកទ្រង់បញ្ជាក់ទៀតថាបំណងនិងចេតនា (របស់មនុស្ស) គឺនៅក្នុងចេតនារបស់ទ្រង់ ពីព្រោះចក្រវាលទាំងមូលគឺជាកម្មសិទ្ធិរបស់អល់ឡោះ គ្មានអ្វីដែលនៅក្នុងកម្មសិទ្ធិរបស់ទ្រង់ដោយទ្រង់ពុំបានដឹង និងទ្រង់ពុំមានចេតនានោះទេ។




> ប្រាកដណាស់យើងបានបង្ហាញមាគ៌ាដល់វា ជួនកាលវា (ទទួលស្គាល់ហើយ) ថ្លែងអំណរអរគុណដល់យើង ជួនកាលវាប្រឆាំង (មិនទទួលស្គាល់)

## យកេលសនឹង្រពះលិខិត

ការដាក់បន្ទុក បទបញ្ញា និងប្រមាមគឺអាស្រ័យេទៅតាមលទ្ធភាព និងការេជ្រីសេរីសរបស់មនុស្សែដលអាចអនុវត្តេទៅបាន។ ្រេគបទានផលបុណ្យចំេពាះអ្នកេធ្វើអំេពីល្អ តាមការេជ្រីសេរីសរបសេ់គនូវមាគ៌ាែដលមានការចង្អុលបង្ហាញ េហើយេគេធ្វទារុណកម្មចំេពាះអ្នកេធ្វើអំេពើអាក្រក់តាមការេជ្រីសេរីសរបសេ់គនូវមាគ៌ាែដលវង្វង។ អលេ់ឡាះទ្រង់មិនបានដាក់បន្ទុកេលើេយើងេទេលើកែលងែតអ្វីែដលពួកេយើងមានលទ្ធភាព េហើយទ្រង់មិនទទួលយកពីអ្នកណាម្នាក់ែដលេបាះបង់ការេគារពសក្ការៈចំេពាះទ្រង់េដាយអាងេលសថាជាព្រះលិខិត។ បន្ទាប់មកេទៀតគឺមនុស្សេលាកមុននឹង្របព្រឹត្តបាបកម្ម េតើគពុំបានដឹងេទអ្វីជាចំេណះដឹង និងអ្វីជាការកំណត់របស់អលេ់ឡាះ? េហើយអលេ់ឡាះទ្រង់បទានចំេពាះេគនូវលទ្ធភាព និងការេជ្រីសេរីស ទ្រង់បានបំភ្លឺចំេពាះេគនូវផ្លូវល្អ និងផ្លូវអាក្រក់។ ដូេច្នះេបើសិនជា្រេគបព្រឹត្តបាបកម្មេនាះ េតើគជាអ្នកេជ្រីសេរីសបាបកម្មេដាយខ្លួនឯង េគសេម្រចចិត្តយកការប្រព្រឹត្តបាបកម្មជាជាងការប្រព្រឹត្តតាម( ការេធ្វើអំេពីល្អ ) ដូេច្នះ្រេគតូវែតទទួលទារុណកម្មចំេពាះការប្រព្រឹត្តបាបកម្មរបសេ់គេដាយខ្លួនឯង។



> ប្រសិនេបើមនុស្សម្នាក់បានបំពានេទៅេលើអ្នកេហើយបានយកទ្រព្យសម្បត្តិរបស់អ្នក េហើយបានប៉ះពាល់ឲ្យរបួសដល់អ្នក បន្ទាប់គាត់បានសុំអភ័េទាសេដាយេប្រីេលសថាវាគឺជាវាសនាែដល្រត្រូវបានកំណត់រួច ប្រាកដជាអ្នកមិនអាចទទួលការសុំអធ្យា្រស័យអំពីវាដ៏េថាកទាបេនាះេឡើយ េហើយប្រាកដជាអ្នកនឹងដាក់ទណ្ឌកម្មដល់វាេហើយដកយកអ្វីែដលជាកម្មសិទ្ធរបស់អ្នកពីវាេហើយ ពីេព្រាះវាបានេធ្វើែបបេនាះេដាយការេជ្រីសេរីសរបស់វានិងេដាយេចតនារបស់វា

## ផលប្រេយាជន៍ៃនជំេនឿេលើពះលិខិត

ផលប្រេយាជន៍ៃនជំេនឿេលើពះលិខិតគឺវាធំធេងនៅក្នុងជីវិតមនុស្សេលាកមានដូចជា៖:

1 ព្រះលិខិតគឺជាកត្តាជំរុញេលើកទឹកចិត្តដ៏បំផុតដល់( មនុស្ស) ចំេពាះការងារភាពសកម្មេក្លវក្លា និងការខំប្រឹងែស្វងរកនូវអ្វីែដលអលេ់ឡាះអនុញ្ញាតយល់ព្រមសម្រាប់ជីវិតរស់េនៅេលើេលាកិយេនះ។

អ្នកមានជំេនឿទាំងអស្រ់តូវបាេនគបង្គាប់ឲ្យយកេហតុជាបច្ច័យជាមួយនឹងការេជឿទុកចិត្តេលើអលេ់ឡាះ។ េហើយ្រត្រូវមានជំេនឿថាមូលេហតុមិនបានផ្តល់ផលអ្វីេទេឡើយ លុះ្រតាែតមានការអនុញ្ញាតពីអលេ់ឡាះ េព្រាះទ្រង់គឺជាអ្នកបេង្កើតមូលេហតុ និងលទ្ធផលទាំងឡាយ។

អ្នកនាំសារមាន្របសាសន៍ថា: “ចូរអ្នកខិតខំេធ្វើអ្វីែដលផ្តល់ផលប្រេយាជន៍ចំេពាះអ្នក ចូរអ្នកសុំជំនួយពីអលេ់ឡាះ េហើយចូរអ្នកកុំខ្ជិលច្រអូស

ប្រសិនបើមានអ្វីកើតឡើងចំពោះអ្នក ចូរអ្នកកុំពោលពាក្យថា៖ ប្រសិនបើខ្ញុំបានធ្វើអ៊ីចេះនឹងបានអ៊ីចេះមួយ បើធ្វើអ៊ីចោះនឹងបានអ៊ីចោះមួយ។ ក៏ប៉ុន្តែអ្នកត្រូវពោលថា៖ អល់ឡោះបានដាក់កំណត់រួចជាស្រេច ហើយអ្វីៗដែលទ្រង់មានចេតនា វានឹងកើតឡើង។ ពិតណាស់ (ពាក្យថា៖) "ប្រសិនបើ" គឺវាបើកផ្លូវឲ្យសកម្មភាពរបស់បិសាចស្ហៃតន (ញុះញង់មនុស្សលោក)"។ (រាយការណ៍ដោយមូស្លីម ២៦៦៤)

2 មនុស្សលោកត្រូវដឹងពីលទ្ធភាពខ្លួនឯង គេមិនត្រូវមានអំនួត ក្រអឺត្រទម ពីព្រោះគេគ្មានលទ្ធភាពដឹងនូវអ្វីដែល (ព្រះលិខិត) បានកំណត់រួចជាស្រេច ហើយនៅពេលអនាគតគេក៏ពុំបានដឹងនូវអ្វីដែលនឹងកើតឡើងដែរ។ ដូច្នេះ មនុស្សលោកត្រូវតែទទួលស្គាល់នូវការអសមត្ថភាពរបស់ខ្លួន និងភាពខ្វះខាតរបស់គេ និងត្រូវការម្ចាស់របស់គេជារៀងរហូត។

កាលណាមនុស្សលោកទទួលផលល្អគេមានអំនួត ក្រអឺតអាល ហើយកាលណាគេទទួលផលអាក្រក់ និងគ្រោះថ្នាក់គេខឹងច្រឡោត កើតទុក្ខព្រួយបារម្ភ។ គ្មានអ្វីអាចរក្សាមនុស្សលោកពីការមានអំនួត ភាពហួសហេតុនៅពេលដែលគេទទួលបានផលល្អ និងការកើតទុក្ខព្រួយបារម្ភនៅពេលដែលគេទទួលបានផលអាក្រក់បាននោះឡើយ មានតែជំនឿលើព្រះលិខិតនេះប៉ុណ្ណោះ។ ពិតណាស់អ្វីៗដែលកើតឡើងគឺប្រព្រឹត្តទៅតាមព្រះលិខិតដែលបានកំណត់រួចជាស្រេច ហើយអល់ឡោះទ្រង់បានដឹងតាំងពីមុនមកហើយ។

3 ជំនឿលើព្រះលិខិតគឺវាបំបាត់អពមង្គលនៃការច្រណែនឈ្នានីស។ អ្នកមានជំនឿគឺមិនច្រណែនឈ្នានីសនូវអ្វីៗដែលអល់ឡោះទ្រង់បានផ្តល់ចំពោះមនុស្សលោកនៃភាពល្អប្រសើរ ពីព្រោះទ្រង់ជាអ្នកផ្តល់លាភសក្ការៈ និងកំណត់សម្រាប់ពួកគេរួចទៅហើយ។ អ្នកមានជំនឿក៏ដឹងទៀតថានៅពេលដែលគេច្រណែនឈ្នានីសអ្នកដទៃនោះគឺជាការប្រឆាំងនឹងព្រះលិខិតរបស់អល់ឡោះ និងការកំណត់របស់ទ្រង់។

4 ជំនឿលើព្រះលិខិតជំរុញចិត្តឲ្យមានភាពក្លាហានក្នុងការប្រឈមមុខនឹងឧបសគ្គ ហើយព្រងឹងឆន្ទៈ ពីព្រោះក្នុងចិត្តជឿជាក់យ៉ាងច្បាស់ថា ពេលកំណត់ (នៃសេចក្តីស្លាប់) លាភសក្ការៈ គឺបានកំណត់រួចជាស្រេច ហើយគ្មានអ្វីកើតឡើងចំពោះមនុស្សក្រៅពីអ្វីដែលគេបានលិខិតកំណត់រួចជាស្រេចសម្រាប់គេ។

5 ជំនឿលើព្រះលិខិតគឺវាបណ្តុះផ្តត់គំនិតអ្នកមានជំនឿនូវធាតុពិតជាច្រើននៃជំនឿ ធ្វើឲ្យគេជានិច្ចកាលតែងតែសុំជំនួយពីអល់ឡោះ ពឹងផ្អែក និងជឿទុកចិត្តលើទ្រង់ជាមួយនឹងការយកហេតុជាបច្ច័យ។ ហើយគេជានិច្ចកាលតែងតែត្រូវការទ្រង់ផងដែរដើម្បីសុំជំនួយឱ្យមានជំហររឹងមាំ។

6 ជំនឿលើព្រះលិខិតនាំឲ្យមានភាពស្កប់ស្កល់ក្នុងខ្លួន។ អ្នកមានជំនឿដឹងថាអ្វីដែលត្រូវកើតឡើងចំពោះគេគឺវាមិនអាចទៅណាខុសពីគេបានទេ ហើយអ្វីដែលត្រូវកើតឡើងលើអ្នកដទៃក្រៅពីគេគឺវាក៏មិនអាចកើតឡើងចំពោះគេជាដាច់ខាត។



# ជំពូក២ អនាម័យរបស់អ្នក



# 2

ព្រះអល់ឡោះបានបង្គាប់ឲ្យអ្នកមូស្លីមធ្វើការជ្រមះសម្អាតចិត្តរបស់គេពីទង្វើស៊ីរិកនិងជំងឺផ្លូវចិត្តដូចជាការច្រណែនឈ្នានីស ក្រអឺត្រកទម និងការចង់គំនុំនឹងគ្នា។ល។ ហើយយេធ្វើការជ្រមុះសម្អាតខ្លួនប្រាណរបស់គេពីភាពកខ្វក់។ ប្រសិនបើបុគ្គលណាបានធ្វើដូច្នោះ គេពិតជាទទួលបាននូវការអាណិត្រសលាញ់ព្រះជាម្ចាស់ជាមិនខានដូច្រទង់បានមានបន្ទូលថាៈ ពិតណាស់អល់ឡោះស្រលាញ់បណ្ដាអ្នកដែលសារភាពទោសកំហុសនិងស្រលាញ់បណ្ដាអ្នកជំរះស្អាត”។(អាល់បាករ៉ះ:២២២)

## មាតិកាជំពូក

### និយមន័យនៃពាក្យ(អាល់តហារ៉ះ)

### ជ្រមះសម្អាតពីភាពកខ្វក់

- ការសម្អាតភាពកខ្វក់
- សុជីវធម៌ក្នុងការបន្ទោបង់និងការសម្អាត

### អាល់ហាឌាស(ភាពកខ្វក់ផ្នែកបញ្ញត្តិច្បាប់)

- ហាឌាសតូចនិងការយកទឹកជ្រមះកាយ(ទឹកវ៉ូហ្ចុ) ពីការមានហាឌាស

### តើខ្ញុំយកទឹកជ្រមះកាយយ៉ាងដូចម្ដេច?

- ការបំបាត់ហាឌាសតូច
- ហាឌាសធំនិងការងូតទឹក
- តើអ្នកមូស្លីមសម្អាតខ្លួនពីការរួមដំណេក ឬហាឌាសធំយ៉ាងដូចម្ដេច?
- អ្នកដែលគ្មានលទ្ធភាពប្រើប្រាស់ទឹក

## > និយមន័យនៃពាក្យ(អាល់តហារ៉ោះ)

ន័យដើមរបស់អាល់តហារ៉ោះគឺ ភាពស្អាតស្អំ អនាម័យ និងជ្រះថ្លា។.

ពិតណាស់អល់ឡោះទ្រង់បានបង្គាប់អ្នកមូស្លីមឲ្យធ្វើការជ្រមះសម្អាតខ្លួនប្រាណនឹងចិត្តរបស់គេ។ហេតុនេះគេត្រូវសម្អាតខ្លួនប្រាណរបស់គេពីរាល់ប្រការណាដែលកខ្វក់ នឹងសម្អាតចិត្តរបស់គេពីការធ្វើស៊ីរិក និងការប្រែចណាន់គុំគួនគ្នាទៅវិញទៅមក។ ប្រសិនបើបុគ្គលណាបានធ្វើដូច្នោះគេពិតជាទទួលបានការអាណិតស្រលាញ់ពីព្រះអល់ឡោះ។ដូច្រទង់បានមានបន្ទូលថា:

ពិតណាស់អល់ឡោះស្រលាញ់បណ្តាអ្នកដែលសារភាពទោសកំហុសនិងស្រលាញ់បណ្តាអ្នកជ្រះស្អាត។ អាល់បាកេរ៉ោះ២២២។

ហើយទ្រង់បានបង្គាប់ឲ្យធ្វើការជ្រមះសម្អាតដើម្បីថ្វាយបង្គំចំពោះទ្រង់ ពីព្រោះការថ្វាយបង្គំគឺជាបួងសួងចំពោះទ្រង់។ ហើយជាធម្មតាមនុស្សគ្រប់រូបនៅពេលទៅជួបស្តេចឬប្រធានណាម្នាក់គេពិតជាជ្រើសរើសសម្លៀកបំពាក់យ៉ាងល្អស្អាតជាមិនខាន។ ចុះយ៉ាងដូចម្តេចវិញសំរាប់អ្នកដែលជួបម្ចាស់នៃស្តេចទាំងឡាយទ្រង់មហាស្អាតស្អំ។.

### តើអ្វីជាការសម្អាតដែលគេទាមទារចង់បានសម្រាប់សឡាត។?

នៅពេលដែលអ្នកមូស្លីមចង់សឡាត្ត(ថ្វាយបង្គំ) និងកាន់គម្ពីរគួរអានគឺចាំបាច់ត្រូវធ្វើការសម្អាត ដើរប្រទក្សិណជុំវិញកៈហ្បះ ហើយចំពោះកន្លែងផ្សេងទៀតដែលទ្រង់ជំរុញឲ្យធ្វើការសម្អាតដូចជាការសូត្រគម្ពីដោយមិនកាន់គម្ពីរគួរអានការបួងសួង គេង។ល។.

ដូច្នេះចាំបាច់លើអ្នកមុស្លីមនៅពេលដែលគេចង់សឡាត្ត( ថ្វាយបង្គំ) គេត្រូវជ្រមះសម្អាតពីរប្រការៈ

1. ប្រការកខ្វក់
2. អាល់ហាឌាស



> អល់ឡោះបានបញ្ជារអ្នកមូស្លិមឲ្យសម្អាតចិត្តរបស់គេឲ្យជ្រះស្អាតអំពីស៊ើរិកនិងអំពីជម្ងឺចិត្ត ហើយនិងសម្អាតផ្នែកខាងក្រៅរបស់គេឲ្យជ្រះស្អាតអំពីប្រការដែលត្រូវបានហាមឃាត់និងប្រការដែលកខ្វក់ទាំងឡាយ

## > ការជម្រះសម្អាតពីប្រការកខ្វក់

- ប្រការកខ្វក់ គឺវត្ថុរូបីទាំងឡាយដែលច្បាប់បានចែងថាវាកខ្វក់ ហើយបានបង្គាប់ឲ្យយើងជម្រះសម្អាតវា ដើម្បីធ្វើការគោរពសក្ការៈចំពោះទ្រង់។.
- ជាគោលការណ៍អ្វីគ្រប់យ៉ាងច្បាប់អនុញ្ញាត និង ជ្រះស្អាត ហើយភាពកខ្វក់វាទើបតែនិងកើតឡើង។ ប្រសិនបើយើងមានការមន្ទិលសង្ស័យចំពោះភាពស្អាតស្អំនៃសម្លៀកបំពាក់របស់យើង ហើយយើងមិនប្រាកដច្បាស់ថាមានភាពកខ្វក់ទេនោះ ជាគោលការណ៍គឺវាជ្រះស្អាត។
- បើសិនជាយើងចង់សឡាត(ថ្វាយបង្គំ) គឺចាំបាច់ណាស់លើយើងត្រូវជម្រះខ្លួនប្រាណនិងសម្លៀកបំពាក់ ទីកន្លែងដែលយើងសឡាត(ថ្វាយបង្គំ)។.

### ប្រការដែលកខ្វក់នោះគឺៈ

| | |
|---|---|
| 1 | លាមកនិងទឹកនោមរបស់មនុស្ស |
| 2 | ឈាម តែគេអនុគ្រោះចំពោះឈាមបន្តិចបន្តួច |
| 3 | លាមកសត្វនិងទឹកនោមសត្វដែលគេហាមមិនឲ្យបរិភោគសាច់របស់វា(មើលទំព័រ១៥៧) |
| 4 | សត្វឆ្កែនិងជ្រូក |
| 5 | សាកសពសត្វ(គឺរាល់សត្វងាប់ទាំងឡាយលើកលែងតែសត្វដែលគេអនុញ្ញាតឲ្យបរិភោគវានៅពេលគេសម្លះវាតាមច្បាប់ឥស្លាម ចូរមើលទំព័រ១៥៨) ចំណែកសាកសពមនុស្សនិងត្រីសត្វល្អិត គឺវាស្អាត។ |

### ការជម្រះសម្អាតពីប្រការកខ្វក់(ណាជិស)

ការលាងជម្រះភាពកខ្វក់ដែលប្រឡាក់លើខ្លួនប្រាណ សម្លៀកបំពាក់ ទីកន្លែង គឺយើងត្រូវគាន់តែលាងវាឱ្យបាត់សារធាតុកខ្វក់ពីរបស់ដែលប្រឡាក់នោះបានហើយ។ ទោះដោយប្រើវិធីណាក៏ដោយ ដោយទឹកឬអ្វីផ្សេងទៀត។ ពីព្រោះច្បាប់ប្រើឱ្យបំបាត់វា ហើយមិនបានដាក់លក្ខខណ្ឌឱ្យលាងជម្រះភាពកខ្វក់នោះចំនួនណាមួយជាក់លាក់ដូរ លើកលែងតែទឹកមាត់ លាមក និងទឹកនោមសត្វឆ្កែប៉ុណ្ណោះដែលយើងត្រូវលាងវាចំនួនប្រាំពីរដងលើកទីមួយត្រូវប្រើទឹកល្បាយដី។ចំណែកភាពកខ្វក់ផ្សេងទៀតគឺយើងគ្រាន់តែលាងវាឲ្យបាត់សារធាតុកខ្វក់ប៉ុណ្ណោះ ហើយក្លិននិងពណ៌របស់វាគ្មានបញ្ហាអ្វីទេ។ដូចណាពីមូហាំម៉ាត់បានមានប្រសាសន៍ទៅកាន់នារីម្នាក់ដែលនាងបានលាងឈាមរដូវរបស់នាងថាៈ នាងគ្រាន់តែលាងឈាមបានហើយ ហើយស្នាមរបស់វាគឺគ្មានបញ្ហាអ្វីឡើយ។រាយការណ៍ដោយអាពូទោត៣៦៥។)



> គ្រប់គ្រាន់ហើយក្នុងការបំបាត់ណាជិស ឲ្យកំចាត់ធាតុរបស់វាដោយរបស់បំបាត់ណាក៏អាចដែរ

## សុជីវធម៌ក្នុងការបន្ទោបង់និងការសម្អាត

- នៅពេលគេចូលបង្គន់គប្បីត្រូវចាប់ផ្តើមដោយជើងឆ្វេង រួចសូត្រថាៈ( بسم الله ) ក្នុងនាមអល់ឡោះ។ ( اللهم إني أعوذ بك من الخبث والخبائث ) បព្រិតអល់ឡោះសូមទ្រង់បញ្ចៀសពីសត្វនេឈ្មោលនិងសត្វនញី។.
- ហើយនៅពេលគេចេញពីបង្គន់វិញគប្បីត្រូវចាប់ផ្តើមដោយជើងស្តាំ ហើយសូត្រថា ( غفرانك ) សូម ទ្រង់អភ័យទោសផងចុះ។.
- ចាំបាច់ត្រូវបិទបាំងខ្លួនប្រាណរបស់គេពីកែសែភ្នែកមនុស្សនៅពេលកំពុងបន្ទោបង់។
- កុំបន្ទោបង់ទីកន្លែងណាដែលធ្វើឲ្យប៉ះពាល់ដល់មនុស្ស.
- ចូរកុំបន្ទោបង់ដាក់រន្ធដី ព្រោះវាអាចមានសត្វចៃច្រងនៅក្នុងនោះដោយហេតុណាមួយ ដែលបណ្តាលឲ្យប៉ះពាល់ដល់ខ្លួនឯងវិញ។.
- ចាំបាច់លើអ្នកមូស្លីមពុំត្រូវត្រមង់ទៅកាន់កិបឡាត់ឬបែរខ្នងដាក់កិបឡាត់ ទោះជានៅទីកន្លែងណាក៏ដោយ លើកលែងតែនៅក្នុងបន្ទប់ទឹកឬបង្គន់គឺគ្មានបញ្ហាទេ។ ព្រោះណាពីបានមានប្រសាសន៍ថាៈ ប្រសិនបើពួកអ្នកធ្វើការបន្ទោបង់ចូរពួកអ្នកកុំត្រមង់ទៅកិបឡាត់ឬបែរខ្នងដាកវា(អាល់ពូខរី៣៨៦ មូស្លីម២៦៤)។.
- ត្រូវប្រយ័ត្នពីការខ្ទាតភាពកខ្វក់(ណាជីស)ទៅលើសម្លៀកបំពាក់របស់គ ហើយត្រូវលាងវាបើមានការប្រឡាក់នោះ.
- បើសិនជាគេបន្ទោបង់រួចគ្រត្រូវធ្វើពីរយ៉ាងៈ:

គឺគ្រត្រូវសម្អាតលាមកឬទឹកនោមពីខ្លួនរបស់គេដោយប្រើទឹក (អាល់អ៊ីសតិញហ្ជាក)

--

ឬក៏គ្រត្រូវសម្អាតវាដោយប្រើកណាត់បីដុំឬច្រើនជាងនេះ ឬដុំថ្ម ឬក្រដាសដែលល្អអាចជ្រមះខ្លួនគេពីណាជីសបាន(អាល់អ៊ីសតិចមើរ)។

# > អាល់ហាឌាស(ភាពកខ្វក់ផ្នែកបញ្ញត្តិច្បាប់)

- **អាល់ហាឌាសគឺជាលក្ខណៈ**អរូបីមួយដែលរារាំងមនុស្សមិនឲ្យប្រតិបត្តិការថ្វាយបង្គំមុននឹងវាជ្រះស្អាតជ្រមះ។ ហើយវាមិនមែនជាវត្ថុរូបីដូចរបស់កខ្វក់នោះទេ។.
- ហើយអាល់ហាឌាសវានឹងជ្រះស្អាតនៅពេលដែលអ្នកមូស្លីមយកទឹកជ្រមះកាយ(វូហ្លូ)ឬក៏ងូតទឹកជ្រមះខ្លួនប្រាណដោយទឹកស្អាត។ ទឹកស្អាតគឺជាទឹកដែលបរិសុទ្ធមិនលាយឡំជាមួយនឹងណាជីស(សារធាតុកខ្វក់)។ ហើយបើសិនជាគេយកទឹកជ្រមះកាយរួច(វូហ្លូ)គឺគេឋិតក្នុងភាពគេអាចប្រតិបត្តិការថ្វាយបង្គំ(សឡាត)បានរហូតដល់គេមានអាល់ហាឌាសសាជាថ្មី។

គេបែងចែកអាល់ហាឌាសជាពីរផ្នែក:

- អាល់ហាឌាសដែលចាំបាច់លើមនុស្សគ្រប់រូបត្រូវតែយកទឹកជ្រមះកាយ(វូហ្លូ) ដើម្បីលុបបំបាត់វាចេញពីខ្លួន ហើយគេឱ្យឈ្មោះថា (ហាឌាសតូច)។
- ២- អាល់ហាឌាសដែលចាំបាច់លើមនុស្សគ្រប់រូបត្រូវតែមុជទឹកនិងចាក់ទឹកឱ្យសព្វប្រាណដើម្បីលុបបំបាត់វាចេញខ្លួនប្រាណ ហើយគេឲ្យឈ្មោះថា(ហាឌាសធំ)។

## ហាឌាសតូចនិងការយកទឹកជ្រមះកាយ:

ភាពជ្រះស្អាតរបស់អ្នកមូស្លីមត្រូវតែអសារបង់ ហើយចាំបាច់ត្រូវយកទឹកជ្រមះកាយ ដើម្បីប្រតិបត្តិការថ្វាយបង្គំ(សឡាត) ប្រសិនបើមានករណីដូចខាងក្រោមនេះ:

1. លាមកឬទឹកនោមនិងរាល់អ្វីៗដែលបានចេញពីទ្វារទាំងពីរដូចជាចេញខ្យល់។ព្រះអល់ឡោះទ្រង់បានមានព្រះបន្ទូលថា: (ឬនរណាម្នាក់ក្នុងចំណោមពួកអ្នកបានបន្ទោបង់....)ជំពូកអាល់នីសាក/៤៣។ ណាពីមូហាំម៉ាត់បានមានប្រសាសន៍ទាក់ទងនឹងអ្នកដែលមានការសង្ស័យថាខ្លួនមានអាល់ហាឌាសក្នុងការថ្វាយបង្គំ( សឡាត) ថា: ចូរគេកុំចាកចេញពីសំពះយ៉ាង( សឡាត)រហូតទាល់តែគេបានឮសំឡេងឬធុំក្លិន។ (អាល់ពូខរី១៧៥មូស្លីម៣៦១)។
2. កាន់្របដាប់ភេទរបស់ខ្លួនផ្ទាល់ដោយដៃដោយគ្មានរបាំង ណាពីមូហាំម៉ាត់បានមានប្រសាសន៍ថា: បុគ្គលណាកាន់្របដាប់ភេទរបស់គេចូរឱ្យគេយកទឹកជ្រមះកាយ(វូហ្លូ)។អាពូដោត១៨១។)
3. បរិភោគសាច់អូដ្ឋ មាននេគសួរណាពីមូហាំម៉ាត់ថា:តើយើងត្រូវយកជ្រមះកាយដែរឬទេក្រោយពីបរិភោគសាច់អូដ្ឋនោះ?គាត់បានតបថា: បាទត្រូវតែយក។
4. បាត់បង់សតិ ដោយការដេកលក់ ឬស្រវឹង ឬឆ្កួត។



> ក្នុងចំណោមប្របការដែលធ្វើឲ្យខូចការស្អាតស្អំគឺបាត់បង់បញ្ញាដោយដេកលក់ឬឆ្កួតឬស្រវឹង

## > តើខ្ញុំយកទឹកជម្រះកាយយ៉ាងដូចម្តេច ?

ការយកទឹកជម្រះកាយនិងការជម្រះសម្អាតគឺជាទង្វើដ៏ល្អប្រសើរ និងថ្លៃថ្លាបំផុត។ ព្រះអល់ឡោះទ្រង់បានអភ័យទោសនិងលុបលាងកំហុសនៅពេលដែលខ្ញុំរបស់ទ្រង់បានប្រតិបត្តិវាដោយចិត្តស្មោះបរិសុទ្ធចង់បានផលបុណ្យពីព្រះជាម្ចាស់។ពិតណាស់ណាពីមូហាំម៉ាត់បានមានប្រសាសន៍ថា: ((នៅពេលដែលអ្នកមូស្លីមយកទឹកជម្រះកាយ ហើយគេបានលាងមុខរបស់គេនោះ រាល់កំហុសឆ្គងបានហូរចេញតាមមុខរបស់គេ គេមើលឃើញផ្ទាល់នឹងភ្នែកទាំងគូរបស់គេជាមួយនឹងទឹក។ ហើយនៅពេលគេលាងដៃរបស់គេទាំងសងខាង រាល់កំហុសឆ្គងបានហូរចេញតាមដៃរបស់គេ កំហុសឆ្គងរលាស់ចេញពីដៃទាំងពីរជាមួយនឹងទឹក។ ហើយនៅពេលគេលាងជើងរបស់គេទាំងពីរ រាល់កំហុសឆ្គងបានហូរចេញតាមជើងទាំងពីររបស់គេ ជើងទាំងពីររបស់គេជាន់កំហុសឆ្គងនោះជាមួយនឹងទឹក រហូតដល់គេបានជ្រះស្អាតពីទោសកំហុសរបស់គេ។មូស្លីម២៤៤។

### តើខ្ញុំយកទឹកជ្រះកាយនិងជម្រះសម្អាតហាឌាសតូចយ៉ាងដូចម្តេច ?



នៅពេលអ្នកមូស្លីមចង់យកទឹកជម្រះកាយគើគ្រូវនៀត មានន័យថា គ្រូវតាំងចិត្តបំបាត់អាល់ហាឌាស ហើយនៀតគឺជាលក្ខខណ្ឌក្នុងគប់ការគោរពប្រតិបត្តិទាំងអស់។ណាពីមូហាំម៉ាត់បានមានប្រសាសន៍ថា:រាល់ការគោរពប្រតិបត្តិត្រូវមានការនៀត។អាល់ពូខរី១ មូស្លីម១៩០៧។ បន្ទាប់មកគេត្រូវយកទឹកជម្រះកាយតាមលំដាប់លំដោយបន្តបន្ទាប់គ្នា គ្មានការឃ្លាតពីគ្នារយៈពេលយូរ។

1

គ្រូវសូត្រថា( بسم الله ) ក្នុងព្រះនាមអល់ឡោះ។



2

លាងប្រអប់ដៃនឹងទឹកចំនួនបីដង



3

ខ្ពុរមាត់នឹងទឹកចំនួនបីដង។ មានន័យថា ដាក់ទឹកចូលក្នុងមាត់ ខ្ពុរវា បន្ទាប់មកខ្ជាក់ចេញ។ គប្បីធ្វើដូច្នេះចំនួនបីដង ហើយមួយ១ដងជាការចាំបាច់។



4

ត្រូវរឹតទឹកចូលក្នុងច្រមុះបន្ទាប់មកញើសេចញមកវិញដោយកន្ទាំងខ្យល់ចេញច្រមុះ។ គប្បីរឹតទឹកឱ្យដល់ទីជម្រៅលើកលែងតែវាបង្កផលប៉ះពាល់ដល់គេ ហើយគប្បីធ្វើបែបនេះដដែលៗចំនួនបីដង។



## 5

លាងមុខរបស់គេ គឺចាប់ផ្តើមពីគល់ថ្ងាសខាងលើរហូតដល់ចង្កានិងព្រៃត្រចៀកមួយដល់ត្រចៀកមួយទៀត។ ត្រចៀកទាំងពីរគេពុំរាប់ចូលក្នុងផ្ទៃមុខ។ គប្បីត្រូវលាងបីដង ហើយម្តងយ៉ាងតិច។



## 6

លាងដៃទាំងពីររបស់គេ ចាប់ផ្តើមពីចុងម្រាមដៃរហូតដល់កែងដៃទាំងសងខាងរបស់គេ (ខាងស្តាំបន្ទាប់មកខាងឆ្វេង) គេត្រូវលាងកែងដៃរបស់គេទាំងពីរដែរ គប្បីគេត្រូវលាងបីដង តែយ៉ាងតិចឲ្យបានម្តង។



## 7

ជូតក្បាលរបស់គេដោយយកដៃរបស់គេទាំងពីរជ្រលក់ទឹក បន្ទាប់មកចាប់ផ្តើមជូតពីខាងមុខរហូតដល់ខាងក្រោយរួចទាញពីក្រោយមកមុខវិញ គប្បីធ្វើដូច្នេះបីដង ហើយយ៉ាងតិចម្តង។



## 8

ជូតត្រចៀកទាំងសងខាងរបស់គេ លូកម្រាមដៃចង្អុលទាំងពីរក្នុងត្រចៀកបន្ទាប់ពីជូតក្បាលរួច និងយកមេដៃទាំងពីរជូតពីខ្នងត្រចៀក។



## 9

លាងជើងទាំងពីររបស់គេ រហូតដល់ភ្នែកគោល ត្រូវលាងបីដង (ខាងស្តាំបន្ទាប់មកខាងឆ្វេង) យ៉ាងតិចម្តង។ ប្រសិនបើគេពាក់ស្រោមជើង គេអាចជូតលើស្រោមជើងបានតាមលក្ខណរបស់វា សូមមើលទំព័រទី៧៧។



## ហាឌាសធំនិងការងូតទឹក:

### ប្រការៗដែលចាំបាច់ត្រូវងូតទឹក:

ជាប្រការដែលនៅពេលអ្នកមូស្លីមបាននប្រព្រឹត្តវាគឺចាំបាច់លើរូបគេត្រូវងូតទឹកមុននឹងប្រតិបត្តិការថ្វាយបង្គំ និងដើរប្រទក្សិណជុំវិញកៈហ្ពះ ហើយមុននឹងមុជទឹកគេឱ្យឈ្មោះថា ហាឌាសធំ។

ហើយប្រការទាំងនោះដូចជា:

**1** ចេញទឹកកាមេដាយចេតនាតាមវិធីណាក៏ដោយ និង្រ្គប់ស្ថានភាព ភ្ញាក់ដឹងខ្លួន ឬដេកលក់។ ហើយទឹកកាមគឺទឹករអិលពណ៌ស ខាប់ ដែលចេញនៅពេលដែលមានអារម្មណ៍ស្រួលដល់កំពូល។

**2** ការរួមដំណេក មានន័យថាបញ្ចូលអង្គជាតេទៅក្នុងទ្វារមុខរបស់ស្ត្រី ទោះបីមិនចេញទឹកកាមក្ដីគឺចាំបាច់លើរូបគេត្រូវងូតទឹក ដោយគ្រាន់តែក្បាលអង្គជាតលិចចូលបន្តិច ព្រះអល់ឡោះទ្រង់មានព្រះបន្ទូលថា: (ហើយប្រសិនបើពួកអ្នកមានជូនុប(ហាឌាសធំ)ពួកអ្នកត្រូវជ្រមុះសម្អាតខ្លួនប្រាណ(ដោយងូតទឹក) អាល់ម៉ាអ៊ីឌះ/៦។)

**3** ចេញឈាមរដូវនិងអាល់នីហ្វាស(ឈាមបន្ទាប់ពីឆ្លងទន្លេ)

- ឈាមរដូវគឺជាឈាមធម្មជាតិដែលស្ត្រីមកជារៀងរាល់ខែក្នុងដែលមានរយៈពេលប្រាំពីរថ្ងៃឬតិចជាងនេះឬច្រើនជាងនេះតាមសភាពលក្ខណៈរបស់ស្ត្រី។.
- អាល់នីហ្វាស(ឈាមចេញបន្ទាប់ពីឆ្លងទន្លេរួចដែលមានរយៈពេលជាច្រើនថ្ងៃ)។.

ហើយគេបានអនុគ្រោះចំពោះស្ត្រីដែលមានរដូវនិងឈាមឆ្លងទន្លេរួចក្នុងរយៈពេលដែលឈាមកំពុងមក មិនឲ្យប្រតិបត្តិការថ្វាយបង្គំ(សឡាត) និងបួស(តមអាហារ) ហើយត្រូវបួសសងវិញ ចំណែកឯការថ្វាយបង្គំវិញមិនត្រូវសងទេឡើយ បន្ទាប់ពីនាងជ្រះស្អាត។ គេមិនអនុញ្ញាតឲ្យប្ដីរបស់នាងរួមដំណេកជាមួយនាងខណៈដែលនាងកំពុងមានរដូវឬបន្ទាប់ពីឆ្លងទន្លេរួច។ តែគេអាចប្រលេងលេងជាមួយនាងបាន។ ហើយចាំបាច់លើរូបនាងត្រូវងូតទឹកជ្រមុះខ្លួនបន្ទាប់ពីអស់រដូវនិងអស់ឈាមឆ្លងទន្លេ។



> គ្រប់គាន់ហើយក្នុងការងូតទឹកវាំងជិត ឲ្យស្រោចសប់ទឹកលើខ្លួនគេទាំងមូល

អល់ឡោះទ្រង់មានបន្ទូលថា:( ចូរពួកអ្នកជៀសវាងពីការរួមដំណេកជាមួយភរិយាក្នុងអំឡុងពេលមានរដូវ ហើយកុំទៅជិតពួកនាង(ដើម្បីរួមដំណេក) រហូតដល់ពួកនាងជ្រះស្អាត(អស់រដូវ ហើយងូតទឹកសម្អាត)ខ្លួនប្រាណសិន។ បើសិនជាពួកនាងជ្រះស្អាតហើយ នោះពួកអ្នកអាចរួមដំណេកជាមួយពួកនាងនៅត្រង់កន្លែង(ទ្វារមុខ)ដែលអល់ឡោះបានអនុញ្ញាតឲ្យពួកអ្នក។អាល់បាករ:២២២

## តើអ្នកមូស្លីម្រូតូវជ្រមះសម្អាតពីជូនុបនិងហាឌាសដ៏យ៉ាងដូចម្តេច?

គ្រប់គ្រាន់ស្រមាប់អ្នកមូស្លីមេដ៉ាយតាំងចិត្តសម្អាតខ្លួនបាណរបសេ់គ ហេ៊ីយចាក់ទឹកឱ្យសព្វេពព្រាបាណ។.

- ក៏ប៉ុន្តែដលេពញលក្ខណៈបំផុតគឺសម្អាតដូចេគេធ្វេ បន្ទាប់ពីបេន្ទាបង់រូច បន្ទាប់មកយកទឹកជ្រមះកាយ(ទឹករូវហ្វ) បន្ទាប់មកេទៀតេគ្រតូវចាក់េលើខ្លួនបាណរបសេ់គទាំងអស់ដេលនៅសល់ ធ្វើបែបេនះេគនឹងទទួលផលបុណ្យជាេច្រីន ព្រពះអុលេទ្បាះ េហើយវាស្របនឹងមាគ៌ារបស់ណាពីមូហាំម៉ាត់( សូមពរជ័យនិងសន្តិភាពេកើតមានដល់គាត់)។.
- េហើយេបើសិនជាអ្នកមូស្លីមងូតទឹកសម្អាតពីជូនុបរួចគឺជំនួសទឹកជ្រុំមះកាយ(ទឹករូវហ្វ) មិនចាំបាច់យកទឹកជ្រមះកាយេទៀតេទ។ ក៏ប៉ុន្តែជាការប្រេសើរគឺមុនទឹកេដលរួមទាំងយកទឹកជ្រមះកាយដូចជាមាគ៌ារបស់ណាពីមូហាំម៉ាត់(សូមពរជ័យនិងសន្តិភាពេកើតមានដល់គាត់)។.

## បុគ្គលេដលគ្មានលទ្ធភាពេប្រីបាស់ទឹកៈ

ប្រសិនេបើអ្នកមូស្លីមមិនអាចេប្រីបាស់ទឹកបានក្នុងការយកទឹកជ្រមះកាយឬងូតទឹកេដាយសារមានជំងឺឬគ្មានទឹកឬទឹកេប្រីបាស់មិនគ្រប់គាន េគេត្រូវេប្រីដីសម្អាតរហូតទាល់តមានទឹកឬអាចេប្រីបាស់ទឹកវិញបាន។

របៀបសម្អាតេដាយដី(តាយ៉ាំមុម) េគត្រូវយកេដទាំងពីរប៉ះនឹងដីចំនួនមួយដង បន្ទាប់មកេគ្រតូវជូតមុខរបសេ់គ បន្ទាប់មកេគ្រតូវជូតខ្នងេដស្តាំរបសេ់គេដាយបាតេដខាងេឆ្វងនឹងជូតខ្នងេដខាងេឆ្វងេដាយបាតេដខាងស្តាំ។



## ការជូតេលើស្រោមេជើងៈ

េដាយភាពងាយស្រួលក្នុងឥស្លាមអ្នកមូស្លីមអាចជូតេលើស្រោមេជើងឬេស្បកេជើងរបស់េគដលេគកំពុងពាក់េដាយេដទទឹករបសេ់គជំនួសការលាងទឹកបានក្នុងការយកទឹកជ្រមុះកាយ។ េត្រតូវមានលក្ខខណ្ឌមួយគឺគាត្រូវមានទឹកជ្រមះកាយខណៈេដលគាត់ពាក់ស្រោមេជើងឬេស្បកេជើងេនាះ។េហើយមានរយៈេពល២៤េម៉ាងស្រមាប់អ្នកេនៅផ្ទះនិង៧២េម៉ាងស្រមាប់អ្នកេដំេណើរ។

េចំណាក្នុងការងូតទឹកជូនុបវិញគឺចាំបាច់ត្រូវលាងេជើងទាំងសងខាងក្នុងគ្រប់ស្ថានភាពទាំងអស់។



# ការសឡាតរបស់អ្នក



# 3

ការសឡាតវ៉ាជាសួរស្រទូងរបស់សាសនា ហើយវាជាតំណភ្ជាប់របស់ខ្ញុំបរិនិងម្ចាស់របសេគ និងអ្នក្រគប្រ់គងេគ ហើយដូច្នោះដែរ វាជាការេគារពសក្ការៈដ៏ឧត្តុងឧត្តម និងជាកិច្ចការដ៏ល្អប្រេព ហើយពិតណាស់អលែឡាះបានប្រើឱ្យអ្នកមូស្លីមែថរក្សាទៅេលើវា រាល់កាលៈទេសរបសេគក្នុងេពលវត្តមាន ឬេធ្វដំេណើរ ពេលមានសុខភាព ឬពេលមានជំងឺ។

## មាតិការជំពូក


ឋានៈ និងគុណសម្បត្តិរបស់សឡាត
ផលបុណ្យៃនសឡាត
ការសឡាត ហ្វារឌូ ប្រាំពេល និងេពលេវលារបស់វា
ទីកែន្លងសឡាត
លក្ខណៈនៃសឡាត
តើខ្ញុំត្រូវសឡាតដូចេម្តច ?
គោលគ្រឹះនៃសឡាត និងការតព្វកិច្ចរបស់វា
- ប្រការដែលនាំឱ្យខូចសឡាត
- ប្រការដែលមិនគប្បើធ្វើពេលសឡាត
តើអ្វីទៅជាការសឡាតគប្បី ?
ការសឡាតជាក្រុម( សឡាតេដើម៉ាអះ )
អាហ្សាន( ការប្រកាសេហាឱ្យមកសឡាត )
កាគោរពយ៉ាង្រជាលេជ្រាក្នុងេពលសឡាត
ការសឡាតយុំអាត់
ការសឡាតរបស់អ្នកេធ្វើដំណើរ
ការសឡាតរបស់អ្នកឈឺ

# ការសឡាត



នៅក្នុងប្រភពដើមសឡាត មានអត្ថន័យថា: ការបួងសួង ហើយវាជាការតភ្ជាប់រវាងខ្ញុំបម្រើ និងម្ចាស់របស់គេនិងអ្នកបម្រើគេ។ហើយនៅក្នុងឈ្មោះនោះរួមមានអត្ថន័យនៃភាពជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិត្រប្រាកដ និងការងាកទៅរកអល់ឡោះ និងសុំជំនួយព្រទង់។ ហើយបួងសួងទៅចំពោះទ្រង់ សន្ទនាជាមួយទ្រង់ និងរលឹកដល់ទ្រង់ តែស្រមួលដោយខ្លួនឯងផ្ទាល់ និងនឹករលឹកអំពីធាតុពិតរបស់គេ និងធាតុពិតរបស់ពិភពលោកដែលគេកំពុងរស់នៅក្នុងវា។ហើយទទួលបានអារម្មណ៍ដ៏អស្ចារ្យចំពោះម្ចាស់របស់គេ និងការអាណិតស្រលាញ់របស់ទ្រង់ចំពោះគេ។ ហើយការសឡាតនេះនឹងជំរុញគាត់ឱ្យឆ្ពោះទៅរកការប្រកាន់ខ្ជាប់នឹងច្បាប់របស់អល់ឡោះ និងចៀសឆ្ងាយអំពីប្រការអយុត្តិធម៌ ប្រការអសីលធម៌ និងអំពើទុច្ចរិត។ ដូចអល់ឡោះបានមានបន្ទូលថា "ពិត្រប្រាកដណាស់ សឡាតអាចហាមឃាត់អំពីការប្រព្រឹត្តអសីលធម៌ និងអំពើទុច្ចរិត"។(ជំពូក អាល់អាំងកាពូត ឃ្លា ៤៥)

## ឋានៈ និងគុណសម្បត្តិរបស់សឡាត

សឡាតវាជាការគោរពសក្ការៈដោយប្រើប្រាស់រាងកាយដ៏ឧត្តុងឧត្តម និងជាកិច្ចការដ៏ល្អប្រពៃបំផុត។វាជាការគោរពសក្ការៈយ៉ាងទូលំទូលាយដែលរួមមានទាំងការប្រើប្រាស់ ចិត្ត គំនិត និងអណ្តាត។ ហើយលក្ខណៈពិសេសរបស់សឡាត បានស្តែងឱ្យឃើញនៅក្នុងកិច្ចការជាច្រើន ដូចជា:

### ស្រមាប់សឡាតគឺមានឋានៈខ្ពស់ជាងគេ:

1 វាជាគោលគ្រឹះទីពីរក្នុងចំណោមគោលគ្រឹះរបស់សាសនាឥស្លាម។ ដូចដែររ៉សូលុល្លោះបានមានប្រសាសន៍ថា "គេបានស្ថាបនាសាសនាឥស្លាមលើប្រាំប្រការៈ ធ្វើសាក្សីថាគ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈពិតគឺមានតែអល់ឡោះហើយណាពីមូហាំម៉ាត់ជាអ្នកនាំសាររបស់ទ្រង់ ហើយ បញ្ឈរសឡាត...."(អាល់ពូខរី ៨ មូស្លីម ១៦)។ ហើយគោលគ្រឹះនៃសំណង់គ្រប់ភពដើមដែលគេពឹងផ្អែកលើវា ហើយមិនអាចឈរបាននៅទ្របសិនបើគ្មានវា។.

2 ២- ភស្តុតាងនៃច្បាប់បានចាត់ទុកភាពខុសគ្នារវាងអ្នកមូស្លីម និងអ្នកគ្មានជំនឿគឺការបញ្ឈរសឡាត។ ដូចរ៉សូលុល្លោះបានមានប្រសាសន៍

“ពិតណាស់ភាពខុសគ្នារវាងបុរស និងស្ទីរិ និង ការគ្មានជំនឿគឺបោះបង់ចោលការសឡាត”(មូស្លីម ៨២)។ ហើយលោកបានមានប្រសាសន៍ទៀតថា “កិច្ចសន្យារវាងពួកយើង និងពួកគេគឺសឡាត ជនណាហើយដែលបោះបង់ចោលវា ពិតណាស់វាជាអ្នកគ្មានជំនឿ” (អាត់តៀរមីហ្ស៊ី ២៦២១ អាន់ណាសើអ៊ី ៤៦៣))

3 អល់ឡោះបានប្រើឱ្យថែរក្សាទៅលើវារាល់កាលៈទេសណាក៏ដោយ ក្នុងពេលធ្វើដំណើរ ពេលរវល់មាន ពេលមានសន្តិភាព ពេលមានសង្គ្រាម ពេលមានសុខភាពល្អ និងពេលមានជំងឺ ហើយប្រតិបត្តិវាទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ដូចអល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នកថែរក្សាសឡាតទាំងប្រាំពេល”។(អាល់ហ្ពាកេរ៉ោះ ២៣៨)។ ហើយទ្រង់បានពណ៌នាអំពីលក្ខណៈសម្បត្តិខ្លះរបស់ទាំងដែលមានជំនឿ ដោយមានបន្ទូលថា “ហើយបណ្ដាអ្នកដែលថែរក្សាការប្រតិបត្តិសឡាតរបស់ពួកគេ”។(អាល់មុមីនូន ៩))

## ផលប្រយោជន៍នៃសឡាត

មានការរាយការណ៍ជាច្រើនអំពីផលប្រយោជន៍នៃសឡាត អំពីភស្តុតាងនៅក្នុង គម្ពីរអាល់គួរអាន និងហាឌីស្ស មានដូចជា: :

1. គេលុបបំបាត់នូវផលបាប ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា “ការសឡាតប្រាំពេល និងការសឡាតយ៉ុមអាត់(សឡាតថ្ងៃសុក្រ) រហូតដល់យ៉ុមអាត់ ត្រូវបានគេលុបបំបាត់នូវផលបាបចន្លោះរវាងពួកវា លើកលែងតែផលបាបធំ”។(មូស្លីម ២៣៣ អាត់តៀរមីហ្ស៊ី ២១៤)

2. ២- វាជាពន្លឺបំភ្លឺសម្រាប់អ្នកមូស្លីមក្នុងជីវិតរបស់គេទាំងអស់ ជំរុញឱ្យគេប្រព្រឹត្តអំពើល្អ និងជៀសឱ្យឆ្ងាយពីប្រការអាក្រក់ ដូចអល់ឡោះបានមានបន្ទូលថា “ពិតប្រាកដណាស់ សឡាតហាមឃាត់អំពីការប្រព្រឹត្តិអសីលធម៌ និងអំពើទុច្ចរិត”។(អាល់អាំងកាពូត ៤៥)។ ហើយរ៉សូលុលឡោះបានមានប្រសាសន៍ថា “ការសឡាតគឺជាពន្លឺ”។(មូស្លីម ២២៣))

3. វានឹងត្រូវបានគេជំនុំជំរះដំបូងគេបង្អស់ក្នុងថ្ងៃបរលោក។ ប្រសិនបើវាល្អត្រឹមត្រូវហើយគេទទួលយកវា ទង្វើផ្សេងទៀតក៏គេទទួលដែរ ប្រសិនបើគេបដិសេធវាចោល គេនឹងបដិសេធចោលទាំងអស់ទង្វើដែលនៅសល់។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា “ អ្វីដែលគេជំនុំជំរះដំបូងគេបង្អស់ទៅលើមនុស្សនៅថ្ងៃបរលោកនោះ គឺសឡាត។ ប្រសិនបើវាល្អត្រឹមត្រូវ ទង្វើផ្សេងទៀតក៏ល្អត្រឹមត្រូវដែរ ប្រសិនបើវាមិនល្អវិញនោះ ទង្វើផ្សេងទៀតក៏មិនល្អត្រឹមត្រូវដែរ”។( អាល់មូកយេមូលអាសុត លីតតូបរ៉ានី ១៨៥៩))



> អល់ឡោះបានប្រើឱ្យថែរក្សាទៅលើសឡាតរាល់កាលៈទេសទាំងអស់របស់មនុស្ស សូម្បីតែក្នុងពេលសង្គ្រាម និងគ្រោះមហន្តរាយ។



សទ្បាតជាពេលវេលាដ៏ល្អដែលមានរសជាតិបំផុតស្រមាប់អ្នកមានជំនឿក្នុងខណៈពេលដែលគេសន្ទនាទៅចំពោះម្ចាស់របស់គេក្នុងពេលសទ្បាត

ហើយគេទទួលបានសន្តិភាព ភាពស្ងប់ស្ងាត់ និងការអារម្មណ៍ត្រេកត្រអាល ពីអល់ឡោះ

ហើយវាជារសជាតិដ៏ល្អប្រពៃបំផុតស្រមាប់ណាពីមូហាំម៉ាត់ ដូចលោកបានមានប្រសាសន៍ថា “ខ្ញុំចាត់ទុកភាពសប្បាយរីករាយរបស់ខ្ញុំនៅក្នុងពេលសទ្បាត”។(អាន់ណាសេអ៊ី ៣៩៤០)

ហើយលោកបានមានប្រសាសន៍ទៅចំពោះ ប៊ីឡាល ដែលជាអ្នកហៅមនុស្សឱ្យមកសទ្បាតថា “ សូមឱ្យយើងមានភាពស្ងប់សុខដោយសារវា ឱ ប៊ីឡាល”។(អាពូដោវូទ ៤៩៨៥)

មាននៅហើយណាពីមូហាំម៉ាត់នៅពេលដែលជួបរឿងពិបាកចិត្តអ្វីមួយលោកតែងតែទៅសទ្បាត”។(អាពូដោវូទ ១៣១៩)

## តើស្រមាប់អ្នកណាដែលចាំបាច់ត្រូវសទ្បាត?

សទ្បាតចាំបាច់ទៅគ្រប់បុគ្គលមូស្លីម មានសតិគ្រប់អាយុ មិនមែនជាអ្នកមករដូវ និងឈាមពេលសម្រាលកូនរួច ដោយមិនត្រូវសទ្បាតខណៈពេលដែលនាងមករដូវ ឬឈាមពេលសម្រាលកូនរួចឡើយ ហើយមិនត្រូវប្រតិបត្តិឡើងវិញនូវអ្វីដែលបានកន្លងផុតទៅក្រោយពីនាងបានជម្រះស្អាតបន្ទាប់ពីអស់ឈាមនោះ។(ចូរមើលទំព័រ)

ហើយគេកំណត់ថាគ្រប់អាយុនៅពេលដែលមានមួយក្នុងចំណោមសញ្ញាៗខាងក្រោមនេះ

| |
|---|
| មានអាយុ១៥ឆ្នាំ |
| ដុះរោមនៅកន្លែងប្រដាប់ភេទខាងមុខ ឬខាងក្រោយ |
| ចេញទឹកកាមក្នុងពេលគេង ឬពេលដឹងខ្លួន |
| ស្ត្រីមករដូវ ឬមានផ្ទៃពោះ |

## > តើអ្វីទៅជាលក្ខខណ្ឌដែលចាំបាច់ត្រូវមានវាមុនពេលសឡាត ?

1 ការជ្រះស្អាតអំពី ហាហ្ញីស និង្រងបការអាក្រក់: ហើយពិតណាស់ដូចបានបក្រសាយយ៉ាងក្បោះក្បាយរួចមកកេហើយ

2 ការបិទបាំង អៅរ៉ាត

គេដាក់លក្ខខណ្ឌក្នុងការបឹទបាំងេអៅរ៉ាតេដាយសំលៀកបំពាក់ ដែលមិនបង្ហាញឱ្យឃើញនូវរាងកាយច្បាស់លាស់ដោយមូលេហតុ វាខ្លី ឬស្តើងេទ្បើយ។

ហើយេអៅរ៉ាតមានប្រីបេភទ:

ស្ត្រី: អៅរ៉ាតរបស់ស្ត្រីដែលេពញវ័យក្នុងេពលសឡាត: ខ្លួនរបស់នាងទាំងមូល លើកែលងេតមុខ និង ប្រអប់ៃដរបស់នាង។

កូនេក្មង: កូនេក្មងតូចេអៅរ៉ាតរបស់វា: គឺកវ៍ខ្មាសទាំងពីរ( មុខ េក្រាយ )ប៉ុេណ្ណាះ។

បុរស: អៅរ៉ាត របស់បុរសែដលេពញវ័យ: គឺពីផ្ចិតរហូតដល់ជង្គង។

អុល្លេះទ្បាះបានមានបន្ទូលថា: “ឱកូនេចៅអាដាំ! ចូរពួកអ្នកលំអសំលៀកបំពាក់របស់ពួកអ្នកេនៅ រាល់ម៉ាស្ជិទ( េពលសឡាត )”។(អាល់អាក់រ៉ហ្វ ៣១ )។ ហើយការបឹទបាំងេអៅរ៉ាតគឺជាការលំអតិចតួចបំផុត។ ហើយអត្ថន័យរបស់ រាល់ម៉ាស្ជិទ: គឺរាល់េពលសឡាត។



> ចាំបាច់េលើស្ត្រីមូស្លីមក្នុងេពលសឡាត្រត្ូវបឹទបាំងខ្លួនរបស់នាងទាំងអស់េលើកែលងេតមុខ និង្រងបអប់ៃដរបស់នាងប៉ុេណ្ណាះ។

## 3 ត្រមងមុខទៅទិសគីបឡាត់

អល់ឡោះបានមានបន្ទូលថា “ហើយគ្រប់កន្លែងដែលអ្នកចេញដំណើរ( ហើយអ្នកចង់សឡាត) ចូរអ្នកត្រមង់មុខរបស់អ្នកទៅកាន់ទិសម៉ាស្ជិទិលហារ៉ម” ។( អាល់ហ្គាក់រ៉ោះ ១៤៩ )

- ហើយគីបឡាត់របស់អ្នកមូស្លីមគឺអាល់កាក់ហ្ពះអាល់មូសរ៉ហ្វះ ដែលបានកសាងដោយឪពុករបស់បណ្តាណាពី គឺ អ៊ីព្រហ៊ីម។ ហើយបណ្តាណាពីបានធ្វើបុណ្យហាជ្ជីនៅទីនោះ។ ហើយយើងទាំងអស់គ្នាបានដឹងហើយថាពិតណាស់វាគ្រាន់ជាថ្មមិនអាចបង្កគ្រោះថ្នាក់ និងមិនផ្តល់ផលប្រយោជន៍អ្វីឡើយ។ ក៏ប៉ុន្តែអល់ឡោះបានប្រើឱ្យយើងត្រមងមុខទៅរកវាក្នុងពេលសឡាត ដើម្បីរួបរួមអ្នកមូស្លីមទាំងអស់ទៅរកទិសតែមួយ និងគោរពសក្ការៈទៅចំពោះអល់ឡោះនឹងទិសមួយនោះ។.
- ជាកាតព្វកិច្ចលើអ្នកមូស្លីមត្រូវត្រមងមុខទៅរកកាក់ហ្ពះប្រសិនបើគេមើលឃើញវានៅពីខាងមុខរបស់គេ។ ចំណែកឯអ្នកដែលនៅឆ្ងាយគ្រប់គាន់ហើយសម្រាប់រូបគេត្រមងមុខទៅទិសម៉ាក្កះ។ ការងាកចេញបន្តិចក្នុងពេលត្រមងមុខមិនមានបញ្ហាឡើយ។ ណាពីបានមានប្រសាសន៍ថា “ចន្លោះរវាងទិសខាងកើតនិងទិសខាងលិចគឺគីបឡាត់”។(អាត់តៀរមីហ្សី ៣៤២)
- ប្រសិនបើគ្មានសមត្ថភាពក្នុងការត្រមងទិស ដោយសារជំងឺ ឬអ្វីផ្សេង កាតព្វកិច្ចត្រូវបានលើកលែង។ ដូចដែលគេបានលើកលែងទាំងអស់កាតព្វកិច្ចដោយការអសមត្ថភាព។ អល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នកកោតខ្លាចចំពោះអល់ឡោះទៅតាមលទ្ធភាពរបស់ពួកអ្នក”។(អាត់តាហ្គពុន ១៦)

## 4 ដល់ពេលសឡាត

វាគឺជាលក្ខខណ្ឌដើម្បីឱ្យការសឡាតបានត្រឹមត្រូវ។ ហើយសឡាតមិនត្រឹមត្រូវឡើយប្រើប្រតិបត្តិវាមុនពេលកំណត់នោះ ហើយហាមមិនឱ្យពន្យាពេលវាជាដាច់ខាត។ ដូចអល់ឡោះបានមានបន្ទូលថា “ពិតណាស់សឡាតជាកាតព្វកិច្ចមួយទៅលើបណ្តាអ្នកមានជំនឿ ដែលមានពេលកំណត់យ៉ាងច្បាស់លាស់”។(អាន់នីសាក ១០៣)

### ហើយគួរតែបញ្ជាក់នៅពេលដែលពេលវេលាបានមកដល់លើកិច្ចការដូចជា:

- ជាការល្អប្រសើរត្រូវប្រតិបត្តិសឡាតនៅពេលដំបូងរបស់វា
- ចាំបាច់ប្រតិបត្តិសឡាតក្នុងពេលរបស់វា ហើយហាមមិនឱ្យពន្យាពេលវាដោយមូលហេតុអ្វីក៏ដោយ។
- ជនណាដែលសឡាតបានកន្លងផុតវាដោយសារគេងលក់ ឬភ្លេច ចាំបាច់លើវារូសរាន់ក្នុងការប្រតិបត្តិវាសាឡើងវិញនៅពេលណាដែលវានឹកឃើញ។



> អល់ឡោះបានមានបន្ទូលថា “ពិត្រប្រាកដណាស់ សឡាតជាកាតព្វកិច្ចមួយទៅលើបណ្តាអ្នកមានជំនឿដែលមានពេលកំណត់យ៉ាងច្បាស់លាស់”។(អាន់នីសាក ១០៣)

## > សឡាតហ្វារឌូប្រាំពេល និងពេលវេលារបស់វា

អល់ឡោះបានដាក់កាតព្វកិច្ចចាំបាច់លើអ្នកមូស្លីមក្នុងមួយថ្ងៃថ្ងមួយយប់ប្រាំពេល វាជាសសរស្រទូងនៃសាសនា ហើយបញ្ជាក់យ៉ាងច្បាស់អំពីកាតព្វកិច្ចចាំបាច់លើវា ហើយបានកំណត់លើវានូវពេលវេលាច្បាស់លាស់ដូចមាននៅខាងក្រោម:



សឡាត អាល់ហ្វាជរី(ស៊ូពោះ): វាមានពីររ៉ក្អាត់ ពេលវេលារបស់វាចាប់ផ្តើមពីសីតរុណរះគឺការចាប់ផ្តើមចេញពន្លឺដំបូងនៅជើងមេឃ ហើយបញ្ចប់នៅពេលថ្ងៃរះ។



សឡាត អាហ្សុហរី(ស៊ូហ៊្វូរ): វាមានបួនរ៉ក្អាត់ ហើយពេលវេលារបស់វាចាប់ផ្តើមពីថ្ងៃរ ហើយបញ្ចប់នៅពេលដែលស្រមោលអ្វីម៉្យាងស្មើនិងខ្លួនវា។



សឡាត អាល់អាសរី: វាមានបួនរឹកអាត់ ហើយពេលវេលារបស់វាចាប់ផ្តើមពីផុតពេលសឡាត អាហ្សុហរី នៅពេលដែលស្រមោលអ្វីម៉្យាងស្មើនិងខ្លួនវា ហើយបញ្ចប់នៅពេលថ្ងៃលិច។ ហើយចាំបាច់ស្រមាប់អ្នកមូស្លីមរួសរាន់ក្នុងការប្រតិបត្តិសឡាតមុនពេលពន្លឺថ្ងៃចុះខ្សោយនិងមានពណ៌លឿង។



សឡាត អាល់មាគ្រិប(ម៉ោគ្រិប): វាមានបីរ៉ក្អាត់ ហើយពេលវេលារបស់វាចាប់ផ្តើមពីថ្ងៃលិចនិងបាត់រូបរាងរបស់វាពីជើងមេឃ ហើយបញ្ចប់នៅពេលដែលបាត់ពន្លឺក្រហមដែលបង្ហាញចេញបន្ទាប់ពីថ្ងៃលិច។



សឡាត អាល់អ៊ីសា(អ៊ីសា): វាមានបួនរ៉ក្អាត់ ហើយពេលវេលារបស់វាចាប់ផ្តើមពីពេលបាត់ពន្លឺក្រហម ហើយបញ្ចប់នៅពាក់កណ្តាលយប់ ហើយអាចប្រតិបត្តិវានៅពេលសីតរុណរះបានក្នុងករណីចាំបាច់ណាមួយ។

ចំពោះអ្នកមូស្លិមអាចពឹងផ្អែកលើប្រតិទិនទាំងឡាយដែលបញ្ជាក់ពីពេលវេលាសឡាត ហើយមិនចាំបាច់ឲ្យវាពិនិត្យមើលការដល់ពេលវេលាសឡាតដោយខ្លួនឯងឡើយ

## > កន្លែងសឡាត



សាសនាឥស្លាមបានប្រើឱ្យប្រតិបត្តិសឡាតជាមួយនិង្រ្គកុម ហើយត្រូវឱ្យមាននៅក្នុងម៉ាស្ជិទដើម្បីឱ្យមានការរួបរួមស្រមាប់អ្នកមូស្លីម ហើយបង្កើនចំណងបងប្អូននិងសេចក្ដីស្រលាញ់រវាងពួកគេ ហើយបានចាត់ទុកវានោះល្អប្រសើរជាងការប្រតិបត្តិសឡាតរបស់បុរសម្នាក់ឯងជាច្រើនកំរិត។ ដូចរ៉សូលុលលោះបានមានប្រសាសន៍ថា “ការសឡាតរួមគ្នា វាល្អប្រសើរជាងការសឡាតម្នាក់ឯងចំនួន២៧កំរិត”។(អាល់ពូខរី ៦១៩ មូស្លីម ៦៥០ អះម៉ាត់ ៥៩២១)

ក៏ប៉ុន្តែសឡាតនៅទីកន្លែងណាក៏ដោយក្រឹតម្រូវដែរ នេះហើយជាក្ដីមេត្តាករុណារបស់អល់ឡោះមកលើយើង។ ដូចរ៉សូលុលឡោះបានមាន្រប្រសាសន៍ថា “ហើយគេបានផ្ដល់ឱ្យខ្ញុំដីគឺជាម៉ាស្ជិទ និងជ្រះស្អាត បុរសម្នាក់ណាក៏ដោយអំព្រូបជាតិរបស់ខ្ញុំនៅពេលដែលដល់ពេលសឡាតចូរឱ្យវាសឡាតចុះ”។(អាល់ពូខរី ៣២៨ មូស្លីម ៥២១)

### លក្ខណៈនៃកន្លែងសឡាតៈ

ឥស្លាមបានដាក់លក្ខខណ្ឌចំពោះកន្លែងសឡាតគឺត្រូវឱ្យដីនោះជ្រះស្អាត អល់ឡោះបានមានបន្ទូលថា “ ហើយយើងបានបញ្ជារចំពោះអ៊ីព្រហ៊ីម និងអ៊ីស្មាអ៊ីលថា ចូរអ្នកទាំងពីរសំអាតកាក់ហ្ពះរបស់យើងស្រមាប់បណ្ដាអ្នកតវ៉ាហ្វ និងបណ្ដាអ្នកអៀកទីកាហ្វ និងបណ្ដាអ្នករ៉ូកុស៊ូជូត”។(អាល់ហ្ពាគោរ៉ះ ១២៥) ហើយប្រភពដើមរបស់វាគឺការជ្រះស្អាត ហើយប្រការអាក្រក់វាកើតតែឡើងមក។ អ្វីដែលមិនបានដឹងថាមានប្រការអាក្រក់ទេគកំណត់ថាជ្រះស្អាត ហើយមិនគប្បីយកកំរាល ឬក្រណាត់ឡើយ

ហើយមិនសឡាតេលើកែលងែតេនាលើវាេឡើយ។.

## ក្នុងេនាះេដរមានចំណុចជាេច្រើនែដលចាំបាច់ត្ូតពិនិត្យវានៅកែន្លងសឡាត ដូចជាៈ

1. កែន្លងសឡាតរបស់វាមិន្រតូវឱ្យមានការប៉ះពាល់ដល់មនុស្សេឡើយ ដូចជាការសឡាតេលើផ្លូវេដើរ និងកែន្លងឆ្លងកាត់ និងកែន្លងែដលហាមមិនឱ្យឈប់ែដលនាំឱ្យមានផលវិបាកនិងកក៏ស្ទះដល់មនុស្សេហើយរសូលុលេឡាះបានហាមឃាត់អំពីការរំេលាភបំពាន និងបង្កេគ្រាះថ្នាក់ េលាកម្ចាន្របស្សាសន៍ថា “កុំបង្កេគ្រាះថ្នាក់ដល់ខ្លួនឯង េហើយកុំបង្កេគ្រាះថ្នាក់ដល់អ្នកេដទ”។(អ៊ិពន្នូម៉ាយ៉ះ ២៣៤០ អះម៉ាត់ ២៨៦៥)

2. មិន្រតូវឱ្យមានក្ការបង្ករផលប៉ះពាលដល់អ្នកសឡាតេទៀយ ដូចជា មានរូបភាព ឬមានសេំលងលឺខ្លាំង និងសំេលងត្រន្តី។.

3. កែន្លងេនាះមិនែមនជាកែន្លងបង្ហាញពីការេគារពសក្ការៈេលងេសើច និងក្ការេសើចចំអកេឡើយ។ ដូចជាបុគ្គលម្នាក់សឡាតក្នុងកែន្លងផឹក្រសា ឬជ្រុលនិយម និងអ្វីផ្សេងេពីនេះេទៀត។ េហើយអលេឡាះបានហាមឃាត់អំពីការេជរប្រមាថដល់ព្រះរបស់អ្នកគ្មានជំេនឿ េព្រាះវាជាេហតុេធ្វើឱ្យពួកេគេជរប្រមាថអលេឡាះទាំងបំពានេដាយគ្មានចំេណះដឹង អលេឡាះបានមានបន្ទូលថា “ចូរពួកអ្នក(មូស្លីម)កុំេជរប្រមាថចំេពាះព្រះែដលពួកេគបួងសួងេផ្សងពីអលេឡាះឱ្យេសាះ េព្រាះវាជាេហតុេធ្វើឱ្យពួកេគេជរប្រមាថអលេឡាះទាំងបំពានេដាយគ្មានចំេណះដឹង”។(អាល់អាន់អាម ១០៨)

4. កែន្លងេនាះមិនែមនជាកែន្លងែដលេរៀបចំស្រមាប់ប្រព្រឹត្តអំេពើខុសឆ្គងនិងអលេឡាះេឡើយ ដូចជា ឌីស្កូ និងក្លឹបរាត្រី ែដលេគស្អប់េខ្ពើមសឡាតេនាក្នុងវា។



## > កន្លែងសឡាត



តើអ្នកអាចប្រតិបត្តិសឡាតក្នុងម៉ាស្ជីទរួមគ្នាបានដែរឬទេ ?

ទេ:

បាទ នេះ

បាទ: បញ្ជាក់លើបុរសម្នាក់ឱ្យប្រត្តិបត្តិសឡាតរួមគ្នាហើយវាជាទង្វើដ៏អស្ចារ្យ និងអល់ឡោះស្រលាញ់បំផុត ហើយគេក៏អនុញ្ញាតផងដែរលើស្ត្រី។

ប្រសិនបើអ្នកមិនអាចប្រតិបត្តិវាក្នុងម៉ាស្ជីទ តើកន្លែងផ្សេងទៀតមានគ្រោះថ្នាក់ដែរឬទេ ?

ទេ:

បាទ នេះ

គេហាមឃាត់មិនឱ្យសឡាតកន្លែងដែលមានប្រការអាក្រក់ឡើយ ហើយអល់ឡោះប្រើឱ្យយើងមានភាពជ្រះស្អាតក្នុងពេលសឡាត។

ប្រសិនបើកន្លែងមិនមានគ្រោះការអាក្រក់ តើការសឡាតនៅទីនោះមានផលប៉ះពាល់ដល់មនុស្សឬអត់ដូចជានៅលើផ្លូវរបស់ពួកគេ ?

ទេ:

បាទ នេះ

បាទ: គេហាមឃាត់មិនឱ្យបំពានលើមនុស្ស និងផ្តល់ភាពលំបាកដល់ពួកគេឡើយ សូម្បីតែក្នុងពេលសឡាតក៏ដោយ ចាំបាច់ស្រមាប់អ្នកត្រូវជ្រើសរើសកន្លែងផ្សេង។

តើកន្លែងនោះមានអ្វីដែលនាំឱ្យអ្នកពិបាកក្នុងការសឡាតែដរឬទេ ដូចជាមានរូបភាព ឬសំលេងលឺខ្លាំង ?

ទេ:

បាទ នេះ

ចាំបាច់ចេញឱ្យឆ្ងាយពីអ្វីដែលនាំឱ្យប៉ះពាល់ដល់អ្នកសឡាត និងការរំខានការសឡាត។

លក្ខណៈពិសេសរបស់របជាជាតិនេះ និងក្តីអាណិត្រសលាញ់ពីអល់ឡោះលើពួកគេ គឺផ្តល់ឱ្យការសឡាត្រតឹមត្រូវនៅកន្លែងណាក៏ដោយអំពើផនដើនេះ។

## > របៀបសទ្បាត



**1** នៀត ( ការប៉ង )

នៀត( ការប៉ង )ជាលក្ខខណ្ឌមួយដើម្បីឱ្យសទ្បាតបានត្រឹមត្រូវ មានន័យថាការប៉ងដោយចិត្តរបស់គេគោរពសក្ការៈទៅចំពោះអល់ឡោះនិងការសទ្បាត ដោយគេដឹងថាគេសទ្បាតម៉ាគរិប ឬអ៊ីសា ឧទាហរណ៍។ ហើយគេមិនបានកំណត់ឱ្យពោលនិងមាត់ទ្បើយក្នុងការប៉ងនេះ ផ្ទុយទៅវិញការប៉ងដោយចិត្តនិងគំនិតវាជាអ្វីដែលត្រូវការ ហើយការពោលដោយមាត់វាជាការខុសឆ្គងពីព្រោះវាគ្មានការនាំមកអំពីណាពីនិងសហាហ្ពះរបស់គាត់ទ្បើយ។.

**2** ឈរឱ្យត្រង់ដើម្បីសទ្បាត

ហើយសូត្រថា អល់ទ្បោះហ៊ូអ៊ីកេពើរ ហើយលើកដៃទាំងពីររបស់គាត់រហូតដល់ស្មាទាំងពីរ ឬខ្ពស់ជាងបន្តិច ហើយដាក់បាតដៃត្រឹមទិសគីបទ្បាត់។

ហើយការតឹកេពៀរមិនត្រឹមត្រូវទេលើងលែងតែសូត្រដោយពាក្យនេះ អល់ទ្បោះហ៊ូអ៊ីកេពើរ អត្ថន័យរបស់វា ការលើកតម្កើង និងសេចក្តីរុងរឿងចំពោះអល់ទ្បោះ។ អល់ទ្បោះខ្ពង់ខ្ពស់លើគប់អ្វីទាំងអស់ ខ្ពង់ខ្ពស់ជាងផែនដីនិងអ្វីដែលទាំងអស់នៅក្នុងវាអំពីការប៉ងប្រាថ្នានិងការសោយសុខ។ ចូរយើងបោះបង់ចោលរាល់ប្រការសប្បាយទាំងនោះ ហើយត្រូវផ្តោះទៅរកអល់ទ្បោះដែលមហាធំធេង និងខ្ពង់ខ្ពស់ក្នុងពេលសទ្បាតដោយចិត្ត និងសតិរបស់យើងដោយភាពកាតខ្លាច។



**3** បន្ទាប់ពី តឹកេពៀរ ដាក់ដៃខាងស្តាំរបស់គាត់លើដៃខាងឆ្វេងហើយដាក់លើដើមទ្រូង ហើយធ្វើដូច្នេះជានិច្ចក្នុងពេលឈរ។.

**4** គប្បីសូត្រ ឌូអាអ៊ីសតីហ្វតះ ( ស៊ុបហាណាកុលទ្បហ៊ុមមា វ៉ាពីហាំទីកា វ៉ាតាហ្ពារ៉ក្ខាសូមូកា វ៉ាតាអាទ្បា ចាត់ទូកា វ៉ាទ្បើអ៊ីទ្បើហេហ្គុយរូកា )។

( سبحانك اللهم وبحمدك، وتبارك اسمك، وتعالى جدك، ولا إله غيرك )

**5** សូត្រ ( អាអូហ្សូពីលទ្បាហ៊ីមីណាស៉ស្សតរ នៀរ៉ជីម )។

( أعـــــوذ بالله من الشيطان الرجيم )

ហើយនេះជាការសូត្រ អ៊ីស្ទីអាហ្សះ វាមានអត្ថន័យថា សុំការគេចចេញ និងថែរក្សាពីអល់ទ្បោះអំពីបការអាក្រក់របស់ ស្ហៃតន។

**6** សូត្រ ( ពីសមីលេទ្បើ ហៀរ៉ោះម៉ានៀរ៉ហ៊ីម )។

( بسم الله الرحمن الرحيم )

ហ្គាស់ម៉ាទ្បះ មានន័យថា ខ្ញុំចាប់ផ្តើមនូវការសុំជំនួយ ភាពចំរុងចំរើន និងនាមរបស់អល់ទ្បោះ។

**តើអ្នកមិនបានទន្ទេញ អាល់ហ្វាតីហះ និងហ្ស៊ីកៀរក្នុងសឡាតត្រូវធ្វើដូចម្ដេច?**

បុគ្គលណាដែលទើបចូលឥស្លាមថ្មី ហើយមិនបានទន្ទេញ អាល់ហ្វាតីហះ និងហ្ស៊ីកៀរក្នុងសឡាត ស្រមាប់គេមានដូចខាងក្រោម:

- គាត់ត្រូវខិតខំទន្ទេញ ហ្ស៊ីកៀរដែលចាំបាច់នៅក្នុងសឡាត ហើយសូឡាតមិនត្រឹមត្រូវជាដាច់ខាតលើកលែងតែជាភាសាអារ៉ាប់ មានដូចជា:
  (អាល់ហ្វាតីហះ) និង (អាត់តឹកេហៀរ) (ស៊ុបហាណា រ៉បពីយ៉ាល់ អាហ្ស៊ីម) និង (សើមីអុលឡហ៊ូ លីមាន់ហាមីហ្ទះ) និង (រ៉បេពើណាវ៉ាឡេ កើលហាំហ្ទ) និង (ស៊ុបហាណាំរ៉បពីយ៉ាល់ អាកេឡ) និង (រ៉ប់ពៀកេហ្វៀរលី) និងសូត្រតេពូល (អាត់តាស្ហាស៊ហ៊ូទ) និង (សលុំវ៉ាតេលើណាពី) និង (អាស់សាឡាមុំអាឡៃគុំ វ៉ារ៉ោះម៉ាតុលេឡោះ)។
- ចាំបាច់លើអ្នកមូស្លីម្រត្រូវសឡាត ទោះបីជាមិនទាន់ទន្ទេញចាំ ដោយឱ្យគាត់រំលឹកវ៉ានូវអ្វីដែលគាត់បានចាំអំពី តាស្រេហៀហ និង តះមីទ និងតឹកេពៀរក្នុងពេលដែលគាត់សឡាត ឬ រំលឹកឃ្លាដែលគាត់បានទន្ទេញក្នុងពេលឈរសឡាត ដូចអល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នកកោតខ្លាចទៅចំពោះអល់ឡោះទៅតាមលទ្ធភាពដែលពួកអ្នកមាន”។(អាត់តាហ្គរ៉ហ្គូន ១៦)
- ចាំបាច់ស្រមាប់គាត់ក្នុងខណៈពេលនេះព្យាយាមយ៉ាងខ្លាំងខ្លាក្នុងការសឡាតរួមគ្នា ដើម្បីអនុវត្តសឡាតរបស់គាត់ ពីព្រោះថា អ៊ីមាំទទួលរ៉ាប់រងទៅលើភាពខ្វះខាតរបស់ម៉ាក់មុំ។

**7** ៧- សូត្រ ស៊ូរ៉ោះ អាល់ហ្វាទីហះ។ ហើយ ហ្វាទីហះជាស៊ូរ៉ោះ ដ៏ថ្កុំថ្កើងបំផុតនៅក្នុងគម្ពីរបស់អល់ឡោះ។

- ហើយពិតណាស់អល់ឡោះបានផ្ដល់ឱ្យអ្នកនាំសាររបស់ទ្រង់ ដោយបញ្ជាក់វ៉ា ទ្រង់មានបន្ទូលថា “ហើយជាការពិតណាស់ យើងបានផ្ដល់ឱ្យអ្នក(ណាពីមូហាំម៉ាត់)ប្រាំពីរឃ្លានៃអាល់ម៉ាសានី(ស៊ូរ៉ោះអាល់ហ្វាទីហះ)រួមជាមួយនិងគម្ពីរគួរអានដ៏ឧត្ដុងឧត្ដម”។(អាល់ហ៊ីជ្ស៍ ៨៧) ហើយប្រាំពីរឃ្លានៃអាល់ម៉ាសានី វ៉ាជាអាល់ហ្វាទីហះ គេឱ្យឈ្មោះវ៉ាបែបនេះពីព្រោះវ៉ាមានប្រាំពីរឃ្លា។
- ចាំបាច់លើអ្នកមូស្លីម្រត្រូវសិក្សាពីវ៉ា ពីព្រោះការសូត្រវ៉ាជាជ្រុងមួយនៃការសឡាត ស្រមាប់អ្នកដែលសឡាតម្នាក់ឯង ឬជាអ្នកតាមអ៊ីម៉ាំក្នុងពេលសឡាតដែលអ៊ីម៉ាមិនសូត្រលឺ។.

**8** កំណត់ក្រោយពីសូត្រហ្វាទីហះចប់ ឬពេលស្ដាប់ការសូត្ររបស់អ៊ីម៉ាំចប់ សូត្រ (អាមីន) មានន័យថា ឱអល់ឡោះសូមលោកទទួលផងចុះ។

**9** សូត្របន្ទាប់ពីហ្វាទីហះក្នុងពីររ៉ក្អាត់ដំបូង ស៊ូរ៉ោះ ឬឃ្លាខ្លះៗអំពីស៊ូរ៉ោះផ្សេងទៀតៗ ចំនែករ៉ក្អាត់ទីបីទីបួនសូត្រតែហ្វាទីហះប៉ុណ្ណោះ។.

- សូត្រហ្វាទីហះ និងអ្វីដែលបន្ទាប់ពីវ៉ាដោយស្ញែលឺក្នុងពេលសឡាត អាល់ហ្វាជរ៍ និងពីររ៉ក្អាត់ដំបូងក្នុងសឡាត ម៉ោគរីប និង អ៊ីសា។ ហើយសូត្រតិចៗនៅក្នុងសឡាតស៊ូហ៊ូទ និងអាស៊េរ។.
- ចំណែកការហ្ស៊ីកៀរក្នុងសឡាត្រូវសូត្រតិចៗ

## ស៊ូរោះ អាល់ហ្វាទីហៈ មានអត្ថន័យដូចខាងក្រោម:

الْحَمْدُ لِلَّهِ رَبِّ الْعَالَمِينَ

រាល់ការសរសើរ គឺចំពោះអល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពទាំងអស់។

الرَّحْمَنِ الرَّحِيمِ

ជាម្ចាស់មហាសប្បុរស មហាអាណិត្រសលាញ់។

مَالِكِ يَوْمِ الدِّينِ

ជាស្តេច(គ្រប់គង)
នៃថ្ងៃជំនុំជំរះ(បរលោក)។

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ

ចំពោះទ្រង់តែមួយគត់តែដលពួកយើង
គោរពសក្ការៈ ហើយចំពោះទ្រង់តែមួ
យគត់ដែលពួកយើងសុំឱ្យជួយ។

اهدِنَا الصِّرَاطَ الْمُسْتَقِيمَ

សូមទ្រង់មេត្តាចង្អុលបង្ហាញដល់ពួក
យើងនូវមាគ៌ាដ៏ត្រឹមត្រូវផងចុះ។

صِرَاطَ الَّذِينَ أَنْعَمْتَ عَلَيْهِمْ

គឺមាគ៌ារបស់បណ្តាអ្នកដែលទ្រង់បានប្
រទានទៀតនេះមាតដល់ពួកគេ។

غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلاَ الضَّالِّينَ

ពុំមែនជា(មាគ៌ា)
អ្នកដែលត្រូវគេខឹងសម្បា
និង ពុំមែនជា(មាគ៌ា)
ពួកដែលវង្វេងឡើយ។





**10** បន្ទាប់មកតឹកេពៀរ ដើម្បីរ៉ូកុដោយឈើកែដទាំងពីរដល់ស្មា ឬលើសបន្តិច ដាក់បាតែដទាំងពីរត្រូវង់ទិសគីបឡាត់ ដូចែដរបានធ្វើវានៅតឹកេពៀរទីមួយ។

**11** រ៉ូកុកេដាយដាក់ខ្នងរបស់គាត់ត្រូវង់ទិសគីបឡាត់ ហើយដាក់ខ្នង និងក្បាលរបស់គាតេស្មើគ្នា ហើយដាកែដទាំងពីររបស់គាតេលើជង្គង់ទាំងពីររបស់គាត់ ហើយដសូត្រថា (ស៊ុបហា ណារ៉ប់ពីយ៉ាលី អាហ្ស៊ីម)។

(سبحان ربي العظيم)

គប្បីសូត្រតាសពីហសាឡើងវិញបីដង ការចាំបាច់តម្តងប៉ុណ្ណោះ ហើយរ៉ុកុជាកែន្លេងលើកតេម្កើង និងេសចក្តីរុងេរឿងចំេពាះអល់ឡោះ។

មានន័យថា ភាពស្អាតស្អំចំេពាះ(سبحان ربي العظيم)

អល់ឡោះដ៏ឧត្តុងឧត្តម និងល្អពិសិដ្ឋេចញពីភាពខ្វះខាត ហើយខ្ញុំសូត្រវានៅពេលែដលខ្ញុំរ៉ូកុបន្ទាបខ្លួន អោនលំទានចំេពាះអល់ឡោះ។



**12** ងើបពីរ៉ូកុហើយឈរត្រង់វិញដាយលើកែដទាំងពីរឱ្យស្មើនិងស្មាទាំងពីរ ហើយបាតែដរបស់គាត់ត្រូវង់ទិសគីបឡាត់ ដូចែដលបានេធ្វើ ហើយសូត្រ (សាមីអល់ឡ ហ៊្លូលីម៉ាន់ហាមីហ្ទះ)

(سمع الله لمن حمده)

ប្រសិនេបើជាអ៊ីម៉ាំ ឬសឡាតម្នាក់ឯង។ បន្ទាប់មកសូត្រទាំងអស់គ្នា ថា (រ៉ប់ហ្ពាណា វ៉ាឡើកាល់ហាំទ៍)

(ربنــا ولك الحمــد)

ហើយគប្បីស្រមាប់គាត់បែន្ថម ដោយសូត្រថា (ហាំហ្ទាន់កាសីរ៉ាន់ត័យយីហ្ពាន់មូបើរ៉ាក់ាន់ ហ្វីហ៊ី មីលអាស់សាម៉ាអ៊ី វ៉ាមីលអុលេអើរឌី វ៉ាមីលអាម៉ាស៊ីអតា មីន ែស្សអ៊ីនហ្ពាក់ទូ)។

(حمداً كثيراً طيباً مباركاً فيه، ملءَ السماء وملء الأرض... وملء ما شئت من شيء بعد)



13 បន្ទាប់មកតឹកេពៀរហើយត្រូវអោចុះទៅលើដីដោយស៊ូជោតេលើអវៃយវៈរបស់គាត់ទាំងប្រាំពីរ វាគឺ ថ្ងាស់ជាមួយច្រមុះ ដៃទាំងពីរ ជង្គង់ទាំងពីរ ជើងទាំងពីរ។ ហើយគួប្បីស្រមាប់គាត្រ់ត្ូវៃញក ដៃទាំងពីរឱ្យឃ្លាតពីដងខ្លួនបន្តិច និងៃញកេពោះឱ្យឃ្លាតពើភ្លៅទាំងពីរ និង ញែកេភ្លៅទាំងពីរឱ្យឃ្លាត ពើជើងទាំងពីរក្នុងេពលស៊ុទ្ជូត ហើយេលើកកំភួនៃដឱ្យផុតពីដី។.

ន

14 ហើយសូត្រក្នុងេពលស៊ូជោទថា
( ស៊ុបហា ណារ៉ប់ពីយ៉ាល់អាក់ឡា )
(سبحان ربي الأعلى)
ចាំបាច់តម្តងគត់ ហើយគប្បីសូត្រសាឡើងវិញបីដង។

ស៊ូជោទជាកែន្លងបួងសួងដ៏ល្អបំផុតេទៅចំពោះអល់ឡោះ ហើយមនុស្សបួងសួងេនៅក្នុងវាបន្ទាប់ពីសូត្រអ្វីដែលជាកាតព្វកិច្ច នូវអ្វីដែលគាត្រ់ត្ូវការអំព្រើបការល្អេនៅក្នុងេផនដី និងេថ្ងបរលោក។ រ៉សូលុល្លេឡាះបានមាន្របសាសន៍ថា “គំលាត្ជិតបំផុតរវាងខ្ញុំបេរនឹងម្ចាស់របស់វាគឺក្នុងេពលស៊ូជោទ ចូរពួកអ្នកបេញ្រៀនការបួងសួង”។( មូស្លីម ៤៨២ )

មានន័យថា ភាពល្អពិសិដ្ឋចំពោះ(سبحان ربي الأعلى) អល់ឡោះដែលខ្ពង់ខ្ពស់លើភាពខ្លាំងពូកែរបស់្រទង់ និងឥទ្ធិពលរបស់្រទង់ ហើយភាពខ្ពង់ខ្ពស់លើមយទាំងអស់ ដោយឃ្លាតឆ្ងាយពីរាល់ភាពខ្វះខាត និងការអសមត្ថភាព។ នៅក្នុងវាដែរគឺផ្តល់ការប្រុង្របយ័ត្នស្រមាប់អ្នកស៊ូជោទ ដោយការភ្ជាប់ខ្លួនេទៅនិងដីដោយការេអានលើទាន នឹងស្តាប់បង្គាប់េដើម្បីនឹករលឹកពីភាពខុសគ្នារវាងគាត់នឹងអ្នកបេង្កើតគាត់ដ៏ខ្ពង់ខ្ពស់( ព្រះអល់ឡោះ ) ហើយបន្ទាបខ្លួនេទៅចំេពាះម្ចាស់របស់គាត់ និងេអានលើទានេទៅចំេពាះអ្នក្រគប់្រគងគាត់។

15 បន្ទាប់មកតឹក្កេពៀរ ហើយេងើបអង្គុយរវាងស៊ូជោទទាំងពីរ គប្បីស្រមាប់គាត់អង្គុយេលើជើងខាងេឆ្វងរបស់គាត់ ហើយេជើងស្តាំដាក់សណ្តូកតង់ ហើយដាក់ៃដទាំងពីរ េលើភ្លៅទាំងពីរបន្ទាប់ពីជង្គង់។.



- ហើយរាល់ការអង្គុយក្នុងសាឡាតទាំងអស់គួបប្រើត្ូវេធ្វើតាមរេបៀបេនះក្នុងេពលអង្គុយេលើកលែងតេពលអង្គុយ អាត់តាសាស់ហ៊ូទចុងេក្រាយ គួប្បីស្រមាប់គាត់ដាក់ជើងស្តាំសណ្តូកតង់ដូចគ្នាដែរ ក៏ប៉ុន្តែដាក់ជើងេឆ្វងពើក្រោមវា ហើយអង្គុយេនៅេលើដី។ .
- បុគ្គលណាដែលមិនអាចអង្គុយក្នុងេពលសឡាតដូចរេបៀបដេលគបានេរៀបរាប់ ដូចជាអង្គុយអាត់តាសាសហ៊ូទដំបូង ឬអាត់សាសហ៊ូទចុងេក្រាយ ដោយមានការឈឺចាប់្រតង់ជង្គង់

ឬដោយសារគាត់មិនអាចធ្វើវាបាន ចូរអង្គុយយ៉ាងមិចឱ្យមានភាពស្រួលតាមបែបណាមួយ អង្គុយរបស់គាត់។



16 សូត្រក្នុងពេលអង្គុយរវាងស៊ូជោទទាំងពីរថា (រ៉ប់ពៀកេហ្វៀរលី)

(ربي اغفر لي)

ហើយគប្បីស្រមាប់គាត់សូត្រសារឡើងវិញបីដង

17 បន្ទាប់មកស៊ូជោទលើកទីពីរដូចស៊ូជោទលើកទីមួយដែរ។.

18 បន្ទាប់មកងើបពីស៊ូជោទទីពីររហូតដល់ឈរត្រង់ដោយសូត្រ អល់ឡហ៊ូអឹកពើរ

(الله أكبر)

19 ហើយសឡាតរ៉ឹកអាត់ទីពីរដូចទីមួយដែរ.

20 ក្រោយពីស៊ូជោទទីពីរ ក្នុងរ៉ឹករ៉ក្អាត់ទីពីរហើយ ត្រូវអង្គុយ អាត់តាសាសហ៊ូទដំបូង ដោយសូត្រ (អាត់តាហីយ៉ា តូលីលឡះ វាស់សុឡាវ៉ាតូ វ៉ាត់ត័យយីហ្ពាត អាស់សាឡាមូអាឡៃកែអយូហាន់ណាពីយូ វ៉ារ៉ោះម៉ាតុលឡហ្ពីវ៉ាហ្ពារ៉កាតុះ អាស់សាឡាមូអាឡៃណាវ៉ាអាឡេឡ អ៊ីហ្ពាទីល្លេឡ ហ៊ុស្សលីហ៊ីន អាស៊ើហ៊ើទូ អាល់ឡាអ៊ីឡាហ៍អ៊ិលឡលលឡះ វ៉ាអាស៊ើហ៊ើទូអាន់ណាមូហាំម៉ាហ្ពាន់អាប់ទូហ៊ូវ៉ារ៉ស៊ូលុះ)។

(التحيات لله والصلوات والطيبات، السلام عليك أيها النبي ورحمة الله وبركاته، السلام علينا وعلى عباد الله الصالحين، أشهد أن لا إله إلا الله، وأشهد أن محمدا عبده ورسوله).

21 បន្ទាប់មកងើបឈរឡើងវិញដើម្បីបំពេញសឡាតដែលនៅសល់ ប្រសិនបើវាជាសឡាតបី ឬបួនរ៉ក្អាត់។ ដោយគ្រាន់តែគាត់សូត្រក្នុងរ៉ក្អាត់ទីបី និងទីបួននៃតហ្វាតីហះប៉ុណ្ណោះ។

ចំណែកឯសឡាតពីររ៉ក្អាត់ ដូចជាសឡាត អាល់ហ្វាជរី គឺត្រូវ អង្គុយអាត់តាសាសហ៊ូទចុងក្រោយ ដូចដែលមានបន្ទាប់នេះ។

22 បន្ទាប់មកក្នុងរ៉ឹកអាត់ចុងក្រោយបន្ទាប់ពីស៊ូជោទទីពីរអង្គុយ អាត់តាសាសហ៊ូទចុងក្រោយ ហើយរបៀបសូត្ររបស់វាគឺដូច អាត់តាសាសហ៊ូទដំបូងដែរ ដោយគ្រាន់តែថែម ការសលវ៉ាតទៅលើណាពីប៉ុណ្ណោះ ហើយរបៀបសូត្រនោះគឺ (អល់ឡហ៊ុម្មម៉ាសល់លីអាឡេឡ មូហាំម៉ាត់ វ៉ាអាឡេឡ អាលីមូហាំម៉ាត់ កេម៉ាសល់លៃតាអាឡេឡ អ៊ីប្រពហ៊ីម វ៉ាអាឡេឡ អាលីអ៊ីប្រពហ៊ីម អ៊ីនណាកេ ហាមីទុំម៉ាជីទ វ៉ាពើរីកអាឡេឡ មូហាំម៉ាត់ វ៉ាអាឡេឡអាលីមូហាំម៉ាត់ កេម៉ាពើរីកតា អាឡេឡអ៊ីប្រពហ៊ីម វ៉ាអាឡេឡ អាលីអ៊ីប្រពហ៊ីម អ៊ីនណាកេ ហាមីទុំម៉ាជីទ)។

(اللهم صل على محمد وعلى آل محمد كما صليت على إبراهيم وعلى آل إبراهيم إنك حميد مجيد، وبارك على محمد وعلى آل محمد كما باركت على إبراهيم وعلى آل إبراهيم إنك حميد مجيد)

ហើយគប្បីស្រមាប់គាត់សូត្របន្ទាប់ពីនោះថា (អាអ៊ូស្សូពីលេឡៃហ៊ី មិន អាហ្សាបពី ជើហាន់ណាំ វ៉ាមិន អាហ្សាបពីល កប៊រី វ៉ាមិន ហ្វិតណាតីល ម៉ះយ៉ា វ៉ាលម៉ាម៉ាត វ៉ាមិន ហ្វិតណាតីល ម៉ាស៊ីហ៊ីទេទើជេជើល)។

(أعوذ بالله من عذاب جهنم، ومن عذاب القبر، ومن فتنة المحيا والممات، ومن فتنة المسيح الدجال)

ហើយបួងសួងនូវអ្វីដែលគេស្រលាញ់

**23** បន្ទាប់មកងាកេ់ទៅទិសខាងស្តាំហើយសូត្រថា អាស់សាឡាមមុ៉ូ អាឡៃគុំវ៉ារ៉ោះម៉ាតុលេឡោះ។

(السلام عليكم ورحمة الله)

បន្ទាប់មកបែរទៅទិសខាងឆ្វេងរួចសូត្រដូចគ្នា។
និងការឱ្យសាឡាមការសឡាតរបស់អ្នកមូស្លីមត្រូវបានបញ្ចប់ ដូចរ៉ស៊ូលុលេឡោះបានមានប្រសាសន៍ថា “ការហាមឃាត់របស់វាគឺបន្ទាប់ពីតីកេពៀរ ហើយការអនុញ្ញាតរបស់វាបន្ទាប់ពី សាឡាម”។(អាពូទើវ៉ូទ ៦១ អាត់តៀរមីហ្ស៊ី ៣) មានន័យថាការចូលក្នុងសឡាតដោយ តីកេពៀរដំបូង ហើយចេញពីសឡាតវិញដោយការឱ្យសាឡាម។

**24** គប្បីស្រមាប់អ្នកមូស្លីមក្រោយអំពីសាឡាមែនសឡាតហ្វារហ្គូ ត្រូវសូត្រ: :

1. (អាស់តាគេហ្វៀរ៉ូលេឡោះ) បីដង

(أستغفر الله)



2. ហើយសូត្រ (អល់ឡហ៊ុម្មម៉ាអាន់តាស្សាឡាម វ៉ាមីនកាសសាឡាម តាពើរីកតាយ៉ា ហ្សៃលជើឡៃលី វ៉ាលអ៊ីករ៉ម)។

(اللهم أنت السلام ومنك السلام تباركت يا ذا الجلال والإكرام)

(អល់ឡហ៊ុម្មម៉ាឡៃ ម៉ានីអា លីម៉ា អាក់តៃយតា វ៉ាលើមុកតីយ៉ា លីម៉ា ម៉ាណាកតា វ៉ាឡៃ យ៉ាន់ហ្វាអ៊ូ ហ្សៃលជើទទីមិនៃកើលេជើទ)។

(اللهم لا مانع لما أعطيت ولا معطي لما منعت ولا ينفع ذا الجد منك الجد)

3. បន្ទាប់មកសូត្រ (ស៊ុបហានុលេឡោះ) ចំនួន៣៣ដង

(سبحان الله) (អាល់ហាំទូ លីលេឡៃហ) ចំនួន៣៣ដង

(الحمد لله) (អល់ឡហ៊ូ អឹកេពើរ) ចំនួន៣៣ដង

(الله أكبر) ហើយបំពេញឱ្យគ្រប់មួយរយដោយសូត្រថា (ឡៃអ៊ីឡៃហ៊ី អ៊ីលលុលេឡោះ វ៉ះទើហ៊ូ ឡៃស៊ើរីកើឡះ ឡៃហ៊ុលម៉ូលគូ វ៉ាឡៃហ៊ុល ហាំឌូ វ៉ាហ៊ូវ៉ា អាឡៃ គុលលើសអ៊ីន កេឌៀរ)។

(لا إله إلا الله وحده لا شريك له، له الملك وله الحمد وهو على كل شيء قدير).

## > តើខ្ញុំត្រូវសឡាតដូចម្តេច ? ( ការឈរ-ការរ៉ូកុ-ការស៊ូជោទ )

1



ឈរឱ្យត្រង់ ហើយសូត្រថា ( អល់ឡោះហួអឹកពើរ ) ហើយលើកដៃទាំងពីររបស់គាត់ដាក់ចន្លោះរវាងស្មាទាំងពីរ និងត្រចៀកទាំងពីរ។

2



ដាក់ដៃខាងស្តាំរបស់គាត់លើដៃខាងឆ្វេងហើយដាក់លើដើមទ្រូង ហើយសូត្រស៊ូរ៉ោះហ្វាតីហះ និងសូត្រជាមួយវាផងដែរអ្វីដែលអ្នកចេះអំពីគួរអាន ក្នុងរ៉កាត់ទី១ និងទី២។

3



គឺកោងឱនដោយលើកដៃទាំងពីររបស់គាត់ បន្ទាប់មកបន្ទន់ខ្នងរបស់គាត់ត្រឹមផ្ទៃទាំទិស គឺបទ្បាត្ត ហើយដាក់បាតដៃទាំងពីរលើជង្គង់ទាំងពីររបស់គាត់ ហើយសូត្រថា ( ស៊ុបហាណារ៉ប្ពីយ៉ាល អាហ្ស៊ីម ) បីដង ( سبحان ربي العظيم )



4 ងើបពីរ៉ូកៀហើយឈរឱ្យត្រង់វិញ ដោយលើកដៃទាំងពីរឱ្យដូចពេលតឹកបៀរ ហើយសូត្រ ( សាមិអល់ឡហ៊្លលិមាន់ហាមីហ្ទុះ ) ប្រសិនបើជាអ៊ីម៉ាំ ឬសឡាតម្នាក់ឯង
( سمع الله لمن حمده )
បន្ទាប់មកសូត្រទាំងអស់គ្នាថា ( រ៉បប៉ាណា វ៉ាឡេកាល់ហាំទ៍ )
( ربنــــا ولك الحمـــــد )

5 បន្ទាប់មកតឹកបៀរដោយមិនលើកដៃទាំងពីរហើយអានចុះទៅស៊ូជោទ ហើយត្រូវស៊ូជោទលើអវយវៈរបស់គាត់ទាំងប្រាំពីរ វាគឺ ថ្ងាស់ជាមួយច្រមុះ ដៃទាំងពីរ ជង្គង់ទាំងពីរ ជើងទាំងពីរ។
ហើយសូត្រថា ( ស៊ុបហា ណារ៉ប់ពីយ៉ាល់អាក់ឡេ ) បីដង
( سبحان ربي الأعلى )





6 បន្ទាប់មកអង្គុយរវាងស៊ូជោទទាំងពីរ ជើងស្តាំដាក់សណ្តូកត្រង់ ហើយអង្គុយលើជើងខាងឆ្វេង ហើយដាក់ដៃទាំងពីរលើគុលេក្លៅ ហើយសូត្រថា រ៉ប់ពៀកេហ្វៀរលី បីដង
( ربي اغفر لي )
បន្ទាប់មកស៊ូជោទម្តងទៀត ធ្វើដូចមុន។





## > តើខ្ញុំត្រូវសឡាតដូចម្តេច ?(រ៉ក្អាត់ទីពីរ-អាត់តាសាស់ហ៊ូទ-សាឡាម)

7

ងើបអំពីស៊ូជោទ ហើយឈរឡើងដើម្បីសឡាតរ៉ក្អាត់ទីពីរ ហើយប្រតិបត្តិវាដូចរ៉ក្អាត់ទីមួយដែរ ការឈរ ការសូត្រ ការរ៉ូកុ ការងើបពីវា និងការស៊ូជោទ។



8

ក្រោយពីស៊ូជោទលើកទីពីរនៃរ៉ក្អាត់ទីពីរ គាត់ត្រូវអង្គុយ អាត់តាស្ហាស់ហ៊ូទដំបូងដូចជាការអង្គុយរវាងស៊ូជោទទាំងពីរ ហើយសូត្រថា (អាត់តាហីយ៉ាតុ លីល្លាហ៍ វ៉ាស់សឡាវ៉ាតុ វ៉ាត់តុយយីបាត អាស់សាឡាមុអាឡៃកើអយូហាន់ណាពីយូ វ៉ារ៉ោះម៉ាតុល្លហ៍ វ៉ាបារ៉ាកាតុះ អាស់សាឡាមុអាឡៃណាវ៉ាអាឡា អ៊ីបាទិល្លាហ៍ ហ្ស៊ូលីហ៊ីន អាស្ហាទូ អាល់ឡាអ៊ីឡាហាអ៊ីល្លាល់ឡោះ វ៉ាអាស្ហាទូអាន់ណាមូហាំម៉ាដាន់អាប់ទូហ៊ូវ៉ារ៉ស៊ូលុះ)។

التحيات لله والصلوات والطيبات السلام عليك أيها النبي ورحمة الله وبركاته السلام علينا وعلى عباد الله الصالحين أشهد أن لا إله إلا الله وأشهد أن محمداً عبده ورسوله ).

9

ប្រសិនបើវាជាសឡាតមានបី ឬបួនរ៉ក្អាត់ ត្រូវឈរឡើងដើម្បីសឡាតរ៉ក្អាត់ទីបី ហើយប្រតិបត្តិវាដូចរ៉ក្អាត់ទីមួយនិងទីពីរដែរ ក៏ប៉ុន្តែមិនសូត្រស៊ូរ៉ោះផ្សេងទៀតបន្ទាប់ពីហ្វាតីហ៊ះចំណែកឯកាយវិកា និងការសូត្រផ្សេងទៀតធ្វើដូចមុន។



**10** នៅក្នុងរ៉កាត់ ចុងក្រោយ
គាត្រូវអង្គុយក្រោយពីស៊ូជោទ
ហើយសូត្រ អាត់តាស្ហាស់ហ្ហ៊ុទដំបូង
បន្ទាប់មកសូលវ៉ាតេលើណាពី
ហើយរបៀបសូត្រនោះគឺ (អល់ឡហ៊ុម្ម៉ាសល់លីអាឡា មូហាំម៉ាត់ វ៉ាអាឡា
អាលីមូហាំម៉ាត់ កើម៉ាសល់ឡតាអាឡា
អ៊ីប្រពហ៊ីម វ៉ាអាឡា អាលីអ៊ីប្រពហ៊ីម
អ៊ីនណាកើ ហាមីទុំម៉ាជីទ វ៉ាពើរីកអាឡា
មូហាំម៉ាត់ វ៉ាអាឡាអាលីមូហាំម៉ាត់
កើម៉ាពើរីកតា អាឡាអ៊ីប្រពហ៊ីម
វ៉ាអាឡា អាលីអ៊ីប្រពហ៊ីម អ៊ីនណាកើ
ហាមីទុំម៉ាជីទ)។
(اللهم صلي على محمد وعلى آل محمد كما صليت
على إبراهيم وعلى آل إبراهيم إنك حميد مجيد،
وبارك على محمد وعلى آل محمد كما باركت على
إبراهيم وعلى آل إبراهيم إنك حميد مجيد).





**11** បន្ទាប់មកឱ្យសាឡាមដោយ
ងាកមុខបែរទៅទិសខាងស្តាំ សូត្រថា (អាស់សាឡាមម៉ូ
អាឡៃគុំវ៉ារ៉ោះម៉ាតុលឡោះ)។
(السلام عليكم ورحمة الله)
បន្ទាប់មកបែរទៅទិសខាងឆ្វេង
សូត្រថា (អាស់សាឡាមម៉ូ
អាឡៃគុំវ៉ារ៉ោះម៉ាតុលឡោះ)។
(السلام عليكم ورحمة الله).

## > គោលគ្រឹះនៃសឡាត និងកាតព្វកិច្ចរបស់វា

គោលគ្រឹះនៃសឡាត: គឺចំណែកគោលរបស់សឡាតដែលសឡាតនិងត្រូវខូចប្រសិនបើបោះបង់វាដោយចេតនា ឬអចេតនា។.

### វាមានដូចខាងក្រោមនេះ

តក់ពៀរ៉តុលអេះរ៉ម ការឈរជាមួយនិងលទ្ធភាព សូត្រហ្វាតីហះស្រមាប់អ្នកមិនមែនជាម៉ាកមុំ ការរ៉ូកុ ការងើបពីរ៉ូកុ ស៊ូជោទ អង្គុយរវាងស៊ូជោទទាំងពីរ អាត់តាសាស់ហ៊ូទចុងក្រោយ និងការអង្គុយក្នុងវា ភាពនឹងនរ ឱ្យសាឡាម។

កាតព្វកិច្ចនៃសឡាត: វាគឺជាចំណែកដែលចាំបាច់ក្នុងសឡាត ហើយធ្វើឱ្យសឡាតខូចបានបើបោះបង់វាដោយចេតនា ក៏ប៉ុន្តែប្រសិនបើភ្លេច ឬអចេតនា គេកំណត់ឱ្យវាបំពេញកន្លែងចន្លោះនោះដោយស៊ូជោទ សះវី។ ដូចដែលនឹងត្រូវបានពន្យល់ពេលក្រោយ

### កាតព្វកិច្ចនៃសឡាតមានដូចខាងក្រោម

តក់ពៀរ៉ទាំងអស់ផ្សេងពីតក់ពៀរ៉តុលអេះរ៉ម ការសូត្រ ស៊ុបហាណារ៉ប្ពីយ៉ាលអាហ្ស៊ីមម្តងគត់ ការសូត្រ សើមីអល់ឡហ៊ូលីម៉ាន់ហាមីហ្ទះ ស្រមាប់ម្នាក់ឯង និងអ៊ីម៉ាំ ការសូត្រ រ៉ប់ប៉ាណាវ៉ាឡាកាល់ហាំទ ស្រមាប់ទាំងអស់គ្នា ការសូត្រ ស៊ុបហាណារ៉ប់ពីយ៉ាលអាក់ឡា ម្តងគត់ក្នុងពេលស៊ូជោទ ការសូត្រ រ៉ប់ពៀគហ្វៀរលី ម្តងគត់ក្នុងពេលអង្គុយរវាងស៊ូជោទទាំងពីរ អាត់តាសាស់ហ៊ូទដំបូង។ កាតព្វកិច្ចទាំងនេះប្រសិនបើភ្លេចដោយអចេតនា ចាំបាច់ត្រូវស៊ូជោទ សះវី។



> គេលើកកំរិតអ្នកសឡាតនិងបន្ថែមនូវផលបុណ្យដល់គាត់ទៅការអានលំទោនរបស់គាត់ចំពោះអល់ឡោះ និងចេញឆ្ងាយពីអ្វីដែលនាំឱ្យគាត់គិតផ្សេងពីសឡាត។

## ស៊ូជោទសះរី

វាជាការស៊ូជោទពីរដងៃដលអលេ់ឡាះបានដាក់វាដើម្បីបំពេញភាពខ្វះខាត និងេធ្វស្របបែហសក្នុងសឡាត។.

ត្រើតូវអនុវត្តវានៅពេលណា ?

គ្រេតូវអនុវត្តស៊ូជោទសះរីក្នុងករណីដូចខាងេក្រាម:

1. ប្រសិនេបើមនុស្សបានែថមក្នុងសឡាត រ៉ូកុ ឬស៊ូជោទ ឬឈរ ឬអង្គុយ ដោយមូលេហតុេភ្លច ឬខុស គ្រេតូវស៊ូជោទសះរី។
2. ប្រសិនេបើបាត់បង់អ្វីមួយអំពើគាល្គេះ ចាំបាច់ឱ្យគាត្រ់តឡប់េទៅបំពុញេគាលគ្រេះនោះ េហើយត្រូវស៊ូជោទសះរី នៅចុងេក្រាយែនសឡាតរបស់គាត់។
3. ប្រសិនេបើបោះបង់កាតព្វកិច្ចមួយអំពីកាតព្វកិច្ចែនសឡាតដូចជា អាត់តាសាសហ៊ូទដំបូង ដោយេធ្វស្របបែហស និងេភ្លចពិតណាស់គាត្រ់តូវស៊ូជោទសះរី។
4. ប្រសិនេបើមានការសង្ស័យក្នុងចំនួនរ៉ាក្អាត់ ពិតណាស់គាត្រ់តូវេជ្រើសេរីសេលើការេជឿជាក់េហើយវាគឺចំនួនតិច េហើយត្រូវស៊ូជោទសះរី។.

េរៀបស៊ូជោទសះរី: ស៊ូជោទពីរដងេដាយអង្គុយរវាងវាទាំងពីរ ដូចជាក្នុងការស៊ូជោទនិងអង្គុយរវាងស៊ូជោទទាំងពីរក្នុងេពលសឡាត។.

េពលស៊ូជោទ: ស្រមាប់ស៊ូជោទសះរីមានពីរេពល េហើយអាច្របតិបត្តិវាក្នុងេពលមួយណាក៏បាន:

- មុនេពលឱ្យសាឡាម េហើយេក្រាយ អាត់តាសាសហ៊ូទចុងេក្រាយ គាត្រ់តូវស៊ូជោទ បន្ទាប់មកឱ្យសាឡាម។.
- េក្រាយេពលឱ្យសាឡាមអំពីសឡាត គាត្រ់តូវស៊ូជោទសះរីពីរដង បន្ទាប់មកឱ្យសាឡាមម្តងេទៀត។



> មិនគប្បីកកេះរុះរើដៃនិងមុខលេងក្នុងពេលសឡាតឡើយ។

## ប្រការដែលនាំឱ្យខូចសឡាត

1. សឡាតនិង្រតូវខូច ដោយការបោះបង់គោលគ្រឹះ ឬលក្ខខណ្ឌ ដោយកំណត់ថាបានធ្វើវាដោយចេតនា ឬអចេតនាក៏ដោយ។.

2. សឡាតនិង្រតូវខូចដោយការបោះបង់កាតព្វកិច្ចមួយនៃកាតព្វកិច្ចសឡាតដោយចេតនា។.

3. សឡាតនិង្រតូវខូចដោយការនិយាយដោយចេតនា។

4. សឡាតនិង្រតូវខូច ដោយការសើចឮសំលេង។.

5. សឡាតនិង្រតូវខូចដោយកាយវិការច្រើនជាប់ៗគ្នាដោយគ្មានការចាំបាច់។.

## ប្រការដែលមិនគប្បីធ្វើពេលសឡាត

វាជាទង្វើដែលនាំឱ្យខាតផលបុណ្យនៃសឡាត និងនាំឱ្យបាត់បង់ភាពនឹងនរ និងការកោតខ្លាច ហើយវាមានដូចខាងក្រោមនេះ:

1. មិនគប្បីងាកមុខនៅក្នុងសឡាត ពីព្រោះណាពីត្រូវបានគេសួរអំពីការងាកនៅក្នុងសឡាត ?លោកបានឆ្លើយថា “វាគឺជាការកញ្ឆក់មួយ ដែលស្ហៃតននឆក់យកសឡាតរបស់មនុស្ស”។(អាល់ពូខរី ៧១៨)។

2. មិនគប្បីកកេះរុះរើដៃនិងមុខលេង និងដាក់ដៃលើចង្កេះ និងស្ងូក្រមាមែដចូលគ្នាហើយកាច់វាឡើយ។

3. មិនគប្បីក្នុងពេលកំពុងសឡាត ចិត្តរបស់គាត់គិតពីអ្វីផ្សេង ដោយត្រូវការទៅបន្ទប់ទឹក ឬត្រូវការចំណីអាហារ។ ដូចដែររ៉សូលុលឡោះបានមានប្រសាសន៍ថា “គ្មានទេការសឡាតនៅពេលគេលើកអាហារមកដល់ ហើយក៏ដូចគ្នាដែរនៅពេលគាត់ខំទប់ទុក្ខសត្វទាំងពីរ”។(មូស្លីម ៥៦០)

## > តើអ្វីទៅជាការសឡាតស៊ូណិត ?

ចាំបាច់ស្រមាប់អ្នកមូស្លីមក្នុងមួយៃថ្ងមួយយប់ស ឡាត្របាំពេលប៉ុណ្ណោះ។

ហ្ោយជាមួយគ្នាផងៃដរ ច្បាប់បានជំរុញដល់អ្នកមូស្លីមផងៃដរលើ ការសឡាតស៊ូណិត វាគឺជាមួលេហតុដែលអល់ឡោះស្រលាញ់ខ្ញុំរបស្រទង់ និងបំពេញរាល់កង្វះខាតែនសឡាត ហ្វារហ្ន។

1 សឡាតស៊ូណិតមាេនច្រើនណាស់ ហ្ើយៃដលសំខាន់ជាេងគេនាះគឺ: ស៊ូណិត រ៉ាទីប: េគឱ្យេឈ្មាះវាដូចេនះេព្រាះវាេនាជាប់ជាមួយនិង សឡាតហ្វារហ្ន និេងដាយសារអ្នកមូស្លីមមិនេបាះបង់វាេឡើយ។.

ពិតណាស់ណាពីបានមានេ្របសាសន៍ថា( ជនមូស្លីម្រគប់រូបៃដលសឡាតេដើម្បីអល់ឡោះរាល់ៃថ្ងចំនួន១២រ៉ក្អាត់ េដាយស្ម័គ្រចិត្ត េក្រាយពីសឡាតហ្វារហ្ន អល់ឡោះនឹងសង់ផ្ទះមួយស្រមាប់គាត់េនាឋានសួគ៌” ។( មូស្លីម ៧២៨ )

វាមានដូចខាងេក្រាម:

| | |
|---|---|
| 1 | ពីររ៉ក្អាត់មុនសឡាតហ្វាជរី( ស៊ូេពាះ ) |
| 2 | បួនរ៉ក្អាត់មុនសឡាតស៊ូហ៊្វូទ េដាយឱ្យសាឡាមរាល់ពីររ៉ក្អាត់ បន្ទាប់មកពីររ៉ក្អាត់េក្រាយសាឡាតស៊ូហ៊្វូទ។ |
| 3 | ពីររ៉ក្អាត់េក្រាយសឡាតម៉ាគ្រិប |
| 4 | ពីររ៉ក្អាត់េក្រាយសឡាតអ៊ីសា |

2 សឡាត វីេតៀរ: េគឱ្យេឈ្មាះដូេច្នះ េព្រាះចំនួនរក្អាត់របស់វាគឺេសសគូរ ហ្ើយវាជាសឡាតស៊ូណិៃតដលល្អប្របេសី។ ណាពីបានមានេ្របសាសន៍ថា “ចូរពួកអ្នកសឡាតវីេតៀរចុះ ឱពួកអ្នកគួរអាន”។( អាត់េតៀរមីហ្ស៊ី ៤៥៣ អ៊ិពនូម៉ាយ៉ះ ១១៧០ )

ហ្ើយេពលៃដលល្អបំផុតេនាះគឺេនាចុងេក្រាយៃនយប់ ហ្ើយស្រមាប់អ្នកមូស្លីម្របតិបត្តិវាក្នុងេពលណាក៏បានចាប់ពីសឡាតអ៊ីសារួចរហូតដល់សីតរុណរះ។

តិចបំផុតគឺមួយរ៉ក្អាត់ ហ្ើយល្អវាមិនេ្រតូវតិចជាងបីរ៉ក្អាត់េទ ហ្ើយគាត់អាចេថមេទៀតតាមអ្វីៃដលគាត់ចង់ មាេនហ្ើយរ៉សូលុលេឡាះគាត់សឡាត១១រ៉ក្អាត់។

ប្រេភេដើមេនការសឡាតស៊ូណិតគឺពីររ៉ក្អាត់ េដាយសឡាតពីររ៉ក្អាត់ ហ្ើយឱ្យសាឡាម ហ្ើយសឡាតវីេតៀរក៏ដូចគ្នាៃដរក៏ប៉ុន្ៃតេនាេពលៃដលេគចង់បញ្ចប់សឡាត េគ្រតូវសឡាតមួយរ៉ក្អាត់េនាេពលចុងេក្រាយ។ ហ្ើយេគបានកំណត់េលើគាត់ េក្រាយេពលៃដលគាត់េងើបពីរ៉ូកុ មុនេពលស៊ូេជាទ េដាយឱ្យេគសូ្រតហ្ស៊ីេកៀ្រៃដលមានក្នុងេពលេនាះ បន្ទាប់មកេលើកៃដទាំងពីររបស់គាត់បួងសួង( ទូអា ) េទាចំេពាះអល់ឡោះនូវអ្វីៃដលគាត់ចង់ ហ្ើយេគឱ្យេឈ្មាះវាថា ទូអាគូណូត។



## ពេលវេលាដែលគេហាមឃាត់មិនឱ្យសឡាតស៊ូណិត:

គេអនុញ្ញាតឱ្យមនុស្សសឡាតស៊ូណិត្រតគប់ពេលទាំងអស់លើកលែងតែពេលមួយចំនួនដែលឥស្លាមបានហាមឃាត់មិនឱ្យសឡាតនៅក្នុងវា ព្រោះវាជាពេលរបស់អ្នកគ្មានជំនឿគោរពសក្ការៈ ដូច្នេះមិនត្រូវសឡាតក្នុងពេលនោះទៀយលើកលែងតសឡាតហ្វារហ្ទៀងវិញដូលបានកន្លងផុត ឬសឡាតស៊ូណិតដែលមានមូលហេតុត្រឹមត្រូវដូចជា ស៊ូណិតតាហ៊ីយ៉ាតុលម៉ាស្ជិត ហើយវាទាក់ទងចំពោះតែសឡាតប៉ុណ្ណោះ ចំណែកឯការរៀនសូត្រទៅចំពោះអល់ឡោះ និងការបួងសួងគឺអាចធ្វើនៅពេលណាក៏បាន។.

ហើយពេលវេលាដែលគេហាមឃាត់មានដូចខាងក្រោម:

| | |
|---|---|
| 1 | ក្រោយពីសឡាតហ្វាជរី រហូតដល់ថ្ងៃរះ។ ហើយការរះឡើងលើមយបន្តិចនោះ ដោយកំណត់ទៅតាមច្បាប់គឺស្មើនឹងប្រវែងលំពង។ ហើយបើនៅក្នុងប្រទេសដែលមានក្រមិតមធ្យមគឺបន្ទាប់ពីថ្ងៃរះប្រហែល ២០ នាទី។ |
| 2 | នៅពេលដែលថ្ងៃនៅចំកណ្ដាលមេឃជិតនិងេរ។ វាជាពេលវេលាដ៏ខ្លីមុនពេលចូលដល់ពេលសឡាតស៊ូហ៊ូទ។ |
| 3 | ក្រោយពីសឡាតអាសើររហូតដល់ថ្ងៃលិច។ |



> គេហាមឃាត់មិនឱ្យសឡាតស៊ូណិតក្រោយពីសឡាតអាសើររហូតដល់ថ្ងៃលិច។

## > សឡាតជើម៉ាអះ (សឡាតរួមជុំគ្នា)

អល់ឡោះបានប្រើឱ្យបុរសៗសឡាតប្រាំពេលជាមួយជើម៉ាអះ។ ហើយពិតណាស់វានិងទទួលបាននូវផលបុណ្យដ៏ឧត្តុងឧត្តម។ រ៉សូលុលឡោះបានមានប្រសាសន៍ថា "ការសឡាតរួមគ្នា ល្អជាងការសឡាតម្នាក់ឯងចំនួន២៧កំរិត"។(អាល់ពូខរី ៦១៩ មូស្លីម ៦៥០)

ហើយចំនួនតិចបំផុត: អ៊ីម៉ាំ និងម៉ាក់មុំ នៅពេលណាដែលមានគ្នាកាន់តែច្រើនអល់ឡោះកាន់តែស្រលាញ់។

### អត្ថន័យ អាល់អ៊ីកតីម៉ាម:

ការភ្ជាប់គ្នារវាងអ្នកសឡាតម៉ាក់មុំជាមួយនិងអ៊ីម៉ាំ ហើយធ្វើតាមគាត់ក្នុងពេលរូកុ ស៊ូជូទ និងស្តាប់ការសូត្ររបស់គាត់ ហើយមិនធ្វើមុន ឬធ្វើខុសអ្វីមួយពីគ្នាតែឡើយ ផ្ទុយទៅវិញគឺធ្វើតាមបន្ទាប់ពីអ៊ីម៉ាំតែម្តង។

រ៉សូលុលឡោះបានមានប្រសាសន៍ថា "ពិតណាស់គេបានកំណត់លើអ៊ីម៉ាំដើម្បីឱ្យអនុវត្តតាមគាត់ នៅពេលដែលគាត់តក់ពៀរ ចូរពួកអ្នកតក់ពៀរ ហើយពួកអ្នកមិនត្រូវតក់ពៀរឡើយលើកលែងតែគាត់តក់ពៀរមុន។ ហើយនៅពេលដែលគាត់រូកុ ចូរពួកអ្នករូកុ ហើយពួកអ្នកមិនត្រូវរូកុឡើយលើកលែងតែគាត់រូកុមុន។ ហើយនៅពេលដែលគាត់សូត្រ: សើមីអល់ឡោះ ហ្លីម៉ាន់ ហាមីហ្ទះ ចូរពួកអ្នកសូត្រថា "រ៉ប្បើណាវ៉ាលើកាលហាំ" នៅពេលដែលគាត់ស៊ូជូទ ចូរពួកអ្នកស៊ូជូទ ហើយពួកអ្នកមិនត្រូវស៊ូជូទឡើយ លើកលែងតែគាត់ស៊ូជូទមុន"។(អាល់ពូខរី ៧០១ មូស្លីម៤១៤ អាពូទើវូទ ៦០៣)



### តើអ្នកណាគួរឱ្យធ្វើអ៊ីម៉ាំ?

អ្នកដែលគួរឱ្យធ្វើអ៊ីម៉ាំ អ្នកដែលបានទន្ទេញគម្ពីរគួរអាន បន្ទាប់មក អ្នកដែលល្អបន្តបន្ទាប់។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា "អ្នកដែលសាកសមធ្វើអ៊ីម៉ាំក្នុងចំណោមក្រុមមួយ អ្នកដែលសូត្រគួរអានបានល្អជាងគេ ប្រសិនបើការសូត្ររបស់ពួកគេមានភាពស្មើគ្នា គឺអ្នកដែលយល់ដឹងច្រើនជាងគេពីស៊ុណ្ណះ"។ (មូស្លីម ៦៧៣)

### តើអ៊ីម៉ាំ និងម៉ាក់មុំឈរនៅកន្លែងណា?

ចាំបាច់លើអ៊ីម៉ាំឈរនៅខាងមុខ ហើយម៉ាក់មុំឈរជាជួរនៅខាងក្រោយអ៊ីម៉ាំ ហើយត្រូវបំពេញជួរទីមួយបន្ទាប់មកជួរបន្ទាប់ទៀត ប្រសិនបើម៉ាក់មុំមានតែម្នាក់ត្រូវឈរនៅខាងស្តាំអ៊ីម៉ាំ។

## តើត្រូវបំពេញដូចម្ដេចនូវអ្វីដែលគេបានខកខានជាមួយអ៊ីម៉ាំ?

អ្នកដែលចូលសឡាតជាមួយអ៊ីម៉ាំក្រោយពីគាត់បានខកខាននូវចំណែកខ្លះនៃសឡាត គាត់ត្រូវតែកុំព្រៀរសឡាតហើយចូលជាមួយអ៊ីម៉ាំរហូតដល់អ៊ីម៉ាំឱ្យសាឡាម បន្ទាប់មកបំពេញអ្វីដែលនៅសល់ពីសឡាតរបស់គាត់។

ហើយត្រូវគណនាអ្វីដែលគាត់ទាន់ជាមួយអ៊ីម៉ាំពីដើមសឡាតរបស់គាត់ ហើយនិងអ្វីដែលគាត់ធ្វើវាក្រោយពីនោះ នៅចុងក្រោយនៃសឡាតរបស់គាត់។

## តើនិងអ្វីទៅបញ្ជាក់ថាទាន់មួយរ៉ក្អាត់?

យើងគណនាវាតាមចំនួននៃសឡាត ហើយជនណាដែលទៅទាន់រ៉ូកុជាមួយអ៊ីម៉ាំ ពិតណាស់គាត់ទាន់មួយរ៉ក្អាត់ពេញលេញ។ ហើយជនណាខកខានរ៉ូកុ ហើយបានចូលសឡាតជាមួយអ៊ីម៉ាំ ក៏ប៉ុន្តែអ្វីដែលនៅសល់អំពីកាយវិកា ពាក្យសំដីនៅក្នុងរ៉ក្អាត់នោះគេមិនរាប់ជារ៉ក្អាត់ឡើយ។

ឧទាហរណ៍ក្នុងការបំពេញសឡាតសម្រាប់អ្នកដែលខកខានសឡាតដំបូងជាមួយអ៊ីម៉ាំ។

ជនណាដែលទៅទាន់អ៊ីម៉ាំរ៉ក្អាត់ទីពីរនៃសឡាតហ្វាជរី (ស៊ូពោះ) ចាំបាច់សម្រាប់គាត់ក្រោយពីអ៊ីម៉ាំឱ្យសាឡាម គាត់ត្រូវឈរឡើងដើម្បីបំពេញមួយរ៉ក្អាត់ទៀតដែលនៅសល់ ហើយមិនត្រូវឱ្យសាឡាមឡើយរហូតទាល់តែចប់។ ពីព្រោះសឡាតហ្វាជរី (ស៊ូពោះ) មានពីររ៉ក្អាត់ ហើយគាត់មកទាន់តែមួយប៉ុណ្ណោះ។

ជនណាដែលទាន់ជាមួយអ៊ីម៉ាំក្នុងពេលរ៉ូកុរ៉ក្អាត់ទីបីនៃសឡាត ស៊ូហ៊្វូរ ពិតណាស់គាត់ទាន់ពីររ៉ក្អាត់ជាមួយអ៊ីម៉ាំ (វាស្រមាប់ម៉ាក់មុំគឺពីររ៉ក្អាត់ដំបូងនៃសឡាតស៊ូហ៊្វូរ) នៅពេលដែលអ៊ីម៉ាំឱ្យសាឡាមចាំបាច់គាត់ឈរឡើង ហើយបំពេញអ្វីដែលនៅសល់វានោះគឺពីររ៉ក្អាត់ គឺរ៉ក្អាត់ទីបីនិងទីបួន ពីព្រោះសឡាតស៊ូហ៊្វូរមានបួនរ៉ក្អាត់។

ជនណាហើយដែលមកទាន់អ៊ីម៉ាំនៅពេលអាត់តាស្សាហ៊ុទចុងក្រោយ នៃសឡាតម៉ាគ្រិប ចាំបាច់សម្រាប់គាត់ក្រោយពីអ៊ីម៉ាំឱ្យសាឡាមត្រូវឱ្យគាត់សឡាតបីរ៉ក្អាត់ពេញ។ ពីព្រោះគាត់មកទាន់អ៊ីម៉ាំក្នុងពេល អាត់តាស្សាហ៊ុទចុងក្រោយ ហើយការទាន់មួយរ៉ក្អាត់គឺទាល់តែទាន់រ៉ូកុជាមួយអ៊ីម៉ាំ។

## > ការប្រកាសហៅឱ្យមកសឡាត(អាហ្សាន)



> ការប្រកាសហៅឱ្យមកសឡាត(អាហ្សាន) ជាទង្វើដ៏ល្អប្រពៃបំផុតសម្រាប់អល់ឡោះ។

អល់ឡោះបានដាក់ច្បាប់លើអ្នកមូស្លីមឱ្យ អាហ្សាន ដើម្បីហៅមនុស្សមកសឡាត និងប្រកាស្រប់ពួកគេពីការដល់ពេលសឡាត ហើយគេដាក់ច្បាប់ឱ្យ កោះម៉ាត់ ដើម្បីប្រកាសប្រាប់ពួកគេពីការចាប់ផ្តើមសឡាត។ ពិតណាស់អ្នកមូស្លីមបានជួបជុំគ្នាដើម្បីបំពេញកាតព្វកិច្ចសឡាតដោយមិនមាននណាម្នាក់ប្រកាសហៅឡើយ ហើយថ្ងៃមួយពួកគេក៏បានពិភាក្សាគ្នា ខ្លះៗនៃពួកគាត់បាននិយាយថា: ពួកយើងប្រើប្រាស់ជួង ដូចជាជួងរបស់ពួកគ្រិស្ទាន ខ្លះទៀតនិយាយថា: ផ្លុំត្រែដូចជាត្រែរបស់ពួកយូដា។ អូមើរបាននិយាយថា: ទេ ត្រូវតែងតាំងបុរសម្នាក់ប្រកាសហៅឱ្យមកសឡាត ហើយរ៉សូលុលលោះបានមានប្រសាសន៍ថា "ឱ ពីឡាល! ចូរក្រោកឈរឡើងហើយប្រកាសហៅមនុស្សឱ្យមកសឡាត"។(អាល់ពូខរី ៥៧៩ មូស្លីម ៣៧៧)

### របៀបអាហ្សាន និង កោះម៉ាត់

- ចាំបាច់ការ អាហ្សាន និង កោះម៉ាត់ ស្រមាប់មនុស្សជាក្រុមមិនមែនម្នាក់ ប្រសិនបើពួកគេបោះបង់ដោយចេតនាសឡាតរបស់ពួកគេគឺត្រឹមត្រូវប៉ុន្តែពួកគេទទួលបាប។.
- ហើយច្បាប់បានកំណត់ឱ្យអាហ្សានដោយសម្លេងខ្លាំងហើយល្អ រហូតអាចឱ្យមនុស្សស្តាប់លើដើម្បីមកសឡាត។
- ហើយពិតណាស់គេទទួលបានរបៀបអាហ្សាន និង កោះម៉ាត់ជាច្រើនលក្ខណៈដែលមានពីណាពីមូហាំម៉ាត់ ហើយដែលពេញនិយមជាងគេនោះមានដូចខាងក្រោម:

អាហ្សាន;

1 អល់ឡរ៍ហូអឹកពើរ អល់ឡរ៍ហូអឹកពើរ
អល់ឡរ៍ហូអឹកពើរ អល់ឡរ៍ហូអឹកពើរ

2 អាសេហើទូ អាលេឡើអ៊ីឡើហេ អ៊ីលលលេឡោះ។
អាសេហើទូ អាលេឡើអ៊ីឡើហេ អ៊ីលលលេឡោះ

3 អាសេហើទូ អាន់ណាមូហាំម៉ាទ៉ាន់ រ៉សូលុលលោះ។
អាសេហើទូ អាន់ណាមូហាំម៉ាទើ រ៉សូលុលលោះ

4 ហៃយ៉ាអាឡស សេឡើហ៍។ ហៃយ៉ាអាឡស សេឡើហ៍

5 ហៃយ៉ាអាឡាល ហ្វាឡើហ៍។ ហៃយ៉ាអាឡាល ហ្វាឡើហ៍

6 អល់ឡរ៍ហូអឹកពើរ អល់ឡរ៍ហូអឹកពើរ

7 ៧-ឡើអ៊ីឡើហេ អ៊ីលលលេឡោះ

កោះម៉ាត់:

1 អល់ឡរ៍ហូអឹកេពើរ អល់ឡរ៍ហូអឹកេពើរ
2 អាសេហើទូ អាលេទ្បើអីទ្បើហើ អ៊ីលលុលេទ្បាះ
3 អាសេហើទូ អាន់ណាមូហាំម៉ាទើ រ៉សូលុលេទ្បាះ
4 ហៃយ៉ាអាទ្បស សេទ្បើហ៍
5 ហៃយ៉ាអាទ្បាល ហ្វាទ្បើហ៍
6 កុទករម៉ាតីស សេទ្បើហ៍ កុទករម៉ាតីស សេទ្បើហ៍
7 អល់ឡរ៍ហូអឹកេពើរ អល់ឡរ៍ហូអឹកេពើរ
8 ទ្បើអីទ្បើហើ អ៊ីលលុលេទ្បាះ

## ការសូត្រតាមក្រោយអ្នកអាហ្សាន:

គប្បីស្រមាប់អ្នកែដលលឺអាហ្សាន្រត្ូវសូត្រតាមេក្រាយអ្នកអាហ្សាន ដោយសូត្រដូចអ្វីដែលអ្នកអាហ្សានបានសូត្រទាំងអស់ េលើកែលងែតនៅពេលែដលអ្នកអាហ្សានសូត្រថា ហៃយ៉ាអាទ្បស សេទ្បើហ៍ ឬ ហៃយ៉ាអាទ្បាល ហ្វាទ្បើហ៍ គាត្រត្ូវសូត្រថា (ទ្បើហៅទ្បើវ៉ាទ្បើគូវ៉ាតាអ៊ីលេទ្បើពលេទ្បើហ៍)

បន្ទាប់ពីស្តាប់អាហ្សានហើយសូត្រតាមហើយគាត្រត្ូវសូត្រ( អល់ឡរហ៊ុម៉ារប៉េពើ ហៃហ្សហ៊ុទទ្ទាក វ៉ាតីតួតាមម៉ុះ វ៉ាស្វសេទ្បើត្ួល កូរអ៊ីម៉ុះ អាតីមូហ៊ាំម៉ាទើនីល វ៉ាសូទ្បាតី វ៉ាល់ហ្វាទីទ្បះ វ៉ាប់អាសហូល ម៉ាករម៉ា ម៉ះមូទើនីល ទ្បើហ្សវ៉ាអាទតះ)



> អលេ់ទ្បាះដ៏មហាស្អាតស្អំខ្ពង់ខ្ពស់នឹងតបស្នងដល់អ្នកមូស្លីមនូវរាល់ជំហានែដលេគឈានេជើងេដើរេទៅកាន់ម៉ាស្ជិទ

## > ការមានចិត្តនឹងនរក្នុងពេលសឡាត

ការមានចិត្តនឹងនរក្នុងេពុលុសឡាតវាុជាធាតុពិតែនសឡាត និងេផ្នកដ៏សុំខានរបស់វា។ មាុនន័យថា វត្តមានចិត្តរបស់ខ្ញុំលេើដរបស់អលេ់ឡោះក្នុងេពលសឡាេតដោយការេគារព និងបន្ទាបខ្លួន ផ្តោតអារម្មណ៍លេើអ្វីដែលខ្ញុំសូត្រអំពី អាយ៉ាត់ ទូអា និង ហេ្សកៀរ។

ហេើយវាជាការេគារពសក្ការៈដ៏ល្អជាេងគ និងការប្រតិបត្តិដ៏ល្អប្រេពៃ។ អលេ់ឡោះបានបញ្ជាក់យ៉ាងច្បាស់ក្នុងគម្ពីរបស្រ់ទង់ថា ពិតណាស់វាជាលក្ខណៈសម្បត្តិរបស់អ្នកមានជំនឿ។ ដូចអលេ់ឡោះបានមានបន្ទូលថា “បណ្តាអ្នកែដលមានជំនឿពិតជាទទួលបានេជាគជ័យ។ គឺអ្នកែដលមានចិត្តនឹងនរក្នុងការប្រតិបត្តិសឡាតរបស់ពួកេគ”។(អាល់មុមីនូន ១-២)



> គំលាតដែលជិតបំផុតរវាងខ្ញុំបំរើ និងម្ចាស់របស់វាគឺពេលស៊ូជោទ

ជនណាដែលរស់េនៅដោយមានចិត្តនឹងនរក្នុងេពលសឡាេតគនិងទទួលបានរស់ជាតិែនការេគារពសក្ការៈនិង ជំនឿ ដូច្នេះហើយរសូលុលេ់ឡោះបានម្ចាន្របសាសន៍ថា “ខ្ញុំចាត់ទុកភាពសប្បាយរីករាយរបស់ខ្ញុំនៅក្នុងេពលសឡាត”។(អាន់ណាសេអី ៣៩៤០)

### វិធីសាស្រ្តដេលធ្វើឱ្យមានចិត្តនឹងនរក្នុងេពលសឡាត

មានវិធីសាស្រ្តជាច្រេើនែដលជួយឱ្យមានចិត្តនឹងនរក្នុងេពលសឡាតដូចជា:

### 1 ត្រូវមានឆន្ទៈក្នុងការសឡាតនិងការេត្រៀមខ្លួនស្រមាប់វា

ដោយការរួសរាន់ក្នុងការេធ្វើដំណើរទៅសឡាតេនៅម៉ាស្ជីតស្រមាប់បុរស និងប្រតិបត្តិ ស៊ុណ្ណាត់ មុនសឡាត ហេើយេស្លៀកសេ្លៀកបំពាក់ែដលស្អាតសមរម្យ និងេដើរេទៅសឡាេតដោយការេគារព និងស្ងប់ស្ងាត់។

### 2 េចញឱ្យឆ្ងាយព្រីបការែដលនាំឱ្យរំខាន

មិន្រតូវសឡាេត្រទបុសិនេបើនៅពីមុខគាត់មានរូបភាព និងអ្វីដែលរំខានដល់គាត់ ឬគាត់លឺសេំលេងែដលរំខានដល់គាត់។ ហេើយមិន្រតូវសឡាេត្រទបសិនេបើគាត្រ់ត្រូវការេទៅបន្ទប់ទឹក ឬគាត់ឃ្លាន ឬខណៈពេលែដលេគលេើកអាហារមកដល់។ ហេើយទាំងអស្់នេះជាការរំខានសតិអ្នកសឡាត ក្នុងេពលែដលគាត់កំពុងេប្រើពញកាតព្វកិច្ចដ៏ឧត្តុងឧត្តមែដលគាត់កំពុង្របឈមមុខវាគឺសឡាតរបស់គាត់ និងការនិយាយជាមួយម្ចាស់របស់គាត់។

## 3 ភាពនឹងនរក្នុងពេលសឡាត

ពិតណាស់រ៉សូលុលឡោះមានភាពនឹងនរជានិច្ចក្នុងពេល រ៉ុកុរបស់គាត់ ស៊ូជោទរបស់គាត់ រហូតទាល់តែត្រឡប់អវៈយវៈទៅកន្លែងរបស់វាវិញ ហើយប្រើឱ្យអ្នកដែលសឡាតមិនបានល្អឱ្យមានភាពនឹងនរក្នុងកាយវិការរបស់គាត់រាល់ពេលសឡាត ហើយហាមឃាត់មិនឱ្យធ្វើលឿនឡើយ ដោយប្រដូចវាទៅនឹងការចឹកចំណីរបស់សត្វក្អែក។

រ៉សូលុលឡោះបានមានប្រសាសន៍ថា “ មនុស្សដែលអាក្រក់បំផុតគឺចោរលួចដែលបានលួចសឡាតរបស់ខ្លួនឯង” ពួកគេបានសួរថា: ឱរ៉សូលុលឡោះតើគេលួចសឡាតរបស់ខ្លួនឯងដូចម្តេច? លោកឆ្លើយថា “គឺគេមិនបានបំពេញរ៉ុកុ និង ស៊ូជោទវាឡើយ”។(អះម៉ាត់ ២២៦៤២) ជនណាហើយដែលមិនមានភាពនឹងនរក្នុងសឡាតរបស់គេទេនោះគេនឹងមិនទទួលបានចិត្តនឹងនរឡើយ។ ពីព្រោះភាពលឿននឹងធ្វើឱ្យបាត់បង់ចិត្តនឹងនរ ហើយការលឿនដូចជាការចឹករបស់សត្វក្អែកនាំឱ្យបាត់បង់ផលបុណ្យ។

## 4 បង្ហាញពីភាពខ្ពង់ខ្ពស់របស់អ្នកដែលយើងនឹងឈរចំពោះមុខ

ការនឹករលឹកពីភាពខ្ពង់ខ្ពស់របស់អ្នកបង្កើតនឹងភាពឧត្តុង្គឧត្តមរបស់ទ្រង់ និងភាពទន់ខ្សោយរបស់ខ្លួនឯង ហើយពិតណាស់គេនឹងឈរនៅចំពោះមុខម្ចាស់របស់គេ និយាយជាមួយទ្រង់ បួងសួងទៅចំពោះទ្រង់ ដោយការគោរពឱនលំទោន និងបន្ទាបខ្លួន។ ហើយនឹករលឹកអ្វីដែលអល់ឡោះបានរៀបចំសម្រាប់អ្នកមានជំនឿនៅថ្ងៃបរលោកអំពីផលបុណ្យ និងអ្វីដែលអល់ឡោះបានរៀបចំសម្រាប់អ្នកប្រឆាំងអំពីទណ្ឌកម្ម និងនឹករលឹកពីស្ថានភាពនៅពេលដែលជួបជាមួយអល់ឡោះក្នុងថ្ងៃបរលោក។

ប្រសិនបើអ្នកមានជំនឿបាននឹកឃើញអ្វីទាំងនោះក្នុងពេលសឡាតរបស់គេ គេប្រៀបដូចជាពួកអ្នកដែលអល់ឡោះបានប្រាប់ពីលក្ខណៈសម្បត្តិនៅក្នុងគម្ពីររបស់ទ្រង់ អំពីអ្នកដែលជឿជាក់ថាពិតណាស់ពួកគេនឹងជួបម្ចាស់របស់ពួកគេ។ អល់ឡោះបានមានបន្ទូលថា “ ហើយពិតប្រាកដណាស់វាពិតជាមានការលំបាកយ៉ាងខ្លាំងលើកលែងតែចំពោះបណ្តាអ្នកដែលឱនលំទោនកោតខ្លាចអល់ឡោះប៉ុណ្ណោះ។ គឺបណ្តាអ្នកដែលជឿជាក់ថាពិតប្រាកដណាស់ ពួកគេនឹងជួបម្ចាស់របស់ពួកគេ។ ហើយពិតប្រាកដណាស់ ពួកគេនឹងត្រូវវិលត្រឡប់ទៅចំពោះទ្រង់វិញ”។ (អាល់បាកោរ៉ោះ ៤៥-៤៦)

ប្រសិនបើអ្នកសឡាតបាននឹកឃើញថាពិតណាស់អល់ឡោះបានលឺគាត់ និងផ្តល់អ្វីៗដល់គាត់ និងទទួលសំណើគាត់ គាត់នឹងមានចិត្តនឹងនរទៅតាមកំរិតនៃការនឹកឃើញរបស់គាត់។

## 5 ត្រូវត្រិះរិះពិចារណាអំពីអាយ៉ាត់ដែលបានសូត្រ និងហ្ស៊ីកៀរផ្សេងទៀតនៅក្នុងសឡាត ហើយបង្កើតសកម្មភាពជាមួយវា:

គួរអានបញ្ចប់មកដើម្បីត្រិះរិះពិចារណា។ អល់ឡោះបានមានបន្ទូលថា “នេះជាគម្ពីរដ៏មានពរជ័យដែលយើងបានបញ្ចុះវាឱ្យអ្នកដើម្បីឱ្យពួកគេត្រិះរិះពិចារណាចំពោះអាយ៉ាត់ៗរបស់វា ហើយក៏ដើម្បីឱ្យបញ្ញាជនទាំងឡាយយកធ្វើជាមេរៀនផងដែរ”។(ស៊ទ ២៩) ហើយមិនអាចទទួលបានការត្រិះរិះពិចារណាទេលើកលែងតែមានចំណេះដឹងអំពីអត្ថន័យថាគាត់អាចសូត្រ អាយ៉ាត់ ហ្ស៊ីកៀរ និង ឌូអា ហើយគាត់អាចគិតពិចារណាក្នុងស្ថានភាពរបស់គេ និងការជាក់ស្តែងរបស់គាត់អំពីអត្ថន័យនៃអាយ៉ាត់ទាំងនោះ ហើយហ្ស៊ីកៀរបាននឹងធ្វើឱ្យមានចិត្តនឹងនរឱនលំទោន បន្ទាបខ្លួន និងស្លាកស្លាំងជួនកាលអាចធ្វើឱ្យស្រក់ទឹកភ្នែកទៀតផង។ ហើយអាយ៉ាត់មិនបានឆ្លងកាត់គេដោយគ្មានស្លាកស្នាមឡើយ ប្រៀបដូចជាគេបាននឹងធ្វើជាមិនលឺ និងមិនឃើញឡើយ

ដូចអល់ឡោះបានមានបន្ទូលថា “និងបណ្តាអ្នកដែលនៅពេលពួកគេត្រូវបានគេរំលឹកនូវអាយ៉ាត់ៗនៃម្ចាស់របស់ពួកគេ ពួកគេមិនបាននឹងធ្វើគ ធ្វើថ្លង់ចំពោះវាឡើយ”។(អាល់ហ្វួរកន ៧៣)

## > សឡាតយុំអាត់ (ថ្ងៃសុក្រ)

អល់ឡោះបានដាក់កាតព្វកិច្ចនៅថ្ងៃសុក្រក្នុងពេលសឡាតស៊ូហ៊្វូរ សឡាតមួយដែលជានិមិត្តសញ្ញារបស់ឥស្លាម។ ហើយបានបញ្ជាក់ពីកាតព្វកិច្ចនេះដោយប្រមូលផ្តុំអ្នកម៉ូស្លីមទាំងអស់ក្នុងមួយសប្តាហ៍ម្តង។ ហើយនាំគ្នាស្តាប់នូវការអប់រំ និងការប្រៀនប្រដៅដែលលើកឡើងដោយអ៊ីម៉ាំយុំអាត់ បន្ទាប់មកនាំគ្នាប្រតិបត្តិសឡាតយុំអាត់។.



> ចាំបាច់ស្រមាប់អ្នកសឡាត្រូវស្តាប់ ខុតហ្ពះយុំអាត់ ហើយមិនត្រូវធ្វើអ្វីផ្សេងឡើយ។

### គុណសម្បត្តិថ្ងៃយុំអាត់ (ថ្ងៃសុក្រ)

ថ្ងៃយុំអាត់ជាថ្ងៃដែលល្អបំផុតក្នុងចំណោមថ្ងៃទាំងអស់ក្នុងសប្តាហ៍។ ពិតណាស់អល់ឡោះបានជ្រើសរើសវាផ្សេងពីថ្ងៃដទៃ។ ហើយឱ្យតម្លៃវាលើអ្វីដែលផ្សេងពីវាអំពីពេលវេលា នូវគុណសម្បត្តិមួយចំនួនដូចជា:

- ពិតណាស់អល់ឡោះបានជ្រើសរើសវាជាពិសេសសម្រាប់ប្រជាជាតិណាពីម៉ូហាំម៉ាត់ ផ្សេងពីប្រជាជាតិដទៃ។ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា "អល់ឡោះបានធ្វើឱ្យអ្នកជំនាន់មុនយើង វង្វេងចេញឆ្ងាយពីថ្ងៃសុក្រ សម្រាប់ពួកសាសនាយូដាគឺថ្ងៃសៅរ៍, និងសម្រាប់ពួកសាសនាគ្រិស្ទានគឺថ្ងៃអាទិត្យ បន្ទាប់មកអល់ឡោះបាននាំយើង ហើយចង្អុលបង្ហាញឱ្យយើងនូវថ្ងៃសុក្រ" ។(ម៉ូស្លីម ៨៥៦)

- ពិតណាស់នៅក្នុងវាគេបង្កើត អាដាំ និងក្នុងវា ថ្ងៃបរលោកនឹងកើតឡើង។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា " ថ្ងៃដែលព្រះអាទិត្យរះល្អបំផុតគឺថ្ងៃសុក្រ នៅក្នុងវាគេបានបង្កើត អាដាំ និងក្នុងវាគេបញ្ចូលអាដាំទៅក្នុងឋានសួគ៌ និងក្នុងវាគេបានបញ្ចេញគាត់មកវិញ ហើយថ្ងៃបរលោកនឹងមិនកើតមានទេលើកលែងតែនៅក្នុងថ្ងៃសុក្រ"។(ម៉ូស្លីម ៨៥៤)

### តើអ្នកណាខ្លះដែលចាំបាច់សឡាតយុំអាត់?

ចាំបាច់សឡាតយុំអាត់លើ:

1. បុរស : មិនចាំបាច់លើស្ត្រីឡើយ។.
2. មានស្មារតី: មិនចាំបាច់លើមនុស្សឆ្កួត និងក្មេងដែលមិនទាន់ដឹងក្តីឡើយ។.
3. អ្នករស់នៅក្នុងភូមិស្រុក: មិនចាំបាច់លើអ្នកដំណើរ និងអ្នកដែលរស់នៅជនបទដែលចេញឆ្ងាយពីទីក្រុង ឬភូមិស្រុកឡើយ។
4. មានសុខភាពល្អ: មិនចាំបាច់លើអ្នកជំងឺដែលមិនអាចធ្វើដំណើរទៅសឡាតយុំអាត់ឡើយ។

## របៀប និងច្បាប់ដែលទាក់ទងនឹងសឡាតយុំអាត់:

1 គប្បីលើអ្នកមូស្លីមងូតទឹកមុនពេលទៅសឡាតយុំអាត់ និងរួសរាន់ក្នុងការទៅម៉ាស្ជិតមុនពេលចាប់ផ្តើម ខុតហ្ពះ និងស្លៀកសំលៀកបំពាក់ដែលស្រស់ស្អាត។.

2 ប្រមូលផ្តុំអ្នកមូស្លីមនៅក្នុងម៉ាស្ជិទ ហើយអ៊ីម៉ាំទៅខាងមុខ ហើយឡើងលើមីមេពើរ ត្រមង់មុខមកកាន់អ្នកសឡាត ហើយសូត្រពីរខុតហ្ពះ ដោយឈប់អង្គុយបន្តិចរវាងខុតហ្ពះទាំងពីរនោះ។ រំលឹកពួកគេពីការកោតខ្លាចចំពោះអល់ឡោះ។ ហើយផ្តល់នូវការណែនាំ ការបង្រៀននិងអាយ៉ាត់ៗ។.

3 ចាំបាច់លើអ្នកសឡាតស្តាប់ខុតហ្ពះ ហាមឃាត់លើពួកគេមិនឱ្យនិយាយ ឬរវល់ជាមួយអ្វីដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍អំពីវា សូម្បីតែការរុះរើកំរាលលេង ឬអេះដៃនិងសំលៀកបំពាក់លេង ឬលេងឈើនិងដី។

4 បន្ទាប់មកអ៊ីម៉ាំក៏ចុះពីលើមីមេពើរ ហើយបញ្ជូរសឡាត ហើយសឡាតជាមួយមនុស្សពីររ៉ក្កាត់ ដោយសូត្រលឺក្នុងវាទាំងពីរ។.

5 សឡាតយុំអាត្រូវបានគេដាក់កាតព្វកិច្ចលើមនុស្សជាក្រុម ហើយមិនចាំបាច់លើមនុស្សម្នាក់ទេ ជនណាដែលបានខកខានវា ឬមិនបានបំពេញវាដោយបញ្ហាណាមួយ គេត្រូវសឡាតស៊ូហ៊្វូរ មិនត្រឹមត្រូវទេបើគេសឡាតយុំអាត់។.

6 ជនណាដែលយឺតយ៉ាវក្នុងការទៅសឡាតយុំអាត់ ហើយគេមិនបានទៅទាន់អ៊ីម៉ាំទេ លើកលែងតែមួយចំណែកតិចតួចនៃរ៉ក្កាត់ចុងក្រោយ គេត្រូវសឡាតហ្ស៊ូហ៊្វូរ។.

7 រាល់ៗអ្នកដែលគេមិនចាំបាច់ឱ្យសឡាតយុំអាត់ ដូចជាស្ត្រី អ្នកធ្វើដំណើរ ពិតណាស់សឡាតរបស់ពួកគេត្រឹមត្រូវ ប្រសិនបើពួកគេសឡាតរួមជាមួយអ្នកមូស្លីម ហើយពួកគេមិនចាំបាច់សឡាតស៊ូហ៊្វូរទេ។.

## តើអ្នកណាដែលគេអភ័យទោសឱ្យក្នុងការមិនបានមកយុំអាត់?

ច្បាប់បានបញ្ជាក់យ៉ាងច្បាស់លើការចាំបាច់ឱ្យមកសឡាតយុំអាត់ លើអ្នកណាដែលមានកាតព្វកិច្ចលើពួកគាត់ ហើយបានព្រមាននៅលើការប្រព្រឹត្តអ្វីផ្សេងចេញឆ្ងាយពីវាអំពីការសប្បាយក្នុងលោកិយ។ អល់ឡោះបានមានបន្ទូលថា “ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលមានគេអំពាវនាវពួកអ្នកឱ្យទៅសឡាតនៅថ្ងៃសុក្រ ចូរពួកអ្នករួសរាន់ទៅរកការរំលឹកចំពោះអល់ឡោះ ហើយចូរពួកអ្នកបោះបង់ចោលនូវការលក់ដូរ។ នោះគឺជាការប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង”។(អាល់ជូមូអះ ៩)



ហើយបាទ្រពមានចំពោះអ្នកែដលមិនបំេពញវាេដាយគ្មានមូលេហតុស្របច្បាប់ដាយការេបាះត្រាក្នុងចិត្តរបស់េគ។ រ៉សូលុលេឡាះបានមាន្រ្ទបសាសន៍ថា “ ជនណាែដលបានេបាះបង់សឡាតយុំអាត់បីដងេដាយមិនយកចិត្តទុកដាក់ ហើយមិនមានមូលេហតុ អល់េឡាះនឹងេបាះត្រាេលើចិត្តរបស់េគ” ។( អាពូទ៊ើវូទ ១០៥២ អះម៉ាត់ ១៥៤៩៨) អល់េឡាះនឹងេបាះត្រាេលើចិត្តរបស់េគ មានន័យថា េបាះត្រាេលើចិត្តវា និង្រគបដណ្ដប់េលើវា ហើយេធ្វើឱ្យវាល្ងង់ខ្លៅនិងទន់េខ្សាយ ដូចជាចិត្តរបស់ពួក មូណាហ្វិកនិងអ្នក្របឆាំង។

មូលេហតុែដលេគអនុញ្ញាតឱ្យេបាះបង់សឡាតយុំអាត់: រាល់ៗអ្វីែដលេកើតេឡើងេលើអ្នកអំពីបញ្ហាធ្ងន់ធ្ងរែដលមិន្របក្រតី ឬខ្លាចមានេគ្រាះថ្នាក់ជាកលាក់េលើការរស់េនារបស់អ្នក និងសុខភាពរបស់អ្នក ដូចជាមានជំងឺស្ថានភាពបន្ទាន់។



> អល់េឡាះបានមានបន្ទូលថា “ចូរអ្នកេពាលថា: អ្វីែដលេនៅជាមួយអល់េឡាះគឺល្អ្របេសើរជាងការេលងសប្បាយ និងជំនួញេទៀត”។(អាល់ជូមូអះ ១១)

## េតើពលេវលាេធ្វើការជាមូលេហតុអាចេបាះបង់សឡាតយុំអាត់បានែដរឬអត់?

ប្រភពេដើម ការងារ និងការរវល់និងអ្វីមួយ ជានិច្ចកាល វាមិនែមនជាមូលេហតុស្រមាប់អ្នកមូស្លីម ក្នុងការេបាះបង់សឡាតយុំអាត់េនាះេទ អល់េឡាះបានេប្រើឱ្យេយើងេបាះបង់កិច្ចការរបស់េយើងេដើម្បីបំេពញកាតព្វកិច្ចសឡាត ទ្រង់មានបន្ទូលថា “ឱបណ្ដាអ្នកែដលមានជំេនឿ! េនៅេពលមានេគអំពាវនាវពួកអ្នក ឱ្យេទៅសឡាតេនៅថ្ងៃសុក្រ ចូរពួកអ្នករួសរាន់េទៅរកការរំលឹកចំេពាះអល់េឡាះ ហើយចូរពួកអ្នកេបាះបង់ចាលនូវការលក់ដូរ។េនាះគឺជាការ្របេសើរបំផុតស្រមាប់ពួកអ្នក ្របសិនេបើពួកអ្នកបានដឹង”។(អាល់ជូមូអះ ៩)។ ចាំបាច់ស្រមាប់អ្នកមូស្លីមេ្រជើសេរីសការងារណា ែដលអាចបំេពញកាតព្វកិច្ចែដលអល់េឡាះដាក់ឱ្យ សូម្បីែត្របាក់ចំណូលតិចជាងកែន្លងេផ្សងេទៀតក៏េដាយ។

អល់េឡាះបានមានបន្ទូលថា “ហើយអ្នកណាែដលកាតខ្លាចអល់េឡាះទ្រង់និងេធ្វើឱ្យេគមានច្រកេចញ។ ហើយទ្រង់នឹងផ្ដល់លាភសក្ការៈដល់េគដាយេគនឹកស្មានមិនដល់។ ហើយអ្នកណាែដល្របគល់ការទុកចិត្តេលើអល់េឡាះ គ្រឹទង់ជាអ្នកផ្ដល់ភាព្រគប់្រគាន់ដល់េគ”។(អាត់ទឡាគ ២-៣)

### នៅពេលណាដែលការងារជាមូលហេតុអាចបោះបង់សឡាតយ៉ុំអាត់បាន:

គេមិនចាត់ទុកការងារអចិន្ត្រៃយ៍ជាមូលហេតុក្នុងការបោះបង់សឡាតយ៉ុំអាត់ ស្រមាប់អ្នកដែលមានកាតព្វកិច្ចលើគាត់នោះទេ លើលែងតែករណីប៉ុណ្ណោះ::

1 មានហើយវាជាការងារដែលផ្តល់ផលប្រយោជន៍ដ៏ធំធេង ហើយមិនអាចសម្រេចវាបានទេលើកលែងតែគាត់នៅធ្វើការងារនោះ ហើយបោះបង់សឡាតយ៉ុំអាត់។ ហើយប្រសិនបើគាត់បោះបង់ការងារវានឹងផ្តល់គ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ហើយមិនមាននណារម្នាក់អាចជំនួសការងារគាត់បានទេឡើយ។.

ឧទាហរណ៍:

- គ្រូពេទ្យនៅក្នុងរថយន្តសង្គ្រោះបន្ទាន់ដែលចាំព្យាបាលករណីអ្នករងរបួសបន្ទាន់។.
- អ្នកយាមនិងប៉ូលីសដែលការពារប្រជាជននិងទ្រព្យសម្បត្តិរបស់ពួកគេពីការលួចនិងសកម្មភាពបទល្មើសព្រហ្មទណ្ឌ។.
- Pមន្ត្រីស្បៀងដែលកាន់តំណែងគ្រប់គ្រងនៅក្នុងក្រុមហ៊ុនធំ ឬផ្សេងពីនេះ ដែលត្រូវឱ្យត្រួតពិនិត្យគ្រប់ពេលវេលា។.

2 ២-ប្រសិនបើការងារនោះវាជាប្រភពដើមតែមួយគត់ក្នុងការទទួលបានប្រាក់ចំណូល ហើយវាមិនបានផ្តល់ឱកាសឱ្យគាត់ក្នុងការសឡាតយ៉ុំអាត់ ហើយមិនមានការងារផ្សេងក្រៅពីវាទេឡើយ ដើម្បីគ្រប់គ្រងលើការចំណាយចាំបាច់ទៅលើ ម្ហូបអាហារ ទឹក និងប្រភការចាំបាច់ផ្សេងទៀត ស្រមាប់ក្រុមគ្រួសាររបស់គាត់។ដូច្នេះគេអនុញ្ញាតឱ្យគាត់នៅបំពេញការងារ ហើយបោះបង់សឡាតយ៉ុំអាត់ ដោយសារការចាំបាច់ រហូតដល់គាត់បានការងារផ្សេង ឬរហូតដល់គាត់ទទួលបានការចំណាយលើម្ហូបអាហារ ទឹក និងប្រភការចាំបាច់ផ្សេងទៀត គ្រប់គ្រាន់ស្រមាប់ខ្លួនគាត់ និងអ្នកដែលនៅក្រោមបន្ទុករបស់គាត់។

## > សឡាតសម្រាប់អ្នកជំងឺ

សឡាតជាកាតព្វកិច្ចលើអ្នកម៉ូស្លីមនៅគ្រប់កាលៈទេសៈទាំងអស់របស់គេដរាបណាគេនៅមានសតិ និងការយល់ដឹង។ ទោះជាយ៉ាងណាសាសនា ឥស្លាមបានយកចិត្តទុកដាក់លើកិច្ចការដែលផ្ទុយពីកាលៈទេសៈ និងត្រូវការរបស់ពួកគេ។ ហើយនៅក្នុងវានោះគឺអ្នកជំងឺ។

ដើម្បីឱ្យកាន់តែច្បាស់ត្រូវនិយាយថា:

- អ្នកជំងឺអាចបោះបង់ការឈរសឡាត នៅពេលណាដែលគាត់មិនអាចឈរបាន ឬពេលឈរធ្វើឱ្យគាត់ពិបាក ឬយឺតយ៉ាវក្នុងការព្យាបាល ចឹងគាត់អាចសឡាតអង្គុយ ប្រសិនបើមិនកើតទៀតឱ្យគាត់សឡាតដោយដេកផ្អៀងរស៉ូលុលឡោះបានមានប្រសាសន៍ថា "ចូរអ្នកឈរសឡាត ប្រសិនបើគ្មានលទ្ធភាព ចូរអង្គុយ ប្រសិនបើគ្មានលទ្ធភាពទៀត ចូរដេកផ្អៀង"។(អាល់ពូខរី ១០៦៦)
- ជនណាដែលគ្មានលទ្ធភាព រ៉ូកុ ឬស៊ូជោទ គាត់គ្រាន់តែឱនទៅមុខតាមលទ្ធភាពដែលគាត់ធ្វើបាន។
- ជនណាដែលពិបាកអង្គុយលើដីចូរឱ្យគាត់អង្គុយលើកៅអីឬអ្វីផ្សេង។.
- ȷជនណាដែលមានការលំបាកក្នុងការយកទឹកសម្អាតកាយរាល់ពេលសឡាតដោយសារជំងឺរបស់គាត់ គេអនុញ្ញាតឱ្យគាត់សឡាតរួមរវាងស៊ូហ៊្រូទ និងអាស៊ើរក្នុងពេលមួយរវាងវាទាំងពីរ ហើយរវាងម៉ាគ្រិប និងអ៊ីសាក្នុងពេលមួយរវាងវាទាំងពីរ។)
- ជនណាដែលមានការលំបាកក្នុងការប្រើប្រាស់ទឹកដោយសារជំងឺ គេអនុញ្ញាតឱ្យគាត់តាយ៉ាំមុំ ដើម្បីប្រតិបត្តិសឡាត។.

## > សទ្បាតសម្រាប់អ្នកធ្វើដំណើរ

- ស្រមាប់អ្នកេធ្វើដំេណើរក្នុងេពលេធ្វើដំេណើរ ឬពេលស្នាក់នៅដោយកំណត់ពេលច្បាស់លាស់ែដលមានរយៈពេល តិចជាងបួនថ្ងៃ គេអនុញ្ញាតិឱ្យគាត់កាត់សទ្បាតែដលមានបួនរ៉ក្អាត់ឱ្យនៅសល់ពីររ៉ក្អាត់។ ដោយសទ្បាតស៊ូហ៊ូទ អាសេរ និងអ៊ីសា ពីររ៉ក្អាត់ជំនួសបួនរ៉ក្អាត់ លើកែលងែតេពលសទ្បាតជាមួយអ៊ីម៉ាំ ដោយប្រតិបត្តិតាមគាត់ក្នុងសទ្បាតរបស់គាត់ ហើយសទ្បាតបួនរ៉ក្អាត់ដូចគាតែដរ។
- ច្បាប់អនុញ្ញាតិឱ្យគាត់អាចេបាះបង់ ស៊ូណិតរ៉ាំទីប លើកែលងែតស៊ូណិតហ្វាជរី( ស៊ូពោះ ) និងស៊ូណ៉ាត វីតៀរ។.
- គេអនុញ្ញាតឱ្យគាត់សទ្បាតរួមរវាងស៊ូហ៊ូទ និងអាសេរ ហើយរវាងម៉ោគ្រិប និងអ៊ីសា ក្នុងពេលមួយនៃវាទាំងពីរ។ទាំងអស់នេះជាការបន្ធូរបន្ថយ ការសន្តោសប្រណី និងកាត់បន្ថយការលំបាកក្នុងខណៈពេលធ្វើដំណើររបស់គាត់។.





# ការបួសរបស់អ្នក



# 4

អល់ឡោះបានដាក់កាតព្វកិច្ចមកលើសាសនិកឥស្លាមនូវការបួសរយៈពេលមួយខែក្នុងមួយឆ្នាំគឺខែរ៉ម៉ាឌនដ៏ពិសិដ្ឋ។ហើយទ្រង់បានដាក់ការបួសនេះជាគោលគ្រឹះទីបួន នៃបណ្តាគោលគ្រឹះរបស់សាសនាឥស្លាមសំខាន់ៗ។ អល់ឡោះបានមានបន្ទូលថាៈ "ឱ! បណ្តាអ្នកមានជំនឿទាំងឡាយ ជាការពិតណាស់គេ( អល់ឡោះ ) បានដាក់កាតព្វកិច្ចមកលើពួកអ្នកទាំងអស់គ្នានូវការបួស ដូចដែលគេបានដាក់កាតព្វកិច្ចនេះមកលើបណ្តាប្រជាជាតិមុនពួកអ្នកដូចគ្នាផងដែរ សង្ឃឹមថាពួកអ្នកនឹងមានការកោតខ្លាច"។(អាល់ហ្ពាក៏ារៈ ១៨៣)

## មាតិកានៃជំពូក

អត្ថន័យនៃការបួស
គុណប្រយោជន៍នៃខែរ៉ម៉ាឌន
វត្ថុបំណងនៃការបួស
គុណប្រយោជន៍នៃការបួសខែរ៉ម៉ាឌន
ប្រការដែលបណ្តាលអោយខូចបួស
អ្នកដែលច្បាប់អនុញ្ញាតអោយសំរាកបួស

- អ្នកជំងឺ
- អ្នកអសមត្ថភាព
- អ្នកដំណើរ
- ស្រ្តីកំពុងមានរដូវ និងស្រ្តីដែលកំពុងមានឈាមពេលសំរាលកូន
- ស្រ្តីកំពុងមានផ្ទៃពោះ និងស្រ្តីដែលបំបៅកូន។

ការបួសស៊ូណាត់( បួសដែលមិនមែនជាកាតព្វកិច្ច )
ពិធីបុណ្យស្រាយបួស

- តើច្បាប់អោយធ្វើអ្វីខ្លះនៅថ្ងៃបុណ្យនេះ

# ការបួសខែរ៉មាឌន

## អត្ថន័យនៃការបួសៈ

ការបួសនៅក្នុងសាសនាឥស្លាម គឺជាការប្រណិប័តន៍ទៅចំពោះអល់ឡោះ ជាម្ចាស់ដោយការតមអាហារ ការរួមភេទ និងតំណែមផ្សេងៗទៀតពីសតរុណ( គឺពេលអាហ្សានស៊ូពោះ ) រហូតដល់ថ្ងៃលិច ( គឺពេលអាហ្សានម៉ាគ្រិប )។.

## > គុណប្រយោជន៍នៃខែរ៉មាឌនៈ

ខែរ៉មាឌនជាខែទី ៩ នៃខែចន្ទគតិនៅក្នុងប្រតិទិនឥស្លាម វាគឺជាខែដែលល្អជាងគេក្នុងចំណោមខែទាំងអស់ ដែលអល់ឡោះបានដាក់នូវលក្ខណៈពិសេសជាច្រើននៅក្នុងខែនេះ មានដូចជាៈ

1 ជាខែដែលអល់ឡោះជ្រើសរើសសំរាប់បញ្ចុះគម្ពីរដ៏វិសេស និងខ្ពង់ខ្ពស់ជាងគេគឺ គម្ពីរគួរអាន អាល់ការីម។ អល់ឡោះបានមានបន្ទូលថាៈ “ខែរ៉មាឌនជាខែដែលត្រូវបានគេ( អល់ឡោះ) បញ្ចុះគួរអានជាការចង្អុលបង្ហាញសំរាប់មនុស្សទាំងឡាយ និងជាការបកស្រាយយ៉ាងច្បាស់លាស់ដែលប្រែកបែដោយភាពត្រឹមត្រូវ។ ប្រសិនបើអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកគាត់បានមានវត្តមានក្នុងខែនេះ ចូរអោយគាត់បួស” ។( អាល់ហ្គាកេរ៉ោះ ១៨៥))

2 រ៉ស៊ូលុលលោះបានមានប្រសាសន៍ថាៈ “ នៅពេលដែលខែរ៉មាឌនបានមកដល់ ទ្វារឋានសួគ៌ត្រូវបានបើក និងទ្វារឋាននរកត្រូវបានបិទ ហើយពួកពពួកបិសាចត្រូវបានគេចាប់ចង”។(អាល់ពូខរី ៣១០៣ មូស្លីម ១០៧៩) អល់ឡោះបានប្រើឱ្យខ្ញុំបំរើរបស់ទង់រៀបចំទទួលវា ដោយការប្រតិបត្តិអំពើល្អ និងបោះបង់បការអាក្រក់។.

3 ជាការពិតអ្នកដែលបានបួសក្នុងថ្ងៃខែរ៉មាឌន និងបានសឡាតនៅពេលយប់ គាត្រូវបានគេ( អល់ឡោះ ) លើកលែងទោសកំហុសរបស់គាត់ទាំងប៉ុន្មានដែលមានកន្លងមក។ ណាពីបានមានប្រសាសន៍ថាៈ “ អ្នកណាបានបួសខែរ៉មាឌនដោយការជឿ និងចង់បានផលបុណ្យ ត្រូវបានគេលើកលែងទោសកំហុសរបស់គាត់កន្លងមក” ។( អាល់ពូខរី ១៩១០ មូស្លីម ៧៦០) ណាពីក៏បានមានប្រសាសន៍ផងដែរថាៈ “ អ្នកណាបានសឡាតស៊ូណាតពេលយប់នៃខែរ៉មាឌន ដោយការជឿ និងចង់បានផលបុណ្យ ត្រូវបានគេលើកលែងទោសកំហុសរបស់គាត់កន្លងមក”។(អាល់ពូខរី ១៩០៥ មូស្លីម ៧៥៩))

4 នៅក្នុងខែរ៉មាឌនមានយប់មួយដ៏ពិសេសជាងគេ គឺ យប់ អាល់ កុដ៏រ ដែលអល់ឡោះបានបញ្ជាក់ប្រាប់នៅក្នុងគម្ពីរ(អាល់គួរអាន )របស់ទ្រង់ថាៈ អំពើល្អនាយប់នោះល្អជាងពេលផ្សេងៗទាំងអស់។ អល់ឡោះបានមានបន្ទូលថាៈ “យប់អាល់ កដ៏រនោះគឺល្អប្រសើជាងមួយពាន់ខែ”។(អាល់កដ៏រ ៣) ហើយប្រសិនបើអ្នកណាបានសឡាតស៊ូណាតពេលយប់នៃខែរ៉មាឌន ដោយការជឿ និងចង់បានផលបុណ្យ ត្រូវបានគេលើកលែងទោសកំហុសរបស់គាត់កន្លងមក។ វាជាយប់ដែលល្អជាងយប់ចុងក្រោយទាំងដប់នៃខែរ៉មាឌននេះទៀត។ ជាការពិតពុំមាននរណាម្នាក់ដឹងពេលវេលារបស់វាច្បាស់លាស់នោះទេ។.

## > វត្ថុបំណងៃនការបួស

អលេ់ឡោះបានដាក់កាតព្វកិច្ចបួស ដោយសារមានឧត្តមគតិ ប្រយោជន៍ជាច្រេីនទាំងក្នុងលោក និងបរលោក មានដូចជាៈ

### 1 ជាការបញ្ជាក់អោយច្បាស់នូវការគោរពកោតខ្លាចអលេ់ឡោះ

ព្រោះថាការបួសវាជាកិច្ចបូណ្ណិប័តន៍ដែលមនុស្សលោកធ្វេីការវាដេីម្បីបញ្ចិតខ្លួនគេទៅម្ចាស់របស់គេ ដោយការបោះប៉ង់( តម ) នូវអ្វីដែលពួកគេពេញចិត្ត និងបញ្ឈប់នូវសេចក្តីស្រេចឃ្លានរបស់គេផ្សេងៗ ពោលគឺគេរៀបចំខ្លួនរបស់គេដោយការកោតខ្លាចទៅចំពោះអលេ់ឡោះនៅគ្រប់ពេលវេលា និងទីកន្លែងទាំងក្នុង និងក្រៅ។ ដូចនេះហេីយទេីបអលេ់ឡោះបានមានបន្ទូលថាៈ "ឱ! បណ្តាអ្នកមានជំនឿទាំងឡាយជាការពិតណាស់គេ( អលេ់ឡោះ ) បានដាក់កាតព្វកិច្ចមកលេីពួកអ្នកទាំងអស់គ្នានូវការបួស ដូចដែលគេបានដាក់កាតព្វកិច្ចនេះមកលេីបណ្តាប្រជាជាតិមុនពួកអ្នកដូចគ្នាផងដែរ សង្ឃឹមថាពួកអ្នកនឹងមានការកោតខ្លាច"។( អាលេហ្គាកេរ៉ាះ ១៨៣ )

### 2 ការហាត់ក្នុងការបោះបង់បការខុសឆ្គង និងអំពេីបាបៈ

នៅពេលដែលអ្នកបួសគាត់បានតមអំព្េីបការដែលច្បាប់អនុញ្ញាតដេីម្បីជាការគោរពទៅចំពោះអលេ់ឡោះជាម្ចាស់ គាត់ច្បាស់ជានឹងមានលក្ខណៈកាន់តែរឹងមាំក្នុងការហាមឃាត់ការស្រេកឃ្លានរបស់គាត់ក្នុងការធ្វេីប្រការដែលច្បាប់ហាមឃាត់ និងឈរលេីដែនកំណត់របស់អលេ់ឡោះ និងច្បាស់ជាមិននៅបន្តក្នុងការប្រព្រឹត្តបការដែលមិនអាក្រក់នោះទេ។ រស៊ូលុលេឡោះបានមានប្រសាសន៍ថាៈ "បេីជនណាមិនព្រមបោះបង់ចោលនូវការនិយាយអាក្រក់ និងអ្វីដែលអាក្រក់ គឺអលេ់ឡោះមិនត្រូវការអោយគេបោះបង់ចំណីអាហាររបស់គេនោះទេ"។( អាល់ពូខរី ១៨០៤ )ពោលគ្រប់សិនបេីនរណាម្នាក់មិនព្រមបោះបង់ចោលនូវការកុហកទាំងពាក្យសំដី និងកាយវិការទេនោះ គាត់មិនទាន់បានបំពេញនូវវត្ថុបំណងៃនការបួសទេ។

### 3 នឹកឃេីញដល់អ្នកក្រីក្រ និងជាការល្បួងចិត្តរបស់ពួកគេៈ

ជាការពិតនៅក្នុងការបួស វាជាបទពិសោធន៍ក្នុងការល្បួងចិត្តអ្នកក្រីក្រ អត់ឃ្លាន និងជាការធ្វេីអោយនឹកឃេីញដល់អ្នកទីទាល់ក្រដែលពួកគេកំពុងទទួលរងនូវការអត់ឃ្លាន និងស្រេកឃ្លាន នៅពេលនោះមនុស្សច្បាស់ជានឹងនឹកឃេីញបងប្អូនរបស់ខ្លួនដែលក្រីក ថាតេីពួកគេកំពុងទទួលនូវទុក្ខលំបាកយ៉ាងណាអំពីការស្រេកឃ្លាន ខណៈនោះវានឹងជំរុញអោយគេមានទឹកចិត្តកាន់តែខ្លាំងក្នុងការជួយដល់អ្នកទីទាល់ក្រ។.



> សម្រាប់អ្នកបួសមានការសប្បាយពីរដង ការសប្បាយមួយ នៅពេលដែលគាត់ស្រាយបួស ហេីយការសប្បាយមួយទៀតនៅពេលដែលគាត់ជួបម្ចាស់របស់គាត់។

## > គុណប្រយោជន៍នៃការបួសៈ

ការបួសមានគុណប្រយោជន៍ជាច្រើន ដែលមាននៃចងក្នុងច្បាប់ឥស្លាម មានដូចជាៈ

1 ជាការពិតអ្នកដែលបានបួសខែរ៉ម៉ាឌន ដោយការជឿចំពោះអល់ឡោះ គោរពតាមការបង្គាប់ប្រើរបស់ទ្រង់ ជឿនូវគុណប្រយោជន៍នៃការបួស ដោយចង់បានផលបុណ្យអំពីអល់ឡោះជាម្ចាស់ ត្រូវបាននគេលើកលែងទោសកំហុសរបស់គាត់កន្លងមក។ ដូចែដលរ៉ស៊ូលុលលេឡោះបានមានប្រសាសន៍ថាៈ (អ្នកណាបានបួសខែរ៉ម៉ាឌន ដោយការជឿ និងចង់បានផលបុណ្យ ត្រូវបាននគេលើកលែងទោសកំហុស របស់គាត់កន្លងមក)។(អាល់ពូខរី ១៩១០ មូស្លីម ៧៦០)

2 ជាការពិតអ្នកបួសសប្បាយរីករាយ ជាមួយនឹងអ្វីដែលគាត់ទទួលបាន អំពីផលបុណ្យ និងការសប្បាយរីករាយ នៅពេលជួបជាមួយអល់ឡោះជាម្ចាស់ ដោយសារតែការបួសរបស់គាត់។ ដូចែដលរ៉ស៊ូលុលលេឡោះបានមានប្រសាសន៍ថាៈ (សំរាប់អ្នកបួសមានការសប្បាយរីករាយពីរៈ ការសប្បាយមួយ នៅពេលដែលគាត់ស្រាយបួស ហើយ ការសប្បាយមួយទៀតនៅពេលដែល គាត់ជួបម្ចាស់របស់គាត់)។(អាល់ពូខរី ១៨០៥ មូស្លីម ១១៥១)

3 ជាការពិតណាស់នៅក្នុងឋានសួគ៌ មានទ្វារមួយឈ្មោះថា អាល់ រ៉យ្យ៉ាន ( اَلرَّيَّانُ ) មិនមាននរណាម្នាក់អាចចូលបាននក្រៅពីអ្នកបួសឡើយ។ រ៉ស៊ូលុលលេឡោះបានមានប្រសាសន៍ថាៈ ជាការពិតណាស់នៅក្នុងឋានសួគ៌មាន ទ្វារមួយឈ្មោះថា អាល់ រ៉យ្យ៉ាន(اَلرَّيَّان) សំរាប់អ្នកបួសចូលនាថ្ងៃបរលោក គ្មាននរណាម្នាក់អាចចូលបាននក្រៅពីពួកគេទ។ នៅពេលនោះគេប្រកាសថាៈ ឯណាទៅអ្នកបួស ខណៈនោះពួកគេក្រោកឡើង គ្មាននរណាម្នាក់ចូលក្រៅពីពួកគេឡើយ ហើយនៅពេលពួកគេបានចូលអស់ ទ្វារក៏ត្រូវបានបិទ ដែលមិនអាចមាននរណាម្នាក់ចូលបាននឡើយ)។(អាលពូខរី ១៧៩៧ មូស្លីម ១១៥២)

4 ជាការពិតអល់ឡោះបានរំលឹកជាពិសេសចំពោះផលតបស្នងនៃការបួសថាទ្រង់នឹងជាអ្នកផ្តល់ផលបុណ្យដោយផ្ទាល់ ហើយបុគ្គលណាដែលមានសំណាងបានទទួលការតបស្នងពីសំណាក់ម្ចាស់ដ៏លមហាសប្បុរស រួបកគច្បាស់ជាមិនមានអ្វីត្រូវព្រួយបារម្ភនូវអ្វីដែលអល់ឡោះបាននរៀបចំសំរាប់គេនោះទេ។ រ៉ស៊ូលុលលេឡោះបានមានប្រសាសន៍ថាៈ “ គ្រប់កិច្ចបណិបត្តន៍ទាំងឡាយរបស់មនុស្សលោក គឺសំរាប់ពួកគេ លើកលែងតែការបួស គឺសំរាប់យើង( អល់ឡោះ ) ហើយ យើងនឹងតបស្នងចំពោះកិច្ចបណិបត្តនេះ”។(អាលពូខរី ១៨០៥ មូស្លីម ១១៥១)



> ខែរ៉ម៉ាទនគឺជាខែទី៩នៃខែតាមច័ន្ទគតិនៅក្នុងប្រក្រតិទិនឥស្លាម

## > ប្រការដែលបណ្តាលអោយខូចបួស:

វាគឺជាប្រការដែលអ្នកបួសត្រូវជៀសវាង ព្រោះថាវាបណ្តាលអោយខូចបួស, ប្រការទាំងនោះមានដូចខាងក្រោម:

1 ារបរិភោគ: អល់ឡោះបានមានបន្ទូលថា: ចូរពួកអ្នកបរិភោគ និងផឹកទាល់តែអំបោះពណ៌ស(ពន្លឺ) បានលាត្រដាងដល់ពួកអ្នកអំពីអំបោះពណ៌ខ្មៅ(យប់) នៃពេលព្រលឹម(ពេលទៀបភ្លឺ)។ បន្ទាប់មកចូរពួកអ្នកបន្តការបួសរហូតដល់ពេលយប់”។(អាល់ហ្គាកេរ៉ះ ១៨៧)

បុគ្គលណាហើយដែលហូប និងផឹកដោយការភ្លេច ការបួសរបស់គាត់ត្រឹមត្រូវ ហើយគាត់មិនទទួលផលបាបឡើយ។ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា:“បុគ្គលណាដែលភ្លេចហើយរូបគាត់កំពុងបួស ដោយបានហូបអាហារ និងពិសារទឹកក្នុងពេលនោះ ចូរឱ្យគាត់បន្តបំពេញការបួសរបស់គាត់។ ការពិតអល់ឡោះគឺជាអ្នកផ្តល់អាហារ និងទឹកនោះដល់គាត់”។(អាល់ពូខរី ១៨៣១ មូស្លីម ១១៥៥)

2 ទង្វើទាំងឡាយដែលមានន័យស្មើនឹងការបរិភោគ មានដូចជា:

- ការគ្រឿងបំប៉នរាងកាយ និងថ្នាំកំលាំង ដែលចូលទៅក្នុងខ្លួន ដើម្បីជួយបំពេញនូវសារធាតុអាស៊ីត និងអាហារដែលខ្វះខាត វាជំនួសអោយការបរិភោគ ដូចនេះច្បាប់របស់វាដូចជាការបរិភោគដែរ។
- ការបញ្ចូលឈាមសំរាប់អ្នកជំងឺ ព្រោះថាឈាមវាជាលទ្ធផលនៃការបរិភោគ។
- ការជក់: គ្រប់ប្រភេទទាំងអស់វាបណ្តាលអោយខូចបួស ព្រោះថាវានាំជាតិពុលទៅក្នុងខ្លួនតាមរយៈការហឺតផ្សែង។.

3 ការរួមភេទ: គឺការបញ្ចូលប្រដាប់ភេទបុរសក្នុងប្រដាប់ភេទស្ត្រី បើទោះជាបាននចេញទឹកកាម ឬអត់ក្តី។.

4 ការបញ្ចេញទឹកកាមដោយចេតនា: ដោយការប្រឡែង ឬការបញ្ចេញទឹកកាមដោយប្រើដៃ។ល។.

ចំណែកឯការចេញទឹកកាមដោយការយល់សប្តិ មិនបណ្តាលអោយខូចបួសទេ។

ស្វាមីអាចថើបភរិយាគាត់បាន ប្រសិនបើគាត់អាចទប់ខ្លួនគាត់មិនអោយប្រព្រឹត្តនូវអ្វីដែលនាំអោយខូចបួសបាន។

5 ការក្អួតដោយចេតនា: ប្រសិនបើក្អួតដោយអចេតនា វាមិនជាបញ្ហាអ្វីទេ។ ណាពីបានមានប្រសាសន៍ថា: (អ្នកណាបានក្អួតដោយអចេតនាខណៈដែលគាត់កំពុងបួស វាមិនមានបញ្ហាអ្វីទេ ហើយបើអ្នកណាមានចេតនាធ្វើអោយក្អួតគេត្រូវបួសសងវិញ)។(អាត់តៀរមីហ្ស៊ី ៧២០ អាពូទើវូទ ២៣៨០)

6 មានឈាមរដូវ និងឈាមពេលសំរាលកូន: នៅពេលណាដែល មានឈាមរដូវ ឬក៏ឈាមពេលសំរាលកូននៅនៃផ្នែកណាមួយនៃពេលថ្ងៃ គាត់ត្រូវខូចបួសហើយ ឬប្រសិនបើបានមានរដូវហើយបានអស់ឈាមរដូវបន្ទាប់ពីពេលព្រលឹម នោះការបួសរបស់គាត់ក៏មិនត្រឹមត្រូវដែរ ហើយគាត់ត្រូវសំរាកបួសនៅថ្ងៃនោះ។ ដោយសារប្រសាសន៍របស់ណាពីបានលើកឡើងថា: (តើវាមិនមែនពេលគាត់មានរដូវគាត់មិនបានសឡាត ហើយក៏មិនបានបួសទេឬ?)។(អាល់ពូខរី ១៨៥០)

ចំណែកឯឈាមដែលចេញពីរាងកាយស្ត្រីដោយមូលហេតុជំងឺវាមិនមែនជាឈាមរដូវដែលមានចំនួនថ្ងៃច្បាស់លាស់រៀងរាល់ខែ ហើយក៏មិនមែនឈាមសំរាលកូនដែលកើតមានបន្ទាប់ពីសំរាលកូនទេនោះ វាមិនបានហាមឃាត់អំពីការបួសឡើយ។

## > អ្នកដែលអល់ឡោះអនុញ្ញាតអោយសំរាកបួសបាន៖

ជាការពិតអល់ឡោះជាម្ចាស់បានអនុញ្ញាតអោយក្រុមមនុស្សខ្លះអាចសំរាកពីការបួសក្នុងខែរ៉ម៉ាឌនបានជាការបន្ធូរបន្ថយ ជាក្ដីមេត្តាករុណា និងជាការផ្ដល់ភាពងាយស្រួលដល់ពួកគេ, ពួកទាំងនោះមានដូចខាងក្រោម៖

1. អ្នកជំងឺ៖ ពោលគឺអ្នកជំងឺដែលមានបញ្ហាក្នុងការបួស ដែលបណ្ដាលអោយគាត់មិនអាចបួសបាន គឺគាត់អាចសំរាកពីការបួសបាន ហើយគាត្រូវបួសសងវិញបន្ទាប់ពីរ៉ម៉ាឌនរួច។

2. អ្នកអសមត្ថភាពក្នុងការបួស៖ ដោយសារតែភាពចាស់ជរា ឬជំងឺដែលមិនសង្ឃឹមអាចជាបាន គឺគាត្រូវបានអនុញ្ញាតអោយស្រាយបួស ហើយផ្ដល់អាហារដល់អ្នកក្រម្នាក់ក្នុងមួយថ្ងៃ គឺគាត់ផ្ដល់ចំនួនប្រហែល មួយគីឡូកន្លះអំពីចំណីអាហារនៅស្រុករបស់គាត់។

3. អ្នកដំណើរ៖ អ្នកដំណើរខណៈដែលកំពុងធ្វើដំណើរ និងការស្នាក់នៅបណ្ដោះអាសន្នក្នុងរយៈពេលតិចជាងបួនថ្ងៃ គាត្រូវបានអនុញ្ញាតអោយស្រាយបួសបាន ហើយគាត្រូវបួសសងវិញបន្ទាប់ពីខែរ៉ម៉ាឌន។ អល់ឡោះបានមានបន្ទូលថា៖ (ជនណាដែលជាអ្នកមានជំងឺ ឬក្នុងការធ្វើដំណើរ គឺត្រូវរាប់ពីក្នុងចំណោមថ្ងៃផ្សេងទៀត។ អល់ឡោះចង់អោយពួកអ្នកងាយស្រួល ទ្រង់មិនចង់អោយពួកអ្នកលំបាកទេ)។(អាល់ហ្គហ្គរ៉ោះ ១៨៥)

4. ស្ត្រីមានឈាមរដូវនិងមានឈាមពេលសំរាលកូន ច្បាប់ហាមដាច់ខាតចំពោះគាត់អំពីការបួស និងការបួសរបស់គាត់ក៏មិនត្រឹមត្រូវដែរ ហើយពួកគាត្រូវបួសសងវិញបន្ទាប់ពីខែរ៉ម៉ាឌន។)

5. - ស្ត្រីមានផ្ទៃពោះ និង ស្ត្រីបំបៅដោះកូន ប្រសិនបើពួកគាត្រូវព្រួយបារម្ភខ្លាចមានបញ្ហាដល់ខ្លួនឬក៏កូនៗរបស់ពួកគាត់ ពួកគាត់អាចស្រាយបួសបាន ហើយគាត់ត្រូវបួសសងវិញតាមចំនួនថ្ងៃដែលគាត់បានស្រាយ។



### តើច្បាប់កំណត់បែបណាចំពោះអ្នកដែលស្រាយបួសក្នុងខែរ៉ម៉ាឌន?

គ្រប់បុគ្គលណាដែលស្រាយបួសក្នុងខែរ៉ម៉ាឌនដោយគ្មានមូលហេតុសមស្រប គាត់ត្រូវតែធ្វើការសុំទទួលស្គាល់កំហុស ( តៅហ្ពាត់ )អំពីអល់ឡោះ ដោយសារតែគាត់បានប្រព្រឹត្តនូវទោសកំហុសដ៏ធំ ហើយវាជាការមិនគោរពនូវការបង្គាប់បញ្ជារបស់ម្ចាស់ឡើយ ហើយគាត់ត្រូវបួសសងវិញនូវថ្ងៃដែលគាត់បានស្រាយ។ ប៉ុន្តែអ្នកដែលស្រាយបួសដោយសារតែការរួមរ័ក្ស គាត់ត្រូវបួសសងសំរាប់ថ្ងៃដែលគាត់បានស្រាយ និងត្រូវទទួលការពិន័យចំពោះទង្វើបាបរបស់គាត់ ដោយត្រូវដោះលែងខ្ញុំបំរើ( ទាសករជាថៃ្ល )ម្នាក់ ពោលគឺត្រូវទិញខ្ញុំបំរើមូស្លីមម្នាក់ ហើយដោះលែងអោយមានសេរីភាព។ ជាការពិតណាស់អ៊ីស្លាមបានបញ្ជាក់យ៉ាងច្បាស់អំពីសារសំខាន់នៃការដោះលែងមនុស្សអោយរួចផុតពីភាពជាខ្ញុំបំរើ( ទាសករជាថៃ្ល នៅគ្រប់ឱកាសទាំងអស់ដែលមាន។ ប្រសិនបើមិនមានដូចនេះទេ គាត់ត្រូវបួសរយៈពេលពីរខែបន្ទាប់គ្នា ហើយប្រសិនបើគ្មានលទ្ធភាព គាត់ត្រូវផ្តល់អាហារដល់អ្នកទីទាល់ក្រចំនួន ៦០ នាក់។

## > ការបួសស៊ូណាត់( ការបួសដែលមិនមែនជាកាតព្វកិច្ច )

អល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចបួសមួយខែក្នុងមួយឆ្នាំ ប៉ុន្តែទ្រង់ក៏ជំរុញអោយបួសនូវថ្ងៃផ្សេងៗទៀតផងដែរ សំរាប់អ្នកដែលគាត់លទ្ធភាព ហើយចង់បានផលបុណ្យបន្ថែម ការបួសទាំងនោះមានដូចខាងក្រោម:

1. ការបួសថ្ងៃអាស៊ូរ៉ា( عَاشُوْرَاءُ ) ជាមួយការបួសមុនមួយ និងក្រោយមួយមួយថ្ងៃ។ អាស៊ូរ៉ាជាថ្ងៃទី ដប់ នៃខែមូហារ៉ម ខែទីមួយនៃប្រតិទិនឥស្លាម វាជាថ្ងៃដែលអល់ឡោះបានសង្គ្រោះណាពី មូសា អំពីផារ៉ាអុង( ហ្វៀរអ៊ូន ) ហើយទ្រង់បានធ្វើឱ្យផារ៉ាអុងនិងបក្សពួកលិចក្នុងសមុទ្រ ដូចនេះហើយទើប សាសនឥស្លាមបួសក្នុងថ្ងៃនេះជាការថ្លែងអំណរគុណទៅចំពោះអល់ឡោះដែលទ្រង់ជួយណាពីមូសាអោយរួចពីសេចក្តីស្លាប់ និងជាការអនុវត្តតាមអ្នកនាំសាររបស់យើង( ណាពីមូហាំម៉ាត់ ) គ្រាដែលលោកបានបួសហើយបានមានប្រសាសន៍ថា: ( ចូរពួកអ្នកទាំងអស់គ្នាបួសមុនវា( ថ្ងៃអាស៊ូរ៉ា ) មួយថ្ងៃឬក្រោយវាមួយថ្ងៃ )។( អះម៉ាត់ ២១៥៤ )នៅពេលដែលមានគេសួរលោកអំពីការបួសនេះ លោកបានឆ្លើយថា: ( វាលុបលាងបាបកម្មដែលបានកើតឡើងមួយឆ្នាំកន្លងទៅ )។( មូស្លីម ១១៦២ )

2. ការបួសថ្ងៃអារ៉ហ្វះ( عَرَفَةُ ) វាជាថ្ងៃទី ៩ នៃខែហ្ស៊ុលហ៊ីជ្ជះ ខែទី១២ នៃប្រតិទិនឥស្លាម វាជាថ្ងៃដែលក្រុមអ្នកធ្វើហាជ្ជីទាំងអស់ជួបជុំគ្នានៅកន្លែងអារ៉ហ្វះ ពួកគេធ្វើការបួងសួង និងសុំដេងនូវការត្រូវការរបស់ពួកគេទៅចំពោះទ្រង់ វាក៏ជាថ្ងៃដែលល្អជាងគេនៅក្នុងឆ្នាំ ហើយគេជំរុញអោយអ្នកដែលមិនទៅធ្វើហាជ្ជី អោយបួសក្នុងថ្ងៃនោះ នៅពេលដែលគេសួរលោកអំពីការបួសនេះ លោកបានឆ្លើយថា: ( វាលុបលាងបាបកម្មដែលបានកើតឡើងមួយឆ្នាំកន្លងទៅ និងឆ្នាំបន្ទាប់ )។( មូស្លីម ១១៦២ )

3. ការបួសប្រាំមួយថ្ងៃអំពីខែស្ហាវ៉ាល់( شَوَال ) វាជាខែទីដប់។ រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថា: ( អ្នកណាបានបួសខែរ៉ម៉ាឌន ហើយបានបួស ៦ ថ្ងៃអំពីខែស្ហាវ៉ាល់ គឺហាក់បីដូចជាគេបានបួសពេញមួយឆ្នាំ )។( មូស្លីម ១១៦៤ )

## > ពិធីបុណ្យស្រាយបួស( عِيْدُ الْفِطْرِ الْمُبَارَكُ )

ពិធីបុណ្យទានផ្សេងៗ វាជានិមិត្តសញ្ញានៃសាសនា។ នៅពេលដែលព្យាការីបានមកដល់ទីក្រុងម៉ាឌីណះ លោកបានឃើញពួកអាន់សរ( اَلْأَنْصَارُ )(ពួកគាត់គឺជាសាសនិកឥស្លាមដែលរស់នៅទីក្រុងម៉ាឌីណះ) កំពុងលេងយ៉ាងសប្បាយចំនួនពីរថ្ងៃក្នុងមួយឆ្នាំ លោកបានសួរពួកគាត់ថាៈ តើថ្ងៃទាំងពីរនេះ ជាថ្ងៃអ្វីដែរ? ពួកគេឆ្លើយថាៈ ជាថ្ងៃដែលពួកយើងធ្លាប់តែលេងសប្បាយកាលពីសម័យយ៉ាហ៊ីលីយ៉ះ( សម័យមុនឥស្លាម )។ លោកក៏បានបន្តថាៈ "ជាការពិតអល់ឡោះបានប្តូរអោយពួកអ្នកនូវពីរថ្ងៃដែលល្អជាងនេះ គឺ ថ្ងៃបុណ្យ អាដហា និង ថ្ងៃបុណ្យស្រាយបួស"។(អាពូទើវូទ ១១៣៤) លោកក៏បានមានប្រសាសន៍បញ្ជាក់ផងដែរថាពិធីបុណ្យ វាជាអត្តសញ្ញាណរបស់សាសនា លោកមានប្រសាសន៍ថាៈ "ជាការពិតណាស់គ្រប់ក្រុមនិមួយៗ តែងតែមានពិធីបុណ្យ ហើយនេះជាពិធីបុណ្យរបស់ពួកយើង"។(អាល់ពូខរី ៩០៩ មូស្លីម ៨៩២)

### ពិធីបុណ្យនៅក្នុងសាសនាឥស្លាមៈ

ពិធីបុណ្យនៅក្នុងសាសនាឥស្លាម គឺជាថ្ងៃដែលស្តែងនូវការសប្បាយរីករាយ ដោយបានបំពេញនូវកិច្ចបណ្តិបត្តិ ជាការថ្លែងអំណរគុណចំពោះអល់ឡោះជាម្ចាស់ដែលទ្រង់បានចង្អុលបង្ហាញនិងប្រទានពរជ័យសំរាប់បំពេញនូវកិច្ចបណ្តិបត្តិ។ នៅក្នុងថ្ងៃនោះច្បាប់អនុញ្ញាតិអោយបង្កើតភាពសប្បាយរីករាយមនុស្សម្នាទាំងឡាយ ដោយស្លៀកសំលៀកបំពាក់ស្អាតៗ ហើយការធ្វើល្អចំពោះអ្នកក្រីក្រ និងធ្វើនូវទង្វើផ្សេងៗទៀតដែលស្របតាមច្បាប់ឥស្លាមដូចជាការរៀបចំកម្មវិធីនិងសកម្មភាពផ្សេងៗដែលនាំមកនូវភាពសប្បាយរីករាយដល់គ្នាទៅវិញទៅមក ហើយរំលឹកដាស់តឿនពួកគេអោយនឹកឃើញនូវការប្រទានទាំងឡាយរបស់អល់ឡោះមកលើពួកគេ។.

### ពិធីបុណ្យរបស់សាសនិកឥស្លាមៈ

សំរាប់សាសនិកឥស្លាមមានពិធីបុណ្យពីរក្នុងមួយឆ្នាំ ដែលពួកគេត្រូវបានធ្វើវាជារៀងរាល់ឆ្នាំ ហើយច្បាប់មិនអនុញ្ញាតអោយកំណត់ថ្ងៃណាមួយធ្វើជាថ្ងៃបុណ្យផ្សេងពីថ្ងៃទាំងពីរនេះទេ ថ្ងៃបុណ្យទាំងពីរនោះគឺៈ បុណ្យ អាល់ហ្វីត្រទី( បុណ្យស្រាយបួស ) ត្រូវបានធ្វើនៅថ្ងៃទីមួយនៃខែ ស្ហាវ៉ាល់ និងបុណ្យអាល់ អាដហា( បុណ្យហាជ្ជី ) ត្រូវបានធ្វើនៅថ្ងៃទី ដប់ នៃខែហ្ស៊ុលហិជ្ជះ។



## ពិធីបុណ្យ អាល់ហ្វីត្រទី( បុណ្យស្រាយបួស )

ពិធីបុណ្យនេះត្រូវបានប្រារព្ធធ្វើនោះថ្ងៃទីមួយនៃខែ ស្ហាវ៉ាល់ ដែលជាខែទីដប់ វាជាពិធីបុណ្យដែលធ្វើឡើងបន្ទាប់ពីបញ្ចប់ការបួសចុងក្រោយនៃខែរ៉ម៉ាឌន ហេតុនេះហើយទើបគេអោយឈ្មោះថាជា ពិធីបុណ្យ អាល់ ហ្វិត្រទី( បុណ្យស្រាយបួស )។ ដូចនេះហើយទើបមនុស្សទាំងឡាយប្រណិប័តន៍ទៅចំពោះអល់ឡោះជាម្ចាស់ ដោយការស្រាយបួស ដូចដែលពួកគេបានប្រណិប័តន៍ចំពោះទ្រង់ដោយការបួសក្នុងខែរ៉ម៉ាឌន ពោលគឺពួកគេគ្រប់គ្នាប្រារព្ធពិធីបុណ្យនេះជាការថ្លែងអំណរគុណទៅចំពោះការប្រទានរបស់អល់ឡោះដែលបានផ្តល់ភាពងាយស្រួលដល់ពួកគេបានបំពេញកាតព្វកិច្ចបួសខែរ៉ម៉ាឌន។ អល់ឡោះបានមានបន្ទូលថា: “ដើម្បីពួកអ្នកនឹងបង្គ្រប់នូវចំនួនរាប់នោះ និងដើម្បីពួកអ្នកលើកតម្កើង អល់ឡោះ លើអ្វីដែលទ្រង់បានចង្អុលបង្ហាញពួកអ្នក ហើយសង្ឃឹមថាពួកអ្នកដឹងគុណ”។(អាល់ហ្គាកេរ៉ះ ១៨៥)



### តើច្បាប់ត្រូវអោយធ្វើអ្វីខ្លះនៅថ្ងៃបុណ្យ?

**1** ការសឡាតថ្ងៃបុណ្យ: វាជាការសឡាតដែលស្លាមជំរុញអោយប្រណិប័តន៍វា ហើយក៏ជំរុញឱ្យចេញទៅចូលរួមទាំងបុរស ស្រី និងក្មេងៗផងដែរ។ ពេលវេលារបស់វាគឺចាប់ផ្តើមពីព្រះអាទិត្យមានកំពស់មួយលំពែង រហូតដល់ថ្ងៃត្រង់។ មានន័យថា អ្នកមើលឃើញកំពស់ព្រះអាទិត្យប្រហែលប្រវែងលំពែង វាគឺប្រហែលមួយម៉ែត្រជាង។

របៀបសឡាត:

ការសឡាតថ្ងៃបុណ្យមានពីររ៉ក្អាត់ អ៊ីម៉ាំសូត្រលឺៗ ហើយសូត្រខុតហ្ពះពីរបន្ទាប់ពីសឡាត។ នៅក្នុងសឡាតថ្ងៃបុណ្យនេះត្រូវអោយបន្ថែមការសូត្រតាក់បៀរ នៅដើមរ៉ក្អាត់នីមួយៗ។ នៅរ៉ក្អាត់ទីមួយមុននឹងសូត្រហ្វាទីហះ ត្រូវសូត្រតាក់បៀរចំនួន ៦ តាក់បៀរ ដោយមិនរាប់តាក់បៀរ អាល់អៀហរ៉មហើយនៅរ៉ក្អាត់ទីពីរ ត្រូវសូត្រតាក់បៀរចំនួន ៥ តាក់បៀរ ដោយមិនរាប់ការសូត្រតាក់បៀរពេលក្រោកពីស៊ូជោទទ។

.

2 ការបរិច្ចាកហ្សាកាត់ហ្វីត្រះ: ជាការពិតអល់ឡោះបានដាក់កាតព្វកិច្ចក្នុងការបរិច្ចាកហ្សាកាត់នេះចំពោះអ្នកដែលមានអាហារសំរាប់ផ្គត់ផ្គង់ជីវភាពរបស់គាត់គ្រប់សំរាប់ យប់ និងថ្ងៃបុណ្យ គាត់ត្រូវតែបរិច្ចាកចំនួន មួយ សក( صَاع ) អំពីចំណីអាហារនៅក្នុងស្រុករបស់គាត់ ដូចជាអង្ករ ស្រូវសាលី ឬក៏ផ្លែល្មើ ទៅអោយអ្នកក្រីក្រ និងអ្នកដែលមានការខ្វះខាត។ ធ្វើបែបនេះដើម្បីអោយថ្ងៃបុណ្យមានតែការសប្បាយរីករាយ មិនមានអ្នកខ្វះខាតទេ។

ពេលវេលារបស់វា( ពេលវេលាដែលត្រូវបរិច្ចាក ហ្សាកាត់ហ្វីត្រះ ) គឺចាប់ពីថ្ងៃលិចនាថ្ងៃចុងក្រោយនៃខែរ៉ម៉ាដនរហូតដល់ពេលសឡាតថ្ងៃបុណ្យ។ ច្បាប់អនុញ្ញាតអោយបរិច្ចាកមុនថ្ងៃបុណ្យមួយយប់ឬពីរយប់។

ចំនួនដែលត្រូវចេញ: គឺចំនួនមួយសក អំពីចំណីអាហារអ្នកស្រុក មានដូចជា: ស្រូវសាលី អង្ករ ផ្លែល្មើ ឬក៏អ្វីផ្សេងទៀតដែលជាអាហាររបស់អ្នកស្រុក។ សក វាជារង្វាល់ ប៉ុន្តែបើយើងគិតជាទំងន់វាងាយស្រួលជាងក្នុងការកំណត់តាមខ្នាតចំនួននាពេលបច្ចុប្បន្ន គឺវាស្មើនឹងទំងន់ប្រហែលជា ៣ គីឡូក្រាម។

វាជាកាតព្វកិច្ចចំពោះខ្លួនគាត់និងអ្នកដែលគាត់មានកាតព្វកិច្ចត្រូវផ្គត់ផ្គង់ ដូចជា ប្រពន្ធ និងកូនៗរបស់គាត់។ ជាការប្រសើរគួរបរិច្ចាកជំនួសអោយទារកដែលនៅក្នុងផ្ទៃម្តាយ គឺទារកម្នាក់ស្មើនឹងមួយសកអំពីអាហាររបស់អ្នកស្រុក ពោលគឺប្រហែលជាទំងន់ ៣ គីឡូក្រាម។

ជាការពិតរ៉ស៊ូលុលឡោះបានដាក់កាតព្វកិច្ចការបរិច្ចាកហ្សាកាតនេះជាការសំអាតសំរាប់អ្នកបួសដូចដែលបានមានប្រសាសន៍ថា: (វា( ហ្សាកាត់ ហ្វីត្រះ ) ជាការសំអាតសំរាប់អ្នកបួសអំពីកំហុសឆ្គង ហើយក៏ជាអាហារសំរាប់អ្នកទីទាល់ក្រផងដែរ ដូចេនះប្រសិនអ្នកណាបានបរិច្ចាកវាមុនពេលសឡាត វាគឺជាហ្សាកាត់ដែលនឹងត្រូវអល់ឡោះទទួលយក ហើយប្រសិនបើអ្នកណាបានបរិច្ចាកវាបន្ទាប់ពីសឡាត វាគឺជាការបរិច្ចាកទាន( សដាកោះ ) មួយប៉ុណ្ណោះ)។(អាពូទាវូទ ១៦០៩)

3 ច្បាប់អនុញ្ញាតអោយបង្ហាញនូវភាពសប្បាយរីករាយ នៅក្នុងគ្រួសារទាំងក្មេង ចាស់ ប្រុស និងស្រី ជាមួយនឹងអ្វីដែលច្បាប់អនុញ្ញាត ហើយស្លៀកសំលៀកបំពាក់ស្អាតៗ និងការប្រណិបត្តិទៅចំពោះអល់ឡោះជាម្ចាស់ដោយការស្រាយបួស ហើយនឹងការទទួលទានអាហារនាថ្ងៃបុណ្យ។ ហេតុដូច្នេះហើយទើបច្បាប់ហាមមិនអោយបួសក្នុងថ្ងៃបុណ្យទេ។.



**4** អោយសូត្រតឹកេពៀរទៅចំពោះអល់ឡោះ(اَلتَّكْبِيْرُ ) នៅយប់ថ្ងៃបុណ្យ និងពេលចាកេចញទៅសឡាតេថ្ងបុណ្យ ហើយេពលសូត្រតឹកេពៀរេនះត្រូវបញ្ចប់ ដោយការសឡាតេថ្ងបុណ្យ។ ការសូត្រតឹកេពៀរេនះគឺជាការបង្ហាញនូវការសប្បាយ រីករាយេដលបានបំេពញការបួសេនខែរម៉ាឧនដ៏ពិសិដ្ឋ និងជាការថ្លែងអំណរគុណ ចំពោះការប្រទាន និងការចង្អុលបង្ហាញរបស់ទ្រង់មកចំពោះពួកេយើងក្រគប់គ្នាសំរាប់ការបួសេនះ។ អល់ឡោះបានមានបន្ទូលថា: (េដើម្បីពួកអ្នកនឹងប្រងុំបំពេញនូវចំនួនរាប់ និងេដើម្បីពួកអ្នកេលើកតំេកើង អល់ឡោះ េលើអ្វីេដលទ្រង់បានមគ្គុទេសពួកអ្នក ហើយសង្ឃឹមថាពួកអ្នកដឹងគុណ)(អាល់េហ្គាេករ៉ោះ ១៨៥)

របៀបនៃការសូត្រតឹកពៀរ:

**اللّٰهُ أَكْبَرُ، اللّٰهُ أَكْبَرُ، لَا إِلَٰهَ إِلَّا اللّٰهُ، اللّٰهُ أَكْبَرُ اللّٰهُ أَكْبَرُ، وَلِلّٰهِ الْحَمْدُ.**

អល់ឡហ៊ុ អ៊ឹកពើរ អល់ឡហ៊ុ អ៊ឹកពើរ ឡៃអ៊ីឡៃហេ៊ អ៊ិលលុលឡោះ អល់ឡហ៊ុ អ៊ឹកពើរ អល់ឡហ៊ុ អ៊ឹកពើរ វ៉ាលីល ឡៃហ៊ិល ហាំទ

ឬសូត្រថា:

**اللّٰهُ أَكْبَرُ كَبِيْرًا، وَالْحَمْدُ لِلّٰهِ كَثِيْرًا، وَسُبْحَانَ اللّٰهِ بُكْرَةً وَأَصِيْلًا.**

អល់ឡហ៊ុ អ៊ឹកពើរ កេពីរ៉ោ វ៉ាលហាំទូលីលឡៃ ហ៊ិកេសីរ៉ វ៉ាស៊ូបហា នុលឡហ៊ិ ហ៊ុករតៅ វ៉ាអាស៊ីឡៃ

ច្បាប់អនុញ្ញាតអោយបុរសបន្លឺសំលេងសូត្រខ្លាំងៗ ដោយធ្វើយ៉ាងណាកុំអោយប៉ះពាល់ និងរំខានដល់អ្នកដទៃ។ ចំណែកឯស្ត្រីគឺតម្រូវអោយសូត្រតិច។



> អ្នកមូស្លីមបន្ទាប់ពីពួកគេបានចេញពីសឡាតរ៉ាយ៉ា



# ហ្សាកាត់របស់អ្នក



# 5

អល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចហ្សាកាត់ និងបានដាក់វាជាគ្រឹះទីបីនៃបណ្ដាគ្រឹះទាំងឡាយរបស់សាសនាឥស្លាម ហើយទ្រង់ក៏បានប្រមានដោយការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលមិនគោរពតាមច្បាប់នេះ ហើយទ្រង់ក៏បានភ្ជាប់វាជាមួយនឹងភាពជាបងប្អូននៅក្នុងសាសនាឥស្លាមដោយការលះបង់នូវការមិនគោរពច្បាប់នេះ ហើយព្រមបរិច្ចាកឡើងវិញ។ អល់ឡោះបានមានបន្ទូលថា: “ក៏ប៉ុន្តែ ប្រសិនបើពួកគេមានវិប្បដិសារី ហើយបានបញ្ឈរសឡាត(ថ្វាយបង្គំ) នឹងបានដកហ្សាកាត់ ពេលនោះពួកគេគឺជាបងប្អូនរបស់ពួកអ្នកនៅក្នុងសាសនា” ។ (អាត់តៅហ្ពះ: ១១)

ណាពីមូហាំម៉ាត់ បានមានប្រសាសន៍ថា: “សាសនាឥស្លាមត្រូវបានសាងសង់លើគឹះ ៥ ...... ក្នុងនោះលោកបានលើកឡើងថា: ការបញ្ឈរសឡាត និងការបរិច្ចាកហ្សាកាត់”។រាយការណ៍ដោយ(អាល់ពូខរី ៨ មូស្លីម ១៦)

## មាតិកានៃជំពូក


គោលបំណងនៃច្បាប់ហ្សាកាត់ ( ការបរិច្ចាគទ្រព្យ )

ទ្រព្យសម្បត្តិដែលត្រូវបរិច្ចាកហ្សាកាត់

- មាស និងប្រាក់
- ទ្រព្យសម្បត្តិ និង លំហូរសាច់ប្រាក់
- សំភារៈធ្វើពាណិជកម្ម
- របស់ដែលដុះចេញពីដី
- សត្វពាហនៈ

ត្រើតូវបរិច្ចាកហ្សាកាត់អោយអ្នកណាខ្លះ ?

# ការបរិច្ចាកហ្សាកាត់:

ការបរិច្ចាកហ្សាកាត់ វាជាចំណែកដ៏តិចមួយអំពីទ្រព្យសម្បត្តិដែលអល់ឡោះបានដាក់ជាកាតព្វកិច្ចលើសាសនិកឥស្លាម ដោយអ្នកមានត្រូវបរិច្ចាគដើម្បីជួយសំរួលការលំបាក និងត្រូវការរបស់អ្នកក្រក្រី និងមានគោលបំណងផ្សេងៗទៀត។:

## គោលបំណងនៃការបរិច្ចាកហ្សាកាត់:

អល់ឡោះបានដាក់កាតព្វកិច្ចហ្សាកាត់មកលើសាសនិកឥស្លាម ក្នុងគោលបំណងធំជាច្រើន យើងសូមលើកមកបញ្ជាក់ខ្លះដូចខាងក្រោម:

1. ជាការពិតការស្រលាញ់ទ្រព្យសម្បត្តិ វាជាឧបនិស្ស័យរបស់មនុស្សលោក គឺមនុស្សតែងព្យាយាមរកគ្រប់វិធីដើម្បីប្រមូលទ្រព្យសម្បត្តិ និងថែរក្សាវាទុក។ហេតុដូច្នេះហើយទើបច្បាប់បានដាក់កាតព្វកិច្ចក្នុងការបរិច្ចាកហ្សាកាត់ ជាការសំអាតសំរាប់ខ្លួនប្រាណអំពីភាពកខ្វក់នៃភាពកំណាញ់ និងភាពលោភលន់ ហើយវាក៏ជាការលុបបំបាត់នៃការស្រលាញ់ និងវិលវល់ក្នុងរឿងលោកិយនេះ។អល់ឡោះបានមានបន្ទូលថា: “ចូរអ្នកយកមួយផ្នែកខ្លះនៃទ្រព្យសម្បត្តិរបស់ពួកគេ វាជាការបរិច្ចាក( ហ្សាកាត់ ) ដែលវាជួយសំអាតពួកគេ និងធ្វើអោយពួកគេបានប្រសើរ”។( អាត់តាវហ្ពះ ១០៣))

2. ការបរិច្ចាកអាចសំរេចបាននូវចំណុចគន្លឹះនៃទំនាក់ទំនង និងភាពស្និទ្ធស្នាល ព្រោះថាមនុស្សតែងមានការគោរពស្រលាញ់ចំពោះអ្នកដែលបានធ្វើអោយល្អមកចំពោះខ្លួន ហេតុនេះហើយទើបសមាជិកនៃសហគមន៍ឥស្លាមរស់នៅប្រកបដោយសេចក្តីស្រលាញ់រាប់អាន និងសាមគ្គីភាពគ្នាហាក់បីដូចជាសំណង់ដ៏រឹងមាំដែលផ្សាភ្ជាប់គ្នាយ៉ាងស្អិតរមួត ហើយមិនសូវកើតមានករណីចោរកម្មឬក៏ឆក់ប្លន់អ្វីទេ។.

3. ភាពជាខ្ញុំអល់ឡោះ និងការគោរពដ៏ពិតប្រាកដទៅចំពោះទ្រង់ មានលក្ខណៈពេញលេញទៅបានអាស្រ័យការប្រគល់ខ្លួនយ៉ាងពេញលក្ខណៈទៅចំពោះអល់ឡោះដែលជាម្ចាស់នៃពិភពទាំងឡាយ ពោលគឺនៅពេលដែលអ្នកមានបរិច្ចាកទ្រព្យសម្បត្តិរបស់គាត់ នោះវាគឺជាការអនុវត្តនូវច្បាប់របស់អល់ឡោះ និងជាការបំពេញនូវការបង្គាប់ប្រើរបស់ទ្រង់។ ការបរិច្ចាកហ្សាកាត់នេះ ក៏ជាការថ្លែងអំណរគុណទៅចំពោះម្ចាស់ដែលបានប្រទានលាភសក្ការៈទាំងនេះផងដែរ។ អល់ឡោះបានមានបន្ទូលថា: “ ប្រសិនបើពួកអ្នកថ្លែងអំណរគុណ យើងនឹងបន្ថែមដល់ពួកអ្នក” ។( អ៊ីព្រហ៊ីម ៧)

4. ដោយការបរិច្ចាកហ្សាកាត់វានឹងផ្តល់កាន់តែច្បាស់នូវអត្ថន័យនៃការគាំពារសង្គម និងរក្សាលំនឹងបានមួយកំរិតក្នុងផ្នែកខ្លះៗនៃសង្គម ពោលគឺដោយការបរិច្ចាកហ្សាកាត់នេះទៅដល់អ្នកដែលត្រូវទទួល វាមិនធ្វើឱ្យទ្រព្យសម្បត្តិទាំងឡាយស្ថិតនៅតែក្នុងដៃមនុស្សមួយក្រុមណាមួយនៅក្នុងសង្គមនោះទេ។ អល់ឡោះបានមានបន្ទូលថា: “ដើម្បីកុំអោយវានៅតែស្ថិតក្នុងរវាងពួកអ្នកដែលជាអ្នកមានក្នុងចំណោមពួកអ្នក” ។( អាល់ហាស្ហ័រ ៧))



> ជាការពិតការស្រលាញ់ទ្រព្យសម្បត្តិ វាជាឧបនិស្ស័យរបស់មនុស្សលោក ហេតុដូចនេះហើយទើបច្បាប់ឥស្លាមបានដាក់កាតព្វកិច្ចក្នុងការបរិច្ចាកហ្សាកាត់ ជាការសម្អាតសំរាប់ខ្លួនប្រាណនិងមិនមានការជាប់ពាក់ពាន់នឹងវា។

## តើទ្រព្យសម្បត្តិអ្វីដែលចាំបាច់ត្រូវបរិច្ចាកហ្សាកាត់?

ទ្រព្យសម្បត្តិដែលយើងមានសំរាប់បំរើអោយការរស់នៅមិនត្រូវអោយបរិច្ចាកហ្សាកាត់ទេ ដូចជាផ្ទះ បើទោះជាវាមានតំលៃយ៉ាងណាក៏ដោយ និងរថយន្តសំរាប់ប្រើប្រាស់ បើទោះជាវាទំនើប ហើយថ្លៃប៉ុណ្ណាក្តី ហើយដូចគ្នានេះដែរសំលៀកបំពាក់ និងគ្រឿងសំរាប់បរិភោគ ក៏មិនត្រូវអោយបរិច្ចាកហ្សាកាត់ដែរ។.

ជាការពិតអល់ឡោះបានដាក់កាតព្វកិច្ចបរិច្ចាកហ្សាកាត់ តែទៅលើប្រភេទទ្រព្យសម្បត្តិដែលមិនសំរាប់ប្រើប្រាស់ ហើយវាមានការរីកលូតលាស់ ដូចជា:




**1** មាស និង ប្រាក់ ដែលមិនសំរាប់ប្រើ គ្រឿងអលង្ការ:

ទ្រព្យទាំងនេះនឹងមិនត្រូវបរិច្ចាកហ្សាកាត់ទេ លុះត្រាតែវាគ្រប់ចំនួនកំណត់( النِّصَابُ ) ហើយត្រូវបានរក្សាទុករយៈពេលមួយឆ្នាំពេញ ដែលមានចំនួន ៣៥៤ ថ្ងៃ។.

ចំនួននៃការកំណត់ត្រូវបរិច្ចាកហ្សាកាត់ក្នុងមាសនិងប្រាក់គឺ:

មាស ស្មើនឹង: ៨៥ ក្រាម។ប្រាក់ ស្មើនឹង: ៥៩៥ ក្រាម។

ដូចនេះប្រសិនសាសនិកឥស្លាមណាម្នាក់គាត់មានគ្រប់ចំនួនដូចបានបញ្ជាក់ខាងលើ ហើយវាមានរយៈពេលមួយឆ្នាំគាត្រូវបរិច្ចាកហ្សាកាត់ ចំនួន: ២,៥%។



**2** ទ្រព្យសម្បត្តិ និង លំហូរសាច់ប្រាក់ ដែលមានជារូបិយប័ណ្ណខុសគ្នា បើទោះជាស្ថិតនៅក្រោមការគ្រប់របស់គាត់ផ្ទាល់ ឬក៏ជាសាច់ប្រាក់ក់នៅក្នុងធនាគារក្តី:

ការបរិច្ចាកហ្សាកាត់របស់វាគឺយោងទៅតាមចំនួនរបស់ទ្រព្យសម្បត្តិទាំងនោះគិតជាតំលៃមាស។ ដូច្នេះប្រសិនបើវាមានចំនួនស្មើនឹងចំនួនកំណត់ដែលត្រូវបរិច្ចាកហ្សាកាត់របស់មាសឬច្រើនជាងដែលមានទំងន់ប្រហែល ៨៥ ក្រាម នៅពេលវេលាដែលត្រូវបរិច្ចាកហ្សាកាត់ ហើយវាមានរយៈពេលមួយឆ្នាំស្ថិតនៅជាកម្មសិទ្ធិរបស់គាត់ គឺគាត្រូវបរិច្ចាកហ្សាកាត់ចំនួន ២,៥%។.

ឧទាហរណ៍: តំលៃមាសមានការប្រែប្រួល ហើយបើយើងឧបមាថាតំលៃមាសក្នុងមួយក្រាមនៅពេលដែលត្រូវចេញហ្សាកាត់ គឺស្មើនឹង ២៥ ដុល្លារ។ ដូចនេះចំនួនកំណត់ដែលត្រូវបរិច្ចាកហ្សាកាត់ដូចខាងក្រោម:

២៥(តំលៃមាសក្នុងមួយក្រាមវាមានការប្រែប្រួល ) x ៨៥(ចំនួនក្រាមដែលច្បាប់កំណត់ត្រូវបរិច្ចាកហ្សាកាត់គឺវាថេរ )= ២១២៥ ដុល្លារ វាជាចំនួនកំណត់ដែលត្រូវបរិច្ចាកហ្សាកាត់នៃទ្រព្យសម្បត្តិ



**3** ពាណិជ្ជកម្មៈ

គឺសំដៅលើទ្រព្យសម្បត្តិ ឬ សំភារៈដែលសំរាប់ធ្វើពាណិជ្ជកម្ម ដូចជា អចលនទ្រព្យ មានអាគារ សំណង់ ឬ ហាង ដូចជាសំភារៈបរិភោគ។

របៀបបរិច្ចាកហ្សាកាត់ៈ គាត់ត្រូវវាយតំលៃ សំភារៈ ឬទ្រព្យសម្បត្តិដែលគាត់សំរាប់ធ្វើពាណិជ្ជកម្មទាំងអស់ នៅពេលដែលវាមានរយៈមួយឆ្នាំ ហើយការវាយតំលៃគឺធ្វើទៅតាមតំលៃទីផ្សារពេលដែលគាត់ចង់បរិច្ចាកហ្សាកាត់។ ប្រសិនបើចំនួនរបស់វាគ្រប់ចំនួនទ្រព្យសម្បត្តិដែលត្រូវបរិច្ចាកហ្សាកាត់ ត្រូវបរិច្ចាកហ្សាកាត់ចំនួនពីរចុចប្រាំភាគរយ២,៥%។



**4** ដំណាំដែលដុះចេញពីដីនៃគាប់ធញ្ញជាតិនិងដំណាំផ្លែឈើ

អល់ឡោះបានមានបន្ទូលថាៈ “ឱ! បណ្ដាអ្នកមានជំនឿទាំងឡាយចូរអ្នកបរិច្ចាកពីរបស់ល្អៗ នូវអ្វីដែលពួកអ្នកបានខំស្វែងរក និងអ្វីដែលយើងបានបញ្ចេញអោយពួកអ្នកមកពីដី”។(អាល់បាក់ការ៉ោះ ២៦៧)

កាតព្វកិច្ចនេះត្រូវបានកំណត់តែទៅលើដំណាំមួយចំនួននៃតប៉ុណ្ណោះ គឺមិនមែនគ្រប់ដំណាំទាំងអស់នោះទេ ហើយត្រូវមានបរិមាណគ្រប់ចំនួនដែលច្បាប់បានកំណត់ថាត្រូវបរិច្ចាកហ្សាកាត់ទៀតផង។ ច្បាប់ក៏បានធ្វើការបែងចែកផងដែរ រវាងដំណាំដែលស្រោចស្រពដោយទឹកភ្លៀង ទឹកទន្លេ និងដំណាំដែលស្រោចស្រពដោយការចំណាយក្នុងការស្រោចស្រព ចំពោះចំនួនចាំបាច់ដែលត្រូវបរិច្ចាកហ្សាកាត់ ជាការគិតលើស្ថានភាពរបស់មនុស្សទាំងឡាយ។



**5** ទ្រព្យសម្បត្តិដែលជាសត្វ មានសត្វគោ សត្វអូដ្ឋ និងសត្វពពែតប៉ុណ្ណោះ ប្រសិនបើសត្វទាំងនោះមិនត្រូវបានចំណាយក្នុងការផ្ដល់ចំណីអោយវា។

ប្រសិនបើម្ចាស់ជាអ្នកផ្គត់ផ្គង់ចំណាយក្នុងការផ្ដល់ចំណីអាហារអោយវាពេញមួយឆ្នាំ ឬភាគច្រើននៃឆ្នាំ គឺមិនត្រូវបរិច្ចាកហ្សាកាត់ទេ។

ចំនួនកំណត់ដែលត្រូវបរិច្ចាកហ្សាកាត់ និងចំនួននៃការបរិច្ចាកហ្សាកាត់ មានបរិយាយលំអិតនៅក្នុងសៀវភៅហ្វីកោះ។

## តើហ្សាកាត់ត្រូវបរិច្ចាគទៅអោយអ្នកណា?

សាសនាឥស្លាមបានកំណត់យ៉ាងច្បាស់នូវអ្នកដែលត្រូវទទួលហ្សាកាត់។ អ្នកមូស្លីមត្រូវបានអនុញ្ញាតអោយបរិច្ចាគហ្សាកាត់ទៅអោយនរណាម្នាក់ ឬច្រើននាក់ក្នុងចំណោមអ្នកដែលច្បាប់បានកំណត់ថាត្រូវទទួលហ្សាកាត់បាន ឬក៏បរិច្ចាគអោយទៅមូលនិធិ និងអង្គការសប្បុរសធម៌នានា ដែលមានភារៈកិច្ចបែងចែកវាទៅដល់អ្នកដែលត្រូវទទួល ហើយជាការគាប្រសើរនោះគឺ ត្រូវបែងចែកនៅក្នុងប្រទេសរបស់ខ្លួន។

អ្នកដែលត្រូវទទួលហ្សាកាត់មានដូចខាងក្រោម:

1 អ្នកទីទាល់ក្រ( អ្នកហ្វាគៀរ និងមីស្គីន ) គឺអ្នកដែលគ្មានលទ្ធភាពក្នុងការផ្គត់ផ្គង់តម្រូវការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់បាន។

2 អ្នកធ្វើការក្នុងការប្រមូលហ្សាកាត់ និងធ្វើការបែងចែកវា។

3 អ្នកបំរើដាច់ថ្លៃដែលសុំលោះខ្លួនពីចៅហ្វាយរបស់គាត់: ក្នុងករណីនេះគឺត្រូវជួយគាត់ដោយផ្តល់ទ្រព្យហ្សាកាត់ដល់គាត់ដើម្បីគាត់បានក្លាយជាអ្នកដែលមានសេរីភាពដូចគេឯង។.

4 អ្នកដែលជំពាក់បំណុលគេ ហើយមិនអាចសងរួច: បើទោះជាបំណុលនោះសំរាប់បំរើប្រយោជន៍សាធារណៈ និងជាអំពើល្អជួយដល់មនុស្សផងទាំងឡាយ ឬ ជាប្រយោជន៍ផ្ទាល់ខ្លួនសំរាប់បុគ្គលគាត់តែឯងក្តី។.

5 អ្នកតស៊ូក្នុងផ្លូវអល់ឡោះ គឺជាអ្នកដែលធ្វើការតស៊ូដើម្បីការពារសាសនា និងប្រទេសជាតិរបស់ពួកគេ ហើយគ្រប់ការងារដែលជាការផ្សព្វផ្សាយនូវសាសនាឥស្លាម

6 អ្នកមូអាល់ឡាហ្វ: គឺជាអ្នកដែលទើបនឹងចូលឥស្លាមថ្មី ឬអ្នក មិនមែនមូស្លីមដែលត្រូវបានគេសង្ឃឹមថាគាត់នឹងចូលឥស្លាម។ ក្រុមនេះ មិនមែនអ្នកក្រគប់គ្នាអាចអោយបាននោះទេ គឺត្រូវផ្តល់អោយពីសំណាក់ថ្នាក់ដឹកនាំ ឬមូលនិធិសប្បុរសធម៌ដែលអាចកំណត់ប្រយោជន៍ក្នុងរឿងនេះ។ វាក៏ចូលក្នុងចំណុចនេះផងដែរ។.

7 អ្នកដំណើរ: គឺជាអ្នកដំណើរដែលដាច់ស្បៀងខណៈកំពុងធ្វើដំណើរ បើទោះជាគាត់មានទ្រព្យសម្បត្តិច្រើននៅស្រុករបស់គាត់ក្តី។ អល់ឡោះបានមានបន្ទូលថា: “តាមពិត ការបរិច្ចាគហ្សាកាត់នោះ គឺសំរាប់តែបណ្តាអ្នកក្រខ្សត់ បណ្តាអ្នកក្រ បណ្តាអ្នកប្រមូលហ្សាកាត់ បណ្តាអ្នកដែលទើបតែចូលសាសនាឥស្លាម បណ្តាអ្នកចង់រំដោះខ្លួនពីទាសករគេ បណ្តាអ្នកជំពាក់បំណុលគេ បណ្តាអ្នកតស៊ូក្នុងមាគ៌ាអល់ឡោះ និងបណ្តាអ្នកដែលធ្វើដំណើរដាច់ស្បៀងប៉ុណ្ណោះ”។ (អាតេតាវហ្ពះ ៦០)



> រូបក្មេងប្រុស និងក្មេងស្រី - អ្នកទីទាល់ក្រ គឺអ្នកដែលគ្មានលទ្ធភាពក្នុងការផ្គត់ផ្គង់តម្រូវការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់បាន



# ការធ្វើបុណ្យហាជ្ជីរបស់អ្នក



# 6

ការធ្វើបុណ្យហាជ្ជីនៅទ្រីកុងម៉ាក្កះវាជាគោលគ្រឹះទី៥នៃគោលគ្រឹះសាសនាឥស្លាម។ ហើយវាជាការគោរពសក្ការៈដែលរួមបញ្ចូលនៅក្នុងវានោះការគោរពសក្ការៈដោយរាងកាយ ចិត្ត និងទ្រព្យសម្បត្តិ។ ហើយអ្នកដែលមានលទ្ធភាពខាងរាងកាយ និងទ្រព្យសម្បត្តិ ចាំបាច់ត្រូវប្រតិបត្តិវាមួយដងក្នុងមួយឆាកជីវិត។

អល់ឡោះបានមានបន្ទូលថា: “ហើយអល់ឡោះបានដាក់កាតព្វកិច្ចលើមនុស្សលោកឱ្យធ្វើបុណ្យហាជ្ជីនៅផ្ទះរបស់អល់ឡោះ(ម៉ាក្កះ)ចំពោះអ្នក ដែលមានលទ្ធភាពទៅដល់។ ហើយបើអ្នកណាបានប្រឆាំង ពិតប្រាកដណាស់ អល់ឡោះមិនត្រូវការអ្វីមួយពីពិភពទាំងអស់ឡើយ”។( អាលីអ៊ិមរ៉ន ៩៧)

## មាតិកាជំពូក


គុណប្រយោជន៍ ម៉ាក្កះ និងម៉ាស្ជិទីលហារ៉ម

អត្ថន័យការធ្វើបុណ្យហាជ្ជី

ស្ថានភាពអ្នកមូស្លីមដែលមានលទ្ធភាពធ្វើបុណ្យហាជ្ជី

លក្ខខណ្ឌមានមះរ៉ម(អ្នកដែលគេមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន)សម្រាប់ស្ត្រីទៅធ្វើបុណ្យហាជ្ជី

គុណប្រយោជន៍នៃការធ្វើបុណ្យហាជ្ជី

គោលបំណងនៃការធ្វើបុណ្យហាជ្ជីPerform Hajj

ការធ្វើអុំរ៉ោះ

អ៊ីទីលអុទហាដ៏ពិសិដ្ឋ

- តើច្បាប់បានកំណត់អ្វីខ្លះក្នុងថ្ងៃថូរ៉យ៉ា?
- លក្ខខណ្ឌសត្វដែលត្រូវសម្លះ
- តើគេធ្វើដូចម្តេចចំពោះសត្វដែលសម្លះ

ដំណើរទស្សនកិច្ចទៅទ្រីកុងម៉ាឌីណះអាន់ណាពើរីយះ

# ធ្វើបុណ្យហាជ្ជី

## គុណប្រយោជន៍ ម៉ាក្កះ និងម៉ាស្ជិទីលហារ៉ម

ម៉ាស្ជិទីលហារ៉មមានទីតាំងស្ថិតនៅក្នុងទីក្រុងម៉ាក្កះភាគខាងលិចនៃឧបទ្វីបអារ៉ាប់ ហើយវាមានគុណប្រយោជន៍ច្រើនណាស់នៅក្នុងសាសនា ឥស្លាមដូចជា:

**1** មានកៈហ្ពះដ៏ពិសិដ្ឋនៅក្នុងវាh
ហើយវាជាគីបទ្បាតែដលអ្នកមូស្លីមត្រមងមុខទៅនៅពេលប្រតិបត្តិសឡាត និងអ្វីផ្សេងទៀតអំពីការគោរពស្តុក្ការៈដែលអលេទ្បាះបានបញ្ជារប្រើ។.
អល់ទ្បាះបានមានបន្ទូលថា: "ហើយ(ចូរចង្ចាំ) នៅពេលដែលអ៊ីព្រហ៊ីម និងអ៊ីស្មាអែលបានតំឡើងគ្រឹះកាកហ្ពះ(ដោយបួងសួងសុំថា) ឱម្ចាស់របស់ ពួកយើងខ្ញុំ! សូមទ្រង់ទទួលយក(អំពើល្អនិងការបួងសួងសុំ)ពី យើងខ្ញុំផង។ ពិត្រប្រាកដណាស់ ទ្រង់មហាឮ មហាដឹង"។(អាល់ហ្ពាគ៉ោរ៉ោះ ១២៧).
ពិតណាស់ណាពីមូហាំម៉ាត់បានចូលរួមជាមួយនិងកុលសម្ព័ន្ធនៃទីក្រុងម៉ាក្កះក្នុងការដាក់ថ្មខ្មៅនៅកន្លែងរបស់វាវិញនៅពេលដែលកសាងវាសារជា ថ្មី។

**2** ពិតណាស់វាជាម៉ាស្ជិទដំបូងគេបង្អស់នៅលើផែនដីនេះ
អាពូ ហ៊ោរ៉ៃរ បានសួររ៉ស៊ូលុលលេទ្បាះថា ឱរ៉ស៊ូលុលលេទ្បាះតើម៉ាស្ជិទ មួយណាដែលមាននៅលើផែនដីនេះដំបូងគេបង្អស់? លោកឆ្លើយថា "ម៉ាស្ជិទីលហារ៉ម" គាត់បាននិយាយទៀតថា: ខ្ញុំបានសួរទៀតថា " បន្ទាប់មកម៉ាស្ជិទណា? " លោកឆ្លើយថា "ម៉ាស្ជិទអុកសរ" ខ្ញុំក៏សួរទៀតថា: រយៈពេលរវាងវាទាំងពីរប៉ុន្មានឆ្នាំដែរ? លោកបានឆ្លើយថា "៤០ឆ្នាំ បន្ទាប់មកកន្លែងណាក៏ដោយឱ្យតែដល់ពេលសឡាតចូរអ្នកសឡាតចុះ ពិតណាស់ផលបុណ្យនិងមាននៅក្នុងវា"។(អាល់ពូខរី ៣១៨៦ មូស្លីម ៥២០)



> ទ្វាកៈហ្ពះ ហើយគេបានសរសេរអាយ៉ាត់គួរអានមួយចំនួននៅលើវា

**3** ផលបុណ្យនៃសឡាតកើនឡើងនៅក្នុងវា
ពិតណាស់រ៉ស៊ូលុលលេទ្បាះបានមានប្រសាសន៍ថា "សឡាតនៅក្នុងម៉ាស្ជិទរបស់ខ្ញុំនេះ-មានន័យថាម៉ាស្ជិទម៉ាឌីណះ)វាល្អប្រសើជាងសឡាតនៅម៉ាស្ជិទផ្សេងទៀតចំនួន១០០០សឡាតលើកលែងតែម៉ាស្ជិទីលហារ៉ម ហើយសឡាតនៅម៉ាស្ជិទីលហារ៉មវាល្អប្រសើជាងសឡាតនៅម៉ាស្ជិទផ្សេងទៀតចំនួន១០០ពាន់សឡាត"។(អ៊ីពនូម៉ាយ៉ះ ១៤០៦ អះម៉ាត់ ១៤៦៩៤)

4 ពិតណាស់វាជាទឹកដីដែលអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់បានហាមឃាត់។

អល់ឡោះបានមានបន្ទូលថា “ ( ឱមូហាំម៉ាត់ចូរអ្នកពោលទៅកាន់មនុស្សលោកថា) តាម ពិតខ្ញុំត្រូវបានគេបង្គាប់ឱ្យគោរពសក្ការៈចំពោះម្ចាស់របស់ទឹកដី (ម៉ាក្កះ)នេះ ដែលទ្រង់បានហាមឃាត់ នៅក្នុងនោះ។ ហើយអ្វីៗ ទាំងអស់ជាកម្មសិទ្ធិរបស់ទ្រង់។ ហើយខ្ញុំត្រូវបានគេបង្គាប់ឱ្យស្ថិត នៅក្នុងចំណោមអ្នកម៉ូស្លីម”។(អាន់ណាំល៍ ៩១))

ម៉ាក្កះត្រូវបានអល់ឡោះហាមឃាត់លើមនុស្សមិនឱ្យបង្ហូរឈាមនៅក្នុងវា ឬប្រព្រឹត្តអំពើអយុត្តិធម៌ទៅលើនរណាម្នាក់ ឬបរបាញ់សត្វនៅក្នុងវា ឬកាត់អ្វីម្យ៉ាងពីដើមឈើ នឹងស្មៅនៅក្នុងវា។.

រ៉សូលុលលោះបានមានប្រសាសន៍ថា “ពិតប្រាកដណាស់ម៉ាក្កះគឺអល់ឡោះជាអ្នកហាមឃាត់ មនុស្សមិនមែនជាអ្នកហាមឃាត់ទេ មិនអនុញ្ញាតឱ្យឡើយលើបុគ្គលណាម្នាក់ដែលជឿចំពោះអល់ឡោះ និងជឿចំពោះថ្ងៃគីយ៉ាម៉ះ(ថ្ងៃបរលោក) បង្ហូរឈាមនៅក្នុងវា និងមិនឱ្យកាប់ដើមឈើនៅក្នុងវាដែរ”(អាល់ពូខរី ១០៤ មូស្លីម ១៣៥៤)

5 វាជាទ្រីកដែលអល់ឡោះ និងណាពីស្រលាញ់ខ្លាំងបំផុត។

មានសហាប៉ះម្នាក់បាននិយាយថាៈ ខ្ញុំបានឃើញរ៉សូលុលលោះនៅលើសត្វអូដ្ឋរបស់គាត់ស្ថិតនៅតំបន់អាល់ហូហ្សូរ៉ោះ( វាជាតំបនមួយនៅម៉ាក្កះ) លោកបានមានប្រសាសន៍ថា “ខ្ញុំស្បថនិងអល់ឡោះ ពិតប្រាកដណាស់អ្នកជាដីរបស់អល់ឡោះដែលល្អប្រសើរ ហើយជាដីរបស់អល់ឡោះដែលអល់ឡោះស្រលាញ់ជាងគេ ប្រសិនបើខ្ញុំមិនត្រូវបានគេឱ្យចេញពីអ្នកទេ ខ្ញុំនឹងមិនចេញទេឡើយ”។(អាត់ទៀរមីហ្សី ៣៩២៥ អាន់នីសាកក្នុងគីតាបគុបរ ៤២៥២)

6 អល់ឡោះបានដាក់កាតព្វកិច្ចធ្វើបុណ្យហាជ្ជីនៅកៈហ្ពះ សម្រាប់អ្នកដែលមានលទ្ធភាពក្នុងការធ្វើដំណើរ ពិតណាស់ណាពីអ៊ីព្រហ៊ីម គាត់បានប្រកាសអំពាវនាវមនុស្សឱ្យមកធ្វើបុណ្យហាជ្ជី មនុស្សបាននាំគ្នាទៅកាន់វាពីគ្រប់ទីកន្លែង ហើយបណ្ដាណាពីក៏បានធ្វើបុណ្យហាជ្ជីនៅក្នុងវាដែរ ដូចដែលអ្វីដែលរ៉សូលុលលោះបានប្រាប់ អល់ឡោះក៏បានប្រាប់អំពីការបញ្ជាប្រើរបស់ទ្រង់ទៅលើណាពីអ៊ីព្រហ៊ីមដោយមានបន្ទូលថា“ ហើយចូរអ្នកប្រកាសអំពាវនាវដល់មនុស្សលោកអំពីការ ធ្វើហាជ្ជី។ ពួកគេនឹងមកកាន់អ្នក( តាមការអំពាវនាវ) ដោយថ្មើរជើងនិងជិះសត្វអូដ្ឋដែលពួកគេនឹងមកពីគ្រប់ច្រកល្ហកដ៏សែនឆ្ងាយ”។(អាល់ហាជ្ជ ២៧)





> តវ៉ាហ្វជុំវិញកៈហ្ពះប្រាំពីរជុំវាជាគោលគ្រឹះមួយនៃគោលគ្រឹះហាជ្ជី និងអុំរ៉ោះ

## > អត្ថន័យការធ្វើបុណ្យហាជ្ជី

ការធ្វើបុណ្យហាជ្ជីវាជាគោលបំណងទៅផ្ទះរបស់អល់ឡោះ(កៈហ្ពះ)ដើម្បីបំពេញកាតព្វកិច្ច។ វាគឺកាយវិកា និងពាក្យសំដីដែលមានលំនាំពីណាពីមូហាំម៉ាត់ ដូចជាពាក់សំលៀកបំពាក់អៀហរ៉ម និងតវ៉ាហ្វ(ដើរជុំវិញ)កៈហ្ពះប្រាំពីរជុំ និងដើរស្អាអ៊ី ប្រាំពីរជុំរវាងភ្នំសរហ្វា និងភ្នំម៉ារវ៉ះ និងស្ថិតនៅតំបន់អារហ្វះ និងចោលគោលនៅតំបន់មីណា និងអ្វីផ្សេងទៀត។

ហើយវាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនចំពោះមនុស្ស ក្នុងការប្រកាសអំពីការគោរពសក្ការៈចំពោះអល់ឡោះតែម្នាក់គត់ ហើយអ្នកធ្វើហាជ្ជីនិងទទួលបានការអភ័យទោសយ៉ាងធំធេង និងការស្គាល់គ្នារវាងអ្នកមូស្លីម និងសិក្សាពីក្បួនច្បាប់សាសនាឥស្លាម និងអ្វីផ្សេងទៀត។

ពេលវេលាធ្វើហាជ្ជី កាតព្វកិច្ចការធ្វើបុណ្យហាជ្ជីគឺនៅចន្លោះរវាងថ្ងៃទី៨ និងថ្ងៃទី១៣ខែហ្សុលហាជ្ជះ។ វាជាខែទី១២នៃប្រតិទិនឥស្លាម។

តើការធ្វើបុណ្យហាជ្ជីជាកាតព្វកិច្ចលើនរណា?

លក្ខខ័ណ្ឌដែលចាំបាច់ត្រូវធ្វើហាជ្ជីនោះគឺជា អ្នកមូស្លីម ម៉ូកាលទ្បាហ្វ មានលទ្ធភាព(ម៉ូកាលទ្បាហ្វ មានន័យថា មានសតិសម្បជញ្ញៈ គ្រប់អាយុ).

មានលទ្ធភាពមានន័យថា?

អាចធ្វើដំណើរមកដល់កៈហ្ពះតាមផ្លូវដែលត្រឹមត្រូវនិងស្របច្បាប់។ ហើយអាចប្រតិបត្តិហាជ្ជីដោយមិនបង្ករការលំបាកធ្ងន់ធ្ងរ បែនមេលើការលំបាកក្នុងការធ្វើដំណើរធម្មតា ជាមួយនិងសុវត្ថិភាពលើរាងកាយនិងទ្រព្យសម្បត្តិ។ ហើយចាំបាច់ត្រូវឱ្យទ្រព្យដែលចំណាយក្នុងការធ្វើហាជ្ជីជាទ្រព្យដែលសល់បន្ទាប់ពីគាត់បានចំណាយលើតម្រូវការទូទៅ និងការចំណាយលើអ្នកដែលនៅក្រោមការគ្រប់គងរបស់គាត់។.

## >ស្ថានភាពអ្នកមូស្លីមដែលមានលទ្ធភាពដើម្បីធ្វើហាជ្ជី

1 មានលទ្ធភាពធ្វើហាជ្ជីដោយខ្លួនឯងផ្ទាល់ មានន័យថា គាត់ត្រូវមានលទ្ធភាពមកដល់កៈហ្ពះដោយខ្លួនរបស់គាត់ដោយមិនបង្ករការលំបាកច្រើនហួសប្រមាណលើសពីធម្មតា ហើយមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ហើយនិងចាំបាច់ឱ្យគាត់ប្រតិបត្តិកាតព្វកិច្ចហាជ្ជីដោយខ្លួនគាត់ផ្ទាល់។.

2 មានលទ្ធភាពដោយផ្តល់ឱ្យអ្នកដទៃមកធ្វើជំនួសខ្លួនឯង គឺសម្រាប់អ្នកដែលគ្មានលទ្ធភាពធ្វើហាជ្ជីដោយខ្លួនឯងដោយសារឈឺ ឬចាស់ជរា ក៏ប៉ុន្តែគាត់មានអ្នកអាចធ្វើជំនួសឱ្យបាន ហើយគាត់មានលទ្ធភាពផ្តល់ប្រាក់ដល់គេដើម្បីគេធ្វើហាជ្ជីឱ្យគាត់ ហើយចាំបាច់គាត់ត្រូវផ្តល់ប្រាក់ដល់អ្នកដែលធ្វើហាជ្ជីឱ្យគាត់។.

3 អ្នកដែលគ្មានលទ្ធភាពធ្វើហាជ្ជីដោយខ្លួនឯងផ្ទាល់ ហើយក៏គ្មានលទ្ធភាពផ្តល់ឱ្យអ្នកដទៃធ្វើនោះគាត់មិនចាំបាច់ធ្វើហាជ្ជីឡើយដរាបណាគាត់មិនមានលទ្ធភាព។

ដូចជា បុគ្គលដែលមិនមានទ្រព្យសម្បត្តិសល់បន្ទាប់ពីគាត់បានចំណាយលើតម្រូវការទូទៅ និងការចំណាយលើក្រុមគ្រួសាររបស់គាត់ ដែលមិនគ្រប់គ្រាន់សម្រាប់គាត់ដើម្បីប្រតិបត្តិហាជ្ជី។

ហើយក៏មិនចាំបាច់លើគាត់ប្រមូលទ្រព្យសម្បត្តិដើម្បីឱ្យមានលទ្ធភាពធ្វើហាជ្ជីដែរ ក៏ប៉ុន្តែនៅពេលណាដែលគាត់មានលទ្ធភាពចាំបាច់សម្រាប់គាត់ត្រូវធ្វើហា ជ្ជី។

តើអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ និងមានលទ្ធភាពខាងរាងកាយក្នុងការធ្វើហាជ្ជីដែរឬទេ?

ទេ: → (ទៅសំណួរបន្ទាប់)

បាទ នេះ: → ចាំបាច់អ្នកត្រូវធ្វើហាជ្ជីដោយខ្លួនឯង។

ឬតើអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់មែនទែន ក៏ប៉ុន្តែអ្នកមិនមានលទ្ធភាពខាងរាងកាយដើម្បីធ្វើហាជ្ជីដោយមូលហេតុអ្នកមានជំងឺដែលគ្មានសង្ឃឹមនឹងអាចជាសះស្បើយ ឬ អ្នកមានវ័យចាស់ជរា?

ទេ: → ប្រសិនបើអ្នកមិនមានទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់ធ្វើហាជ្ជីដែលសល់បន្ទាប់ពីគាត់បានចំណាយលើតម្រូវការទូទៅ និងការចំណាយលើក្រុមគ្រួសាររបស់គាត់ គាត់មិនមានការតព្វកិច្ចក្នុងការធ្វើហាជ្ជីទេ ហើយក៏មិនចាំបាច់ឱ្យគាត់ប្រមូលទ្រព្យដើម្បីធ្វើហាជ្ជីដែរ។

បាទ នេះ: → ចាំបាច់លើអ្នកផ្តល់ទ្រព្យសម្បត្តិឱ្យអ្នកដែលធ្វើហាជ្ជីជំនួសអ្នក។

## > លក្ខខ័ណ្ឌមានម៉ោះរ៉ម(ប្ដីរបស់គាត់ឬបុគ្គលដែលគេមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន)សម្រាប់ស្ដ្រីទៅធ្វើបុណ្យហាជ្ជី

គេដាក់លក្ខខ័ណ្ឌក្នុងការប្រតិបត្តិកាតព្វកិច្ចហាជ្ជីលើស្ដ្រីត្រូវមានម៉ោះរ៉ម។ ហើយមិនមែនជាកាតព្វកិច្ចក្នុងការធ្វើហាជ្ជីទេលើស្ដ្រីលើកលែងតែមានអ្នកទៅធ្វើហាជ្ជីជាមួយគាត់ម្នាក់នៃម៉ោះរ៉មរបស់គាត់។ ហើយពួកគេនោះគឺ ប្ដីរបស់គាត់ ឬអ្នកដែលគាត់មិនអាចរៀបការជាមួយបានដូចជា ឪពុក ជីតា កូន ចៅ បងប្អូន កូនៗរបស់ពួកគេ ឪពុកមាខាងឪពុក និងឪពុកមាខាងម្ដាយ។

ប្រសិនបើស្ដ្រីទៅធ្វើហាជ្ជីដោយគ្មានម៉ោះរ៉មដោយមធ្យោបាយត្រឹមត្រូវនិងមានសុវត្ថិភាពលើខ្លួនរបស់នាងការធ្វើហាជ្ជីរបស់គាត់ត្រឹមត្រូវ និងទទួលបានផលបុណ្យ។

## > គុណប្រយោជន៍នៃការធ្វើបុណ្យហាជ្ជី

មានការរាយការណ៍ជាច្រើនដែលទាក់ទងនិងគុណប្រយោជន៍ និងរង្វាន់នៃការធ្វើបុណ្យហាជ្ជី ក្នុងនោះមានដូចជា:

1. ពិតណាស់វាជាទង្វើដ៏ល្អប្រពៃបំផុត។ដូចជាមានគេសួររ៉សូលុលឡោះថា: តើទង្វើណាដែលល្អជាងគេ? លោកឆ្លើយថា "គឺការជឿចំពោះអល់ឡោះនិងរ៉សូលរបស់ទ្រង់"។គេបានសួរថា: តើបន្ទាប់មកគឺអ្វី? លោកបានឆ្លើយថា "គឺការតស៊ូក្នុងផ្លូវអល់ឡោះ"។ គេបានសួរទៀតថា: តើបន្ទាប់មកទៀតគឺអ្វី? លោកបានឆ្លើយថា "គឺការធ្វើបុណ្យហាជ្ជីដែលត្រូវគេទទួលយក"។(អាល់ពូខរី១៤៤៧ និងមូស្លីម៨៣)

2. រង្វាន់ដ៏អស្ចារ្យសម្រាប់ការអភ័យទោស រ៉សូលុលឡោះបានមានប្រសាសន៍ថា "បុគ្គលណាធ្វើបុណ្យហាជ្ជី ដោយមិនបាននិយាយនូវការទាក់ទងនឹងការរួមភេទ និងមិនបានប្រព្រឹត្តនូវបាបកម្ម គាត់នឹងត្រឡប់មកវិញ(ដោយគ្មានបាបកម្មជាប់ខ្លួន)ដូចជាថ្ងៃដែលម្ដាយគាត់បង្កើតគាត់"។(អាល់ពូខរី ១៤៤៩ មូស្លីម ១៣៥០) មានន័យថា គាត់ត្រឡប់មកវិញដោយគ្មានបាបកម្មជាប់ខ្លួនដូចជាគាត់ទើបតែប្រសូត្រ។

3. ឱកាសដ៏ធំធេងបំផុតសម្រាប់ដោះលែងមនុស្សពីឋាននរក រ៉សូលុលឡោះបានមានប្រសាសន៍ថា "គ្មានថ្ងៃណាមួយដែលអល់ឡោះដោះលែងមនុស្សពីឋាននរក ច្រើនជាងថ្ងៃអារ៉ហ្វះទេឡើយ"។(មូស្លីម ១៣៤៨)

4. ពិតណាស់រង្វាន់របស់វានោះគឺឋានសួគ៌ រ៉សូលុលឡោះបានមានប្រសាសន៍ថា "ការធ្វើបុណ្យហាជ្ជីដែលគេទទួលយកនោះគ្មានអ្វីតបស្នងក្រៅពីឋានសួគ៌ឡើយ"។(អាល់ពូខរី១៦៨៣ មូស្លីម ១៣៤៩)

រាល់គុណប្រយោជន៍ទាំងនេះ និងអ្វីៗផ្សេងទៀតវាគឺសម្រាប់តែអ្នកដែលជឿជាក់ និងមានចិត្តបរិសុទ្ធ និងជ្រមុះរាល់ប្រការដែលរាំងខ្ទប់ ហើយនិងអនុវត្តតាមគន្លងរបស់ណាពីមូហាំម៉ាត់ដ៏ត្រឹមត្រូវ។

# > គោលបំណងនៃការធ្វើបុណ្យហាជ្ជី

ការធ្វើបុណ្យហាជ្ជីគឺមានគោលបំណង និងគោលដៅដ៏ធំធេង ដូច្នេះហើយបានជា

អល់ឡោះបានមានបន្ទូលបន្ទាប់ពីគាត់បានរៀបរាប់ព្រឹត្តិការណ៍ដែលជាកាតព្វកិច្ចលើអ្នកធ្វើហាជ្ជីអំពីការសម្លេះសត្វជំនូន ដែលអ្នកធ្វើហាជ្ជីសម្លេះវាដើម្បីគោរពសក្ការៈទៅចំពោះអល់ឡោះនៅក្នុងថ្ងៃអាន់ណះរ៍ដោយអល់ឡោះបានមានបន្ទូលថា “ សាច់របស់វា និងឈាមរបស់វាទាំងអស់មិនអាចទៅដល់អល់ឡោះឡើយ ក៏ប៉ុន្តែការកោតខ្លាច( អល់ឡោះ )អំពីពួកអ្នកទេដែលអាចទៅដល់ទ្រង់នោះ” ។( អាល់ហាជ្ជ ៣៧ ) រ៉សូលុលឡោះបានមានប្រសាសន៍ថា “ការពិតគេប្រើឱ្យតវ៉ាហ្វ( ដើរជុំវិញ )កាអ្បះ និងដើររវាងភ្នំសហ្វានិងភ្នំម៉ារវ៉ះ និងចោលគ្រាប់គ្រួស គឺដើម្បីបញ្ជ្រាបការនឹករលឹកទៅចំពោះអល់ឡោះ”។(អាពូដាវូទ ១៨៨៨))

ក្នុងចំណោមគោលដៅ និងគោលបំណងទាំងនេះមានដូចជា:



> ចាំបាច់សម្រាប់អ្នកដែលចង់ធ្វើហាជ្ជី និងអ៊ុំរ៉ោះត្រូវតែសិក្សារៀនសូត្រពីក្បួនច្បាប់របស់វា។

## 1 បង្ហាញពីភាពឱនលំទោន និងភាពរាបសារទៅចំពោះអល់ឡោះ

ពីព្រោះថាអ្នកធ្វើហាជ្ជីបានបោះបង់ចោលទម្រង់នៃការស្រស់ស្អាតនិងការតុបតែង។ ហើយគាត់ស្លៀកស្លៀកបំពាក់អ៊ីហ្រ៉ម ដើម្បីបង្ហាញពីភាពក្រីក្ររបស់គាត់ទៅចំពោះម្ចាស់របស់គាត់។ និងផ្ដាច់ខ្លួនរបស់គាត់ពីកិច្ចការលោកិយ៍ដែលនាំឱ្យគាត់ចាកឆ្ងាយពីចិត្តស្មោះត្រង់ទៅចំពោះម្ចាស់របស់គាត់។ និងបង្ហាញពីការអភ័យទោស និងការអាណិតស្រលាញ់របស់គាត់។ បន្ទាប់មកត្រូវស្ថិតនៅតំបន់អារ៉ហ្វះដោយភាពឱនលំទោន កោតសរសើរ និងថ្លែងអំណរគុណទៅចំពោះម្ចាស់របស់គាត់ នូវរាល់នៀកម៉ាត់ និងការសន្ដោសប្រណីរបស់គាត់។ និងការសុំអភ័យទោសនូវរាល់បាបកម្ម និងកំហុសរបស់គាត់។.

## 2 ការថ្លែងអំណរគុណដល់នៀកម៉ាត់

ការថ្លែងអំណរគុណក្នុងពេលប្រតិបត្តិការតព្វកិច្ចហាជ្ជីមានពីរផ្នែក: ១ - ថ្លែងអំណរគុណដល់នៀកម៉ាត្រទ្រព្យសម្បត្តិ២-ថ្លែងអំណរគុណលើសុវត្ថិភាពរាងកាយទាំងពីរនេះជានៀកម៉ាត់ដ៏ធំធេងដែលមនុស្សបានទទួលវាអំពីនៀកម៉ាត់នៅលើលោកិយនេះ ជាពិសេសក្នុងពេលធ្វើហាជ្ជីគឺត្រូវថ្លែងអំណរគុណដល់នៀកម៉ាត់ដ៏ធំធេងទាំងពីរនេះ ក្នុងខណៈពេលដែលមនុស្សខិតខំប្រឹងប្រែងនឹងខ្លួនរបស់គេ និងបរិច្ចាគទ្រព្យសម្បត្តិរបស់គេក្នុងការអនុវត្តតាម និងបញ្ជិតខ្លួនទៅចំពោះម្ចាស់របស់គាត់។ហើយពិតណាស់ការថ្លែងអំណរគុណដល់នៀកម៉ាត់ជាកាតព្វកិច្ចដែលវិចារណញ្ញាណទទួលស្គាល់ និងច្បាប់សាសនាបានដាក់ជាកាតព្វកិច្ច។.

## 3 ការជួបជុំអ្នកមូស្លីម

អ្នកមូស្លីមរាប់លាននាក់មកពីបណ្តាប្រទេសជុំវិញពិភពលោកបានមកជួបជុំគ្នាក្នុងពេលធ្វើហាជ្ជី ហើយក៏បានស្គាល់គ្នាទៅវិញទៅមក និងបានប្រង្គប់ប្រង្គុំចិត្តគ្នាទៅវិញទៅមក ហើយវាលុបបំបាត់ភាពខុសគ្នារវាងមនុស្ស ដូចជាភាពខុសគ្នារវាងអ្នកមានទ្រព្យសម្បត្តិ និងអ្នកក្រីក្រ ភេទ ពណ៌សម្បុរ ការនិយាយស្តី និងភាសា។វាជាការប្រមូលផ្តុំអ្នកមូស្លីមក្នុងសន្និសីទដ៏អស្ចារ្យរបស់មនុស្សជាតិ ប្រមូលផ្តុំពាក្យសំដីរបស់ពួកគេទៅលើអំពើល្អ និងការកោតខ្លាច និងលើកការផ្តែផ្តាំគ្នាឱ្យប្រកាន់ខ្ជាប់នូវការពិត និងការផ្តែផ្តាំគ្នាឱ្យមានការអត់ធ្មត់។ វាជាគោលដៅដ៏ចំបងដែលភ្ជាប់ទំនាក់ទំនងរវាងមូលហេតុនៃជីវិតទៅនឹងហេតុផលលើលោកិយ។.

## 4 ការរំលឹកអំពីថ្ងៃអាខេរ៉ាះ(ថ្ងៃបរលោក)

បុណ្យហាជ្ជីគឺជាការរំលឹកដល់អ្នកមូស្លីមអំពីថ្ងៃគីយ៉ាម៉ះ។ ដូច្នោះដែរនៅពេលដែលពួកគេបានបោះបង់សំលៀកបំពាក់របស់ពួកគេហើយក៏ស្លៀកសំលៀកបំពាក់អ៊ះរ៉ម និងស្ថិតនៅតំបន់អារ៉ហ្វះ ហើយបានឃើញមនុស្សជាច្រើននៅក្នុងសំលៀកបំពាក់តែមួយ ប្រៀបដូចជាសំលៀកបំពាក់សាកសព នេះជាចំណុចមួយដែលរំឭកគេពីស្ថានភាពរបស់គេបន្ទាប់ពីគេស្លាប់ និងជំរុញឱ្យពួកគេរៀបចំខ្លួនសម្រាប់វា និងខិតខំស្វែងរកផលបុណ្យមុនពេលជួបជាមួយអល់ឡោះ។.

## 5 បង្ហាញពីគោលជំនឿចំពោះអល់ឡោះតែមួយគត់ និងការគោរពសក្ការៈដោយពាក្យសំដី និងកាយវិការទៅចំពោះទ្រង់តែម្នាក់គត់

និមិត្តសញ្ញារបស់អ្នកធ្វើបុណ្យហាជ្ជីគឺសូត្រតាលពីយ៉ះ

(لبيك اللهم لبيك، لبيك لا شريك لك لبيك،إن الحمد و النعمة لك و الملك، لا شريك لك)

(ឡាប៉ៃប៊ិកអល់ឡហុំម៉ាឡាប៉ៃប៊ិក ឡាប៉ៃប៊ិកឡាឆារីកាឡាកឡាប៉ៃប៊ិក អ៊ិនណាលហាំទេ វ៉ាននេអ៊្មាតា ឡាកាវ៉ាលមុលក៍ ឡាឆារីកាឡាក)

ដូច្នេះហើយបានជាហ្សាប៊ែរ ប្រាប់ពីរបៀបសូត្រតាលពីយ៉ះរបស់ណាពីថា “ចាប់ផ្តើមនិងគោលជំនឿ”។(មូស្លីម ១២១៨) បង្ហាញពីគោលជំនឿដ៏ច្បាស់លាស់ក្នុងរាល់និមិត្តសញ្ញារបស់ហាជ្ជី និងកាយវិការ .

> ជាកាតព្វកិច្ចលើអ្នកដែលមានលទ្ធភាពធ្វើអ៊ំរ៉ោះមួយដងក្នុងមួយឆាកជីវិត



# > អាល់អ៊ុំរ៉ោះ

វាគឺជាការគោរពសក្ការៈចំពោះអល់ឡោះដោយការស្លៀកសំលៀកបំពាក់អៈរ៉ម ការតវ៉ាហ្វជុំវិញកៈហ្ពះប្រាំពីរជុំ និងដើរសាកអ៊ីរវាងសរហ្វា និងម៉ារវ៉ះប្រាំពីរជុំ បន្ទាប់មកកោរសក់ ឬកាត់។

ច្បាប់របស់វា: វាជាកាតព្វកិច្ចលើអ្នកដែលមានលទ្ធភាពមួយដងក្នុងមួយឆាកជីវិត។ ហើយគប្បីធ្វើវាច្រើនដង។

ពេលវេលារបស់វា: គេអាចប្រតិបត្តិវាមួយឆ្នាំពេញ ក៏ប៉ុន្តែនៅក្នុងខែរ៉ម៉ាឌនផលបុណ្យរបស់វាទ្វេគុណ ដូចដែររ៉សូលុលឡោះបានមានប្រសាសន៍ថា “ការធ្វើអ៊ុំរ៉ោះក្នុងខែរ៉ម៉ាឌនេះស្មើនិងធ្វើហាជ្ជី”(អាល់ពូខរី ១៧៦៤ មូស្លីម ១២៥៦)



> ជាកាតព្វកិច្ចលើអ្នកដែលមានលទ្ធភាពធ្វើអ៊ុំរ៉ោះមួយដងក្នុងមួយឆាកជីវិត

# ពិធីបុណ្យរ៉យ៉ាអាលេអាឌហា ( បុណ្យរ៉យ៉ាហាជ្ជី )

វាជាបុណ្យទីពីរស្រមាប់អ្នកមូស្លីម ហើយគេប្រារព្ធវានៅក្នុងថ្ងៃទី១០ក្នុងខែហ្ស៊ុលហាជ្ជះ (ខែទី១២នៃប្រតិទិនឥស្លាម) ហើយពិតណាស់នៅក្នុងវានោះមានគុណប្រយោជន៍ជាច្រើនដូចជា:

1 **វាជាថ្ងៃដែលល្អជាងគេក្នុងមួយឆ្នាំ។** ហើយបណ្ដាថ្ងៃដែលល្អជាងគេក្នុងមួយឆ្នាំគឺ១០ថ្ងៃដំបូងនៃខែហ្ស៊ុលហាជ្ជះ ដូចដែលរ៉សូលុលលោះបានមានប្រសាសន៍ថា "គ្មានថ្ងៃណាមួយដែលការសាងទង្វើកុសលនៅក្នុងថ្ងៃនោះអល់ឡោះស្រលាញ់ជាងបណ្ដាថ្ងៃទាំងនេះទេ (១០ថ្ងៃខាងដើមនៃខែហ្ស៊ុលហាជ្ជះ) ពួកគេក៏បានសួរថា: ឱរ៉សូលុលលោះ! តើសូម្បីតែការតស៊ូក្នុងផ្លូវអល់ឡោះឬ? លោកបានឆ្លើយថា "សូម្បីតែការតស៊ូក្នុងផ្លូវអល់ឡោះក៏ដោយលើកលែងតែបុរសម្នាក់ចេញទៅដោយលះបង់ទាំងខ្លួនប្រាណនិងទ្រព្យសម្បត្តិរបស់គាត់ហើយគ្មានអ្វីត្រឡប់មកវិញ"។(អាល់ពូខរី ៩២៦ អាត់ទៀរមីហ្ស៊ី ៧៥៧)

2 **ពិតណាស់វាជាថ្ងៃបុណ្យហាជ្ជីធំ:** ហើយនៅក្នុងវានោះមានភារកិច្ចហាជ្ជីដ៏ច្រើន ហើយសំខាន់ៗ និងខ្ពង់ខ្ពស់ដូចជាការគប់ដុំថ្មជុំវិញកះហ្ពះ សំលេះសត្វជំនួន និងចាលើគាលអាល់អាករ៉ហ្ពះ(គោលធំជាងគេ)

## តើច្បាប់កំណត់អ្វីខ្លះនៅក្នុងថ្ងៃបុណ្យរ៉យ៉ាអាលេអាឌហា(បុណ្យរ៉យ៉ាហាជ្ជី)?

ច្បាប់បានកំណត់នៅក្នុងថ្ងៃបុណ្យរ៉យ៉ាអាលេអាឌហា( បុណ្យរ៉យ៉ាហាជ្ជី) ស្រមាប់អ្នកដែលមិនធ្វើហាជ្ជីដូចដែលបានកំណត់នៅក្នុងថ្ងៃបុណ្យរ៉យ៉ាស្រាយបួស លើកលែងតែហ្សាកាត់ហ្វិតរ៉វាគឺស្រមាប់តែបុណ្យរ៉យ៉ាស្រាយបួសប៉ុណ្ណោះ។

ហើយមានចំនុចពិសេសមួយនៅក្នុងថ្ងៃបុណ្យរ៉យ៉ាអាលេអាឌហា( បុណ្យរ៉យ៉ាហាជ្ជី) គឺគប្បីត្រូវសំលេះអាល់អ៊ុទហ៊ីយ៉ះ( សត្វស្រមាប់សំឡេះក្នុងថ្ងៃបុណ្យរ៉យ៉ាហាជ្ជី) ដើម្បីគោរពសក្ការៈទៅចំពោះអល់ឡោះ។

អាល់អ៊ុទហ៊ីយ៉ះ( សត្វស្រមាប់សំឡេះក្នុងថ្ងៃបុណ្យរ៉យ៉ាហាជ្ជី) : វាគឺជាអ្វីដែលគេយកមកសំលេះដូចជាសត្វអូដ្ឋ ឬសត្វគោ ឬពពែដើម្បីគោរពសក្ការៈចំពោះអល់ឡោះក្នុងថ្ងៃបុណ្យរ៉យ៉ាអាលេអាឌហា(បុណ្យរ៉យ៉ាហាជ្ជី) ចាប់ផ្ដើមពីសឡាតក្នុងថ្ងៃបុណ្យរហូតដល់ថ្ងៃលិចថ្ងៃនៃថ្ងៃទី១៣ នៃខែហ្ស៊ុលហាជ្ជះ អល់ឡោះបានមានបន្ទូលថា "ដូច្នេះ ចូរអ្នកសឡាត និងសំលេះសត្វដើម្បីម្ចាស់របស់អ្នកចុះ" ។( អាល់កាវសើរ ២) ហើយគេបានបកស្រាយថា សឡាតថ្ងៃបុណ្យរ៉យ៉ាហាជ្ជី និងសំលេះសត្វ។

ក្បួនច្បាប់របស់វា: ស៊ូណិតមូអាក្កាត់ស្រមាប់អ្នកដែលមានលទ្ធភាព ហើយអ្នកមូស្លីមសំលេះសត្វស្រមាប់ខ្លួនរបស់គេនិងក្រុមគ្រួសាររបស់គេ។

ច្បាប់កំណត់ស្រមាប់អ្នកដែលចង់សំលេះសត្វ មិនឱ្យគេកាត់សក់ ក្រចកនិងអ្វីម្យ៉ាងពីស្បែករបស់គេ ចាប់ពីថ្ងៃដំបូងនៃខែហ្ស៊ុលហាជ្ជះរហូតដល់ពេលសំលេះសត្វ។

## លក្ខខណ្ឌស្រមាប់សត្វែដលយកេទៅសេម្លះ មានដូចជា:

1 ចាំបាច់ត្រូវែតជាសត្វពាហណៈ វាគឺ សត្វព្រៃព ឬសត្វេគា ឬសត្វអូដ្ឋ។ េហើយមិនែតឹម្រតូវ េទេបើសិនជាេសម្លះសត្វេផ្សងេពីនះ ឬបក្សី។.

2 េហើយគ្រប់គាន់ស្រមាប់បុគ្គលម្នាក់ និង្រកុម្រគួសាររបស់គាត់ េចៀមមួយក្បាល ឬេពពមួយក្បាល។ េហើយេគអនុញ្ញាតឱ្យចូលហ៊ុនជាមួយគ្នាប្រាំពីរចំែណកក្នុងសត្វេគាមួយក្បាល ឬសត្វអូដ្ឋមួយក្បាល។.

3 សត្វ្រតូវែតមានសុវត្ថិភាពពីពិការភាពច្បាស់លាស់។ រ៉សូលុលេឡាះបានមាន្របសាសន៍ថា “មានបួន(្របេភទៃនសត្វ)ែដលេគមិនទទួលយក ការេសម្លះរបស់វាេឡើយ: សត្វែដលខ្វាក់ែភ្នក ែដលវាខ្វាក់ច្បាស់លាស់ សត្វែដលមានជំងឺ ែដលវាឈឺច្បាស់លាស់ សត្វែដលខ្វិន ែដលវាខ្វិនច្បាស់លាស់ សត្វែដលស្គមស្គាំេហើយគ្មានសង្ឃឹមជា”។(អាន ណីសាអ៊ី ៤៣៧១ អាេតៀរមីហ្ស៊ី ១៤៩៧)

## េតើត្រូវេធ្វើដូចេម្តចជាមួយនិងអាេល់អាឌហ៊ីយះ(សត្វស្រមាប់េសម្លះក្នុងៃថ្ងបុណ្យរ៉យ៉ាហាជ្ជី)?

- ហាមមិនឱ្យលក់អ្វីម៉្យាងពីអាេល់អាឌហ៊ីយះ(សត្វស្រមាប់េសម្លះក្នុងៃថ្ងបុណ្យរ៉យ៉ាហាជ្ជី) េឡើយ.
- គប្បីែបងែចកសាច់របស់វាជាបីចំែណក មួយចំែណកស្រមាប់ហូបខ្លួនឯង មួយចំែណកស្រមាប់ផ្តល់ឱ្យេគ និងមួយចំែណកេទៀតស្រមាប់បរិច្ចាកឱ្យអ្នក្រក្រីក។.
- េគអនុញ្ញាតឱ្យផ្តល់សិទ្ធឱ្យនរណាម្នាក់ និងផ្តល់ប្រាក់ដល់អង្គការសប្បុរសធម៌ែដលេជឿទុកចិត្តបានេដើម្បីឱ្យេគេសម្លះអាេល់អាឌហ៊ីយះ(សត្វស្រមាប់េសម្លះក្នុងៃថ្ងបុណ្យរ៉យ៉ាហាជ្ជី) និងែចកឱ្យអ្នកែដលេគ្រតូវការចាំបាច់។.



> ឥស្លាមបានដាក់លក្ខខណ្ឌសម្រាប់សត្វែដលយកទៅសម្លេះ េនាះ្រតូវែតមានសុវត្ថិភាពពីពិការភាព។

## ការទស្សនាទ្រីកុង ម៉ាឌីណះ

ម៉ាឌីណះជាទ្រីកុងែដលព្យាការីមូ៉ហាំម៉ាត់បានេធ្វើដំេណីទាកាន់វា នៅពេលែដលេលាកបានចាកេចញពីម៉ាក់កះ ដោយសារពួកអ្នក្របឆាំងបង្កេ្រគាះថ្នាក់ដល់េលាក។

ហើយកិច្ចការដំបូងែគដលព្យាការីបានេធ្វីនៅទីនោះគឺសាងសង ម៉ាស្ជិតអាន់ណាេពីរ ហើយវាក៏បានក្លាយជាមណ្ឌលផ្តល់នូវចំេនះដឹង ការអំពាវនាវ និងផ្សព្វផ្សាយប្រការល្អេទាដល់មនុស្សេលាក។

គុប្បីជាដាច់ខាតក្នុងការេទាទស្សនាម៉ាស្ជិទអាន់ណាេពីរ ទោះបីជានៅក្នុងរដូវេធ្វីហាជ្ជីឬផ្សេងពីនេះក៏ដោយ។

ហើយការេទាទស្សនាវានោះមិនជាប់ពាក់ព័ន្ធនិងការប្រតិបត្តិហាជ្ជីទេ ហើយក៏មិនមានេពលកំណត់ែដរ។រ៉

សូលុលេឡាះបានមាន្រ្ទបសាសន៍ថា “គេមិនបានដាក់សំពាធឱ្យេធ្វីដំេណីទាទីណាេ្រទលើែកលែងតម៉ាស្ជិទ( វិហាគូស្ឋាម) បីប៉ុេណ្ណាះ: ម៉ាស្ជីទីលហារ៉ម( នៅម៉ាក់កះ) ម៉ាស្ជិទរបស់ខ្ញុំ( នៅម៉ាឌីណះ) និងម៉ាស្ជីទីលអុកសរ( នៅបាល្លីស្ទីន)”។( អាល់ពូខរី ១១៣៩ មូស្លីម ១៣៩៧ អាពូេទៅូទ ២០៣៣)

រ៉សូលុលេឡាះបានមាន្របសាសន៍ថា “ការសឡាតនៅក្នុងម៉ាស្ជិទរបស់ខ្ញុំនេះល្អប្រេសីជាងការសឡាតេនាកែន្លងែផ្សង១០០០ដងេលីែកលែងតម៉ាស្ជីទីលហារ៉ម”។( អាលពូខរី ១១៣៣ មូស្លីម ១៣៩៤)



### តើទីកន្លែងណាដែលច្បាប់កំណត់ឱ្យទៅទស្សនាវា នៅក្នុងទីក្រុងម៉ាឌីណះ?

ចាំបាច់សម្រាប់អ្នកដែលចង់ទៅទស្សនាទីក្រុងម៉ាឌីណះត្រូវតែមានគោលបំណងទៅទស្សនាម៉ាស្ជីទរ៉សូលុលឡោះ និងប្រតិបត្តិសឡាតនៅក្នុងវា នៅពេលដែលគេមកដល់ម៉ាឌីណាះច្បាប់បានកំណត់ឱ្យទៅទស្សនាកន្លែងមួយចំនួន ដូចជា:

1. សឡាតនៅក្នុងរ៉ៅដោះ( ជាកន្លែងមួយនៅក្នុងម៉ាស្ជិទណាពី): វាជាកន្លែងដែលគេកំណត់មួយនៅខាងមុខនៃម៉ាស្ជិទ ចន្លោះរវាផ្ទះរបស់ណាពី និងមីមពើររបស់គាត់។ ការសឡាតនៅទីនោះទទួលផលបុណ្យដ៏ច្រើន។ រ៉សូលុលឡោះបានមានប្រសាសន៍ថា “នៅចន្លោះរវាងផ្ទះរបស់ខ្ញុំនិងមីមពើររបស់ខ្ញុំវាគឺជាសួនច្បារមួយនៃសួនច្បារឋានសួគ៌”។( អាល់ពូខរី ១១៣៧ មូស្លីម ១៣៩០))

2. ឱ្យសាឡាមទៅលើណាពី: ធ្វើដំណើទៅកន្លែងផ្នូររបស់ណាពី ហើយឈរនៅពីមុខផ្នូររបស់គាត់ តម្រង់មុខទៅផ្នូរ ហើយគឺបឡាត់នៅខាងក្រោយ ហើយនិយាយដោយសីលធម៌ និងប្រើសំលេងតិចៗថា: “អាស្សាឡាមូអាឡៃកើ យ៉ារ៉សូលុលឡហ៊ុ វ៉ារ៉ោះម៉ាតុលឡហ៊ី វ៉ាប៉ារ៉ាកើតុះ អាស្សហ្លើទុ អាន់ណាកើ កត់ពើលលុកតារ រ៉សើឡះ វ៉ាអាទទៃតាល អាម៉ាណះ វ៉ាណាស៊ោះតាល អ៊ុំម៉ះ វ៉ាជើហ៊ើទតា ហ្វីលឡហ៊ិ

ហ៊ុក្គុកជីហើទីស ហ្វាជើហ្សើកុលទ្យហ៊ីអាន់ អ៊ុំម៉ាតីកើ អាហ្វដល្ល ម៉ាជើហ្សេ ណ៊ុព៉យ៉ាន់ អាន អ៊ុំម៉ាតីហ៊ុ”។ ហើយពិតណាស់រ៉សូលុលឡោះបានមានប្រសាសន៍ថា “ពេលមនុស្សគ្រប់រូបដែលគាត់អោយសាឡាមមុមកចំពោះខ្ញុំ អល់ឡោះបង្វិលព្រលឹង របស់ខ្ញុំមកវិញ ដើម្បីអោយខ្ញុំឆ្លើយតបចំពោះការអោយសាឡាមរបស់គាត់”។(អាពូទើវូទ ២០៤១).

បន្ទាប់មកែបរមុខេទៅខាងស្ដាំដើម្បេីអោយសាឡាមេទៅ អាពួពើកើរ ដែលជាមេដឹកនាំឥស្លាម ហើយជាសហាហ្ពះដែលល្អប្រែពជាងេគ។

បន្ទាប់មកឈានទៅខាងស្ដាំហើយអោយសាឡាមទៅលើ អ៊ុម៉ើរ ដែលជាមេដឹកនាំទីពីរ ហ្ហើយជាសហាហ្ពះដែលល្អប្រពៃបន្ទាប់ពី អាពូពើកើរ។

ហើយរ៉សូលុលឡោះគាត់ជាមនុស្សដែលល្អប្រពៃបំផុត ហើយគាត់គ្មានលទ្ធភាពផ្ដល់ផលប្រយោជន៍ ឬបង្ករគ្រោះថ្នាក់ដល់នរណាម្នាក់ឡើយ មិនអនុញ្ញាតទេចំពោះការបួងសួង ឬសុំជំនួយពីគាត់ ផ្ទុយទៅវិញការបួងសួង នឹងការគោរពសក្ការៈទាំងអស់គឺចំពោះអល់ឡោះតែម្នាក់គត់គ្មានអ្វីចូលរួមជាមួយទ្រង់ឡើយ។



> ម៉ាស្ជិតកូពើ នៅម៉ាទីណះ អាល់មូណាវ៉រ៉ោះ ក្នុងចំណោមសុណ្ណះគឺឲ្យយើងទៅទស្សនកិច្ចនឹងសឡាតនៅក្នុងនោះ

3 ការទៅទស្សនាម៉ាស្ជីទកូហ្ពើក(វិហាឥស្លាម): វាជាម៉ាស្ជីទដែលគេក៏សាងដំបូងគេបង្អស់នៅក្នុងសាសនាឥស្លាមមុនពេលណាពីសាងសង់ម៉ាស្ជីទរបស់គាត់។ ហើយគប្បីសម្រាប់អ្នកដែលរស់នៅទីក្រុងម៉ាឌីណះទៅទស្សនាម៉ាស្ជីទកូហ្ពើក ហើយពិតណាស់រ៉សូលុលឡោះតែងតែទៅទស្សនាវា។ ហើយរ៉សូលុលឡោះបានមានប្រសាសន៍ថា “បុគ្គលណាហើយដែលបានសំអាតខ្លួននៅក្នុងផ្ទះរបស់គាត់ បន្ទាប់មកគាត់ធ្វើដំណើរទៅម៉ាស្ជីទកូហ្ពើក ហើយសឡាតនៅទីនោះ មានហើយសម្រាប់គាត់ទទួលបានផលបុណ្យដូចធ្វើអ៊ុំរ៉ោះ”។(អ៊ិពនូម៉ាយ៉ះ ១៤១២)។




# ប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក



# 7

សាសនាឥស្លាមបានដាក់បទបញ្ញត្តិនិងក្បួនច្បាប់ទាំងអស់ដើម្បីថែរក្សាមនុស្ស និងការពារទ្រព្យសម្បត្តិនិងវិជ្ជាជីវៈរបស់ពួកគេ សូម្បីតែអ្នកមាន ឬអ្នកក្រកក៏ដោយ។ ហើយរួមចំណែកក្នុងការផ្សាភ្ជាប់សង្គម និងការវិវត្តន៍ និងការអភិវឌ្ឍ ក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិត។

## មាតិការជំពូក

ប្រភពដើមនៃប្រតិបត្តិការហាឡាល(អនុញ្ញាត្តិ)

អ្វីដែលបានហាមឃាត់ដោយសារតែមិនបរិសុទ្ធពីខ្លួនរបស់វា

អ្វីដែលបានហាមឃាត់ដោយសារតែទទួលបានផលប្រយោជន៍ពីវា

ការប្រាក់(រីពើ)

- ការប្រាក់ក្នុងបំណុល
- ការប្រាក់ក្នុងប្រាក់កម្ចី
- ច្បាប់ឥស្លាមទាក់ទងនិងការប្រាក់
- ទារុណកម្មក្នុងការប្រាក់

ហានិភ័យរបស់ប្រាក់ការទៅលើបុគ្គល និងសង្គម

ភាពមិនប្រាកដប្រជានិងភាពល្ងង់ខ្លៅ

ភាពអយុត្តិធម៌ និងការយកទ្រព្យសម្បត្តិរបស់មនុស្សដោយមិនត្រឹមត្រូវ

- ផលប៉ះពាល់នៃការលេងល្បែងស៊ីសងទៅលើបុគ្គលនិងសង្គម

សុជីវធម៌ដែលឥស្លាមបានសង្កត់ធ្ងន់ក្នុងប្រតិបត្តិការហិរញ្ញវត្ថុគឺ:

- ការផ្តល់ទំនុកចិត្ត
- សេចក្តីទៀងត្រង់
- ជំនាញ

# ប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក

អល់ឡោះបាននៃប្រើឱ្យស្វែងរកនៅលើផែនដីដើម្បីទាមទាលាភសក្ការៈ និងមានឆន្ទៈទៅលើវា។ ហើយក៏មានការបង្ហាញយ៉ាងច្បាស់ពីចំណុចនេះដូចជា:

- ពិត្រុបាកួដណាស់គេបានហាមឃាត់អំពីការសុំទានពីមនុស្សដរាបណាគេនៅមានលទ្ធភាពធ្វើការ និងទទួលផលពីការខិតខំប្រឹងប្រែង និងទង្វើរបស់គេ។ ហើយគេបានប្រាប់ថាអ្នកដែលសុំទានមនុស្ស ហើយវាមានលទ្ធភាពធ្វើការ និងទទួលផល ពិត្រុបាកដណាស់វាខាតបង់ឋានៈរបស់គេចំពោះអល់ឡោះ និងចំពោះមនុស្ស។ រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថា "អ្នកខ្លះនៃពួកអ្នកនៅសុំគេរហូតដល់ពេលជួបនឹងអល់ឡោះ នៅលើមុខរបស់គាត់គ្មានសាច់មួយដុំឡើយ"។(អាល់ពូខរី ១៤០៥ មូស្លីម ១០៤០)
  រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថា (បុគ្គលណាមានតម្រូវការទ្រព្យសម្បត្តិអ្វីមួយ ហើយគាត់សុំអំពីមនុស្ស គេនឹងមិនអាចបំពេញតម្រូវការរបស់គាត់ឡើយ។ ចំណែកបុគ្គលណាមានតម្រូវការទ្រព្យសម្បត្តិអ្វីមួយ ហើយគាត់សុំអំពីអល់ឡោះ អល់ឡោះនឹងផ្តល់លាភសក្ការៈដល់គាត់ភ្លាមៗ ឬនៅពេលក្រោយ)។(អះម៉ាត់ ៣៨៦៩ អាពូទើវូទ ១៦៤៥)

- វិជ្ជាជីវៈឧស្សាហកម្ម សេវាកម្ម និងការវិនិយោគទាំងអស់នេះជាកិច្ចការថ្លៃថ្នូរ វាមិនថោកទាបនោះទេ ដរាបណាស្ថិតក្នុងដែនដែលគេអនុញ្ញាត។ ហើយបទបញ្ញត្តិបាននាំមកថាបណ្ដាណាពីពួកគាត្រូវបកបរការងារទៅតាមវិជ្ជាជីវៈគោលរបស់ពួកគាតែដលេគអនុញ្ញាត។ ដូចរ៉ស៊ូលុលឡោះបានមានប្រសាសន៍ថា "គ្រប់ណាពីទាំងអស់ដែលអល់ឡោះបានចាត់តាំងសុទ្ធតែជាអ្នកគង្វាលចៀម"។(អាល់ពូខរី ២១៤៣) ណាពីហ្សាការីយ៉ាគឺជាជាងឈើ (មូស្លីម ២៣៧៩) ហើយក៏ដូច្នោះដែរណាពីៗដ៏ទៃទៀតគាត្រូវបកបរការងារទៅតាមវិជ្ជាជីវៈនោះ។)



> កិច្ចការដែលគេអនុញ្ញាតិទាំងអស់គឺជាកិច្ចការដែលថ្លៃថ្នូរ វាមិនថោកទាបនោះទេ។

- ពិតណាស់ស្រមាប់អ្នកដែលប្រកបការងារដោយចិត្តស្មោះសរដើម្បីផ្គត់ផ្គង់លើខ្លួនរបស់គេ និងក្រុមគ្រួសាររបស់គេ និងបំពេញតម្រូវការរបស់មនុស្ស និងផ្តល់ផលប្រយោជន៍ដល់អ្នកដែលត្រូវការ ពិតណាស់រូបគាត់នឹងទទួលបានផលបុណ្យពីការប្រកបការងាររបស់គាត់និងការខិតខំប្រឹងប្រែងរបស់គាត់។.

## ប្រភពដើមនៃប្រតិបត្តិការ

ប្រភពដើមនៃប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់គឺមកពីការលក់ ការទិញ និងការជួល និងផ្សេងពីនេះទៀតដែលមនុស្សប្រតិបត្តិការវានិងត្រូវការវា: គេអនុគ្រោះនិងគេអនុញ្ញាត លើកលែងតែអ្វីដែលគេហាមឃាត់ដោយសារតែមិនបរិសុទ្ធពីខ្លួនរបស់វា ឬអ្វីដែលបានហាមឃាត់ដោយសារតែទទួលបានផលប្រយោជន៍ពីវា។.

## អ្វីដែលគេហាមឃាត់ដោយសារតែមិនបរិសុទ្ធពីខ្លួនរបស់វា

វាជាប្រការហាមឃាត់ដែលអល់ឡោះបានហាមវាដោយសារមិនបរិសុទ្ធពីខ្លួនរបស់វា ហើយមិនអនុញ្ញាតឱ្យលក់វា ទិញវា ជួលវា ឬកិច្ចការអ្វីដែលទទួលបានផលនៃចកចាយទៅដល់មនុស្ស។.

ឧទាហរណ៍អំពីអ្វីដែលត្រូវហាមឃាត់ដោយសារតែមិនបរិសុទ្ធពីខ្លួនរបស់វា:

- សត្វឆ្កែ និងសត្វជ្រូក
- សត្វដែលបានស្លាប់ ឬផ្នែកខ្លះអំពីវា
- សុរា និងគ្រឿងបរិភោគដែលមានជាតិអាកុល
- គ្រឿងញៀន និងរាល់អ្វីដែលនាំឱ្យខូចសុខភាព
- សម្ភារៈដែលមានបំណងក្នុងការរីករាលដាលអំពើបាសចាក់ទៅដល់មនុស្ស ដូចជាវីដេអូរបៀបសាយ និងទស្សនាវដ្តីអាសអាភាស។s
- រូបសំណាក និងរាល់អ្វីដែលគេគោរពផ្សេងពីអល់ឡោះ

## អ្វីដែលបានហាមឃាត់ដោយសារតែទទួលបានផលប្រយោជន៍ពីវា

វាគឺជាទ្រព្យសម្បត្តិដែលប្រភពដើមវាគេអនុញ្ញាត ប៉ុន្តែគេហាមឃាត់វាដោយមូលហេតុទទួលផលពីវាដែលនាំឱ្យបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គម។ ដូច្នេះគេហាមឃាត់វាដោយមូលហេតុនោះ។ បណ្តាមូលហេតុដែលគេហាមឃាត់ក្នុងប្រតិបត្តិការវានោះគឺ:

ការប្រាក់ ភាពមិនប្រាកដប្រជា និងភាពល្ងង់ខ្លៅ រំលោភបំពាន ល្បែងស៊ីសង។.

ហើយយើងនឹងបកស្រាយអំពីវាដូចខាងក្រោម:

## > ការប្រាក់

> ការប្រាក់វាជាអ្វីដែលលើសដែលច្បាប់ហាមឃាត់ ដោយសារនៅក្នុងវាមានការរំលោភបំពាន និង បង្កគ្រោះថ្នាក់។

វាមានច្រើនប្រភេទ ប្រភេទដែលល្បីល្បាញ និងគេហាមឃាត់ខ្លាំងបំផុតនោះគឺ: ការប្រាក់ក្នុងប្រាក់កម្ចី និងបំណុល។ វាគឺ: ជាការបន្ថែមពីលើបាក់ដើមដោយមិនមែនជាការលក់ ឬទិញរវាងពីរភាគី។ហើយវាមានពីរប្រភេទ: .



> រាល់ប្រាក់កម្ចី ឬបំណុលដែលជាមូលហេតុផ្តល់ផលដល់អ្នកដែលឱ្យគេខ្ចី វាគឺជាការប្រាក់។

### ■ ការប្រាក់ក្នុងបំណុល

វាជាការបន្ថែមលើបំណុលនៅពេលដែលដល់ពេលកំណត់ទូទាត់ ប្រសិនបើកូនបំណុលមិនមានលទ្ធភាពសង។.

Eឧទាហរណ៍របស់វា: សាអ៊ីទបានខ្ចីលុយពី ខលីទ ១000ដុល្លា និងទូទាត់គ្នានៅខែក្រោយ។ នៅពេលដែលដល់ថ្ងៃខែហើយពេលវេលាទូទាត់ក៏មកដល់ ប៉ុន្តែ សាអ៊ីទមិនមានលទ្ធភាពសង និងទូទាត់បាក់នោះទេ។ អ្នកដែលឱ្យគេខ្ចី ខលីទ បានដាក់លក្ខខណ្ឌថាបើទូទាត់គ្នាពេលនេះគឺមិនមានការបន្ថែមទេ តែបើចាំទូទាត់គ្នាខែក្រោយគឺ ១១00ដុល្លា ហើយបើសិនជានៅតែគ្មាននៅខែក្រោយមួយទៀតគឺ ១២00ដុល្លា។.

### ■ ការប្រាក់ក្នុងប្រាក់កម្ចី

វាមានន័យថាការខ្ចីប្រាក់មួយចំនួនពីបុរសម្នាក់ ឬពីធនាគារដោយលក្ខខណ្ឌឱ្យប្រាក់បន្ថែមនៅពេលទូទាត់ ដោយឯកភាពគ្នាលើចំនួន៥%ក្នុងមួយឆ្នាំ ឬតិចជាង ឬច្រើនជាង។.

ឧទាហរណ៍របស់វា: គេចង់ទិញផ្ទះដែលមានតម្លៃ(មួយរយពាន់) ហើយគេគ្មានប្រាក់គ្រប់គាន់។ ហើយគេក៏ទៅធនាគារ ហើយខ្ចីប្រាក់(មួយរយពាន់)ដើម្បីទិញផ្ទះ ដោយលក្ខខណ្ឌគេនឹងទូទាត់ទៅឱ្យធនាគារវិញចំនួនមួយរយហាសិបពាន់នៅលើការបង់រំលស់រយៈពេលប្រាំឆ្នាំ។.

ការប្រាក់គឺត្រូវហាមឃាត់ហើយវាជាបាបកម្មដ៏ធំដែលរាល់ប្រាក់កម្ចីទទួលបានផលប្រយោជន៍។ ទោះបីជាប្រាក់កម្ចីនោះផ្តល់ផលដល់ការវិនិយោគពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬដើម្បីទិញទ្រព្យសម្បត្តិសំខាន់ដូចជាផ្ទះឬអាគារឬប្រើប្រាស់ដើម្បីបំពេញតម្រូវការ។

ចំណេញការទិញទំនិញដោយតំលៃថ្លៃជាងតំលៃដើម ដោយការបង់រំលស់វាមិនមែនជាការប្រាក់ឡើយ។

ឧទាហរណ៍: បុគ្គលម្នាក់ទិញឧបករណ៍មួយតំលៃ១០០០ដុល្លាឱ្យលុយភ្លាម ឬតំលៃ១២០០ដុល្លាដោយបង់រំលស់ប្រចាំខែរយៈពេលមួយឆ្នាំក្នុងមួយឆ្នាំ១០០ដុល្លាបង់វាឱ្យម្ចាស់ហាងពីការដែលគាត់ទិញឧបករណ៍នោះ។

## ច្បាប់ទាក់ទងនឹងការប្រាក់

ភស្តុតាងពីអត្ថបទ គួរអាន និងហាឌីសរបស់ណាពីបានចង្អុលបង្ហាញយ៉ាងច្បាស់ថា ការប្រាក់ត្រូវបានហាមឃាត់យ៉ាងតឹងរឹងក្នុងសាសនាឥស្លាម ហើយវាជាអំពើបាបកម្មដ៏ធំមួយ ដែលអល់ឡោះបានសន្យាប្រកាសស្រង្គ្រាមលើបុគ្គលណាមួយមិនមនុស្សប្រឆាំងឡើយលើកលែងតែអ្នកស៊ីការប្រាក់ និងអ្នករួមចំណែក។ការប្រាក់ ត្រូវបានហាមឃាត់មិនមែនមានតែនៅក្នុងសាសនាឥស្លាមទេតែថែមទាំងនៅក្នុងសាសនារបស់អល់ឡោះពីមុនទាំងអស់ ក៏ប៉ុន្តែវាត្រូវបានគេកែប្រែ និងប្រឆាំងដូចដែលគេបានធ្វើវាក្នុងច្បាប់ផ្សេងទៀត។ អល់ឡោះបានមានបន្ទូលបញ្ជាក់យ៉ាងច្បាស់ពីមូលហេតុការផ្តន្ទាទោសដល់ក្រុម អះលីគីតាប់ថា “ និងដោយសារតែពួកគេទទួលយកការប្រាក់ដែល អល់ឡោះបានហាមឃាត់ពួកគេអំពីវា”។(អាន់នីសាក ១៦១)

## ការផ្តន្ទាទោសលើការស៊ីការប្រាក់

1 អ្នកដែលបានចូលរួមប្រតិបត្តិការក្នុងការប្រាក់ វាបានបង្ហាញខ្លួនដើម្បីស្រង្គ្រាមជាមួយអល់ឡោះនិងរ៉សូលុលឡោះ ហើយបានក្លាយជាសត្រូវជាមួយអល់ឡោះនិងរ៉សូលុលឡោះ។អល់ឡោះបានមានបន្ទូលថា “ ហើយប្រសិនបើពួកអ្នកមិនព្រមបោះបង់ចោល (ការប្រាក់)ទេ ពួកអ្នកត្រូវដឹងថា នឹងមានស្រង្គ្រាមមកពីអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ តែប្រសិនបើពួកអ្នកបោះបង់ចោល(ការប្រាក់)សម្រាប់ពួកអ្នកគឺប្រាក់ដើមរបស់ពួកអ្នក។ (ការធ្វើដូច្នេះ) ពួកអ្នកមិនបំពានលើគេ ហើយគេក៏មិនបំពានលើពួកអ្នកដែរ”។(អាល់ហ្ពាក៏រ៉ោះ ២៧៩) វាគឺជាស្រង្គ្រាមជាមួយនឹងផលប៉ះពាល់ផ្លូវចិត្តនិងរាងកាយ។ អ្វីដែលមនុស្សទទួលបានបច្ចុប្បន្នអំពីការព្រួយបារម្ភ ពិបាកចិត្ត ទុក្ខព្រួយ ទុក្ខលំបាកលើកលែងតែវាជាសញ្ញាមួយចំនួននៃសង្គ្រាមដែលអល់ឡោះបានប្រកាសលើពួកអ្នកដែលមិនគោរពតាមបទបញ្ជារបស់ទ្រង់ និងយកប្រាក់ការ ឬចូលរួមជាមួយគេ។ ចុះបើស្រង្គ្រាមនៅថ្ងៃបរលោកវិញតើវានឹងផ្តល់ផលប៉ះពាល់កំរិតណា?.

2 អ្នកដែលយកប្រាក់ការ និងអ្នកដែលចូលរួមជាមួយគ្នាត្រូវបានគេដាក់បណ្តាសា និងដាក់ចេញពីក្តីមេត្តាករុណារបស់អល់ឡោះ សម្រាប់វានិងអ្នកដែលចូលរួមជាមួយវាដូចគ្នា។ អំពី ជើព្រៀរ គាត់បាននិយាយថា “រ៉សូលុលឡោះបានដាក់បណ្តាសាចំពោះអ្នកដែលស៊ីប្រាក់ការ និងអ្នកដែលឱ្យគេស៊ីវា និងអ្នកកត់ត្រា ព្រមទាំងសាក្សីទាំងពីរ”ហើយលោកមានប្រសាសន៍ថា “ពួកគេទាំងអស់នោះគឺដូចគ្នា” ។( មូស្លីម ១៥៩៨)

3 អ្នកដែលយកប្រាក់ការពួកគេនឹងត្រូវបានរស់ឡើងវិញនៅថ្ងៃបរលោកក្នុងរូបភាពដែលថោកទាបបំផុតនិងទទួលរងពីជំងឺស្កន់ និងឆ្កួត។អល់ឡោះបានមានបន្ទូលថា “ ពួកដែលស៊ីការប្រាក់នោះ ពួកគេមិនអាចក្រោកឈរបានទេ(នៅថ្ងៃបរលោក) លើកលែងតែគេក្រោកឈរដូចអ្នកដែលស្ហៃតនចូលដល់ធ្វើឱ្យគេឆ្កួតប៉ុណ្ណោះ”។(អាល់ហ្ពាក៏រ៉ោះ ២៧៥)

4 ទ្រព្យសម្បត្តិបានពីការប្រាក់ការនៃតែច្រើនវានិងលុបបំបាត់ភាពរីកចំរើន វាមិនទទួលបានក្តីសុខសុភមង្គល និងស្ងប់ស្ងាត់ឡើយ។ អល់ឡោះបានមានបន្ទូលថា “ អល់ឡោះបំបាត់ភាពរីកចំរើនចំពោះការប្រាក់។ ប៉ុន្តែ ទ្រង់បង្កើនផលចំពោះទ្រព្យបរិច្ចាគនានា”។(អាល់ហ្ពាក៏រ៉ោះ ២៧៦

## ហានិភ័យរបស់ការប្រាក់ទៅលើបុគ្គល និងសង្គម

ពិតណាស់ឥស្លាមបានសង្កត់ធ្ងន់លើការប្រាក់ដោយសារវាផ្តល់ផលប៉ះពាល់ការបំផ្លិចបំផ្លាញទៅលើបុគ្គល និងសង្គម។ ដូចជា:

### 1 វាបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរក្នុងការបែងចែកចាយទ្រព្យសម្បត្តិនិងពង្រីកនូវភាពឆ្ងាំឆ្ងងរវាងអ្នកមាននិងអ្នកក្រ

ដោយសារការប្រាក់ផ្តោតលើទព្យសម្បត្តិនៅក្នុងដៃរបស់បុគ្គលមួយចំនួនតូចក្នុងចំណោមបុគ្គលក្នុងសង្គមមួយ ហើយបានហាមឃាត់មួយក្រុមធំ។វាបណ្តាលឱ្យមានបញ្ហាក្នុងការចែកចាយទ្រព្យសម្បត្តិ អំពីសង្គមទៅឱ្យបុគ្គលមួយចំនួនតូចដែលមានទ្រព្យសម្បត្តិទំនើបសម្បូរបែប ហើយទៅសល់តែអ្នកក្របំរែងប្រែងធ្វើការអ្នកក្រក្រីក និងអ្នកខ្វះខាត។ នេះគឺជាបរិស្ថានដែលល្អប្រសើរសម្រាប់ការរីករាលដាលនៃការស្អប់និងឧក្រិដ្ឋកម្មក្នុងសង្គម។.

### 2 ផ្តល់ឱ្យមានទម្លាប់ហ៊ីហា និងកង្វះការសន្សំសំចៃ។

ភាពងាយស្រួលនៃប្រាក់កម្ចីការប្រាក់នេះបានលើកទឹកចិត្តមនុស្សជាច្រើននៃលើការហ៊ីហានិងកង្វះការសន្សំសំចៃ។ ពេព្រោះវាមានអ្នកដែលចាំឱ្យប្រាក់កម្ចីវាលៃពលដែលត្រូវការ ដោយមិនបានគិតគូរពីបច្ចុប្បន្ន និងអនាគតរបស់គេឡើយ គឺតែគិតពីចំណាយបំពេញតម្រូវការរហូតដល់បំណុលជុំទិស និងជីវិតដែលចង្អៀត។ ហើយស្ថិតនៅក្នុងឆាកជីវិតលំបាកវេទនាដោយសារតែបំណុល និងប្រាក់កម្ចីទាំងនោះ។.

### 3 វាបានទប់ស្កាត់អ្នកមានទ្រព្យពីការវិនិយោគនៅក្នុងគម្រោងប្រយោជន៍ក្នុងស្រុក

ម្ចាស់ប្រាក់ទទួលបានព្រឹបព័ន្ធការប្រាក់ នូវឱកាសដើម្បីទទួលបានភាគរយមួយចំនួននៅក្នុងការប្រាក់ប្រាក់របស់គាត់។ ហើយពួកគាត់បានបញ្ឈប់ពីការវិនិយោគដើមទុនរបស់ខ្លួននៅក្នុងគម្រោងឧស្សាហកម្ម កសិកម្មនិងពាណិជ្ជកម្មទោះបីជាវាផ្តល់ផលប្រយោជន៍ក្នុងសង្គមក៏ដោយ។ដោយសារតែវាមានក្រមិតនៃហានិភ័យ និងទាមទារឱ្យមានការខិតខំប្រឹងប្រែង និងទង្វើ។.

### 4 ការប្រាក់ជាមូលហេតុក្នុងការលុបបំបាត់ភាពរីកចំរើននៃទ្រព្យសម្បត្តិនិងនាំឱ្យមានវិបត្តិសេដ្ឋកិច្ច

រាល់វិបត្តិសេដ្ឋកិច្ច និងការក្ស័យធនរបស់សហគ្រាសធំៗ ឬបុគ្គល គឺដោយសារការចូលរួមក្នុងការយកការប្រាក់ដែលគេហាមឃាត់ វាគឺជាសញ្ញាមួយដែលពិត្រាប្រាកដែលអល់ឡោះបានប្រាប់ ដែលជួយពីការបរិច្ចាគ និងអំពើល្អចំពោះមនុស្ស វាគឺ ផ្តល់ភាពចំរុងចំរើនដល់ទ្រព្យសម្បត្តិ និងបង្កើនវា។ អល់ឡោះបានមានបន្ទូលថា “ អល់ឡោះបំបាត់ភាពរីកចំរើនចំពោះការប្រាក់។ ប៉ុន្តែ ទ្រង់បង្កើនផលចំពោះទ្រព្យបរិច្ចាគនានា” ។( អាល់ហ្គោកេរ៉ាៈ ២៧៦ )



> ការប្រាក់ជាមូលហេតុក្នុងការលុបបំបាត់ភាពរីកចំរើននៃទ្រព្យសម្បត្តិនិងនាំឱ្យមានវិបត្តិសេដ្ឋកិច្ច

## តើច្បាប់ចែងដូចម្តេចចំពោះបុគ្គលម្នាក់ចូលឥស្លាមហើយគាត់នៅជាប់ពាក់ព័ន្ធជាមួយកិច្ចសន្យាការប្រាក់?

ប្រសិនបើបុរសម្នាក់ចូលឥស្លាមហើយគាត់នៅជាប់ពាក់ព័ន្ធជាមួយកិច្ចសន្យាការប្រាក់ ស្រមាប់គាត់មានពីរករណី:

1. ប្រសិនបើគាត់ជាអ្នកយកប្រាក់បន្ថែម(យកការប្រាក់) គាត់ត្រូវយកតែប្រាក់ដើមរបស់គាត់ ហើយមិនត្រូវយកអ្វីបន្ថែមទៀតឡើយដោយសារគាត់បានចូលឥស្លាម។អល់ឡោះបានមានបន្ទូលថា “តែប្រសិនបើពួកអ្នកបោះបង់ចោល(ការប្រាក់)ស្រមាប់ពួកអ្នកគឺប្រាក់ដើមរបស់ពួកអ្នក។ (ការធ្វើដូច្នេះ) ពួកអ្នកមិនបំពានលើគេ ហើយគេក៏មិនបំពានលើពួកអ្នកដែរ”។(អាល់ហ្ពាក់ករ៉ោះ ២៧៩).

2. ២-ប្រសិនបើគាត់ជាអ្នកបង់ប្រាក់បន្ថែម ស្រមាប់គាត់មានពីរករណី:

- ប្រសិនបើគាត់មានសមត្ថភាពលុបកិច្ចសន្យា និងចេញអំពីវាដោយគ្មានគ្រោះថ្នាក់ធ្ងន់ធ្ងរចាំបាច់ឱ្យគាត់ធ្វើដូចនោះ។.
- តែបើសិនជាគាត់មិនអាចលុបកិច្ចសន្យាលើកលែងតែមានគ្រោះថ្នាក់ធ្ងន់ធ្ងរ នោះពិតណាស់គាត់ត្រូវបំពេញកិច្ចសន្យាហើយគាត់ត្រូវប្តេជ្ញាចិត្តថាមិនត្រលប់ទៅធ្វើដូចនេះទៀតទេ។ អល់ឡោះបានមានបន្ទូលថា “ ហើយអ្នកណា ដែលទទួលបាននូវការទូន្មានពីម្ចាស់របស់គេ ហើយគេបោះបង់ចោល(ឈប់យកការប្រាក់) ដូច្នេះអ្វីដែលមានពីមុន(មុនទទួលមាន មកដល់)គឺជាកម្មសិទ្ធិរបស់គេ ហើយរឿងរ៉ាវរបស់គេគឺអាស្រ័យលើអល់ឡោះ។ រីឯអ្នកណាបានត្រឡប់ទៅ(ស៊ីការប្រាក់)វិញ ពួកទាំងនោះជាពួកនរក។ ពួកគេគឺស្ថិតនៅក្នុងនោះជាអមតៈ”។(អាល់ហ្ពាកេរ៉ោះ ២៧៥)



# > ភាពមិនប្រាកដប្រជានិងភាពល្ងង់ខ្លៅ



មានន័យថារាល់កិច្ចសន្យាទាំងអស់ដែលមានមូលដ្ឋាននៅលើភាពមិនច្បាស់លាស់និងភាពល្ងង់ខ្លៅ ហើយវាអាចជាមូលហេតុក្នុងការខ្វែងគំនិត និងមានជម្លោះរវាងភាគីទាំងពីរ ឬជាការប្រៀបប្រាស់ម្នាក់រវាងគេទាំងពីរលើម្នាក់ទៀត។.

ពិតណាស់សាសនាឥស្លាមបានហាមឃាត់ដើម្បីទប់ស្កាត់មេធ្យាបាយនាំឱ្យមានជម្លោះ ឬការប្រៀបប្រាស់ និងភាពអយុត្តិធម៌។ ហើយសូម្បីតែមនុស្សព្រមព្រៀងលើវាក៏គេមិនអនុញ្ញាតែដែរ ពិតណាស់ណាពីបានហាមឃាត់អំពីការលក់ដែលមិនប្រាកដប្រជា(មូស្លីម ១៥១៣)

## ឧទាហរណ៍ ស្រមាប់ការលក់ដែលមិនប្រាកដប្រជានិងល្ងង់ខ្លៅ:

1. លក់ផ្លែឈើមុនពេលវាបង្ហាញផ្តល់ដែលល្អរបស់វាហើយនឹងត្រូវបានត្រៀមខ្លួនជាស្រេចសម្រាប់ការជ្រើសរើស។ ពិតណាស់រសូលុល្លោះបានហាមឃាត់ទៅលើវា ពីព្រោះការមិនច្បាស់លាស់អំពីការខូចខាតរបស់វាមុនពេលកំណត់។.
2. ការបង្រ់បាក់មួយចំនួននៃដើម្បីទិញព្រាបអបេដោយមិនបានដឹងថាអ្វីដែលមានក្នុងវា វាអាចជារបស់ដែលមានតែម្លៃថ្លៃ ឬក៏អ្វីដែលធម្មតា។ ហើយដូចគ្នាផងដែរ ការលក់អ្វីដែលមិនមែនជារបស់គេ និងអ្វីដែលគេគ្មានលទ្ធភាពទទួលយកវា។.

## នៅពេលណាដែលការមិនច្បាស់លាសផ្តល់ផលប៉ះពាល?

ការមិនច្បាស់លាស់និងភាពល្ងង់ខ្លៅមិនមានផលប៉ះពាល់ដល់ការហាមឃាត់នៃកិច្ចសន្យានោះទេ លើកលែងតែវាមិនច្បាស់ខ្លាំង និងវាមានក្នុងប្រភពដើមនៃកិច្ចសន្យាមិនមែនក្នុងសាខារបស់វា។.

ដូច្នេះអ្នកមូស្លីមអាចទិញផ្ទះមួយ បើទោះបីជាគាត់មិនបានដឹងពីប្រភេទនៃសម្ភារៈសំណង់ដែលត្រូវបានប្រើក្នុងការសាងសង់ផ្ទះ និងប្រភេទនៃទឹកថ្នាំលាប និងអ្វីផ្សេងទៀត ពីព្រោះវាជាភាពល្ងង់ខ្លៅតូចតាច បន្ទាប់មកវាកើតនៅក្នុងសាខានៃកិច្ចសន្យាមិនមែនប្រភពដើមរបស់វាទេ។

## > ភាពអយុត្តិធម៌ និងការយកទ្រព្យសម្បត្តិរបស់មនុស្សដោយមិនត្រឹមត្រូវ

ភាពអយុត្តិធម៌វាជាទង្វើដែលថោកទាបបំផុត ដែលអ៊ីស្លាមបានប្រើឱ្យមានការប្រុងប្រយ័ត្នអំពីវា។រ៉សូលុល្លោះបានមានប្រសាសន៍ថា "ទង្វើអយុត្តិធម៌ធ្វើឱ្យមានភាពងងឹតនៅថ្ងៃបរលោក"។(អាល់ពូខរី ២៣១៥ មូស្លីម ២៥៧៩)

ការយកទ្រព្យសម្បត្តិរបស់មនុស្សដោយមិនត្រឹមត្រូវសូម្បីតែតិចតួចក៏ដោយវាជាអំពើបាប និងជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ដែលគេបានសន្យាចំពោះអ្នកដែលប្រព្រឹត្តវាក្នុងការដាក់ទណ្ឌកម្មយ៉ាងខ្លាំងក្លាក្នុងថ្ងៃបរលោក។រ៉សូលុល្លោះបានមានប្រសាសន៍ថា "ជនណារំលោភបំពានដើគ មួយចង្អាម គេនឹងយកដីនោះប្រាំពីរជាន់ដាក់រុំលើគាត់នៅថ្ងៃបរលោក"។(អាល់ពូខរី ២៣២១ មូស្លីម ១៦១០)

### ឧទាហរណ៍ខ្លះៗអំពីភាពអយុត្តិធម៌ក្នុងការប្រតិបត្តិការៈ

**1** ការបង្ខិតបង្ខំៈ មិនអនុញ្ញាតេទឱ្យមានការបង្ខិតបង្ខំក្នុងការប្រតិបត្តិការឡើយ ទោះជាប្រភេទនៃការបង្ខិតបង្ខំនិងគាបសង្កត់ណាក៏ដោយ។ហើយកិច្ចសន្យាមិនបានត្រឹមត្រូវទេឡើយលើកលែងតែមានការយល់ព្រម។ រ៉សូលុល្លោះបានមានប្រសាសន៍ថា "តាមពិតការលក់ដូរត្រឹមត្រូវនោះគឺដោយមានការយល់ព្រម។" ( អ៊ីពនូម៉ាយ៉ះ ២១៨៥)

**2** ការបោកប្រាស់ និងលួចបន្លំមនុស្សៈ ដើម្បីយកទ្រព្យសម្បត្តិរបស់ពួកគេដោយមិនត្រឹមត្រូវ។វាគឺជាអំពើបាបដ៏ធ្ងន់ធ្ងរ។ រ៉សូលុល្លោះបានមានប្រសាសន៍ថា " ហើយជនណាបោកប្រាស់ពួកយើង មិនមែនជាក្រុមរបស់ពួកយើងទេ"។(មូស្លីម ១០១)
ហើយមូលហេតុនៃហាឌីសនេះ ពិតណាស់រ៉សូលុល្លោះបានដើរឆ្លងកាត់អាហារមួយពំនូក លោកក៏បានលូកដៃចូលក្នុងអាហារនោះ ស្រាប់តែម្រាមដៃរបស់គាត់មានសំណើមទឹក។ លោកក៏សួរថាៈ ឱម្ចាស់អាហារតើនេះជាអ្វីទៅ? "គាត់បានឆ្លើយថាៈ ឱរ៉សូលុល្លោះ! ត្រូវទឹកភ្លៀង។លោកក៏បានតបវិញថា "ហេតុអ្វីបានជាអ្នកមិនដាក់វានៅលើអាហារដើម្បីឱ្យគេមើលឃើញ! ជនណាបោកប្រាស់យើង មិនមែនជាក្រុមរបស់យើងទេ" ។( អាត់តៀរមីហ្ស៊ី ១៣១៥)

**3** លេងសើចលើច្បាប់ៈ ដើម្បីយកទ្រព្យសម្បត្តិដោយអយុត្តិធម៌គ្មានការពិត។ ពិតណាស់មនុស្សខ្លះគាត់មានភាពឆ្លាតវៃ និងមានប្រាជ្ញាដែលអាចយកទ្រព្យសម្បត្តិដោយមិនមែនតាមផ្លូវច្បាប់ និងតុលាការ។ ក៏ប៉ុន្តែការកាត់ក្តីរបស់ចៅក្រមមិនអាចប្រែប្រួលប្រការមិនត្រឹមត្រូវពិតនោះទេ។ រ៉សូលុល្លោះបានមានប្រសាសន៍ថា "ការពិតខ្ញុំក៏ជាមនុស្សដែរ ហើយពួកអ្នកបានប្តឹងតវ៉ាគ្នាមកចំពោះខ្ញុំ ជួនកាលអ្នកខ្លះពូកែនិយាយបញ្ជាក់ហេតុផលជាងអ្នកខ្លះទៀត ហេតុនេះ ខ្ញុំក៏កាត់ក្តីតាមអ្វីដែលខ្ញុំបានលឺ។ ជនណា ដែលខ្ញុំបានសម្រេចក្តីឱ្យគាត់នូវកម្មសិទ្ធិរបស់បងប្អូនគាត់( គាត់មិនត្រូវទទួលយកឡើយ) ការពិតខ្ញុំកាត់ឱ្យគាត់នូវភ្លើងនរកមួយចំណែក"។(អាល់ពូខរី ៦៧៤៨ មូស្លីម ១៧១៣)


> ការយកទ្រព្យសម្បត្តិរបស់មនុស្សដោយអយុត្តិធម៌សូម្បីតែតិចតួចក៏ដោយវាជាអំពើបាប និងជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត

4 សំណូកៈ វាគឺជាការបង្រ់បាក់របស់មនុស្ស ឬការបំរើដើម្បីទទួលបានភាពត្រឹមត្រូវ ដែលមិនមែនជារបស់គេ ហើយវាជាប្រភេទនៃភាពអយុត្តិធម៌ដ៏អាក្រក់បំផុត និងជាអំពើបាបធ្ងន់ធ្ងរបំផុត។ ពិតណាស់រ៉សូលុល្លោះបានដាក់បណ្ដាសាលើអ្នកឱ្យសំណូក និងអ្នកដែលយកសំណូក”។(អាតេត្រៀរម៉ីហ្ស៊ី ១៣៣៧).

នៅពេលដែលការសូកប៉ាន់បានរីករាលដាលនៅក្នុងសង្គម, វាបំផ្លាញប្រព័ន្ធនៃសង្គមនិងប៉ះពាល់ដល់ការអភិវឌ្ឍនិងភាពរុងរឿង។

## តើច្បាប់ចែងដូចម្ដេចចំពោះបុគ្គលដែលបានចូលឥស្លាមហើយមុនគាត់ចូលឥស្លាមគាត់បានយកទ្រព្យសម្បត្តិគេមិនត្រឹមត្រូវ?

បុគ្គលណាដែលបានចូលឥស្លាម ហើយគាត់មានទ្រព្យទុច្ចរិត ដែលគាត់បានយកពីការបោកប្រាស់មនុស្ស និងរំលោភបំពានលើពួកគេដោយការលួច ឬកេងបន្លំ និងអ្វីផ្សេងទៀត ចាំបាច់សម្រាប់គាត្រូវតែប្រគល់វាទៅឱ្យម្ចាស់របស់វាវិញ ប្រសិនបើគាត់ស្គាល់ពួកគេ ហើយគាត់មានលទ្ធភាពក្នុងការប្រគល់វាឱ្យពួកគេដោយគ្មានគ្រោះថ្នាក់លើគាត់។

ទោះបីជាវាបានកើតឡើងមុនពេលចូលឥស្លាមក៏ដោយ ព្រោះទ្រព្យដែលស្ថិតនៅក្នុងដៃរបស់គាត់នោះគឺទទួលបានដោយការបោកប្រាស់ និងរំលោភបំពាន។ ដូច្នេះចាំបាច់ឱ្យគាត់ត្រូវប្រគល់ទ្រព្យទាំងនោះវិញប្រសិនបើគាត់មានលទ្ធភាព។ អល់ឡោះបានមានបន្ទូលថា “ពិតប្រាកដណាស់ អល់ឡោះបញ្ជាពួកអ្នកឱ្យប្រគល់បញ្ញើ ទាំងឡាយទៅឱ្យម្ចាស់របស់គេវិញ”។(អាន់នីសាក ៥៨)

ប្រសិនបើគាត់បានខិតខំស្វែងរកម្ចាស់វាហើយ នូវែតមិនជួបម្ចាស់របស់វាទៀតនោះ ចូរជ្រមះវាទៅលើបការដែលល្អ។



> រ៉សូលុលឡោះបានដាក់បណ្ដាសាលើអ្នកឱ្យ សំណូក និងអ្នកដែលយកសំណូក។

# > ល្បែងស៊ីសង

## តើល្បែងស៊ីសងជាអ្វី ?

ល្បែងស៊ីសងវាគឺជាការប្រគួតប្រជែង និងការលេងល្បែងដែលគេដាក់លក្ខខណ្ឌរវាងអ្នកលេងពីរនាក់ ឬអ្នកប្រកួតពីរនាក់ ដោយនរណាម្នាក់ឈ្នះនឹងទទួលបានប្រាក់ពីអ្នកដែលចាញ់។ អ្នកដែលចូលរួមគឺស្ថិតនៅរវាងការទទួលបានប្រាក់ពីម្នាក់ទៀត ឬក៏គាត់ចាញ់ គេយកប្រាក់ពីគាត់វិញ។.

## ច្បាប់របស់វា

ល្បែងស៊ីសងត្រូវគេហាមឃាត់ មានការរាយការយ៉ាងតឹងរឹងទាក់ទងនឹងវានៅក្នុងគួរអាន និងហាឌីស ដូចជា::

1. អល់ឡោះបានដាក់ស្រមាប៉ែល្បែងស៊ីសងនូវបាបកម្ម និងគ្រោះថ្នាក់ធ្ងន់ធ្ងរជាងគុណប្រយោជន៍របស់វា។ អល់ឡោះបានមានបន្ទូលថា “ពួកគេនឹងសួរអ្នក( មូហាំម៉ាត់ ) អំពីស្រា និងល្បែងស៊ីសង។ ចូរអ្នកឆ្លើយថា: វាទាំងពីរនេះគឺមានបាបកម្មធំ តែក៏មានផលប្រយោជន៍ខ្លះដល់មនុស្សលោកដែរ។ ប៉ុន្តែបាបកម្មរបស់វាទាំងពីរគឺធ្ងន់ធ្ងរជាងគុណប្រយោជន៍របស់វាទាំងពីរទៅទៀត” ។ (អាល់ហ្គាកេរ៉ោះ ២១៩))

2. អល់ឡោះបានចាត់ទុកការលេងល្បែងស៊ីសងជាប្រការមិនស្អាតស្អំ ដោយសារគ្រោះថ្នាក់របស់វាបានប៉ះពាល់ដល់បុគ្គល និងសង្គម និងប្រើឱ្យជៀសឱ្យឆ្ងាយពីវា ហើយវាជាមូលហេតុក្លាយជាស្រតូវ និងស្អប់ខ្ពើមគ្នា

## ល្បែងស៊ីសងបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គម

ល្បែងស៊ីសងបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ និងជាពិសេសលើបុគ្គលនិងសង្គម។ ដូចជា: :

1. វាធ្វើឱ្យពួកអ្នកក្លាយជាស្រតូវ និងស្អប់ខ្ពើមគ្នា ។ ពិតណាស់អ្នកដែលលេងល្បែងស៊ីសងភាគច្រើននៃពួកគេគឺជាមិត្តភក្តិ និងមនុស្សជាទីស្រឡាញ់ ប៉ុន្តែនៅពេលណាដែលមាននរណាម្នាក់ឈ្នះ ហើយយកប្រាក់ពួកគេ



> ល្បែងស៊ីសងបានធ្វើឱ្យម្ចាស់របស់វាញៀន

និងជាមូលហេតុបោះបង់ចោលការសឡាត និងរំលឹកចំពោះអល់ឡោះ។ អល់ឡោះបានមានបន្ទូលថា “ ឱបណ្ដាអ្នកមានជំនឿ! ពិតប្រាកដណាស់ស្រា ល្បែងស៊ីសង ការគោរពបូជារូបបដិមា និងជ្រើសរើសទស្សន៍ទាយវាសនា គឺជាអំពើដ៏កខ្វក់នៃទង្វើរបស់ស្ហៃតន។ ដូច្នេះ ចូរពួកអ្នកចៀសវាងឱ្យឆ្ងាយពីវា សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។ ពិតប្រាកដណាស់ ស្ហៃតនចង់ធ្វើឱ្យពួកអ្នកក្លាយជាសត្រូវ និងស្អប់ខ្ពើមគ្នាតាមរយៈស្រា និងល្បែងស៊ីសង ហើយវារារាំងពួកអ្នកអំពីការរំលឹកទៅចំពោះអល់ឡោះ និងការសឡាត។ ដូច្នេះ ចូរពួកអ្នកឈប់”។(អាល់ម៉ាអ៊ីដះ ៩០-៩១)

ច្បាស់ណាស់ពួកគេនិងខឹងសម្បា និងការអន់ចិត្តលើគេនោះ ហើយនាំឱ្យពួកគេក្លាយជាស្រតូវ និងឈ្លានីសគ្នា។ ហើយពួកគេបានធ្វើល្បិច ដើម្បីឱ្យគាត់ធ្លាក់ក្នុងគ្រោះថ្នាក់ ដោយសារគាត់បានធ្វើឱ្យពួកគេធ្លាក់ក្នុងភាពខាតបង់។ ទាំងនេះជាភាពជាក់ស្ដែងដែលមនុស្សទាំងអស់បានដឹង ហើយវាបានបញ្ជាក់យ៉ា

ងពិតេដាយបន្ទូលអល់េឡាះថា “ពិត្របាកដណាស់ ស្តៃតនចង់េធ្វើឱ្យពួកអ្នកក្លាយជាស្រ្ទីតូវ និងស្អប់េខ្ពើមគ្នាតាមរយៈសុរា និងេល្បងសុីសង”។េហើយវាបានរារាំងមនុស្សអំពីកាតព្វកិច្ចសទ្បាត និងការរំលឹកចំេពាះអល់េឡាះ។ ដូចែដលអល់េឡាះបានេរៀបរាប់ពីល្បិចស្តៃតនក្នុងការបង្វក់មនុស្សឱ្យេលងេល្បងសុីសងថា “េហើយវារារាំងពួកអ្នកអំពីការរំលឹកេទៅចំេពាះអល់េឡាះ និងការសទ្បាត”)

2 ២-េល្បងសុីសងវាបានបំផ្លាញទ្រព្យ និងទ្រព្យសម្បត្តិនិងបណ្តាលឱ្យអ្នកេលងេល្បងទទួលរងការខាតបង់យ៉ាងធ្ងន់ធ្ងរ។

3 ការេលងេល្បងសុីសងវានឹងបណ្តាលឱ្យក្លាយេទៅជាការេញៀន។េនៅេពលែដលេគេលងឈ្នះ ភាពេលាភលន់និងេកើនេឡើង ក្នុងការបន្តេលងេល្បងសុីសងេទៀត េហើយគាត់េនៅែតទទួលបានផលព្រៃបាក់ែដលេគហាមឃាត់។ ែត្របសិនេបើគាត់ចាញ់ គាត់េនៅែតសង្ឃឹមថាគាត់នឹងេលងឈ្នះវិញ និងត្រលប់យកអ្វីែដលគាត់បានចាញ់នាះមកវិញ។ទាំងពីរេនះគឺជាឧបសគ្គចំេពាះការងារនិងេបង្កើតបានជាការវិនាសអន្តរាយដល់សង្គម។

## ប្រេភទៃនេល្បងសុីសង

ប្រេភទនការេលងេល្បងសុីសង ពីអតីតកាលនិងបច្ចុប្បន្នេនះគឺមានជាេច្រើនទំរង់។ក្នុងចំេណាម្របេភទរបស់វាបច្ចុប្បន្នមានដូចជា: :

1. រាល់េល្បងទាំងអស់ែដលេគដាក់លក្ខខ័ណ្ឌថាអ្នកែដលឈ្នះត្រូវយក្របាក់ពីអ្នកែដលចាញ់មួយចំនួន។ ឧទាហរណ៍ មនុស្សមួយក្រុមបានេលងេល្បងមួយែនសន្លឹកេបៀជាមួយគ្នា េហើយពួកេគម្នាក់ៗត្រូវដាក់ចំនួនជាក់លាក់មួយៃន្របាក់ េហើយអ្នកណាឈ្នះនិងត្រូវទទួលបាន្របាក់ទាំងអស់េនាះ។.
2. ការភ្នាល់េលើកុមមួយណាែដលឈ្នះ ឬអ្នកេលងមួយណា ឬអ្វីេផ្សងេទៀត។ េហើយអ្នកែដលភ្នាល់គ្នាេនាះបានដាក់ចំនួន្របាក់។ េហើយម្នាក់ៗបានភ្នាល់ថាក្រុមរបស់េគ ឬអ្នកេលងរបស់េគ ឈ្នះ។ ប្រសិនេបើក្រុមរបស់េគឈ្នះេគនឹងទទួលបាន្របាក់ ែត្របសិនេបើកុមរបស់េគចាញ់េគនឹងត្រូវបាត់បង់្របាក់។.
3. ផ្សងសំណាងនឹងេលងេឆ្នាត។ ឧទាហរណ៍ េគទិញកាតមួយក្នុងតៃម្លមួយដុល្លា េដើម្បីចូលរួមក្នុងការផ្សងសំណាងការឈ្នះរង្វាន់១០០០០ដុល្លាេនៅេពលែដលេគចាប់េឆ្នាត។.
4. គ្រប់ប្រេភទនការេលងេល្បងសុីសងទាំងអស់ែដលមានចលនា និងថាមពលអគ្គិសនី និងេអឡិចត្រូនិក ឬបណ្តាញអិនធឺណិតែដលមានេហើយអ្នកែដលេលងវាេនាះប្រឈមមុខនឹងភាពមិនច្បាស់លាស់ពីរគឺ ទទួលបាន្របាក់ ឬបាត់បង់្របាក់។.



> គ្រប់ប្រេភទៃនការេលងេល្បងសុីសងទាំងអស់ែដលមានចលនា និងថាមពលអាគ្គិសនី ឬេដាយលក្ខណៈែបបណាក៏េដាយគឺត្រូវបានេគហាមឃាត់ េហើយវាជាអំេពើបាបដ៏ធំ។

# សុជីវធម៌ដែលឥស្លាមបានសង្កត់ធ្ងន់ក្នុងការទំនាក់ទំនងប្រតិបត្តិការហិរញ្ញវត្ថុ

ដូចែដរឥស្លាមបានុបក្រុសាយយ៉ាងច្បាស់ពីច្បាប់ទាក់ទងនិងប្រតិបត្តិការហិរញ្ញវត្ថុ ហើយេគបានសង្កត់ធ្ងន់ថ្មីពាះអ្នក្របូតិបត្តិការនូវសុជីវធម៌ និងសីលធម៌មួយចំនួនដូចជា:

1



## ស្មោះត្រង់

ស្មោះត្រង់ក្នុងការប្រតិបត្តិការពាណិជ្ជកម្មជាមួយអ្នកដៃទ ស្ទូម្បីតែគជាអ្នកមូស្លីម ឬមិនែមនមូស្លីម វាជាសុជីវធម៌សំខាន់ស្រមាប់អ្នកមូស្លីមែដលេគារពតាមច្បាប់អេល់ឡោះ ហើយបង្ហាញពីការសង្កត់ធ្ងន់េលើវានោះដូចខាងេក្រាម:

- អេល់ឡោះបានមានបន្ទូលថា “ ពិត្របាកដណាស់ អេល់ឡោះបញ្ជាពួកអ្នកឱ្យប្រគល់េបើញ្ញើ ទាំងឡាយេទាឱ្យម្ចាស់របេស់គវិញ”។(អាន់នៃសេក ៥៨)

- រ៉សូលុលេឡាះបានរាប់បញ្ចូលការបាត់បង់ភាពស្មោះត្រង់និងការក្បត់សន្យា ជាសញ្ញាស៉ំគាល់អ្នកពុតត្បុត(មូណាហ្វិក) ដោយេលាកមាន្រប្ធសាសន៍ថា “សញ្ញាស៉ំគាល់អ្នកពុត្តត្បុត(មូណាហ្វិក)មានបី : នៅពេលនិយាយគាត់កុហក់ នៅពេលសន្យាមិនបំពេញតាមការសន្យា នៅពេលេគទុកចិត្តគាត់បាក្របាស់”។(អាល់ពូខរី ៣៣ មូស្លីម ៥៩)

- ស្មោះត្រង់ វាជាលក្ខណៈសម្បត្តិដ៏សំខាន់ស្រមាប់អ្នកមានជំនឿ។ អេល់ឡោះបានមានបន្ទូលថា “ បណ្តាអ្នកែដលមានជំនឿពិតជាទទួលបានេជាគជ័យ”។រហូតដល់បន្ទូលទ្រង់ថា “ហើយនិងបណ្តាអ្នកែដលែថរក្សានូវភាពស្មោះត្រង់និងការសន្យារបស់ពួកេគ”។(អាល់មុមុនូន ១-៨)

- ស្មោះត្រង់ វាជាលក្ខណៈសម្បត្តិដ៏សំខាន់ស្រមាប់អ្នកមានជំនឿ។ អេល់ឡោះបានមានបន្ទូលថា “ បណ្តាអ្នកែដលមានជំនឿពិតជាទទួលបានេជាគជ័យ”។រហូតដល់បន្ទូលទ្រង់ថា “ហើយនិងបណ្តាអ្នកែដលែថរក្សានូវភាពស្មោះត្រង់និងការសន្យារបស់ពួកេគ”។(អាល់មុមុនូន ១-៨)

- ពិតណាស់រ៉សូលុលេឡាះត្រូវបានេគឱ្យងារគាត់នៅ មីក្កៈមុនេពលែតងតាំងថាស្មោះត្រង់សច្ចៈ។េព្រោះគាត់ជានិម្មិត្តរូបែនភាពស្មោះត្រង់ក្នុងការទំនាក់ទំនង និងការប្រតិបត្តិការរបស់គាត់។



2

## សេចក្ដីទៀងត្រង់

សេចក្ដីទៀងត្រង់និងការច្បាស់លាស់វាជាលក្ខណៈពិសេសដ៏សំខាន់ដែលឥស្លាមបានសង្កត់ធ្ងន់ទៅលើវា

- រ៉សូលុល្លោះបានមានប្រសាសន៍ចំពោះអ្នកលក់ និងអ្នកទិញថា "ប្រសិនបើគេទាំងពីរមានសេចក្ដីទៀងត្រង់ និងបញ្ជាក់ច្បាស់ គេនឹងទទួលភាពចំរុងចំរើនដល់គេទាំងពីរក្នុងការលក់ទិញរបស់គេទាំងពីរនោះ ប្រសិនបើគេលាក់លាម និងកុហកគ្នានិងបំបាត់ភាពចំរុងចំរើននៃការលក់ទិញរបស់គេទាំងពីរនោះ"។(អាលពូខរី ១៩៧៣ មូស្លីម ១៥៣២)
- រ៉សូលុល្លោះបានមានប្រសាសន៍ថា "ចូរពួកអ្នកប្រកាន់នូវសេចក្ដីទៀងត្រង់ ពិតណាស់សេចក្ដីទៀងត្រង់នាំទៅដល់ទង្វើកុសល ហើយទង្វើកុសលនាំទៅដល់ឋានសួគ៌ ហើយបុគ្គលខ្លះនៅតែនិយាយទៀងត្រង់រហូតដល់ត្រូវគេកត់ត្រានៅនឹងអល់ឡោះថា ជាមនុស្សទៀងត្រង់បំផុត"។(មូស្លីម ២៦០៧))
- ឥស្លាមបានចាត់ទុកអ្នកដែលស្បថកុហកដើម្បីស្វែងរកផលប្រយោជន៍លោកិយនោះ ពិតណាស់គេបានប្រព្រឹត្តអំពើបាបយ៉ាងធំធេង។រ៉សូលុល្លោះបានមានប្រសាសន៍ថា "មនុស្សបីប្រភេទដែលអល់ឡោះមិនមានបន្ទូលទៅកាន់ពួកគេនៅថ្ងៃបរលោក ហើយមិនមើលពួកគេ និងមិនសំអាតពួកគេឡើយ ហើយសម្រាប់ពួកគេគឺទណ្ឌកម្មដ៏ឈឺចាប់បំផុតៈ ហើយក្នុងនោះមាន អ្នកពុតត្បុតនិងទំនិញរបស់វាដោយស្បថកុហក"។(មូស្លីម ១០៦))



3

## ជំនាញ និងធ្វើការល្អ

ចាំបាច់លើរាល់មូស្លីមដែលជាអ្នកផលិត បុគ្គលិកត្រូវមានជំនាញច្បាស់លាស់ និងបំពេញការងារឱ្យមានប្រសិទ្ធភាពល្អទៅតាមគោលការណ៍ និងឯកសិទ្ធរបស់ខ្លួន ដែលមិនមានការធ្លាក់ចុះនៃគុណភាពវាឡើយ។

- អល់ឡោះបានកត់ត្រាអំពើល្អនៅលើអ្វីគ្រប់យ៉ាង ហើយបានបញ្ជាឱ្យស្វែងរកតែមើលវាគ្រប់ប្រភេទនៃជីវិត សូម្បីតែអ្វីដែលស្ដែងចេញមកនូវភាពល្អក្នុងចំពោះសេចក្ដីសប្បុរសនិងជំនាញក្រោយ ដូចជា ការប្រមាញ់ និងការសំឡះ។រ៉សូលុល្លោះបានមានប្រសាសន៍ថា "ពិតណាស់អល់ឡោះបានដាក់បទបញ្ជាឱ្យធ្វើល្អចំពោះអ្វីៗទាំងអស់។ ហេតុនេះនៅពេលពួកអ្នកសម្លាប់សត្វ(ដែលបង្កគ្រោះថ្នាក់) ចូរពួកអ្នកសម្លាប់ដោយល្អប្រសើរ ហើយនៅពេលពួកអ្នកសំឡះសត្វ ចូរពួកអ្នកសំឡះក្នុងលក្ខណៈល្អប្រសើរ។ ចូរឱ្យពួកអ្នកសំលៀងកាំបិតឱ្យមុត ហើយធ្វើយ៉ាងណាឱ្យសត្វនោះស្លាប់ដោយស្រួលបំផុត"។(មូស្លីម ១៩៥៥)
- Oរ៉សូលុល្លោះបានចូលរួមការស្លាប់របស់មនុស្សម្នាក់ គាត់បានណែនាំសហាហ្ពះអំពីការជីកផ្នូរ និងការបញ្ចុះសពឱ្យបានល្អប្រសើរ បន្ទាប់មកគាត់ក្រោកឡើងទៅមើលពួកគេហើយបានមានប្រសាសន៍ថា "ទាំងនេះវាមិនបានផ្ដល់ផលប្រយោជន៍ ឬបង្កគ្រោះថ្នាក់អ្វីដល់សពទេឡើយ ក៏ប៉ុន្តែអល់ឡោះទ្រង់ស្រឡាញ់បុគ្គលណា ហើយដែលវាធ្វើកិច្ចការអ្វីមួយគ្រប់ធ្វើបានយ៉ាងល្អប្រសើរ"។(អាល់បៃហាគី ក្នុង ស៊ូអាពូលអ៊ីម៉ាន ៥៣១៥) ក្នុងឃ្លាមួយទៀត "ពិតណាស់អល់ឡោះស្រឡាញ់ចំពោះម្នាក់ក្នុងចំណោមពួកអ្នកដែលធ្វើកិច្ចការបានយ៉ាងល្អឥតខ្ចោះ"។(អាពូយ៉ាកែឡា ៤៣៨៦ ស៊ូអាពូលអ៊ីម៉ាន ៥៣១២)



# ចំណីអាហាររបស់អ្នកិ ងេភសជ្ជៈរបស់អ្នក



# 8

ចំពោះចំណីអាហារដែលហាឡាលគឺមានមានតួនាទីយ៉ាងសំខាន់នៅក្នុងសាសនាឥស្លាម ហើយវាជាមូលហេតុដែលគេទទួលយកការបួងសួង និងផ្តល់ភាពចំរុងចំរើននៅក្នុងទ្រព្យសម្បត្តិ និងក្រុមគ្រួសារ។

ហើយអត្ថន័យនៃអាហារដែលហាឡាល (ច្បាប់អនុញ្ញាត) គឺរាល់អាហារដែលគេអនុគ្រោះ និងទទួលបានតាមរយៈផ្លូវត្រឹមត្រូវ និងដោយទ្រព្យសម្បត្តិសុចរិត ដោយគ្មានការកេងប្រវ័ញ្ច និងរំលោភបំពានលើសិទ្ធអ្នកដទៃ។

## មាតិកាជំពូក


ប្រភពដើមនៃអាហារ និងភេសជ្ជៈ
ដំណាំ និងផលានុផល
សុរា និងជាតិអាកុល
គ្រឿងញៀន
អាហារសមុទ្រ
សត្វរស់នៅលើដី
- ការសម្លះតាមច្បាប់ឥស្លាម
- ច្បាប់ដែលទាក់ទងនឹងសាច់ក្នុងភោជនីយដ្ឋាននិងកន្លែងលក់ដូររបស់អ្នកគ្មានជំនឿ

ការប្រមាញ់សត្វតាមច្បាប់ឥស្លាម
សុជីវធម៌នៃចំណីអាហារ និងភេសជ្ជៈ

# ចំណីអាហាររបស់អ្នក និងភេសជ្ជៈរបស់អ្នក

## ប្រភពដើមនៃអាហារ និងភេសជ្ជៈ

ប្រភពដើមនៃចំណីអាហារ និង ភេសជ្ជៈទាំងអស់ត្រូវបានគេអនុញ្ញាតនិងហាឡាល លើកលែងតែអ្វីដែលត្រូវបានដកចេញអំពីរបស់ដែលគេហាមឃាត់(ហារ៉ម) ដែលនាំឱ្យមានគ្រោះថ្នាក់ដល់សុខភាព សីលធម៌ និងសាសនារបស់មនុស្ស។ ហើយពិតណាស់អល់ឡោះបានផ្តល់ឱ្យមនុស្សដោយបង្កើតសម្រាប់ពួកគេ រាល់អ្វីគ្រប់យ៉ាងដែលមាននៅលើផែនដីដើម្បីឱ្យពួកគេទទួលបានផលប្រយោជន៍អំពីវា លើកលែងតែអ្វីដែលអល់ឡោះបានហាមឃាត់(ហារ៉ម) លើពួកគេ។អល់ឡោះបានមានបន្ទូលថា (ទ្រង់គឺជាអ្នកដែលបានបង្កើតអ្វីៗទាំងអស់នៅលើផែនដីនេះសម្រាប់ពួកអ្នក)។(ជំពូក អាល់បាការ៉ោះ ឃ្លា ២៩))

## >ដំណាំ និងផលានុផល

គ្រប់រុក្ខជាតិដែលមនុស្សដាំដុះ ឬ យកវាពីព្រៃរហោស្ថាន និងព្រៃស្តុក និងវាលស្មៅ និងរុក្ខជាតិផ្សេងៗគ្រប់ប្រភេទទាំងអស់គឺត្រូវបានគេអនុញ្ញាតឱ្យបរិភោគ។ លើកលែងតែអ្វីដែលនាំឱ្យគ្រោះថ្នាក់ដល់ខ្លួនប្រាណ និងសុខភាព ឬធ្វើឱ្យបាត់បង់សតិសម្បជញ្ញៈ ដូចជាស្រា ឬគ្រឿងញៀន។ ពិតណាស់វាត្រូវបានគេហាមឃាត់(ហារ៉ម)ដោយមូលហេតុ គ្រោះថ្នាក់ និងបាត់បង់សតិសម្បជញ្ញៈ។e.



## > សុរា និង ជាតិអាកុល

វាគឺរាល់ៗអ្វីដែលធ្វើឱ្យវង្វេងវង្វាន់សតិ មានន័យថាធ្វើឱ្យវាលាយឡំគ្នា ឬគ្រប់ដណ្តប់វា ឬបិទបាំងវា ឬប៉ះពាល់ដល់វា។ ដូចែដុវរ៉ស្វូលុលែទ្បាះបានមាន្បនបសាសន៍ថា( រាល់ៗអ្វីដែលធ្វើឱ្យស្រវឹងគឺជាសុរា ហើយរាល់ៗសុរាទាំងអស់គឺគហាមឃាត់(ហារ៉ម)។(មូស្លីម ២០០៣) ស្លូម្បីត្រែតូវបានេគផលិតពីផ្លែឈើក៏ដោយ ដូចជា ទំពាំងបាយជូ ល្ពៃស្រែកៀល ផ្លែទីន និងទំពាំងបាយជូស្រែគៀម ឬធ្វើអំព្រីគាប់ធញ្ញជាតិ ដូចជាស្រូវសាលី ស្រូវពោត និងអង្ករ ឬធ្វើអំពីសារធាតុផ្អែម ដូចជាទឹកឃ្មុំ។ រាល់ៗអ្វីដែលធ្វើឱ្យបាត់បង់សតិ វាគឺជាស្រាដែលេគហាមឃាត់( ហារ៉ម) និងេឈ្មាះអ្វី ឬលក្ខណៈបែបណាក៏ដោយ រហូតស្លូម្បីតែគយកេទៅលាយជាមួយទឹកផ្លែឈើធម្មជាតិ ឬបែង្អម ឬសូកូឡាក៏ដោយ។e.



> សាសនាឥស្លាមបានយកចិត្តទុកដាក់លើការថែរក្សាសតិអំពីអ្វីដែលប៉ះពាល់ទៅលើវា និងផ្តល់គ្រោះថ្នាក់ទៅលើវា។

### ការថែរក្សាសតិសម្បជញ្ញៈ

ពិត្រប្រាកដណាស់សាសនាដ៏ឧត្តុង្គឧត្តមេនះបាននាំមកេដើម្បីបញ្ជាក់យ៉ាងច្បាស់ពីផលប្រយោជន៍របស់មនុស្សែនៅក្នុងេលាកីយរបស់ពួកេគ និងបរេលាករបស់ពួកេគ។ ហើយពិេសស្តជាងេនាះទៅទៀតគឺការថែរក្សាប្រការចាំបាច់ទាំងប្រាំ: សាសនា ខ្លួនប្រាណ សតិ ទ្រព្យសម្បត្តិ និងពូជអំបូរ។

សតិគឺជាមូលដ្ឋាននៃការទទួលខុស្រត្រូវផ្នែកច្បាប់ ហើយជាមូលេហតុចម្បងក្នុងការផ្តល់កិត្តិយស និងជាការេជ្រើសេរីសរបស់ម្ចាស់ចំេពាះមនុស្ស។ ហើយច្បាប់បានថែរក្សាវា និងការពារវាអំពីអ្វីទាំងអស់េដែលធ្វើឱ្យវាបាត់បង់ ឬចុះេខ្សាយ។

### ច្បាប់អ៊ីស្លាមទាក់ទង់និងសុរា

សុរាគឺជាផ្នែកមួយនៃអំេពីបាបដ៏ធំ និងខ្លាំងខ្លាប់ផុត ហើយការហាមឃាត់(ហារ៉ម) អំពីសុរា និងការេផ្តាតសំខាន់េនៅក្នុងកិច្ចការរបស់វាេនាះ ត្រូវបានបញ្ជាក់េដាយគួរអាន និង ហាឌីសណាពីដែលក្នុងេនាះរួមមានដូចខាងេក្រាម:

- អល់ឡោះបានមានបន្ទូលថា( ឱបណ្តាអ្នកមានជំនឿ! ពិត្រប្រាកដណាស់សុរា ល្បែងស៊ីសង គោរពបូជារូបបដិមា និងេជឿព្រួញទស្សន៍ទាយវាសនា គឺជាអំពើដ៏កខ្វក់េនទង្វើរបស់ស្ហតន។ ដូេច្នះចូរពួកអ្នកេជៀសវាងឱ្យឆ្ងាយពីវា េដើម្បីឱ្យពួកអ្នកទទួលបានេជាគជ័យ)។(ជំពូក អាលម៉ាអ៊ីដះ ឃ្លា ៩០) អល់េឡាះបានឱ្យលក្ខណៈរបស់វាគឺជាអំេពីដ៏កខ្វក់ ហើយពិតណាស់វាជាទង្វើរបស់ស្ហតន ហើយក៏បានេប្រីឱ្យពួកេយើងេជៀសវាងឱ្យឆ្ងាយពីវា ប្រសិនេបើេយើងចង់ទទួលបានជ័យជំនះនិងេជាគជ័យ។.
- រ៉សូលុលេឡាះបានមាន្របសាសន៍ថា( រាល់ៗអ្វីដែលធ្វើឱ្យស្រវឹងគឺជាសុរា ហើយរាល់ៗអ្វីដែលធ្វើឱ្យស្រវឹងគឺគហាមឃាត់(ហារ៉ម) ជនណាហើយេដលបរិេភាគសុរាេនៅក្នុងេលាកិយ៍េនះ ហើយេគបានស្លាប់ក្នុងសភាពជាអ្នក

ញៀនសុរា នោះវាមិនបានបរិភោគសុរា នៅក្នុងថ្ងៃបរលោកេឡើយ)។ (មូស្លីម ២០០៣)

- វិសូលុលេឡោះបាននៃលើកេឡើងនៅលើភាពផ្ទុយគ្នានៃការបរិភោគសុរា និងជំនឿ ហើយនិងការថយចុះរបស់វាថា (គ្មានបុគ្គលណាម្នាក់ផឹកសុរាខណៈពេលដែលរូប គេជាអ្នកមានជំនឿនោះឡើយ)។(អាល់ពូខរី ៥២៥៦ មូស្លីម ៥៧)
- សាសនាឥស្លាមបានបង្គាប់ឱ្យដាក់ទណ្ឌកម្មទៅលើអ្នកដែលបរិភោគសុរា, បាត់បង់សេចក្ដីថ្លៃថ្នូររបស់ពួកេគ,និងការធ្លាក់ចុះនៃភាពជឿជាក់របស់ពួកេគនៅក្នុងសង្គម។
- គេបានរៀបចំស្រមាប់អ្នកដែលេនៅតែបន្តក្នុងការបរិភោគសុរា និងអ្វីដែលដូចនិងវាដែរនោះ រហូតដល់ស្លាប់ហើយេគមិនបានទទួលសារភាពកំហុសដោយទទួលនូវទារុណកម្មយ៉ាងធ្ងន់ធ្ងរ។ វិសូលុលេឡោះបានមានប្រសាសន៍ថា( ពិតណាស់ចំពោះអល់ឡោះគឺមានការប្រមានមួយស្រមាប់អ្នកដែលបរិភោគសុរា គឺឱ្យពួកេគផឹកទឹកតីនាតុលខាពេល)។(មូស្លីម ២០០២) ទឹក តីនាតុលខាពេល វាគឺជាសារធាតុរាវរបស់អ្នកេនៅឋាននរក សំដៅលើសារធាតុរាវដែលអាក្រក់ និងខ្ទុះដែលេចញពីរាងកាយអ្នកដែលបានវិនាសដោយេភ្លើងនរក។.
- ហើយគ្រប់បុគ្គលដែលចូលរួម ឬជ្រុំជ្រែងទៅលើការបរិភោគសុរាមិនថាជិត ឬឆ្ងាយគឺនៅក្នុងការប្រមាននេះ។ ( ពិតណាស់វិសូលុលេឡោះបានដាក់បណ្ដាសារទៅលើសុរា ១០ផ្នែក: អ្នកដែលផលិតសុរា, អ្នកដែលឱ្យគេផលិតឱ្យគាត់, អ្នកដែលផឹកវា, អ្នកដែលជញ្ជូនវា, អ្នកដែលគេជញ្ជូនឱ្យគាត់, អ្នកដែលចាក់សា, អ្នកដែលលក់សា, អ្នកដែលទទួលប្រយោជន៍ពីតម្លៃសា, អ្នកដែលទិញវា និងអ្នកដែលគេទិញឱ្យគាត់) ។(អាតេទៀរមីហ្ស ១២៩៥)

## > គ្រឿងញៀន

ការប្រើប្រាស់គ្រឿងញៀន សូម្បីត្រៃបភពដើមរបស់វាជារុក្ខជាតិ ឬផលិតផល ហើយសូម្បីតែការប្រើប្រាស់វាដោយការស្រូបហើយបញ្ចេញមកវិញ ឬការលេប ឬការចាក់ក៏ដោយ វាជាអំពើបាប និងអំពើអាក្រក់ធំធេងបំផុត។ ហើយជាមួយគ្នាផងដែរនោះធ្វើឱ្យបាត់បង់ស្មារតី ហើយវាបានបំផ្លាញប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស ហើយធ្វើឱ្យអ្នកដែលប្រើប្រាស់វាមានជំងឺសៃស្របសាទ និងវិកលចរិកនានា និងប្រហែលជាអាចនាំឱ្យគាត់ស្លាប់ផងដែរ។ អល់ឡោះដែលជាអ្នកអាណិតស្រលាញ់ទៅចំពោះខ្ញុំរបស់ទ្រង់បានមានបន្ទូលថា( ហើយចូរពួកអ្នកកុំសម្លាប់ខ្លួនឯង( ឬសម្លាប់អ្នកដទៃ)ឱ្យសោះ ពិតប្រាកដណាស់ អល់ឡោះអាណិតស្រលាញ់បំផុតចំពោះពួកអ្នក) ។( ជំពូក អាន់នីសាក ឃ្លា ២៩)

## > អាហារសមុទ្រ

អាហារសមុទ្រមានន័យថាអ្វីដែលមិនអាចរស់នៅបានទេលើកែលងែតនៅក្នុងទឹក។ហើយមិនអាចរស់នៅលើគោកបានេឡើយ។ ហើយពាក្យថាសមុទ្រនៅត្រង់នេះមានន័យថាកែន្លងមានទឹកច្រើន ហើយរាប់បញ្ចូលទៅក្នុងនោះដែរមានដូចជា៖ទន្លេ បឹង និងអ្វីដែលផ្សេងពីវាដែលមានទឹកច្រើន។

ហើយអាហារសមុទ្រទាំងអស់នោះ មិនថាវាសត្វ ឬជារុក្ខជាតិ បានរបមាញ់វា ឬជួបវាស្លាប់ក៏ដោយ ពិតណាស់ការបរិភោគវាគឺអនុញ្ញាត អន្ទេគ្រោះ បើសិនជាវាមិនផ្ដល់គ្រោះថ្នាក់ដល់សុខភាព។ អល់ឡោះបានមានបន្ទូលថា( គេ(អល់ឡោះ)បានអនុញ្ញាតឱ្យពួកអ្នកនេសាទសត្វសមុទ្ររស់ និងយកសត្វសមុទ្រស្លាប់មកធ្វើជាអាហារ)។(ជំពូក អាល់មាអ៊ីដះ ឃ្លា ៩៦) ការនេសាទវាគឺការយកបានដោយមានជីវិត ហើយអាហារគឺអ្វីដែលយកពីសមុទ្រក្រោយពីវាបានស្លាប់។

## > សត្វនៅលើដី

គេដាក់លក្ខខ័ណ្ឌក្នុងការអនុញ្ញាតឱ្យបរិភោគសត្វនៅលើដីនឹងពីរលក្ខខ័ណ្ឌ:

1. ១/វាគឺជាសត្វែដលេគអនុញ្ញាតឱ្យបរិភោគ
2. ២/ត្រូវបានេបមាញ់វា និងសេម្លះវាទៅតាមក្បួនច្បាប់ឥស្លាម

### តើសត្វអ្វីខ្លះដែលេគអនុញ្ញាតឱ្យបរិភោគ ?

ប្រភពដើមែនសត្វទាំងអស់គឺហាឡាល់( អនុញ្ញាត )លើកែលងែតអ្វីែដលមានភស្តុតាងចង្អុលបង្ហាញពី គួរអាន និង ហាឌីស លើការហាមឃាត់វា.

េហើយសត្វែដលេគហាមឃាត់មានដូចខាងេក្រាម:

1 សត្វជ្រូក: វាជាសត្វែដលេគហាមឃាត់ និងក្ខកេំនៅគ្រប់ែផ្នកទាំងអស់របស់វា និងអវៈយវៈរបស់វា និងអ្វីែដលេចញពីវាក្នុងសាសនាឥស្លាម។ ដូចអលេ់ឡាះបានមានបន្ទូលថា( េគ(អលេ់ឡាះ) បានហាមឃាត់ចំេពាះពួកអ្នក( បរិេភាគ )សត្វស្លាប់ ឈាម សាច់ជ្រូក )។( ជំពូក អាល់ម៉ាអ៊ីដះ ឃ្លា ៣ ) េហើយអលេ់ឡាះបានមានបន្ទូលេទៀតថា( ឬសាច់ជ្រូក េពីព្រោះវាជារបស់កខ្វក់ )។( ជំពូក អាល់អាន់អាម ឃ្លា ១៤៥ ) )

2 រាល់សត្វសាហាវែដលមានេចង្កាម: មានន័យថា រាល់សត្វទាំងអស់ែដលបរិេភាគសាច់ជាអាហារ េទាះបីពួកេគមានទំហំធំដូចជាសត្វតោ និងសត្វខ្លា, ឬតូចដូចជាសត្វឆ្មា និងអ្វីែដលេផ្សងពីវា េហើយក៏ដូច្នោះែដរសត្វឆ្កែ។.

3 រាល់បក្សីែដលមានេក្រចក: វាគឺរាល់បក្សីទាំងអស់ែដលបរិេភាគសាច់ជាអាហារដូចជាសត្វស្ទាំង សត្វឥន្ទ្រី សត្វទីទុយ និងអ្វីេផ្សងពីេនះេទៀត

4 សត្វល្អិត: រាល់សត្វល្អិតទាំងអស់នៅេលើដីេគឺេគមិនអនុញ្ញាតឱ្យបរិេភាគវាេឡើយ េពីព្រោះមិនអាចេសម្លះវាបានេឡើយ េលើកែលងែតកណ្ដូប វាេគឺេគអនុញ្ញាតឱ្យបរិេភាគ។ ដូចរ៉សូលុលេឡាះបានមានប្រសាសន៍ថា( េគបានអនុញ្ញាត( ការបរិេភាគ )មកចំេពាះេយើងនូវសត្វស្លាប់ពីរប្រេភទ៖ ត្រី និង កណ្ដូប ) ។( អ៊ីពនូម៉ាយ៉ះ ៣២១៨ )

5 សត្វពស់ និងកណ្ដុរ: េគបានហាមឃាត់មិនឱ្យបរិេភាគវាេឡើយ េហើយបានេប្រើឱ្យេយើងសម្លាប់វា រ៉សូលុលេឡាះបានមានបន្ទូលថា ( ប៉ ំប្រេភទេនសត្វអាក្រក់ែដលអាចសម្លាប់ពួកវាបាននៅក្នុងេពលែដលេគអនុញ្ញាត ឬេពលេគមិនអនុញ្ញាត( អះរ៉ម ): សត្វពស់ សត្វេក្អក កណ្ដុ ែឆ្កឆ្កួត និងសត្វេខ្លងខ្លា )។( អាល់ពូខរី ៣១៣៦ មូស្លីម ១១៩៨ )

6 សត្វលាក្នុងស្រុក: វាគឺសត្វលាែដលេគេប្រើប្រាស់វានៅក្នុងភូមិស្រមាប់ជិះ និងដឹកជញ្ជូនរបស់របរ។.

## ប្រភេទសត្វដែលគេអនុគ្រោះ

អ្វីដែលអល់ឡោះបានអនុញ្ញាតឱ្យវាអំពីសត្វទាំងអស់នេះត្រូវបានបែងចែកចេញជាពីរ:

- មួយប្រភេទរស់នៅក្នុងព្រៃហើយរត់គេចពីមនុស្ស ហើយមិនអាចចាប់វាយកមកសម្លះបានទេ: គេអនុញ្ញាតឱ្យយើងបាញ់វាទៅតាមក្បួនច្បាប់នៃការបាញ់របស់ឥស្លាម។.

- មួយប្រភេទទៀតសត្វចិញ្ចឹមអាចចាប់វាបាន: គេមិនអនុញ្ញាតទេលើកលែងតែសម្លះតាមក្បួនច្បាប់ ឥស្លាម។

## ការសម្លះតាមក្បួនច្បាប់ឥស្លាម

វាជាការសម្លះដែលមានគ្រប់លក្ខខ័ណ្ឌនៃច្បាប់ឥស្លាម.

លក្ខខណ្ឌនៃការសម្លះតាមក្បួនច្បាប់ឥស្លាម

1. អ្នកសម្លះគឺជាក្រុមដែលគេអនុញ្ញាតឱ្យសម្លះ ពួកគេគឺ អ្នកមូស្លីម ឬអះលុលគីតាប( យូដាសាសនិក និងគ្រីសសាសនា) ដែលដឹងខុសត្រូវ និងមានគោលបំណងសម្លះ។.
2. ឧបករណ៍ដែលបានប្រើសម្រាប់សម្លះសត្វត្រូវតែមុតស្រួច ដែលអាចធ្វើឱ្យហូរឈាម និងមុតដូចជាកាំបិត។ ហើយគេបានហាមឃាត់មិនឱ្យប្រើអ្វីដែលអាចសម្លាប់សត្វដោយដាក់សង្កត់ធ្ងន់ពីលើ និងវាយក្បាលរបស់សត្វ ឬដោយការដុតវាដូចជាការឆក់ដោយអគ្គិសនី។
៣- ពោលនឹងនាមអល់ឡោះដោយសូត្រថា( ពីសមីលឡាហ៍ )

(بسم الله)

នៅពេលដែលគេកំពុងតែដើម្បីសម្លះ

3. កាត់ផ្តាច់អ្វីដែលចាំបាច់ក្នុងការសម្លះ វាគឺ បំពង់អាហារ បំពង់ក និងសរសៃឈាមពីរ




> អល់ឡោះបានអនុញ្ញាតមកលើយើងនូវចំណីអាហារអះលីគីតាប( យូដាសាសនិក និងគ្រីសសានិក )នៅពេលដែលពួកគេសម្លះតាមក្បួនច្បាប់ឥស្លាម។

ហើយវាជាសរសៃសំខាន់នៃបំពង់ក។ ឬកាត់បើនៅក្នុងចំណោមបួននេះ។

4. ប្រសិនបើលក្ខខ័ណ្ឌទាំងនេះត្រូវបានបំពេញ សាច់សត្វដែលបានសម្លះគឺត្រូវបានគេអនុញ្ញាត។ ប្រសិនបើខ្វះលក្ខខ័ណ្ឌណាមួយក្នុងចំណោមលក្ខខ័ណ្ឌទាំងនេះ ពិតណាស់សាច់សត្វដែលបានសម្លះមិនត្រូវបានគេអនុញ្ញាតទេ។.

## ប្រភេទសាច់ដែលបម្រើការនៅក្នុងភោជនីយដ្ឋាន និងហាង

1. ការសម្លះ:វាដោយអ្នកមិនមែនមូស្លីម និងអះលីគីតាប ដូចជាអ្នកកាន់ពុទ្ធសាសនា ហិណ្ឌូសាសនា និងអ្នកគ្មានសាសនា គឺត្រូវបានគេហាមឃាត់ ហើយក៏ចូលក្នុងចំនុចនេះដែរអ្វីដែលមាននៅក្នុងភោជនីយដ្ឋាន ឬហាង នៅក្នុងប្រទេសដែលភាគច្រើនជនជាតិរបស់គេមិនមែនឥស្លាម និងអះលីគីតាប។ ហើយច្បាប់របស់វាគឺហាមឃាត់( ហារ៉ម ) រហូតទាល់តែមានការទទួលស្គាល់ផ្ទុយពីនោះ។.
2. ការសម្លះ:វាដោយអ្នកមូស្លីម ឬអះលីគីតាប ទៅតាមក្បួនច្បាប់ឥស្លាម ហើយវានេះត្រូវបានអនុញ្ញាតដោយការឯកភាពទាំងអស់។.
3. ការសម្លះ:វាដោយអ្នកមូស្លីម ឬអះលីគីតាប ទៅតាមក្បួនច្បាប់ដែលមិនមែនឥស្លាម ដូចជាការឆក់ដោយអគ្គិសនី និងធ្វើឱ្យលង់ទឹក: ហើយវានេះត្រូវបានគេហាមឃាត់ជាដាច់ខាត។.

4 **ការសម្លះវាដោយអះ**លីគីតាប ហើយមិនបានដឹងអំពីស្ថានភាពសម្លះ ហើយដូច្នោះដែរអ្វីដែលមាននៅក្នុងភោជនីយដ្ឋានរបស់ពួកគេ និងហាងរបស់ពួកគេ ពីតំណាស្របភពដើមវាមកពីការសម្លះរបស់ពួកគេ ហើយយើងត្រូវប្រុងប្រយ័ត្ន អនុញ្ញាតឱ្យបរិភោគអំពីវាជាមួយនិងការប្រុងប្រយ័ត្នលើការសូត្រ( ពីសមីលឡាហ៍ )ក្នុងពេលបរិភោគ។ ជាការល្អបំផុតនោះគឺស្វែងរកសាច់ដែលហាឡាលដែលគេអនុញ្ញាតច្បាស់លាស់។.

## > ការប្រមាញ់តាមក្បួនច្បាប់ឥស្លាម

ការប្រមាញ់សត្វពាហនៈ និងបក្សីស្របច្បាប់ ដែលគេអនុញ្ញាតឱ្យបរិភោគវា ហើយមិនអាចចាប់វាយកមកសម្លះបាន មានដូចជាប្រភេទសត្វស្វាបនៅជនបទ និងទីវេហាស្ថានដែលមិនបរិភោគសាច់ជាអាហារ ហើយក៏ដូចគ្នាដែរសត្វក្តាន់ និងទន្សាយព្រៃ និងអ្វីផ្សេងទៀត។.

លក្ខខ័ណ្ឌក្នុងការបរបាញ់មានដូចខាងក្រោម:

1 មានហើយអ្នកដែលបរបាញ់នោះត្រូវមានស្មារតី មានបំណងក្នុងការបរបាញ់ជាអ្នកមូស្លីម ឬអះលីគីតាប ហើយការបរបាញ់មិនអនុញ្ញាតទេសម្រាប់អ្នកដែលគោរពបូជាព្រះ និងអ្នកដែលឆ្កួត។.

2 សត្វដែលយើងគ្មានលទ្ធភាពក្នុងការចាប់យកមកសម្លះ ដោយសារការរត់គេចនៃល្បឿនឆាប់របស់វា។ ប្រសិនជាមានលទ្ធភាពក្នុងការចាប់វាយកមកសម្លះ ដូចជាមាន់ ពពែ និងគោ មិនអនុញ្ញាតឱ្យបរបាញ់វាឡើយ។.

3 ឧបករណ៍ក្នុងការប្រមាញ់ចាំបាច់ត្រូវតែមុត ដូចជា ព្រួញ និងកាំបិតកាំភ្លើង ឬអ្វីផ្សេងទៀត។ ចំណែកឯការប្រមាញ់ដោយឧបករណ៍ធ្ងន់ ដូចជា ដុំថ្ម ឬអ្វីផ្សេងទៀតមិនអនុញ្ញាតឱ្យបរិភោគសាច់វាទេ លើកលែងតែនៅពេលដែលជួបវាមិនទាន់ស្លាប់ ហើយក៏យកវាមកសម្លះ។.

4 ពោលនឹងនាមអល់ឡោះដោយសូត្រថា( ពីសមីលឡាហ៍ )( بسم الله )

មុនពេលដែលបាញ់ឧបករណ៍នោះ

5 ប្រសិនជាគេបានជួបសត្វ ឬបក្សី ក្រោយពីបរបាញ់វាហើយឃើញវានៅមានជីវិតមិនទាន់ស្លាប់ ចាំបាច់លើគេត្រូវតែសម្លះវា។.

6 ហាមឃាត់មិនឱ្យបរបាញ់សត្វដោយគ្មានគោលបំណងបរិភោគវាផ្ដាច់ខាត ដូចជាអ្នកដែលបរបាញ់សត្វដើម្បីការកម្សាន្ត និងការសប្បាយ បន្ទាប់មកគេមិនបរិភោគអ្វីដែលគេបានបរបាញ់នោះទេ។



## > សីលធម៌នៃការទទួលទានអាហារ និងភេសជ្ជៈ



អល់ឡោះបានដាក់ច្បាប់ជាច្រើនអំពីសីលធម៌ក្នុងការទទួលទានអាហារ និងភេសជ្ជៈ ដើម្បីបញ្ជាក់យ៉ាងច្បាស់អំពីគោលដៅ និងគតិបណ្ឌិតរបស់ព្រះ ដូចជាការរំលឹកអំពីគុណបំណាច់ដែលអល់ឡោះបានប្រទានឱ្យមនុស្ស និងការពារអំពីជំងឺផ្សេងៗ និងដោយគ្មានការខ្ជះខ្ជាយ និងឥតប្រយោជន៍។

ខ្លះៗអំពីសុជីវធម៌នេះ:

1. **ហាមឃាត់មិនឱ្យបរិភោគ** និងទទួលទានទឹកនៅក្នុងវត្ថុប្រើប្រាស់ដែលធ្វើពីមាស និងប្រាក់ ឬកែស្រោបអំពីវាទាំងពីរ។ ដោយសារធ្វើដូច្នេះវាជាការខ្ជះខ្ជាយ និងល្មើសព្រំដែន ហើយនឹងបំបាក់ទឹកចិត្តអ្នកក្រីក្រ។ រ៉សូលុលឡោះបានមានប្រសាសន៍ថា ( ចូរពួកអ្នកកុំផឹកទឹកនៅក្នុងឧបករណ៍មាស និងប្រាក់ ហើយកុំទទួលអាហារនៅក្នុងថាសទាំងពីរនេះ ពិតណាស់ឧបករណ៍ទាំងនេះសម្រាប់ពួកគេ(អ្នកគ្មានជំនឿ) នៅលើលោកិយ ហើយវាសម្រាប់ពួកអ្នកនៅថ្ងៃបរលោក)។(អាលពូខរី ៥១១០ មូស្លីម ២០៦៧))
2. **លាងសម្អាតដៃទាំងពីរ** មុននិងក្រោយបរិភោគអាហារ។
3. **សូត្រពីសមីលឡាហ៍**( بسم الله ) មុនពេលចាប់ផ្តើមបរិភោគអាហារ និងភេសជ្ជៈ ហើយអត្ថន័យរបស់វានោះគឺ: ខ្ញុំសុំភាពចំរុងចំរើន និងសុំជំនួយនឹងនាមអល់ឡោះ។ ប្រសិនបើភ្លេចហើយនឹកឃើញវិញពេលកំពុងបរិភោគចូរសូត្រថាពីស្មីលលើហិអៅវ៉ាលីហ៊ីវ៉ាអាខិរីហិ ( بسم الله أَوَّلُه وَآخِره ) ខ្ញុំចាប់ផ្តើមនិងនាមរបស់អល់ឡោះនឹងបញ្ចប់និងនាមរបស់ទ្រង់។ ហើយពិតណាស់ណាពីបានឃើញក្មេងតូចម្នាក់ដែលមិនបានយល់ដឹងច្បាស់ពីសីលធម៌នៃការបរិភោគអាហារ គាត់បានបង្រៀនទៅកាន់វាថា ( ឱក្មេងប្រុស ចូរអ្នកសូត្រពីសមីលឡាហ៍( بسم الله ) បរិភោគអាហារនឹងដៃស្តាំ និងបរិភោគនិងអ្វីដែលនៅជិតអ្នក )
4. **បរិភោគអាហារ និងទឹកដោយដៃស្តាំ** រ៉សូលុលឡោះបានមានប្រសាសន៍ថា ( ចូរពួកអ្នកកុំបរិភោគនឹងដៃឆ្វេង ពិតណាស់ស៊ៃតនវាបរិភោគនិងដៃឆ្វេង )។( មូស្លីម ២០១៩ )
5. **គប្បីសម្រាប់គាត់មិនត្រូវផ្លុំទឹក ឬបរិភោគអាហារឈរឡើយ.**
6. បរិភោគអាហារដែលនៅជិតនឹងខ្លួនរបស់គាត់ មិនត្រូវបរិភោគអំពីកន្លែងអ្នកដទៃទេ

ព្រោះការបរិភោគអំពីកន្លែងអ្នកដទៃវាជាសីលធម៌អាក្រក់ ពិតណាស់រ៉សូលុលលោះបានមានប្រសាសន៍ទៅកាន់ក្មេងប្រុសថា(ចូរបរិភោគនូវអ្វីដែលនៅជិតអ្នក)។

7 គប្បីរើសបំណែកដែលធ្លាក់

ហើយជូតអ្វីដែលប្រឡាក់ចេញ ហើយបរិភោគវា នៅពេលណាដែលយើងអាចយកចេញនូវប្រការមិនល្អ ហើយនៅក្នុងនោះដែរបញ្ជាក់អំពីការថែរក្សាលើគុណបុណ្យ និងអាហារ។.

8 ហាមមិនឱ្យបន្ទោសបង្អាប់ រិះគន់

ឬមើលងាយអាហារឡើយ។ តែគប្បីសរសើរវា ឬនៅស្ងៀម។ ណាពីរបស់យើងមិនធ្លាប់បន្ទោសបង្អាប់ចំណីអាហារឡើយ ប្រសិនបើលោកចូលចិត្តលោកទទួលទានវា ហើយប្រសិនបើលោកមិនពេញចិត្តលោកទុកវា)។(អាល់ពូខរី ៥០៩៣ មូស្លីម ២០៦៤)

9 ជៀសវាងការបរិភោគច្រើនហួសហេតុ ស្រមាប់ការធ្វើដូច្នេះជាទូទៅបណ្តាលអោយមានជំងឺនិងខ្ជិល, ខណៈពេលដែលកម្រិតមធ្យមគឺល្អបំផុតនៃកិច្ចការនេះ។ ដូចដែររ៉សូលុលលោះបានមានប្រសាសន៍ថា »គ្មានមនុស្សណាម្នាក់បំពេញពោះនូវប្រការអាក្រក់នោះទេ អាហារប៉ុន្មានម៉ាត់គ្រប់គ្រាន់ដើម្បីផ្តល់ឱ្យគាត់នូវកម្លាំងក្នុងការក្រោកឈរ។ ប៉ុន្តែប្រសិនបើគាត់ត្រូវការបន្ថែមទៀត, គាត់គួរបំពេញមួយភាគបី [នៃក្រពះរបស់គាត់] ជាមួយនឹងអាហារ, មួយភាគបីជាមួយភេសជ្ជៈ នឹងទុកមួយភាគបីសម្រាប់ដកដង្ហើម» ។(អាត់តៀរមីហ្ស៊ី ២៣៨០ អ៊ិពនូមាយ៉ះ ៣៣៤៩)

10 សូត្រនៅពេលបរិភោគរួច

អាល់ហាំទូលីលឡោះ( الحمد لله ) ថ្លែងអំណរអរគុណទៅចំពោះអល់ឡោះលើគុណបុណ្យនេះដែលបានផ្តល់វាមកដល់គាត់ដោយមនុស្សជាច្រើនមិនបានទទួលវា។ ហើយក៏អាចបន្ថែមពីលើវាដោយសូត្រ អាល់ហាំទូលីលឡោហ៍ល្លើហ្សីអាតអាមានីហ៊ើហ្សាវ៉ារ៉ហ្សាកនីហ៊ីមីនហ្គាយរីហៅលីមីននីវ៉ាឡាគូវ៉ះ

الحمد لله الذي أطعمني هذا ورزقنيه من غير حول مني ولا قوة

រាល់ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះដែលបានឱ្យខ្ញុំបានទទួលទានអាហារនេះ និងបានផ្តល់លាភសក្ការៈនេះដល់ខ្ញុំដោយវាមិនមែនដោយសារការខំប្រឹងប្រែង ឬអនុភាពរបស់ខ្ញុំឡើយ។.



> រ៉សូលុលលោះបានមានប្រសាសន៍ថា( ពិតណាស់ អល់ឡោះពេញចិត្តចំពោះខ្ញុំរបស់ទ្រង់ ដែលទទួលទានអាហារម្តង ហើយកោតសរសើរទៅចំពោះទ្រង់និងទទួលទានទឹកម្តង ហើយកោតសរសើរទៅចំពោះទ្រង់)។(មូស្លីម ២៧៣៤)



# សំលៀកបំពាក់របស់អ្នក



# 9

សំលៀកបំពាក់គឺជាគុណបុណ្យមួយក្នុងចំណោមគុណបុណ្យដែលអល់ឡោះបានផ្តល់មកឱ្យមនុស្ស។ ដូចអល់ឡោះបានមានបន្ទូលថា (ឱកូនចៅអាដាំ! យើងបានបញ្ជូនមកឱ្យពួកអ្នកនូវសំលៀកបំពាក់ដែលអាចបិទបាំងរាងកាយរបស់ពួកអ្នក និងសំលៀកបំពាក់សម្រាប់តុបតែងលំអខ្លួន។ តែសំលៀកបំពាក់កោតខ្លាច (ធ្វើអ្វីដែលអល់ឡោះប្រើ និងជៀសវាងពីការហាមឃាត់) នោះ វាប្រសើរជាងអ្វីៗទាំងអស់។ ទាំងអស់នោះគឺក្នុងចំណោមភស្តុតាងរបស់អល់ឡោះសង្ឃឹមថាគេនឹងចងចាំ)។ (ជំពូក អាល់អាក់រ៉ហ្វ ឃ្លាទី ២៦)

## មាតិកាជំពូក


### សំលៀកបំពាក់នៅក្នុងសាសនាឥស្លាម
### សំលៀកបំពាក់ដែលគេហាមឃាត់ (ហារ៉ម)

- សំលៀកបំពាក់ដែលចញ អៅរ៉ោះ (កន្លែងដែលគេហាមឃាត់មិនឱ្យអ្នកដទៃឃើញអំពីរាងកាយ)
- សំលៀកបំពាក់ដែលមានភាពស្រដៀងគ្នារវាងប្រុស និងស្រី
- សំលៀកបំពាក់ដែលដូចនិងសំលៀកបំពាក់អ្នកគ្មានជំនឿ
- សំលៀកបំពាក់ដែលធ្វើឱ្យមានភាពក្អេងក្អាង និងក្រអឺតក្រទម
- សំលៀកបំពាក់ដែលមានសៃសូត្រ ឬមាស
- សំលៀកបំពាក់ដែលមានភាពខ្ជះខ្ជាយ និងហួសកំរិត

## សំលៀកបំពាក់នៅក្នុងសាសនាឥស្លាម

សំលៀកបំពាក់របស់អ្នកមានជំនឿចាំបាច់ត្រូវតែស្អាត និងមានអនាម័យ ជាពិសេសក្នុងពេលទំនាក់ទំនងជាមួយនឹងមនុស្សនិងពេលប្រតិបត្តិសឡាត។ដូចែដរអល់ឡោះបានមានបន្ទូលថា (ឱកូនចៅអាដាំ! ចូរពួកអ្នកលំអសំលៀកបំពាក់របស់ពួកអ្នកនៅរាល់ម៉ាស្ជិទ(ពេលសឡាត)។

ហើយពិតណាស់អល់ឡោះបានដាក់ច្បាប់ស្រមាប់មនុស្សឱ្យសម្អាតសំលៀកបំពាក់របស់ពួកគេ និងរាងកាយរបស់ពួកគេ ព្រោះធ្វើដូច្នោះវាជាផ្នែកមួយនៃការនឹករលឹកដល់គុណបុណ្យដែលអល់ឡោះបានផ្តល់ឱ្យ។ អល់ឡោះបានមានបន្ទូលថា (ចូរអ្នកពោលថា: តើអ្នកណាបានហាមឃាត់ពួកអ្នកនូវសំលៀកបំពាក់ស្អាត និងលាភសក្ការៈដែលល្អ ដែលអល់ឡោះបានផ្តល់ឱ្យបណ្តាខ្ញុំរបស់ទ្រង់នោះ? ចូរអ្នកពោលថា: វាគឺស្រមាប់បណ្តាអ្នកដែលមានជំនឿក្នុងការរស់នៅលើលោកិយនេះ ជាពិសេសគឺ(ស្រមាប់ពួកគេ)នៅថ្ងៃបរលោក។ ដូច្នោះដែរ យើងបញ្ជាក់ភស្តុតាងជាច្រើន (ច្បាប់ឥស្លាម)យ៉ាងច្បាស់ស្រមាប់ក្រុមដែលចេះដឹង)។(ជំពូក អាល់អាក់រ៉ហ្វ ឃ្លា ៣២)

### សំលៀកបំពាក់បានសម្រេចនូវសេចក្តីត្រូវការជាច្រើន

1. បិទបាំងផ្នែកសំខាន់ៗនៃរាងកាយរបស់មនុស្សពីការមើលឃើញរបស់អ្នកដទៃ នៅក្រោមអារម្មណ៍សុភាពស្អាតស្អំទៅចំពោះមនុស្ស

2. ការពាររាងកាយរបស់មនុស្សអំពីក្តៅ ត្រជាក់ និងគ្រោះថ្នាក់។ ក្តៅ និងត្រជាក់គឺជាការផ្លាស់ប្តូរនៃអាកាសធាតុ ចំណែកឯគ្រោះថ្នាក់ គឺជាការបំពានទៅលើរាងកាយរបស់មនុស្ស។ អល់ឡោះបានមានបន្ទូលអំពីលក្ខណៈរបស់សំលៀកបំពាក់ថា ( ហើយទ្រង់បានធ្វើឱ្យមានសំលៀកបំពាក់ស្រមាប់ពួកអ្នកដើម្បីការពារពួកអ្នកពីកំដៅ( ឬរងា) និងសំលៀកបំពាក់( អាវក្រោះ)ដើម្បីការពារពួកអ្នកក្នុងពេលស្រ្គាម។ ដូច្នោះហើយទ្រង់បំពេញនៀកម៉ាត់របស់ទ្រង់ដល់ពួកអ្នក ដើម្បីឱ្យពួកអ្នកប្រគល់ខ្លួនទៅចំពោះទ្រង់)។( ជំពូក អាន់ណះល៍ ឃ្លា ៨១)



> សំលៀកបំពាក់បានសម្រេចនូវអត្ថប្រយោជន៍ដល់មនុស្សជាច្រើន

## > ប្រភពដើមនៃសំលៀកបំពាក់



> សាសនាឥស្លាមមិនបានកំណត់ប្រភេទនៃស្លៀកពាក់ដោយឡែកពីគេ ឡើយ ហើយជាការល្អប្រសើរគ្រឺត្រូវស្លៀកសំលៀកបំពាក់សមរម្យទៅតាមសំលៀកបំពាក់របស់ប្រជាជននៃដលរស់នៅក្នុងប្រទេសដលេគអនុញ្ញាតឲ្យពាក់។

ឥស្លាមជាសាសនាស្អាតស្អំ ហើយមិនបានកំណត់ច្បាប់ស្រមាប់មនុស្សក្នុងកិច្ចការនៃជីវិតរស់នៅរបស់ពួកគេទេ លើកលែងតែអ្វីដែលសម្រសបទៅនិងភាពស្អាតស្អំ សន្តិភាព និងអារម្មណ៍ទទួលយកបាន និងទូទៅសមហេតុសមផល។.

ប្រភពដើមនៃសំលៀកបំពាក់របស់អ្នកមូស្លីម និងការតុបតែងខ្លួនរបស់ពួកគេគឺគេអនុញ្ញាត.

សាសនាឥស្លាមមិនបានកំណត់ស្រមាប់មនុស្ស នូវប្រភេទនៃសំលៀកបំពាក់ដោយឡែកពីគេឡើយ។ ប៉ុន្តែច្បាប់បានទទួលស្គាល់រាល់សំលៀកបំពាក់ទាំងអស់ ដរាបណាវាស្ថិតនៅក្នុងចំណោមប្រការដែលត្រូវការដោយមិនមានការបំពាន និងលើស្រពើដន។.

រ៉ស៊ូលុលលោះគាត់បានស្លៀកសំលៀកបំពាក់ដែលមាននៅក្នុងសម័យរបស់គាត់។ ហើយគាត់មិនបានប្រើឱ្យស្លៀកសំលៀកបំពាក់ជាក់លាក់ណាមួយឡើយ ហើយគាត់ក៏មិនបានហាមឃាត់ការស្លៀកពាក់ជាក់លាក់ណាមួយដែរ។ ប៉ុន្តែគាត់បានហាមឃាត់នូវលក្ខណៈជាក់លាក់នៃសំលៀកបំពាក់មួយចំនួន។ប្រភពដើមនៃការទំនាក់ទំនង មានដូចជា សំលៀកបំពាក់ គឺគអនុញ្ញាតដោយមិនមានការហាមឃាត់ឡើយ លើកលែងតែមានភស្តុតាងបញ្ជាក់ នេះគឺផ្ទុយអំពីការគោរពសក្ការៈដែលប្រភពដើមរបស់វាគឺមិនត្រូវអនុវត្តឡើយ ហើយច្បាប់មិនបានកំណត់ទេលើកលែងតែមានភស្តុតាងបញ្ជាក់។.

រ៉ស៊ូលុលលោះបានមានប្រសាសន៍ថា( ចូរពួកអ្នកបរិភោគ ចូពួកអ្នកបរិច្ចាក ចូរពួកអ្នកស្លៀកសំលៀកបំពាក់ចុះ ដោយមិនមានការខ្ជះខ្ជាយ និងការកំណាញ់)។(អាន់នើសើក ២៥៥៩)

### សំលៀកបំពាក់ដលេគហាមឃាត់

1 សំលៀកបំពាក់ដលេចញ អៅរ៉ោះ (កែន្លងដែលគេហាមឃាត់មិនឱ្យអ្នកដទៃឃើញអំពីរាងកាយ): ចាំបាច់ស្រមាប់អ្នកមូស្លីម្រត្វូវបិទបាំង អៅរ៉ាត់របស់ពួកគេដោយសំលៀកបំពាក់។ ដូចអល់ទ្បោះបានមានបន្ទូលថា (យើងបានបញ្ចុះមកឱ្យពួកអ្នកនូវសំលៀកបំពាក់ ដែលអាចបិទបាំងរាងកាយរបស់ពួកអ្នក)។(ជំពូកអាល់អាក់រហ្វ ឃ្លា ២៦)

១- សំលៀកបំពាក់ដលេចញ អៅរ៉ោះ(កែន្លងដលេគហាមឃាត់មិនឱ្យអ្នកដទៃឃើញអំពីរាងកាយ): ចាំបាច់ស្រមាប់អ្នកមូស្លីម្រត្វូវបិទបាំងអៅរ៉ាត់ របស់ពួកគេដោយសំលៀកបំពាក់។ ដូចអល់ទ្បោះបានមានបន្ទូលថា (យើងបានបញ្ចុះមកឱ្យពួកអ្នកនូវសំលៀកបំពាក់ ដែល

អាចបិទបាំងរាងកាយរបស់ពួកអ្នក) ។( ជំពូក អាល់អាក់រ៉ហ្វ ឃ្លា ២៦)

ហើយសាសនាឥស្លាមបានកំណត់ខ្នាតដើម្បីបិទបាំង អៅរ៉ោះ ស្រមាប់បុរសនិងស្ត្រី។ អៅរ៉ោះរបស់បុរស ចាប់ពីផ្ចិតរបស់គាត់រហូតដល់ជង្គង់របស់គាត់ ហើយចំណែកឯ អៅរ៉ោះ របស់ស្ត្រីនៅមុខបុរសដែលអាចរៀបការជាមួយបានគឺរាងកាយទាំងអស់របស់នាង លើកលែងតែមុខ និងបាតដៃទាំងពីរ។

ហើយមិនអនុញ្ញាតឱ្យបិទបាំងដោយសំលៀកបំពាក់ដែលរឹបចង្អៀតដែលអាចកំណត់ផ្នែកៗនៃរាងកាយ។ ហើយមិនត្រូវស្តើងពេកដែលអាចចេញខ្លួនប្រាណនៅខាងក្នុងវា។ ដូច្នេះហើយអល់ឡោះបានព្រមានដល់អ្នកដែលស្លៀកសំលៀកបំពាក់ដែលអាចមើលឃើញអៅរ៉ោះរបស់វានោះ រ៉សូលុលឡោះបានមានប្រសាសន៍ថា(“ ពីរក្រុមអ្នកព្រៃកុំមេដែលចូលឋាននរក” ហើយគាត់បានរំលឹកថា “ស្ត្រីដែលស្លៀកពាក់ស្តើងចេញអៅរ៉ោះ”)

2 អ្វីដែលធ្វើឱ្យមានភាពដូចគ្នារវាងភេទទាំងពីរ: មានន័យថាគឺការប្រដូចខ្លួនបុរសទៅនឹងស្ត្រីដោយស្លៀកសំលៀកបំពាក់ ដែលស្រមាប់តែស្ត្រីប៉ុណ្ណោះ។ ហើយក៏ដូចគ្នាផងដែរការប្រដូចស្ត្រីទៅនឹងបុរស។ ទង្វើបែបនេះគេហាមឃាត់ ហើយវាជាបាបកម្មមួយនៃបាបកម្មកំរិតធ្ងន់។ ហើយគេរាប់បញ្ចូលទៅក្នុងវានោះដែរ គឺការប្រដូចរបស់ពួកគេនៅក្នុង ការនិយាយ ការដើរ និងកាយវិការ។ ពិតណាស់រ៉សូលុលឡោះបានដាក់បណ្តាសារលើបុរសដែលស្លៀកសំលៀកបំពាក់របស់ស្ត្រី និងស្ត្រីដែលស្លៀកសំលៀកបំពាក់បុរស។(អាពូទើវូទ ៤០៩៨) ហើយក៏ដូច្នោះដែររ៉សូលុលឡោះបានដាក់បណ្តាសារលើបុរសដែលប្រដូចខ្លួនទៅ និងស្ត្រី និងស្ត្រីដែលប្រដូចខ្លួនទៅនឹងបុរស(អាល់ពូខរី ៥៥៤៦) ហើយបណ្តាសារមានអត្ថន័យ បណ្តេញចេញនិងចេញឆ្ងាយអំពីការអាណិតស្រលាញ់របស់អល់ឡោះ។ ឥស្លាមចង់ឱ្យទំលាប់របស់បុរស និងរូបរាងកាយរបស់គាត់មានភាពខុសប្លែកពីស្ត្រីហើយស្រមាប់ស្ត្រីក៏ដូចគ្នាដែរដូច្នោះហើយវាជាគោលបំណងនៃភាពស្អាតស្អំដែលសន្តិភាព និងជាប្រការត្រឹមត្រូវសមហេតុសមផល។

3 សំលៀកបំពាក់ដែលដូចនិងអ្នកគ្មានជំនឿ ដោយវាជាសំលៀកបំពាក់ជាក់លាក់របស់ពួកគេ ដូចជាសំលៀកបំពាក់សង្ឃនិងអាចារ្យ និងពាក់រូបឈើឆ្កាង និងអ្វីដែលជាសញ្ញាជាក់លាក់របស់សាសនាណាមួយ ហើយទាំងអស់នោះត្រូវបានគេហាមមិនឱ្យពាក់វា ដោយរ៉សូលុលឡោះបានមានប្រសាសន៍ថា “ ជនណាហើយដែលប្រដូចខ្លួនទៅនិងក្រុមណាមួយ ពិតណាស់រូបគេគឺជាផ្នែកមួយនៃក្រុមនោះ”(អាពូទើវូទ ៤០៣១) រួមបញ្ចូលទៅក្នុងការប្រដូចនោះផងដែរគឺការស្លៀកសំលៀកបំពាក់ដែលមាននិមិត្តសញ្ញាជាក់លាក់ពីសាសនាដទៃ ឬនិកាយដែលវង្វេង។ ការប្រដូចនេះជាភស្តុតាងបង្ហាញពីការអស្ចារ្យធំ និងការមិនស្មោះត្រង់នឹងខ្លួនលើអ្វីដែលជាសិទ្ធិរបស់មនុស្ស។

ហើយមិនមែនជាការប្រដូចនោះទេ ប្រសិនបើអ្នកមូស្លីមស្លៀកសំលៀកបំពាក់ដែលល្បីសុះសាយនៅក្នុងប្រទេសរបស់គាត់ សូម្បីតែភាគច្រើនមនុស្សគ្មានជំនឿស្លៀកពាក់វាក់ដោយ។ ពិតណាស់រ៉សូលុលឡោះគាត់បានស្លៀកសំលៀកបំពាក់ដូចជាសំលៀកបំពាក់អ្នកគ្មានជំនឿនៃក្រុមគូរ៉ៃស្ហ៍ដែរ លើកលែងតែអ្វីដែលបានបញ្ជាក់ពីការហាមឃាត់ក្នុងវា។

4 សំលៀកបំពាក់ដែលធ្វើឱ្យមានភាពក្អេងក្អាង និងក្រអឺតក្រទម។ ពិតណាស់រ៉សូលុលឡោះបានមានប្រសាសន៍ថា “មិនបានចូលក្នុងឋានសួគ៌ឡើយ ជនណាហើយដែលមានភាពក្រអឺតក្រទមនៅក្នុងចិត្តរបស់វាសូម្បីតែទម្ងន់ប៉ុនលំអងធូលីក៏ដោយ” ។(មូស្លីម ៩១)

ដូច្នេះហើយឥស្លាមបានហាមឃាត់អំពីការស្លៀកសារុង(ឬខោ)ហៀរផុតតែភ្នែកគោលស្រមាប់បុរស ដោយសារការធ្វើដូច្នោះជាមូលហេតុនាំឱ្យមានភាពក្អេងក្អាង និងក្រអឺតក្រទម។ រ៉សូលុលឡោះបានមានប្រសាសន៍ថា “ជនណាស្លៀកសារុង(ឬខោ)ហៀរកង្វេជើងដោយក្រអឺតក្រទមនោះ អល់ឡោះនិងមិនមើលគាត់ឡើយនៅថ្ងៃបរលោក”។(អាល់ពូខរី ៣៤៦៥ មូស្លីម ២០៨៥)

ហើយហាមឃាត់ពីសំលៀកបំពាក់ដែលល្បីល្បាញ វាគឺសំលៀកបំពាក់ដែលធ្វើឱ្យមនុស្សមានការភ្ញាក់ផ្អើលនៅពេលដែលបុគ្គលណាម្នាក់ស្លៀកវា ហើយពួកគេគន់និងដែជិតគ្នាអំពីវា និងធ្វើឱ្យអ្នកដែលស្លៀកវាមានភាពល្បីល្បាញ។ដោយសារវាចម្លែក ឬមនុស្សស្អប់ខ្ពើមវាដោយមូលហេតុរូបរាង និងពណ៌របស់វាមិនធម្មតា ឬធ្វើឱ្យអ្នកដែលស្លៀកវាក្លាយជាអ្នកអត្រេបយោជន៍ និងក្លែងក្លាយ។ រសូលុល្លលោះបានមានប្រសាសន៍ថា “ជនណាហើយស្លៀកសំលៀកបំពាក់ដុលល្បីល្បាញនៅក្នុងលោកិយនេះ អល់លោះនិងឱ្យវាស្លៀកសំលៀកបំពាក់ដែលធ្វើឱ្យគេអាម៉ាស់នៅថ្ងៃបរលោក” ។( អះម៉ាត់ ៥៦៦៤ អ៊ិពនូមាយ៉ះ ៣៦០៧)

5 សំលៀកបំពាក់ដែលមានមាស ឬក៏មានសែសសូត្រធម្មជាតិពិសេសស្រមាប់បុរស។ ពិតណាស់សាស្វនាឥស្លាមបានហាមឃាត់វាទាំងពីរមកលើបុរស។ ដូចរសូលុលលោះបានមានប្រសាសន៍អំពីមាស និងសូត្រថា “ពិតណាស់វាទាំងពីរនេះគឺត្រូវបានហាមឃាត់មកលើបុរសៗនៃប្រជាជាតិខ្ញុំ ហើយអនុញ្ញាតស្រមាប់ស្ត្រី”។(អ៊ិបនូម៉ាយ៉ះ ៣៥៩៥ អាពូទើវូទ ៤០៥៧)

ស្បៃដែលគេហាមឃាត់លើបុរសនោះមានន័យថា: សូត្រធម្មជាតិដែលគេយកវាចេញពីដង្កូវនាង

6 សំលៀកបំពាក់ដែលមានភាពខ្ជះខ្ជាយ និងហួសកំរិត។ រសូលុលលោះបានមានប្រសាសន៍ថា “ចូរពួកអ្នកបរិភោគ ចូរពួកអ្នកបរិច្ចាក ចូរពួកអ្នកស្លៀកសំលៀកបំពាក់ចុះ ដោយមិនមានការខ្ជះខ្ជាយ និងការកំណាញ់”។(អាន់នីសាក ២៥៥៩)

ហើយវាមានភាពខុសគ្នាអាស្រ័យលើការប្រែប្រួលស្ថានភាព។ ស្រមាប់អ្នកមានគាត់អាចទិញសំលៀកបំពាក់ដែលអ្នកក្រកមិនសាកសមនឹងទិញវា ដោយយើងប្រៀបទៅនិងទ្រព្យសម្បត្តិរបស់គេ និងប្រាក់ចំណូលប្រចាំខែ និងការចំណាយចាយ និងសិទ្ធិដ៏ទៃទៀត ដែលនៅក្រោមការគ្រប់គ្រងរបស់គេ។ សំលៀកបំពាក់មួយវាអាចជាការខ្ជះខ្ជាយសម្រាប់អ្នកក្រ តែវាមិនមែនជាការខ្ជះខ្ជាយទេស្រមាប់អ្នកមាន។



> គេបានហាមឃាត់ការខ្ជះខ្ជាយនៅក្នុងសំលៀកបំពាក់ ហើយវាខុសគ្នាទៅតាមប្រាក់ចំណូល និងអ្វីដែលនៅក្រោមការគ្រប់គ្រង។



# គ្រួសាររបស់អ្នក



# 10

ឥស្លាមបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើស្ត្រី ភាពនិងលំនឹងក្នុងគ្រួសារ ហើយនិងថែរក្សាវាអំពីបុការដែលធ្វើឱ្យប៉ះពាល់ដល់វា និងបំផ្លាញសុភមង្គលរបស់វា។ ពីព្រោះសេចក្ដីល្អនៅក្នុងក្រុមគ្រួសារ និងសង្គម វានឹងធានាដល់សេចក្ដីល្អរបស់បុគ្គល និងសង្គមជាលក្ខណៈទូទៅ។

## មាតិកាជំពូក


ឋានៈគ្រួសារនៅក្នុងសាសនាឥស្លាម

ឋានៈស្ត្រីនៅក្នុងសាសនាឥស្លាម

- ស្ត្រីត្រូវបានឥស្លាមយកចិត្តទុកដាក់ថែទាំចំពោះពួកនាង
- គ្មានជម្លោះទេរវាងភេទទាំងពីរ
- ប្រេភទ្រស្តីចំពោះបុរស
- គោលការណ៍ទំនាក់ទំនងរវាងបុរសនិងស្ត្រីដែលអាចរៀបការជាមួយបាន
- ដែនកំណត់នៃហេីជេី( ការបិទបាំងលើ អ្វីដែលត្រូវបានច្បាប់តម្រូវឱ្យបិទ ) ?

ការរៀបអាពាហ៍ពិពាហ៍ក្នុងសាសនាឥស្លាម

សិទ្ធិរបស់ប្ដី និងប្រពន្ធ

ការយកប្រពន្ធច្រើន

ការលែងលះ

សិទ្ធរបស់ឪពុក ម្ដាយ

សិទ្ធរបស់កូនៗ

# > ឋានៈគ្រួសារនៅក្នុងសាសនាឥស្លាម

សាសនាឥស្លាមបានបង្ហាញពីការយកចិត្តទុកដាក់ចំពោះគ្រួសារ ដូចអ្វីដែលមាននៅខាងក្រោមៈ

**1** ឥស្លាមបានសង្កត់ធ្ងន់លើការចាប់ផ្ដើមរៀបអាពាហ៍ពិពាហ៍ និងការបង្កើតគ្រួសារ ហើយបានចាត់ទុកវាជាកិច្ចការដ៏ឧត្ដុងឧត្ដម និងជាមាគ៌ារបស់បណ្ដាអ្នកនាំសារទាំងឡាយ។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា “ ប៉ុន្ដែខ្ញុំបួសខ្ញុំស្រាយ ខ្ញុំប្រតិបត្ដិសឡាតខ្ញុំគេង ខ្ញុំរៀបការជាមួយស្ដ្រី បុគ្គលណាមិនពេញចិត្ដនឹងមាគ៌ារបស់ខ្ញុំបុគ្គលនោះមិនស្ថិតនៅក្នុងក្រុមរបស់ខ្ញុំឡើយ” ។( អាល់ពូខរី ៤៧៧៦ មូស្លីម ១៤០១ )

- គម្ពីរអាល់គួរអានត្រូវបានគេចាត់ទុកជាលាភសក្ការៈ និងជាភស្ដុតាងដ៏អស្ចារ្យដែលអល់ឡោះបានបង្កើតវាឱ្យមានការរួមរស់ការស្រលាញ់គ្នា ការអាណិតអាសូរគ្នា និងការរស់នៅជាមួយគ្នារវាងស្វាមីនឹងភរិយា។អល់ឡោះបានមានបន្ទូលថា “ ហើយក្នុងចំណោមភស្ដុតាងរបស់ទ្រង់ គឺទ្រង់បានបង្កើតឱ្យពួកអ្នកនូវភរិយាចេញពីខ្លួនពួកអ្នក ដើម្បីឱ្យពួកអ្នកមានភាពកក់ក្ដៅជាមួយនាង។ ហើយទ្រង់បានបង្កើតឱ្យមានការស្រលាញ់និងការអាណិតអាសូររវាងពួកអ្នក”។( ជំពូក អើររ៉ូម យ៉ា ២១ )
- ឥស្លាមបានប្រើឱ្យផ្ដល់ភាពងាយស្រួលក្នុងការរៀបអាពាហ៍ពិពាហ៍ និងជួយដល់អ្នកដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ដើម្បីទប់ស្កាត់តណ្ហារបស់ខ្លួនគេ។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា “ប្រ៊កុម មាន់សិទ្ធិឱ្យអល់ឡោះជួយដល់ពួកគេ” ហើយនៅក្នុងនោះមាន “អ្នករៀបការដែលមានគោលបំណងចង់ទប់ស្កាត់តណ្ហារបស់ខ្លួនកុំឱ្យប្រព្រឹត្ដបការដែលច្បាប់ហាមឃាត់”។ (អាតេតៀរមីហ្ស៊ី ១៦៥៥ ) )
- ឥស្លាមបានប្រើឱ្យយុវជនរៀបអាពាហ៍ពិពាហ៍នៅក្នុងពេលដែលពួកគេមានកំលាំងមាំមួន និងមានសមត្ថភាព។ដែលជាហេតុធ្វើឱ្យពួកគេមានការរួមរស់ និងមានភាពនឹងនរ។ ហើយក៏ទទួលបានដំណោះស្រាយស្របច្បាប់ដើម្បីទប់ស្កាត់តណ្ហា និងចំណងផ្លូវភេទដ៏ខ្លាំងខ្លារបស់ពួកគេ។.



> គម្ពីរគួរអានបានរាប់បញ្ចូលការរួមរស់ ការស្រលាញ់ និងការអាណិតអាសូរ រវាងប្ដីប្រពន្ធជាលាភសក្ការៈដ៏ធំធេងបំផុត។

**2** ឥស្លាមបានផ្ដល់ការគោរពយ៉ាងពេញលេញចំពោះសមាជិកគ្រប់រូបក្នុងគ្រួសារ ទោះបីជាបុរស ឬស្ដ្រីក៏ដោយ។.

ឥស្លាមបានចាត់ទុក ឪពុកម្ដាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងការអប់រំកូនៗរបស់ពួកគាត់។ អ៊ីពអាប់ឌុលឡោះកូន អូមើរ គាត់បានលឺរ៉សូលុលឡោះបានមានប្រសាសន៍ថា “ពួកអ្នកទាំងអស់គឺជាអ្នកមើលការខុសត្រូវ ហើយនឹងត្រូវទទួលខុសត្រូវអំពីអ្វីដែលគាត់មើលការខុសត្រូវនោះ។ មេដឹកនាំគឺជាអ្នកមើលការខុសត្រូវ ហើយត្រូវទទួលខុសត្រូវអំពីអ្នកនៅក្រោមការគ្រប់គ្រងរបស់គាត់។ បុរសគឺជាអ្នកមើលការខុសត្រូវចំពោះគ្រួសាររបស់គាត់ ហើយនឹងត្រូវទទួលខុសត្រូវអំពីអ្នកនៅក្រោមការគ្រប់គ្រងរបស់គាត់។ ស្ដ្រីគឺជាអ្នកមើលការខុសត្រូវផ្ទះស្វាមីរបស់នាង ហើយនឹងត្រូវទទួលខុសត្រូវអំពីអ្នកនៅក្រោមការគ្រប់គ្រងរបស់នាង។ អ្នកបំរើគឺជាអ្នកមើលការខុសត្រូវ ចំពោះទ្រព្យសម្បត្ដិចៅហ្វាយរបស់គាត់ហើយនឹងត្រូវទទួលខុសត្រូវអំពីអ្វីដែលគាត់មើលការខុសត្រូវនោះ:”។(អាល់ពូខរី ៨៥៣ មូស្លីម ១៨២៩ )

## 3 ឥស្លាមយកចិត្តទុកដាក់លើការបណ្តុះនៃគោលការណ៍លើកតំកើនចំពោះឪពុកម្តាយ ហើយប្រតិបត្តិការថែរក្សាពួកគាត់ និងគោរពតាមបទបញ្ជារបស់ពួកគាត់រហូតដល់ពួកគាត់លាចាកលោកនេះទៅ។.

ទោះបីជាកូនប្រុស ឬកូនស្រីស្ថិតក្នុងវ័យណាក៏ដោយ ក៏ចាំបាច់ត្រូវតែគោរព និងធ្វើល្អទៅចំពោះពួកគាត់ទាំងពីរ។ពិតណាស់អល់ឡោះបានភ្ជាប់ការធ្វើល្អចំពោះគាត់ទាំងពីរជាមួយនិងការគោរពសក្ការៈទៅចំពោះទ្រង់ ហើយបានហាមឃាត់មិនឱ្យជ្រួលជ្រួសពាក្យសំដី ឬកាយវិការទៅលើគាត់ទាំងពីរឡើយ សូម្បីតែការប្រើប្រាស់ពាក្យសំដី ឬសំលេងដំលួចង្អួលបង្ហាញពីភាពធុញទ្រាន់ចំពោះគាត់ទាំងពីរក៏ដោយ។អល់ឡោះបានមានបន្ទូលថា “ហើយម្ចាស់របស់អ្នកបានបញ្ជាថាៈ ពួកអ្នកមិនត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ។ ហើយត្រូវតែធ្វើល្អទៅចំពោះឪពុកម្តាយ។ ប្រសិនបើម្នាក់នៃគាត់ទាំងពីរ ឬគាត់ទាំងពីរមានភាពចាស់ជរារស់នៅជាមួយអ្នក ចូរអ្នកកុំនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសំដីមិនសមរម្យ ឬគំហកដាក់គាត់ទាំងពីរឱ្យសោះ។ តែអ្នកត្រូវនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសំដីណាដែលទន់ភ្លន់បំផុត” ។( ជំពូកអាល់អ៊ីសរ៉ក ឃ្លា ២៣))

## 4 ឥស្លាមប្រើឱ្យថែរក្សាសិទ្ធិកូនប្រុស និងកូនស្រី ហើយចាំបាច់ត្រូវឱ្យមានភាពយុត្តិធម៌រវាងពួកគេក្នុងការផ្តល់ថវិកា និងកិច្ចការខាងក្រៅ។.

## 5 អ្នកមូស្លីមត្រូវបានគេដាក់កាតព្វកិច្ចឱ្យភ្ជាប់ទំនាក់ទំនងជាមួយសាច់ញាតិ។ មានន័យថាៈការភ្ជាប់ទំនាក់ទំនងជាមួយមនុស្ស និងធ្វើល្អជាមួយនឹងសាច់ញាតិរបស់គេទាំងខាងឪពុក និងខាងម្តាយ។

ដូចជាបងប្អូនប្រុស និងបងប្អូនស្រីរបស់គេ មាមីងខាងឪពុករបស់គេ និងកូនៗរបស់ពួកគាត់ ហើយនិងមាមីងខាងម្តាយរបស់គេ និងកូនៗរបស់គាត់។ ហើយគេបានចាត់ទុកការធ្វើដូច្នោះ



> សាសនាឥស្លាមបានបណ្តុះគោលការណ៍គោរពលើកតំកើនចំពោះឪពុកម្តាយ

ជាការបញ្ចិតខ្លួន និងជាការគោរពដ៏ធំធេងបំផុត។ ហើយត្រូវមានការប្រុងប្រយ័ត្នអំពីការផ្តាច់ទំនាក់ទំនងជាមួយពួកគេ ឬធ្វើប្រការអាក្រក់ទៅចំពោះពួកគេ ហើយគេចាត់ទុកទង្វើបែបនេះជាបាបកម្មយ៉ាងធំ។ រ៉សូលុលលេាះបានមានប្រសាសន៍ថា “មិនចូលឋានសួគ៌ឡើយអ្នកដែលកាត់ផ្តាច់ទំនាក់ទំនងជាមួយសាច់ញាតិ”។(អាល់ពូខរី ៥៦៣៨ មូស្លីម ២៥៥៦)

## >ឋានៈស្ត្រីនៅក្នុងសាសនាឥស្លាម

សាសនាឥស្លាមបានលើកតំកើនស្ត្រី និងបានផ្តល់សិទ្ធិសេរីភាពដល់នាងអំពីភាពជាខ្ញុំបំរើជាថៃ្នរបស់បុរស ដូច្នោះដែរក៏បានផ្តល់សេរីភាពដល់នាងអំពីការក្លាយជាទំនិញដើម្បីថោកទាប ដែលគ្មានកិត្តិយសស្រមាប់នាង និងគ្មានការគោរព។ ក្នុងចំណោមឧទាហរណ៍នៃច្បាប់ទាក់ទងនឹងការលើកតំកើនស្ត្រីមានដូចជាៈ

- សាសនាឥស្លាមផ្តល់ឱ្យស្ត្រីនូវចំណែករបស់នាងនៃកេរមរតកក្នុងការបែងចែក ដ៏យុត្តិធម៌ ថ្លៃថ្នា ហើយកន្លែងខ្លះមានភាពស្មើគ្នារវាងប្រុសនិងស្រី ហើយកន្លែងខ្លះទៀតក៏មានភាពខុសគ្នា

ដោយគិតតាមការជាប់សាច់ញាតិរបស់នាង និងការចំណាយចាយដែលជាបន្ទុកលើនាង។.

- បុរស និងស្ត្រីមានភាពស្មើគ្នានៅក្នុងកិច្ចការជាច្រើនខុសៗគ្នាដូចជាការទំនាក់ទំនងជាមួយហិរញ្ញវត្ថុទាំងអស់។ រហូតដល់រ៉សូលុល្លោះបានមានប្រសាសន៍ថា "ស្ត្រីជាបងប្អូនបង្កើតនិងបុរស"។ (អាពូទើវូទ ២៣៦))
- ផ្តល់សេរីភាពដល់ស្ត្រីក្នុងការជ្រើសរើសស្វាមី ហើយដាក់កាតព្វកិច្ចលើនាងមួយផ្នែកនៃការទទួលខុសត្រូវក្នុងការអប់រំកូនៗ។ រ៉សូលុលឡោះបានមានប្រសាសន៍ថា "ស្ត្រីគឺជាអ្នកមើលការខុសត្រូវផ្ទះស្វាមីរបស់នាង ហើយនិងត្រូវទទួលខុសត្រូវអំពីអ្នកនៅក្រោមការគ្រប់គ្រងរបស់នាង"។( អាល់ពូខរី ៨៥៣ មូស្លីម ១៨២៩)
- ថែរក្សាឈ្មោះរបស់នាងឱ្យនៅដូចដើម និងផ្តល់កិត្តិយសឱ្យនាងយកត្រកូលតាមឪពុករបស់នាង ដោយមិនមានការកែប្រែត្រកូលរបស់នាងឡើយបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច ផ្ទុយទៅវិញបន្សល់ទុកឱ្យនាងយកត្រកូលតាមឪពុករបស់នាង និងក្រុមគ្រួសាររបស់នាង។.
- គេបានដាក់កាតព្វកិច្ចទៅលើបុរសឱ្យថែរក្សា និងផ្តល់ការចំណាយចាយទៅឱ្យនាងដោយគ្មានការនិយាយរំលឹកគុណ ប្រសិនបើនាងជាអ្នកដែលច្បាប់ដាក់កាតព្វកិច្ចឱ្យផ្តល់ការចំណាយចាយលើនាង ដូចជាៈ ប្រពន្ធ ម្តាយ និងកូនស្រី។.
- គេបានបញ្ជាក់យ៉ាងច្បាស់ចំពោះភាពល្អប្រពៃ និងអត្ថប្រយោជន៍ក្នុងការមើលថែស្ត្រីដែលទន់ខ្សោយដែលគ្មាននរណាម្នាក់រស់នៅជាមួយគាត់ សូម្បីតែសាច់ញាតិណាម្នាក់។ ហើយគេបានជំរុញឱ្យខិតខំបំរើគាត់ ហើយបានចាត់ទុកទង្វើនោះជាកិច្ចការល្អប្រពៃបំផុតចំពោះអល់ឡោះ។ រ៉សូលុលឡោះបានមានប្រសាសន៍ថា "អ្នកថែរក្សាស្ត្រីមេម៉ាយ និងអ្នកក្រីក្រ ដូចជាអ្នកតស៊ូក្នុងផ្លូវអល់ឡោះ ហើយដូចជាអ្នកស៊ីឡាតរហូត បួសរហូត"។(អាល់ពូខរី ៥៦៦១ មូស្លីម ២៩៨២).

## ស្ត្រីត្រូវបានឥស្លាមយកចិត្តទុកដាក់ថែទាំចំពោះពួកនាង

**ម្តាយៈ** អំពី អាពូហ៊ូរ៉យរ៉ោះ គាត់បាននិយាយថា មានបុរសម្នាក់មកជួបរ៉សូលុលឡោះ ហើយក៏បានសួរថាៈ ឱរ៉សូលុលឡោះ! តើអ្នកណាដែលខ្ញុំត្រូវធ្វើល្អចំពោះគាត់ជាងគេ? លោកបានឆ្លើយថាៈ ម្តាយរបស់អ្នក។ គាត់បានសួរថាៈ បន្ទាប់មកទៀតអ្នកណា? លោកបានឆ្លើយថាៈ ម្តាយរបស់អ្នក។ គាត់បានសួរថាៈ បន្ទាប់មកទៀតអ្នកណា?លោកបានឆ្លើយថាៈ ម្តាយរបស់អ្នក។ គាត់បានសួរទៀតថាៈ បន្ទាប់មកទៀតអ្នកណា? លោកបានឆ្លើយថាៈ គឺឪពុករបស់អ្នក។ (អាល់ពូខរី ៥៦២៦ មូស្លីម ២៥៤៨)

**កូនស្រីៈ** អំពី អុកពះ កូន អាមៀរ បាននិយាយថាៈ ខ្ញុំបានឮរ៉សូលុលឡោះលោកបានមានប្រសាសន៍ថា "ជនណាហើយដែលមានកូនស្រីបីនាក់ ហើយគេបានអត់ធ្មត់ជាមួយពួកនាង ផ្តល់ចំណីអាហារដល់ពួកនាង ផ្តល់ទឹកផឹកដល់ពួកនាង ផ្តល់សំលៀកបំពាក់ដល់ពួកនាង ការខិតខំប្រឹងប្រែងរបស់គាត់ វានឹងក្លាយជារណាំងការពារអំពីភ្លើងនរកនៅថ្ងៃបរលោក"។ (អ៊ីពនូមាយ៉ះ ៣៦៦៩))

**ប្រពន្ធៈ** អំពី អាអ៊ីស្ហះ បាននិយាយថាៈ រ៉សូលុលឡោះបានមានប្រសាសន៍ថា "អ្នកដែលល្អជាងគេក្នុងចំណោមពួកអ្នកគឺអ្នកដែលធ្វើល្អចំពោះគ្រួសាររបស់ពួកអ្នក ហើយខ្ញុំគឺជាអ្នកដែលធ្វើល្អជាងគេចំពោះគ្រួសាររបស់ខ្ញុំ"។(អាត់តៀរមីហ្ស៊ី ៣៨៩៥)

> ទំនាក់ទំនងរវាងបុរស និងស្ត្រីក្នុងច្បាប់គឺទំនាក់ទំនងដ៏ពេញលេញ ដែលជួយបំពេញកង្វះខាតរបស់ពួកគេទៅវិញទៅមកក្នុងការកសាងសង្គមឥស្លាម។



## គ្មានជម្លោះទេរវាងភេទទាំងពីរ

គំនិតនៃការឈ្លោះគ្នារវាងបុរសនិងស្ត្រីបានបញ្ចប់ ដោយការគ្រប់គ្រងរបស់បុរសលើស្ត្រី។ ដូចជានៅក្នុងសហគមន៍លោកខាងលិចមួយចំនួន ឬការបះបោររបស់ស្ត្រី ហើយនឹងការចាកចេញរបស់នាងពីតួនាទីពេញលេញ និងលក្ខណៈធម្មជាតិរបស់ពួកនាង ដែលគេបង្កើតវាសម្រាប់នាង ដូចជានៅក្នុងសង្គមដទៃទៀត ដែលចេញឆ្ងាយពីច្បាប់របស់អល់ឡោះ។

ដូច្នេះវានឹងមិនអាចកើតឡើងទេ ប្រសិនបើវាចាកចេញឆ្ងាយពីច្បាប់របស់អល់ឡោះដែលប្រកបដោយគតិបណ្ឌិត ដោយអល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នកកុំទន្ទឹងចង់បានដូចអ្វីដែលអល់ឡោះបានប្រទានឱ្យអ្នកខ្លះក្នុងចំណោមពួកអ្នក។ ស្រមាប់បុរសៗនឹងទទួលផលពីអ្វីដែលពួកគេបានសាង ហើយស្រមាប់ស្ត្រីក៏នឹងទទួលផលពីអ្វីដែលពួកនាងបានសាងដែរ។ ចូរពួកអ្នកសុំពីអល់ឡោះនូវការសន្ដោសប្រណីរបស់ទ្រង់”។(ជំពូក អាន់នីសាក ឃ្លា៣២) ដូច្នេះនូវគ្រប់លក្ខណៈពិសេសរបស់វា មុខងាររបស់វានិងកិត្តិយសរបស់វា ហើយនិងអ្វីៗទាំងអស់នោះដោយការខិតខំដើម្បីទទួលបានការប្រោសប្រទាន និងការយល់ព្រមពីអល់ឡោះ។ហើយច្បាប់មិនបាននាំមកនូវផលស្រមាប់បុរស ឬស្ត្រីទេ ប៉ុន្តែបាននាំមកនូវផលស្រមាប់ មនុស្ស និងសង្គមឥស្លាម។

នៅក្នុងមាគ៌ានៃសាសនាឥស្លាមគឺគ្មានសមរភូមិ ឬជម្លោះឡើយរវាងភេទទាំងពីរ ហើយក៏មិនមែនមានន័យចំពោះការប្រកួតប្រជែងក្នុងកិច្ចការលោកិយ៍ដែរ ហើយក៏មិនមែនការភ្លក់រសជាតិនៃយុទ្ធនាការលើស្ត្រី ឬយុទ្ធនាការលើបុរសដែរ ហើយការប៉ុនប៉ងដើម្បីធ្វើឱ្យប៉ះពាល់ដល់នរណាម្នាក់ និងគំនិតអវិជ្ជមានរបស់គេ និងការតាមដានកង្វះខាតរបស់គេ!

ហើយទាំងអស់នោះគឺជាផ្នែកមួយដែលមានការភាន់ច្រឡំនិងយល់ខុសមកលើសាសនាឥស្លាមហើយក៏ជាការយល់ខុសអំពីមុខងារពិត្របាកដនៃភេទទាំងពីរនៅក្នុងផ្នែកផ្សេងទៀតៗហើយស្រមាប់មនុស្សគ្រប់រូបត្រូវតែបួងសួងសុំពីអល់ឡោះដើម្បីទទួលបានការប្រោសប្រទានពីទ្រង់។

### ប្រភេទស្ត្រីចំពោះបុរស

### ស្ត្រីចំពោះបុរសត្រូវបានបែងចែកជាច្រើនប្រភេទ

**1** ស្ត្រីម្នាក់នោះគឺជាប្រពន្ធរបស់គាត់:

បុរសត្រូវបានអនុញ្ញាតិឱ្យមើល និងទទួលភាពរីករាយ ពីប្រពន្ធរបស់គាត់ទៅតាមអ្វីដែលចង់បាន ហើយដូច្នោះដែរស្ត្រីក៏ត្រូវបានអនុញ្ញាតជាមួយនឹងប្ដីរបស់នាង

ដែរ ពិតណាស់អល់ឡោះបានឱ្យឈ្មោះប្ដីថា ជាសំលៀកបំពាក់របស់ប្រពន្ធ ហើយប្រពន្ធជាសំលៀកបំពាក់របស់ប្ដី វាប្រៀបដូចជារូបភាពដ៏អស្ចារ្យនៃការផ្សាភ្ជាប់រវាងផ្លូវកាយ ផ្លូវចិត្តនិងរាងកាយពួកគេទាំងពីរ។ អល់ឡោះបានមានបន្ទូលថា "ពួកនាង(ប្រពន្ធ) គឺជាសំលៀកបំពាក់ស្រមាប់ពួកអ្នក ហើយពួកអ្នក(ប្ដី)គឺជាសំលៀកបំពាក់ស្រមាប់ពួកនាង"។ (ជំពូក អាលហ្ពាកេរ៉ោះ ឃ្លា ១៨៧) (ចូរមើលទំព័រ ១៧៧)

## 2 ស្ត្រីដែលជាម៉ុះរ៉ម(មិនអនុញ្ញាតឱ្យរៀបការជាមួយបាន)របស់គាត់

ស្ត្រីដែលជាម៉ុះរ៉មមានអត្ថន័យថា បណ្ដាស្ត្រីដែលច្បាប់ឥស្លាមហាមឃាត់ចំពោះបុរសមិនឱ្យការរៀបការជាមួយនាង ជាដាច់ខាត។ ហើយស្ត្រីដែលជាម៉ុះរ៉មមានដូចជា:

| | |
|---|---|
| 1 | ម្ដាយបង្កើត ឬជីដូន ខាងឪពុកនិងខាងម្ដាយ ដូចជាម្ដាយរបស់ម្ដាយ ឬម្ដាយរបស់ឪពុក និងអ្នកលើនិងទៀត។ |
| 2 | កូនស្រីបង្កើត ឬកូនស្រីរបស់កូនប្រុស ឬកូនស្រីរបស់កូនស្រី និងអ្នកក្រោមនិងទៀត |
| 3 | បងប្អូនស្រីបង្កើត ឬបងប្អូនស្រីខាងឪពុក ឬបងប្អូនស្រីខាងម្ដាយ |
| 4 | មីងផ្ទាល់ គាត់គឺបងប្អូនស្រីបង្កើតរបស់ឪពុក ឬខាងឪពុក ឬខាងម្ដាយ។ ហើយរាប់បញ្ចូលនៅក្នុងនោះដែរមីងរបស់ឪពុក និងមីងរបស់ម្ដាយ។ |
| 5 | មីងផ្ទាល់ គាត់គឺបងប្អូនស្រីបង្កើតរបស់ម្ដាយ ឬខាងឪពុក ឬខាងម្ដាយ ។ ហើយរាប់បញ្ចូលនៅក្នុងនោះដែរមីងរបស់ឪពុក និងមីងរបស់ម្ដាយ។ |
| 6 | កូនស្រីរបស់បងប្អូនប្រុសបង្កើត ឬខាងឪពុក ឬខាងម្ដាយ និងនៅក្រោមទៀត ដូចជាកូនស្រីរបស់កូនបងប្អូនប្រុស |
| 7 | កូនស្រីរបស់បងប្អូនស្រីបង្កើត ឬខាងឪពុក ឬខាងម្ដាយ និងអ្នកនៅក្រោមទៀត ដូចជាកូនស្រីរបស់កូនបងប្អូនស្រី |
| 8 | ម្ដាយរបស់ប្រពន្ធ ទោះបីជាប្រពន្ធនៅជាមួយគាត់ ឬលែងគ្នាក៏ដោយ ម្ដាយរបស់នាងគឺជាម៉ុះរ៉មពេញលេញ ហើយក៏ដូច្នោះដែរជីដូនរបស់ប្រពន្ធ |
| 9 | កូនស្រីរបស់ប្រពន្ធដែលមិនមែនជាកូនរបស់គាត់ |
| 10 | ប្រពន្ធរបស់កូន និងអ្នកនៅក្រោមទៀត ដូចជាប្រពន្ធរបស់ចៅ |
| 11 | ប្រពន្ធរបស់ឪពុក និងអ្នកនៅលើទៀត ដូចជាប្រពន្ធរបស់ជីតា |
| 12 | ម្ដាយដែលបំបៅដោះ គាត់ជាស្ត្រីដែលបំបៅដោះ ឱ្យគេនៅក្នុងពេលពីរឆ្នាំដំបូងនៃការស្រមាលរបស់គេដោយបំបៅផ្ទៃត្រីបាំដង ពិតណាស់ឥស្លាមបានផ្ដល់សិទ្ធិឱ្យគាត់ដោយមូលហេតុការបំបៅរបស់គាត់ចំពោះគេ។ |
| 13 | បងប្អូនស្រីអំពីការបំបៅ នាងគឺកូនស្រីរបស់ស្ត្រីដែលបំបៅគាត់ខណៈពេលដែលគាត់នៅក្មេងដូចដែរបានរៀបរាប់មក។ ដូច្នោះដែររាល់សាច់ញាតិអំពីការបំបៅទាំងអស់ត្រូវបានគេហាមឃាត់ដូចជាសាច់ញាតិនពូជអំបូរដែរ ដូចជាមីងខាងឪពុក មីងខាងម្ដាយ កូនស្រីបងប្អូនប្រុស កូនស្រីបងប្អូនស្រី អំពីការបំបៅដោះ។ |




ពួកគេគឺជាម៉ះរ៉មទាំងនេះត្រូវបានអនុញ្ញាតឲ្យដើរចេញក្រៅឆ្លងកាត់ខាងមុខបុរសនោះដោយអាចបញ្ចេញអាវរ៉ាតដែលជាធម្មតាតែងតែលេចចេញនៅពីមុខសាច់ញាតិ ដូចជាការលេចចេញកំភួនដៃ ក និងសក់ ហើយនិងផ្សេងៗទៀតដោយមិនហួសហេតុឬហួសព្រំដែន

## 3 ស្ត្រីអាជណាពីយ៉ះ(ស្ត្រីដែលអាចរៀបការជាមួយបាន):

ស្ត្រីអាជណាពីយ៉ះ គឺបណ្ដាស្ត្រីដែលមិនមែនមុះរ៉មរបស់គេ ទោះបីជានាងជាសាច់ញាតិរបស់គេ ដូចជា កូនស្រីរបស់មាឬមីងខាងឪពុកគេ ឬកូនស្រីរបស់មាឬមីងខាងម្ដាយគេ។ ប្រពន្ធរបស់បងប្អូនប្រុសគេ ឬសាច់ញាតិរបស់ស្ត្រីក្រុមគ្រួសារគេ។ ឬមិនមែនជាសាច់ញាតិរបស់គេ និងមិនមានជាប់ទំនាក់ទំនងសាច់ញាតិជាមួយនាង ឬសាច់ញាតិក្រុមគ្រួសារនាងឡើយ។.

ពិតណាស់សាសនាឥស្លាមបានដាក់គោលការណ៍ និងច្បាប់ដើម្បីក្ដាប់ក្ដីលើការទំនាក់ទំនងរវាងជនម៉ូស្លីមនិងស្ត្រីអាជណាពីយ៉ះ( ស្ត្រីដែលអាចរៀបការជាមួយបាន) ក្នុងគោលបំណងការពារកិត្តិយសនិងបិទទ្វាររបស់ស៊ូតនេទៅចំពោះមនុស្ស។ ម្ចាស់ដែលបង្កើតមនុស្សទ្រង់ដឹងបំផុតអំពីអ្វីដែលល្អប្រសើរសម្រាប់វា។ អល់ឡោះបានមានបន្ទូលថា "តើម្ចាស់ដែលបានបង្កើត( អ្វីទាំងអស់) មិនបានដឹងទេឬ? ហើយទ្រង់គឺជាអ្នកដែលទន់ភ្លន់ ដឹងជ្រៅជ្រះបំផុត"។(ជំពូក អាល់មុលក៍ ឃ្លា១៤)

រាល់ឧប្បត្តិហេតុ... 

រាល់ព្រឹត្តិការណ៍...

របាយការណ៍និងស្ថិតិនានាតែងនិយាយជារឿងរ៉ាវថ្មីអំពីករណីនៃការរំលោភសេពសន្ថវៈនិងការទំនាក់ទំនងមានភាពខុសឆ្គងដែលច្បាប់ហាមឃាត់នោះគឺបានបំផ្លាញជាច្រើននៃក្រុមគ្រួសារនិងសហគមន៍ ដោយសារការឃ្លាតឆ្ងាយពីការអនុវត្តច្បាប់របស់អល់ឡោះ។



> ឥស្លាមបានដាក់កន្លែងច្បាប់ដើម្បីកំណត់ទំនាក់ទំនងរវាងបុរសនិងស្ត្រី

## វិធីសាស្ត្រទំនាក់ទំនងរវាងបុរសនិងស្ត្រីអាជណាពីយ៉ះ(ស្ត្រីដែលអាចរៀបការជាមួយបាន)

**1** ដាក់កែវភ្នែកចុះពីការសម្លឹងមើល

ចាំបាច់លើអ្នកម៉ូស្លីមមិនត្រូវមើលចំពោះអៅរ៉ោះ ហើយមិនត្រូវមើលទៅលើអ្វីដែលនាំឱ្យមានតណ្ហានៅក្នុងខ្លួន និងមិនត្រូវមើលស្ត្រីក្នុងរយៈពេលវែងដោយគ្មានកិច្ចការចាំបាច់ឡើយ។.

A ពិតណាស់អល់ឡោះបានប្រើឱ្យភេទទាំងពីរ ដាក់កែវភ្នែកចុះពីការសម្លឹងមើល ព្រោះវាជាវិធីរក្សាភាពបរិសុទ្ធនិងការពារកិត្តិយស ដូចជាការចាប់ផ្ដើមនៃការសម្លឹងមើលដោយគ្មានព្រំដែនវាជាអំពើបាបនិងអំពើអាក្រក់។ អល់ឡោះបានមានបន្ទូលថា "ចូរអ្នក(ណាពីមូហាំម៉ាត់)ពោលទៅកាន់បណ្ដាលបុរសដែលមានជំនឿឱ្យពួកគេដាក់កែវភ្នែករបស់ពួកគេចុះពីការសម្លឹងមើល(ស្ត្រី និងអ្វីដែលច្បាប់ឥស្លាមបានហាមឃាត់) ហើយឱ្យពួកគេថែរក្សានូវប្រដាប់ភេទរបស់ពួកគេ( អំពីការហ្ស៊ីណា)។ នោះគឺជាប្រការស្អាតស្អំបំផុតសម្រាប់ពួកគេ។ ពិតប្រាកដណាស់ អល់ឡោះដឹងជ្រៅជ្រះបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។ ចូរអ្នក( ណាពីមូហាំម៉ាត់) ពោលទៅកាន់បណ្ដាលស្ត្រីដែលមានជំនឿឱ្យពួកនាងដាក់កែវភ្នែកចុះពីការសម្លឹងមើល(បុរសនិងអ្វីដែលច្បាប់ឥស្លាមហាមឃាត់) ហើយឱ្យពួកនាងថែរក្សាប្រដាប់ភេទរបស់ពួកនាង( អំពីការហ្ស៊ីណា)។(ជំពូក អាន់នូរ ឃ្លា៣០-៣១))

ប្រសិនជាវាបានកើតឡើងដោយមនុស្សបានមើលឃើញដោយចៃដន្យ ចាំបាច់សម្រាប់វាត្រូវតែងាកការមើលរបស់វាចេញអំពីការដែលគេហាមឃាត់ ហើយការដាក់កែវភ្នែកចុះពីការសម្លឹងមើលវារួមបញ្ចូលទាំងប្រព័ន្ធផ្សព្វផ្សាយ និងអ៊ិនធើណិតទាំងអស់។ ហើយហាមឃាត់មិនឱ្យសម្លឹងមើលអ្វីដែលនាំឱ្យមានតណ្ហា និងជំរុញឱ្យមានសភាវគតិនៅក្នុងវា។

## 2 ការទំនាក់ទំនងដោយសីលធម៌ និងសុជីវធម៌និងសុជីវធម៌

ការនិយាយជាមួយស្ត្រីអាជ្ញាណាពីយ៉ះ( ស្ត្រីដែលរៀបការជាមួយបាន) និងនាងនិយាយតបមកវិញ ហើយនិងទំនាក់ទំនងរវាងគេទាំងពីរដោយសីលធម៌ និងសុជីវធម៌ ជាមួយនិងការជៀសឆ្ងាយអំពីអ្វីទាំងអស់ដែលនាំឱ្យមានសកម្មភាពនៃសភាវគតិដោយវិធីណាមួយក៏ដោយ ហើយដូចេនះ

- អល់ឡោះបានហាមឃាត់ស្ត្រីចំពោះការនិយាយដោយស្រទន់ និងម៉ូកម៉ូកជាមួយបុរសអាជណាពី( បុរសដែលរៀបការជាមួយបាន )និងដាក់បទបញ្ជាដោយបន្ទូលរបស់ទ្រង់យ៉ាងច្បាស់លាស់។ អល់ឡោះបានមានបន្ទូលថា “ ពួកនាងកុំប្រើពាក្យស្ដីទន់ភ្លន់ម៉ូកម៉ូក់( ជាមួយបុរសដែលមិនមែនជាស្វាមី) ឱ្យសោះ ជាហេតុធ្វើឱ្យបុរសដែលមានជម្ងឺ ( ចំណង់តណ្ហា ) នៅក្នុងចិត្តរបស់គេមានអារម្មណ៍(ចំពោះពួកនាង)។ តែពួកនាងត្រូវនិយាយនូវពាក្យសំដីណាដែលល្អ” ។( ជំពូកអាល់អះហ្សាប ឃ្លា ៣២))
- ហាមឃាត់អំពីការបញ្ចេញសកម្មភាពក្បាច់រាំងក្នុងពេលដើរ និងបញ្ចេញនូវខ្លះៗអំពីការតុបតែងលំអរ។ អល់ឡោះបានមានបន្ទូលថា “ ដូច្នោះដែរកុំឱ្យពួកនាងដើរទ្រទន្ទាំជើងបន្លឺសម្លេង ដើម្បីឱ្យគេដឹងនូវអ្វីដែលពួកនាងលាក់បាំងអំពីការតុបតែងរបស់ពួកនាងឱ្យសោះ”។( ជំពូក អាន់នួរ ឃ្លា ៣១ )

## 3 ហាមឃាត់ការនៅកន្លែងស្ងាត់

ការនៅកន្លែងស្ងាត់មានន័យថាការនៅតែពីរនាក់រវាងបុរសនិងស្ត្រីអាជណាពីយ៉ះ ក្នុងកន្លែងដែលគ្មាននរណាម្នាក់មើលឃើញពួកគេ។ ហើយពិតណាស់សាសនាឥស្លាមបានហាមឃាត់ការនៅកន្លែងស្ងាត់តែពីរនាក់ ពីព្រោះវាធ្វើឱ្យស្ទើតែនបញ្ចូលប្រការអាក្រក់។ រ៉សូលុលឡោះបានមានប្រសាសន៍ថា “គ្មាននៃបុរសម្នាក់ណាបាននៅកន្លែងស្ងាត់ជាមួយនឹងស្ត្រីម្នាក់ លើកលែងតែមានស្ហៃតនជាអ្នកទីបីនៃពួកគេទាំងពីរ”។(អាត់តៀរមីហ្ស៊ី ២១៦៥)



## 4 អាល់ហ៊ីជើប( អ្វីដែលយកមកបិទបាំងរាងកាយដែលច្បាប់បានបង្គាប់ប្រើ)

អល់ឡោះបានដាក់កាតព្វកិច្ចពាក់ហ៊ីជើបលើស្ត្រីខុសពីបុរស ដោយសារមានការរួមបញ្ចូលនៅក្នុងវាអំពីការបង្ហាញនូវស្រមស់ និងកត្តាទាក់ទាញដែលធ្វើឱ្យមានមហន្តរាយដល់បុរសច្រើនជាង បុរសធ្វើឱ្យមានមហន្តរាយដល់ស្ត្រី។

ពិតណាស់អល់ឡោះបានដាក់ច្បាប់មួយចំនួនលើការពាក់ហ៊ីជើប ក្នុងនោះមាន :

- ស្ត្រីអាចអនុវត្តកិច្ចការរបស់នាងនៅក្នុងជីវិតរស់នៅ និងសង្គមក្នុងផ្នែកសិក្សានិងការងារដោយមានភាពល្អប្រសើរ ជាមួយនិងការថែរក្សានូវសេចក្តីថ្លៃថ្នូរនិងភាពបរិសុទ្ធរបស់នាង។.
- កាត់បន្ថយនិងបន្ធូរស្រាលដល់ឱកាសនៃការប្រព្រឹត្តខុស និងការរំលោភបំពានដើម្បីធានាដល់ការជ្រះស្អាតនៃសង្គមក្នុងផ្នែកមួយ និងម្យ៉ាងផ្សេងទៀតដើម្បីថែរក្សាសេចក្តីថ្លៃថ្នូររបស់ស្ត្រី។.
- ជួយដល់បុរសក្នុងការសម្លឹងមើលទៅស្ត្រីលើភាពបរិសុទ្ធ និងមានវិន័យ។ ហើយពួកគេធ្វើការទំនាក់ទំនងជាមួយនាងដូចជាមនុស្សទទួលបានភាពរីករាយដូចអ្វីដែលពួកគេទទួលបានភាពរីករាយពីវាអំពីការរួមផ្សំពីវប្បធម៌ និងចំណេះដឹង។ ពោលគឺរូបនាងមិនមែនជាវត្ថុបម្រើការល្បួងទៅលើសភាវគតិ និងជាឧបករណ៍សម្រាប់ការលេងសើចនិងភាពសប្បាយរីករាយនោះទេ។.



> ការថែរក្សាការពាក់ហ៊ីជើបសម្រាប់ស្ត្រី និងដើម្បីឱ្យពួកគេអាចបំពេញបេសកកម្មរបស់នាងក្នុងសង្គមនៅក្នុងរូបភាពបរិសុទ្ធបំផុតដែលមនុស្សជាតិអាចស្គាល់នាង។

## ព្រំដែននៃការពាក់ហ៊ីជើប

អល់ឡោះបានដាក់កាតព្វកិច្ចលើស្ត្រីពេលនៅមុខបុរសអាជណាពី( បុរសដែលរៀបការជាមួយបាន) ត្រូវបិទបាំងទាំងអស់ខ្លួនប្រាណរបស់នាងលើកលែងតែមុខនិងប្រអប់ដៃរបស់នាងប៉ុណ្ណោះ។ ដូចអល់ឡោះបានមានបន្ទូលថា “ហើយកុំឱ្យពួកនាងបង្ហាញស្រមស់របស់នាង លើកលែងតែអ្វីដែលស្តែងចេញជាធម្មតា”។(ជំពូក អាន់នូរ ឃ្លា ៣១) អ្វីដែលស្តែងចេញជាធម្មតានោះគឺ មុខនិងប្រអប់ដៃ។ លើកលែងតែនៅពេលណាដែលជួបនឹងមហន្តរាយដោយសារការបង្ហាញមុខនិងប្រអប់ដៃ ចាំបាច់ត្រូវបិទបាំងវាទាំងពីរនៅខណៈពេលនោះ។.

## វិធីសាស្ត្រពាក់ហ៊ីជើប

អនុញ្ញាតសម្រាប់ស្ត្រីពាក់ហ៊ីជើបអ្វីដែលនាងចង់អំពីរូបរាង និងពណ៌ទៅតាមលក្ខខណ្ឌខាងក្រោមនេះ:

1. មាននៅហើយហ៊ីជើបគ្របដណ្តប់លើកន្លែងអ្វីដែលចាំបាច់ត្រូវបិទបាំងវា.
2. ត្រូវឱ្យមានទំហំធំទូលាយ និងមិនចង្អៀតដែលអាចកំណត់ផ្នែករាងកាយ។.
3. មិនត្រូវឱ្យស្តើងពេក អាចមើលឃើញរាងកាយខ្លួនប្រាណនៅខាងក្នុង.

## > ការរៀបអាពាហ៍ពិពាហ៍នៅក្នុងសាសនាឥស្លាម



> ការរៀបអាពាហ៍ពិពាហ៍ជាការទំនាក់ទំនង ដ៏អស្ចារ្យដែលសាសនាឥស្លាមបានបញ្ជាក់លើវាយ៉ាងច្បាស់

ការរៀបអាពាហ៍ពិពាហ៍គឺជាទំនាក់ទំនងដ៏អស្ចារ្យបំផុតដែលឥស្លាមបានបញ្ជាក់យ៉ាងច្បាស់ចំពោះវា និងមានចំណងក្នុងវា ហើយនឹងបានចាត់ទុកវាជាមាគ៌ារបស់បណ្តាអ្នកនាំសារ។ (ចូរមើលទំព័រ ១៧០)

សាសនាឥស្លាមត្រូវបានយកចិត្តទុកដាក់យ៉ាងលម្អិតនៅក្នុងច្បាប់នៃអាពាហ៍ពិពាហ៍ និងសីលធម៌ និងសិទ្ធិប្តីប្រពន្ធ, នៅក្នុងគោលបំណងដើម្បីរក្សាទំនាក់ទំនងនេះឱ្យបន្ត និងមានស្ថេរភាព និងកសាងគ្រួសារដែលទទួលបានជោគជ័យដែលជាកន្លែងដែលកុមាររីកដុះដាល ដោយមាន ស្ថេរ ភាពខ្លួនឯង និងស្ថិតនៅលើសាសនា និងឧត្តមភាពក្នុងផ្នែកទាំងអស់នៃជីវិត។.

### ច្បាប់ទាំងនោះមានដូចខាងក្រោម:

ឥស្លាមបានដាក់លក្ខខ័ណ្ឌចាំបាច់សម្រាប់ប្តីនិងប្រពន្ធដើម្បីឱ្យការរៀបអាពាហ៍ពិពាហ៍បានត្រឹមត្រូវ វាមានដូចខាងក្រោម:

### លក្ខខ័ណ្ឌសាសនាឥស្លាមចំពោះប្រពន្ធ

1. ស្ត្រីជាអ្នកមូស្លីម ឬអះលីគីតាប(មានន័យថា នាងជាអ្នកកាន់សាសនាយូដា ឬសាសនាគ្រីស្ទ)មានជំនឿនិងសាសនារបស់នាង។ ក៏ប៉ុន្តែឥស្លាមបានជំរុញលើក្នុងការជ្រើសរើសស្ត្រីមូស្លីមដែលប្រកាន់ខ្ជាប់និងសាសនា ពីព្រោះនាងនិងក្លាយជាម្តាយអប់រំកូនៗរបស់អ្នក ជួយដល់អ្នកលើសចក្តីល្អនិងភាពត្រឹមត្រូវ ដូចដែររ៉សូលុលឡោះបានមានប្រសាសន៍ថា “ ចូរអ្នកត្រូវជ្រើសយកអ្នកដែលមានសាសនាអ្នកនិងមានភាពសុខសាន្ត” ។(អាល់ពូខរី ៤៨០២ មូស្លីម ១៤៦៦)

2 ២- ស្ត្រីដែលល្អបរិសុទ្ធ ហើយគេបានហាមឃាត់មិនឱ្យរៀបការជាមួយនិងស្ត្រីដែលប្រព្រឹត្តអំពើមិនគប្បី និងអំពើ ដូចដែរអល់ឡោះបានមានបន្ទូលថា “ហើយ(គេអនុញ្ញាតឱ្យពួកអ្នករៀបអាពាហ៍ពិពាហ៍ផងដែរ)ជាមួយស្ត្រីបរិសុទ្ធក្នុងចំណោមស្ត្រីដែលមានជំនឿនិងស្ត្រីបរិសុទ្ធនពួកដែលគេផ្តល់គម្ពីរឱ្យមុនពួកអ្នក”។(ជំពូក អាលមាអ៊ីដះ ឃ្លា ៥)

3 ៣-ស្ត្រីនោះមិនត្រូវជាម៉ុះរ៉មជាមួយគាត់ ដែលគេហាមឃាត់មិនឱ្យរៀបការជាមួយនិងពួកនាងជាដាច់ខាត ដូចដែរបានបញ្ជាក់ពីមុន។ ហើយមិនត្រូវរួមគ្នាជាមួយប្តីតែមួយរវាងស្ត្រីនិងបងប្អូនស្រីរបស់នាង ឬមីងខាងឪពុករបស់នាង ឬមីងខាងម្តាយរបស់នាង។.



## លក្ខខ័ណ្ឌសាសនាឥស្លាមចំពោះប្តី

គេដាក់លក្ខខ័ណ្ឌស្រមាប់ប្តីជាអ្នកមូស្លីម ហើយនៅក្នុងសាសនាឥស្លាមគេបានហាមឃាត់មិនឱ្យស្ត្រីមូស្លីមរៀបការជាមួយនិងបុរសគ្មានជំនឿឡើយ សូម្បីតែសាសនារបស់គេជាអះលីគីតាប ឬមិនមែនក៏ដោយ។ ហើយសាសនាឥស្លាមបានបញ្ជាក់អំពីការទទួលយកប្តីប្រសិនបើមានពីរលក្ខណៈខាងក្រោមនេះ:

- មាននស្ថិរភាពនៅក្នុងសាសនា
- សុជីវធម៌ល្អ

រ៉សូលុល្លោះបានមានប្រសាសន៍ថា “ប្រសិនបើមានគេមកស្តីដណ្តឹងអំពីពួកអ្នកនអ្នកដែលពួកអ្នកឯកភាពជាមួយសាសនា និងសុជីវធម៌ល្អរបស់គេ ចូរពួកអ្នករៀបការឱ្យគេចុះ” ។(អាតើតៀរមីហ្ស ១០៨៤ អ៊ិពនូមាយ៉ះ ១៩៦៧)

## > សិទ្ធិរបស់ប្ដីប្រពន្ធ

អល់ឡោះបានដាក់កាតព្វកិច្ចទាំងប្ដីនិងប្រពន្ធឱ្យមានសិទ្ធ និងឱ្យមានចំណង លើរាល់កិច្ចការដើម្បីអភិវឌ្ឍទំនាក់ទំនងអាពាហ៍ពិពាហ៍ និងការពារទៅលើវា។ ហើយទំនួលខុសត្រូវនៅលើគេទាំងពីរ ហើយសម្រាប់ប្ដីនិងប្រពន្ធមិនត្រូវទាមទារនូវអ្វីដែលគេគ្មានលទ្ធភាពនោះឡើយ។ អល់ឡោះបានមានបន្ទូលថា "ហើយពួកនាងមានសិទ្ធទៅលើប្ដីដូចសិទ្ធរបស់ប្ដីទៅលើពួកនាងដោយស្របច្បាប់ដែរ"។( ជំពូក អាលើហ្គាកេរ៉ះ ឃ្លា ២២៨) ចាំបាច់ក្នុងការអធ្យាស្រ័យ និងសប្បុរសដើម្បីទទួលបានភាពងាយស្រួលនៅក្នុងឆាកជីវិត និងក្លាយជាគ្រួសារដែលមានសុភមង្គល។

### សិទ្ធិរបស់ប្រពន្ធ

#### 1 ការផ្គត់ផ្គង់និងលំនៅដ្ឋាន

- ចាំបាច់សម្រាប់ប្ដីត្រូវផ្គត់ផ្គង់ទៅលើបពន្ធរបស់គេសម្រាប់ចំនីអាហារ ភេសជ្ជៈ សំលៀកបំពាក់ និងកិច្ចការរបស់នាង។ ត្រូវផ្ដល់ឱ្យនាងនូវលំនៅដ្ឋានដែលសមរម្យដើម្បីឱ្យនាងបានស្នាក់នៅក្នុងវា សូម្បីតែនាងជាអ្នកមានក៏ដោយ។.
- ចំនួននៃការផ្គត់ផ្គង់: ចំនួននៃការផ្គត់ផ្គង់ត្រូវផ្ដល់ឱ្យ សមរម្យទៅតាមចំណូលរបស់ប្ដីដោយមិនមានការខ្ជះខ្ជាយ និងខ្វះខាត។ ដូចអល់ឡោះបានមានបន្ទូលថា "អ្នកដែលមានទ្រព្យសម្បត្តិច្រើន ចូរឱ្យគេបរិច្ចាគឱ្យបានសមរម្យអំពីទ្រព្យសម្បត្តិរបស់គេ។ រីឯអ្នកណាដែលទ្រព្យសម្បត្តិរបស់គេមានកំណត់ ចូឱ្យគេបរិច្ចាគទៅតាមអ្វីដែលអល់ឡោះបានផ្ដល់ឱ្យគេ"។ (ជំពូក អាត់ឡាគ ឃ្លា ៧)
- ចាំបាច់ក្នុងការផ្គត់ផ្គង់នោះ: មិនត្រូវមានការរំលើសនិងបំបាក់មុខឡើយ។ផ្ទុយទៅវិញដូចដែរអល់ឡោះបានរៀបរាប់គឺដោយសមរម្យ មានន័យថាល្អប្រសើរ វាមិនមែនការលើកដំកើននេទ



> ចាំបាច់សម្រាប់បុរសត្រូវផ្គត់ផ្គងដល់ប្រពន្ធ និងកូនៗរបស់គាត់ដោយសមរម្យ

- ការផ្គត់ផ្គង់ទៅលើប្រពន្ធនិងគ្រួសារក្នុងសាសនាឥស្លាមវានឹងទទួលបានផលបុណ្យដ៏ធំធេង។ រ៉សូលុលឡោះបានមានប្រសាសន៍ថា “នៅពេលដែលអ្នកមូស្លីមម្នាក់ផ្គត់ផ្គង់ទ្រព្យសម្បត្តិទៅឱ្យគ្រួសាររបស់គាត់ ដោយរំពឹងចង់បានផលបុណ្យ ទ្រព្យនោះ ដូចជាទ្រព្យបរិច្ចាគទានសម្រាប់គាត់”។(អល់ពូខរី ៥០៣៦ មូស្លីម ១០០២)។ ហើយរ៉សូលុលឡោះក៏បានមានប្រសាសន៍ទៀតថា “ទ្រព្យសម្បត្តិណាមួយដែលអ្នកបរិច្ចាគដើម្បីអល់ឡោះ អ្នកនឹងត្រូវគេផ្តល់ផលបុណ្យឱ្យសូម្បីតែចំណីអាហារដែលអ្នកដាក់បញ្ចូលក្នុងមាត់ប្រពន្ធរបស់អ្នកក៏ដោយ”។(អាល់ពូខរី ៥៦ មូស្លីម ១៦២៨)។ ជនណាហើយដែលមិនផ្គត់ផ្គង់ទ្រព្យសម្បត្តិ ឬផ្តល់បន្តិចបន្តួចអំពីវា ដោយគេមានលទ្ធភាពក្នុងការផ្តល់វានោះ ពិតណាស់គេកំពុងប្រព្រឹត្តិអំពើបាបកម្មដ៏ធំធេងមួយ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា “គ្រប់គ្រាន់ហើយបាបកម្មរបស់បុគ្គលម្នាក់ នៅពេលដែលគាត់បោះបង់ចោលអ្នកដែលគាត់មានភារកិច្ចផ្គត់ផ្គង់អាហារដល់គេ”។ (អាពូដាវូទ ១៦៩២)

## 2 ការរស់នៅដោយមានសុភមង្គល

ការរស់នៅដោយមានសុភមង្គលមានន័យថា: សុជីវធម៌ល្អ សុភាពរាបសា សំដីទន់ភ្លន់ និងមានការទទួលខុសត្រូវរាល់កំហុសឆ្គង និងនិងប្រការធ្វេសប្រហែសផ្សេងៗ ដែលគ្មាននរណាម្នាក់អាចគេចផុតវាបាននោះទេ។ អល់ឡោះបានមានបន្ទូលថា “ ចូរពួកអ្នករួមរស់ជាមួយពួកនាងដោយគុណធម៌។ ប្រសិនបើពួកអ្នកមិនពេញចិត្តពួកនាង(ចូរអត់ធ្មត់) ជួនកាលការមិនពេញចិត្តរបស់ពួកអ្នកលើអ្វីមួយនោះ អល់ឡោះអាចនឹងធ្វើឱ្យវាល្អប្រសើរលើសលប់វិញ”។(អានណើសេ ១៩)

រ៉សូលុលឡោះបានមានប្រសាសន៍ថា “អ្នកមានជំនឿពេញលេញជាងគេ គឺអ្នកដែលមានសីលធម៌ល្អជាងគេ ហើយអ្នកដែលល្អជាងគេនៃពួកអ្នក គឺអ្នកដែលធ្វើល្អជាងគេចំពោះភរិយារបស់ពួកអ្នកដោយសីលធម៌ល្អ” ។( អាត់តៀរមីហ្ស៊ី ១១៦២)

រ៉សូលុលឡោះបានមានប្រសាសន៍ថា “អ្នកមានជំនឿពេញលេញជាងគេ គឺអ្នកដែលមានសីលធម៌ល្អជាងគេ និងមានភាពទន់ភ្លន់ជាងគេជាមួយនឹងភរិយារបស់ពួកអ្នក” ។( អាត់តៀរមីហ្ស៊ី ២៦១២ អះម៉ាត់ ២៤៦៧៧)

ហើយរ៉សូលុលឡោះបានមានប្រសាសន៍ថា “ អ្នកដែលល្អជាងគេនៃពួកអ្នក គឺអ្នកដែលធ្វើល្អជាងគេចំពោះភរិយារបស់ពួកអ្នក ហើយខ្ញុំជាអ្នកដែលធ្វើល្អជាងគេចំពោះភរិយារបស់ខ្ញុំ” ។( អាត់តៀរមីហ្ស៊ី ៣៨៩៥)

ហើយមានសហាហ្ពះម្នាក់បានសួររ៉សូលុលឡោះថា “ឱរ៉សូលុលឡោះ តើសិទ្ធិរបស់ប្រពន្ធមកលើពួកយើងមានអ្វីខ្លះ?” លោកតបថា “ អ្នកត្រូវផ្តល់ចំណីអាហារដល់នាង ពេលអ្នកទទួលទាន ត្រូវផ្តល់សំលៀកបំពាក់ដល់នាងនៅពេលអ្នកស្លៀកពាក់ មិនត្រូវវាយមុខ មិនត្រូវជេរប្រមាថ និងមិនត្រូវបែកនាងពីទីដេកណាទេឡើយ លើកលែងតែនៅក្នុងផ្ទះ”។(អាពូដាវូទ ២១៤២)



### 3 ការអត់ធ្មត់និងការអត់ឱន

ចាំបាច់ត្រូវតែសង្កេតមើលធម្មជាតិរបស់ស្ត្រីដែលមានភាពខុសគ្នាអំពីធម្មជាតិរបស់បុរស និងខិតខំឃ្លាំមើលអំពីជីវិតរស់នៅគ្រប់ផ្នែកទាំងអស់របស់នាង។ គ្មាននរណាម្នាក់គេចផុតពីកំហុសនោះទេ ស្រមាប់យើងត្រូវតែអត់ធ្មត់ និងពិចារណានៅក្នុងផ្លូវវិជ្ជមាន ហើយអល់ឡោះបានរំលឹកដល់ប្តីប្រពន្ធក្នុងការពិចារណានៅក្នុងផ្លូវវិជ្ជមាន។ ដោយអល់ឡោះបានមានបន្ទូលថា "ហើយចូរពួកអ្នកកុំភ្លេចនូវអំពើសប្បុរសរវាងពួកអ្នក"។(ជំពូក អាល់បាកើរ៉ះ ឃ្លា ២៣៧)។ ហើយរ៉សូលុលឡោះបានមានប្រសាសន៍ថា " អ្នកមានជំនឿមិនត្រូវស្អប់ភរិយារបស់គាត់ជាអ្នកមានជំនឿឡើយ ប្រសិនជាគាត់មិនពេញចិត្តនូវចរិកលក្ខណៈណាមួយរបស់នាង គាត់នឹងពេញចិត្តនូវចរិកលក្ខណៈផ្សេងៗទៀតរបស់នាង"។(មូស្លីម ១៤៦៩))

ហើយរ៉សូលុលឡោះបានបញ្ជាក់យ៉ាងច្បាស់លើការយកចិត្តទុកដាក់ចំពោះស្ត្រី និងការរួមរស់ជាមួយពួកនាងដោយអំពើល្អ និងសមរម្យ ជាមួយនឹងការប្រុងប្រយ័ត្នទៅលើធម្មជាតិរបស់ស្ត្រីទាំងផ្លូវកាយ និងផ្លូវចិត្ត ដែលមានភាពខុសគ្នាអំពីបុរស ហើយភាពខុសគ្នានេះនិងបំពេញទៅចំពោះគ្រួសារ ហើយចាំបាច់មិនត្រូវឱ្យភាពខុសគ្នានោះជាមូលហេតុនាំឱ្យមានការបែកបាក់ និងលែងលះឡើយ។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា "ចូរពួកអ្នកធ្វើល្អចំពោះស្ត្រី។ ការពិត ស្ត្រីត្រូវបានគេបង្កើតពីឆ្អឹងជំនី នាងមិនអាចស្ថិតនៅលើផ្លូវតែមួយស្រមាប់អ្នកទេ ប្រសិនបើអ្នករីករាយជាមួយនាងអ្នកអាចរីករាយជាមួយនាង ហើយនាងមានភាពវៀចវេរ ប្រសិនបើអ្នកពត់នាងអ្នកនឹងធ្វើឱ្យនាងបាក់ ហើយការបាក់នោះគឺការលែងលះ"។(អាល់ពូខរី ៣១៥៣ មូស្លីម ១៤៦៨))

### 4 ការស្នាក់នៅe

គប្បីស្រមាប់បុរសត្រូវដេកនៅជាមួយភរិយារបស់គាត់ ហើយចាំបាច់ស្រមាប់គាត់មិនត្រូវឱ្យរំលងលើសពីបួនថ្ងៃក្នុងចំណោមបួនថ្ងៃឡើយ ក៏ដូចជាត្រូវចាំបាច់ស្រមាប់គាត់ផងដែរបែងចែករវាងប្រពន្ធៗរបស់គាត់ ដោយយុត្តិធម៌ប្រសិនបើគាត់មានប្រពន្ធលើសពីមួយនាក់.

### 5 ការការពារនាងពីព្រោះនាងជាកិត្តិយស និងភាពថ្លៃថ្នូររបស់គាត់

នៅពេលដែលបុរសម្នាក់រៀបការជាមួយស្ត្រីម្នាក់នាងបានក្លាយទៅជា «កិត្តិយស» របស់គាត់ ចាំបាច់គាត់ត្រូវតែការពារ កិត្តិយសនេះទោះបីជាគាត់ត្រូវតែស្លាប់ក៏ដោយ។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា "អ្នកដែលត្រូវគេសម្លាប់ដោយសារការពារគ្រួសាររបស់គាត់គឺជាអ្នកពលី" ។( អាត់ទៀរមីហ្ស៊ី ១៤២១ អាពូទើវូទ ៤៧៧២)

### 6 មិនត្រូវបញ្ចេញរឿងសម្ងាត់រវាងប្តីប្រពន្ធឡើយ

មិនអនុញ្ញាតឱ្យបុរសនិយាយអំពីរឿងសម្ងាត់ប្រពន្ធរបស់គាត់និងអ្វីដែលកើតឡើងរវាងប្តីប្រពន្ធ ហើយផ្សព្វផ្សាយនៅក្នុងចំណោមមនុស្សឡើយ។ ដូចរ៉សូលុលឡោះបានមានប្រសាសន៍ថា "ពិតណាស់នៅក្នុងចំណោមមនុស្សដែលស្ថិតនៅក្នុងលំដាប់អាក្រក់បំផុតចំពោះអល់ឡោះនៅថ្ងៃបរលោកគឺ បុរសដែលរួមដំណេកជាមួយស្ត្រីជាភរិយារបស់គាត់ហើយនាងបានរួមដំណេកជាមួយគាត់ បន្ទាប់មកគាត់ផ្សព្វផ្សាយនូវបការអាថ៌កំបាំងរបស់នាង"។(មូស្លីម ១៤៣៧)

### 7 មិនត្រូវរំលោភបំពានទៅលើស្ត្រីឡើយ

សាសនាឥស្លាមបានដាក់ក្បួនច្បាប់មួយចំនួន ដើម្បីដោះស្រាយបញ្ហាគ្រួសារក្នុងនោះរួមមានដូចខាងក្រោម:

- គួរតែដោះស្រាយដោយការពិភាក្សា និងការផ្តល់ដំបូន្មាន និងការប្រៀនប្រដៅដើម្បីកែកំហុស.
- ប្តីអាចឈប់និយាយទៅកាន់នាង, ប៉ុន្តែមិនត្រូវលើសពីបីថ្ងៃឡើយ បន្ទាប់មកគាត់អាចបោះបង់ចោលការរួមដំណេកប៉ុន្តែដោយមិនចាកចេញពីផ្ទះឡើយ.
- អាអ៊ីសះបាននិយាយថា "រ៉សូលុលឡោះមិនដែលវាយស្ត្រី ឬខ្ញុំបម្រើណាម្នាក់ឡើយ លើកលែងតែពេលប្រយុទ្ធក្នុងផ្លូវអល់ឡោះ"។

## 8 ការបង្រៀន និងផ្តល់ដំបូន្មានដល់នាង

ស្រមាប់បុរស្រតូវបង្គាប់ប្រើ និងហាមឃាត់ភរិយ្យារបស់គាត់ ត្រូវប្រុងប្រយ័ត្នទៅលើអ្វីដែលតភ្ជាប់ពួកគេទៅកាន់សួនមេនារម្យ និងការពារពួកគេពីភ្លើងឋាននរក តាមការជួយស្រម្រួលក្នុងការប្រព្រឹត្តបទបញ្ញានិងជំរុញនាងទៅលើវា និងរារាំងមិនឱ្យប្រព្រឹត្តបុការរេគហាមឃាត់និងង្វេគចេចញឱ្យឆ្ងាយអំពីវា។ ហើយស្រមាប់ស្រ្តីក៏ដូច្នោះដែរ ត្រូវយកចិត្តទុកដាក់លើការផ្តល់ដំបូន្មានប្តីរបស់នាង និងចង្អុលបង្ហាញគាត់ទៅរកផ្លូវដ៏ល្អ និងអប់រំកូនៗអំពីការអប់រំដែលត្រឹម្រត្ូវ។ អល់ឡោះបានមានបន្ទូលថា “ឱបណ្តាលអ្នកជឿមានជំនឿ! ចូរពួកអ្នកថែរក្សាខ្លួនប្រាណរបស់ពួកអ្នក និងក្រុម្រគួសាររបស់ពួកអ្នកឱ្យផុតពីភ្លើងនរក ដែលវត្ថុស្រមាប់ដុតវានោះ គឺមនុស្សនិងដុំថ្ម”។(ជំពូក អាត់តះរីម ឃ្លា ៦)។ ហើយរសូលុលលោះបានមានប្រសាសន៍ថា “ហើយបុរសជាអ្នកគ្របគ្រងលើគ្រួសាររបស់គាត់ ហើយទទួលខុស្រតូវចំពោះអ្វីដែលគាត់គ្រប់គ្រងនោះ”។(អាល់ពូខរី ២៤១៦ មូស្លីម ១៨២៩)

## 9 ការប្រកាន់ខ្ជាប់នូវលក្ខខណ្ឌរបស់ប្រពន្ធ

ប្រសិនបើស្ត្រីម្នាក់បានដាក់លក្ខខណ្ឌនិងខ្លួនរបស់នាងលើកិច្ចការដែលគេអនុញ្ញាតក្នុងពេលរៀបអាពាហ៍ពិពាហ៍ដូចជាប្រភេទពិសេសនៃលំនៅដ្ឋាន ការផ្គត់ផ្គង់ និងឱ្យប្តីមើលនាងចាំបាច់ស្រមាប់គាត់ត្រូវតែបំពេញវានោះ ហើយនេះជាលក្ខខណ្ឌយ៉ាងច្បាស់លាស់ក្នុងការចាំបាច់បំពេញវា និងប្រកាន់ខ្ជាប់នឹងវា។ ពីព្រោះការរៀបអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធវាជាកិច្ចសន្យា និងកេរ៍មរតកដ៏អស្ចារ្យ។ ដូចរសូលុលលោះបានមានប្រសាសន៍ថា “អ្វីដែលពួកអ្នកស្ទាក់សមបំពេញវាបំផុតអំពីលក្ខខណ្ឌនោះ គឺអ្វីដែលគេអនុញ្ញាតវាឱ្យពួកអ្នកក្នុងការទំនាក់ទំនងជាមួយការរៀបអាពាហ៍ពិពាហ៍”។(អាល់ពូខរី ៤៨៥៦ មូស្លីម ១៤១៨)



> ចាំបាច់សម្រាប់ប្តីត្រូវប្រកាន់ខ្ជាប់និងលក្ខខណ្ឌរបស់ប្រពន្ធដែលបានរៀបរាប់នៅក្នុងកិច្ចសន្យាអាពាហ៍ពិពាហ៍

## សិទ្ធិរបស់ប្តី

### 1 ចាំបាច់ត្រូវគោរពដោយសមរម្យ

អល់ឡោះបានផ្តល់ឱ្យបុរសជាអ្នកគ្រប់គ្រងលើស្ត្រី មានន័យថាទទួលខុសត្រូវអំពីកិច្ចការរបស់នាង ការចង្អុលបង្ហាញនាង និងការថែរក្សានាង។ ដូចជាអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវលើអ្នកក្នុងបន្ទុករបស់គេ។ ហើយអ្វីដែលអល់ឡោះបានដាក់ដោយឡែកសម្រាប់បុរសអំពីការបញ្ជាក់ដោយឡែក និងលក្ខណៈពិសេស។ ហើយនិងអ្វីដែលជាកាតព្វកិច្ចអំពីការតព្វកិច្ចហិរញ្ញវត្ថុ។ អល់ឡោះបានមានបន្ទូលថា "បុរសទាំងឡាយជាអ្នកគ្រប់គ្រងលើពួកស្ត្រីដោយសារអល់ឡោះបានលើកតម្កើងពួកគេឱ្យមានលក្ខណៈពិសេសជាងគ្នា និងដោយសារតែបុរសមានភារកិច្ចផ្គត់ផ្គង់ទ្រព្យសម្បត្តិរបស់ពួកគេ(ដល់ប្រពន្ធ)"។(ជំពូក អាន់នីសាក់ ឃ្លា ៣៤)

### 2 ផ្តល់លទ្ធភាពឱ្យប្តីដើម្បីទទួលបានភាពរីករាយ

សិទ្ធិរបស់ប្តីទៅលើបពន្ធគឺការផ្តល់លទ្ធភាពឱ្យគាត់ដើម្បីទទួលបានភាពរីករាយ និងការរួមដំណេក ហើយគប្បីសម្រាប់នាងតុបតែងខ្លួននិងរៀបចំខ្លួនសម្រាប់គាត់។ ប្រសិនបើបពន្ធបដិសេធអំពីការសុំដីប្តីរបស់នាងក្នុងការរួមដំណេក នាងនិងធ្លាក់ក្នុងប្រការហាមឃាត់ និងប្រព្រឹត្តអំពើបាបធំធេង។ លុះត្រាតែមានការលើកលែងដែលជាការលើកលែងស្របច្បាប់ដូចជា មករដូវ បួស(ហ្វារឌូ) មានជំងឺ និងអ្វីដែលស្រដៀងនិងនោះ។.

រ៉សូលុលឡោះបានមានបន្ទូលថា "នៅពេលដែលបុរសបានហៅប្រពន្ធរបស់គាត់មករួមដំណេកជាមួយគាត់ ហើយនាងបានបដិសេធ ហើយគាត់គុំគួនទាំងការខឹងទៅចំពោះនាង ម៉ាឡាអ៊ីកាត់នឹងដាក់បណ្តាសសារឱ្យនាងរហូតដល់ភ្លឺ"។(អាល់ពូខរី ៣០៦៥ មូស្លីម ១៤៣៦)

### 3 ស្ត្រីមិនត្រូវអនុញ្ញាតឱ្យអ្នកដែលប្តីមិនចូលចិត្តចូលក្នុងផ្ទះឡើយ

ក្នុងចំណោមសិទ្ធិរបស់ប្តីលើបពន្ធរបស់គាត់គឺមិនត្រូវឱ្យអ្នកដែលគាត់មិនពេញចិត្តចូលទៅក្នុងផ្ទះរបស់គាត់ឡើយ រ៉សូលុលឡោះបានមានប្រសាសន៍ថា "ស្ត្រីមិនអាចបួសស៊ូណិតបានឡើយ ខណៈពេលដែលប្តីរបស់នាងនៅមានវត្តមាននៅជាមួយនាងនោះ ហើយនាងមិនត្រូវអនុញ្ញាតឱ្យអ្នកណាម្នាក់ចូលផ្ទះប្តីរបស់នាងឡើយលើកលែងតែមានការអនុញ្ញាតអំពីប្តីរបស់នាង"។(អាល់ពូខរី ៤៨៩៩)

### 4 ស្ត្រីមិនអាចចេញពីផ្ទះទេលើកលែងតែមានការអនុញ្ញាតពីប្តីរបស់នាង

O ក្នុងចំណោមសិទ្ធិរបស់ប្តីលើបពន្ធរបស់គាត់គឺនាងមិនអាចចេញពីផ្ទះឡើយលើកលែងតែមានការអនុញ្ញាតពីប្តីរបស់នាង ទោះបីជាការអនុញ្ញាតដោយលក្ខណៈក្នុងការចេញទៅកន្លែងណាមួយច្បាស់លាស់ ឬការអនុញ្ញាតទូទៅក្នុងការចេញពីផ្ទះទៅកន្លែងធ្វើការរបស់នាង ឬទៅបំពេញកិច្ចការរបស់នាងក៏ដោយ។

### 5 ការបម្រើរបស់បពន្ធចំពោះប្តី

គប្បីសម្រាប់បពន្ធត្រូវបម្រើប្តីរបស់នាងដោយសមរម្យក្នុងការចំអិនម្ហូប និងកិច្ចការផ្ទះទាំងអស់។

## > ការលែងលះ

> សាសនាឥស្លាមបានជំរុញឱ្យបន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ ហើយបានបញ្ជាក់យ៉ាងច្បាស់ទៅលើវានោះ ក៏ប៉ុន្តែគេបានចែងនៅក្នុងច្បាប់អ្វីដែលធ្វើឱ្យមានរបៀបរៀបរយលើដំណើរការលែងលះ នៅពេលណាដែលប្តីប្រពន្ធទាំងពីរត្រូវការវា។




សាសនាឥស្លាមបានជំរុញឱ្យស្ថិតនៅលើកិច្ចសន្យាអាពាហ៍ពិពាហ៍ជានិច្ច ហើយបន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ឱ្យនៅមានជានិច្ចរវាងប្តីប្រពន្ធទាំងពីររហូតដល់ស្លាប់រវាងពួកគេទាំងពីរ។ ហើយអល់ឡោះបានឱ្យឈ្មោះអាពាហ៍ពិពាហ៍ថាសម្ពន្ធមេត្រីដ៏មហិមា ហើយសាសនាឥស្លាមមិនអនុញ្ញាតឱ្យកំណត់ពេលបញ្ចប់អាពាហ៍ពិពាហ៍នោះឡើយ។

ក៏ប៉ុន្តែសាសនាឥស្លាមបានជំរុញឱ្យធ្វើដូច្នេះដើម្បីគ្រប់គ្រង។ ពិតណាស់វាជាច្បាប់ស្រមាប់មនុស្សដើម្បីរស់នៅលើផែនដីនេះ។ ស្រមាប់ពួកគេមានលក្ខណៈពិសេសរបស់ពួកគេ និងលក្ខណៈធម្មជាតិរបស់ពួកគេ ដូច្នេះហើយបានជាគេដាក់ច្បាប់លើពួកគេនូវរបៀបជំរះអំពីកិច្ចសន្យានេះ ប្រសិនបើមានការពិបាកក្នុងការរស់នៅ គ្មានផ្លូវជ្រើសរើស និងបរាជ័យរាល់វិធីសាស្ត្រក្នុងការកែលអរ គឺត្រូវតែអនុវត្តទៅតាមភាពជាក់ស្តែង និងខ័ណ្ឌចែករវាងពួកគេទាំងបុរស និងស្ត្រី។

អ្វីដែលកើតឡើងច្រើនរវាងប្តីប្រពន្ធគឺមកពីមូលហេតុ ការមិនពេញចិត្ត និងបញ្ហាដែលជាហេតុធ្វើឱ្យការលែងលះជាប្រការចាំបាច់បំផុត និងជាវិធីសាស្ត្រច្បាស់លាស់ដើម្បីទទួលបានភាពល្អប្រសើរពិត និងមានស្ថេរភាពនៅក្នុងគ្រួសារ និងសង្គមរវាងពួកគេទាំងពីរ។ ពីព្រោះថាចំណងអាពាហ៍ពិពាហ៍របៀបនេះ វាមិនបានផ្តល់នូវអត្ថន័យពិតប្រាកដរបស់វានោះទេ ហើយការបែកបាក់រវាងប្តីប្រពន្ធ( ដែលមានសភាពបបនេះ )បានក្លាយជាប្រការដែលនាំឱ្យមានការខូចខាតតិចជាងការរស់នៅជាមួយគ្នា។

ហេតុនេះហើយបានជាគេអនុញ្ញាតឱ្យមានការលែងលះដែលជាវិធីសាស្ត្រដើម្បីចាកចេញពីស្ថានភាពនេះ។ ហើយក៏ផ្លាស់ប្តូររាល់ពួកគេទាំងពីរនូវការរៀបការផ្សេងទៀត សង្ឃឹមថានិងទទួលបានជាមួយនិងអ្នកថ្មីនូវអ្វីដែលអ្នកមុនមិនមាន។ បញ្ជាក់យ៉ាងច្បាស់និងបន្លឺអល់ឡោះថា “ប៉ុន្តែបើសិនបើគេទាំងពីរបែកបាក់គ្នា(លែងលះគ្នា)វិញនោះ អល់ឡោះនឹងផ្តត់ផ្គង់ដល់គេម្នាក់ៗនូវលាភសក្ការៈដ៏ទូលំទូលាយរបស់ទ្រង់។អល់ឡោះមហាទូលំទូលាយមហាគតិបណ្ឌិត”។(ជំពូក អាន់នីសាក ឃ្លា ១៣០)

### ក៏ប៉ុន្តែគេបានដាក់ច្បាប់និងវិន័យជាច្រើននៅដើម្បីគ្រប់គ្រងលើវា ហើយក្នុងនោះមានដូចជា

- ប្រភពដើមនៃការលែងលះគឺនៅក្នុងដៃរបស់បុរស មិនមែននៅក្នុងដៃស្ត្រីទេ.
- ស្រមាប់ស្ត្រីនៅពេលដែលនាងមិនអាចរស់នៅជាមួយនឹងប្តីរបស់នាង ហើយគាត់មិនព្រមលែងលះនាង នាងអាចស្នើសុំលែងលះពីចៅក្រម ហើយចៅក្រមអាចលែងលះឱ្យនាងប្រសិនបើហេតុផលសមរម្យ។.
- គេអនុញ្ញាតឱ្យត្រឡប់ទៅរកស្ត្រីវិញបានបន្ទាប់ពីការលែងលះពីរដង តែបើសិនជាគេលែងលះនាងលើកទីបី គាត់មិនអាចរៀបការជាមួយនាងបានទេរហូតទាល់តែនាងរៀបការជាមួយបុរសផ្សេងទៀតរៀបការពេញលេញ។ហើយការលែងលះតាមច្បាប់គឺបុរសម្នាក់គាត់លែងលះប្រពន្ធរបស់គាត់នៅក្នុងពេលជ្រះស្អាតដោយគាត់មិនបានរួមដំណេកជាមួយនាង។

## > សិទ្ធិរបស់ឪពុកម្តាយ



គេចាត់ទុកភាពកតញ្ញូចំពោះឪពុកម្តាយ និងធ្វើល្អទៅចំពោះគាត់ទាំងពីរជាកិច្ចការដែលល្អប្រសើរបំផុត ហើយទទួលបានផលបុណ្យច្រើនអំពីអល់ឡោះ ហើយពិតណាស់អល់ឡោះបានរៀបរាប់វាភ្ជាប់ជាមួយនិងការគោរពសក្ការៈទៅចំពោះទ្រង់ និងជំនឿទៅចំពោះទ្រង់។

ហើយបានចាត់ទុកភាពកតញ្ញូ និងការធ្វើល្អទៅចំពោះគាត់ទាំងពីរជាមូលហេតុដ៏ចំបងក្នុងការចូលឋានសួគ៌ រ៉សូលុល្លោះបានមានប្រសាសន៍ថា "ឪពុកម្តាយ គឺជាទ្វារឋានសួគ៌ដែលល្អជាងគេ ហេតុនេះ ប្រសិនបើអ្នកចង់បោះបង់ទ្វារនោះ ឬថែរក្សាវា គឺអាស្រ័យលើអ្នក"។(អាត់តៀរមីហ្ស៊ី ១៩០០)

• ប្រការគ្រោះថ្នាក់ពីភាពអកតញ្ញូចំពោះឪពុកម្តាយ និងធ្វើអាក្រក់ទៅលើគាត់

Aអំពើបាបកម្មដ៏ធំបំផុតដែលច្បាប់បានឯកភាពឱ្យហាមឃាត់វា និងឱ្យប្រុងប្រយ័ត្នអំពីវានោះគឺការធ្វើអាក្រក់ជាមួយឪពុកម្តាយ។ ដូច រ៉សូលុល្លោះបានមានប្រសាសន៍ទៅកាន់ហ៍សហាពះថា "តើពួកអ្នកចង់ឱ្យខ្ញុំប្រាប់ពីបាបកម្មដ៏ធំបំផុតឬទេ?ពួកគេបានឆ្លើយថា : ឱរ៉សូលុល្លោះពួកយើងចង់ លោកបានមានប្រសាសន៍ថា "គឺការធ្វើស្ហ៊ីរិកចំពោះអល់ឡោះ និងការធ្វើអំពើអកតញ្ញូនឹងឪពុកម្តាយ"។(អាល់ពូខរី ៥៩១៨)

• ការគោរពតាមគាត់ទាំងពីរក្រៅពីប្រការដែលប្រឆាំងចំពោះអល់ឡោះ

ចាំបាច់ត្រូវគោរពតាមគាត់ទាំងពីររាល់ប្រការទាំងឡាយណាដែលគាត់ទាំងពីរបានបញ្ជាឱ្យប្រើលើកែលែងតែវាជាប្រការដែលប្រឆាំងចំពោះអល់ឡោះ មិនត្រូវគោរពតាមគាត់ទាំងពីរឡើយ ពីព្

រោះគ្មានការគោរពតាមអ្វីដែលគេបង្កើតឡើយ ក្នុងរបការដែលប្រឆាំងនឹងអ្នកបង្កើតនោះ។ អល់ឡោះបានមានបន្ទូលថា “ហើយយើងបានបង្គាប់មនុស្សលោកឱ្យធ្វើល្អចំពោះឪពុកម្ដាយរបស់គេ ក្រែងប្រសិនបើគាត់ទាំងពីរបង្ខំអ្នកឱ្យធ្វើស្ហ៊ីរិកចំពោះយើងនូវអ្វីដែលអ្នកគ្មានចំណេះដឹងនឹងវាទេនោះ ចូរអ្នកកុំប្រតិបត្តិតាមពួកគាត់ទាំងពីរឱ្យសោះ”។(ជំពូក អាល់អាំងកាពូត ឃ្លា ៨)

- ## ការធ្វើល្អជាមួយគាត់ទាំងពីរ ជាពិសេសក្នុងពេលគាត់ទាំងពីរចាស់ជរា

អល់ឡោះបានមានបន្ទូលថា“ហើយម្ចាស់របស់អ្នកបានបញ្ជាថា: ពួកអ្នកមិនត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ ហើយត្រូវតែធ្វើល្អទៅចំពោះឪពុកម្ដាយ។ ប្រសិនបើម្នាក់ក្នុងគាត់ទាំងពីរ ឬគាត់ទាំងពីរមានភាពចាស់ជរានៅជាមួយអ្នក ចូរអ្នកកុំនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសំដីមិនសមរម្យ ឬគំហកដាក់គាត់ទាំងពីរឱ្យសោះ។ តែអ្នកត្រូវនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសំដីណាដែលទន់ភ្លន់បំផុត”។(ជំពូក អាល់អ៊ីសរ៉ក ឃ្លា ២៣)

អល់ឡោះបានប្រាប់ថាពិតណាស់គាត់បានដាក់កាតព្វកិច្ច និងការចាំបាច់លើមនុស្សឱ្យគោរពតាមឪពុកម្ដាយរបស់គេ ហើយមិនត្រូវប្រើពាក្យសំដីមិនសមរម្យ ឬគំហកដាក់គាត់ទាំងពីរឡើយ ជាពិសេសក្រោយពេលគាត់ទាំងពីរចាស់ជរា និងទន់ខ្សោយ។ សូម្បីតែវានោះគ្រាន់តែជាកាយវិការមិនសមរម្យដោយមិននិយាយក៏ដោយ។

- ## ឪពុកម្ដាយជាអ្នកគ្មានជំនឿ



ចាំបាច់ស្រម្មាប់អ្នកមូស្លីមត្រូវកតញ្ញូចំពោះឪពុកម្ដាយ និងគោរពតាមគាត់ និងធ្វើល្អជាមួយគាត់សូម្បីតែគាត់ជាអ្នកគ្មានជំនឿក៏ដោយ។ អល់ឡោះបានមានបន្ទូលថា “ហើយប្រសិនបើគាត់ទាំងពីរ(ឪពុកម្ដាយ) ព្យាយាមជំរុញឱ្យអ្នកធ្វើស្ហ៊ីរិកជាមួយយើង(អល់ឡោះ) នូវអ្វីដែលអ្នកមិនបានដឹងវាទេនោះ ចូរអ្នកកុំស្ដាប់បង្គាប់ពួកគាត់ទាំងពីរឱ្យសោះ។ តែអ្នកកតញ្ញូចំពោះគាត់ទាំងពីរនៅក្នុងលោកិយនេះដោយអំពើល្អ”។(ជំពូក លុកម៉ាន ឃ្លា ១៥)

# > សិទ្ធិរបស់កូនៗ



• ការជ្រើសរើសភរិយាដ៏ល្អម្នាក់ដើម្បីក្លាយជាម្ដាយដ៏ល្អម្នាក់ គឺជាអំណោយដ៏ល្អប្រពៃដែលឪពុកផ្ដល់ជូនឱ្យកូនៗរបស់គាត់។.

• ផ្ដល់ឈ្មោះដល់ពួកគេនូវឈ្មោះដែលល្អស្រស់ស្អាតពីព្រោះវានឹងក្លាយជាសញ្ញាយ៉ាងជាក់លាក់សម្រាប់កូនៗ.

• ត្រូវអប់រំពួកគេឱ្យបានល្អនិងបង្រៀនពួកគេអំពីគោលគ្រឹះនៃសាសនា និងធ្វើឱ្យពួកគេស្រលាញ់ទៅចំពោះរ៉ាសូលុលលោះបានមានប្រសាសន៍ថា "ពួកអ្នកគ្រប់ៗគ្នាសុទ្ធតែជាអ្នកគ្រប់គ្រង ហើយនឹងត្រូវទទួលខុសត្រូវនូវអ្វីដែលគេគ្រប់គ្រងនោះ។ មេដឹកនាំ គឺជាអ្នកគ្រប់គ្រងលើមនុស្ស ហើយគាត់ត្រូវទទួលខុសត្រូវចំពោះពួកគេ។ បុរស គឺជាអ្នកគ្រប់គ្រងលើក្រុមគ្រួសាររបស់គាត់ ហើយគាត់ជាអ្នកទទួលខុសត្រូវចំពោះពួកគេ។ ស្ត្រី គឺជាអ្នកគ្រប់គ្រងលើផ្ទះប្ដីរបស់នាង និងកូនៗរបស់គាត់ ហើយនាងជាអ្នកទទួលខុសត្រូវចំពោះពួកគេ។ ហេតុនេះ ពួកអ្នកទាំងអស់គ្នា ជាអ្នកគ្រប់គ្រង ហើយពួកអ្នកទាំងអស់គ្នានឹងត្រូវទទួលខុសត្រូវចំពោះអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់អ្នក"។(អាល់ពូខរី ២៤១៦ មូស្លីម ១៨២៩)។ ឪពុកម្ដាយត្រូវចាប់ផ្ដើមបង្រៀនកូនៗរបស់គាត់ទៅលើប្រការណាដែលសំខាន់ ហើយប្រការសំខាន់ត្រូវចាប់ផ្ដើមអប់រំពួកគេអំពីគោលជំនឿដ៏ត្រឹមត្រូវជ្រះស្អាតអំពីស្ទីរិក និងប្រការបង្កើតថ្មី បន្ទាប់មកបង្រៀនអំពីការគោរពសក្ការៈជាពិសេសការប្រតិបត្តិសឡាត បន្ទាប់មកបង្រៀន និងអប់រំពួកគេអំពីសុជីវធម៌ និងសីលធម៌ដែលគេកោតសរសើរ និងរាល់អ្វីដែលមានតែល និងល្អប្រសើរ ហើយនេះនៅក្នុងគោលបំណងប្រតិបត្តិកិច្ចការទៅចំពោះអល់ឡោះ។

• ការផ្ដត់ផ្គង់: ចាំបាច់ស្រមាប់ឪពុកត្រូវផ្ដត់ផ្គង់បាក់ដល់កូនៗទាំងប្រុសនិងស្រី ហើយមិនអនុញ្ញាតឱ្យគាត់កាត់បន្ថយ ឬបោះបង់ចោលឡើយ។ ប៉ុន្តែចាំបាច់ឱ្យគាត់ប្រតិបត្តិលើផ្លូវដែលត្រឹមត្រូវទៅតាមសមត្ថភាព និងលទ្ធភាពរបស់គាត់។ រ៉ាសូលុលលោះបានមានប្រសាសន៍ថា "គ្រប់គ្រាន់ហើយបាបកម្មរបស់បុគ្គលម្នាក់ នៅពេលដែលគាត់បោះបង់ចោលអ្នកដែលគាត់មានភារកិច្ចផ្ដត់ផ្គង់អាហារដល់គេ"។(អាពូទៅវូទ ១៦៩២)។ ហើយរ៉ាសូលុលលោះបានមានប្រសាសន៍ចំពោះការគ្រប់គ្រង និងការផ្ដត់ផ្គង់ លើកូនស្រីៗដោយលើកថា "បុគ្គលណាដែលមាននៅក្រោមការគ្រប់គ្រងរបស់គាត់ កូនស្រីៗ ចូរគាត់អប់រំពួកនាងឱ្យបានល្អ ពួកនាងនឹងក្លាយជារណាំងឃាំងគាត់ពីភ្លើងឋាននរក"។(អាល់ពូខរី ៥៦៤៩ មូស្លីម ២៦២៩)

• ភាពយុត្តិធម៌រវាងកូនៗទាំងប្រុស និងស្រី ដូចរ៉ាសូលុលលោះបានមានប្រសាសន៍ថា "ចូរពួកអ្នកកោតខ្លាចចុះទៅចំពោះអល់ឡោះ និងផ្ដល់ភាពយុត្តិធម៌រវាងកូនៗរបស់ពួកអ្នក"។(អាល់ពូខរី ២៤៤៧ មូស្លីម ១៦២៣)។ មិនអនុញ្ញាតឱ្យលើកតម្កើងស្ត្រីទៅលើបុរស ក៏ដូចជាមិនអនុញ្ញាតឱ្យលើកតម្កើងបុរសលើស្ត្រីដែរ ពីព្រោះធ្វើដូច្នោះនឹងនាំឱ្យមានវិនាសកម្ម អល់ឡោះដឹងអំពីវាច្បាស់បំផុត។



# សីលធម៌របស់អ្នកនៅក្នុងសាសនាឥស្លាម



# 11

សីលធម៌នៅក្នុងសាសនាឥស្លាមមិនមែនជាប្រការល្អប្រណិតឬការបំពេញអ្វីមួយទេ, ប៉ុន្តែជាផ្នែកមួយនៃការសហការគ្នាមួយដែលភ្ជាប់ទៅនឹងសាសនានៅក្នុងទិដ្ឋភាពទាំងអស់ដែលនៅជិតខ្លួនរបស់វា, ស្រមាប់សីលធម៌នៅក្នុងសាសនាឥស្លាមវាមានតំលៃ ឧត្តុងឧត្តម និងឋានៈខ្ពស់បំផុត។ ហើយទាំងអស់នោះត្រូវបានបង្ហាញនៅក្នុងបទបញ្ញត្តិនិងច្បាប់ទាំងអស់នៃសាសនាឥស្លាម ហើយគេបានតែងតាំងព្យាការីមូហាំម៉ាត់ដើម្បីបំពេញសីលធម៌ដ៏ល្អឥតខ្ចោះ។

## មាតិកាជំពូក

### ឋានៈរបស់សីលធម៌ក្នុងសាសនាឥស្លាម

- វាគឺជាផ្នែកមួយនៃគោលបំណងសំខាន់បំផុតនៃការតែងតាំងព្យាការី
- សីលធម៌ជាផ្នែកមួយយ៉ាងជិតស្និទ្ធនៃជំនឿនិងការជឿជាក់
- សីលធម៌មានទំនាក់ទំនងជាមួយនឹងការគោរពបូជាគ្រប់ប្រភេទ
- គុណសម្បត្តិដ៏អស្ចារ្យ និងផលបុណ្យយ៉ាងធំធេងដែលអល់ឡោះបានរៀបចំស្រមាប់អ្នកដែលមានសីលធម៌ល្អ

### លក្ខណៈពិសេសនៃសីលធម៌ក្នុងសាសនាឥស្លាម

- សីលធម៌ល្អគឺមិនមែនស្រមាប់តែប្រភេទមនុស្សមួយចំនួននោះទេ
- សីលធម៌ល្អគឺមិនមែនស្រមាប់តែមនុស្សនោះទេ
- សីលធម៌ល្អមានគ្រប់វិស័យទាំងអស់នៃជីវិត
- សីលធម៌ល្អមានគ្រប់ករណីទាំងអស់

### រូបភាពក្នុងសម័យណាពីរស់នៅ

- ឱនលំទោន
- មេត្តាករុណា
- យុត្តិធម៌
- សប្បុរសធម៌និងមានចិត្តទូលំទូលាយ

## ឋានៈរបស់សីលធម៌ក្នុងសាសនាឥស្លាម

1 វាគឺជាផ្នែកមួយនៃគោលបំណងសំខាន់បំផុតនៃការតែងតាំងព្យាការីមកដល់មនុស្ស អល់ឡោះបានមានបន្ទូលថា(ទ្រង់គឺជាអ្នកដែលបានចាត់តាំងអ្នកនាំសារម្នាក់អំពីពួកគេក្នុងចំណោមពួកអវិជ្ជា ដោយគាត់សូត្រអាយ៉ាត់ៗរបស់ទ្រង់ឱ្យពួកគេស្តាប់និងសំអាតពួកគេ(អំពីបុរការស្ទីរិក)។(ស៊ូរ៉ោះជុមូអះ ឃ្លាទី២)
អល់ឡោះបានផ្តល់ឱ្យអ្នកដែលមានជំនឿដោយតែងតាំងអ្នកនាំសារម្នាក់ដើម្បីបង្រៀនគួរអានដល់ពួកគេនិងសំអាតពួកគេ(អំពើបការស្ទីរិក)។ការសំអាតនោះមានន័យថា ជម្រះចិត្តពួកគេអំពើបការស្ទីរិក និងសីលធម៌អាក្រក់ដូចជាការនិយមជុលនិងការឈ្នានីស ហើយនិងជម្រះពាក្យសំដី និងទង្វើអសីលធម៌និងទំលាប់អាក្រក់។ ព្យាការីបានមានប្រសាសន៍យ៉ាងច្បាស់ថា(ពិត្រប្រាកដណាស់គេបានបង្កើតខ្ញុំមកដើម្បីបំពេញសីលធម៌ដ៏ល្អឥតខ្ចោះ)។(អាល់ពហាគី ២១៣០១)មួយក្នុងចំណោមហេតុផលចម្បងសម្រាប់ការតែងតាំងនេះគឺការលើកតម្កើងនិងភាពខ្ពង់ខ្ពស់នៃសីលធម៌បុគ្គលនិងសង្គម។.




> ការបំពេញសីលធម៌ល្អគឺជាគោលដៅដ៏ចម្បងក្នុងការតែងតាំងណាពីមូហាំម៉ាត់

2 សីលធម៌ជាផ្នែកមួយយ៉ាងជិតស្និទ្ធនៃជំនឿនិងការជឿជាក់

នៅពេលដែលគេសួររ៉សូលុលលោះថាៈ តើអ្នកដែលមានជំនឿបែបណាដែលល្អជាងគេនោះ?គាត់ក៏បានមានប្រសាសន៍ថា(អ្នកដែលមានសីលធម៌ល្អជាងគេ)។(អាត់តៀតមីស៊ុ១១៦២ និងអាប៊ូឌើវូត៤៦៨២)

អល់ឡោះបានអោយឈ្មោះជំនឿថាជាអំពើល្អ ដោយអល់ឡោះបានមានបន្ទូលថា(ការត្រឹមង់មុខរបស់ពួកអ្នកឆ្ពោះទៅទិសខាងលិចនោះមិនចាត់ទុកជាអំពើល្អឡើយ។ប៉ុន្តែអំពើល្អនោះគឺអ្នកណាដែលមានជំនឿលើអល់ឡោះ និងថ្ងៃបរលោកនិងម៉ាឡាអ៊ីកាត់និងគម្ពីទាំងឡាយនិងបណ្តាណាពី)។(ស៊ូរ៉ោះ បើគរ៉ស់ ឃ្លា១៧៧) អំពើល្អគឺជាពាក្យទូលំទូលាយដែលគ្របដណ្តប់ក្រុមការល្អគ្រប់ប្រភេទអំពីសីលធម៌ ពាក្យសំដី និងកាយវិការ។ដូច្នេះហើយបានជារ៉សូលុលលោះមានប្រសាសន៍ថា(ទង្វើបុណ្យគឺសីលធម៌ល្អ)។(ម៉ូស្លីម ២៥៥៣)

ហើយវាបានបង្ហាញយ៉ាងច្បាស់នៅក្នុងពាក្យសម្តីរ៉សូលុលលោះថា(ជំនឿមានច្រើនជាង៦០ផ្នែក។លំដាប់ខ្ពស់បំផុតនោះគឺការពោលពាក្យ( لا إله إلا الله )គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវមានតែអល់ឡោះ ហើយលំដាប់ក្រោមបំផុតគឺការយកអ្វីចេញពីផ្លូវដែលបង្ករបញ្ហាដល់អ្នកធ្វើដំណើរតាមផ្លូវ។ការខ្មាស់អៀនជាផ្នែកមួយនៃជំនឿ)។(មូស្លីមលេខ៣៥)

3 សីលធម៌មានទំនាក់ទំនងជាមួយនឹងការគោរពបូជាគ្រប់ប្រភេទ

គ្មានទេអល់ឡោះគាត់បញ្ជាប្រើឱ្យធ្វើការគោរពសក្ការៈលើកែលងតែទង់បានៃណនាំអំពើគាលេដៅរបស់វាគឺសីលធម៌ឬផលបុណ្យរបស់វាមកលើខ្លួនឯងផ្ទាល់ ឬសង្គម។ហើយនឹងមានឧទាហរណ៍ជាច្រើនទៀតដូចជា

សទ្បាត អល់ឡោះបានមានបន្ទូលថា (ចូរអ្នកប្រតិបត្តិសឡាត ពិតប្រាកដណាស់សឡាតអាចហាមឃាត់អំពីការប្រព្រឹត្តអសីលធម៌និងអំពើទុច្ចរិត)។ (ស៊ូរ៉ោះអាល់អាំងកាប៊ូត ឃ្លា៤៥)

ការបរិច្ចាគទាន អល់ឡោះបានមានបន្ទូលថា (ចូរអ្នក (ណាពីមូហាំម៉ាត់) យកការបរិច្ចាគពីទ្រព្យសម្បត្តិរបស់ពួកគេមួយចំនួនដើម្បីជម្រះនិងសំអាត (បាបកម្ម) ពួកគេដោយការបរិច្ចាគនេះ)។ (ស៊ូរ៉ោះអាតាវហ្ពះ ឃ្លា១០៣)

ការបរិច្ចាគទានពិតប្រាកដនោះគឺការធ្វើអំពើល្អចំពោះមនុស្សនិងចូលរួមរំលែកទុក្ខពួកគេ ហើយវាក៏ជាការអប់រំខ្លួននិងជម្រះសំអាតអំពីសីលធម៌អាក្រក់។

បួស អល់ឡោះបានមានបន្ទូលថា (អល់ឡោះបានដាក់កាតព្វកិច្ចបួសមកលើពួកអ្នកដូចដែលអល់ឡោះបានដាក់កាតព្វកិច្ចទៅលើពួកអ្នកជំនាន់មុនៗដែរ ដើម្បីឱ្យពួកអ្នកកោតខ្លាចអល់ឡោះ)។ (អាល់ហ្គាកោរ៉ោះ ឃ្លា១៨៣)

មានអត្ថន័យថាការកោតខ្លាចចំពោះអល់ឡោះ ដោយធ្វើតាមអ្វីដែលទ្រង់បានបញ្ជាប្រើ និងជៀសឆ្ងាយពីអ្វីដែលទ្រង់បានហាមឃាត់។ រ៉សូលុលលោះបានមានប្រសាសន៍ថា (នរណាហើយដែលវាមិនបោះបង់ចោលនូវពាក្យសំដីអាក្រក់ហើយនៅតែធ្វើវានោះ ស្រាប់អល់ឡោះគឺវាគ្មានបានផលប្រយោជន៍អ្វីអំពីការបោះបង់ចំណីអាហារ និងភេសជ្ជៈរបស់វានោះទេ)។ (អាល់ប៊ុខរី ១៨០៤)

នរណាហើយដែលការបួសរបស់វាមិនបានផ្តល់ផលដល់ខ្លួននិងសីលធម៌របស់វាជាមួយនឹងមនុស្ស ពិតប្រាកដណាស់វាមិនបានទទួលគោលដៅដ៏ពិតប្រាកដរបស់ការបួសឡើយ។

## 4 គុណសម្បត្តិដ៏អស្ចារ្យនិងផលបុណ្យយ៉ាងធំធេងដែលអល់ឡោះបានរៀបចំសម្រាប់អ្នកដែលមានសីលធម៌ល្អ

មានភស្តុតាងជាច្រើនអំពីគួរអាននិងហាឌីសដែលទាក់ទងនឹងវា ដូចជា:

- វាគឺជាកិច្ចការល្អដែលធ្ងន់ជាងគេនៅលើជញ្ជីងនៅថ្ងៃបរលោក (ថ្ងៃគីយ៉ាម៉ាត់)
- ណាពីបានមានប្រសាសន៍ថា (គ្មានអ្វីមួយដែលដាក់លើជញ្ជីងធ្ងន់ជាងសីលធម៌ល្អនោះឡើយ ស្រាប់អ្នកដែលមានសីលធម៌ល្អអាចនិងឈានទៅដល់ឋានៈរបស់អ្នកបួស និងអ្នកសឡាត)។ (អាតេទៀតមីស៊ី ២០០៣):
- ០វាជាមូលហេតុដ៏សំខាន់ដែលនាំឱ្យបានចូលឋានសួគ៌

ណាពីបានមានប្រសាសន៍ថា (ប្រការដែលធ្វើឱ្យមនុស្សចូលឋានសួគ៌ច្រើនជាងគេគឺការកោតខ្លាចអល់ឡោះ និងសីលធម៌ល្អ)។ (អាតេទៀតមីហ្ស៊ី ២០០៤ អ៊ិបនូម៉ាយ៉ះ ៤២៤៦)

- អ្នកដែលមានសីលធម៌ល្អជាមនុស្សដែលមានឋានៈជិតទៅចំពោះរ៉សូលុលលោះបំផុតនៅថ្ងៃបរលោក (ថ្ងៃគីយ៉ាម៉ាត់)

ដូចដែលរ៉សូលុលលោះបានមានប្រសាសន៍ថា (ពិតប្រាកដអ្នកដែលខ្ញុំស្រលាញ់ជាងគេក្នុងចំណោមពួកអ្នក និងនៅជិតខ្ញុំជាងគេក្នុងថ្ងៃបរលោក (ថ្ងៃគីយ៉ាម៉ាត់) គឺអ្នកដែលមានសីលធម៌ល្អជាងគេក្នុងចំណោមពួកអ្នក)។ (អាតេទៀរមីហ្ស៊ី ២០១៨)

- គាត់នឹងបាននៅក្នុងឋានសួគ៌លំដាប់ខ្ពស់ជាងគេដោយមានការធានានិងការបញ្ជាក់ពីរ៉សូលុលលោះ

ណាពីបានមានប្រសាសន៍ថា (ខ្ញុំជាអ្នកធានានូវផ្ទះមួយនៅក្នុងឋានសួគ៌លំដាប់ទាបជាងគេស្រាប់ជនណាហើយដែលបោះបង់ចោលការឈ្លោះប្រកែកគ្នា សូម្បីតែគាត់ត្រូវក៏ដោយ។ ខ្ញុំក៏ធានានូវផ្ទះមួយនៅចំកណ្តាលនៃឋានសួគ៌ស្រាប់អ្នកដែលបោះបង់ការភូតកុហកសូម្បីតែនៅក្នុងការលេងសើចក៏ដោយ។ ហើយខ្ញុំក៏ធានានូវផ្ទះមួយទៀតនៅក្នុងឋានសួគ៌លំដាប់ខ្ពស់ជាងគេ ស្រាប់អ្នកដែលមានសីលធម៌ល្អ)។ (អាប៊ូដៅវូត៤៨០០)

# លក្ខណៈពិសេសនៃសីលធម៌ក្នុងសាសនាឥស្លាម

គេកត់សម្គាល់សីលធម៌នៅក្នុងសាសនាឥស្លាមដោយលក្ខណៈពិសេស និងចំនុចសំខាន់មួយចំនួនដែលមាននៅតែនៅក្នុងសាសនាដ៏ឧត្តុងឧត្តមនេះមួយគត់ ដូចជា

## 1. សីលធម៌ល្អគឺមិនមែនសម្រាប់តែប្រភេទមនុស្សមួយចំនួននោះទេ

អល់ឡោះបានបង្កើតមនុស្សដោយមានមុខមាត់ ពណ៌សម្បុរ និងភាសាខុសៗគ្នា ហើយក៏បានដាក់ពួកគេនៅលើផែនដីរបស់អល់ឡោះដោយមានលក្ខណៈស្មើភាពៗគ្នា ដោយមិនឱ្យមាននរណាម្នាក់អំពីពួកគេល្អជាងនរណាម្នាក់ឡើយ លើកលែងតែសេចក្តីជំនឿ ការកោតខ្លាចនិងរូបការល្អរបស់ពួកគេប៉ុណ្ណោះ។ដូចដែលអល់ឡោះបានមានបន្ទូលថា( ឱមនុស្សលោក! ពិតប្រាកដណាស់យើងបានបង្កើតពួកអ្នកពីបុរសនិងស្រ្តី ហើយយើងធ្វើអោយពួកអ្នកមានជនជាតិនិងកុលសម្ព័ន្ធជាច្រើនដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅមក។ពិតប្រាកដណាស់អ្នកដែលថ្លៃថ្នូរជាងគេចំពោះអល់ឡោះក្នុងចំណោមពួកអ្នកគឺអ្នកដែលកោតខ្លាចអល់ឡោះជាងគេក្នុងចំណោមពួកអ្នក) ។( ស៊ូរ៉ោះអាល់ហ៊ូជូរ៉ត វាក្យ១៣)

សីលធម៌ល្អបញ្ជាក់ពីទំនាក់ទំនងអ្នកមូស្លីម និងមនុស្សដទៃទៀតដោយមិនមានភាពខុសគ្នាឡើយរវាងអ្នកមានទ្រព្យនិងអ្នកក្រ ឬឋានៈខ្ពស់ និងឋានៈទាប ឬសម្បុរខ្មៅ និងស ឬជនជាតិអារ៉ាប់ និងជនជាតិដទៃទៀត

សីលធម៌ជាមួយនឹងអ្នកមិនមែនជាមូស្លីម

អល់ឡោះបានប្រើឱ្យធ្វើអំពើល្អជាមួយនឹងអ្វីគ្រប់យ៉ាងទាំងអស់។ ភាពយុត្តិធម៌ សប្បុរសធម៌និងមេត្តាករុណាគឺជាសីលធម៌របស់អ្នកមូស្លីម ដែលដំណាងឱ្យគាត់ ក្នុងឥរិយាបទនិងពាក្យសំដីរបស់គាត់ជាមួយនឹងអ្នកមូស្លីមនិងអ្នកមិនមែនមូស្លីម ហើយចាំបាច់ត្រូវតែថែរក្សាសីលធម៌ល្អនោះ ដោយសារវាជាមាគ៌ាសម្រាប់អំពាវនាវអ្នកមិនមែនមូស្លីមឱ្យចូលក្នុងសាសនាដ៏ថ្កុំថ្កើងនេះ អល់ឡោះបានមានបន្ទូលថា( អល់ឡោះមិនហាមឃាត់ពួកអ្នកក្នុងការធ្វើល្អ និងផ្តល់ភាពយុត្តិធម៌ចំពោះពួកដែលមិនបានធ្វើសង្គ្រាមប្រឆាំងនឹងពួកអ្នកនៅក្នុងសាសនា និងមិនបានបណ្តេញពួកអ្នកចេញពីលំនៅដ្ឋានរបស់ពួកអ្នកឡើយ។ពិតប្រាកដណាស់អល់ឡោះស្រឡាញ់បណ្តាអ្នកដែលប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌) ។( ជំពូកអាល់មុមតាហ៊ីណះ វាក្យ៨) ប៉ុន្តែអល់ឡោះបានហាមឃាត់ពួកយើងមិនឱ្យគាំទ្រអ្នកដែលមិនមែនមូស្លីម និងស្រឡាញ់អ្វីដែលពួកគេកំពុងប្រព្រឹត្តអំពីការប្រឆាំង និងការស្អប់គេឡើយ។ ដូចអល់ឡោះបានមានបន្ទូលថា( ពិតប្រាកដណាស់អល់ឡោះហាមឃាត់ពួកអ្នកមិនឱ្យបង្កើតមិត្តភាពជាមួយពួកដែលបានធ្វើសង្គ្រាមប្រឆាំងនឹងពួកអ្នកនៅក្នុងសាសនា និងបានបណ្តេញពួកអ្នកចេញពីលំនៅដ្ឋានរបស់ពួកអ្នកហើយពួកគេជួយអ្នកដទៃបណ្តេញពួកអ្នកទៀត។អ្នកណាហើយដែលយកពួកគេធ្វើជាមិត្តនោះអ្នកទាំងនោះគឺជាអ្នកបំពាន)។( ជំពូកអាល់មុមតាហ៊ីណះ វាក្យ៩)



> អ្នកមូស្លីមធ្វើការទំនាក់ទំនងដោយសីលធម៌ល្អជាមួយនឹងមនុស្សគ្រប់រូបបើទោះបីជាខុសជាតិសាសន៍ឬសាសនាក៏ដោយ

## 2. សីលធម៌ល្អគឺមិនមែនមានស្រមាប៉ែតមនុស្សនោះទេ

សីលធម៌ជាមួយនឹងសត្វពាហនៈៈរ៉សូលុលេឡោះបាននិយាយប្រាប់យើងអំពីស្ត្រីម្នាក់បានចូលឋាននរក ដោយសារគាត់ឃុំឃាំងឆ្មារហូតទាល់តែឃ្លានស្លាប់។ផ្ទុយពីនេះគាត់បាននិយាយប្រាប់យើងអំពីបុរសម្នាក់ដែលអល់ឡោះបានជម្រះចោលឧសារ(បាបកម្ម)របស់គាត់ ដោយគាត់បានផ្ដល់ទឹកដល់សត្វឆ្កែនៅពេលដែលវាស្រេកទឹកខ្លាំង។ ណាពីបាននិយាយប្រាប់សាសន៍ថា(ស្ត្រីម្នាក់បានចូលឋាននរកដោយសារឆ្មា គាត់ឃុំឃាំងវាទុកដោយមិនឱ្យចំណីវា ហើយក៏មិនដោះលែងវាឱ្យដើររកចំណីនៅលើផែនដី)។(អាល់ពូខរី ៣១៤០ មូស្លីម ២៦១៩)

ហើយណាពីមានប្រសាសន៍ថា(នៅពេលដែលបុរសម្នាក់កំពុងដើរតាមផ្លូវមួយ ស្រាប់តែគាត់ស្រេកទឹកយ៉ាងខ្លាំង។ពេលនោះគាត់ក៏បានឃើញអណ្ដូងមួយ ហើយគាត់ក៏បានចុះទៅផឹកទឹកអណ្ដូងនោះ បន្ទាប់មកគាត់ក៏បានចេញមកវិញ។ ខណៈពេលនោះគាត់បានឃើញសត្វឆ្កែកំពុងតែយកអណ្ដាតរបស់វាលិតដីភក់ដោយការស្រេកទឹកខ្លាំង។ ហើយបុរសម្នាក់នោះក៏បានគិតថា(ឆ្កែនេះកំពុងតែស្រេកទឹកខ្លាំងដូចខ្ញុំមុននេះចឹង)ហើយគាត់ក៏បានចុះទៅក្នុងអណ្ដូងម្ដងទៀត ហើយគាត់បានដួសទឹកដាក់ពេញស្បែកជើង បន្ទាប់មកខាំវានឹងមាត់របស់គាត់រហូតឡើងផុតពីអណ្ដូង ហើយក៏យកឱ្យឆ្កែនោះផឹក។ ហើយអល់ឡោះបានថ្លែងអំណរអរគុណទៅចំពោះបុរសនោះ និងបានអភ័យទោសឱ្យគាត់ ពួកគេបានសួរថា ឱរ៉សូលុលេឡោះ!តើពួកយើងធ្វើល្អចំពោះសត្វពាហនៈបានទទួលផលបុណ្យដែរឬ?គាត់តបឆ្លើយថា : រាល់ការជួយសត្វទាំងអស់ដែលមានជីវិតគឺបានទទួលផលបុណ្យ)។(អាល់ពូខរី ៥៦៦៣ មូស្លីម ២២៤៤)

សីលធម៌ដើម្បីការពារបរិស្ថានសាសនាឥស្លាមបានប្រើឱ្យយើងកសាងនៅលើផែនដី មានន័យថាការធ្វើការងារ ការអភិវឌ្ឍ បង្កើនផលិតផល និងកសាងអារ្យធម៌ ជាមួយនឹងការការពារនិងថែរក្សាទៅលើគុណបុណ្យនេះ និងហាមឃាត់មិនឱ្យមានការបំផ្លាញ និងរំលោភបំពានឬខ្ជះខ្ជាយក្នុងការធ្វើអាជីវកម្មលើធនធាននោះ សូម្បីតែការបំផ្លាញនោះគឺដោយសារតែមនុស្ស សត្វ ឬរុក្ខជាតិក៏ដោយ ពិតប្រាកដណាស់វាជាការងារដែលសាសនាឥស្លាមប្រចាំនូវចាលនិងស្អប់ខ្ពើមជាទីបំផុត ហើយអល់ឡោះមិនស្រឡាញ់ការបំផ្លាញនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។ដូចអល់ឡោះបានមានបន្ទូលថា(ហើយអល់ឡោះមិនស្រលាញ់អំពើវិនាសកម្មឡើយ)។(អាលបាការ៉ះ ឃ្លា២០៥)

ហើយការព្រួយបារម្ភអំពីបញ្ហានេះបានឈានទៅដល់ការផ្ដាំផ្ញើរបស់ណាពីម៉ូហាំម៉ាត់មកលើអ្នកមូស្លីមទាំងអស់ឱ្យប្រព្រឹត្តតែអំពើល្អ និងចូលរួមនៅក្នុងការដាំដុះលើផែនដី សូម្បីតែនៅក្នុងកាលៈទេសៈលំបាកបំផុត ឬក្នុងគ្រាដ៏រន្ធត់ណាក៏ដោយ គាត់បានមានប្រសាសន៍ថា(ប្រសិនបើថ្ងៃបរលោក(ថ្ងៃគីយ៉ាម៉ាត់)បានមកដល់ ហើយនៅក្នុងដៃរបស់ពួកអ្នកមានកូនរុក្ខជាតិ ប្រសិនបើអ្នកអាចដាំវាមុនថ្ងៃបរលោក(ថ្ងៃគីយ៉ាម៉ាត់)តែឡើងចូរអ្នកដាំវាចុះ)។(អះម៉ាត់ លេខ១២៩៨១)



> សាសនាឥស្លាមជំរុញឱ្យថែរក្សាបរិស្ថាន

## 3. សីលធម៌ល្អមានគ្រប់វិស័យទាំងអស់នៃជីវិតe



គ្រួសារ សាសនាឥស្លាមបានបញ្ជាក់ពីសារៈសំខាន់នៃសីលធម៌ក្នុងវិស័យនៃគ្រួសាររវាងសមាជិកគ្រួសារទាំងអស់។ ហើយណាពីបានមានប្រសាសន៍ថា( អ្នកដែលល្អជាងគេក្នុងចំណោមពួកអ្នកគឺអ្នកដែលបានធ្វើល្អជាងគេចំពោះភរិយារបស់ពួកអ្នក ហើយខ្ញុំជាអ្នកធ្វើល្អជាងគេចំពោះភរិយារបស់ខ្ញុំ )។(អាត់តៀរមីហ្ស លេខ៣៨៩៥ )

- មានហើយរ៉សូលុលឡោះគឺជាមនុស្សដែលល្អជាងគេបំផុតលោកបានជួយធ្វើកិច្ចការផ្ទះ និងជួយសម្រួលការងារដល់គ្រួសាររបស់លោកមិនថាក្មេងឬចាស់។ដូចដែលប្រពន្ធរបស់លោក អាអ៊ីសាស់បានរាយការណ៍មកថា( មានហើយលោកបានជួយវិជ្ជាជីវៈគ្រួសាររបស់លោក )។(អាល់ពូខរី លេខ៥០៤៨) មានន័យថា លោកបានជួយពួកគេ និងធ្វើរាល់កិច្ចការផ្ទះដែលគ្រួសារលោកបានធ្វើ។)
- ហើយពេលខ្លះលោកលេងសើចជាមួយក្រុមគ្រួសារលោកផងដែរ។ដូចដែលប្រពន្ធរបស់លោក អាអ៊ីសាស់បានរាយការណ៍មកថា( ខ្ញុំបានរួមដំណើរជាមួយនឹងរ៉សូលុលឡោះ ក្នុងការធ្វើដំណើរមួយរបស់លោកនៅពេលដែលខ្ញុំនៅក្មេង និងស្គម។ លោកបានសុំឱ្យមនុស្សធ្វើដំណើរទៅមុនពួកគេក៏បានធ្វើដំណើរទៅមុន បន្ទាប់មកលោកក៏បាននិយាយមកកាន់ខ្ញុំថា «សូមអញ្ជើញមកនេះ, ខ្ញុំនឹងទៅឱ្យដល់មុនអ្នក”ខ្ញុំបានចេញដំណើរយ៉ាងលឿនហើយខ្ញុំបានទៅដល់មុនលោក។ ហើយលោកមិនបាននិយាយពីហេតុការណ៍នេះទៀតទេ ក្រោយពេលដែលខ្ញុំបានឡើងទម្ងន់ ហើយខ្ញុំបានភ្លេចអំពីហេតុការណ៍នេះ ខ្ញុំបានរួមដំណើរជាមួយលោក ម្តងទៀត នៅក្នុងការធ្វើដំណើរមួយរបស់លោក លោកបានសុំឱ្យមនុស្សធ្វើដំណើរទៅមុន ពួកគេក៏បានធ្វើដំណើរទៅមុន បន្ទាប់មកលោកក៏បាននិយាយមកកាន់ខ្ញុំថា «សូមអញ្ជើញមកនេះ, ខ្ញុំនឹងទៅឱ្យដល់មុនអ្នក” ខ្ញុំបានធ្វើដំណើរយ៉ាងលឿនមុនលោកប៉ុន្តែលោកបានទៅដល់មុនខ្ញុំ។ ហើយគាត់បានសើចហើយនិយាយថា «នេះគឺដើម្បីធ្វើឱ្យអ្នកដឹងចំពោះការបរាជ័យពីមុនរបស់ខ្ញុំ”។)

### ពាណិជ្ជកម្ម

ដោយសារសេចក្តីស្រឡាញ់របស់មនុស្សនូវទ្រព្យសម្បត្តិទើបធ្វើឱ្យមនុស្សចង់បានហួសហេតុ និងធ្វើឱ្យពួកគេធ្លាក់ចូលទៅក្នុងរបការហាមឃាត់ សាសនាឥស្លាមបានមកដល់ដើម្បីបញ្ជាក់ពីសារៈសំខាន់នៃការគ្រប់គ្រងវាដោយប្រើសីលធម៌ល្អ ហើយខ្លះៗអំពីការអះអាងទាំងនេះ:

- ឥស្លាមបានហាមឃាត់មិនឱ្យមានការគេងបន្លំ ឬរំលោភបំពាននៅលើភ្នែកជញ្ជីងឡើយ ហើយក៏បានដាក់កិច្ចសន្យាទៅលើអ្នកដែលបានធ្វើទង្វើនេះដោយទារុណកម្មយ៉ាងធ្ងន់ធ្ងរ។ដូចដែលអល់ឡោះបានមានបន្ទូលថា( ភាពវិនាសអន្តរាយគឺស្រមាប់ពួកអ្នកដែលគេងបន្លំ។ជាពួកដែលទាមទារចង់បានគ្រប់ចំនួននៅពេលដែលពួកគេថ្លឹងវាស់ ឬវាល់ពីអ្នកដទៃ។តែនៅពេលដែលពួកគេវាស់ឬវាល់ឬថ្លឹងឱ្យអ្នកដទៃគឺពួកគេធ្វើឱ្យខ្វះ )។( សូរ៉ោះអាល់មូតហ្វហ្វីហ្វីន ឃ្លា១-៣ ).
- ជំរុញក្នុងការអធ្យាស្រ័យនិងភាពទន់ភ្លន់ក្នុងការលក់និងទិញ,ណាពីបានមានប្រសាសន៍ថា(អល់ឡោះអាណិតស្រលាញ់បុរសម្នាក់ដែលវាអធ្យាស្រ័យក្នុងពេលលក់ ពេលទិញ និងពេលទាមទារបំណុល )។(អាល់ពូខរី លេខ១៩៧០ )

### ឧស្សាហកម្ម

សាសនាឥស្លាមបានបញ្ជាក់ទៅលើចំនួនសិប្បករ អំពីសីលធម៌ និងវិជ្ជាជីវៈ មានដូចជា:

- ត្រូវធ្វើកិច្ចការឱ្យល្អឥតខ្ចោះនឹងបំពេញផលិតផលយ៉ាងល្អប្រណិត។ ដូចណាពីបានមានប្រសាសន៍ថា( ពិតប្រាកដណាស់អល់ឡោះស្រលាញ់ទៅចំពោះនរណាម្នាក់ក្នុងចំណោមពួកអ្នក ដែលវាបាន្ធ្វើកិច្ចការយ៉ាងល្អឥតខ្ចោះ )។( អាប៊ូយ៉ាកេឡៃ ៤៣៨៦ អាំលៃពហាគី នៅក្នុងហ្សុកអាពូល អ៊ីម៉ាន ៥៣១៣ )
- ប្រកាន់ខ្ជាប់ពេលវេលាដែលបានកំណត់ជាមួយនឹងមនុស្ស។ណាពីបានមានប្រសាសន៍ថា "សញ្ញាសំគាល់អ្នកពុតត្បុត( មូណាហ្វិក )មាន៣"មួយក្នុងចំនោមនោះ "នៅពេលសន្យាមិនបំពេញតាមសន្យា"។( អាល់ពូខរី ៣៣ )

## 4. សីលធម៌ល្អមានគ្រប់ករណីទាំងអស់

សាសនាឥស្លាមគ្មានករណើលើកលែងក្នុងផ្នែកសីលធម៌ឡើយ អ្នកមូស្លីមត្រូវបានកំណត់ឱ្យអនុវត្តន៍តាមច្បាប់របស់អល់ឡោះ និងការអនុវត្តតាមសីលធម៌ល្អ ទោះបីជានៅក្នុងពេលធ្វើសង្គ្រាម ឬក្នុងកាលៈទេសៈលំបាកកើតឡើយ ស្រមាប់គាត់ដៅនឹងគោលបំណងដល់ត្រឹមត្រូវមិនបង្ហាញអំពីភាពព្រឹត្តិម្រត្តូវនៃមធ្យោបាយអាក្រក់ឬមិនបិទបាំងអំពើបុការខុសឆ្គងនិងប្រការវង្វេងឡើយ។ ដោយសារបែបនេះហើយទើបសាសនាឥស្លាមបានដាក់ក្បួនច្បាប់ស្រមាប់កាត់ក្តីអ្នកមូស្លីម និងការរៀបចំរាល់សកម្មភាពរបស់ពួកគេសូម្បីតែនៅពេលដែលមានការឈ្លានពាននិងពេលមានស្រង្គ្រាមកើតឡើយ គឺដើម្បីកុំឱ្យការងារនោះឈានទៅរកការខឹងសំបា និងការប្រកាន់ពូជសាសន៍ ហើយនឹងកុំនាំឱ្យមានការឈ្នានីស ភាពសាហាវឃោរឃៅ និងអាត្មានិយម។

### អំពីសីលធម៌ឥស្លាមក្នុងពេលធ្វើស្រង្គាម

1. ឥស្លាមប្រើឱ្យមានភាពយុត្តិធម៌ជាមួយនឹងស្រត្រូវ ហើយនឹងហាមឃាត់មិនឱ្យធ្វើប្រការអយុត្តិធម៌ និងការរំលោភបំពានទៅលើពួកគេ

   ដូចអល់ឡោះបានមានបន្ទូលថា( ហើយចូរកុំបណ្តោយឱ្យការស្អប់ខ្ពើមរបស់ក្រុមមួយធ្វើឱ្យពួកអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ឱ្យសោះ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ ព្រោះវាជិតបំផុតក្នុងការកោតខ្លាចអល់ឡោះ )។( ជំពូកអាល់ម៉ាអ៊ីឌះ ឃ្លា៨ )មានន័យថា ចូរពួកអ្នកកុំធ្វើឱ្យការស្អប់ខ្ពើមរបស់ពួកអ្នក ទៅលើស្រត្រូវរបស់ពួកអ្នក បញ្ជាឱ្យអ្នកធ្វើការរំលោភបំពាន និងធ្វើប្រការអយុត្តិធម៌ទៅលើស្រត្រូវរបស់ពួកអ្នក ប៉ុន្តែចាំបាច់អ្នកត្រូវតែប្រកាន់ខ្ជាប់នឹងភាពយុត្តិធម៌នៅក្នុងពាក្យសំដី ឬកាយវិការ។.

2. ការហាមឃាត់មិនឱ្យក្បត់សន្យា និងការបោកប្រាស់ជាមួយនឹងខ្មាំងស្រត្រូវ

   ការក្បត់សន្យានិងការបោកប្រាស់ជាប្រការដែលត្រូវបានគេហាមឃាត់(ហារ៉ាំ )សូម្បីតែជាមួយសត្រូវក៏ដោយ។ដូចដែលអល់ឡោះបានមានបន្ទូលថា( ពិតប្រាកដណាស់អល់ឡោះមិនចូលចិត្តពួកដែលក្បត់កិច្ចសន្យាឡើយ )។( ជំពូកអាល់អាន់ហ្វាល ឃ្លាទី៥៨ )

3. ការហាមឃាត់មិនឱ្យធ្វើទារុណកម្ម ឬប្រដូចនឹងសាកសព គេបានហាមឃាត់មិនឱ្យប្រដូចទៅនឹងសាកសពទេ ដូចដែររ៉សូលុលឡោះបានមានប្រសាសន៍ថា( ចូរពួកអ្នកកុំប្រដូច )។( មូស្លីម លេខ១៧៣១ )

4. ការហាមឃាត់លើការសម្លាប់ជនស៊ីវិលដែលមិនបានចូលរួមក្នុងស្រង្គាមនិងការបំផ្លាញផែនដី និងបរិស្ថាន នេះជាលោក អាពូពើកើរ អាស់ស៊ីទទីក ដែលជាមេដឹកនាំឥស្លាមហើយជាមនុស្សដែលល្អបំផុតក្នុងចំណោមសហាហ្ពះបានផ្តាំទៅចំពោះលោក អូសាម៉ាស កូន ហ្សេត ខណៈពេលដែលគាត់ត្រូវបានគេតងតាំងធ្វើជាមេទ័ពទៅឯប្រទេសសាម( ចូរពួកអ្នកកុំសម្លាប់កូនក្មេង មនុស្សចាស់ និងស្ត្រី ហើយមិនត្រូវដុតដើមល្មើ និងដុតវាចោលទេ ហើយមិនត្រូវកាប់ដើមឈើណាដែលផ្តល់ផ្លែផ្កាឡើយ ហើយមិនត្រូវសម្លះសត្វពពែ ឬសត្វគោ ឬសត្វអូដ្ឋឡើយលើកលែងតែស្រមាប់បរិភោគ។ហើយនឹងមានមួយក្រុមដែលនឹងចាកចេញពីលំនៅឋានរបស់ពួកគេ ចូរអំពាវនាវពួកគេកុំឱ្យពួកគេចាកចេញទៀត )( អ៊ិបនូអូសាគៀត ២/៥០ )

# រូបភាពក្នុងសម័យណាពីរសៀនៅ

មានៃហើយណាពីម៉ូហាំម៉ាត់គឺជាគំរូនៃសីលធម៌ល្អឥតខ្ចោះរបស់មនុស្សជាតិ ដូច្នេះហើយគម្ពីគួរអានបានរៀបរាប់ពីលក្ខណៈសីលធម៌អស្ចារ្យរបស់លោក ហើយប្រពន្ធរបស់លោកក៏បានរៀបរាប់ពីលក្ខណៈសីលធម៌របស់លោក ដោយនិយាយថា(សីលធម៌របស់លោកគឺគួរអាន) មានន័យថាគឺគំរូសម្រាប់ការអនុវត្តការបង្រៀនគឺគួរអាននិងសីលធម៌របស់លោក



> មានហើយណាពីមូហាំម៉ាត់គឺជាមនុស្សដែលមានសីលធម៌ល្អបំផុត

## ការឱនលំទាន

- រ៉សូលុលឡោះមិនបានអនុញ្ញាតឱ្យនរណាម្នាក់លើកដំកើនខ្លួនរបស់លោកនោះទេ ផ្ទុយទៅវិញលោកបានហាមឃាត់មិត្តភក្តិរបស់លោកមិនឱ្យធ្វើដូច្នេះទេ ដោយសារតែមិត្តភក្តិរបស់លោស្រឡាញ់លោកខ្លាំង នៅពេលដែលពួកគេបានឃើញណាពីមកដល់ពួកគេក៏នាំគ្នាក្រោកឈរឡើងដោយពួកគេបានដឹងថាណាពីមិនចូលចិត្តបែបនេះទេ។(អះម៉ាត់ លេខ១២៣៤៥ អាលំពៃសេហ៊្សេរ លេខ៦៦៣៧)
- លោក អាឌី កូន ហាតឹម បាននៅជួបណាពីមុនពេលគាត់ចូលឥស្លាមមានហើយគាត់ជាអ្នកដែលមានមុខមាន់មាត់ម្នាក់របស់ជនជាតិអារ៉ាប់ គាត់ចង់ដឹងអំពីការពិតនៃការអំពាវនាវរបស់ណាពី។ អាឌីបាននិយាយថា(ខ្ញុំបាននៅជួបលោក(ណាពីមូហាំម៉ាត់) ពេលនោះមាននៅជាមួយនឹងលោកនូវស្ត្រីម្នាក់និងកូនក្នុង -គាត់បានរំលឹកថាពួកគេនៅជិតនឹងណាពីមូហាំម៉ាត- ហើយខ្ញុំក៏បានដឹងថាលោកមិនមែនជាស្តេចដែលអស្ចារ្យ ឬព្រះចៅអធិរាជអ្វីនោះទេ។(អះម៉ាត់ លេខ១៩៣៨១)ការឱនលំទានជាសីលធម៌របស់បណ្ដាណាពីៗទាំងអស់។)
- លោកអង្គុយជាមួយមិត្តភក្តិរបស់លោកដូចជាម្នាក់ក្នុងចំណោមពួកគេ ដោយលោកមិនបានអង្គុយកន្លែងពិសេសណាដើម្បីឱ្យខុសប្លែកពីអ្នកដទៃដែលនៅជុំវិញលោកឡើយ រហូតដល់អ្នកចំទៀតដែលមិនដែលស្គាល់លោកសោះ នៅពេលដែលមកចូលរួមជាមួយលោក គាត់មិនអាចកំណត់បានថាម្នាក់ណាជាលោកម្នាក់ណាជាមិត្តភក្តិលោកទេ ហើយគេក៏បានសួរថា តើម្នាក់ណាជាម៉ូហាំម៉ាត់?(អាល់ពូខរី លេខ៦៣)
- លោក អាណេស កូន ម៉ាឡឹកបាននិយាយថា( ទាសករស្ត្រីណាម្នាក់ក្នុងចំណោមទាសករដែលរស់នៅក្នុងទីក្រុងម៉ាទីណះ ដែលបានកាន់ដៃរបស់ណាពីម៉ូហាំម៉ាត់ពិតណាស់លោកនឹងយកនាងទៅគ្រប់ទីកន្លែងដែលនាងប្រាថ្នា)។(អាល់ពូខរី លេខ៥៧២៤)អត្ថន័យរបស់នរណាហើយដែលបានកាន់ដៃណាពី: គឺសេចក្ដីសប្បុរស និងការចង្អុលបង្ហាញរបស់លោកទៅចំពោះកូនក្មេងនិងអ្នកទន់ខ្សោយ។វាបានបង្ហាញឱ្យមានឃើញពីភាពឱនលំទានទាំងស្រុងរបស់លោក( ណាពីមូហាំម៉ាត់) ដោយគេបានរៀបរាប់អំពីស្ត្រីមិនមែនបុរស និងជាទាសករមិនមែនអ្នកមានសេរីភាព ដោយនាងអាចចាប់យកវាពេលដែលនាងត្រូវការដើម្បីដោះស្រាយបញ្ហារបស់នាង។

- ណាពីបានមានប្រសាសន៍ថា( មិនបានចូលឋានសួគ៌ទេជនណាហើយដែលមានក្នុងចិត្តរបស់វានោះភាពក្រអឺតក្រទមសូម្បីតែប៉ុនលំអងធូលីក៏ដោយ )( មូស្លីម លេខ៩១ )

## ការអាណិតស្រលាញ់

- ណាពីបានមានប្រសាសន៍ថា( ពួកអ្នកដែលអាណិតស្រលាញ់គេ អល់ឡោះនឹងអាណិតស្រលាញ់ពួកគេវិញ ចូរពួកអ្នកអាណិតស្រលាញ់អ្នកដែលនៅលើផែនដីទាំងអស់ ហើយអ្នកដែលនៅលើមេឃទាំងអស់នឹងអាណិតស្រលាញ់ពួកអ្នកវិញ )។( អាត់តៀរមីហ្ស៊ី លេខ១៩២៤ អាពូដេវូទ លេខ៤៩៤១ )

ការអាណិតស្រលាញ់របស់ណាពីមូហាំម៉ាត់មានច្រើនផ្នែកដូចជា:

### ការអាណិតស្រលាញ់របស់គាត់ទៅចំពោះកូនក្មេង

- មានបុរសជនបទម្នាក់មកជួបណាពីមូហាំម៉ាត់ ហើយបាននិយាយទៅកាន់ណាពីថា( ពួកអ្នកថើបកូនៗរបស់ពួកអ្នក ? ពួកយើងមិនដែលបានថើបពួកគេសោះ ណាពីក៏បានតបទៅវិញថា( ខ្ញុំមិនអាចជួយពួកអ្នកបានទេ ប្រសិនបើអល់ឡោះបានដកក្ដីអាណិតស្រលាញ់ចេញពីចិត្តរបស់ពួកអ្នកនោះ )។( អាល់ពូខរី ៥៦៥២ មូស្លីម ២៣១៧ ) ហើយម្នាក់ទៀតបានឃើញណាពីថើបហាសេន កូន អាលី ហើយក៏បាននិយាយថា( ខ្ញុំមានកូនដល់ទៅ១០នាក់តែមិនដែលបានថើបម្នាក់ក្នុងចំណោមពួកគេទេ ណាពីក៏បានមានប្រសាសន៍ថា( នរណាហើយដែលមិនអាណិតស្រលាញ់មនុស្ស អល់ឡោះក៏មិនអាណិតស្រលាញ់គាត់ដែរ )។( មូស្លីម លេខ២៣១៨ ))
- ពេលមួយណាពីបានពរចៅស្រីរបស់គាត់ អាម៉ាម៉ះ កូន ហ្សៃណាប់ ខណៈពេលដែលគាត់កំពុងសឡាត នៅពេលដែលគាត់ស៊ូជោទគាត់ដាក់នាងចុះ ហើយនៅពេលដែលគាត់ឈរគាត់ពរនាងឡើង )។( អាល់ពូខរី លេខ៤៩៩៤ មូស្លីម លេខ៥៤៣ )
- នៅពេលដែលគាត់សឡាតហើយបានលឺសំលេងក្មេងយំគាត់ប្រញាប់ប្រញាល់ និងសូត្រខ្លីៗនៅក្នុងការសឡាត។អំពី អាពីគូតាដះ ពិត្រប្រាកដណាស់ណាពីបានមានប្រសាសន៍ថា( ជាការពិតណាស់ ពេលខ្លះខ្ញុំសឡាត ហើយខ្ញុំចង់សឡាតឱ្យបានយូរ ប៉ុន្តែខ្ញុំបានលឺសំលេងក្មេងយំ ខ្ញុំក៏សឡាតខ្លីវិញ ដោយខ្ញុំមិនចង់បង្កការលំបាកដល់ម្ដាយរបស់គេ )។( អាល់ពូខរី ៦៧៥ មូស្លីម ៤៧០ )

### ការអាណិតស្រលាញ់របស់លោកទៅចំពោះស្ត្រី

ណាពីមូហាំម៉ាត់បានជំរុញឱ្យថែរក្សាក្មេងស្រីនិងមានសេចក្ដីសប្បុរសទៅចំពោះពួកនាង ហើយគាត់បានមានប្រសាសន៍ថា( បុគ្គលណាត្រូវបានគេសាកល្បងដោយឱ្យមានកូនស្រីច្រើន ហើយគាត់បានធ្វើល្អចំពោះកូនៗទាំងនោះ ពួកនាងគឺជារនាំងស្រមាប់ការពារគាត់ពីភ្លើងឋាននរក )។( អាល់ពូខរី ៥៦៤៩ មូស្លីម ២៦២៩ )



ប៉ុន្តែលោកបានសង្កត់ធ្ងន់ក្នុងការផ្ដែផ្ដាំឱ្យធ្វើល្អជាមួយប្រពន្ធ និងមានការចាប់អារម្មណ៍ក្នុងកិច្ចការរបស់ពួកនាងហើយយកចិត្តទុកដាក់លើបញ្ហារបស់ពួកនាង ហើយលោកក៏បានប្រើឱ្យអ្នកមូស្លីមផ្ដែផ្ដាំគ្នាទៅវិញទៅមកអំពី



បញ្ហានេះផងដែរ ដោយលោកបានមានប្រសាសន៍ថា( ចូរពួកអ្នកធ្វើល្អទៅចំពោះស្ត្រី )។(អាល់ពូខរី ៤៨៩០ )

ហើយណាពីមូហាំម៉ាត់បានលើកយកឧទាហរណ៍ដ៏អស្ចារ្យ អំពីភាពទន់ភ្លន់ជាមួយនឹងសមាជិកគ្រួសាររបស់លោក។ នៅពេលលោកបានអង្គុយនៅក្បែរសត្វអូដ្ឋរបស់លោក ហើយដាក់ជង្គង់របស់លោកស្រមាប់ឱ្យ ហ្សាហ្វីយ៉ាស ដាក់ជើងរបស់នាងនៅលើជង្គង់របស់លោក ដើម្បីឡើងទៅលើសត្វអូដ្ឋ។(អាល់ពូខរី ២១២០ )

នៅពេលណាដែលកូនស្រីរបស់លោក ហ្វាទីម៉ាស បានចូលមកលេងលោកនោះ លោកបានទទួលស្វាគមន៍នាងដោយចាប់ដៃរបស់នាង ហើយនឹងថើបនាង និងផ្តល់ឱ្យនាងអង្គុយកន្លែងដែលលោកបានអង្គុយ។(អាពូទើវូទ ៥២១៧ )

## ការអាណិត្រសលាញ់របស់លោកជាមួយនឹងអ្នកទន់ខ្សោយ

- ដូច្នេះហើយបានជាណាពី ជ្រមុញមនុស្សលើការថែរក្សាក្មេងកំព្រា។ដោយលោកបានមានប្រសាសន៍ថា( ខ្ញុំ នឹងអ្នកថែរក្សាក្មេងកំព្រា នៅក្នុងឋានសួគ៌ក្បែរគ្នាដូចនេះ )ហើយគាត់បានបង្ហាញម្រាមដៃចង្អុលនឹងម្រាមដៃកណ្តាល ហើយញែកវាចេញពីគ្នាបន្តិច។(អាល់ពូខរី ៤៩៩៨ )
- គាត់បានចាត់ទុកអ្នកដែលជួយដល់ស្ត្រីមេម៉ាយនឹងអ្នកក្រីក្រប្រៀបដូចជាអ្នកដែលចម្បាំងក្នុងផ្លូវអល់ឡោះ ហើយក៏ដូចជាអ្នកដែលបួសនៅពេលថ្ងៃ និងសឡាតនៅពេលយប់។(អាល់ពូខរី ៥៦៦១ មូស្លីម ២៩៨២ )

- ផ្តល់សេចក្តីសប្បុរសចំពោះអ្នកដែលទន់ខ្សោយនិងផ្តល់ជូនពួកគេនូវសិទ្ធិរបស់ពួកគេដែលជាមូលហេតុទទួលបានលាភសក្ការៈ និងជំនួយលើខាំងស្រូវ។ ណាពីបានមានប្រសាសន៍ថា( ចូរពួកអ្នកស្វែងរកអ្នកទន់ខ្សោយឱ្យខ្ញុំ ការពិតពួកអ្នកត្រូវបានគេជួយនិងត្រូវបានគេផ្តល់លាភសក្ការៈ ដោយសារអ្នកទន់ខ្សោយក្នុងចំណោមពួកអ្នក)។(អាពូទើវូទ ២៥៩៤))

■ ការអាណិត្រសលាញ់របស់លោកទៅកាន់សត្វពាហនៈs

- មាននេហើយណាពី បានជំរុញឱ្យមនុស្សមានសេចក្តីសប្បុរសចំពោះសត្វពាហនៈ មិនត្រូវប្រើប្រាស់ពួកគេលើសពីសមត្ថភាពឡើយ និងមិនត្រូវធ្វើបាបពួកគេទ។ ណាពីបានមានប្រសាសន៍ថា( ពិតណាស់អល់ឡោះបានដាក់បទបញ្ជាឱ្យធ្វើល្អចំពោះអ្វីៗទាំងអស់ ហេតុនេះនៅពេលដែលពួកអ្នកសម្លាប់សត្វ( ដែលបង្ករគ្រោះថ្នាក់) ចូរពួកអ្នកសម្លាប់ដោយវិធីសាស្រ្តល្អ ហើយនៅពេលពួកអ្នកសម្លះសត្វ( ដើម្បីទទួលទាន) ចូរពួកអ្នកសម្លះដោយវិធីសាស្រ្តល្អ ចូរឱ្យពួកអ្នកសំលាងកាំបិតរបស់ពួកអ្នកឱ្យមុត ហើយធ្វើយ៉ាងណាឱ្យសត្វនោះស្លាប់ដោយងាយស្រួលបំផុត) ។( មូស្លីម ១៩៥៥)



> ណាពីមូហាំម៉ាត់បានចាត់ទុកអ្នកដែលធ្វើល្អជាមួយស្រ្តីមេម៉ាយនឹងអ្នកក្រក្រីកដូចជាអ្នកដែលទៅធ្វើសង្គ្រាមក្នុងផ្លូវអល់ឡោះ។



> នៅពេលដែលណាពីបានឃើញបក្សីក្នុងភាពខ្វះខ្វែងនិងចលនារបស់វានៅក្នុងការស្វែងរកកូនៗរបស់វា ដែល សហាហ្វះ មួយចំនួនបានយកវាទៅ ហើយគាត់បានមានប្រសាសន៍ថា: (តើនណារធ្វើឱ្យមានការភ័យរន្ធត់នុះដល់ម្ដាយរបស់វា )ចូរត្រឡប់ពួកគេទៅឱ្យម្តាយរបស់ពួកគេវិញ

- សហាហ្វះម្នាក់បាននិយាយថា:ណាពីបានឃើញកន្លែងបម្លុលផ្ទុំរបស់ស្រមោចមួយ កន្លែងដែលត្រូវបានពួកយើងដុត លោកក៏បានមានប្រសាសន៍ថា( តើអ្នកណាជាអ្នកដុតវានេះ? ) ពួកយើងក៏បានឆ្លើយថា( ពួកយើងជាអ្នកដុត )លោកក៏មានប្រសាសន៍ថា ( ជាការពិតណាស់គ្មានអ្នកណាម្នាក់មានសិទ្ធប្រើភ្លើងជាទណ្ឌកម្មឡើយ លើកលែងតែម្ចាស់របស់ភ្លើងប៉ុណ្ណោះ )។( អាពូទើវូទ ២៦៧៥)

# យុត្តិធម៌

- ពិតណាស់ណាពីមូហាំម៉ាត់គឺជាមនុស្សដែលយុត្តិធម៌បំផុត លោកអនុវត្តច្បាប់អល់ឡោះសូម្បីតែជាមួយញាតិសន្តានគេដាយ ដោយប្រណិបត្តិតាមបទបញ្ជារបស់អល់ឡោះ (ឱ!បណ្តាអ្នកដែលមានជំនឿ!ចូរពួកអ្នកក្រហកាន់ឱ្យបានខ្ជាប់ខ្ជួននូវភាពយុត្តិធម៌ ដូចជាការធ្វើសាក្សីចំពោះអល់ឡោះសូម្បីតែ(ធ្វើសាក្សី)លើខ្លួនឯង ឬឪពុកម្តាយនិងញាតិសន្តានគេដាយ) ។( ជំពូកអាន់និសេក ឃ្លា១៣៥))

- នៅពេលដែលសហាហ្ពះមួយចំនួនបានមកសុំឱ្យណាពីធ្វើអន្តរាគមន៍ ដោយមិនឱ្យធ្វើទារុណកម្មទៅលើនារីម្នាក់ដែលមានឋានៈខ្ពស់នៅក្នុងកុលសម្ព័ន្ធ ដោយនាងបានលួចគេ ណាពីក៏បានមានប្រសាសន៍ថា( ខ្ញុំសូមស្បថនឹងអ្នកដែលជីវិតរបស់ខ្ញុំស្ថិតនៅលើដៃរបស់ទ្រង់ថា ប្រសិនបើ ហ្វាតុីម៉ាស់ កូន មូហាំម៉ាត់ បានលួចគេ ខ្ញុំនឹងកាត់ដៃរបស់នាង)។(អាល់ពូខរី ៤០៥៣ មូស្លីម ១៦៨៨)

- នៅពេលដែលគេហាមឃាត់មនុស្សទៅលើការយកការប្រាក់ អ្នកដែលចាប់ផ្តើមដំបូងគេគឺជាអ្នកដែលនៅជិតណាពីបំផុត ហើយលោកក៏បានហាមមិនឱ្យយកការប្រាក់ ហើយគាត់នោះគឺឪពុកមាររបស់លោក អាល់អាពេពើស។ណាពីបានមានប្រសាសន៍ថា( ការយកការប្រាក់ដំបូងគេគឺការយកការប្រាក់របស់ អាពុពេើស កូន អាបឌុលមូតឡិបពិត្របាកដណាស់វាត្រូវបានគេលុបចោលទាំងអស់) ។(មូស្លីម ១២១៨)

- ផ្តល់ភាពស្មើគ្នានៅក្នុងសង្គម និងលើកដំកើនវា ដោយទាមទារកម្មសិទ្ធិរបស់អ្នកទន់ខ្សោយពីអ្នកដែលមានអំណាចដោយគ្មានការភ័យខ្លាចឬស្ទាក់ស្ទើរ។ណាពីបានមានប្រសាសន៍ថា( គ្មានការជ្រះស្អាតទេចំពោះក្រុមណាហើយដែល មិនបានផ្តល់ឱ្យអ្នកទន់ខ្សោយនូវកម្មសិទ្ធិរបស់គេ ដោយគ្មានការស្ទាក់ស្ទើរ)។(អ៊ីពន្នូម៉ាយ៉ាស់ ២៤២៦)

# សេចក្តីសប្បុរស និងមានចិត្តទូលាយ

- មានហើយណាពីជាមនុស្សដែលមានចិត្តសប្បុរសបំផុត ហើយពេលដែលលោកមានចិត្តសប្បុរសបំផុតនោះគឺនៅក្នុងខែរ៉ម៉ាឌននៅពេលដែល ជីព្រីល មកជួបលោក។ ហើយ ជីព្រីល បានមកជួបលោកជារៀងរាល់យប់ក្នុងខែរ៉ម៉ាឌនរហូតដល់ចប់ ហើយបង្រៀនលោកនូវគម្ពីគួរអាន។ ពេលដែលលោកបានជួប ជីព្រីល លោករួសរាន់បំផុតចំពោះភាពសប្បុរសធម៌ ជាងខ្យល់ដែលបក់នាំអ្វីៗទៅទៀត)។(អាល់ពូខរី ១៨០៣ មូស្លីម ២៣០៨)

- គេមិនបានសុំអ្វីម៉្យាងអំពើលាកេឡើយលើកែលងែតែលាកផ្តល់ឱ្យទាំងអស់។ មានបុរសម្នាក់បានមកជួបលោក លោកក៏បានផ្តល់ឱ្យបុរសនោះនូវសត្វព



> មានហើយណាពីមូហាំម៉ាត់ជាមនុស្សដែលយុត្តិធម៌បំផុតមិនថាជាមួយនឹងសាច់ញាតិឬក៏ស្រតូវឡើយ។

ព្រៃពាសពេញចន្លោះភ្នំទាំងពីរ។ ពេលបុរសម្នាក់នោះបានត្រឡប់ទៅជួបក្រុមរបស់គាត់វិញ ក៏បាននិយាយថា(ឱក្រុមរបស់យើង! ចូរពួកអ្នកចូលឥស្លាមចុះ ពិតណាស់មូហាំម៉ាត់ បានធ្វើការបរិច្ចាគដោយមិនខ្លាចភាពក្រីក្រឡើយ)។(មូស្លីម ២៣១២)

- មាននេគយក្របាក់ ៨០ពាន់ឌីរហាំមកឱ្យលោក ហើយបានដាក់ចំនួនទឹកប្រាក់នោះនៅលើគ្រែ បន្ទាប់មកលោកក៏បានបែងចែកប្រាក់ទាំងនោះ ហើយគ្មានអ្នកសុំណាម្នាក់ងាកចេញឡើយ លើកលែងត្រាតែប្រាក់នោះអស់។(អាល់ហាគីម ៥៤២៣)
- មានបុរសម្នាក់មកជួបលោកហើយក៏បានសុំលោក លោកក៏បានមានបន្ទូលថា(ខ្ញុំគ្មានអ្វីនោះទេ ក៏ប៉ុន្តែអ្នកតាមខ្ញុំមកប្រសិនបើយើងបានទទួលអ្វីម្យ៉ាងយើងនឹងផ្តល់វាឱ្យអ្នក)(មាននិយថាយើងនឹងទិញអ្វីដែលអ្នកត្រូវការហើយវាគឺជាការទូទាត់របស់ខ្ញុំ) អូម៉ើត បាននិយាយថា( ឱរ៉សូលុលឡោះ! អល់ឡោះមិនបានធ្វើឱ្យវាចាំបាច់សម្រាប់អ្នកដើម្បីធ្វើអ្វីមួយដែលហួសពីសមត្ថភាពរបស់អ្នកឡើយ)ហើយណាពីក៏មានការអន់ចិត្តនឹងសំដើនេះ ហើយបុរសនោះក៏បាននិយាយថា(ចូរបរិច្ចាកទានចុះ ហើយអ្នកកុំខ្លាចភាពក្រីក្រ អល់ឡោះមិនធ្វើឱ្យទ្រព្យសម្បត្តិរបស់អ្នកថយចុះឡើយ)ហើយណាពីក៏បានញញឹមហើយមុខរបស់គាត់ពោពេញដោយសេចក្តីសប្បាយរីករាយ(អាល់អាហាទីសអាល់មូខតើរ៉ះ ៨៨)
- ពេលដែលណាព្វីត្រឡប់មកពីសមរភូមិ ហូណៃន ពួកកុលសម្ព័ន្ធបេឌូអ៊ីនដែលទើបចូលឥស្លាមថ្មីបានមកទាមទារពីណាពី នូវចំណែករបស់ពួកគេ អំពីជ័យភណ្ឌនៃសង្គ្រាម។ ពួកគេបានព័ទ្ធជុំវិញលោក ហើយនាំលោកទៅកន្លែងដើមឈើ ហើយពួកគេក៏បានចាប់ក្រន្ធាក់យកអាវធំរបស់លោក ណាពីក៏បានក្រោកឈរហើយមានបន្ទូលថា«សូមឱ្យអាវធំរបស់ខ្ញុំត្រឡប់មកវិញ ប្រសិនបើខ្ញុំមានសត្វអូដ្ឋជាច្រើនដូចជាដើមឈើ [នៅជុំវិញនេះ] ខ្ញុំនឹងចែកឱ្យពួកអ្នកទាំងអស់គ្នា ដើម្បីឱ្យអ្នកដឹងផងដែរថាខ្ញុំមិនមែនកំណាញ់ឬបោកបញ្ឆោតឬកំសាកឡើយ»)

ពិតណាស់ណាពីមូហាំម៉ាត់បានលើកយកឧទាហរណ៍ដ៏អស្ចារ្យនៃសីលធម៌ល្អមានគ្រប់វិស័យទាំងអស់នៃជីវិត





# ជីវិតថ្មីរបស់អ្នក

# 12

ពិតណាស់ខណៈពេលដែលមនុស្សបានចូលសាសនាឥស្លាម វាជាឱកាសដ៏អស្ចារ្យបំផុតនៃជីវិតរបស់គាត់។ ហើយវាជាការចាប់កំណើតយ៉ាងពិតប្រាកដរបស់គាត់ ដែលបានធ្វើឱ្យដឹងក្រោយអំពីវានូវមូលហេតុដែលមានវានៅក្នុងជីវិត និងត្រូវធ្វើដូចម្តេចដើម្បីមានជីវិត និងការរស់នៅដោយអនុវត្តតាមច្បាប់សាសនាឥស្លាមដែលពេញទៅដោយភាពអច្ឆរិយៈ។

## មាតិកាជំពូក

តើធ្វើដូចម្តេចដើម្បីចូលសាសនាឥស្លាម?
ការទទួលស្គាល់កំហុស
ថ្លែងអំណរគុណដល់ ផលបុណ្យនៃការចង្អុលបង្ហាញនិងការទទួលស្គាល់កំហុស

- ការអំពាវនាវទៅកាន់សាសនាឥស្លាម
- គុណសម្បត្តិនៃការអំពាវនាវទៅរកអល់ឡោះ
- របៀបអំពាវនាវដែលត្រឹមត្រូវ

ការអំពាវនាវក្រុមគ្រួសារ
ការចូលឥស្លាមរបស់ក្មេងៗ
ការផ្តូរឈ្មោះបន្ទាប់ពីចូលឥស្លាម
លក្ខណៈនៃភាពស្អាតស្អំ (ស៊ូណានូលហ្វីតេរ៉ាៈ)

## > តើធ្វើដូចម្តេចដើម្បីចូលសាសនាឥស្លាម?

ដើម្បីចូលក្នុងសាសនាឥស្លាមចាំបាច់ត្រូវពោលសេចក្តីជំនឿពីរឃ្លា(ស្មើហោឌុំតែន)ជាមួយនឹងការយល់ពីអត្ថន័យរបស់វា និងជឿជាក់នឹងវានិងអនុវត្តតាមភស្តុតាងវា ហើយសេចក្តីជំនឿទាំងពីរនោះគឺ:

1. أشهد أن لا إله إلا الله ខ្ញុំធ្វើសាក្សីថាគ្មានទេម្ចាស់ដែលពិតត្រូវគេគោរពសក្ការៈក្រៅពីអល់ឡោះ (មានន័យថាខ្ញុំធ្វើសាក្សីនិងជឿជាក់ថាគ្មានទេម្ចាស់ដែលពិតត្រូវគេគោរពសក្ការៈក្រៅពីអល់ឡោះហើយខ្ញុំគោរពសក្ការៈគាត់តែម្នាក់គត់ដោយខ្ញុំមិនធ្វើស្ហ៊ីរិកជាមួយគាត់ឡើយ).

2. وأشهد أن محمداً رسول الله ហើយខ្ញុំធ្វើសាក្សីទៀតថាមូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ( មានន័យថាខ្ញុំធ្វើសាក្សីថាមូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះមកកាន់មនុស្សទាំងអស់។ ត្រូវប្រតិបត្តិតាមការបញ្ជាប្រើរបស់លោក ជៀសវាងបម្រាមដែលលោកហាមឃាត់ ហើយខ្ញុំគោរពសក្ការៈទៅចំពោះអល់ឡោះដោយអនុវត្តតាមច្បាប់របស់លោកនិងអ្វីដែលលោកបាននាំមក) ។( មើលក្នុងទំព័រ )

### ការងូតទឹកស្រមាប់អ្នកចូលឥស្លាមថ្មី

ពិតណាស់ខណៈពេលដែលមនុស្សបានចូលសាសនាឥស្លាមវាជាឱកាសដ៏អស្ចារ្យបំផុតនៃជីវិតរបស់គាត់។ ដែលជាការចាប់កំណើតយ៉ាងពិត្របាកដរបស់គាត់ ដែលបានធ្វើឱ្យដឹងក្រោយអំពីវា នូវមូលហេតុដែលមានវានៅក្នុងជីវិតនេះ ហើយគេបានកំណត់ជាមួយនឹងការចូលក្នុងសាសនាមួយនេះផងដែរ ដោយការងូតទឹកនិងស្រោចទឹកឱ្យស្ពេញខ្លួនប្រាណ ប្រៀបដូចជាគាត់បានសអាតចិត្តរបស់គាត់ពីបការស្ហ៊ីរិកនិងបការអាក្រក់ គប្បីគាត្រូវសំអាតខ្លួនប្រាណរបស់គាត់ដោយងូតទឹកផងដែរ។.

ហើយណាពីបានប្រើ សហាហ្ពះម្នាក់នៅពេលដែលគាត់ចង់ចូលឥស្លាម ឱ្យគាត់ទៅងូតទឹក។(អាល់បៃហាគី ៨៣៧)



## > ការទទួលសារភាពកំហុស

ការទទួលសារភាពកំហុសគឺជាការត្រឡប់ទៅរកអល់ឡោះ ﷻ ម្នាក់ៗ មនុស្សដែលបានប្រព្រឹត្តអំពើអាក្រក់ឬប្រឆាំងនឹងទ្រង់ហើយត្រឡប់ទៅរកអល់ឡោះវិញដោយភាពស្មោះស្ម័គ្រនឹងទ្រង់ដោយចិត្តរបស់គាត់ នោះហើយគឺជាការទទួលសារភាពកំហុសទៅចំពោះអល់ឡោះ។

អ្នកមូស្លីមគ្រប់រូបចាំបាច់ត្រូវទទួលសារភាពកំហុសនិងសុំអភ័យទោសនៅគ្រប់ដំណាក់កាលនៃជីវិតរបស់គាត់ ដោយសារតែមនុស្សជាធម្មតាតែងតែធ្វើខុស ហើយរាល់ពេលដែលគេប្រព្រឹត្តខុស ច្បាប់បានចែងឱ្យគាត់សុំការអភ័យទោសពីអល់ឡោះ និងទទួលសារភាពកំហុសទៅចំពោះអល់ឡោះ។

### តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីឱ្យការទទួលសារភាពកំហុសបានត្រឹមត្រូវ?

ការទទួលសារភាពកំហុសអំពីបាបកម្មទាំងអស់ មានដូចជាការប្រឆាំង នឹងប្រការស្ទីរិកចាំបាច់ត្រូវប្រង្គប់រាល់លក្ខខណ្ឌទាំងអស់ដើម្បីឱ្យគេទទួលយកនិងត្រឹមត្រូវ។ ហើយលក្ខខណ្ឌទាំងនោះមានដូចជា:

**1** ត្រូវបញ្ឈប់ការប្រព្រឹត្តអំពើបាបកម្ម

ការទទួលសារភាពកំហុសមិនបានត្រឹមត្រូវទេបើការប្រព្រឹត្តអំពើបាបកម្មនៅតែបន្តក្នុងពេលទទួលសារភាពកំហុសនោះ រីឯការត្រឡប់ទៅប្រព្រឹត្តអំពើបាបកម្មបន្ទាប់ពីការទទួលកំហុសបានត្រឹមត្រូវហើយនោះ ការទទួលសារភាពកំហុសពីមុននោះមិនត្រូវបានខូចខាតនោះទេ ក៏ប៉ុន្តែចាំបាច់ឱ្យគេនោះធ្វើការទទួលសារភាពកំហុសសារជាថ្មី។.

**2** ការសោកស្តាយចំពោះការប្រព្រឹត្តអំពើបាបកម្មដែលកន្លងផុតមក

មិនអាចក្លាយជាការទទួលសារភាពកំហុសដ៏ត្រឹមត្រូវនោះទេ លើកលែងត្រប្រព្រឹត្តទៅដោយមានអារម្មណ៍សោកស្តាយ ទុក្ខព្រួយ នឹងការសូមអភ័យទោសចំពោះអំពើបាបដែលបានប្រព្រឹត្តកន្លងផុតមក។ គេមិនរាប់ជាការសោកស្តាយឡើយប្រើគាត់នៅតែគបាននិយាយអំពីអំពើបាបពីអតីតកាលរបស់គាត់ និងបាននៅកែញក នឹងបង្ហាញអំពីទង្វើទាំងនោះ។ដូចេនះហើយបានជារ៉សូលុលឡោះបានមានប្រសាសន៍ថា "ការសោកស្តាយគឺជាការទទួលសារភាពកំហុស" ។( អ៊ិពនូម៉ាយ៉ះ ៤២៥២ )

**3** ការប្តេជ្ញាចិត្តមិនវិលត្រឡប់ទៅប្រព្រឹត្តវាទៀត

ការទទួលសារភាពកំហុសមិនបានត្រឹមត្រូវទេ ដរាបណាបុគ្គលនោះនៅតែមានបំណងត្រឡប់ទៅប្រព្រឹត្តអំពើបាបក្រោយអំពីការទទួលសារភាពកំហុសនោះ។.

### ផែនការដើម្បីសម្រេចការប្តេជ្ញាចិត្ត

- វាជាការសន្យាជាមួយនិងខ្លួនឯងមិនឱ្យត្រឡប់ទៅប្រព្រឹត្តអំពើដែលបានធ្វើកន្លងផុតមកទោះបីជាមានឱកាសមួយប្រពិចែភ្នកក្នុងកាលៈទេសៈនិងឧបសគ្គណាកើដោយ។ ហើយពិត្របាកដណាស់ណាពីបានមានប្រសាសន៍ថា( ប្រើបការ ជនណាហើយមានប្រើបការនេះនិងទទួលបានរសជាតិនៃជំនឿ ( ហើយគាត់បាននៀបរាប់នៅក្នុងវានោះ ) ការស្អប់ខ្ពើមមិនចង់វិលត្រឡប់ទៅជាអ្ន



កគ្មានជំនឿវិញ បន្ទាប់ពីអល់ឡោះបានរំដោះគេពីវានោះ ដូចជាគេស្អប់ខ្ពើមមិនចង់ឱ្យគេបោះបញ្ចូលទៅក្នុងភ្លើងនរក) ។(អាល់ពូខរី ២១ ម៉ូស្លីម ៤៣)

- ចេញឱ្យឆ្ងាយពីមនុស្សឬទីកន្លែងដែលធ្វើឱ្យជំនឿរបស់គាត់ចុះខ្សោយ ហើយបានល្បួងគាត់ឱ្យប្រព្រឹត្តអំពើបាប។.
- បញ្ជើនការបួងសួង( ឌូអា) ទៅចំពោះអល់ឡោះ ឱ្យនៅនឹងនរក្នុងសាសនារបស់គាត់រហូតដល់ស្លាប់ ទោះបីជានៅក្នុងទ្រង់ទ្រាយនិងភាសាណាមួយក៏ដោយ។ ដូចជាមានេនៅក្នុង គួរអាន និងហាឌីស។
    - ឱម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំបែរចិត្តរបស់ពួកយើង ក្រោយពេលដែលទ្រង់បានចង្អុលបង្ហាញដល់ពួកយើងហើយនោះ។( ស៊ូរ៉ោះ អាលីអ៉ីមរ៉ន ឃ្លា ៨)
    - ឱអ្នកដែលបង្វែចិត្ត ! សូមទ្រង់ធ្វើអោយចិត្តរបស់ខ្ញុំនៅនឹងនរក្នុងសាសនារបស់ទ្រង់ផងចុះ។(អាត់តៀតមីហ្ស៊ី ២១៤០)

## តើមានអ្វីកើតឡើងបន្ទាប់ពីការទទួលសារភាពកំហុស?

នៅពេលដែលមនុស្សម្នាក់បានទទួលសារភាពកំហុសនិងផ្លាស់ប្តូរចិត្ត ពិត្រប្រាកដណាស់អល់ឡោះនិងអភ័យទោសនូវបាបកម្មវាទាំងអស់ទោះបីជាបាបកម្មនោះធំឬខ្លាំងខ្លាយ៉ាងណាក៏ដោយ ក្តីមេត្តាករុណារបស់អល់ឡោះរីកសាយរាល់អ្វីគ្រប់យ៉ាង។ ដូចដែលអល់ឡោះបានមានបន្ទូលថា( ចូរអ្នក( ណាពីមូហាំម៉ាត់) ពោលថាៈ ឱខ្ញុំទាំងឡាយរបស់យើងដែលបានបំពានលើខ្លួនឯង! ចូរពួកអ្នកកុំអស់សង្ឃឹមចំពោះក្តីមេត្តាករុណារបស់អល់ឡោះឱ្យសោះ។ពិត្រប្រាកដណាស់ អល់ឡោះនឹងអភ័យទោសនូវរាល់ទោសកំហុសទាំងអស់។ពិត្រប្រាកដណាស់អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិត្រសឡាញ់)។( ស៊ូរ៉ោះ អាស់ហ្ស៊ូមើត ឃ្លា ៥៣)

ជនមូស្លីមបន្ទាប់ពីបានទទួលសារភាពកំហុសដោយស្មោះស្ម័គ្រ ត្រឹមត្រូវ បាបកម្មអ្វីសោះនៅលើគាត់ ជាការពិតណាស់អល់ឡោះប្រទានរង្វាន់ដល់បណ្តាលអ្នកដែលសច្ចៈ និងបណ្តាលអ្នកដែលគោរពប្រតិបត្តិ និងបណ្តាអ្នកដែលសោកស្តាយដែលមានការសោកស្តាយពិត្រប្រាកដនូវរង្វាន់ដ៏អស្ចារ្យ ដោយផ្លាស់ប្តូរអំពើអាក្រក់របស់ពួកគេទៅជាអំពើល្អវិញ។អល់ឡោះបានមានបន្ទូលថា( លើកលែងតែអ្នកណាដែលបានសារភាពកំហុស និងមានជំនឿ ព្រមទាំងបានសាងនូវអំពើល្អត្រឹមត្រូវ គឺអ្នកទាំងនោះហើយដែលអល់ឡោះនឹងប្តូរអំពើអាក្រក់របស់ពួកគេទៅជាអំពើល្អវិញ។ហើយអល់ឡោះមហាអភ័យទោស មហាអាណិត្រសលាញ់។

ជនណាហើយដែលស្ថិតនៅក្នុងស្ថានភាពនេះ ចូរខិតខំប្រឹងប្រែងក្នុងការថែទាំការទទួលសារភាពកំហុសនោះ និងខិតខំព្យាយាមឱ្យកាន់តែខ្លាំងខ្លាដើម្បីជៀសវាងពីការធ្លាក់ចូលក្នុងអន្ទាក់របស់ស្ហូតនដែលនាំឱ្យមានការបរាជ័យ។

## រសជាតិនៃជំនឿ

ជនណាហើយដែលស្រលាញ់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ដែលជាការស្រលាញ់ដ៏ខ្លាំងខ្លាបំផុតស្រមាប់ខ្លួនគាត់ ហើយក៏បានក្លាយជាអ្នកដែលស្រលាញ់អ្នកដទៃទៅតាមលទ្ធភាពដើម្បី បញ្ជិតខ្លួនពួកគេទៅចំពោះអល់ឡោះ និងមានភាពត្រឹមត្រូវនៃសាសនារបស់ពួកគេ និងឥស្លាមរបស់ពួកគេ។ ហើយគាត់បានក្លាយជាអ្នកដែលស្អប់ខ្ពើមការត្រឡប់ទៅរកអ្វីដែលគាត់បានធ្វើពីមុន ដូចជាការគ្មានជំនឿ ការស្ទីរិក និងការវង្វេង ដូចដែលគាត់បានស្អប់ខ្ពើមការដុតដោយភ្លើង។ នៅក្នុងខណៈពេលនោះគាត់នឹងទទួលបានស្រមាប់ជំនឿនោះ នូវភាពផ្អែមល្ហែមនិងរសជាតិនៅក្នុងចិត្តរបស់គាត់ ដូចដែលគាត់ទទួលបានភាពជឿតស្និតទៅចំពោះអល់ឡោះ និងទំនុកចិត្ត និងសុភមង្គលក្នុងការគោរពតាមច្បាប់របស់អល់ឡោះនិងគុណបុណ្យរបស់អល់ឡោះមកលើគាត់ដោយបានចង្អុលបង្ហាញផ្លូវត្រឹមត្រូវ។ដូចដែលរ៉សូលុលឡោះបានមានប្រសាសន៍ថា( ប្រការ ជនណាមានប្រការនេះគេនឹងទទួលបានរសជាតិនៃជំនឿ គឺការស្រលាញ់អល់ឡោះនិងរ៉សូលរបស់ទ្រង់ជាងអ្នកដទៃ ការស្រលាញ់រាប់អានបុគ្គលណាម្នាក់គឺគ្មានដើម្បីអ្វីក្រៅពីអល់ឡោះ និងការស្អប់ខ្ពើមមិនចង់វិលត្រឡប់ទៅជាអ្នកគ្មានជំនឿវិញបន្ទាប់ពីអល់ឡោះបានរំដោះគេដូចជាគេស្អប់ខ្ពើមមិនចង់អោយគេបោះបញ្ចូលក្នុងនរក)។(រាយការណ៍ដោយ អាល់ពូខរី ២១ ម៉ូស្លីម ៤៣)

## > ការថ្លែងអំណរគុណទៅចំពោះគុណបុណ្យនៃការចង្អុលបង្ហាញនិងការទទួលសារភាពកំហុស

អំពីសកម្មភាពៃដលអស្ចារ្យរបស់អ្នកមូស្លីមេដើម្បីថ្លែងអំណរគុណដល់គុណបុណ្យរបស់អល់ឡោះដែលបានឱ្យគេទទួលសារភាពកំហុសនិងការចង្អុលបង្ហាញនោះ:

### 1 ប្រកាន់ខ្ជាប់និងសាសនាហើយអត់ធ្មត់និងប្រការលំបាកក្នុងវា

ជនណាហើយដែលមានទ្រព្យសម្បត្តិវិសេសវិសាល គេនិងប្រុងប្រយ័ត្នក្នុងការថែរក្សាវា មិនឱ្យវាធ្លាក់ទៅក្នុងដៃពួកអ្នករំលោភបំពាន និងពពួកចោរ និងការពារវាពីអ្វីគ្រប់យ៉ាងដែលប៉ះពាល់ដល់វា។ ហើយសាសនាឥស្លាមគឺជាអំណោយទានដែលអស្ចារ្យបំផុតសម្រាប់មនុស្សលោកទាំងអស់ ហើយវាមិនមែនគ្រាន់តែជាការផ្តល់ដល់គាត់នូវផ្នត់គំនិតមួយ ឬចំណង់ចំណូលចិត្តដែលមនុស្សចង់អនុវត្តន៍នៅពេលណាក៏បាននោះទេ ប៉ុន្តែសាសនាមានវិធានការរាល់អ្វីទាំងអស់ក្នុងជីវិតរបស់គាត់ ទាំងសកម្មភាពរបស់វានិងភាពស្ងាត់ស្ងៀមរបស់វា ដូច្នេះអល់ឡោះបានមានបន្ទូលទៅកាន់រ៉សូលរបស់គាត់ដោយប្រើឱ្យគាត់ប្រកាន់ខ្ជាប់យ៉ាងខ្ជាប់ខ្ជួននឹងសាសនាឥស្លាម និងគម្ពីគួរអាន ហើយមិនត្រូវបោះបង់វាជាដាច់ខាតពីព្រោះវាស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវ: (ដូច្នេះ ចូរពួកអ្នកកាន់ឱ្យបានខ្ជាប់ខ្ជួននូវអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះឱ្យអ្នក។ពិតប្រាកដណាស់ អ្នកកំពុងស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវ)។(សូរ៉ោះអាហ្សហ្សុខរ៉ូហ្វ ឃ្លា៤៣) ចាំបាច់អ្នកមូស្លីមមិនគួរមានការព្រួយបារម្ភណ៍ប្រសិនបើគាត់បានជួបប្រទះការសាកល្បងណាមួយបន្ទាប់ពីគាត់បានចូលឥស្លាម ហើយនេះគឺជាផែនការរបស់អល់ឡោះដើម្បីសាកល្បង ហើយខ្លះៗអំពីពួកគេគឺជាអ្នកដែលល្អប្រសើរជាងពួកយើងពួកគេត្រូវបានគេសាកល្បងអំពីការលំបាកយ៉ាងធ្ងន់ធ្ងរហើយពួកគេក៏បានអត់ធ្មត់និងពុះពាររាល់ឧបសគ្គ ហើយពួកគេនោះគឺជាបណ្តាណាពី(អ្នកនាំសារ)របស់អល់ឡោះ ដែលអល់ឡោះបានប្រាប់យើងអំពីរឿងរ៉ាវរបស់ពួកគាត់ ហេតុអ្វីបានជាពួកគាត់បានជួបប្រទះទុក្ខលំបាកជាច្រើនលើសលុបនៅក្នុងដៃរបស់អ្នកដែលនៅជិតខ្លួនគាត់មុននិងអ្នកដែលនៅឆ្ងាយពីគាត់។ហើយពួកគាត់មិនបាក់ទឹកចិត្តនូវអ្វីដែលបានកើតឡើងចំពោះពួកគាត់ក្នុងមាគ៌ារបស់អល់ឡោះឡើយ ហើយពួកគាត់មិនមានការផ្លាស់ប្តូរនិងមិនមានការប្រែប្រួលឡើយ។វាគឺជាការសាកល្បងអំពីអល់ឡោះដើម្បីដឹងអំពីសេចក្តីជំនឿដ៏ស្មោះត្រង់របស់អ្នក និងការជឿជាក់យ៉ាងមុតមាំរបស់អ្នក ចូរស្ថិតនៅលើកិច្ចព្រមព្រៀងនៃការសាកល្បងនេះ ហើយកាន់ឱ្យខ្ជាប់ខ្ជួននិងសាសនានេះ ហើយចូរបួងសួងទៅចំពោះអល់ឡោះ ដូចដែលណាពីមូហាំម៉ាត់បានបញ្ជ្រើនក្នុងការបួងសួងដោយគាត់បានមានប្រសាសន៍ថា «يا مقلب القلوب ثبت قلبي على دينك» មានន័យថា(ឱអ្នកដែលបង្វែចិត្ត ! សូមទ្រង់ធ្វើអោយចិត្តរបស់ខ្ញុំនៅនឹងនរក្នុងសាសនារបស់ទ្រង់ផងចុះ)។(រាយការណ៍ដោយ អាត់តៀតមីហ្ស៊ី ២១៤០) ហើយនៅក្នុងន័យនេះដែរអល់ឡោះក៏បានមានបន្ទូលថា (តើមនុស្សលោកគិតថា ពួកគេត្រូវគេបណ្តោយឱ្យនិយាយថា ពួកយើងបានជឿហើយ ដោយពួកគេមិនត្រូវបានគេសាកល្បងឬ? ហើយជាការពិតណាស់ យើងបានសាកល្បងអ្នកជំនាន់មុនពួកគេរួចមកហើយ។ហើយអល់ឡោះដឹងបំផុតបណ្តាអ្នកដែលទៀងត្រង់ និងដឹងបំផុតចំពោះពួកដែលភូតកុហក)។(សូរ៉ោះអាល់អាំងកាពូត ឃ្លា២-៣)

### 2 ឧស្សាហ៍ព្យាយាមក្នុងការអំពាវនាវមនុស្សទៅរកឥស្លាមដោយគតិបណ្ឌិត និងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អ

វាគឺជាមាគ៌ាដ៏អស្ចារ្យក្នុងការថ្លែងអំណរគុណទៅចំពោះគុណបុណ្យនៃសាសនាឥស្លាមដែលបានផ្តល់ឱ្យមនុស្ស ក៏ដូចជាវាជាមូលហេតុដ៏អស្ចារ្យដែលធ្វើឱ្យមានការនឹងនរនៅក្នុងសាសនារបស់អល់ឡោះ។ ជនណាហើយដែលវាបានរួចផុតជីវិតពីជំងឺដ៏គ្រោះថ្នាក់ ហើយជម្រះរាងកាយរបស់គេពីជំងឺដែលមើលមិនជាយូរមកហើយដែលនៅជាប់ជាមួយនឹងគេហើយបានបំផ្លាញពេលវេលាទាំងថ្ងៃទាំងយប់របស់គេ ហើយបន្ទាប់មកក៏បានរកឃើញវិធីសាស្ត្រសម្រាប់ការព្យាបាលជំងឺនោះមានហើយមនុស្សនិងយកចិត្តទុក្ខដាក់ក្នុងការផ្សព្វផ្សាយវាទៅឱ្យមនុស្សដទៃទៀត និងជាពិសេសរវាងក្រុមគ្រួសារនិងសាច់ញាតិនៃមនុស្សដែលគាត់ស្រឡាញ់។ហើយវាគឺជាអ្វីដែលនឹងត្រូវបានបកស្រាយដូចខាងក្រោម:

## > ការអំពាវនាវទៅកាន់សាសនាឥស្លាម

### គុណសម្បត្តិនៃការអំពាវនាវទៅរកអល់ឡោះ

ការអំពាវនាវទៅរកអល់ឡោះវាជាកិច្ចការដ៏ល្អប្រសើមួយនិងជាការបញ្ចិតខ្លួនដ៏អស្ចារ្យទៅចំពោះអល់ឡោះ ហើយក៏មានការសរសើរនៅក្នុងគម្ពីគួរអាន និងហាឌីសទៅលើវាផងដែរ:

1 ការអំពាវនាវទៅរកអល់ឡោះវាគឺជាមាគ៌ាដែលនាំទៅរកភាពជោគជ័យ និងជ័យជំនះទាំងនៅលើផនដី និងថ្ងៃបរលោក។ដូចអល់ឡោះបានមានបន្ទូលថា (ហើយចូរឱ្យមានក្រុមមួយក្នុងចំណោមពួកអ្នកអំពាវនាវទៅរកផ្លូវល្អ និងប្រើគ្នាឱ្យធ្វើប្រការដែលត្រឹមត្រូវ( តាមច្បាប់ឥស្លាម) និងហាមឃាត់គ្នាអំពីប្រការអាក្រក់។ហើយអ្នកទាំងនោះគឺជាអ្នកដែលជោគជ័យ)។(សូរ៉ោះ អាលីអ៊ិមរ៉ន ឃ្លា១០៤)

2 ពាក្យសំដីរបស់អ្នកអំពាវនាវវាជាពាក្យសំដីដែលល្អប្រសើរបំផុត និងជាពាក្យសំដីដែលអល់ឡោះស្រលាញ់ជាងគេ។ ដូចែដលអល់ឡោះបានមានបន្ទូលសសើរទៅចំពោះពាក្យសំដីរបស់អ្នកអំពាវនាវថា (ហើយគ្មានអ្នកណាម្នាក់ដែលមានពាក្យសំដីល្អប្រសើរជាងអ្នកដែលបានអំពាវនាវទៅចំពោះអល់ឡោះ និងបានសាងអំពើល្អត្រឹមត្រូវព្រមទាំងបាននិយាយថា:
ពិតប្រាកដណាស់ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមអ្នកមូស្លីមទាំងឡាយនោះ)។(សូរ៉ោះ ហ្វូសស៊ុឡាត់ ឃ្លា៣៣)។ហើយគ្មានពាក្យសុំដីណាដែលល្អជាងពាក្យសំដីរបស់គាត់ឡើយ ហើយវាជាការណែនាំមនុស្ស និងការនាំផ្លូវពួកគេទៅរក ការគោរពសក្ការៈចំពោះម្ចាស់របស់ពួកគេ អ្នកបង្កើតពួកគេ អ្នកគ្រប់គ្រងពួកគេ អ្នកបញ្ចេញពួកគេពីភាពងងឹតប្រការស្ទើរកុំ ទៅរកភាពមានពន្លឺមានជំនឿ។.

3 ការអំពាវនាវ ជាការគោរពប្រតិបត្តិទៅតាមបទបញ្ជារបស់អល់ឡោះ។ ដូចែដលអល់ឡោះបានមានប្រសាសន៍ថា( ចូរអ្នក( ណាពីមូហាំម៉ាត់ )ពាវនាវ( មនុស្សលោក )ទៅកាន់មាគ៌ានៃម្ចាស់របស់អ្នកដោយគតិបណ្ឌិតនិងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អចុះ ហើយចូរអ្នកជជែកជាមួយពួកគេតាមមធ្យោបាយណាដែលល្អបំផុត )។(សូរ៉ោះ អាន់ណះល៍ ឃ្លា១២៥)។ ហើយចាំបាច់សម្រាប់អ្នកដែលអំពាវនាវទៅរកសាសនាឥស្លាមនោះ ត្រូវអំពាវនាវដោយគតិបណ្ឌិត ហើយនិងចាត់ចែងកិច្ចការឱ្យចំកន្លែងរបស់វា និងដឹងអំពីស្ថានភាពអ្នកដែលត្រូវអំពាវនាវនិងអ្វីដែលសាកសមស្រមាប់ពួកគេ ហើយនិងអ្វីដែលពួកគេត្រូវការវា ដោយការប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អ ហើយនិងសន្ទនាជាមួយពួកគេតាមមាគ៌ាដែលល្អបំផុត និងភាពទន់ភ្លន់ និងបញ្ចិតខ្លួន ដើម្បីចង្អុលបង្ហាញភាព្រត៏ម្រតូវដល់ពួកេគ។.

4 ពិតណាស់ការអំពាវនាវវាជាភារកិច្ចរបស់បណ្ដាអ្នកនាំសារគ្រប់រូប អ្នកដែលសំខាន់ជាងគេនោះគឺអ្នកនាំសាររបស់ពួកយើងណាពីមូហាំម៉ាត់ អល់ឡោះបានបញ្ជូនគាត់មកដើម្បីធ្វើជាសាក្សីទៅលើមនុស្សលោក និងជាអ្នកផ្ដល់ដំណឹងរីករាយស្រមាប់អ្នកដែលមានជំនឿ អំពីឋានសួគ៌និងផលបុណ្យ។ ហើយនិងជាអ្នកដាស់តឿនព្រមានស្រមាប់អ្នកដែលគ្មានជំនឿ និងអ្នកដែលប្រឆាំង អំពីឋាននរក និងទណ្ឌកម្ម។
ហើយក៏ជាអ្នកអំពាវនាវទៅកាន់អល់ឡោះ និងផ្សព្វផ្សាយពន្លឺទៅដល់មនុស្សជាតិទាំងអស់។ ដូចែដលអល់ឡោះបានមានបន្ទូលថា( ឱណាពី( ណាពីមូហាំម៉ាត់ )! ពិត្រប្រាកដណាស់យើងបានបញ្ជូនអ្នកធ្វើជាសាក្សី និងជាអ្នកផ្ដល់ដំណឹងរីករាយ ហើយនិងជាអ្នកដាស់តឿនព្រមាន។ ហើយក៏ជាអ្នកអំពាវនាវ( មនុស្សលោក ) ទៅកាន់អល់ឡោះដោយការអនុញ្ញាតរបស់ទ្រង់ និងជាពន្លឺដើម្បីបំភ្លឺ។ ហើយចូរអ្នកផ្ដល់ដំណឹងរីករាយដល់បណ្ដាអ្នកមានជំនឿថា:ពិត្របាកដណាស់ ស្រមាប់ពួកគេគឺទទួលបានការប្រោសប្រទានដ៏ធំធេងពីអល់ឡោះ )។( សូរ៉ោះអាល់អះហ្សាប ឃ្លា ៤៥-៤៧ )

5 ការអំពាវនាវជាទ្វានៃអំពើល្អដែលមិនេចះដាច់ឡើយ។ ស្រមាប់បុគ្គលណាម្នាក់ែដលទទួលយកការអំពាវនាវរបស់អ្នក េហើយទទួលបានការចង្អុលបង្ហាញដាយែដរបស់អ្នក ពិតណាស់សម្រាប់អ្នកនឹងទទួលបានផលបុណ្យដូចជារូបេគែដរ ដោយការសុទ្ធាតរបស់េគការេគារពសក្ការៈរបស់េគ និងការបេង្រៀនរបស់េគេទាចំេពាះមនុស្ស។ នេះជាផលបុណ្យដ៏អស្ចារ្យែដលអល់ទ្បាះបានផ្តល់ដល់អ្នកអំពាវនាវ។ ណាពីបានមាន្រសបសាសន៍ថា (បុគ្គលណាចង្អុលបង្ហាញផ្លូវល្អដល់េគ គាត់និងទទួលផលបុណ្យដូចផលបុណ្យអ្នកែដលអនុវត្តតាមគាត់ ដោយេគមិនកាត់បន្ថយផលបុណ្យរបស់អ្នកែដលអនុវត្តតាមគាត់បន្តិចណាេទ្បើយ)។(មូស្លីម ២៦៧៤)

6 ផលបុណ្យអ្នកែដលអំពាវនាវេទារកអល់ទ្បាះល្អប្រេសើរជាងការសប្បាយទាំងអស់េនពិភពេលាកេនះ។ េហើយផលបុណ្យអ្នកអំពាវនាវគឺេនាេលើអល់ទ្បាះ ដោយេគមិនយកពីនរណាម្នាក់េទ្បើយ ដូេច្នះេហើវាជាផលបុណ្យដ៏អស្ចារ្យបំផុត អ្នកសប្បុរសេគមិនផ្តល់ឱ្យអ្នកណាែដលេគ្រសលាញ់េទេលើែលងែតជាមនុស្សអស្ចារ្យ ដូចអល់ទ្បាះបានមានបន្ទូលថា (ប៉ុែន្តប្រសិនេបើពួកអ្នកបាែនបេរចញ(ពីការអំពាវនាវរបស់ខ្ញុំ) ខ្ញុំពិតជាមិនេស្នើសុំែកម្រពីពួកអ្នកេទ្បើយ។ ែកម្ររបស់ខ្ញុំគឺែកម្រពីអល់ទ្បាះែតមួយគត់ េហើយខ្ញុំ្រតូវបានេគបង្គាប់ឱ្យក្លាយជាអ្នកែដលស្ថិតក្នុងចំណោមអ្នកមូស្លីម)។(សូេរ៉ាះ យូនូស ឃ្លា៧២)។ េហើយណាពីក៏បានមាន្របសាសន៍ថា (ប្រសិនេបើអល់ទ្បាះចង្អុលបង្ហាញនរណាម្នាក់(ឱ្យចូលឥស្លាម) តាមរយៈអ្នកេនាះ វាល្អប្រេសើរសម្រាប់អ្នកជាងសត្វអូដ្ឋពណ៌្រកហមេទៀតេទៀត)។(អាល់ពូខរី ២៨៤៧ មូស្លីម ២៤០៦).

## របៀបអំពាវនាវែដល្រតឹម្រតូវ

អល់ទ្បាះបានេរៀបរាប់ពីរេបៀបែនការអំពាវនាវែដល្រតឹម្រតូវ និងលក្ខណៈសម្បត្តិមួយចំនួនែដលមានភាពខុសែប្លកេពីគ វានោះដូចមានេនខាងេក្រាម:

1 ការេចះដឹងច្បាស់លាស់ ងចំេណះ

ដឹង ជាការចាំបាច់េទាេលើអ្នកអំពាវនាវមានេហើយគាត់ជាអ្នកមានចំេនះដឹងនិងអ្វីែដលគាត់អំពាវនាវេទារក។ ស្គាល់អ្វីែដលគាត់កំពុងនិយាយ ដូចអល់ទ្បាះបានមានបន្ទូលថា (ចូរអ្នក(ណាពីមូហាំម៉ាត់) េពាលថាៈនេះជាមាគ៌ារបស់ខ្ញុំ ែដលខ្ញុំអំពាវនាវេទាកាន់អល់ទ្បាះ ដោយមានការេចះដឹងច្បាស់លាស់ ខ្ញុំនិងអ្ន



ដែលបានដើរតាមខ្ញុំ(ត្រូវអំពាវនាវអ្នកផ្សេងទៀតទៅកាន់អល់ឡោះ)។ មានន័យថា ចូរអ្នកពោលទៅ ឱណាពី នេះជាមាគ៌ារបស់ខ្ញុំ និងការចង្អុលបង្ហាញរបស់ខ្ញុំ ខ្ញុំអំពាវនាវទៅកាន់អល់ឡោះ ដោយមានចំណេះដឹង និងការដឹងច្បាស់លាស់។ហើយវាជាមាគ៌ាអ្នកដែលបានដើរតាមខ្ញុំនៃអ្នកអំពាវនាវ។

ហើយការអំពាវនាវទៅកាន់អល់ឡោះ មិនចាំបាច់សម្រាប់តែអ្នកមូស្លីមដែលមានចំណេះដឹងច្រើននោះទេ។ នៅពេលណាដែលគេបានដឹងពីច្បាប់អ្វីមួយចាំបាច់ត្រូវតែអំពាវនាវទៅកាន់វា។ ហើយនៅពេលដែលអ្នកដឹងថាការគោរពសក្ការៈគឺសម្រាប់តែអល់ឡោះម្នាក់គត់ ចាំបាច់ត្រូវតែផ្សព្វផ្សាយវាទៅកាន់មនុស្ស ហើយនៅពេលដែលអ្នកដឹងអំពីភាពល្អរបស់សាសនាឥស្លាម ចាំបាច់អ្នកផ្សព្វផ្សាយវាទៅកាន់មនុស្ស សូម្បីតែវានោះមួយឃ្លាអំពីអាល់គួរអានក៏ដោយ ដូចណាពីបានមានប្រសាសន៍ថា (ចូរពួកអ្នកផ្សព្វផ្សាយអំពីខ្ញុំ ទោះបីជាមួយវាក្យខណ្ឌក៏ដោយ)។(អាល់ពូខរី ៣២៧៤)

ដូច្នេះ មានហើយបណ្ដាសហាហ្ពះដែលបានចូលឥស្លាមដោយដៃរបស់ណាពី ហើយពួកគេបានរៀនពីគោលការណ៍នៃសាសនាឥស្លាមនិងគោលគ្រឹះរបស់វានៅក្នុងពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់មកពួកគេក៏ត្រឡប់ទៅក្រុមរបស់ពួកគេ ហើយក៏អំពាវនាវពួកគេឱ្យចូលឥស្លាម ហើយពួកគេក៏មានការចាប់អារម្មណ៍ចង់ចូលឥស្លាមហើយដោយសារសីលធម៌ល្អរបស់ពួកគាត់ធ្វើឱ្យមនុស្សមានចំណាប់អារម្មណ៍ក្នុងការចូលសាសនាឥស្លាម

## 2 អំពាវនាវដោយគតិបណ្ឌិត

អល់ឡោះបានមានបន្ទូលថា (ចូរអ្នក(ណាពីមូហាំម៉ាត់) អំពាវនាវ(មនុស្សលោក)ទៅកាន់មាគ៌ានៃម្ចាស់របស់អ្នកដោយគតិបណ្ឌិត និងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អចុះ ហើយចូរអ្នកជជែកជាមួយពួកគេតាមមធ្យោបាយណាដែលល្អបំផុត)។(ស៊ូរ៉ោះ អាន់ណះល៍ ឃ្លា ១២៥) គតិបណ្ឌិត គឺសកម្មភាពដែលចាំបាច់ធ្វើទៅតាមមាគ៌ា



ដែលសមរម្យ ជាមួយនឹងការជ្រើសរើសពេលវេលានិងទីកន្លែងសមរម្យ។.

មនុស្សមានលក្ខណៈខុសគ្នារវាងធម្មជាតិរបស់ពួកគេ និងកូនសារបេះដូងរបស់ពួកគេ និងខុសគ្នានៅក្នុងសមត្ថភាពរបស់ពួកគេក្នុងការយល់ដឹងនិងការទទួលបាន។ ស្រមាប់អ្នកអំពាវនាវត្រូវតែជ្រើសរើសវិធីសាស្ត្រដែលសមរម្យស្រមាប់ពួកគេ ដោយការឆក់យកឱកាសមានឥទ្ធិពលបំផុតនៅក្នុងជីវិតរបស់ពួកគេ។

ហើយទាំងអស់វានោះគឺដោយភាពទន់ភ្លន់និងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អ និងចិត្តមេត្តាករុណានិងក្ដីអាណិតស្រលាញ់ចំពោះពួកអ្នកដែលយើងអំពាវនាវ និងការពិភាក្សាស្ងប់ស្ងាត់និងមានតុល្យភាពដែលមិនធ្វើឱ្យមានការឈ្លើចាប់ និងការជំរុញឱ្យស្អប់។ ដូច្នេះហើយ អល់ឡោះបានផ្ដល់ឱ្យរសូលរបស់ទ្រង់នូវភាពទន់ភ្លន់ អធ្យាស្រ័យ ជាមួយមនុស្ស។ ហើយពិតណាស់ប្រសិនជាគាត់មានអាកប្បកិរិយាកោងកាច និងរឹងរូសវិញនោះ មនុស្សនឹងចាកចេញពីគាត់មិនខាន។ ដូចអល់ឡោះបានមានបន្ទូលថា (ដោយសារ

មានក្តីអាណិតស្រលាញ់ពីអល់ឡោះ អ្នក( ណាពីមូហាំម៉ាត់ )បាននធ្វើទន់ភ្លន់ចំពោះមនុស្ស។ តែបើអ្នកមានអាកប្បកិរិយាកោងកាចនិងរឹងរូសវិញនោះគឺពួកគេគនឹងចាកេចញពីអ្នកជាមិនខាន )។( សូរ៉ោះ អាលីអ៊ិមរ៉ន ឃ្លា ១៥៩ )

## ការអំពាវនាវក្រុមគ្រួសារ

ជាការចាំបាច់ស្រមាប់អ្នកែដលអល់ឡោះបាន្របទានផលបុណ្យដល់គាត់ឱ្យបានចូលក្នុងសាសនាឥស្លាម គឺគាត្រ៉ូវត្របុង្របយ័ត្ន ក្នុងការអំពាវនាវក្រុម្រគួសារ និងសាច់ញាតិរបស់គាត់ ដោយសារពួកេគជាមនុស្សែដលេនាជិត និងជាអ្នកែដលគាត្រស្រលាញ់បំផុត។ ដោយការអត់ធ្មត់េនាេលើអ្វីែដលគាត់បានចូលរួមជាមួយពួកេគ និងែស្វងរកេគបំរ៉ិធីសាស្រ្តេទាេលើវាេនាះ។ ដូចអល់ឡោះបានមាន្របសាសន៍ថា ( េហើយចូរអ្នក( ណាពីមូហាំម៉ាត់ )បង្គាប់ឱ្យក្រុម្រគួសាររបស់អ្នក្របតិបត្តិសឡាត និងអត់ធ្មត់ចំេពាះវា )។( សូរ៉ោះ តហា ឃ្លា ១៣២ )

េហើយពិតណាស់មានខ្លះអំពីអ្នកអំពាវនាវ ត្រូវបានេគទទួលយកការអំពាវនាវរបស់គាត់ែតអ្នកែដលេនាឆ្ងាយពីគាត់ េហើយមិនមានេឡើយអ្នកែដលេនាជិតគាត់បំផុតេនាះ េនះការឈឺចាប់និងេសាកេសង្ហក។ ក៏ប៉ុន្តែអ្នកអំពាវនាវែដលទទួលបានេជាគជ័យ គឺអ្នកែដលខិតខំនិងព្យាយាមែស្វងរកមូលេហតុ េប្រើវិធីសាស្រ្តនិងបេច្ចកេទសនានានិងបួងសួងដល់អល់ឡោះសុំការចង្អុលបង្ហាញត្រឹម្រត្រូវដល់ពួកេគ េហើយេគមិនអស់សង្ឃឹម សូម្បីែតស្ថិតេនាេក្រាមការលះេទសៈដ៏ខ្លាំងបំផុតក៏េដាយ។

ដូចែដលរ៉សូលុលេឡាះបានេធ្វើជាមួយនិងឪពុកមាររបស់គាត់ អាពូ តរលីប ជាអ្នកែដលែតងែតជួយនិងការពារគាត្របឈមមុខជាមួយនិង កុលសម្ព័ន្ធ គូរេស ក៏ប៉ុន្តែគាត់មិនបានចូលឥស្លាមេឡើយ។ េហើយរ៉សូលុលេឡាះេនាែតបន្តកិច្ចខិតខំប្រឹងែប្រងក្នុងការអំពាវនាវរបស់គាត់ រហូតដល់េពលចុងេក្រាយែនជីវិតរបស់គាត់ េហើយណាពីបានមាន្របសាសន៍ថា( ឱ!ឪពុកមាររបស់ខ្ញុំ ចូរអ្នកេពាល( لا إله إلا الله ) គ្មានេទពម្ចាស់ែដលត្រូវេគេគារពសក្ការៈដ៏ពិត្រប្រាកដមានែតអល់ឡោះមួយគត់ នឹងពាក្យេនះ ខ្ញុំ្របែហលជាអាចជួយអ្នកេនាេពលជួបជាមួយអល់ឡោះ )។( អាល់ពូខរី ៣៦៧១ មូស្លីម ២៤ ) ក៏ប៉ុន្តែគាត់មិនបានទទួលយកការអំពាវនាវ េហើយក៏បានស្លាប់េនាេលើការគ្មានេជំនឿ េហើយក៏បានបញ្ចុះបន្ទូលរបស់អល់ឡោះថា ( ពិត្រប្រាកដណាស់អ្នក( ណាពីមូហាំម៉ាត់ )មិនអាចចង្អុលបង្ហាញចំេពាះអ្នកណាែដលអ្នក្រស្រលាញ់បានេឡើយ ក៏ប៉ុន្តែអល់ឡោះអាចចង្អុលបង្ហាញចំេពាះអ្នកណាែដលទ្រង់មានេចតនា។េហើយទ្រង់ដឹងបំផុតចំេពាះបណ្តាអ្នកែដលបានទទួលការចង្អុលបង្ហាញ )។( សូរ៉ោះ អាល់កសស ឃ្លា ៥៧) ស្រមាប់អ្នកអំពាវនាវត្រូវខិតខំេប្រើប្រាស់សមត្ថភាពរបស់ខ្លួន និងផ្សព្វផ្សាយសាសនា នឹងចង្អុលបង្ហាញមនុស្សេទាកាន្របការល្អ ក៏ប៉ុន្តែចិត្តគឺេនាក្នុងៃដរបស់អល់ឡោះ ទ្រង់អាចចង្អុលបង្ហាញចំេពាះអ្នកណាែដលទ្រង់មានេចតនាេទាកាន់មាគ៌ាដ៏ត្រឹម្រត្រូវ។



## កុមារមូស្លីម

មនុស្សទាំងអស់ត្រូវបានបង្កើតនៅលើភាពស្អាតស្អំ និងសាសនាឥស្លាម។ ចំណែកឯសាសនាដទៃទៀតបានកើតឡើងនៅលើវាដោយមូលហេតុការបង្រៀនរបស់ឪពុកម្តាយពួកគេ និងការអប់រំពួកគេ។ រ៉សូលុលឡោះបានមានប្រសាសន៍ថា: “គ្មានទារកបានកើតមកលើកែលែងតែកើតនៅលើភាពស្អាតស្អំ ប៉ុន្តែបន្ទាប់មកឪពុកម្តាយរបស់គាត់ធ្វើឱ្យគាត់ក្លាយជាសាសនាយូដា សាសនាគ្រិស្ត និងសាសនាម៉ាយូស៊ី”។(អាល់ពូខរី ១២៩២ មូស្លីម ២៦៥៨)

ក៏ប៉ុន្តែកុមារៗដែលគ្មានជំនឿហើយបានស្លាប់ ពិតណាស់យើងកំណត់ជាមួយពួកគេនឹងច្បាប់អ្នកគ្មានជំនឿនៅក្នុងលោកិយនេះ ហើយអល់ឡោះទ្រង់ដឹងការសម្ងាត់និងការលាក់បាំង ហើយម្ចាស់របស់អ្នកទ្រង់មិនបំពានទៅលើជនណាម្នាក់ឡើយ។ គេនឹងប្រឡងពួកគេនិងសាកល្បងពួកគេនៅថ្ងៃបរលោក ជនណាហើយដែលធ្វើតាមបានចូលឋានសួគ៌ ហើយជនណាហើយប្រឆាំងបានចូលឋាននរក។

នៅពេលដែលមានគេមកសួររ៉សូលុលឡោះអំពីកូនៗរបស់ពួកអ្នកគ្មានជំនឿ គាត់បានមានប្រសាសន៍ថា(អល់ឡោះនៅពេលដែលបង្កើតពួកគេ ទ្រង់ដឹងនូវអ្វីដែលពួកគេនឹងប្រព្រឹត្ត)។(អាល់ពូខរី ១៣១៧)

## ក៏ប៉ុន្តែតើនៅពេលណាទើបយើងអាចកាត់ក្តីថាកុមារៗដែលគ្មានជំនឿជាអ្នកមានជំនឿវិញនៅក្នុងលោកិយនេះ?

ដើម្បីបញ្ជាក់អំពីឥស្លាមរបស់កុមារៗមានករណីជាច្រើនខុសៗគ្នា រួមមាន:

1. នៅពេលដែលឪពុកម្តាយចូលឥស្លាមទាំងពីរ ឬម្នាក់ក្នុងចំណោមគេទាំងពីរចូលឥស្លាម ពិតណាស់កុមារនឹងតាមម្នាក់ក្នុងចំណោមពួកគេដែលមានសាសនាល្អ។.

2. នៅពេលដែលកុមារដឹងខុសត្រូវតែគេមិនទាន់ពេញវ័យ(គ្រប់អាយុ) បានចូលឥស្លាម សូម្បីតែឪពុកម្តាយរបស់គេមិនចូលឥស្លាមក៏ដោយ។ ហើយពិតណាស់មានហើយក្នុងសាសនាយូដាម្នាក់ដែលបម្រើរ៉សូលុលឡោះ គេបានឈឺ ហើយណាពីក៏បានទៅសួរសុខទុក្ខគេ ហើយបានអង្គុយត្រង់កន្លែងក្បាលរបស់គេ ហើយក៏មានប្រសាសន៍ទៅកាន់គេថា(សូមចូលឥស្លាម) ហើយគេក៏បានមើលទៅឪពុករបស់គេ គាត់នៅជាមួយគេដែរ ហើយក៏បាននិយាយទៅកាន់គាត់ថា(ខ្ញុំតាមឪពុករបស់ អាល់កស៊ីម(ណាពី) ហើយក៏ចូលឥស្លាម ណាពីក៏បានចាកចេញហើយលោកក៏បានមានប្រសាសន៍ថា(រាល់ការសរសើរគឺចំពោះអល់ឡោះដែលបានរំដោះគេអំពីឋាននរក)។(អាល់ពូខរី ១២៩០)

តើឪពុកម្តាយរបស់គចូលឥស្លាមទាំងពីនាក់ឬម្នាក់ក្នុងចំណោមពួកគេ?

ទេ | បាទ

បាទ: ច្បាប់កំណត់ថាគេជាមូស្លីម ហើយទំនាក់ទំនងជាមួយគេនឹងច្បាប់អ្នកមូស្លីម

ទេ: តើគចូលឥស្លាមដោយឯករាជ្យអំព្រីគ្រួសាររបស់គ?

ទេ | បាទ

ច្បាប់កំណត់ថាគេជាមូស្លីម្រតឹម្រូតូវនៅក្នុងលោកីយ៍បើសិនជាគេដឹងខុសត្រូវ យល់អ្វីដែលគេនិយាយដូច្នេះវានឹងផ្តល់ផលប្រយោជន៍ដល់គេ និងការពារគេនៅថ្ងៃបរលោក ដោយមានការឯកភាពអំពីអ្នកមូស្លីមទាំងអស់។

កុមារៗដែលគ្មានជំនឿហើយបានស្លាប់ ពិតណាស់យើងកំណត់ជាមួយពួកគេគនឹងច្បាប់អ្នកគ្មានជំនឿនៅក្នុងលោកីយ៍នេះ ហើយអល់ឡោះទ្រង់ដឹងការសម្ងាត់និងការលាក់បាំង ហើយម្ចាស់របស់អ្នកទ្រង់មិនបំពានទៅលើជនណាម្នាក់ឡើយ។ ហើយទ្រង់នឹងប្រឡងពួកគេនិងសាកល្បងពួកគេនៅថ្ងៃបរលោក ជនណាហើយដែលធ្វើតាម បានចូលឋានសួគ៌ ហើយជនណាហើយប្រឆាំង បានចូលឋាននរក។



## > តើគេអនុញ្ញាត ក្នុង ការផ្លាស់ប្តូរឈ្មោះបន្ទាប់ពីចូលសាសនាឥស្លាមដែរឬទេ?

ប្រភពដើមគឺអ្នកមូស្លីមរក្សាទុកឈ្មោះរបស់គេក្រោយអ្វីពចូលឥស្លាមដោយមិនផ្លាស់ប្តូរទេឡើយ។ ហើយគ្មានទេការផ្លាស់ប្តូរឈ្មោះត្រូវបានគេដឹងនៅក្នុងសម័យសហាហ្ពះពិតណាស់មនុស្សបានចូលឥស្លាមហើយក៏ស្ថិតនៅលើឈ្មោះរបស់ពួកគេដែលមិនមែនជាឈ្មោះអារ៉ាប់លើកលែងតែវាមានអត្ថន័យអាក្រក់ទើបគេផ្លាស់ប្តូរវាដោយមូលហេតុវាមានអត្ថន័យអាក្រក់។




### ហើយចាំបាច់តូវផ្លាស់ប្តូរឈ្មោះក្នុងករណីដលមានដូចខាងក្រោមនេះ

**1** ប្រសិនបើវាបង្ហាញពីភាពជាខ្ញុំទៅចំពោះអ្វីផ្សេងអំពីអល់ឡោះ ឬមានអត្ថន័យដែលផ្ទុយពីជំនឿ:

ដូចជាឈ្មោះរបស់គាត់ខ្ញុំរបស់អាល់ម៉ាសៀហ ឬខ្ញុំរបស់ណាពី ឬអ្វីដែលមានអត្ថន័យដូចវា ឬឈ្មោះមានអត្ថន័យផ្ទុយអំពីជំនឿដូចជាឈ្មោះ សានូឌះដែលមានន័យថា (កូនអល់ឡោះ) អល់ឡោះខ្ពង់ខ្ពស់អំពីអ្វីទាំងនោះជាទីបំផុត។

ឬក៏ឱ្យឈ្មោះដែលបានបង្ហាញថាជាផ្នែកមួយនៃលក្ខណៈផ្ទាល់របស់អល់ឡោះឬលក្ខណៈសម្បត្តិរបស់ទ្រង់.

ដូចជាឱ្យលក្ខណៈអ្វីម៉្យាងទៅខ្ញុំបម្រើដែលជាលក្ខណៈផ្ទាល់របស់អល់ឡោះ ដូចជាឱ្យឈ្មោះថា ស្តេចរបស់ស្តេចទាំងអស់ ឬផ្សេងពីនេះទៀត

**2** ឈ្មោះនោះបានបង្ហាញពីអត្ថន័យការអាក្រក់ដែលមានការស្អប់ខ្ពើម ពីធម្មជាតិនិងមនុស្សជាតិជាមួយគ្នាផងដែរ)

ហើយអល់ឡោះបានដាក់ ហារ៉ម លើយើងនូវអ្វីដែលអាក្រក់នៅក្នុងចំណីអាហារនិងភេសជ្ជៈនិង កិច្ចការទាំងអស់នៅក្នុងជីវិត។ គ្មានការចាំបាច់ដែលត្រូវឱ្យឈ្មោះដែលមានអត្ថន័យអាក្រក់ឬបង្ហាញទៅលើអ្វីដែលអាក្រក់ក្រោយអំពីឥស្លាមទៀយ។អល់ឡោះបានមានបន្ទូលថា(ការដាក់ងារមិនល្អក្រោយពីមានជំនឿហើយនោះគឺអាក្រក់បំផុត)។(សូរ៉ោះអាល់ហ៊ូជូរ៉ត ឃ្លា ១១)

## ប្រការដែលគប្បីក្នុងការផ្លាស់ប្តូរឈ្មោះ

ប្រសិនបើឈ្មោះថ្មីនោះ គឺជាឈ្មោះដែលអល់ឡោះស្រលាញ់ ដូចជាផ្លាស់ប្តូរឈ្មោះទៅជា عبد الله (អាប់ឌុល្លោះ)និង عبد الرحمن (អាប់ឌុររ៉ស្មាន) និងអ្វីដែលមានភាពជាខ្ញុំស្រមាប់អល់ឡោះ ហើយវាទាំងអស់វានោះជាឈ្មោះដែលគេអនុញ្ញាត កុំប៉ុន្តែទាំងអស់នោះវាមិនមានទំនាក់ទំនងអ្វីជាមួយនឹងការចូលឥស្លាមរបស់គាត់ឡើយ។.

- ហើយស្រមាប់គាត់ផងដែរអាចផ្លាស់ប្តូរឈ្មោះរបស់គាត់តម្តងសូម្បីតែគ្មានមូលហេតុអ្វីក៏ដោយ ដូចជាការផ្លាស់ប្តូរឈ្មោះរបស់គាត់ដែលមិនមែនជាអារ៉ាប់ឱ្យទៅជាឈ្មោះអារ៉ាប់ក៏ប៉ុន្តែទាំងនោះវាមិនមែនជាការគប្បី ហើយក៏មិនមានទំនាក់ទំនងអ្វីនឹងការចូលឥស្លាមរបស់គាត់ដែរ។.

តើអត្ថន័យនៃឈ្មោះ វាភាពផ្ទុយអំពីសាសនាឬជំនឿដែរឬទេ ?

ទេ → (សំណួរបន្ទាប់)

បាទ → បាទ: ចាំបាច់ត្រូវតែផ្លាស់ប្តូរឈ្មោះដែលមានអត្ថន័យបែបនេះ

តើឈ្មោះនោះចង្អុលបង្ហាញទៅលើសាសនាដែលផ្សេងពីអ្នកឥស្លាម ឬមានភាពល្បីល្បាញរវាងសាសនាដទៃដែលមិនមែនជាអ្នកមូស្លីមដែរឬទេ ?

ទេ → (សំណួរបន្ទាប់)

បាទ → បាទ: ចាំបាច់ត្រូវតែផ្លាស់ប្តូរវាដើម្បីទប់ស្កាត់ ហ្វីតណាស់(បង្កភាពវឹកវរ) ហើយជៀសឱ្យឆ្ងាយអំពីការប្រដូចនោះ

ទេ: តើវាមានអត្ថន័យអាក្រក់ដែលធ្វើឱ្យមនុស្សមិនពេញចិត្តដែរឬទេ ?

ទេ → ទេ: បើសិនជាវាមិនមានអត្ថន័យអ្វីម៉្យាងដូចខាងលើទមិនចាំបាច់ផ្លាស់ប្តូរវាទេ ពិតណាស់អ្នកមូស្លីមជាច្រើនបាននៅតែនៅលើឈ្មោះដើមរបស់ពួកគេដែលមិនមែនអារ៉ាប់ដោយមិនបានផ្លាស់ប្តូរឡើយក្នុងពេលដែលឥស្លាមបានរីកសុះសាយដំបូង។

បាទ → បាទ: គប្បីផ្លាស់ប្តូរវាទៅជាឈ្មោះដែលមានអត្ថន័យល្អដើម្បីឱ្យស្រុបជាមួយនិងការចូលឥស្លាមរបស់បុគ្គលម្នាក់នោះ។

# > លក្ខណៈនៃភាពស្អាតស្អំ (ស៊ូណាន់ូលហ្វីតរ៉ោះ)



> សាសនាឥស្លាមចង់ឱ្យអ្នកមូស្លីមមានរាងកាយស្រស់ស្អាតបំផុត

## តើលក្ខណៈនៃភាពស្អាតស្អំ(ស៊ូណាន់ូលហ្វីតរ៉ោះ)មានអត្ថន័យដូចម្តេច?

លក្ខណៈនៃភាពស្អាតស្អំ( ស៊ូណាន់ូលហ្វីតរ៉ោះ) វាជាលក្ខណៈដែលអល់ឡោះបង្កើតមនុស្សនៅលើវា ហើយអ្នកមូស្លីមពេញលក្ខណៈដោយអនុវត្តវា ហើយនឹងធ្វើឱ្យមានលក្ខណៈសម្បត្តិល្អប្រសើ និងរាងកាយស្រស់ស្អាតបំផុត ដូច្នោះពិតណាស់ឥស្លាមយកចិត្តទុកដាក់លើផ្នែកសស់ស្អាត និងពេញលក្ខណៈចំពោះអ្នកមូស្លីម ដោយរួមបញ្ចូលស្រមាប់គាត់នូវភាពស្អាតស្អំទាំងខាងក្រៅ និងខាងក្នុង។

រ៉សូលុលលោះបានម្នាន្របស្មាសន៍ថា( ភាពស្អាតស្អំមាន្រប៉ាំយ៉ាងគឺការកាត់ស្បែកចុងលិង្គ ការកោររោមប្រដាប់ភេទ កាត់ពុកមាត់ ការកាត់ក្រចក និងការដកររោមក្លៀក) ។( អាល់ពូខរី ៥៥៥២ មូស្លីម ២៥៧))

ការកាត់ស្បែកចុងលិង្គ: គឺការយកចេញស្បែកដែលនៅខាងចុងនៃលិង្គ(ក្រោប) ហើយជាធម្មតាគេធ្វើវានោះនៅក្នុងពេលស្រមាលកូនដំបូង។.

ហើយវាជាប្រការគប្បី និងជាលក្ខណៈនៃភាពស្អាតស្អំ(ស៊ូណាន់ូលហ្វីតរ៉ោះ) ស្រមាប់បុរស។ ហើយវាមានអត្ថប្រយោជន៍ស្រមាប់សុខភាពជាច្រើន ក៏ប៉ុន្តែវាមិនមែនជាលក្ខខណ្ឌស្រមាប់ចូលឥស្លាមនោះទេ ហើយមិនទទួលផលបាបនោះទេស្រមាប់ជនមូស្លីមដែលមិនបានកាត់ស្បែកចុងលិង្គ ដោយមូលហេតុគាត់ខ្លាច ឬមូលហេតុអ្វីផ្សេង។.

ការកោររោមប្រដាប់ភេទ: ការយកចេញនូវសក់រដុប(រោម) នៅប្រដាប់ភេទដោយការកោរ ឬដោយវិធីផ្សេងទៀត

កាត់ពុកមាត់: ការរក្សាទុកពុកមាត់ជាប្រការអន្តរាយគ្រោះមិនមែនជាប្រការគប្បីទ ក៏ប៉ុន្តែអ្នកមូស្លីមប្រសិនបើចង់ទុកវា គាត់មិនត្រូវទុកវែងពេកទេ ហើយត្រូវកំណត់ពេលកាត់ ឬបង់ខ្លីវា។

ថែរក្សាពុកចង្ការ: សាសនាឥស្លាមជំរុញឱ្យ

ថែរក្សាពុកចង្ការហើយវាគឺសក់ដុះនៅលើចង្កានិងឆ្អឹងថ្គាម

ហើយអត្ថន័យថែរក្សាវា គឺការទុកវាដោយមិនកាត់វាចោលអនុវត្តតាមស៊ុនណះណាពីមូហាំម៉ាត់

កាត់ក្រចកដៃ: ចាំបាច់សម្រាប់អ្នកមូស្លីមតាមដានក្រចកដៃរបស់គេដោយកាត់ឱ្យខ្លី កុំឱ្យវាក្លាយជាកន្លែងកខ្វក់ និងស្នាមគ្រោក

ការដករោមក្លៀក: ហើយចាំបាច់សម្រាប់អ្នកមូស្លីមជម្រះចេញនូវរោមដែលនៅក្នុងស្លាបក្លៀកដោយដកវាឬដោយវិធីជម្រះផ្សេងទៀតដើម្បីការពារមិនឱ្យមានក្លិនអាក្រក់ចេញពីរោមគេក្រៅ។






## សេចក្តីបញ្ចប់នៃសៀវភៅ

### តើជំហានបន្តគិតតើធ្វើយ៉ាងដូចម្តេច?

ដោយអ្នកបានបញ្ចប់ការរៀបចំសៀវភៅនេះប្រាកដណាស់អ្នកបានបំពេញនូវជំហានទី១ ក្នុងការស្គាល់អ្វីដែលចាំបាច់នៃកិច្ចការសាសនារបស់អ្នក ហើយនៅសល់កាតព្វកិច្ចលើអ្នកអោយអ្នកយកចិត្តទុកដាក់អនុវត្តតាមអ្វីដែលអ្នកបានរៀនសូត្ររួចហើយអ្នកបានធ្វើឲ្យវាជារឿងជាក់ស្តែងក្នុងឆាកជីវិតរបស់អ្នក ព្រោះថាការចេះដឹងដោយគ្មានការអនុវត្តតាមទេនឹងក្លាយទៅជាមហន្តរាយដល់ម្ចាស់របស់គេនៅថ្ងៃបរលោក.

ដូចែដលជាកាតព្វកិច្ចរបស់អ្នកអោយអ្នកប្រឹងប្រែងក្នុងការរៀនសូត្រកិច្ចការដែលអ្នកមានសេចក្តីត្រូវការចំពោះវានៃរបៀបដែលអាចជឿបាននៃអ្នកមិនបានប្រទះវានៅក្នុងសៀវភៅនេះទេ

ហើយអ្នកមូស្លីមទោះបីជំនឿរបស់វាត្រូវការបន្ថែមការបង្ហាញផ្លូវ ហេតុដូច្នេះហើយនៅក្នុងស៊ូរ៉ោះអាល់ហ្វាតីហះស៊ូរ៉ោះដ៏ធំធេងជាងគេនៅក្នុងគម្ពីររបស់អល់ឡោះ ហើយជាស៊ូរ៉ោះដែលអ្នកមូស្លីមសូត្រវាឡើងវិញរាប់ចាប់ថ្ងៃនៅក្នុងរាល់សឡាតរបស់គេជាច្រើនដង បង្ហាញផ្លូវដល់ខ្ញុំផងនូវផ្លូវដែលត្រឹមត្រូវ

### ចូរពួកអ្នកគោរពកោតខ្លាចទៅចំពោះអល់ឡោះតាមដែលពួកឯងមានសមត្ថភាព

នៅក្នុងសៀវភៅនេះអ្នកនឹងមិនបានជួបប្រទះទេហើយក៏មិនបានក៏មិនបានឃើញនៅក្នុងសៀវភៅផ្សេងទៀតដែរនូវចំលើយពិស្តារអំពីរាល់ស្ថានភាពនិងព្រឹត្តិការណ៍ដែលនឹងជួបវា ដូច្នេះជាមួយនិងការសាកសួរពួកអ្នកចេះដឹងក៏អ្នកត្រូវប្រឹងប្រែងដើម្បីគោរពកោតខ្លាចចំពោះអល់ឡោះតាមកំរិតសមត្ថភាពរបស់អ្នកនៅក្នុងរឿងរ៉ាវដែលកើតឡើងជាបន្តបន្ទាប់ហើយនិងព្រឹត្តិការណ៍ថ្មីនិងសេចក្តីលំអិតនៃទំនាក់ទំនងប្រចាំថ្ងៃដែលអ្នកមិនអាចត្រលប់ទៅរកពួកអ្នកចេះដឹងបាន ដោយជឿលើអាយ៉ាត់ដ៏ថ្កុំថ្កើង ចូរពួកអ្នកគោរពកោតខ្លាចទៅចំពោះអល់ឡោះតាមដែលពួកឯងមានសមត្ថភាព

### ចូរអ្នកយកចិត្តទុកដាក់គិតគូដល់បងប្អូនអ្នកដែលជាអ្នកមូស្លិម ហើយចូរអ្នកចូលទៅឲ្យបានជិតដិតនិងពួកគេ

ចូរអ្នកនៅក្បែរបងប្អូនឥស្លាមរបស់អ្នក ហើយសូមទៅសួរសុខទុក្ខមជ្ឈមណ្ឌលឥស្លាមឲ្យបានញឹកញាប់ ហើយសូមអ្នករស់នៅជាមួយពួកគេ រួមចំណែកជាមួយពួកគេក្នុងការសប្បាយរបស់ពួកគេនិងទុក្ខព្រួយរបស់ពួកគេ ហើយប្រាកដណាស់អល់ឡោះបានបង្គាប់ប្រើណាហ្ពីសល់ឡល់ឡោហ៊ូអាឡាយហ៊ីវ៉ាសាល់ឡាំ ខណៈដែលគាត់គឺជាមនុស្សម្នាក់ដែលមានជំនឿជឿជាក់ដ៏អស្ចារ្យ

បំផុត អល់ឡោះប្រើឲ្យគាត់ស៊ូទ្រាំនិងប្រឹងប្រែងក្នុងការរស់ពគប់ពួកអ្នកសាងអំពើល្អ ដូចដែលទ្រង់បានមានព្រះបន្ទូលថា ៖ចូរឯងស៊ូទ្រាំរស់នៅជាមួយពួកអ្នកដែលសុំបួងសួងទៅចំពោះម្ចាស់របស់ពួកគេពេលព្រឹកនិងពេលល្ងាចពួកគេចង់បានការពេញព្រះហឫទ័យរបស់អល់ឡោះ

ដូចដែលណាហ្វីសល់ឡាល់ឡាហ៊ូអាឡាយហ៊ីវ៉ាសាល់ឡាំបានព្រមានមិនឲ្យឃ្លាតឆ្ងាយអំពីពួកអ្នកមូស្លីម ព្រោះថាវាជាមូលហេតុដែលនាំឲ្យវង្វេងហើយនិងប្រាសចាក ប្រៀបបីដូចជាសត្វពពែដែលឃ្លាតឆ្ងាយអំពីក្រុមរបស់វាក្លាយទៅគ្រោះថ្នាក់ធំបំផុតពីសត្វខ្លា

រ៉ស៊ូលុលឡោះសល់ឡាល់ឡាហ៊ូអាឡាយហ៊ីវ៉ាសាល់ឡាំបានមានប្រសាសន៍ថា៖ចាំបាច់លើពួកឯងឲ្យនៅជាមួយក្រុមមូស្លីមនជាការពិតណាស់ខ្លាស៊ីពពែព្រោះតែពពែដែលបែកឆ្ងាយពីក្រុម

ហេតុផលនេះការដែលអ្នកមូស្លីមជាទូទៅកាលណាគេបញ្ចិតខ្លួននិងបងប្អូនប្រុសរបស់វាហើយនិងនៅជាប់លាប់ជាមួយពួកគេគឺជាមូលហេតុដ៏ធំផងនាំឲ្យមានផលល្អ ទទួលការបង្ហាញផ្លូវនិងស្ថិរភាពសាសនាក្នុងចិត្តរបស់គេ

ចុះយ៉ាងណាទៅវិញចំពោះអ្នកដែលចាប់ផ្ដើមផ្លូវរបស់វាហើយត្រូវការអ្នកដែលល្អនៅលាមេគនិងចាប៉ៃដេគ

សូមឲ្យអល់ឡោះផ្ដល់អ្នកឲ្យបានសម្រេចគប់កិច្ចការ ហើយនិងស្ថិរភាពសាសនា ហើយនិងស្រោចស្រប់បសិទ្ធពរជ័យលើអ្នកខាងក្រៅនិងខាងក្នុង។



دليل المسلم الجديد

The New Muslim **Guide**

**Guide** du converti musulman

ለአዲስ ሰለምቴዎች መመሪያ

**Ang Gabay** Para sa Bagong Muslim

**Vodič** novom muslimanu

新改宗者のためのガイドブック

**La guida del nuovo musulmano**

**새내기 무슬림을 위한 지침서**

**Handbuch für den neuen Muslim**

नव मुस्लिम मार्गदर्शिका

**Guia para o novo muçulmano**

新穆斯林指南

**Руководство** для принявшего ислам

**Guía para el Nuevo Musulmán**


U.K -Birmingham
B11 1AR
Tel : +441214399144

K . S . A
Tel : +966112922240

www.newmuslimguide.com
www.guide-muslim.com
info@modern-guide.com

Cambodian

គោលជំនឿរបស់អ្នក



ជំពូក២
អនាម័យរបស់អ្នក



ការសឡាតរបស់អ្នក



ការបួសរបស់អ្នក



ហ្សាកាត់របស់អ្នក



ការធ្វើ
បុណ្យហាជ្ជីរបស់អ្នក



ប្រតិបត្តិ
ការហិរញ្ញវត្ថុរបស់អ្នក



ចំណីអាហាររបស់អ្នក
និងភេសជ្ជៈរបស់អ្នក



សំលៀក
បំពាក់របស់អ្នក



គ្រួសាររបស់អ្នក



សីលធម៌របស់អ្នក
នៅក្នុងសាសនាឥស្លាម



ជីវិតថ្មីរបស់អ្នក



# មគ្គុទ្ទេសអ្នកមុស្លីមថ្មី

សូមអបអរសាទរចំពោះអ្នក ដោយអល់ឡោះធ្វើឲ្យងាយស្រួលនិងបានទទួលភាពស់ប្បូរសប្បាយទៅលើអ្នកដោយបានការចង្អុលបង្ហាញហើយបានចាកចេញផុតអំពីសភាពងងឹតទៅរកពន្លឺភ្លឺស្វាងនិងប្រកាន់សាសនាឥស្លាមដ៏ធំធេងនេះ

ហើយសូមអបអរសាទរចំពោះឯងចំពោះសេចក្តីក្លាហាននោះនិងវត្ថុបំណងស្វែងរកការពិតដែលធ្វើឲ្យអ្នកសម្រេចចិត្តយ៉ាងសំខាន់ក្នុងឆាកជីវិតរបស់អ្នកដោយបានចូលកាន់សាសនាដ៏ធំធេងនេះ។

ហើយអ្នកណាបានទិញឧបករណ៍ឬបានចូលរួមក្នុងក្លិបណាមួយឬក្រុមណាមួយឬអង្គការណាមួយដែលចាប់អារម្មណ៍ក្នុងការអានហើយនិងស្គាល់អ្វីដែលវាត្រូវទទួលបានហើយអ្វីដែលជាកាតព្វកិច្ចលើវាឲ្យធ្វើហើយធ្វើយ៉ាងណាដំណោះស្រាយជាមួយស្ថានការថ្មី។

ចុះយ៉ាងម៉េចដែរចំពោះអ្នកដែលអល់ឡោះបានប្រទានពរជ័យ ដោយបានចាកចេញផុតអំពីភាពងងឹតស្លុងទៅកាន់ពន្លឺភ្លឺស្វាង ហើយបានជួយជ្រោមជ្រែងបានទទួលការបង្ហាញផ្លូវនិងបានទទួលកាន់សាសនាឥស្លាមដូច្នេះគ្មានសង្ស័យឡើយថាប្រាកដណាស់សេចក្តីប្រាថ្នាដ៏ធំបំផុតដើម្បីយល់ដឹងក្បួនច្បាប់សាសនារបស់គេដើម្បីគោរពសក្ការៈទៅចំពោះអល់ឡោះដោយឈរលើការយល់ដឹងទូលំទូលាយនិងមានចំនេះដឹងហើយអាចប្រឈមនិងការប្រែប្រួលជុំវិញខ្លួនវាទាំងអស់ស្របទៅតាមក្បួនច្បាប់ឥស្លាមដែលពោពេញដោយការអត់អោន។

ហើយជាការផ្តល់ដំណឹងល្អសម្រាប់អ្នកនៅពេលដែលអ្នកបានរៀនសូត្រដែលថាពត៌មានទាំងនេះដែលអ្នកកំពុងរៀនវាគឺជាកេរ្តិ៍មរតកនៃពួកណាហ្គីៗនិងពួកអ្នកនាំសារ ព្រោះថាប្រាកដណាស់ពួកណាហ្គីៗមិនបន្សល់ទុកកេរ្តិ៍មរតកទ្រព្យសម្បត្តិអ្វី ហើយនិងរបស់របរអ្វីឡើយគឺមានតែបន្សល់ទុកចំណេះដឹងសាសនាដូច្នេះអ្នកណាហើយបានរៀនសូត្រចំណេះដឹងសាសនាប្រាកដជាវាបានទទួលលាភដ៏ធំធេងហើយនិងគុណសម្បត្តិដ៏សន្ធឹកសន្ធាប់នៃកេរ្តិ៍មរតកពួកណាហ្គី។(អាពូទើវ៉ូទ : ៨៨)

ហើយមគ្គុទេសដែលត្រូវបានធ្វើជារូបភាពនេះវានឹងផ្តល់ឲ្យអ្នក(សម្រាប់អ្នកកាន់សាសនាឥស្លាមថ្មី)ជាជំហានទី១និងជាគម្រិតមូលដ្ឋានក្នុងការយល់ដឹងសាសនាដ៏ធំធេងនេះដែលជាការប្រទានមួយធំបំផុតសម្រាប់មនុស្សលោកនៅក្នុងជ្រុងជ្រោយជាច្រើននៃឆាកជីវិតដែលអ្នកកំពុងរួមរស់និងដែលអ្នកកំពុងត្រូវការចំពោះវាដូច្នេះដែរមគ្គុទ្ទេសន៍នេះវានឹងឆ្លើយតបទៅលើសំណួរបន្ទាន់ជាច្រើនរបស់អ្នកហើយវាជួយគាំទ្រអ្នកក្នុងការប្រឈមនិងការពិតដែលនៅជុំវិញខ្លួនអ្នក ដោយតាមរចនាប័ទច្បាស់លាស់ងាយស្រួលហើយនិងទទួលបានពត៌មានជាក់លាក់និងត្រូវបានចងក្រងអនុលោមទៅតាមគម្ពីអាល់គួរអានអាល់ការីមនិងអាល់សុណ្ណះណាហ្គីសល់ឡល់ឡោហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ

www.newmuslimguide.com

MODERN GUIDE

NEW MUSLIM GUIDE

Tel: +441214399144 uk@modern-guide.com